# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍
# វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្ត
# គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥

"តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផលដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម"

**បានឯកភាពពីគណៈរដ្ឋមន្ត្រី**
**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥**
**ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១**

**រាជរដ្ឋាភិបាលកម្ពុជា**

# របាយការណ៍
# វាយតម្លៃពាក់កណ្ដាលអាណត្តិនៃការអនុវត្ត
# គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥

*"តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផលដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម"*

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**
**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥**
**ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១**

# អារម្ភកថា

ឈរលើភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល កម្ពុជាទទួលបាននូវសន្តិភាពពេញលេញ សន្តិសុខនិងស្ថិរភាពសង្គម អធិបតេយ្យភាពនិងបូរណភាពទឹកដី ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវរបៀបវារៈអភិវឌ្ឍន៍ជាតិ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ព្រមជាមួយនឹងគោលនយោបាយដទៃទៀត ដែលមានសង្គតិភាពជាមួយបរិការណ៍ថ្មីៗ។

ផ្អែកលើទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ២០៣០ និង២០៥០ រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ចការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព សំដៅរួមចំណែកសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចរបស់ខ្លួន និងឆ្លើយតបទៅនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងការប្រែប្រួលនិម្នាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។

ទោះជាយ៉ាងនេះក្តី បរិការណ៍អភិវឌ្ឍន៍សកលកំពុងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដូចជាបដិវត្តន៍ឧស្សាហកម្ម ៤.០ បរិវត្តកម្មឌីជីថល សេដ្ឋកិច្ចឌីជីថល និងការរីករាលដាលសកលនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យមានការប្រែប្រួលនិម្នាបនកម្មសេដ្ឋកិច្ច និងខ្សែច្រវាក់ផ្គត់ផ្គង់សកល និងតំបន់។ ក្នុងន័យនេះ ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយ IDP ពិតជាមានសារៈសំខាន់ និងចាំបាច់សម្រាប់ត្រួតពិនិត្យលើវឌ្ឍនភាពដែលសម្រេចបាន និងបញ្ហាប្រឈមនៃការអនុវត្តនាពេលកន្លងមក ដើម្បីជាមូលដ្ឋានក្នុងការរៀបចំវិធានការឆ្លើយតប និងតម្រង់ទិសការអនុវត្ត ក្នុងដំណាក់កាលបន្ទាប់។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូន **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ក្នុងការរៀបចំ និងសម្របសម្រួលការអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃសម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិ ការវាយតម្លៃវឌ្ឍនភាពប្រចាំឆ្នាំ និងការវាយតម្លៃចុងអាណត្តិនៃការអនុវត្តគោលនយោបាយ IDP ។

របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនេះ បានផ្តល់មូលដ្ឋានរឹងមាំ ច្បាស់លាស់ និងជាធាតុចូលសម្រាប់រាជរដ្ឋាភិបាលពិនិត្យពិចារណាក្នុងការកំណត់គោលដៅថ្មី និងការតម្រង់ទិសសម្រាប់ការអនុវត្តដំណាក់កាលបន្ទាប់ ដើម្បីធ្វើឱ្យវិស័យឧស្សាហកម្មកម្ពុជាកាន់តែមានភាពរស់រវើក និងខ្លាំងក្លាឡើង ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានលេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយ IDP ជាសេនាធិការ និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនេះឡើងប្រកបដោយគុណភាព និងអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍ រួមមាន កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលបានជួយពង្រឹងសមត្ថភាពលេខាធិការដ្ឋាន IDP នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាពិសេស អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) ដែលបានបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីជំនាញ និងគាំទ្រផ្នែកបច្ចេកទេសក្នុងដំណើរការរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនេះឱ្យចប់សព្វគ្រប់ និងមានភាពគ្រប់ជ្រុងជ្រោយ តាមរយៈកម្មវិធីភាពជាដៃគូប្រចាំប្រទេស (The Programme for Country Partnership-PCP) ក្រោមការផ្តល់ហិរញ្ញប្បទានពីសាធារណរដ្ឋកូរ៉េ។

ខ្ញុំជឿជាក់ថា គ្រប់ក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់ ទាំងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ នឹងប្រើប្រាស់របាយការណ៍នេះ ជាមូលដ្ឋានកំណត់យុទ្ធសាស្ត្រដ៏មុតស្រួច និងរស់រវើក ដើម្បីឆ្លើយតបតាមតម្រូវការ និងបរិការណ៍ជាក់ស្តែងនៃសង្គម-សេដ្ឋកិច្ច និងការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក សំដៅជំរុញការសម្រេចនូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការកែប្រែនិងធ្វើទំនើបកម្មវិស័យឧស្សាហកម្ម ដែលនឹងចូលរួមពន្លឿនកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យមានសន្ទុះខ្លាំងក្លាឡើង។ ៤

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


ខ្លឹមសារសង្ខេបប្រតិបត្តិ ...... I

១. សេចក្តីផ្តើម ...... ១

២. វិធីសាស្ត្រនៃការវាយតម្លៃ ...... ៣

៣. ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP ...... ៦

៣.១. សមិទ្ធកម្មនៃការសម្រេចបាននូវចក្ខុវិស័យរបស់គោលនយោបាយ IDP ...... ៦

៣.២. សមិទ្ធកម្មគោលបំណងទី១ “បង្កើនសកម្មភាពឧស្សាហកម្ម” ...... ១០

៣.៣. សមិទ្ធកម្មគោលបំណងទី២ “បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម” ...... ១៩

៣.៤. សមិទ្ធកម្មគោលបំណងទី៣ “សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម” ...... ២៩

៣.៥. សមិទ្ធកម្មគោលបំណងទី៤ “ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ” ...... ៤៣

៣.៦. សមិទ្ធកម្មគោលបំណងទី៥ “បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា” ...... ៥៥

៣.៧. សមិទ្ធកម្មគោលនយោបាយ IDP ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ...... ៦៥

៣.៨. ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងឥណទាននៃវិស័យធនាគារគាំទ្រការអនុវត្តគោលនយោបាយ IDP ...... ៧០

៤. ការវាយតម្លៃលើការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយ IDP ...... ៧៣

៤.១. របកគំហើញសំខាន់ៗពីការវិភាគលើការរៀបចំគោលនយោបាយ IDP ...... ៧៣

៤.២. សង្ខេបវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ IDP ...... ៧៦

៥. សមិទ្ធផលរំពឹងទុក និងអនុសាសន៍គោលនយោបាយ ...... ៧៩

៥.១. សមិទ្ធផលរំពឹងទុករបស់គោលដៅ IDP ...... ៧៩

៥.២. អនុសាសន៍សម្រាប់ពង្រឹងការអនុវត្តវិធានការគោលនយោបាយ ...... ៨៤

៥.៣. អនុសាសន៍សម្រាប់ការកែសម្រួលវិធានការគោលនយោបាយ និងអន្តរាគមន៍គោលនយោបាយ ...... ៨៧

៥.៤. អនុសាសន៍សម្រាប់ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាន និងវាយតម្លៃ IDP ...... ៩៣

៥.៥. បច្ច័យវិជ្ជមាននៃការដាក់ចេញគោលនយោបាយថ្មីៗ លើគោលនយោបាយ IDP ...... ៩៤

៥.៦. ផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើការអនុវត្ត IDP និងការផ្តល់អនុសាសន៍ ...... ៩៥

៦. សេចក្តីសន្និដ្ឋាន និងទិសដៅបន្ត ...... ១០០

ឧបសម្ព័ន្ធ

បញ្ជីពាក្យកាត់ ...... I

បញ្ជី រូបភាព និងតារាង ...... IV

១. ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាទីមោទនៈក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងធានាបានសន្តិសុខសង្គម សន្តិភាព និងស្ថិរភាពនយោបាយ ព្រមទាំងរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចរឹងមាំជាមួយនឹងកំណែទម្រង់ស្ថូល និងការលើកកម្ពស់ និងអភិវឌ្ឍន៍វិស័យឯកជន។ ផ្អែកលើសមិទ្ធផលទាំងនេះ កម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចជាមធ្យម ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយ ដែលធ្វើឱ្យអត្រាភាពក្រីក្រធ្លាក់ចុះមកត្រឹមក្រោម ១០% នៅឆ្នាំ២០១៩ និងសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប នៅឆ្នាំ២០១៥។

២. ឈរលើទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ២០៣០ និង២០៥០ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និងរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន។ ដើម្បីធានាវឌ្ឍនភាពជាប្រចាំ ប្រសិទ្ធភាពនិងសង្គតិភាពនៃការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) រៀបចំ និងសម្របសម្រួលអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃដ៏ពេញលេញ និងគ្រប់ជ្រុងជ្រោយមួយ។ កន្លងមក របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ចំនួន២ ត្រូវបានរៀបចំ គឺរបាយការណ៍វឌ្ឍនភាពគិតត្រឹមឆ្នាំ២០១៦ និងក្នុងឆ្នាំ២០១៧-២០១៨ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។ បន្ថែមលើការរៀបចំរបាយការណ៍វឌ្ឍនភាពទាំងពីរ ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ IDP ដែលជាត្រីវិស័យក្នុងការរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃ ក៏ត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាលផងដែរ សម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិ ការតាមដានវឌ្ឍនភាពប្រចាំឆ្នាំ និងការវាយតម្លៃចុងអាណត្តិនៃការអនុវត្តគោលនយោបាយ IDP។

៣. ផ្អែកលើមូលដ្ឋានខាងលើ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ (MTR) ត្រូវបានរៀបចំឡើងក្នុងគោលបំណងវាយតម្លៃវឌ្ឍនភាព និងបច្ច័យនៃការអនុវត្តគោលនយោបាយ សម្រាប់ឆ្នាំ២០១៥-២០២០ និងផ្តល់អនុសាសន៍គោលនយោបាយគន្លឹះ ដើម្បីកែលម្អ និងពន្លឿនការអនុវត្តសម្រាប់ឆ្នាំ ២០២២-២០២៥។ របាយការណ៍នេះប្រើប្រាស់វិធីសាស្ត្រចម្រុះ ដោយរួមបញ្ចូលការវិភាគ និងការវាយតម្លៃបែបបរិមាណវិស័យ និងគុណវិស័យពីបច្ច័យ សមិទ្ធកម្ម និងបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ IDP ទាំងនៅកម្រិតយុទ្ធសាស្ត្រ វិស័យ និងបច្ចេកទេស តាមរយៈការប្រើប្រាស់ទាំងទិន្នន័យជាតិ និងអន្តរជាតិ និងឧបករណ៍នៃប្រព័ន្ធតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ IDP ចំនួន ៣

រួមមាន តក្កកម្មអន្តរាគមន៍ (Intervention Logic) ក្របខណ្ឌតក្កកម្ម (Log-frame) និងទម្រង់គំរូរបាយការណ៍ (RTF)។

៤. លទ្ធផលសង្ខេបនៃការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP មានដូចខាងក្រោម៖

ក. សមិទ្ធកម្មក្នុងការសម្រេចបានចក្ខុវិស័យនៃគោលនយោបាយ IDP៖ ការវាយតម្លៃបង្ហាញថា ចក្ខុវិស័យគោលនយោបាយ IDP ក្នុងការជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញ ត្រឹមឆ្នាំ២០២៥ **សម្រេចបានលទ្ធផលដោយផ្នែក**។ ចំណែកនៃវិស័យឧស្សាហកម្មក្នុង ផ.ស.ស. បានកើនពី ២៧,៧% ក្នុងឆ្នាំ២០១៥ ដល់ ៣៤,២% ក្នុងឆ្នាំ២០១៩ ខ្ពស់ជាងគោលដៅឆ្នាំ២០២៥ (៣០%) ដែលបានកំណត់ដោយគោលនយោបាយ IDP។ ដោយឡែក ចំណែកនៃវិស័យកម្មន្តសាលក្នុង ផ.ស.ស. មានការកើនឡើងយឺតជាងការរំពឹងទុក ដោយបានកើនឡើងពី ១៦% នៅឆ្នាំ២០១៥ ដល់ត្រឹម ១៦,៣% ក្នុងឆ្នាំ២០១៩ ដែលហាក់នៅឆ្ងាយពីគោលដៅឆ្នាំ ២០២០ (១៨%) និងគោលដៅឆ្នាំ២០២៥ (២០%) នៅឡើយ។ ជាងនេះទៅទៀត ចំណែកនៃការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យមនិងខ្ពស់ ធៀបនឹងការនាំចេញទំនិញកម្មន្តសាលសរុប បានកើនឡើងបន្តិចពី ៨,៩% ក្នុងឆ្នាំ២០១៥ ដល់ត្រឹម ៩% ក្នុងឆ្នាំ២០១៩ ប៉ុណ្ណោះ ដែលបង្ហាញថាកម្ពុជានៅមានបញ្ហាប្រឈម ក្នុងការឈានទៅឧស្សាហកម្មផ្អែកលើជំនាញ និងបច្ចេកវិទ្យាទំនើបត្រឹមឆ្នាំ២០២៥។

ខ. សមិទ្ធកម្មគោលបំណងគោលនយោបាយ៖ ផ្អែកតាមប្រព័ន្ធតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ IDP គោលបំណងគោលនយោបាយចំនួន ៥ ដូចខាងក្រោម ត្រូវបានកំណត់ដើម្បីវាយតម្លៃពីបច្ច័យរបស់គោលនយោបាយ IDP ក្នុងការសម្រេចចក្ខុវិស័យ។

*គោលបំណងទី ១ "បង្កើនសកម្មភាពឧស្សាហកម្ម"៖* ការបង្កើនសកម្មភាពឧស្សាហកម្មនៅកម្ពុជា ត្រូវបានវាយតម្លៃថា **សម្រេចបានដោយផ្នែក**។ ជាក់ស្តែង តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់ បានកើនពី ២២៨,៣ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ដល់ ៣២០,៧ដុល្លារអាមេរិក នៅឆ្នាំ២០១៩ ខណៈដែលតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់ បានកើនពី ១៦៣,៨ ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ដល់ ២០២,៦ដុល្លារអាមេរិក នៅឆ្នាំ២០១៩។ វិហ្វទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម ក៏មានការកើនឡើងជាបន្តបន្ទាប់ពី ១.៦៥៣លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៥ ដល់ ៣.២០១លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ខណៈដែលទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាលមានការប្រែប្រួល ដោយថយចុះពី ៤៩៧លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៥ មកត្រឹម ៣៥៦លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ប៉ុន្តែបានកើនឡើងដល់ ៦៣១លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៩។

*គោលបំណងទី ២ "បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម"៖* លទ្ធផលនៃការបង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្មត្រូវបានវាយតម្លៃថា **សម្រេចបានភាគច្រើន**។ ជាក់ស្តែង ការនាំចេញទំនិញឧស្សាហកម្មមានការរីកចម្រើនជាលំដាប់ ដោយការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ បានកើនឡើងពី ៥៣៤ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ទៅដល់ ៨៥៥ដុល្លារអាមេរិក នៅឆ្នាំ២០១៩។ ជាងនេះទៅទៀត ការនាំចេញកសិផលកែច្នៃបានបន្តរក្សាកំណើនប្រចាំឆ្នាំ ដោយទំហំនៃការនាំចេញបានកើនឡើងពីប្រមាណ ៥១៦លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦ ដល់ ៨៤៦លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ បើទោះបីជាចំណែកធៀបនឹងការនាំចេញសរុប បានធ្លាក់ចុះពី ៥,៨% ក្នុងឆ្នាំ២០១៥ មកត្រឹម ៤,៩% ក្នុងឆ្នាំ២០២០ ធៀបនឹងគោលដៅកំណត់ ១០% នៅឆ្នាំ២០២០។

*គោលបំណងទី ៣ "សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម"៖* លទ្ធផលនៃការពង្រឹងភាពធន់ និងធ្វើពិពិធកម្មសេដ្ឋកិច្ច ត្រូវបានវាយតម្លៃថា **សម្រេចបានដោយផ្នែក**។ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង ធៀបនឹងការនាំចេញសរុប បានកើនឡើងពី ៥,៦% ក្នុងឆ្នាំ២០១៥ ដល់ ១៥,៥% នៅឆ្នាំ២០២០ លើសគោលដៅដែលបានកំណត់ត្រឹម ១៥% នៅឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាល ៥ នាំមុខ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប បានធ្លាក់ចុះពី ៩៤,៦% នៅឆ្នាំ ២០០៥ មក ៨៣,៥% នៅឆ្នាំ២០១៥ និងបន្តធ្លាក់មកត្រឹម ៦៣,៣% នៅឆ្នាំ២០១៩ ដែលបង្ហាញថា ការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជាលែងសូវពឹងផ្អែក ឬប្រមូលផ្តុំលើផលិតផលនាំមុខមួយចំនួនតូចទៀតហើយ។ ទោះជាយ៉ាងនេះក្តី វឌ្ឍនភាពនៃការធ្វើពិពិធកម្ម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ ដោយមូលដ្ឋានផលិតកម្មនៅតូចចង្អៀត ខណៈទីផ្សារនាំចេញរបស់កម្ពុជានៅមានលក្ខណៈប្រមូលផ្តុំ។ ជាក់ស្តែង វិស័យកម្មន្តសាលនៅបន្តពឹងផ្អែកលើសកម្មភាពផលិតកម្មមួយចំនួនតូច ដូចជា តម្បាញ សម្លៀកបំពាក់និងស្បែកជើង, ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, និង ឈើ ក្រដាស និងបោះពុម្ព។ បន្ថែមលើនេះ ការនាំចេញផលិតផលកម្មន្តសាលនៅតែពឹងផ្អែកលើទីផ្សារធំៗមួយចំនួនដដែល។

*គោលបំណងទី ៤ "ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ"៖* ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ ត្រូវបានវាយតម្លៃថា **សម្រេចបានភាគច្រើន** ដោយចំនួនការងារនៅក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ បានកើនជាលំដាប់ពីប្រមាណ ៣៤៧.០០០ ក្នុងឆ្នាំ២០១០ ដល់ប្រមាណ ៤៨៧.០០០ ក្នុងឆ្នាំ២០២០ ខណៈដែលចំណែកនៃការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុប បានកើនឡើងពី ១៦% ដល់ ២៤,៧% ក្នុងរយៈពេលដូចគ្នា។ ជាមួយគ្នានេះ ភាពប្រសើរឡើងនៃគុណភាពការងារក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃអត្រាសហគ្រាសគ្រឹះស្ថានដែលមានសេវាសង្គ្រោះអប្បបរមា, ការកើនឡើងនៃចំនួនកម្មករដែលទទួលបានបណ្ណសមាជិក ប.ស.ស, និងការពង្រឹងសុខដុមនីយកម្ម

នៃទំនាក់ទំនងវិជ្ជាជីវៈ ដែលស្តែងចេញតាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទការងារ ការថយចុះនៃចំនួនកូដកម្ម និងបាតុកម្មប្រចាំឆ្នាំ, និងយន្តការសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមាដែលមានដំណើរការល្អ។

*គោលបំណងទី ៥ "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា"៖* លទ្ធផលនៃការបង្កើនផលប្រយោជន៍ក្នុងស្រុក ត្រូវបានវាយតម្លៃថា **នៅមានកម្រិតនៅឡើយ**។ ជាក់ស្តែង ឱនភាពជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាលបានកើនឡើងពី ១,២ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៥ ដល់ ៤,៧ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩។ ទន្ទឹមនឹងនេះ ចំណែកនៃតម្លៃបន្ថែមសរុបក្នុងវិស័យកម្មន្តសាល ធៀបនឹងការនាំចេញផលិតផលកម្មន្តសាល បានថយចុះជាបន្តបន្ទាប់ពីប្រមាណ ៣០,៧% នៅឆ្នាំ២០១៥ មកត្រឹម ២៣,៧% នៅឆ្នាំ២០១៩ ហើយការប្រើប្រាស់វត្ថុធាតុដើមពីក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក ដើម្បីជំរុញការបង្កើនការតភ្ជាប់ឧស្សាហកម្មនៅមានបញ្ហាប្រឈមជាច្រើន ទាំងការប្រកួតប្រជែង គុណភាព និងតម្លៃ។ និន្នាការទាំងនេះ បង្ហាញថាឧស្សាហកម្មប្រតិគមន៍ និងខ្សែច្រវាក់តម្លៃក្នុងស្រុក ពុំទាន់ត្រូវបានពង្រឹងឱ្យមានប្រសិទ្ធភាពនៅឡើយ។

គ. ការរួមចំណែករបស់គោលនយោបាយ IDP ក្នុងគោលដៅអភិវឌ្ឍន៍ជាតិ ៖ ការវាយតម្លៃបង្ហាញថា ការអនុវត្តគោលនយោបាយ IDP **បានចូលរួមចំណែកដោយផ្នែក** ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ជាតិ ទាំង៣ ដែលក្នុងនោះរួមមាន ១) កំណើនសេដ្ឋកិច្ចដែលមានភាពធន់នឹងវិបត្តិ, ២) កំណើនបរិមាណការងារ និង ៣) ការកាត់បន្ថយភាពក្រីក្រ។ កម្ពុជារក្សាបានកំណើន ផ.ស.ស. ប្រចាំឆ្នាំជាមធ្យមក្នុងរង្វង់ប្រមាណ ៧% ហើយវិស័យដែលចូលរួមចំណែកធំជាងគេគឺ វិស័យឧស្សាហកម្ម ដែលគិតជាមធ្យម ៣,២% ពីឆ្នាំ២០១០-២០១៤ និង ៣,៦% ពីឆ្នាំ២០១៥-២០១៩។ ជាមួយគ្នានេះ កំណើននៃចំនួនការងារផ្លូវការថ្មីដែលបានចុះបញ្ជី បានកើនឡើងជាមធ្យម ១៧% ក្នុងមួយឆ្នាំ ក្រោយការដាក់ចេញគោលនយោបាយ IDP ដែលបានកើនឡើងពី ៣៩.៩២៥កន្លែង ក្នុងឆ្នាំ២០១៥ ដល់ ៧៣.៦៧៥កន្លែង ក្នុងឆ្នាំ២០១៩។ ចំណែកនៃចំនួនការងារក្នុងវិស័យកម្មន្តសាលធៀបនឹងចំនួនការងារសរុប បានកើនពី ១៦,៥% នៅឆ្នាំ២០១៥ ដល់ ១៦,៧% នៅឆ្នាំ២០១៧។ ប៉ុន្តែចំណែកនេះ បានធ្លាក់ចុះបន្តិចមកត្រឹម ១៥,៥% នៅឆ្នាំ២០២០ ដោយសារតែផលប៉ះពាល់អវិជ្ជមាននៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាមានវឌ្ឍនភាពជាបន្តបន្ទាប់ ដោយបានបន្តធ្លាក់ចុះពី ១១,៩% នៅឆ្នាំ២០១៥ មកក្រោម ១០% នៅឆ្នាំ២០១៩។

យើងអាចសម្គាល់ឃើញថា វិស័យកម្មន្តសាល នៅពុំទាន់ក្លាយជាវិស័យគន្លឹះក្នុងការជំរុញកំណើន ផ.ស.ស. តាមការរំពឹងទុករបស់គោលនយោបាយ IDP ហើយវិស័យនេះក៏ពុំទាន់ឈានដល់កម្រិតសក្តានុពលរបស់ខ្លួននៅឡើយ។ ក្នុងន័យនេះ ដើម្បីបន្តជំរុញការចូលរួមការអនុវត្តគោលនយោបាយ IDP ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលគួរបន្តជំរុញការធ្វើពិពិធកម្ម និងជាពិសេស

បង្កើនតួនាទីនៃសកម្មភាពកម្មន្តសាលទំនើបៗនៅក្នុងសេដ្ឋកិច្ចជាតិ ដែលនឹងរួមចំណែកបង្កើនការងារដែលមានគុណភាពខ្ពស់ប្រកបដោយចីរភាព។

ឃ. ហិរញ្ញប្បទានសហប្រតិបត្តិរបស់ដៃគូអភិវឌ្ឍន៍ និងឥណទាននៃវិស័យធនាគារគាំទ្រការអនុវត្តគោលនយោបាយ IDP៖ ហិរញ្ញប្បទានសហប្រតិបត្តិការ បានដើរតួនាទីជាកាតាលីករក្នុងការកៀរគរប្រភពធនធានដទៃទៀត និងជាប្រភពធនធានគាំទ្រដោយផ្ទាល់ដល់ការអនុវត្តគោលនយោបាយ IDP។ ជាក់ស្តែង យោងតាមប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជាបង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៥ - ២០២០ ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានប្រមាណ ១.២៨៧,២លានដុល្លារអាមេរិក ជាមធ្យម ២១៥ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ សម្រាប់គាំទ្រការអនុវត្តគោលនយោបាយ IDP ដោយក្នុងនោះ វិធានការគន្លឹះបួនជាក់ស្តែងទទួលបានការគាំទ្រច្រើនជាងគេ ប្រមាណ ៩៣៨,៥លានដុល្លារអាមេរិក, ការសម្របសម្រួលគោលនយោបាយគាំទ្រ ប្រមាណ ១៨៨,៦លានដុល្លារអាមេរិក, ការជំរុញការទាក់ទាញវិនិយោគ ប្រមាណ ៧៣,៧លានដុល្លារអាមេរិក, ការកែលម្អបរិស្ថាននិយ័តកម្ម ប្រមាណ ៦១,៨លានដុល្លារអាមេរិក និងការពង្រីក និងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម ប្រមាណ ២៤,៦លានដុល្លារអាមេរិក។

វិស័យធនាគារ ក៏បានចូលរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា។ ជាក់ស្តែង ចាប់ពីឆ្នាំ២០១៥-២០២០ ឥណទាននៃវិស័យធនាគារទៅកាន់វិស័យកម្មន្តសាលបានកើនឡើងជាមធ្យម ៦,៦% ក្នុងមួយឆ្នាំ ជាមួយនឹងទំហំឥណទានសរុបប្រមាណ ៤១៧លានដុល្លារអាមេរិក ដែលបានជួយជំរុញកំណើនសកម្មភាពក្នុងវិស័យនេះ។

**៥. ការវាយតម្លៃលើការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយ IDP៖** លទ្ធផលវាយតម្លៃលើការរៀបចំវិធានការគោលនយោបាយ បង្ហាញថា ច្រើនជាង៥០% នៃវិធានការគោលនយោបាយទាំងអស់ បានគាំទ្រដល់អន្តរាគមន៍គោលនយោបាយចំនួន ៤ (ក្នុងចំណោម២០) រួមមាន ១) ការបង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម, ២) ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់, ៣) ការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម និង ៤) ការធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស។ យ៉ាងណាក្តី ពុំមានវិធានការណាមួយចែងជាក់លាក់គាំទ្រដល់ការផ្លាស់ប្តូរ និងការពង្រឹងភាពប្រកួតប្រជែងរបស់ឧស្សាហកម្មក្នុងស្រុក ដូចជា ការបង្កើនការផលិតដើម្បីជំនួសផលិតផលនាំចូល, ការពង្រឹងខ្សែច្រវាក់តម្លៃជាតិ និងការបង្កើនភាពជាម្ចាស់របស់ឧស្សាហកម្មក្នុងស្រុក។ ចំពោះលទ្ធផលនៃការអនុវត្តវិធានការបង្ហាញថា ក្នុងចំណោមវិធានការទាំងអស់ដែលគោលនយោបាយ IDP បានដាក់ចេញ (និងអនុវិធានការគាំទ្រមួយចំនួន) មានវិធានការ ៥៦% សម្រេចបានពេញលេញ, ២០% កំពុងអនុវត្ត និង ២៣% មានភាពយឺតយ៉ាវ។ វិធានការជាងពាក់កណ្តាល ត្រូវបានអនុវត្តបានពេញលេញទាន់ពេលវេលា ដែលតួលេខនេះបង្ហាញថា ការអនុវត្តគោលនយោបាយ IDP ក្នុងរយៈពេល ៥ឆ្នាំដំបូងកន្លងទៅនេះ មាន

វឌ្ឍនភាពល្អប្រសើរតាមកាលកំណត់។ ចំណែកឯវិធានការដែលនៅសល់ពាក់កណ្តាលទៀត នៅតែអាចត្រូវបានបន្តអនុវត្តឱ្យបានពេញលេញក្នុងរយៈពេល៥ឆ្នាំបន្ទាប់។

**៦. សមិទ្ធផលរំពឹងទុករបស់គោលដៅគោលនយោបាយ IDP៖** លទ្ធផលនៃការវិភាគបង្ហាញថា ទី១) អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. បានកើនឡើងយ៉ាងឆាប់រហ័សដល់ ៣៤,២% ក្នុងឆ្នាំ ២០១៩ លើសគោលដៅឆ្នាំ២០២៥ ដែលបានកំណត់ត្រឹម ៣០%។ យ៉ាងណាមិញ បទពិសោធន៍អន្តរជាតិ និងការប្រៀបធៀបជាមួយប្រទេសដទៃបង្ហាញថា អត្រាកំណើនខ្ពស់នេះមិនអាចបន្តនិរន្តភាពក្នុងរយៈពេលវែងបានទេ ហើយដែលនឹងអាចថមថយទៅវិញ។ ទី២) អនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. បានកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ប្រមាណ ០,២% ក្នុងរយៈពេល៥ឆ្នាំ ចុងក្រោយ (២០១៥-២០១៩) ដោយបានកើនដល់ ១៦,៣% ក្នុងឆ្នាំ២០១៩ ហើយដែលរំពឹងថានឹងមិនអាចសម្រេចបានគោលដៅដែលបានកំណត់ ២០% នៅឆ្នាំ២០២៥។ ទី៣) ចំណែកនៃការនាំចេញកសិផលកែច្នៃធៀបនឹងការនាំចេញសរុបបានធ្លាក់ចុះមកត្រឹម ៤,៩% នៅឆ្នាំ២០២០ ដែលទំនងជាមិនអាចសម្រេចបានគោលដៅ ១២% នៅឆ្នាំ២០២៥។ ទោះជាយ៉ាងណា ទំហំនៃការនាំចេញកសិផលកែច្នៃបានកើនពី ៥១៦លានដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដល់ ៨៤៦លានដុល្លារអាមេរិក នៅឆ្នាំ២០២០ ក្នុងអត្រាកំណើនមធ្យមប្រចាំឆ្នាំខ្ពស់ជាងបណ្តាប្រទេសជិតខាង។ ទី៤)ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើងបានកើនពី ៥,៦% នៅឆ្នាំ២០១៥ ដល់ ១៥,៥% នៅឆ្នាំ២០២០ លើសគោលដៅឆ្នាំ២០២៥ ដែលបានកំណត់ត្រឹម ១៥%។ ទី៥) អត្រាចុះបញ្ជីផ្លូវការសហគ្រាសធុនតូចបានធ្លាក់ចុះពី ៦៤,៤% នៅឆ្នាំ២០១៥ មកត្រឹម ៤៩,៧% នៅឆ្នាំ២០១៩ ដែលទំនងជាមិនអាចសម្រេចបានគោលដៅ ៨០% នៅឆ្នាំ២០២៥។ ប៉ុន្តែ អត្រាចុះបញ្ជីផ្លូវការសហគ្រាសធុនមធ្យម ៨៣,១% នៅឆ្នាំ២០១៥ គឺលើសគោលដៅឆ្នាំ២០២០ ដែលបានកំណត់ត្រឹម ៨០% ចាប់ពីការអនុវត្តគោលនយោបាយ IDP នៅឆ្នាំទី១។ ទី៦) អត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យសាមញ្ញ ត្រឹមត្រូវបានកើនពី ១៣% ក្នុងឆ្នាំ២០១៦ មកត្រឹម ១៨,៥៣% ក្នុងឆ្នាំ២០២០ ដែលមិនអាចសម្រេចបានគោលដៅឆ្នាំ២០២០ ដែលបានកំណត់ ៣០%។ ចំណែកឯអត្រាសហគ្រាសធុនមធ្យមដែលមានតារាងតុល្យការបានកើនពី ៣៤,៨៤% នៅឆ្នាំ ២០១៦ ដល់ ៣៨,៦៩% ឆ្នាំ២០២០ ដែលមិនអាចសម្រេចបានគោលដៅឆ្នាំ២០២០ ដែលបានកំណត់ ៥០%។

**៧. អនុសាសន៍គោលនយោបាយសម្រាប់ជំរុញការអនុវត្តគោលនយោបាយ** IDP៖ ដើម្បីសម្រេចគោលដៅរំពឹងទុកពេញលេញក្នុងការអនុវត្តគោលនយោបាយ IDP ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពសម្រាប់ដំណាក់កាលបន្ទាប់ ឆ្នាំ២០២២-២០២៥, អនុសាសន៍គោលនយោបាយគន្លឹះមួយចំនួនគួរយកមកពិចារណា រួមមាន៖

- ចំពោះការរៀបចំគោលនយោបាយគួរផ្តោតលើ៖ ការកែសម្រួលអន្តរាគមន៍គោលនយោបាយដែលគ្មានវិធានការ និងដែលពុំមានវិធានការគ្រប់គ្រាន់។
- ចំពោះការពង្រឹងការអនុវត្តវិធានការគោលនយោបាយគួរផ្តោតលើ៖ ១) ការបញ្ជ្រាបការយល់ដឹងពីចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយ IDP ដល់គ្រប់តួអង្គពាក់ព័ន្ធ, ២) ការបង្កើតក្រុមការងារទទួលបន្ទុកអនុវត្តគោលនយោបាយ IDP ដើម្បីធានាបាននូវការអនុវត្តប្រកបដោយចីរភាព និងប្រសិទ្ធភាព, ៣) ការធ្វើឱ្យប្រសើរឡើងនូវសូចនាករគោលនិងសូចនាករវឌ្ឍនភាពបន្ថែម ឬ/និងបង្កើតផែនការសកម្មភាពដែលមានលទ្ធផលរំពឹងទុកច្បាស់លាស់, ៤) ការកំណត់វិធានការគោលនយោបាយច្បាស់លាស់និងជាក់លាក់ដែលមានវិសាលភាពសមស្រប និង ៥) ការពង្រឹងការអនុវត្តវិធានការដែលមានភាពយឺតយ៉ាវខ្លាំង និងវិធានការណាដែលអាចទទួលបានផលក្នុងរយៈពេលខ្លីទៅមធ្យម (Low-hanging fruit)។
- ចំពោះការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាននិងវាយតម្លៃគួរផ្តោតលើ៖ ការធ្វើឱ្យប្រសើរឡើងនូវទម្រង់គំរូរបាយការណ៍ (RTF) និងការបង្កើតម៉េតាទិន្នន័យ (Metadata)។

**៨. ផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងការផ្តល់អនុសាសន៍៖** ការរីករាលដាលនៃជំងឺកូវីដ-១៩ ចាប់តាំងពីចុងឆ្នាំ២០១៩មក គឺជាបញ្ហាប្រឈមនិងការរំខានធំបំផុតនៃសកលភាវូបនីយកម្មក្នុងប្រវត្តិសាស្ត្រទំនើប ដែលបានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ច និងសង្គម។ កម្ពុជាក៏ដូចជាបណ្តាប្រទេសផ្សេងៗដែរ ការរីករាលដាលនៃជំងឺកូវីដ-១៩ បាននាំមកនូវផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យមួយចំនួន ដូចជា សេវាកម្ម, ការដឹកជញ្ជូននិងភស្តុភារកម្ម, សំណង់ និងអចលនទ្រព្យនិងកម្មន្តសាល ជាដើម។

វិស័យដែលរងផលប៉ះពាល់តិចជាងគេនោះគឺ វិស័យកសិកម្ម។ ក្នុងបរិការណ៍នេះ កម្ពុជាអាចសម្របខ្លួនទៅរកប្រក្រតីភាពថ្មីនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ តាមរយៈការដាក់ចេញវិធានការបុរេសកម្ម និងការឆ្លើយតបភ្លាមៗប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ កាត់ផ្តាច់ខ្សែចម្លង និងកាត់បន្ថយការឆ្លងបានទាន់ពេលវេលា ព្រមទាំងបានកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រគន្លឹះ។ កត្តាទាំងនេះ បានក្លាយជាលក្ខខណ្ឌដ៏សំខាន់មួយសម្រាប់ផ្តល់នូវជំនឿចិត្ត និងសុវត្ថិភាពដល់ធុរជន ក៏ដូចជាវិនិយោគិនក្នុងការមកវិនិយោគ និងធ្វើធុរកិច្ចនៅកម្ពុជា។

ទោះបីជាបច្ចុប្បន្ន រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ និងចំណាត់ការសំខាន់ៗដ៏មានប្រសិទ្ធភាពក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩ ប៉ុន្តែសម្រាប់រយៈពេលមធ្យមទៅវែងខាងមុខ ការអភិវឌ្ឍវិស័យឧស្សាហកម្មរបស់កម្ពុជាអាចប្រឈមនឹងការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកល ដែលមាននិន្នាការធំៗចំនួន ៣ គឺ៖

- បដិសកលភាវូបនីយកម្ម (Deglobalization) និងការរៀបចំឡើងវិញនៃខ្សែប្រវាក់ផ្គត់ផ្គង់សកលៈ ប្រទេសភាគច្រើនបានដាក់ចេញនូវវិធានការគោលនយោបាយឧស្សាហកម្ម ដែលមានទំនោរប្រកាន់យកបដិសកលភាវូបនីយកម្ម។ ជាមួយគ្នានេះ សាជីវកម្មពហុជាតិ ដែលបានរងផលប៉ះពាល់ពីការរាំងស្ទះនៃខ្សែប្រវាក់ផ្គត់ផ្គង់សកលបាននិងកំពុងគិតគូរ និងរៀបចំឡើងវិញនូវយុទ្ធសាស្ត្រខ្សែប្រវាក់ផ្គត់ផ្គង់របស់ខ្លួន ដើម្បីពង្រឹងភាពធន់នឹងវិបត្តិ ក្នុងនោះរួមមាន ការផ្តោតលើតំបន់ភាវូបនីយកម្ម ព្រមទាំងការបង្រួមនិងធ្វើសាមញ្ញកម្មនៃខ្សែប្រវាក់តម្លៃសកលឬតំបន់ មកកៀកនឹងទីផ្សារសំខាន់ៗ។
- ការបង្កើនការយកចិត្តទុកដាក់លើការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាពៈ រដ្ឋាភិបាលមួយចំនួន កំពុងដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពដ៏មានមហិច្ឆតាខ្ពស់ ដើម្បីធ្វើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្មកាន់តែមានចីរភាព ដែលការណ៍នេះបានកំណត់នូវលក្ខខណ្ឌតឹងរ៉ឹងជាងមុន សម្រាប់ការឈានចូលទៅក្នុងទីផ្សារនាពេលអនាគត។
- ការថយចុះនៃតួនាទីរបស់សហគ្រាសធុនតូចនិងមធ្យម ក្នុងផលិតកម្មឧស្សាហកម្មទំនើបបន្ទាប់ពីជំងឺកូវីដ-១៩ ដោយសារសហគ្រាសទាំងនោះ មិនអាចដើរឱ្យទាន់ល្បឿននៃការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មីៗ ដែលតម្រូវឱ្យមានធនធាន និងសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ ជាហេតុធ្វើឱ្យពួកគេក្ស័យធន ឬកាត់បន្ថយទំហំអាជីវកម្មរបស់ពួកគេ។

ដើម្បីសម្របខ្លួនបានទៅនឹងប្រក្រតីភាពថ្មី និងឆ្លើយតបទៅនឹងនិន្នាការខាងលើ សម្រាប់ដំណាក់កាលបន្ទាប់ ឆ្នាំ២០២២-២០២៥ គោលនយោបាយ IDP គួរផ្តោតលើ ៖

- ការបន្តពង្រឹងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការជំរុញការធ្វើពិពិធកម្មទីផ្សារដោយផ្តោតការយកចិត្តទុកដាក់បន្ថែមលើការនាំចេញទៅទីផ្សារក្នុងតំបន់ និងការបង្កើនសកម្មភាពផលិតផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក តាមរយៈការបន្តអនុវត្តវិធានការគោលនយោបាយ IDP ដែលមានស្រាប់ និងពិចារណាដាក់ចេញនូវវិធានការថ្មីៗបន្ថែមទៀត ដើម្បីសម្របខ្លួនឱ្យបានឆាប់រហ័សទៅនឹងការផ្លាស់ប្តូរទាំងនេះ។
- ការផ្តោតលើការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាព ដោយពិចារណាបង្កើតជាគោលបំណងគោលនយោបាយថ្មីមួយបន្ថែមទៀត ដែលមានអន្តរាគមន៍គោលនយោបាយ និងវិធានការគាំទ្រច្បាស់លាស់ និងមានភាពប្រាកដនិយម។
- ការបង្កើនការយកចិត្តទុកដាក់ និងពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម។

៩. ជារួម ការដាក់ចេញ និងការអនុវត្តគោលនយោបាយ IDP រយៈពេល៥ឆ្នាំកន្លងមកនេះ ថ្វីត្បិតតែទទួលបានលទ្ធផលល្អមួយចំនួន ប៉ុន្តែលទ្ធផលមួយចំនួនទៀតនៅមានភាពយឺតយ៉ាវ ឬមិនទាន់ស្របនឹងការរំពឹងទុកនៅឡើយ។ បើពិនិត្យលើទិដ្ឋភាពមួយជ្រុងទៀត រយៈពេល៥ឆ្នាំបន្ទាប់ពីការដាក់ចេញគោលនយោបាយ IDP គឺជាដំណាក់កាលដែលកម្ពុជាបាននិងកំពុងអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង និងផ្នែកទន់ ដែលមិនទាន់ផ្តល់បច្ច័យភ្លាមៗ ប៉ុន្តែនឹងផ្តល់បច្ច័យដល់ការសម្រេចគោលបំណងសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។ ជាមួយគ្នានេះ ការដាក់ចេញ និងការរៀបចំនូវច្បាប់បទដ្ឋានគតិយុត្ត គោលនយោបាយ និងក្របខណ្ឌគោលនយោបាយមួយចំនួនទៀត ដូចជា ច្បាប់ស្តីពីវិនិយោគ, ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥, សេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣០, ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍២០៣០ និងសេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ឆ្នាំ២០២១-២០២៦ ។ល។ ក៏នឹងមានបច្ច័យទៅលើការសម្រេចបាននូវគោលបំណងរបស់គោលនយោបាយ IDP ផងដែរ។

១០. ឈរលើលទ្ធផលនៃការវាយតម្លៃខាងលើនេះ និងផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ-១៩ ការកំណត់ទស្សនវិស័យ ឬការប្រមើលមើលទៅថ្ងៃខាងមុខ ព្រមទាំងសំណើអនុសាសន៍គោលនយោបាយជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់បញ្ចូលនៅក្នុងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនេះ។ ក្នុងន័យនេះ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ គឺជាឯកសារឆ្លុះបញ្ចាំងដែលមានមូលដ្ឋានរឹងមាំ និងច្បាស់លាស់សម្រាប់ជូនរាជរដ្ឋាភិបាល និងអង្គពាក់ព័ន្ធ ពិនិត្យពិចារណាក្នុងការកំណត់គោលដៅថ្មី, ការតម្រង់ទិសសម្រាប់ការអនុវត្តបន្ត, និងការដាក់ចេញនូវវិធានការជាកញ្ចប់។ វិធានការជាកញ្ចប់ដែលនឹងដាក់ចេញ នឹងដើរតួនាទីជាកូនសោគន្លឹះដ៏ស័ក្តិសិទ្ធិក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានរកឃើញខាងលើ និងដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិការណ៍ថ្មីៗ ដូចជា បដិវត្តន៍ឧស្សាហកម្ម៤.0 បរិវត្តកម្មឌីជីថល និងការរីករាលដាលនៃជំងឺកូវីដ-១៩ សំដៅជំរុញសម្រេចឱ្យបានពេញលេញនូវគោលបំណង និងចក្ខុវិស័យនៃគោលនយោបាយនេះ ព្រមទាំងអាចចូលរួមស្តារនិងពន្លឿនកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យល្អប្រសើរឡើងវិញតាមប្រក្រតីភាពនៃគន្លងថ្មី។

១១. របកគំហើញនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ បានបង្ហាញឱ្យឃើញពីភាពចាំបាច់ក្នុងការពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវនិងភាពពាក់ព័ន្ធនៃចក្ខុវិស័យ IDP សម្រាប់ការអនុវត្តក្នុងដំណាក់កាលបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលភូមិសាស្ត្រសេដ្ឋកិច្ច-សង្គម និងនយោបាយ ការប្រែប្រួលអាកាសធាតុ បដិវត្តឧស្សាហកម្មទី៤ និងរបត់នៃការផ្លាស់ប្តូរបច្ចេកវិទ្យា និងឌីជីថល ជាពិសេសក្នុង

បរិការណ៍នៃការរស់នៅជាមួយនឹងកូវីដ-១៩ ក្នុងប្រក្រតីភាពថ្មី។ ក្នុងន័យនេះ ដើម្បីពន្លឿន និងធានាប្រសិទ្ធភាពនៃការកំណត់ទិសដៅបន្ទាប់នៃគោលនយោបាយ IDP រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូន **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ដឹកនាំការសិក្សាវាយតម្លៃលម្អិតទៅលើនិន្នាការ និងការផ្លាស់ប្តូរនៃនិម្មាបនកម្មតំបន់ និងសកល ទាំងផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយ ដើម្បីកែសម្រួលចក្ខុវិស័យ គោលដៅ និងគោលបំណងនៃគោលនយោបាយ IDP សម្រាប់រយៈពេលបន្តខាងមុខ ដោយមានការចូលរួមសហការពីលេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្តគោលនយោបាយ IDP នៃ ក.អ.ក៕

# របាយការណ៍
# វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្ត
# គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥

*"តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផលដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម"*

## ១. សេចក្តីផ្តើម

ទន្ទឹមនឹងការធានាបានសន្តិភាព សន្តិសុខសង្គម និងស្ថិរភាពនយោបាយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាទីមោទនៈក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ការបន្តពង្រឹងកំណែទម្រង់ស្នូល ការលើកកម្ពស់ និងការអភិវឌ្ឍវិស័យឯកជន។ ព្រមជាមួយការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាព និងធន់នឹងវិបត្តិ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧% ជារៀងរាល់ឆ្នាំ ក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមកនេះ និងអត្រាភាពក្រីក្រធ្លាក់ចុះមកក្រោម ១០% នៅឆ្នាំ២០១៩ និង ផ.ស.ស. សម្រាប់មនុស្សម្នាក់បានកើនពី ១.២១៨ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ដល់ ១.៦៥៣ដុល្លារអាមេរិក នៅឆ្នាំ២០២០ ដែលសន្ទុះនៃការរីកចម្រើននេះ បានត្រួសត្រាយផ្លូវសម្រាប់កម្ពុជា ទទួលបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៥ ហើយអាចនឹងឈានទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០ និងកំពុងឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននិងកំពុងដាក់ចេញនូវវិធានការឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិការណ៍ថ្មីៗ ដូចជា បដិវត្តន៍ឧស្សាហកម្ម៤.០ បរិវត្តកម្មឌីជីថល និងការរីករាលដាលនៃជំងឺកូវីដ-១៩ សំដៅស្តារ និងពន្លឿនកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យល្អប្រសើរឡើងវិញតាមគន្លងប្រក្រតីភាពថ្មី។

ការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការតភ្ជាប់ ការពង្រឹងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារបន្ថែម គឺជាអាទិភាពនៃកិច្ចអភិវឌ្ឍន៍ ដូចមាន

ចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣។ ដើម្បីរួមចំណែកក្នុងការសម្រេចបានអាទិភាពទាំងនេះ រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ (IDP) ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើន និងរក្សាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពដែលឆ្លើយតបនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងការធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងសកល។ ជាមួយគ្នានេះដែរ ដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យឈានទៅកម្រិតខ្ពស់ក្នុងខ្សែច្រវាក់តម្លៃតំបន់ និងសកល, គោលនយោបាយ IDP ក៏បានកំណត់នូវយុទ្ធសាស្ត្រគន្លឹះ, វិធានការគោល-នយោបាយ និងផែនការសកម្មភាពផ្សារភ្ជាប់ទៅនឹងគោលបំណង និងគោលដៅ ដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ២០២៥។

ក្នុងការធានាបានវឌ្ឍនភាពជាប្រចាំ ប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការរៀបចំ និងសម្របសម្រួលអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រព័ន្ធតាមដាននិងវាយតម្លៃដ៏ពេញលេញ និងគ្រប់ជ្រុងជ្រោយមួយសម្រាប់ការអនុវត្តគោលនយោបាយ IDP។ ចាប់តាំងពីការអនុម័ត និងការអនុវត្តគោលនយោបាយ IDP នៅឆ្នាំ២០១៥ របាយ-ការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ចំនួន ២លើក គឺ របាយការណ៍វឌ្ឍនភាពគិតត្រឹមឆ្នាំ២០១៦ និងក្នុងឆ្នាំ២០១៧-២០១៨ ដែលត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាល។ បន្ថែមពីលើការរៀបចំរបាយការណ៍វឌ្ឍនភាពទាំង២ ក្របខណ្ឌតាមដាន និងវាយតម្លៃនៃការអនុវត្តគោល-នយោបាយ IDP ដែលជាត្រីវិស័យក្នុងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃ សម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិ ការតាមដានវឌ្ឍនភាពប្រចាំឆ្នាំ និងការវាយតម្លៃចុងអាណត្តិ នៃការអនុវត្តគោលនយោបាយ IDP ក៏ត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាលផងដែរ។ ក្របខណ្ឌតាមដាននិងវាយតម្លៃនេះ បានដាក់ចេញនូវយន្តការ និងឧបករណ៍សំខាន់ៗសម្រាប់វាយតម្លៃពីស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តគោលនយោបាយ IDP។

ផ្អែកលើមូលដ្ឋានខាងលើ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ (MTR) ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការចូលរួមផ្តល់ធាតុចូល និងពិនិត្យបន្ថែមពីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ក្នុងគោលបំណងវាយតម្លៃវឌ្ឍនភាព និងបច្ច័យនៃការអនុវត្តគោល-នយោបាយ សម្រាប់ឆ្នាំ២០១៥-២០២០ សមិទ្ធផលរំពឹងទុករបស់គោលដៅគោលនយោបាយ IDP និងដាក់ចេញនូវអនុសាសន៍គោលនយោបាយ ដោយផ្អែកលើលទ្ធផលគន្លឹះ ដើម្បីកែលម្អនិងពន្លឿនការអនុវត្តគោលនយោបាយ IDP សម្រាប់ដំណាក់កាលបន្ទាប់ ឆ្នាំ២០២២-២០២៥។

បន្ទាប់ពីសេចក្តីផ្តើមនេះ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ នេះមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែកទី២ បកស្រាយអំពីវិធីសាស្ត្រ និងឧបករណ៍សំខាន់ៗសម្រាប់ធ្វើការតាមដាន និងវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយ IDP
- ផ្នែកទី៣ វាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP
- ផ្នែកទី៤ វាយតម្លៃលើការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយ IDP
- ផ្នែកទី៥ និងផ្នែកទី៦ រំលេចសមិទ្ធផលរំពឹងទុក អនុសាសន៍គោលនយោបាយគន្លឹះ និងសេចក្តីសន្និដ្ឋាន។

## ២. វិធីសាស្ត្រនៃការវាយតម្លៃ

របាយការណ៍ MTR ត្រូវបានរៀបចំដោយប្រើប្រាស់ឧបករណ៍ចាំបាច់នៃប្រព័ន្ធតាមដាននិងវាយតម្លៃចំនួន ៣ រួមមាន៖ តក្កកម្មអន្តរាគមន៍, ក្របខណ្ឌតក្កកម្ម និងទម្រង់គំរូរបាយការណ៍។ ដើម្បីវិភាគឱ្យបានគ្រប់ជ្រុងជ្រោយពីវឌ្ឍនភាព និងបច្ច័យនៃការអនុវត្តគោលនយោបាយ IDP វិធីសាស្ត្រចម្រុះត្រូវបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍នេះ។

**តក្កកម្មអន្តរាគមន៍** (Intervention Logic) គឺជាឧបករណ៍បង្ហាញពីរចនាសម្ព័ន្ធគោលរបស់គោលនយោបាយ IDP ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។ ឧបករណ៍នេះបង្ហាញពីលទ្ធផលរំពឹងទុករយៈពេលមធ្យម នៃការអនុវត្តវិធានការគោលនយោបាយ, គោលបំណង និងការរួមចំណែករបស់គោលនយោបាយ IDP ក្នុងគោលដៅអភិវឌ្ឍន៍ជាតិ (រូបភាពទី១)។ ឧបករណ៍ត្រូវបានប្រើប្រាស់ដើម្បីកំណត់ថា តើចំណុច "អ្វីខ្លះ" ត្រូវធ្វើការវាស់វែងក្នុងប្រព័ន្ធតាមដាននិងវាយតម្លៃ និងវិភាគក្នុងរបាយការណ៍ MTR។

តក្កកម្មអន្តរាគមន៍ត្រូវបានរៀបចំជា ៤ ផ្នែក គឺ៖ (១) បង្ហាញពីការផ្សារភ្ជាប់រវាងគោលនយោបាយ IDP ជាមួយគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២) គូសបញ្ជាក់អំពីចក្ខុវិស័យ និងគោលបំណងរបស់គោលនយោបាយ IDP (៣) កំណត់អន្តរាគមន៍គោល-នយោបាយចាំបាច់ ដើម្បីសម្រេចគោលបំណងរបស់គោលនយោបាយ IDP និង (៤) បង្កើតការផ្សារភ្ជាប់រវាងវិធានការគោលនយោបាយនីមួយៗ ជាមួយអន្តរាគមន៍គោលនយោបាយ គោលបំណង ចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍ជាតិ។ ជាលទ្ធផល គោលដៅអភិវឌ្ឍន៍ជាតិចំនួន ៣, ចក្ខុវិស័យចំនួន ១, គោលបំណងគោលនយោបាយចំនួន ៥, និងអន្តរាគមន៍គោលនយោបាយចំនួន ២០ ត្រូវបានកំណត់ជាតក្កកម្មអន្តរាគមន៍របស់គោលនយោបាយ IDP។

**ក្របខណ្ឌតក្កកម្ម** (Log-frame) គឺជាឧបករណ៍ប្រើប្រាស់ដើម្បីប្រែក្លាយតក្កកម្មអន្តរាគមន៍ទៅជា តារាងម៉ាទ្រីសដែលអាចវាស់វែងបាន ដោយប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធទាំងអស់ និងកំណត់ថាសមាសធាតុផ្សេងៗ នៃតក្កកម្មអន្តរាគមន៍ត្រូវវាស់វែង "ដោយរបៀបណា"។ ក្នុងក្របខណ្ឌតក្កកម្ម សូចនាករត្រូវបានកំណត់ដើម្បីវាស់វែងសមិទ្ធកម្ម ឬវឌ្ឍនភាពតាមកម្រិតនីមួយៗ (ឧទាហរណ៍៖ គោលបំណងគោលនយោបាយ, អន្តរាគមន៍គោលនយោបាយ, វិធានការគោលនយោបាយ ជាដើម) រួមទាំងការបញ្ជាក់ប្រភពទិន្នន័យត្រឹមត្រូវ និងព័ត៌មានចាំបាច់ដទៃទៀត។ សរុបមក សូចនាករគន្លឹះ (KPIs) ចំនួន ៧២ ត្រូវបានកំណត់ដើម្បីវាស់វែងសមិទ្ធកម្មរបស់ IDP ក្នុងកម្រិតយុទ្ធសាស្ត្រ (គោលដៅអភិវឌ្ឍន៍ជាតិ, ចក្ខុវិស័យ, និងគោលបំណង) និងក្នុងកម្រិតវិស័យ (អន្តរាគមន៍គោលនយោបាយ)។ ប្រភពទិន្នន័យបែបបរិមាណវិស័យនៃសូចនាករគន្លឹះទាំងនេះ គឺ ផ្តល់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ទិន្នន័យដែលមានប្រភពពីប្រព័ន្ធទិន្នន័យអន្តរជាតិ ដូចជា UN COMTRADE និង World Development Indicators (WDI) ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងៗ។ ក្នុងករណីខ្លះ ប្រភពទិន្នន័យអន្តរជាតិក៏ត្រូវបានប្រើប្រាស់ដើម្បីបំពេញបន្ថែមលើសូចនាករដែល ពុំមានប្រភពទិន្នន័យជាតិ ។

**ទម្រង់គំរូរបាយការណ៍** (Reporting Template Format-RTF) គឺជាឧបករណ៍ប្រើប្រាស់ដើម្បីប្រមូលព័ត៌មាន និងពិនិត្យវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយក្នុងកម្រិតបច្ចេកទេស។ ឧបករណ៍នេះ គឺជាតារាងដែលដាក់បញ្ចូលរាល់វិធានការគោលនយោបាយ និងសូចនាករសម្រាប់អនុវត្តដែលបានមកពីក្របខណ្ឌតក្កកម្ម។ តារាងនេះប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យបែបបរិមាណវិស័យ និងគុណវិស័យដើម្បីវាស់វែងវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តវិធានការគោលនយោបាយនីមួយៗ របស់ក្រសួងស្ថាប័នពាក់ព័ន្ធ។ សូចនាករគោលចំនួន ៣ ត្រូវបានកំណត់សម្រាប់វិធានការគោលនយោបាយនីមួយៗ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តក្នុងកម្រិតបច្ចេកទេស។ សូចនាករវឌ្ឍនភាពបន្ថែម (API) អាចត្រូវបានកំណត់ដើម្បីប្រមូលទិន្នន័យបែបបរិមាណវិស័យបន្ថែមលើការអនុវត្តនិងលទ្ធផលនៃវិធានការគោលនយោបាយជាក់លាក់ណាមួយ។

របាយការណ៍ MTR ត្រូវបានប្រើប្រាស់វិធីសាស្ត្ររួមបញ្ចូលគ្នាទាំងបែបបរិមាណវិស័យ និងគុណវិស័យ។ វិធីសាស្ត្របែបបរិមាណវិស័យត្រូវបានប្រើប្រាស់សម្រាប់វិភាគបច្ច័យ និងលទ្ធផលនៃការអនុវត្តគោលនយោបាយ IDP ដូចជា ការកំណត់ចំណុចគោល (benchmarking), ការវិភាគនិន្នាការ ឬ វិភាគស៊េរីមុន និងក្រោយអន្តរាគមន៍ (interrupted time series) ក្នុងការវាយតម្លៃពីសមិទ្ធកម្មរបស់គោលនយោបាយ IDP។ វិធីសាស្ត្រវាយតម្លៃបែបគុណវិស័យ គឺជាការវាយតម្លៃលើការរៀបចំគោលនយោបាយ និងការអនុវត្តគោល-នយោបាយ IDP ដោយប្រើប្រាស់ទិន្នន័យបែបគុណវិស័យ និងបរិមាណវិស័យ។ ទិន្នន័យសម្រាប់វិភាគក្នុងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ប្រើប្រាស់ប្រភពទិន្នន័យជាតិ និងអន្តរជាតិ, ទម្រង់គំរូរបាយការណ៍, ឯកសារពាក់ព័ន្ធ និងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តគោលនយោបាយ IDP របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

ដែលបានរៀបចំកន្លងមក។ ដោយរបាយការណ៍នេះប្រើប្រាស់វិធីសាស្ត្រ និងប្រភពទិន្នន័យចម្រុះ លទ្ធផលនៃការវាយតម្លៃ និងសម្មតិកម្មប្រើប្រាស់ដើម្បីពន្យល់អំពីសមិទ្ធកម្មរបស់គោលនយោបាយ IDP គឺមានសុពលភាពខ្ពស់។

រូបភាពទី១៖ តក្កកម្មអន្តរាគមន៍គោលនយោបាយ IDP



# ៣. ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

## ៣.១. សមិទ្ធកម្មនៃការសម្រេចបាននូវចក្ខុវិស័យរបស់គោលនយោបាយ IDP

ចក្ខុវិស័យរបស់គោលនយោបាយ IDP គឺជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជាពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥។ យោងតាមចក្ខុវិស័យនេះ វិស័យឧស្សាហកម្មរបស់កម្ពុជា គួរតែផ្តោតលើការពង្រឹងមូលដ្ឋានឧស្សាហកម្ម ជាពិសេសឧស្សាហកម្មដែលពឹងផ្អែកលើជំនាញបច្ចេកទេសនិងប្រើប្រាស់បច្ចេកវិទ្យាទំនើប ក្នុងខ្សែច្រវាក់ផលិតកម្មឱ្យបានច្រើនជាងមុន។ តាមរយៈចក្ខុវិស័យនេះ គេអាចសន្និដ្ឋានបានថា កម្ពុជាមិនត្រឹមតែមានទស្សនវិស័យក្នុងការបង្កើនចំណែកឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ចរបស់ខ្លួនឡើយ ប៉ុន្តែថែមទាំងមានមហិច្ឆតាខ្ពស់ឆ្ពោះទៅកាន់ឧស្សាហកម្មដែលប្រើប្រាស់ជំនាញឱ្យបានច្រើនជាអតិបរមា ត្រឹមឆ្នាំ២០២៥។

សូចនាករចំនួន៣ ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងសមិទ្ធកម្មរបស់គោលនយោបាយនេះ ក្នុងការសម្រេច បាននូវចក្ខុវិស័យខាងលើ គឺ (១) "ចំណែកនៃវិស័យឧស្សាហកម្មក្នុង ផ.ស.ស.", (២) "ចំណែកនៃវិស័យកម្មន្តសាលក្នុង ផ.ស.ស." និង (៣) "ចំណែកនៃការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យម និងខ្ពស់ក្នុងការនាំចេញទំនិញកម្មន្តសាលសរុប"។ ខណៈដែលសូចនាករទី១និងទី២ បង្ហាញពីការប្រែក្លាយរចនាសម្ព័ន្ធជារួមនៃសេដ្ឋកិច្ចកម្ពុជាពីសកម្មភាពកសិកម្មឆ្ពោះទៅឧស្សាហកម្ម សូចនាករទី៣ធ្វើការវាស់វែងអំពីការផ្លាស់ប្តូររចនាសម្ព័ន្ធនៅក្នុងវិស័យឧស្សាហកម្មផ្ទាល់ពីសកម្មភាពឧស្សាហកម្មសាមញ្ញ (ការផលិតសម្លៀកបំពាក់) ទៅជាសកម្មភាពឧស្សាហកម្មដែលប្រើបច្ចេកវិទ្យាទំនើបជាងមុន (ដូចជា ការផលិតគ្រឿងអេឡិចត្រូនិក ការផលិតយានយន្ត ការផលិតគ្រឿងម៉ាស៊ីន ជាដើម)។ សូចនាករទី១ និងទី២ ត្រូវបានច្របាច់បញ្ចូលគ្នា ដើម្បីបង្ហាញពីលទ្ធផលវិភាគមួយដែលស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។




ប្រភពទិន្នន័យ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ចំណែកនៃវិស័យឧស្សាហកម្មក្នុង ផ.ស.ស. បានកើនឡើងពី ២៧,៧% នៅឆ្នាំ២០១៥ ទៅ ៣៤,២%នៅឆ្នាំ២០១៩ ដែលកើនលើសគោលដៅ ២៨% នៅឆ្នាំ២០២០ និង ៣០% នៅឆ្នាំ២០២៥ (រូបភាពទី២)។ ដោយឡែក ចំណែកនៃវិស័យកម្មន្តសាលក្នុង ផ.ស.ស. បែរជាពុំសូវមានការប្រែប្រួល ឬ អាចនិយាយបានថាហាក់ដូចជានៅទ្រឹង ទាំងក្នុងអំឡុងពេលមុននិងក្រោយការដាក់ចេញគោលនយោបាយ IDP។ ចំណែកនេះបានកើនពី ១៦% នៅឆ្នាំ២០១៥ មកត្រឹម ១៦,៣% នៅឆ្នាំ២០១៩ ដែលកំណើននេះហាក់ដូចជាមានល្បឿនយឺត និងទំនងជាមិនអាចសម្រេចបានតាមគោលដៅ ២០% នៅឆ្នាំ២០២៥។ ការណ៍នេះបង្ហាញថាតួនាទីរបស់អនុវិស័យកម្មន្តសាល ដែលជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម មិនទាន់ត្រូវបានធ្វើឱ្យប្រសើរឡើងដូចការរំពឹងទុកនៅឡើយ។ ផ្ទុយទៅវិញ សកម្មភាពក្នុងវិស័យឧស្សាហកម្មផ្សេងៗទៀតដែលមិនបានកំណត់ជាគោលដៅជាក់លាក់នៅក្នុងគោលនយោបាយ IDP ដូចជាវិស័យសំណង់ និងការផ្គត់ផ្គង់សេវាសាធារណៈ បានក្លាយជាចលករដ៏សំខាន់ក្នុងការជំរុញកំណើន។

រូបភាពទី៣៖ ចំណែកនៃការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យម និងខ្ពស់ (MHT) ក្នុងការនាំចេញទំនិញកម្មន្តសាលសរុប




ប្រភពទិន្នន័យ៖ WITS

កំណត់សម្គាល់៖ ការកំណត់ផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យមនិងខ្ពស់ ត្រូវបានធ្វើឡើងដោយផ្អែកលើក្រុមផលិតផលដែលត្រូវបានចាត់ថ្នាក់ដោយអង្គការ UNIDO (UNIDO Classifications of Medium and High tech products SITC Rev.3)

ចាប់តាំងពីការដាក់ចេញគោលនយោបាយ IDP នៅឆ្នាំ២០១៥មក ទំហំនៃការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យមនិងខ្ពស់បានកើនឡើងគួរឱ្យកត់សម្គាល់ ពីប្រមាណ ៧១៣លានដុល្លារអាមេរិក ទៅ ១,២ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩។ កំណើននេះ បង្ហាញថាសកម្មភាពឧស្សាហកម្មដែលប្រើប្រាស់ជំនាញនិងបច្ចេកវិទ្យាកំពុងមានការរីកចម្រើននៅកម្ពុជា។ ទោះជាយ៉ាងនេះក្តី ការកើនឡើងនេះ នៅមានកម្រិតតិចតួចនៅឡើយ ដោយសារចំណែកនៃការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យមនិងខ្ពស់ក្នុងការនាំចេញទំនិញកម្មន្តសាលសរុប បានកើនឡើងត្រឹមតែ ០,១% ប៉ុណ្ណោះ ពោលគឺបានកើនឡើងពី ៨,៩% នៅឆ្នាំ២០១៥ ដល់ត្រឹម ៩% នៅឆ្នាំ២០១៩ (រូបភាពទី៣)។ លទ្ធផលនេះបង្ហាញថា ឧស្សាហកម្មកម្ពុជានៅមានលក្ខណៈសាមញ្ញ និងប្រើបច្ចេកវិទ្យាទាប ដោយមិនទាន់មានការប្រែប្រួល ឬផ្លាស់ប្តូរទៅរកឧស្សាហកម្មដែលប្រើបច្ចេកវិទ្យាប្រសើរជាងមុននៅឡើយ។

ជារួម ការឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យរបស់គោលនយោបាយ IDP ក្នុងការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សហកម្ម សម្រេចបានលទ្ធផលដោយផ្នែក។ ទោះបីជាចំណែកនៃវិស័យឧស្សាហកម្មក្នុង ផ.ស.ស. សម្រេចបានលើសគោលដៅកំណត់ដោយគោលនយោបាយ IDP ក្តី សមិទ្ធកម្មនៃវិស័យកម្មន្តសាលហាក់ដូចជាមិនទាន់មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ លើសពីនេះទៀត ជវភាពនៃការឈានទៅរកសកម្មភាពឧស្សាហកម្មដែលប្រើប្រាស់ជំនាញ និងមានតម្លៃបន្ថែមខ្ពស់ជាងមុន នៅមានកម្រិតនៅឡើយ។ ហេតុនេះហើយ ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្មនៅចុងឆ្នាំ២០២៥ តាមការរំពឹងទុក កម្ពុជាគួរបន្តប្រឹងប្រែងឱ្យកាន់តែសកម្មជាងមុនក្នុងការទាក់ទាញសកម្មភាពកម្មន្តសាលផ្សេងៗបន្ថែមទៀត ជាពិសេស សកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់។

ការវិភាគស៊ីជម្រៅលើគោលបំណងគោលនយោបាយទាំង៥ដែលអាចវាស់វែងបាន ដូចបានកំណត់ក្នុងប្រព័ន្ធតាមដាននិងវាយតម្លៃរបស់គោលនយោបាយ IDP ត្រូវបានធ្វើឡើង ដើម្បីបង្ហាញអំពីបច្ច័យរបស់ IDP ក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន។ គោលបំណងគោលនយោបាយទាំង៥ ដែលរំលេចនៅក្នុងតក្កកម្មអន្តរាគមន៍ គឺជាបុរេលក្ខខណ្ឌចម្បងដើម្បីសម្រេចបាននូវចក្ខុវិស័យ និងដើម្បីធានាបាននូវការចូលរួមចំណែកជាវិជ្ជមានរបស់គោលនយោបាយ IDP ក្នុងគោលដៅអភិវឌ្ឍន៍ជាតិ។ គោលបំណងទាំង៥ រួមមាន៖ (១) បង្កើនសកម្មភាពឧស្សាហកម្ម (២) បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម (៣) សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម (៤) ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ និង (៥) បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា។

ដើម្បីកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ច និងរក្សាកំណើនសេដ្ឋកិច្ចរយៈពេលវែង ចាំបាច់ត្រូវបង្កើនសកម្មភាពឧស្សាហកម្មឱ្យកាន់តែខ្លាំង និងជំរុញការនាំចេញផលិតផលឧស្សាហកម្មឱ្យបានកាន់តែច្រើនឡើង។ ការជំរុញកំណើននៃតម្រូវការផលិតផលឧស្សាហកម្ម តាមរយៈការពង្រីកការនាំចេញផលិតផលទៅកាន់ទីផ្សារផ្សេងៗទៀតឱ្យកាន់តែទូលាយ នឹងធ្វើឱ្យសកម្មភាពឧស្សាហកម្មមានការកើនឡើង ហើយចុងក្រោយ

នឹងចូលរួមចំណែកដល់ការបង្កើនតួនាទីនៃវិស័យឧស្សាហកម្មក្នុងខឿនសេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី ការបង្កើនសកម្មភាពឧស្សាហកម្មតែមួយមុខនឹងមិនទាន់គ្រប់គ្រាន់ទេ ហេតុនេះហើយ ការកសាងសេដ្ឋកិច្ចដែលមានភាពធន់និងមានពិពិធកម្មពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សាបាននូវកំណើនប្រកបដោយចីរភាព និងបង្កើតឱ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្ម។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចគឺចាំបាច់ណាស់ដើម្បីរក្សាបាននូវកំណើន ដែលនឹងជួយកាត់បន្ថយភាពងាយរងគ្រោះដែលបង្កដោយវិបត្តិខាងក្រៅ។ ទន្ទឹមនឹងនេះ ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារក៏ដើរតួយ៉ាងសំខាន់ក្នុងការកែប្រែរចនាសម្ព័ន្ធឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។ ការកើនឡើងនៃសកម្មភាពឧស្សហកម្ម មិនត្រឹមតែជួយជំរុញដល់ការបង្កើតការងារប្រកបដោយគុណភាពសម្រាប់កម្មករ/និយោជិតដែលមានជំនាញប៉ុណ្ណោះទេ តែថែមទាំងចូលរួមចំណែកក្នុងការបង្កើតឱកាសការងារផ្សេងៗទៀត សម្រាប់កម្មករ/ពលករ ដែលមានជំនាញទាបផងដែរ។ មួយវិញទៀត ការកើនឡើងនៃសកម្មភាពឧស្សាហកម្មទាំងនោះ មិនអាចធានាបានថាផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលបានបង្កើត ត្រូវបានប្រើប្រាស់ជាប្រយោជន៍ក្នុងស្រុកនោះទេ។ ក្នុងន័យនេះ ការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមាជាកត្តាសំខាន់ ដែលគោល-នយោបាយ IDP បានចង្អុលបង្ហាញ ជាពិសេសតាមរយៈការពង្រឹងភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក ការបង្កើនខ្សែច្រវាក់តម្លៃក្នុងស្រុក ការជំរុញការតភ្ជាប់ និងការបង្កើតកម្រងឧស្សាហកម្ម។

ផ្នែកបន្តបន្ទាប់ចាប់ពីចំណុច ៣.២ ដល់ ៣.៦ បង្ហាញពីលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គោលបំណងទាំង៥ខាងលើ។ ផ្នែកទាំងនេះនឹងពន្យល់ឱ្យដឹងថាតើគោលបំណងគោលនយោបាយណាខ្លះ ដែលគ្មានវឌ្ឍនភាព ឬយឺតខ្លាំង សម្រេចបានដោយផ្នែក សម្រេចបានភាគច្រើន និងសម្រេចបានពេញលេញ។ ការវាយតម្លៃនេះនឹងចង្អុលបង្ហាញពីអាទិភាពរូបនីយកម្មនៃសកម្មភាពដែលត្រូវធ្វើជាចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមិទ្ធកម្មរបស់គោលនយោបាយ IDP នៅដំណាក់កាលបន្ទាប់ ឆ្នាំ២០២២-២០២៥។ ផ្នែកនីមួយៗបង្ហាញអំពីលទ្ធផលនៃការវិភាគលើសូចនាករសមិទ្ធកម្មគន្លឹះក្នុងគោលបំណងនីមួយៗ ជាមួយនឹងការវាយតម្លៃលើការរៀបចំគោលនយោបាយ និងអនុវត្តវិធានការគោលនយោបាយនៃអន្តរាគមន៍គោលនយោបាយនីមួយៗរបស់គោលបំណងទាំងនោះ មុននឹងឈានដល់ការសង្ខេបលទ្ធផលគន្លឹះ និងបច្ច័យសម្រាប់ការអនុវត្តបន្ត។ បន្ថែមលើនេះ ផ្នែកចុងក្រោយ ៣.៧ វាយតម្លៃអំពីការរួមចំណែករបស់គោលនយោបាយ IDP ក្នុងគោលដៅអភិវឌ្ឍន៍ជាតិរបស់កម្ពុជាជារួម។

# ៣.២. សមិទ្ធកម្មគោលបំណងទី១ “បង្កើនសកម្មភាពឧស្សាហកម្ម”

# ៣. ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

## ៣.២. សមិទ្ធកម្មគោលបំណងទី១ “បង្កើនសកម្មភាពឧស្សាហកម្ម”

### ៣.២.១. ការវាយតម្លៃសមិទ្ធកម្មគោលបំណងទី១

ការពង្រីកមូលដ្ឋានឧស្សាហកម្ម ជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការឈានទៅសម្រេចបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការអភិវឌ្ឍឧស្សាហកម្ម។ ដោយសារតែរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាមានមូលដ្ឋានតូចចង្អៀត ការបង្កើនសកម្មភាពឧស្សាហកម្មពិតជាមានសារៈសំខាន់ណាស់។ សូចនាករចំនួន ២ ដែលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងសមិទ្ធកម្មនៃគោលបំណងគោលនយោបាយទី១នេះ រួមមាន៖ (១) "តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់" និង (២) "តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់"។ សូចនាករទាំង២នេះ វាស់វែងពីទំហំនៃតម្លៃបន្ថែមសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំដែលបានបង្កើតឡើងនៅក្នុងវិស័យឧស្សាហកម្ម ឬវិស័យកម្មន្តសាល។ គួរកត់សម្គាល់ថា តម្លៃបន្ថែមក្នុងវិស័យកម្មន្តសាលរាប់បញ្ចូលត្រឹមតែឧស្សាហកម្មផលិតកែច្នៃប៉ុណ្ណោះ ចំណែកឯតម្លៃបន្ថែមក្នុងវិស័យឧស្សាហកម្មរាប់បញ្ចូលបន្ថែមទាំងសកម្មភាពក្នុងវិស័យសំណង់ និងការផ្គត់ផ្គង់សេវាសាធារណៈផងដែរ។

រូបភាពទី៤៖ តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម សម្រាប់មនុស្សម្នាក់ (គិតជាដុល្លារអាមេរិក)




ប្រភពទិន្នន័យ៖ ក្រសួងផែនការ

រូបភាពទី៥៖ តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល សម្រាប់មនុស្សម្នាក់ (គិតជាដុល្លារអាមេរិក)




ប្រភពទិន្នន័យ៖ ក្រសួងផែនការ

រូបភាពទី៤ និងរូបភាពទី៥ បង្ហាញពីនិន្នាការនៃតម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម និងវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់ ពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០១៩។ ខ្សែបន្ទាត់ពណ៌ទឹកក្រូចបង្ហាញពីកំណើនជាក់ស្តែង រីឯខ្សែបន្ទាត់ពណ៌ខៀវបង្ហាញពីនិន្នាការកំណើនគន់គូរ ក្នុងករណីដែលនិន្នាការ

កំណើនមុនពេលដាក់ចេញ IDP ត្រូវបានបន្តរហូតដល់ឆ្នាំ២០១៩។ ការប្រៀបធៀបនេះ បង្ហាញពីភាពខុសគ្នារវាងនិន្នាការកំណើន ក្នុងករណីមាន និងគ្មានការដាក់ចេញ IDP ព្រមទាំងបច្ច័យនៃការអនុវត្តគោលនយោបាយ។

លទ្ធផលនៃការវិភាគពីសមិទ្ធកម្មនៃសូចនាករទាំងពីរ "តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់" (រូបភាពទី៤) និង "តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់" (រូបភាពទី៥) បង្ហាញពីកំណើនជាបន្តបន្ទាប់ ទាំងមុនពេល និងក្រោយការដាក់ចេញគោលនយោបាយ IDP។ ការប្រៀបធៀប បង្ហាញថាតម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មមានកំណើនលឿនជាងមុន ដោយបានកើនរហូតដល់ ៣២០,៧ដុល្លារអាមេរិក។ ដោយឡែក តម្លៃបន្ថែមសរុបក្នុងវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់មានការកើនឡើងយឺតជាងមុនពេលការដាក់ចេញ IDP។ ប្រសិនបើនិន្នាការកំណើនមុនពេលដាក់ចេញគោលនយោបាយ IDP ត្រូវបានបន្តនោះ តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់អាចនឹងកើនដល់ ២១៦,៧ដុល្លារអាមេរិក ប៉ុន្តែតម្លៃជាក់ស្តែងបានកើនឡើងមកត្រឹមតែ ២០២,៦ដុល្លារអាមេរិកប៉ុណ្ណោះ។ យើងអាចទាញសេចក្តីសន្និដ្ឋាន ចំនួន៣ តាមរយៈលទ្ធផលនៃការវាយតម្លៃនេះ ដូចខាងក្រោម៖

(១) ការកើនឡើងនៃតម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម និងវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់ បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពជាទូទៅនៃសកម្មភាពឧស្សាហកម្មនៅកម្ពុជា

(២) ទោះជាយ៉ាងនេះក្តី និន្នាការនេះហាក់ដូចជាមានបច្ច័យតិចតួចក្នុងការបន្ត ឬបង្កើនកំណើននៃវិស័យកម្មន្តសាលដែលមានពីមុនមក ដោយហេតុថា កំណើននៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់ នៅមុនពេលដាក់ចេញគោលនយោបាយ IDP មានល្បឿនលឿនជាងកំណើននៅក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP។ ជាក់ស្តែង តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់ បានកើនឡើងជាបន្តបន្ទាប់ ទោះបីមាននិន្នាការទាបជាងកំណើនដែលបានគន់គូរបន្តិចក៏ដោយ។

(៣) កំណើននៃតម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់ ដែលបានកើនឡើងយ៉ាងលឿននៅក្រោយឆ្នាំ២០១៥នោះ អាចជាលទ្ធផលនៃការរីកចម្រើនក្នុងវិស័យសំណង់ និង/ឬវិស័យរ៉ែ។

### ៣.២.២. ការវាយតម្លៃអន្តរាគមន៍គោលនយោបាយក្នុងគោលបំណងទី១

គោលនយោបាយ IDP បានដាក់ចេញនូវវិធានការគោលនយោបាយចំនួន២០ នៅក្នុងអន្តរាគមន៍គោលនយោបាយចម្បងចំនួន៤ ដើម្បីជំរុញការពង្រីកមូលដ្ឋានឧស្សាហកម្ម។ អន្តរាគមន៍គោលនយោបាយចម្បងទាំង៤ រួមមានៈ (១) បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល (២)បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម (៣) បង្កើនផលិតភាពការងាររបស់សហគ្រាស និង (៤) បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស។ តារាងទី១ សង្ខេបអំពីការចូលរួមចំណែកនៃអន្តរាគមន៍គោលនយោបាយចម្បងទាំង៤ ក្នុងការបង្កើនសកម្មភាពឧស្សាហកម្ម។ លើសពីនេះទៅទៀតនោះ ការសម្រេចបាននូវគោលបំណងទី១ ក៏ត្រូវបានបំពេញបន្ថែមដោយវិធានការគោលនយោបាយចំនួន ៥៩ ផ្សេងទៀតទាក់ទងនឹង (១) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម (២) ការបង្កើនសកម្មភាពឧស្សាហកម្មថ្មី (៣) ការបង្កើននវានុវត្តន៍ឧស្សាហកម្ម និង (៤) ការពង្រឹងការអភិវឌ្ឍជំនាញនិងធនធានមនុស្ស ដែលជាអន្តរាគមន៍គោលនយោបាយបន្ទាប់បន្សំ។ ការវាយតម្លៃលម្អិតពីសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយបន្ទាប់បន្សំមានរៀបរាប់នៅក្នុងការវិភាគពីសមិទ្ធកម្មនៃគោលបំណងគោលនយោបាយផ្សេងទៀត ដែលអន្តរាគមន៍គោលនយោបាយទាំងនោះមានបច្ច័យដោយផ្ទាល់ក្នុងការសម្រេចបាន។

៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

តារាងទី១៖ សង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គ.ប.ទី១

| អន្តរាគមន៍គោលនយោបាយ | សមិទ្ធកម្ម | ការរៀបចំគោលនយោបាយ | ការអនុវត្ត |
|---|---|---|---|
| បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល | ការនាំចូលផលិតផលកម្មន្តសាលធៀបនឹងតម្លៃបន្ថែមកម្មន្តសាល សរុប កាន់តែមានការកើនឡើង ពី ២២៦% ក្នុងឆ្នាំ២០០៥ ទៅ ៣៧៧% ក្នុងឆ្នាំ២០១៥ និង ៥៦៨%ក្នុងឆ្នាំ២០១៩ចង្អុលបង្ហាញថាពីការកើនឡើងនៃភាពពឹងផ្អែកលើទំនិញកម្មន្តសាលនាំចូល ដោយមិនបានប្រើប្រាស់សក្តានុពលនៃផលិតកម្មក្នុងស្រុក | មិនមានវិធានការគោលនយោបាយច្បាស់លាស់ចែងក្នុង IDP | មិនមានវិធានការគោលនយោបាយច្បាស់លាស់ចែងក្នុង IDP |
| បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម | ទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្មក៏មានការកើនឡើងជាបន្តបន្ទាប់ពី ១.៦៥៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ដល់៣.២០១លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ ខណៈដែលទុនវិនិយោគផ្ទាល់ពីបរទេសក្នុង វិស័យកម្មន្តសាលមានការឡើងចុះ ដោយថយចុះពី ៤៩៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ដល់ត្រឹម ៣៥៦លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ | វិធានការគោលនយោបាយមានចំនួនច្រើន គ្រប់ជ្រុងជ្រោយ និងមានភាពច្បាស់លាស់ភាគច្រើន។ | ក្នុងចំណោមវិធានការគោលនយោបាយទាំង ១៧ មាន ១០វិធានការបានអនុវត្តពេញលេញ, ១វិធានការកំពុងអនុវត្ត, និង៦វិធានការយឺតយ៉ាវ |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| | ប៉ុន្តែក្រោយមកក៏ហក់ឡើងវិញយ៉ាងឆាប់រហ័សរហូតដល់ ៦៣១លាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។ | | |
| បង្កើនផលិតភាពការងាររបស់សហគ្រាស | ផលិតភាពការងារក្នុងវិស័យឧស្សាហកម្មបានបន្តកើនឡើងពី ១.៨៩៩ ដុល្លារអាមេរិកសម្រាប់កម្មករម្នាក់នៅក្នុងឆ្នាំ ២០១០ ដល់ ២.៤២៤ដុល្លារអាមេរិកសម្រាប់កម្មករម្នាក់ក្នុងឆ្នាំ២០១៩។ ប៉ុន្តែតួលេខនេះ បង្ហាញពីកំណើនតិចតួច និងមានដរភាពទាបជាងប្រទេសជាដៃគូប្រៀបធៀប។ | • ផ្តោតទៅលើការបង្កើនផលិត-ភាពនិងការបង្កើនគុណភាពរបស់សហគ្រាសធុនតូចនិងមធ្យម<br>• ការរៀបចំគោលនយោបាយមានភាពច្បាស់លាស់ ប៉ុន្តែចំនួននៃវិធានការគោលនយោបាយនៅមិនទាន់គ្រប់គ្រាន់នៅឡើយ | វិធានការគោនយោបាយមានតែ ១ ហើយវិធានការគោលនយោបាយនោះនៅកំពុងអនុវត្ត |
| បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស | មានការរីកចម្រើនខ្លាំង ដោយសារការនាំចូលគ្រឿងម៉ាស៊ីន ឬបច្ចេកវិទ្យាទាក់ទងទៅនឹងតម្លៃបន្ថែមកម្មន្តសាល បានកើនឡើងយ៉ាងឆាប់រហ័សចាប់តាំងពីការដាក់ចេញនូវ IDP ពោលគឺពី៤៤,៤% ក្នុងឆ្នាំ២០០៥ ទៅ១០២,៣% ក្នុងឆ្នាំ២០១៩។ | • ផ្តោតតិចតួចទៅលើការធ្វើទំនើបកម្មផ្នែកបច្ចេកវិទ្យារបស់ក្រុមហ៊ុនដូចបានចែងក្នុង IDP<br>• ចំនួនវិធានការគោលនយោបាយមានតិច និងការរៀបចំគោលនយោបាយមានភាពមិនសូវច្បាស់លាស់ | ក្នុងចំណោមវិធានការគោលនយោបាយទាំង ២ មាន ១ វិធានការកំពុងអនុវត្ត និង១ វិធានការយឺតយ៉ាវ |

**កំណត់សម្គាល់៖** សម្រាប់ការវិភាគលម្អិតលើអន្តរាគមន៍គោលនយោបាយចម្បងទាំង៤ (ការវាយតម្លៃសមិទ្ធកម្មបែបបរិមាណវិស័យ ការរៀបចំគោលនយោបាយ និងការអនុវត្តគោលនយោបាយ) សូមមើលឧបសម្ព័ន្ធទី១។

### អន្តរាគមន៍គោលនយោបាយ “បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល”

ការបង្កើនផលិតកម្ម និងតម្រូវការទំនិញក្នុងស្រុកដែលអាចជំនួសផលិតផលនាំចូល គឺជាការផ្លាស់ប្តូរមួយ ដែលគោលនយោបាយ IDP រំពឹងចង់បាន ហើយដែលអាចជាបច្ច័យដ៏សំខាន់ក្នុងការពង្រឹងផលិតកម្មក្នុងស្រុក។ សូចនាករចំនួន ១ "អនុបាតនៃការនាំចេញផលិតផលកម្មន្តសាលធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ” ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងលទ្ធផលនៃអន្តរាគមន៍គោលនយោបាយនេះ។ ការវាយតម្លៃបង្ហាញថា (១) ទំហំនៃទំនិញកម្មន្តសាលដែលបានផលិតនៅកម្ពុជានៅមានបរិមាណតិចតួចនៅឡើយ បើធៀបនឹងទំនិញកម្មន្តសាលដែលបាននាំចូល ហើយដែល (២) និន្នាការនេះបានកើនឡើងយ៉ាងឆាប់រហ័សនៅប៉ុន្មានឆ្នាំចុងក្រោយ ដែលស្ថានភាពនេះបង្ហាញថា សក្តានុពលនៃតម្រូវការក្នុងស្រុកមិនទាន់បានបំពេញដោយការផ្គត់ផ្គង់ក្នុងស្រុកឱ្យអស់ពីលទ្ធភាពនៅឡើយ។ ការទទួលបានលទ្ធផលមិនទាន់ឆ្លើយតបបែបនេះអាចបណ្តាលមកពីគោលនយោបាយ IDP ខកខានមិនបានដាក់ចេញនូវវិធានការជាក់លាក់ ពាក់ព័ន្ធនឹងការបង្កើនតម្រូវការផលិតផលក្នុងស្រុក និងការជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុកជំនួសឱ្យការនាំចូល។

### អន្តរាគមន៍គោលនយោបាយ “បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម”

ការវិភាគបង្ហាញថា ការរៀបចំគោលនយោបាយមានភាពគ្រប់ជ្រុងជ្រោយ ហើយវិធានការភាគច្រើនត្រូវបានអនុវត្តពេញលេញ។ ការវាយតម្លៃបែបបរិមាណវិស័យបានបង្ហាញថា ក្នុងដំហានដំបូងនៃការអនុវត្តគោលនយោបាយ IDP ទាំងទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម ទាំងទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល សុទ្ធតែរក្សាបាននូវកំណើនវិជ្ជមាន ប៉ុន្តែទុនវិនិយោគក្នុងស្រុកបានកើន (ជាមធ្យម ១៨%ក្នុងមួយឆ្នាំ) លឿនជាងទុនវិនិយោគផ្ទាល់ពីបរទេស (ជាមធ្យម ៦%ក្នុងមួយឆ្នាំ)។ ទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្មមានការកើនឡើងជាបន្តបន្ទាប់ពី ១.៦៥៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ដល់ ៣.២០១លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ខណៈដែលទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាលមានការឡើងចុះ ដោយថយចុះពី ៤៩៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ដល់ត្រឹម ៣៥៦លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ប៉ុន្តែក្រោយមកបានហក់ឡើងវិញយ៉ាងឆាប់រហ័សរហូតដល់ ៦៣១លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩។ យ៉ាងណាក្តី អត្រាកំណើនជាមធ្យមប្រចាំឆ្នាំនៃទុនវិនិយោគទាំងពីរប្រភេទ (ក្នុងស្រុកនិងបរទេស) ក្នុងដំណាក់កាលដំបូងនៃការអនុវត្ត IDP ជាអត្រាកំណើនមួយយឺតជាងអត្រាកំណើនមុនពេលមានគោលនយោបាយ។ បើទោះជាការពន្យល់ហេតុផលជាក់លាក់ពីសមិទ្ធកម្មដែលមានកម្រិតបែបនេះ អាចនឹងហួសពីវិសាលភាពនៃរបាយការណ៍នេះក៏ពិតមែន ប៉ុន្តែគេអាចទាញសម្មតិកម្មពាក់ព័ន្ធចំនួន ២ រួមមាន ១) ទោះបីជាកម្រងនៃវិធានការដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយ

នេះបានផ្តោតលើការជំរុញការវិនិយោគហើយក៏ដោយប៉ុន្តែភាពជាក់លាក់នៃការរៀបចំវិធានការគោលនយោបាយមួយចំនួនក៏នៅមានលក្ខណៈមិនច្បាស់លាស់ និងជាន់គ្នាផងដែរ ដែលការណ៍នេះ អាចនាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការគោលនយោបាយទាំងនោះនិង២) អភិក្រមបច្ចុប្បន្ននៃការជំរុញការវិនិយោគផ្ទាល់ពីបរទេសដែលមានលក្ខណៈទូទៅ ទំនងជាបានឈានដល់កម្រិតដែលប្រើប្រាស់អស់សក្តានុពលរួចហើយ ដែលទាមទារឱ្យមានការគិតគូបន្ថែមនូវការអនុវត្តអភិក្រមថ្មីក្នុងការទាក់ទាញវិនិយោគ។ ក្នុងន័យនេះ ដើម្បីជំរុញសន្ទុះនៃលំហូរទុនវិនិយោគផ្ទាល់ពីបរទេស គួរមានការផ្តោតការយកចិត្តទុកដាក់បន្ថែមឱ្យបានកាន់តែខ្លាំងជាងមុនលើការជំរុញការវិនិយោគតាមវិស័យជាក់លាក់ និងចំគោលដៅ។

**អន្តរាគមន៍គោលនយោបាយ "បង្កើនផលិតភាពការងាររបស់សហគ្រាស"**

គោលនយោបាយ IDP បានកំណត់ការបង្កើននូវផលិតភាពការងាររបស់សហគ្រាសជាបុរេលក្ខខណ្ឌដ៏សំខាន់មួយក្នុងការបង្កើនផលិតកម្មឧស្សាហកម្ម និងការពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា។ អន្តរាគមន៍គោលនយោបាយនេះមានគោលបំណងបង្កើនស័ក្តសិទ្ធភាពនៃសកម្មភាពផលិតដែលមានស្រាប់ តាមរយៈការកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនជាតុចេញផលិតកម្មឱ្យបានជាអតិបរិមា។ ការវាយតម្លៃ បង្ហាញថា ផលិតភាពការងារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា កើនឡើងជាមធ្យម ៥,២% ក្នុងមួយឆ្នាំ នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តគោលនយោបាយ IDP (២០១៥-២០១៩) ដែលលឿនជាងកំណើននៅក្នុងអំឡុងឆ្នាំ២០១០-២០១៥ (០,៨%ក្នុងមួយឆ្នាំ)។ ទោះបីជាយ៉ាងណាក៏ដោយ ការវិភាគដោយប្រៀបធៀបសមិទ្ធកម្មរបស់កម្ពុជាជាមួយប្រទេសមួយចំនួន (ដូចជា ប្រទេសបង់ក្លាដែស អេត្យូពី និងវៀតណាម) ពីឆ្នាំ២០១០-២០១៩ បង្ហាញថា កំណើនផលិតភាពការងាររបស់ប្រទេសកម្ពុជានៅតែទាបជាងប្រទេសទាំងអស់នោះ។ ការរៀបចំអន្តរាគមន៍គោលនយោបាយនេះ គឺនៅមិនទាន់គ្រប់គ្រាន់ ព្រោះមានវិធានការគោលនយោបាយតែមួយប៉ុណ្ណោះ ដែលផ្តោតលើការបង្កើនគុណភាព និងផលិតភាពរបស់សហគ្រាសធុនតូចនិងមធ្យម (SMEs) តាមរយៈមជ្ឈមណ្ឌលផលិតភាពជាតិនៃកម្ពុជា។ ម៉្យាងវិញទៀត វិធានការគោលនយោបាយនៅក្នុងអន្តរាគមន៍គោលនយោបាយនេះ គឺកំពុងបន្តអនុវត្តនៅឡើយ ដោយមានគោលដៅអនុវត្តឱ្យបានពេញលេញត្រឹមឆ្នាំ២០២៥។ ក្នុងបរិការណ៍នេះ យើងអាចសន្និដ្ឋានបានថា ការផ្លាស់ប្តូរផលិតភាពការងារខាងលើនេះ ទំនងមិនមែនជាលទ្ធផលដែលកើតចេញពីការអនុវត្តគោលនយោបាយ IDP ទេ តែជាលទ្ធផលដែលអាចកើតចេញពីការវិវត្តនៃទីផ្សារទៅវិញ។

**អន្តរាគមន៍គោលនយោបាយ "បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស"**

ការបង្កើនបច្ចេកវិទ្យារបស់សហគ្រាស ក៏ជាអន្តរាគមន៍គោលនយោបាយដ៏សំខាន់មួយដែលបានកំណត់ក្នុងគោលនយោបាយ IDP ដើម្បីពង្រីកផលិតកម្មឧស្សាហកម្ម។ តាមរយៈការវាយតម្លៃបែបបរិមាណវិស័យបង្ហាញថា អនុបាតនៃការនាំចូលទំនិញមូលធន ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលកើនឡើងថេរជាមធ្យមក្នុងអត្រា ២,៣% ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ២០០៥-២០១៥ និងបានកើនឡើងលឿនរហូតដល់ ៨,៦% ក្នុងមួយឆ្នាំ នៅក្រោយការដាក់ចេញនូវគោលនយោបាយ IDP។ កំណើនដ៏លឿននេះបង្ហាញថា សហគ្រាសកាន់តែច្រើនកំពុងបង្កើនការវិនិយោគទៅលើបច្ចេកវិទ្យា និងគ្រឿនម៉ាស៊ីនថ្មីៗក្នុងដំណើរការផលិតកម្មរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី អនុបាតនេះបានកើនឡើងលើស១០០% (១០២,៣%) នៅឆ្នាំ២០១៩ ដែលតួលេខនេះអាចត្រូវបានពន្យល់ថា ទំនិញមូលធននាំចូលទាំងនោះមិនទាន់ត្រូវបានប្រើប្រាស់ពេញសមត្ថភាពភ្លាមៗក្នុងការផលិតទំនិញដែលមានតម្លៃបន្ថែមខ្ពស់នៅក្នុងប្រទេសនៅឡើយទេ។ សម្មតិកម្មដែលបានលើកឡើងនេះ គួរតែមានការសិក្សាបន្ថែមឱ្យបានច្បាស់លាស់។ រីឯសហគ្រាសក៏គួរតែទទួលបាននូវការគាំទ្រដើម្បីប្រើប្រាស់ទំនិញមូលធនរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន។ ទន្ទឹមនេះ ការអនុវត្តវិធានការគោលនយោបាយហាក់នៅមានកម្រិត ព្រោះមិនទាន់មានវិធានការណាមួយដែលគាំទ្រដល់អន្តរាគមន៍គោលនយោបាយនេះ ត្រូវបានអនុវត្តសម្រេចពេញលេញនៅឡើយទេ (វិធានការភាគច្រើនកំពុងអនុវត្ត និងវិធានការចំនួន ១ មានភាពយឺតយ៉ាវ)។

## ៣.២.៣. លទ្ធផលគន្លឹះ និងបច្ច័យសម្រាប់ការអនុវត្តបន្ត

សរុបសេចក្តីមក ការបង្កើនសកម្មភាពឧស្សាហកម្មនៅកម្ពុជា ត្រូវបានវាយតម្លៃថា សម្រេចបានដោយផ្នែក។ ទោះបីការពង្រីកមូលដ្ឋានឧស្សាហកម្មមានការរីកចម្រើនជាបន្តបន្ទាប់ វឌ្ឍនភាពនេះអាចត្រូវបានមើលឃើញថា ជាការបន្តនិន្នាការកំណើននៃការអភិវឌ្ឍកន្លងមក ជាជាងលទ្ធផលដែលត្រូវបានរំពឹងទុកពីការអនុវត្ត IDP។ ជាក់ស្តែង ខណៈដែលកំណើនក្នុងវិស័យឧស្សាហកម្មមានការកើនឡើងលឿន កំណើនក្នុងវិស័យកម្មន្តសាល ដែលត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រស្នូលរបស់គោលនយោបាយ IDP ហាក់បីដូចជាមានល្បឿនយឺតជាងមុន។ ការថមថយនៃកំណើនក្នុងវិស័យកម្មន្តសាល អាចបណ្តាលមកពីភាពខ្វះចន្លោះ និងភាពមិនគ្រប់ជ្រុងជ្រោយនៃការរៀបចំ និងការអនុវត្តវិធានការគោលនយោបាយ។

ការវិភាគលើការរៀបចំ និងការអនុវត្តវិធានការគោលនយោបាយ បង្ហាញថា អភិក្រមនៃការជំរុញការវិនិយោគដែលមានស្រាប់ ប្រហែលជាឈានដល់ចំណុចសក្តានុពលពេញលេញហើយ ដែលតម្រូវឱ្យមានការគិតគូរបន្ថែមលើយុទ្ធសាស្ត្រទាក់ទាញវិនិយោគចំគោលដៅ។ម្យ៉ាងវិញទៀត ការវិនិយោគលើសកម្មភាពផលិតជំនួសផលិតផលនាំចូលហាក់ដូចជាមិនទាន់ត្រូវបានទទួលការយកចិត្តទុកដាក់គ្រប់គ្រាន់នៅឡើយ។ បន្ថែមលើនេះ វឌ្ឍនភាពនៃផលិតភាពការងារ ទំនងមិនមែនជាលទ្ធផលនៃការអនុវត្តវិធានការ

គោលនយោបាយ IDP ឡើយ ព្រោះការរៀបចំវិធានការគោលនយោបាយនៅមានភាពខ្វះចន្លោះ ហើយការអនុវត្តក៏នៅមានភាពយឺតយ៉ាវ។

វិធានការគោលនយោបាយដែលមានសក្តានុពល និងទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែម ដើម្បីទទួលបានលទ្ធផលល្អប្រសើរជាងនេះ រួមមាន៖ ការជំរុញការវិនិយោគថែមទៀត ដោយផ្តោតសំខាន់លើការទាក់ទាញវិនិយោគដាក់លាក់និងចំគោលដៅ ចំពោះវិស័យឧស្សាហកម្មអាទិភាព, ការដាក់ចេញវិធានការគោលនយោបាយបន្ថែមដើម្បីគាំទ្រដល់ផលិតកម្ម និងការប្រើប្រាស់ក្នុងស្រុក ក៏ដូចជាការដាក់ចេញនូវវិធានការគោលនយោបាយជាក់លាក់ ដើម្បីពង្រឹងសមិទ្ធកម្មរបស់សហគ្រាស ដោយផ្តោតបន្ថែមលើការគាំទ្រដល់សហគ្រាសក្នុងការស្រូបយកបច្ចេកវិទ្យា។

# ៣.៣. សមិទ្ធកម្មគោលបំណងទី២ "បង្កើនការនាំចេញទំនិញ ឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម"

# ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

## ៣.៣. សមិទ្ធកម្មគោលបំណងទី២ "បង្កើនការនាំចេញទំនិញឧស្សាហកម្ម និង កសិ-ឧស្សាហកម្ម"

### ៣.៣.១. ការវាយតម្លៃសមិទ្ធកម្មនៃគោលបំណងទី២

ការពង្រឹងការនាំចេញទំនិញឧស្សាហកម្ម គឺជាមូលដ្ឋានគ្រឹះសម្រាប់ការជំរុញឧស្សាហូបនីយកម្មនៅកម្ពុជា។ កំណើននៃការនាំចេញទំនិញឧស្សាហកម្ម នឹងបង្កើតឱ្យមានតម្រូវការបន្ថែមនៃទំនិញឧស្សាហកម្មផលិតនៅកម្ពុជា និងត្រួសត្រាយផ្លូវសម្រាប់ការកែប្រែរចនាសម្ព័ន្ធវិស័យឧស្សាហកម្មទាំងមូល។ ក្នុងបរិការណ៍នេះ តាមការចង្អុលបង្ហាញរបស់គោលនយោបាយ IDP ផលិតផលកសិផលកែច្នៃ គឺជាផលិតផលចម្បងមួយដែលមានសក្តានុពលខ្ពស់សម្រាប់ការនាំចេញរបស់កម្ពុជា។ ដូច្នេះ សូចនាករចំនួន ២ គឺ "ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់" និង "ចំណែកនៃការនាំចេញកសិផលកែច្នៃនៅក្នុងការនាំចេញសរុប" ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងសមិទ្ធកម្មនៃការនាំចេញឧស្សាហកម្មរបស់កម្ពុជា។ សូចនាករទាំងពីរនេះ អាចឆ្លុះបញ្ចាំងអំពីបច្ច័យដែលគោលនយោបាយ IDP មានទៅលើការជំរុញការនាំចេញឧស្សាហកម្មកន្លងមក។

រូបភាពទី៦៖ ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់
(គិតជាដុល្លារអាមេរិក)




ប្រភពទិន្នន័យ៖ WITS និងក្រសួងផែនការ

រូបភាពទី៦ បង្ហាញថា ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ បានកើនឡើងជាលំដាប់ពី ២៦០ដុល្លារអាមេរិក ក្នុងឆ្នាំ២០១០ ទៅដល់ ៥៣៤ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៥ និង ៨៥៥ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។ ទោះជាយ៉ាងនេះក្តី កំណើននៅក្នុងរង្វង់ ១២% ក្នុងមួយឆ្នាំ នៅក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP មានភាពប្រសើរជាងអត្រាកំណើនមធ្យមនៅចន្លោះឆ្នាំ២០១០-២០១៥ (១១% ក្នុងមួយឆ្នាំ) តែបន្តិចបន្តួចប៉ុណ្ណោះ។ ជាមួយគ្នានេះ បើធៀបនឹងតួលេខនៃការនាំចេញកម្មន្ត-សាលសម្រាប់មនុស្សម្នាក់ដែលបានគន់គូរ (៨២៤ដុល្លារអាមេរិក) ការកើនឡើងមកដល់ត្រឹម ៨៥៥ដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ នៅតែជាកំណើនក្នុងកម្រិតមួយទាប ដោយចន្លោះនៃតួលេខទាំងពីរមានប្រមាណ ៣១ដុល្លារអាមេរិកប៉ុណ្ណោះ។ កំណើនដ៏តិចតួចក្នុងរង្វង់ ៣១ដុល្លារអាមេរិកនេះ បង្ហាញថាសមិទ្ធកម្មដែលបានសង្កេតឃើញខាងលើ គឺជាការបន្តនៃនិន្នាការកំណើនកន្លងមក ជាជាងលទ្ធផលដែលកើតចេញពីបច្ច័យណាមួយនៃការអនុវត្តវិធានការគោលនយោបាយ IDP។




ប្រភពទិន្នន័យ៖អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

ទំហំនៃការនាំចេញកសិផលកែច្នៃបានបន្តរក្សាកំណើនប្រចាំឆ្នាំ ដោយបានកើនឡើងពី ៥១៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦ ទៅ ៨៤៦លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ ប៉ុន្តែជាចំណែកធៀបនឹងការនាំចេញសរុបបានធ្លាក់ចុះពី ៥,៨% ក្នុងឆ្នាំ២០១៥ មកត្រឹម ៤,៩% ក្នុងឆ្នាំ២០២០ ដែលមិនអាចសម្រេចតាមគោលដៅកំណត់ ១០% នៅឆ្នាំ២០២០ (រូបភាពទី៧)។ ទោះបីជាទំហំនៃការនាំចេញកសិផលកែច្នៃត្រូវបានពង្រីកក្តី ការនាំចេញក្នុងវិស័យដទៃទៀតបានកើនឡើងលឿនជាង ដែលនាំឱ្យមានការមើលរំលងពីតួនាទីរបស់អនុវិស័យកសិផលកែច្នៃសម្រាប់ការនាំចេញរបស់កម្ពុជា។ ជារួម ការប្រែប្រួលចំណែកនៃការនាំចេញកសិផលកែច្នៃក្នុងការនាំចេញសរុប បង្ហាញថាការពង្រឹងសមិទ្ធកម្មនាំចេញនៃឧស្សាហកម្មកែច្នៃកសិផលដែលបានកំណត់ដោយគោលនយោបាយ IDP នៅតែជាកិច្ចការសំខាន់សម្រាប់ពេលអនាគត។

## ៣.៣.២.ការវាយតម្លៃអន្តរាគមន៍គោលនយោបាយក្នុងគោលបំណងទី២

ដើម្បីជំរុញវិស័យនាំចេញរបស់កម្ពុជា គោលនយោបាយ IDP បានដាក់ចេញនូវវិធានការចំនួន ២៨ ក្រោមអន្តរាគមន៍គោលនយោបាយចម្បងចំនួន២ ដែលពាក់ព័ន្ធខ្លាំងទៅនឹងគោលបំណងទី២នេះ រួមមាន (១) បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក និង (២) ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់។ តារាងទី២ សង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ នៅក្នុងអន្តរាគមន៍គោលនយោបាយចម្បងទាំង២នេះ។ ជាងនេះទៅទៀត សមិទ្ធកម្មនៃគោលបំណងទី២ ក៏ត្រូវបានបំពេញបន្ថែមតាមរយៈការអនុវត្តវិធានការគោលនយោបាយចំនួន៣៣ ក្រោមអន្តរាគមន៍គោលនយោបាយបន្ទាប់បន្សំចំនួន៤ រួមមាន (១) បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម (២) បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ (៣) ពង្រីកនិងធ្វើពិពិធកម្មទីផ្សារនិងផលិតផលនាំចេញ និង (៤) តភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា។ ការវាយតម្លៃលម្អិតពីសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយបន្ទាប់បន្សំនីមួយៗទាំងអស់នេះ មានរៀបរាប់នៅក្នុងការវិភាគពីសមិទ្ធកម្មនៃគោលបំណងគោលនយោបាយផ្សេងទៀត ដែលអន្តរាគមន៍គោលនយោបាយទាំងនេះមានបច្ច័យដោយផ្ទាល់។

## តារាងទី២៖ សង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គ.ប.ទី២

| អន្តរាគមន៍គោលនយោបាយ | សមិទ្ធកម្ម | ការរៀបចំគោលនយោបាយ | ការអនុវត្ត |
|---|---|---|---|
| បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូច និងមធ្យមក្នុងស្រុក | (ទិន្នន័យនៃសូចនាករទាំងនេះអាចរកបានសម្រាប់តែឆ្នាំ២០១៩ ប៉ុណ្ណោះ)<br>• ចំណែកនៃចំនួនសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យ កម្មន្តសាលដែលធ្វើការនាំចេញធៀបនឹងចំនួនសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាលសរុបមានត្រឹមចំនួន ០,០២% នៅឆ្នាំ២០១៩<br>• ចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាល ធៀបនឹងការនាំចេញសរុប មានចំនួន ០,០១% នៅឆ្នាំ២០១៩ | • ផ្ដោតលើការរៀបចំផែនការ និងបង្កើតនូវមូលដ្ឋានរបស់ក្រុមហ៊ុនធុនតូច និងមធ្យម ប៉ុន្តែមិនសូវផ្ដោតលើការអភិវឌ្ឍសមត្ថភាពនាំចេញរបស់សហគ្រាសធុនតូច និងមធ្យម<br>• ចំនួននៃវិធានការគោលនយោបាយនៅមានតិចសម្រាប់វាស់វែងនូវលទ្ធផលដែលបានរំពឹងទុក<br>• ក្នុងចំណោម ៣ វិធានការ៖ មានវិធានការដាក់លាក់ចំនួន២ និងវិធានការត្រៀមចំនួន១ | ក្នុងចំណោមវិធានការទាំង៣៖ ១ វិធានការបានអនុវត្តពេញលេញ, ១ វិធានការកំពុងអនុវត្ត, និង ១ វិធានការមានការយឺតយ៉ាវក្នុងការអនុវត្ត |
| ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់ | • បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោកកើនឡើងពី ១,៧ លានតោន នៅឆ្នាំ២០១៦ ដល់ ២,២លានតោន នៅឆ្នាំ២០២០ ខណៈដែលអត្រាកំណើនជាមធ្យមប្រចាំឆ្នាំមានប្រមាណ ៦,៣% | • ផ្ដោតជាពិសេសលើការអភិវឌ្ឍការដឹកជញ្ជូន, ឡូជីស្ទិក និងរចនាសម្ព័ន្ធថាមពល ប៉ុន្តែពុំបានកំណត់វិធានការដាក់លាក់ពីលក្ខណៈឌីជីថលនៅឡើយ | ក្នុងចំណោម វិធានការគោលនយោបាយទាំង២៥ ក្នុងនោះវិធានការចំនួន៩បានកំពុងអនុវត្ត, វិធានការចំនួន |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| | • បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវដែកបានធ្លាក់ចុះ ពីប្រមាណ ៣១៧,៤ពាន់តោន នៅឆ្នាំ២០០៦ មកត្រឹម ៣,៦ ពាន់តោន នៅឆ្នាំ ២០១០ និងកើនឡើងវិញដល់ ៥៣៨,៣ ពាន់តោន នៅឆ្នាំ២០១៥ និងបន្តកើនឡើងដល់ប្រមាណ ១,១លានតោន នៅឆ្នាំ២០២០ ខណៈដែលអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ(២០១៥-២០២០) មានប្រមាណ ១៥,៦%<br>• នៅអំឡុងពេលមុនការដាក់ចេញ IDP ការដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែបានកើនឡើងក្នុងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ២៣,២% ពោលគឺបានកើនឡើងពីប្រមាណ ៧៣៧,៤ ពាន់តោន នៅឆ្នាំ ២០០៥ ដល់ប្រមាណជិត ៦ លានតោន នៅឆ្នាំ ២០១៥ ខណៈដែល អត្រាកំណើនក្នុងអំឡុងពេលអនុវត្ត IDP មានប្រមាណ ១១,៤% ក្នុងមួយឆ្នាំ ដោយបានកើនដល់ប្រមាណ ១០,២ លានតោននៅឆ្នាំ២០២០<br>• បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាសបានកើនឡើងពីប្រមាណ ១៦,៩ ពាន់តោន នៅឆ្នាំ ២០០៥ ដល់ប្រមាណ ៣៦,៩ ពាន់តោននៅឆ្នាំ ២០១៥ និងបន្ត កើនឡើងដល់ ១១០,៥ពាន់តោន នៅឆ្នាំ២០២០។ អត្រាកំណើននៃបរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាសក្នុងអំឡុងពេលមុនការដាក់ចេញIDP(ប្រមាណ ៨.១% ក្នុងមួយឆ្នាំ) មានទំហំប្រមាណ ១/៣ នៃអត្រាកំណើន ក្នុងអំឡុងពេលអនុវត្ត IDP (២៤,៥%ក្នុងមួយឆ្នាំ) | • វិធានការគោលនយោបាយមានចំនួនច្រើន ហើយវិធានការស្ទើរតែទាំងអស់មានភាពច្បាស់លាស់ | ១៣ បានអនុវត្តពេញលេញ និងវិធានការចំនួន៣ មានការយឺតយ៉ាវ |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| | • ប្រកទ្វាព្រំដែនសរុបចំនួន ៥ ត្រូវបានបង្កើតជាផ្លូវការនៅឆ្នាំ ២០១៦ និង ២០១៧ និងប្រកទ្វាព្រំដែនសរុបចំនួន ៧ ត្រូវបានដំឡើងកម្រិតសមត្ថភាពឱ្យស្របតាមប្រទេសជិតខាង ចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩<br>• អត្រាអ្នកប្រើប្រាស់អ៊ីនធឺណិតល្បឿនលឿនបានកើនឡើងយ៉ាងខ្លាំងពីប្រមាណ ០,៩% នៅឆ្នាំ២០១៥ ដល់ ៨៧,៨% នៅឆ្នាំ ២០២០ ខណៈដែលអត្រាវិសាលភាពគ្របដណ្ដប់នៃសេវាអ៊ីនធឺណិតល្បឿនលឿននៅក្នុងតំបន់ដែលមានប្រជាជនរស់នៅបានកើនឡើងពីប្រមាណ ១៣,៨២% នៅឆ្នាំ ២០១៥ ដល់ ៨៤,៦% នៅឆ្នាំ២០២០<br>• សន្ទស្សន៍ភូមិដែលទទួលបានការផ្គត់ផ្គង់អគ្គិសនីបានកើនឡើងពី ៧,៨% នៅឆ្នាំ ២០០៥ ដល់ ៦៦,៦% នៅឆ្នាំ ២០១៥ និងបន្តកើនឡើងដល់ ៩៧,៣៩% នៅឆ្នាំ២០២០។ ចំនួននៃការដាច់ចរន្តអគ្គិសនីបានកើនឡើងពី ៨ ដង នៅឆ្នាំ ២០១៧ ដល់ ២៣ ដង នៅឆ្នាំ ២០២០ ខណៈរយៈពេលនៃការដាច់ចរន្តអគ្គិសនីស្ថិតក្នុងកម្រិតទាប ពោលគឺមិនឱ្យលើសពី ២៤ ម៉ោងក្នុងមួយឆ្នាំ<br>• តម្លៃអគ្គិសនីដែលបានទិញពីអនុស្ថានីយបានធ្លាក់ចុះពី ១២,៩ សេនក្នុងមួយគីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៥ មកត្រឹម ១២,១ សេនក្នុងមួយគីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០២០ | | |

**កំណត់សម្គាល់៖** សម្រាប់ការវិភាគលម្អិតទៅលើអន្តរាគមន៍គោលនយោបាយចម្បងទាំង៤ (ក្នុងនោះមានការវាយតម្លៃសមិទ្ធកម្មបែបបរិមាណវិស័យ ការរៀបចំគោលនយោបាយ និងការអនុវត្តគោលនយោបាយ) សូមមើលឧបសម្ព័ន្ធទី១។

### អន្តរាគមន៍គោលនយោបាយ “បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូច និង មធ្យមក្នុងស្រុក”

អន្តរាគមន៍គោលនយោបាយនេះ មានគោលបំណងពង្រឹងសមត្ថភាពនាំចេញទំនិញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក និងបង្កើនគុណភាពផលិតផលឱ្យកាន់តែមានភាពប្រកួតប្រជែងជាងមុនក្នុងទីផ្សារអន្តរជាតិ។ សូចនាករចំនួន២ ត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយនេះ។ សូចនាករទី១ គឺចំណែកនៃចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលដែលធ្វើការនាំចេញធៀបនឹងចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលសរុប និងសូចនាករទី២ គឺចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យកម្មន្តសាលធៀបនឹងការនាំចេញសរុប។ ជាការកត់សម្គាល់ ទិន្នន័យនៃសូចនាករទាំងពីរនេះអាចរកបានសម្រាប់តែឆ្នាំ២០១៩ ប៉ុណ្ណោះ ដែលមិនអាចធ្វើការសិក្សាពីនិន្នាការវិវត្តនារយៈពេលកន្លងមកបាន។ នៅក្នុងឆ្នាំ២០១៩ ចំណែកនៃចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលដែលបានធ្វើការនាំចេញ ធៀបនឹងចំនួនសហគ្រាសធុនតូចនិងមធ្យមសរុបក្នុងវិស័យកម្មន្តសាល មានត្រឹមចំនួន ០,០២% ខណៈចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាលធៀបនឹងការនាំចេញសរុប មានត្រឹម ០,០១% ប៉ុណ្ណោះ។ ទិន្នន័យនៃសូចនាករទាំង២នេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា មិនមានសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកច្រើនទេ ដែលបានចូលរួមក្នុងសកម្មភាពនាំចេញ ដោយសារសមត្ថភាពនៃការនាំចេញរបស់សហគ្រាសទាំងនោះនៅមានកម្រិតនៅឡើយ។

ការវិភាគលើការរៀបចំគោលនយោបាយបង្ហាញថា វិធានការគោលនយោបាយទាំង ៣ ដែលស្ថិតក្រោមអន្តរាគមន៍គោលនយោបាយនេះ ពុំអាចនាំមកនូវបច្ច័យវិជ្ជមានរួមចំណែកដល់ការសម្រេចបាននៃអន្តរាគមន៍គោលនយោបាយនេះបានឡើយ ដោយសារវិធានការទាំងនោះផ្តោតសំខាន់តែលើការបង្កើតយន្តការគាំទ្រការនាំចេញរបស់សហគ្រាសធុនតូចនិងមធ្យម ខណៈដែលបញ្ហាភាគច្រើនដែលរាំងដល់ការនាំចេញរបស់សហគ្រាសទាំងនោះពុំទាន់ត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាពនៅឡើយ។ ក្នុងន័យនេះ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុក គួរមានការកំណត់វិធានការគោលនយោបាយបន្ថែមទៀត ជាពិសេសលើការកសាងសមត្ថភាពនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមក្នុងប្រទេស។ ជាមួយគ្នានេះ សមិទ្ធកម្មនេះក៏ឆ្លុះបញ្ចាំងពីភាពយឺតយ៉ាវនៃការអនុវត្តវិធានការគោលនយោបាយ ដែលមកទល់បច្ចុប្បន្នមានតែវិធានការចំនួន ១ ពាក់ព័ន្ធនឹងការបង្កើតសមាគមប៉ុណ្ណោះ ត្រូវបានអនុវត្តពេញលេញ។

អន្តរាគមន៍គោលនយោបាយ “ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់”

ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនិងការតភ្ជាប់ គឺជាអន្តរាគមន៍គោលនយោបាយដ៏សំខាន់មួយដែលគោលនយោបាយ IDP បានដាក់ចេញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការកាត់បន្ថយថ្លៃដើមផលិតកម្ម ឱ្យមានកម្រិតទាប និងធ្វើឱ្យល្អប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម សំដៅបង្កើនផលិតភាពក្រុមហ៊ុននៅកម្ពុជា។ ការវាយតម្លៃសមិទ្ធកម្មជារួមនៃការអនុវត្តគោលនយោបាយ IDP ក្រោមអន្តរាគមន៍គោលនយោបាយនេះ ទាមទារនូវការកំណត់សូចនាករច្រើន ដើម្បីវាស់វែងផ្នែកនីមួយៗនៃហេដ្ឋារចនា-សម្ព័ន្ធឧស្សាហកម្ម រួមមានសូចនាករពាក់ព័ន្ធនឹងថាមពល ប្រព័ន្ធដឹកជញ្ជូននិងភស្តុភារកម្ម និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។

ក្នុងចំណោមវិធានការទាំងអស់ក្រោមអន្តរាគមន៍គោលនយោបាយនេះ វិធានការពាក់ព័ន្ធនឹងការដឹកជញ្ជូន និងភស្តុភារកម្ម មានសារៈសំខាន់ជួយជំរុញកំណើនការនាំចេញ ដោយសារការកាត់បន្ថយចំណាយដឹកជញ្ជូន និងភស្តុភារកម្ម នឹងរួមចំណែកបង្កើនការប្រកួតប្រជែងការនាំចេញរបស់សហគ្រាស។ ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្មសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ជាក់ស្តែង ទិន្នន័យសូចនាករពាក់ព័ន្ធនឹងការដឹកជញ្ជូន បង្ហាញពីកំណើនជាបន្តបន្ទាប់នៃបរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក ផ្លូវដែក ផ្លូវអាកាស និងកំពង់ផែ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ វឌ្ឍនភាពគួរឱ្យកត់សម្គាល់ទាំងនេះ អាចជាលទ្ធផលនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផែនការអភិវឌ្ឍនានា ដែលរួមមាន ការអភិវឌ្ឍផែនការមេតភ្ជាប់ការដឹកជញ្ជូនឆ្លងដែន, ការស្តារឡើងវិញនូវផ្លូវដែកនៅភាគខាងត្បូង និងខាងជើង, ការសាងសង់ផ្លូវនិងការអភិវឌ្ឍសមត្ថភាពកំពង់ផែ។ ការវិភាគលើការរៀបចំគោលនយោបាយបង្ហាញថា IDP បានដាក់ចេញនូវអន្តរវិធានការគោលនយោបាយដែលប្រទាក់ក្រឡាគ្នា ដោយផ្តោតលើការអភិវឌ្ឍបណ្តាញផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ និងព្រលានយន្តហោះ និងបានកំណត់វិធានការទាំងនេះជាវិធានការគន្លឹះជាក់ស្តែងទី២ ព្រមទាំងបាននិងកំពុងអនុវត្ត។ យ៉ាងណាមិញ ការអនុវត្តក៏នៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនពិសេសកង្វះធនធានថវិកា និងការសម្របសម្រួលគោលនយោបាយ។

បន្ថែមលើនេះ ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី គឺជាវឌ្ឍនភាពគួរជាទីមោទនៈសម្រាប់គោលនយោបាយ IDP។ សក្ខីកម្មនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះជាបន្តបន្ទាប់នូវថ្លៃអគ្គិសនីនារយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដែលសម្រេចបានស្របតាមគោលដៅកំណត់ក្នុងគោលនយោបាយ។ ទន្ទឹមនេះ វិសាលភាពនៃការគ្របដណ្តប់ការផ្គត់ផ្គង់ថាមពលបានពង្រីកទៅដល់ស្ទើរតែគ្រប់ភូមិទាំងអស់នៅទូទាំងប្រទេស ដែលវិសាលភាពនេះ ឆ្លុះបញ្ចាំងពីការរៀបចំវិធានការគោលនយោបាយជាក់លាក់ និងការប្តេជ្ញាយ៉ាងមុតមាំពីក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយ។ ការវិភាគលើការរៀបចំគោលនយោបាយ

បង្ហាញថា ការពន្លឿនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពល ត្រូវបានចាត់ទុកជាអាទិភាពចម្បងសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដោយវិធានការនេះត្រូវបានកំណត់ជាវិធានការគន្លឹះមួយ ក្នុងចំណោមវិធានការជាក់ស្តែងទាំងបួនដែលត្រូវសម្រេចបាន នៅឆ្នាំ២០១៨។ ក្នុងន័យនេះ ក្រសួង ស្ថាប័ន បានអនុវត្តយ៉ាងពេញលេញនូវរាល់វិធានការពាក់ព័ន្ធទាំងអស់ ពិសេសនៅក្នុងការអភិវឌ្ឍវិស័យថាមពល និងការកាត់បន្ថយថ្លៃអគ្គិសនី។

ពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ពុំមានវិធានជាក់លាក់ណាមួយកំណត់ក្នុងគោលនយោបាយ IDP ដើម្បីគាំទ្រដល់ការអភិវឌ្ឍក្នុងវិស័យនេះនៅឡើយ។ យ៉ាងណាមិញ ទិន្នន័យស្តីពីការប្រើប្រាស់អ៊ីនធើណែត និងវិសាលភាពនៃការគ្របដណ្តប់នៅក្នុងប្រទេសកម្ពុជាមានការកើនឡើងចាប់តាំងពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០។ កំណើននៃការប្រើប្រាស់អ៊ីនធើណែត និងវិសាលភាពនៃការគ្របដណ្តប់បញ្ជាក់ពីការកើនឡើងយ៉ាងឆាប់រហ័សនៃការប្រើប្រាស់អ៊ីនធើណែតចល័តតាមរយៈទូរស័ព្ទវៃឆ្លាត ហើយផ្តល់នូវតម្លៃសមរម្យដែលអ្នកប្រើប្រាស់អាចទទួលយកបាន ក៏ដូចជាបង្ហាញពីការកើនឡើងនៃការវិនិយោគលើបច្ចេកវិទ្យា 4G ទន្ទឹមនឹងការជំរុញឌីជីថលូបនីយកម្ម តាមរយៈគោលនយោបាយអភិវឌ្ឍន៍ វិស័យទូរគមនាគន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ បន្ថែមលើនេះ គួរគូសបញ្ជាក់ផងដែរថា នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលទើបបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ព្រមទាំងកំពុងតែរៀបចំគោលនយោបាយរាជរដ្ឋាភិបាលឌីជីថលដែលត្រូវបានរំពឹងថានឹងជំរុញសន្ទុះនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលបន្ថែមទៀត។

### ៣.៣.៣. លទ្ធផលគន្លឹះ និងបច្ច័យសម្រាប់ការអនុវត្តបន្ត

សរុបមក លទ្ធផលនៃការបង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម ត្រូវបានវាយតម្លៃថា សម្រេចបានភាគច្រើន។ ជាក់ស្តែង ការនាំចេញទំនិញកម្មន្តសាលមានការកើនឡើងជាលំដាប់ ប៉ុន្តែអត្រាកំណើននេះគួរមានល្បឿនលឿនជាងកំណើនជាក់ស្តែងនៅក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ តាមរយៈការអនុវត្តគោលនយោបាយ IDP។ ផ្ទុយមកវិញ ទោះបីចំណែកនៃការនាំចេញកសិផលកែច្នៃបានធ្លាក់ចុះ ទំហំនៃការនាំចេញបានកើនឡើងជារៀងរាល់ឆ្នាំ ដែលហាក់នៅឆ្ងាយពីគោលដៅ ១០% នៅឆ្នាំ២០២០។ លទ្ធផលដែលមានកម្រិតបែបនេះ អាចបណ្តាលមកពីភាពខ្វះចន្លោះនៃការរៀបចំ និងការអនុវត្តវិធានការគោលនយោបាយ ក្រោមអន្តរាគមន៍គោលនយោបាយ "បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក" ដែលបានធ្វើឱ្យក្រុមហ៊ុនបរទេសធំៗ នៅបន្តគ្របដណ្តប់វិស័យឧស្សាហកម្មនាំចេញ។ ក្នុងន័យនេះ វិធានការគោលនយោបាយជាក់លាក់ គួរត្រូវបានរៀបចំដើម្បីគាំទ្រដល់ក្រុមហ៊ុននាំចេញ ទាំងសហគ្រាសធុនតូចនិងមធ្យម និងក្រុមហ៊ុនធុនធំៗក្នុងស្រុក។

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

ទោះបីអន្តរាគមន៍គោលនយោបាយពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានកំណត់ជាអាទិភាពនៅក្នុង IDP ហើយការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្មបានបន្តមានវឌ្ឍនភាពល្អប្រសើរក្តី កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយបន្ថែមទៀតនូវថ្លៃដើមដឹកជញ្ជូន និងភស្តុភារកម្ម គួរត្រូវបានបន្ត។ លើសពីនេះ ការសម្រេចបាននូវគោលបំណងនេះ ក៏ពឹងផ្អែកផងដែរទៅលើគោលបំណងគោលនយោបាយទី១ "បង្កើនសកម្មភាពឧស្សាហកម្ម" និង៣ "សេដ្ឋកិច្ចដែលមានភាពធន់និងមានពិពិធកម្ម"។ ការជំរុញវិស័យនាំចេញនឹងមិនអាចសម្រេចទៅរួចទេ ប្រសិនបើមូលដ្ឋានឧស្សាហកម្ម មិនត្រូវបានពង្រីក និងធ្វើពិពិធកម្ម។ ការបង្កើនការធ្វើពិពិធកម្ម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច តាមរយៈការផលិត និងនាំចេញទំនិញដែលមានភាពសម្បូរបែប និងមានតម្លៃបន្ថែមខ្ពស់ ទៅកាន់ទីផ្សារកាន់តែច្រើន ក៏ជាចលករមួយដ៏សំខាន់ក្នុងការជំរុញការសម្រេចបាននៃចក្ខុវិស័យ IDP ដែលសមិទ្ធកម្មរបស់ IDP ក្នុងផ្នែកនេះនឹងត្រូវពិភាក្សានៅក្នុងផ្នែកបន្ទាប់។

# ៣.៨. សមិទ្ធកម្មគោលបំណងទី៣ “សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម”

# ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

## ៣.៨.សមិទ្ធកម្មគោលបំណងទី៣ “សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម”

### ៣.៨.១. ការវាយតម្លៃសមិទ្ធកម្មគោលបំណងទី៣

ការជំរុញពិពិធកម្មសេដ្ឋកិច្ច គឺពិតជាកត្តាមូលដ្ឋានមួយដ៏សំខាន់សម្រាប់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង និងការពង្រឹងភាពធន់នៃសេដ្ឋកិច្ច។ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម កម្ពុជានឹងអាចកាត់បន្ថយបាននូវភាពងាយរងគ្រោះដែលបង្កដោយវិបត្តិពីខាងក្រៅ ព្រមទាំងពង្រឹងភាពធន់សម្រាប់ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ខ្លួន។ ក្នុងន័យនេះ ដោយហេតុថារចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជានៅមានលក្ខណៈតូចចង្អៀត និងប្រមូលផ្តុំនៅឡើយ ការជំរុញការធ្វើពិពិធកម្មរចនាសម្ព័ន្ធឧស្សាហកម្ម តាមរយៈការកាត់បន្ថយការពឹងផ្អែកខ្លាំងទៅលើសហគ្រាសធុនធំដែលមានចំនួនតិចតួច, ការបង្កើនសកម្មភាពផលិតកម្មក្នុងស្រុក, និងការពង្រីកមុខសញ្ញាផលិតផលនិងទីផ្សារសម្រាប់ការនាំចេញរបស់ខ្លួនឱ្យកាន់តែសម្បូរបែបជាងមុន ពិតជាមានសារៈសំខាន់។ ដើម្បីធ្វើការវាយតម្លៃពីសមិទ្ធកម្មនៃការធ្វើពិពិធកម្ម និងការពង្រឹងភាពធន់នៃសេដ្ឋកិច្ចរបស់កម្ពុជា សូចនាករចំនួន ២ ត្រូវបានយកមកប្រើប្រាស់ រួមមាន៖ ១) ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេ ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល និង ២) ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើងធៀបនឹងការនាំចេញសរុប។ សូចនាករទី១ ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងពីភាពប្រមូលផ្តុំនៃតម្លៃបន្ថែមក្នុងវិស័យកម្មន្តសាល ឯសូចនាករទី២ ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងពីស្ថានភាពនៃការកាត់បន្ថយការពឹងផ្អែកនៃឧស្សាហកម្មកម្ពុជាទៅលើអនុវិស័យកម្មន្តសាលសម្លៀកបំពាក់ និងស្បែកជើង ដែលជាវិស័យកម្មន្តសាលនាំមុខគេ។

រូបភាពទី៨៖ ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល (%)




ប្រភពទិន្នន័យ៖ ក្រសួងផែនការ

តាមរយៈការវាយតម្លៃបែបបរិមាណវិស័យ ចំណែកនៃតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេ (តម្បាញ សម្លៀកបំពាក់និងស្បែកជើង, ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, ឈើ ក្រដាស និងបោះពុម្ព) ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល មិនមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ទេ ព្រោះទាំងមុន និងក្រោយការដាក់ចេញគោលនយោបាយ IDP តួលេខជាមធ្យមនៃសូចនាករនេះ នៅតែស្ថិតក្នុងកម្រិតមួយខ្ពស់ក្នុងរង្វង់ ៨៨% ក្នុងមួយឆ្នាំ (រូបភាពទី៨)[៧]។ ការដែលចំណែកតម្លៃបន្ថែមនេះនៅតែស្ថិតក្នុងកម្រិតមួយខ្ពស់ និងមិនសូវថយចុះបែបនេះ បង្ហាញឱ្យឃើញថា វិស័យកម្មន្តសាលរបស់កម្ពុជា នៅតែប្រមូលផ្តុំជុំវិញសកម្មភាពដដែលៗមួយចំនួនតូចប៉ុណ្ណោះ ដោយមូលដ្ឋានផលិតកម្មមិនទាន់មានពិពិធកម្មនៅឡើយ។ ប្រសិនបើសេដ្ឋកិច្ចមួយបានចាប់ផ្តើម ឬត្រូវបានធ្វើពិពិធកម្ម នោះចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេ ត្រូវមានការថយចុះបន្តិចម្តងៗ ឬអាចថយចុះក្នុងកម្រិតមួយខ្ពស់តែម្តង។ ស្ថានភាពនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមនៅក្នុងការជំរុញពិពិធកម្មមូលដ្ឋានផលិតកម្ម ដើម្បីឈានទៅចាប់យកវិស័យកម្មន្តសាលថ្មីបន្ថែមទៀត និងផ្តល់សន្ទុះបន្ថែមដល់ការធ្វើពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច ព្រមទាំងឈានឆ្ពោះទៅការធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ទៅឧស្សាហកម្មផ្អែកលើជំនាញ តាមការរំពឹងទុករបស់គោលនយោបាយ IDP។

រូបភាពទី៩៖ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និង ផលិតស្បែកជើង ធៀបនឹងការនាំចេញសរុប (%)




ប្រភពទិន្នន័យ៖អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

[៧] លើកលែងតែនៅក្នុងឆ្នាំ២០១៩ (អំឡុងពេលវិបត្តិហិរញ្ញវត្ថុសកល) ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល បានកើនឡើងរហូតទៅដល់ ៩៧,១%

យ៉ាងណាមិញ ថ្វីត្បិតតែវិស័យកម្មន្តសាលរបស់កម្ពុជា នៅតែមានភាពប្រមូលផ្តុំខ្លាំងដូចបានបង្ហាញខាងលើក្តី ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង (រួមបញ្ចូលទាំងទំនិញសម្រាប់ការធ្វើដំណើរ) ធៀបនឹងការនាំចេញសរុប មានការកើនឡើងជាបន្តបន្ទាប់ពី ៥,៦% នៅឆ្នាំ២០១៥ ទៅ ១៥,៥% នៅឆ្នាំ២០២០ (រូបភាពទី៩) ដែលតួលេខនេះបានសម្រេចលើសគោលដៅ ១៥% នៅឆ្នាំ២០២៥ រួចស្រេចទៅហើយ ។ ការកើនឡើងនេះបានបង្ហាញថា កម្ពុជាបាននិងកំពុងនាំចេញផលិតផលច្រើនមុខសញ្ញាជាងមុន។

## ៣.៤.២. ការវាយតម្លៃអន្តរាគមន៍គោលនយោបាយក្នុងគោលបំណងទី៣

ដើម្បីជំរុញការធ្វើពិពិធកម្ម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច គោលនយោបាយ IDP បានដាក់ចេញនូវវិធានការគោលនយោបាយចំនួន ៣៩ នៅក្រោមអន្តរាគមន៍គោលនយោបាយចម្បងចំនួន ៥ ដូចជា ១) បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ, ២) ពង្រីកនិងធ្វើពិពិធកម្មទីផ្សារនិងផលិតផលនាំចេញ, ៣) ធ្វើឱ្យមានតុល្យ-ភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូចនិងមធ្យម, ៤) បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម, និង ៥) ធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម ដែលការវាយតម្លៃសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយចម្បងទាំង៥ នេះ នឹងត្រូវរៀបរាប់សង្ខេបនៅក្នុងតារាងទី៣ ខាងក្រោម។ គួរបញ្ជាក់ផងដែរថា បច្ច័យនៃគោលបំណងទី៣ ក៏នឹងត្រូវបំពេញបន្ថែមផងដែរ ដោយលទ្ធផលនៃការអនុវត្តវិធានការគោលនយោបាយនានានៅក្រោមអន្តរាគមន៍គោលនយោបាយ ចំនួន ៤ ផ្សេងទៀត រួមមាន ១) បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក, ២) ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក, ៣) បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក, និង ៤) បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ។

## តារាងទី៣៖ សង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គ.ប.ទី៣

| អន្តរាគមន៍គោលនយោបាយ | សមិទ្ធកម្ម | ការរៀបចំគោលនយោបាយ | ការអនុវត្ត |
|---|---|---|---|
| បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ | • ចំនួនក្រុមហ៊ុន និងសហគ្រាសធុនការថ្មីដែលបានចុះបញ្ជី មានការកើនឡើងពី ១.៩៤២ នៅឆ្នាំ២០០៥ ទៅដល់ ៥.៩២១ នៅឆ្នាំ២០១៥ និង ១៣.៥៤៧ នៅឆ្នាំ២០១៩។<br>• ចំនួនមុខទំនិញកម្មន្តសាលដែលបាននាំចេញមានកំណើនតិចតួចពី ៤៦៨ នៅឆ្នាំ២០១៧ ទៅ ៦៨៤ នៅឆ្នាំ២០២០។ | • ការរៀបចំគោលនយោបាយផ្តោតសំខាន់លើការលើកកម្ពស់សកម្មភាពផលិតកម្មទូទៅជាជាងសកម្មភាពផលិតកម្មថ្មីៗ ដោយសារ IDP មិនបានរំលេចឱ្យបានច្បាស់ពីសកម្មភាពគោលដៅ និងលក្ខខណ្ឌជាក់លាក់។<br>• ទោះបីចំនួនវិធានការគោលនយោបាយនៅក្រោមអន្តរាគមន៍គោលនយោបាយនេះនៅមានចំនួនតិចតួចក្តី វិធានការទាំងនោះ ជាវិធានការច្បាស់លាស់។ | ក្នុងចំណោមវិធានការគោលនយោបាយសរុប ៤ វិធានការ ចំនួន ១ ជា វិធានការកំពុងអនុវត្ត, វិធានការចំនួន ២ ជាវិធានការសម្រេចពេញលេញ, និងវិធានការ ១ ទៀត ជាវិធានការយឺតយ៉ាវ។ |
| ពង្រីក និងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ | • ចំណែកនៃការនាំចេញផលិតផលកម្មន្តសាល ៥ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប បានធ្លាក់ចុះពី ៩៤,៦% នៅឆ្នាំ២០០៥ មកត្រឹម ៨៣,៥% នៅឆ្នាំ២០១៥ និងមកត្រឹម ៦៣,៣% នៅឆ្នាំ២០១៩។<br>• ចំណែកនៃការនាំចេញផលិតផលកម្មន្តសាល ៣ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប បានធ្លាក់ចុះពី ៨៣,៣% នៅឆ្នាំ២០០៥ មកត្រឹម ៤១,៩% នៅឆ្នាំ២០១៦ ប៉ុន្តែមានការកើនឡើងដល់ ៤៨,៣% វិញនៅឆ្នាំ២០១៩។ ចំនួនទីផ្សារនាំចេញ | • ការរៀបចំគោលនយោបាយផ្តោតសំខាន់លើយន្តការសម្របសម្រួលពាណិជ្ជកម្ម (ដូចជាកាត់បន្ថយការបំពេញបែបបទស្មុគស្មាញ) និងការរៀបចំយន្តការគាំទ្រដើម្បីជំរុញសហគ្រាសឱ្យធ្វើការនាំចេញបន្ថែម។<br>• វិធានការគោលនយោបាយ មានចំនួនគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃអន្តរាគមន៍គោលនយោបាយ ឯការរៀបចំគោលនយោបាយមានភាពច្បាស់លាស់ ដោយក្នុងនោះវិធានការគោលនយោបាយ | ក្នុងចំណោមវិធានការ និងអនុវិធានការគោលនយោបាយ ចំនួន ៩ វិធានការចំនួន ៦ ជាវិធានការសម្រេចពេញលេញ, វិធានការចំនួន ១ ជាវិធានការកំពុងអនុវត្ត, និងវិធានការចំនួន ២ ជាវិធានការយឺតយ៉ាវ។ |

| | | | |
|---|---|---|---|
| | (ដែលការនាំចេញខ្ពស់ជាងកម្រិត ១០លានដុល្លារ) មានការកើនឡើងពី ១១ នៅឆ្នាំ២០០៥ ទៅដល់ ៤០ នៅឆ្នាំ២០១៥ និង ៤៥ នៅឆ្នាំ២០១៩។ | ចំនួន ៥ ជាវិធានការច្បាស់លាស់, វិធានការចំនួន ១ ជាវិធានការមិនច្បាស់លាស់ ហើយវិធានការចំនួន ២ ទៀត ជាសកម្មភាព ត្រៀម។ | |
| ធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូច និងមធ្យម | • ចំណែកនៃចំនួនការងារដែលផ្តល់ដោយសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម មានការកើនឡើងគួរឱ្យកត់សម្គាល់ពី ២១,៨% នៅឆ្នាំ២០១៨ ទៅដល់ ៣៣,៥% នៅ ឆ្នាំ ២០១៩ (គួរបញ្ជាក់ផងដែរថា ទិន្នន័យសម្រាប់សូចនាករនេះមានតែចំនួន ២ឆ្នាំ ប៉ុណ្ណោះ)។ | • ការរៀបចំគោលនយោបាយផ្តោតលើការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់បង្កើនចំនួនសហគ្រាសធុនតូចនិងមធ្យម, ពង្រឹងការកសាងសមត្ថភាព និងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន។<br>• ការរៀបចំគោលនយោបាយមានភាពច្បាស់លាស់ និងអាចនាំមកនូវបច្ច័យវិជ្ជមានដែលនឹងរួមចំណែកដល់ការសម្រេចបាននៃអន្តរាគមន៍គោលនយោបាយនេះ។ ទោះជាយ៉ាងនេះក្តី ជោគជ័យនៃអន្តរាគមន៍គោលនយោបាយនេះ ទាមទារឱ្យមានការដាក់ចេញបន្ថែមនូវវិធានការគោលនយោបាយផ្នែកតម្រូវការ (Demand-side policy measures)។ | ក្នុងចំណោមវិធានការ និងអនុវិធានការគោលនយោបាយទាំង៤ វិធានការចំនួន ២ ជាវិធានការសម្រេចពេញលេញ, វិធានការចំនួន ១ ជាវិធានការកំពុងអនុវត្ត និងវិធានការចំនួន ១ ទៀតជាវិធានការយឺតយ៉ាវ។ |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម | • ចំនួនសំណើសុំប្រកាសនីយបត្រតក្កកម្ម បានកើនឡើងពី ១៣ នៅឆ្នាំ២០០៧ ទៅដល់ ៦៥ នៅឆ្នាំ២០១៥ ហើយតួលេខនេះបានកើនឡើងទៅដល់ ១.១៩០ នៅឆ្នាំ២០២០។ ដោយឡែក ចំនួនសំណើសុំដែលបានស្នើដោយនិវាសនជននៅមានចំនួនតិចតួចនៅឡើយ។<br>• ចំនួនសំណើសុំប្រកាសនីយបត្រតក្កកម្ម ដែលបានស្នើដោយអនិវាសនជន ភាគច្រើនធ្វើឡើងសម្រាប់ការពាររបកគំហើញដែលត្រូវបានរកឃើញនៅបរទេស និងកម្មសិទ្ធិបញ្ញាអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ ២០១៤ ពុំមានប្រកាសនីយបត្រតក្កកម្មត្រូវបានអនុញ្ញាតផ្តល់ជូនអ្នកស្នើសុំនោះទេ ដោយសារពាក្យស្នើសុំពុំបានភ្ជាប់មកជាមួយនូវឯកសារតម្រូវគ្រប់គ្រាន់។ ចំនួនប្រកាសនីយបត្រតក្កកម្មដែលទទួលបានការអនុញ្ញាតសរុបបានកើនឡើងដល់ ១៨៣ នៅឆ្នាំ២០១៩។ គិតមកទល់ពេលទទួលបានទិន្នន័យនេះ ប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ជូននិវាសនជនមានចំនួនតែ ១ ប៉ុណ្ណោះ គឺនៅឆ្នាំ២០១៥។ | • ការរៀបចំគោលនយោបាយផ្តោតសំខាន់លើការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់ការជំរុញនវានុវត្តន៍ និងការលើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ប៉ុន្តែមិនបានកំណត់ឱ្យបានជាក់លាក់ពីវិធីសាស្ត្រ/មធ្យោបាយក្នុងការជំរុញ R&D នោះឡើយ ពោលគឺ IDP ពុំបានដាក់ចេញនូវវិធានការគ្រប់គ្រាន់ ដើម្បីបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្មឡើយ។<br>• ការរៀបចំគោលនយោបាយមានភាពជាក់លាក់ ក្នុងនោះវិធានការគោលនយោបាយចំនួន ៨ ជាវិធានការច្បាស់លាស់, វិធានការចំនួន ៣ ជាវិធានការមិនច្បាស់លាស់ និង វិធានការចំនួន ៥ ទៀត ជាសកម្មភាពត្រៀម។ | ក្នុងចំណោមវិធានការ និងអនុវិធានការគោលនយោបាយទាំង ១៧ វិធានការចំនួន ៤ ជាវិធានការសម្រេចពេញលេញ, វិធានការចំនួន ៨ ជាវិធានការកំពុងអនុវត្ត និង វិធានការចំនួន ៤ ទៀតជាវិធានការយឺតយ៉ាវ។ |
| ធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម | • អត្រាចុះបញ្ជីរបស់សហគ្រាសធុនមធ្យមមានការកើនឡើងពី ៨៣,១% នៅឆ្នាំ២០១៥ ទៅ ៨៧% នៅឆ្នាំ២០១៩ ដែលលើសពីគោលដៅកំណត់ឆ្នាំ២០២០ (៨០%) ខណៈពេលដែលការចុះបញ្ជីសហគ្រាសធុនតូចបានធ្លាក់ចុះពី ៦៤% នៅឆ្នាំ២០១៥ មកត្រឹម | • ការរៀបចំគោលនយោបាយផ្តោតលើការបង្កើតយន្តការនានា ដើម្បីជំរុញការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងជំរុញការផ្សព្វផ្សាយការយល់ដឹងពីផលប្រយោជន៍នៃការប្រើប្រាស់បញ្ជីគណនេយ្យសាមញ្ញដល់សហគ្រាសធុនតូច និងមធ្យម។ | ក្នុងចំណោមវិធានការគោលនយោបាយទាំង ៩ វិធានការចំនួន ២ ជាវិធានការ សម្រេចពេញលេញ, វិធានការចំនួន ១ ជាវិធានការកំពុងអនុវត្ត, |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| | ៥០% នៅឆ្នាំ២០១៩ ដែលស្ថិតនៅឆ្ងាយពីគោលដៅឆ្នាំ ២០២០ (៧០%)។<br>• អត្រាសហគ្រាសធុនមធ្យមដែលកាន់តារាងតុល្យការ នៅឆ្នាំ២០២០ មាន ៣៨,៦៩% ដែលមិនអាចសម្រេច គោលដៅឆ្នាំ២០២០ (៥០%)នោះទេ។ ទន្ទឹមនឹងនេះ អត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យ សាមញ្ញបានកើនឡើងពី ១៣% នៅឆ្នាំ២០១៦ ដល់ ១៨,៥៣% នៅឆ្នាំ២០២០ ដែលអត្រានេះទាបជាង គោលដៅឆ្នាំ២០២០ (៣០%)។ | • វិធានការគោលនយោបាយនៅមានចំនួនតិច តួច ដែលមិនគ្រប់គ្រាន់ សម្រាប់ជំរុញការចុះ បញ្ជីសហគ្រាសធុនតូច និងមធ្យមឡើយ។<br>• វិធានការគោលនយោបាយទាំង៧ មានភាព ច្បាស់លាស់ លើកលែងតែវិធានការចំនួន ២ ប៉ុណ្ណោះដែល ជាវិធានការមិន ច្បាស់លាស់។ | និងវិធានការចំនួន ៦ ទៀតជា វិធានការយឺតយ៉ាវ។ |

**កំណត់សម្គាល់៖** សម្រាប់ការវិភាគលម្អិតទៅលើអន្តរាគមន៍គោលនយោបាយចម្បងទាំង៤ (ការវាយតម្លៃសមិទ្ធកម្មបែបបរិមាណវិស័យ ការរៀបចំគោលនយោបាយ និងការអនុវត្តគោលលនយោបាយ) សូមមើលឧបសម្ព័ន្ធទី១។

### អន្តរាគមន៍គោលនយោបាយ “បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ”

អន្តរាគមន៍គោលនយោបាយនេះ ផ្តោតសំខាន់លើការធ្វើឱ្យប្រសើរឡើងនូវសកម្មភាពផលិតកម្មដែលមានស្រាប់ និងលើកកម្ពស់ការទាក់ទាញវិនិយោគក្នុងសកម្មភាពឧស្សាហកម្មថ្មីឈានមុខ។ សូចនាករចំនួន ២ ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយនេះ រួមមាន ១) ចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលផ្លូវការដែលបានចុះបញ្ជី និង ២) ចំនួនផលិតផលកម្មន្តសាលនាំចេញថ្មីៗ។ ការវាយតម្លៃបង្ហាញថា ចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជីមានការកើនឡើងពីចំនួន ៥.៩២១ នៅឆ្នាំ២០១៥ ទៅដល់ ១៣.៥៤៧ នៅឆ្នាំ ២០១៩។ ទោះជាយ៉ាងនេះក្តី ការកើនឡើងនេះ មិនមានន័យថា ក្រុមហ៊ុនទាំងនោះមានសកម្មភាពផលិតកម្មនៅក្នុងឧស្សាហកម្មថ្មីៗដែលមិនធ្លាប់មានពីមុននោះឡើយ។ បន្ថែមលើនេះ ទោះបីរាជរដ្ឋាភិបាល តាមរយៈក្រសួង ស្ថាប័នពាក់ព័ន្ធបាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទាក់ទាញការវិនិយោគក្នុងសកម្មភាពឧស្សាហកម្មថ្មីក៏ដោយ ចំនួនផលិតផលនាំចេញថ្មីៗ ហាក់មានការកើនឡើងបន្តិចបន្តួចប៉ុណ្ណោះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ការវាយតម្លៃទៅលើការរៀបចំគោលនយោបាយបង្ហាញថា វិធានការគោលនយោបាយនីមួយៗមានគោលបំណងច្បាស់លាស់ក្នុងការទាក់ទាញការវិនិយោគ ប៉ុន្តែវិធានការទាំងនោះនៅមិនទាន់មានការកំណត់លក្ខណសម្បត្តិ និងវិសាលភាពគ្រប់គ្រាន់ សម្រាប់ជំរុញការទាក់ទាញវិនិយោគនៅក្នុងសកម្មភាពឧស្សាហកម្មថ្មីៗនៅឡើយ។ ជាក់ស្តែង គោលនយោបាយ IDP មិនបានកំណត់ជាក់លាក់ពីវិស័យ ឬអនុវិស័យអាទិភាព (លើកលែងតែឧស្សាហកម្មកែច្នៃកសិផលដែលត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងគោលនយោបាយ IDP) និងការលើកទឹកចិត្ត ដើម្បីទាក់ទាញការវិនិយោគក្នុងសកម្មភាពថ្មីៗទាំងនោះឡើយ។ លើសពីនេះ ការអនុវត្តវិធានការគោលនយោបាយនៅមានកម្រិតនៅឡើយ ដោយនៅក្នុងចំណោមវិធានការសរុបចំនួន ៤ មានតែវិធានការចំនួន ២ ប៉ុណ្ណោះ បានសម្រេចពេញលេញ ឯវិធានការចំនួន ២ ទៀត ជាវិធានការកំពុងអនុវត្ត និងវិធានការយឺតយ៉ាវ។ ក្នុងន័យនេះ គួរត្រូវមានការយកចិត្តទុកដាក់បន្ថែមទៅលើការរៀបចំគោលនយោបាយ ក៏ដូចជាការអនុវត្តវិធានការពាក់ព័ន្ធនានា ដើម្បីជំរុញការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ ដែលជាអន្តរាគមន៍គោលនយោបាយមួយដ៏សំខាន់ ចូលរួមចំណែកនៅក្នុងការសម្រេចបាននៃចក្ខុវិស័យរបស់ IDP។

### អន្តរាគមន៍គោលនយោបាយ “ពង្រីក និងធ្វើពិពិធកម្មទីផ្សារនិងផលិតផលនាំចេញ”

បន្ថែមលើការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ គោលនយោបាយ IDP ក៏បានសង្កត់ធ្ងន់ផងដែរទៅលើការពង្រីក និងធ្វើពិពិធកម្មការនាំចេញរបស់កម្ពុជា ដោយបង្កើនចំនួនទីផ្សារ និងផលិតផលនាំចេញ។ ការពង្រីករចនាសម្ព័ន្ធវិស័យនាំចេញ, ការធ្វើពិពិធកម្មឈានឆ្ពោះទៅការនាំចេញផលិតផលថ្មីៗដែលមានតម្លៃបន្ថែមខ្ពស់, និងការបន្តស្វែងរកទីផ្សារនាំចេញបន្ថែម នឹងរួមចំណែកជួយសេដ្ឋកិច្ចកម្ពុជាក្នុងការកាត់បន្ថយភាពងាយរងគ្រោះដែលបង្កដោយវិបត្តិខាងក្រៅដែលបង្កពីកត្តាខាងក្រៅ។

ការវាយតម្លៃការរៀបចំគោលនយោបាយបានបង្ហាញថា វិធានការក្រោមអន្តរាគមន៍គោលនយោបាយនេះ ផ្តោតសំខាន់ទៅលើការពង្រីក និងធ្វើពិពិធកម្មទីផ្សារនាំចេញច្រើនជាងការធ្វើពិពិធកម្មផលិតផលនាំចេញ។ ផ្ទុយមកវិញ ការធ្វើពិពិធកម្មផលិតផលនាំចេញមានវឌ្ឍនភាពល្អប្រសើរជាងការធ្វើពិពិធកម្មទីផ្សារនាំចេញ។ ជាក់ស្តែង ទោះបីជាចំនួនទីផ្សារនាំចេញ (ដែលទំហំនាំចេញខ្ពស់ជាង ១០លានដុល្លារអាមេរិក) បានកើនឡើងជារៀងរាល់ឆ្នាំក៏ដោយ ចំណែកនៃទីផ្សារនាំចេញធំៗទាំង៣ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុបបានកើនឡើងបន្តិចមកវិញនៅក្រោយឆ្នាំ២០១៥ ដែលកំណើននេះបង្ហាញពីនិន្នាការនៃការពឹងផ្អែកកាន់តែខ្លាំងរបស់កម្ពុជាទៅលើការនាំចេញទៅទីផ្សារមួយចំនួនតូច។ ដោយឡែក ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់ ៥ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយចំណែកនេះបានធ្លាក់ចុះក្នុងអត្រា ៥,១%ក្នុងមួយឆ្នាំ ក្រោយការដាក់ចេញគោលនយោបាយ IDP ពោលគឺលឿនជាងអត្រា ១,១% ក្នុងមួយឆ្នាំ នៅមុនឆ្នាំ២០១៥។ ការអនុវត្តវិធានការពាក់ព័ន្ធនឹងការពង្រីកនិងធ្វើពិពិធកម្មទីផ្សារនាំចេញ ហាក់មានវឌ្ឍនភាពប្រសើរជាងការអនុវត្តវិធានការពាក់ព័ន្ធនឹងការពង្រីកនិងធ្វើពិពិធកម្មផលិតផលនាំចេញ ដែលនៅក្នុងករណីនេះ គេពិបាកនឹងផ្សារភ្ជាប់វឌ្ឍនភាពនៃការធ្វើពិពិធ-កម្មផលិតផលនាំចេញដូចបានរៀបរាប់ខាងលើ ទៅនឹងការអនុវត្តវិធានការគោលនយោបាយដែលដាក់ចេញដោយ IDP បាននោះឡើយ។ ទោះជាយ៉ាងនេះក្តី ការពង្រឹងការអនុវត្តវិធានការគោលនយោបាយពាក់ព័ន្ធនឹងការពង្រីកមុខសញ្ញាផលិតផលនាំចេញក្នុងជំហានបន្ទាប់ នឹងអាចនាំមកនូវវឌ្ឍនភាពបន្ថែមទៀតនៅក្នុងការធ្វើពិពិធកម្មផលិតផលនាំចេញ។ ជាមួយគ្នានេះ ដើម្បីកាត់បន្ថយភាពប្រមូលផ្តុំខ្លាំងទៅលើទីផ្សារនាំចេញមួយចំនួនតូចនោះ ទាមទារឱ្យមានការជំរុញ និងយកចិត្តទុកដាក់ទៅលើការអនុវត្តសកម្មភាពជាក់លាក់ដែលពាក់ព័ន្ធនឹងការពង្រីកទីផ្សារនាំចេញ។

អន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូច និងមធ្យម"

ការធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូចនិងមធ្យម តាមរយៈការបង្កើនតួនាទីរបស់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងវិស័យផលិតកម្ម និងការកាត់បន្ថយការពឹងផ្អែកទៅលើសហគ្រាសធុនធំ ក៏ជាអន្តរាគមន៍គោលនយោបាយអាទិភាព ដែលគោលនយោបាយ IDP បានផ្តោតការយកចិត្តទុកដាក់ផងដែរ។ ដើម្បីវាយតម្លៃសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយនេះ សូចនាករដែលវាស់វែងពីចំណែកនៃការបង្កើតការងារដោយសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងការងារសរុបនៅក្នុងវិស័យឧស្សាហកម្ម ត្រូវបានប្រើប្រាស់ ប៉ុន្តែទិន្នន័យដែលអាចប្រើប្រាស់បានសម្រាប់សូចនាករនេះមានតែពីរឆ្នាំប៉ុណ្ណោះ។ តាមរយៈទិន្នន័យនេះ ចំណែកនៃការបង្កើតការងារដោយសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងការងារសរុបនៅក្នុងវិស័យឧស្សាហកម្ម បានកើនឡើងពី ២១,៨% នៅឆ្នាំ ២០១៨ ដល់ ៣៣,៥% នៅឆ្នាំ២០១៩។ ដោយសារកង្វះទិន្នន័យ ការធ្វើសេចក្តីសន្និដ្ឋានស៊ីជម្រៅណាមួយពីកំណើននេះមិនអាចធ្វើឡើងបានទេ។ បន្ថែមលើនេះ វិធានការគោលនយោបាយចំនួន ៣ ដែល IDP បានដាក់ចេញ នៅមានភាពខ្វះចន្លោះច្រើន ដែលនឹងមិនអាចផ្តល់បច្ច័យវិជ្ជមាន ដើម្បីជំរុញការសម្រេចបាននៃអន្តរាគមន៍គោលនយោបាយនេះឡើយ។ ក្នុងករណីនេះ វិធានការគោលនយោបាយជាក់លាក់បន្ថែមទៀតគួរត្រូវបានដាក់ចេញនាពេលអនាគត ដើម្បីជំរុញវឌ្ឍនភាពនៃការអនុវត្តអន្តរាគមន៍គោលនយោបាយនេះ។ ដូចគ្នានេះដែរ ការអនុវត្តវិធានការគោលនយោបាយនៅមានកម្រិតនៅឡើយ ដោយមានតែវិធានការចំនួន ១ ប៉ុណ្ណោះ ពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់សហគ្រាសធុនតូចនិងមធ្យម តាមរយៈការបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យម និងសាជីវកម្មធានាឥណទានកម្ពុជានៅត្រីមាសទី៤ ឆ្នាំ២០២០។ ដោយហេតុថាឧស្សាហកម្មកម្ពុជានៅបន្តពឹងផ្អែកខ្លាំងទៅលើ សហគ្រាសធុនធំមួយចំនួនតូច ការជំរុញការអនុវត្តវិធានការនៅក្នុងអន្តរាគមន៍គោលនយោបាយនេះជាកិច្ចការសំខាន់មិនអាចខ្វះបាន ដើម្បីជំរុញការសម្រេចបានដោយជោគជ័យនូវចក្ខុវិស័យនៃការប្រែក្លាយរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា។

អន្តរាគមន៍គោលនយោបាយ "បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម"

ការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម នឹងជួយជំរុញឱ្យកម្ពុជាបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ព្រមទាំងបោះជំហានឆ្ពោះទៅចាប់យកវិស័យឧស្សាហកម្ម សេវាកម្ម ឬសកម្មភាពសេដ្ឋកិច្ចថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់។ ការវាយតម្លៃបែបបរិមាណវិស័យបង្ហាញថា ចំនួនពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មសរុប បានកើនឡើងជាលំដាប់ ជាពិសេសក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ ប៉ុន្តែពាក្យស្នើសុំទាំងនោះភាគច្រើនត្រូវបានស្នើដោយអនិវាសជន។ ទោះបីជាមានការកើនឡើង

នូវចំនួនប្រកាសនីយបត្រតក្កកម្មដែលទទួលបានការអនុញ្ញាតនៅក្រោយឆ្នាំ២០១៥ក្តី ប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ជូននិវាសនជនកម្ពុជាមានចំនួនតែ ១ ប៉ុណ្ណោះ។ លទ្ធផលនេះអាចបណ្តាលមកពីកត្តាធំៗចំនួន២ រួមមាន (១) ការដាក់ពាក្យស្នើសុំមិនបានផ្តល់ឯកសារគ្រប់គ្រាន់ និងពុំបានបំពេញតាមលក្ខខណ្ឌតម្រូវ និង (២) កង្វះមន្ត្រីជំនាញគ្រប់គ្រាន់ សម្រាប់ពិនិត្យ និងវាយតម្លៃលើសំណើ។ ការវាយតម្លៃការរៀបចំគោលនយោបាយបង្ហាញថា វិធានការគោលនយោបាយទាំង១៦ ដែលគោលនយោបាយ IDP បានដាក់ចេញ អាចមានបច្ច័យតែទៅលើការជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍មូលដ្ឋានប៉ុណ្ណោះ ដែលមិនគ្រប់គ្រាន់សម្រាប់ជំរុញសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងរយៈពេលខ្លីណាមួយបាននោះទេ។ បន្ថែមលើនេះ ការអនុវត្តវិធានការគោលនយោបាយពាក់ព័ន្ធមានការយឺតយ៉ាវដោយមានតែវិធានការចំនួន ៤ ប៉ុណ្ណោះ បានសម្រេចពេញលេញ។ ក្នុងករណីនេះ ការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្មគួរត្រូវទទួលបានការយកចិត្តទុកដាក់បន្ថែម ដោយបច្ច័យនៃអន្តរាគមន៍គោលនយោបាយនេះ នឹងរួមចំណែកយ៉ាងសំខាន់នៅក្នុងការលើកកម្ពស់ភាពប្រកួតប្រជែងវិស័យឧស្សាហកម្មកម្ពុជា ក៏ដូចជាជំរុញ និងប្រែក្លាយរចនាសម្ព័ន្ធឧស្សាហកម្មនាពេលអនាគត។ ទោះបីជាយ៉ាងនេះក្តី ការដាក់ចេញនូវវិធានការគោលនយោបាយថ្មីណាមួយដើម្បីគាំទ្រអន្តរាគមន៍គោលនយោបាយនេះ ទំនងជាមិនអាចនាំមកនូវបច្ច័យវិជ្ជមានក្នុងរយៈពេលខ្លី ដើម្បីជំរុញការសម្រេចបាននូវគោលដៅរបស់គោលនយោបាយ IDP នៅត្រឹមឆ្នាំ២០២៥ បាននោះឡើយ ដោយជាទូទៅវិធានការពាក់ព័ន្ធនឹងការបង្កើននវានុវត្តន៍ ទាមទារពេលវេលាច្រើនក្នុងការអនុវត្ត មុននឹងអាចទទួលបាននូវលទ្ធផលតាមការរំពឹងទុក។

**អន្តរាគមន៍គោលនយោបាយ "ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម"**

ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម ក៏ជាបុរេលក្ខខណ្ឌដ៏សំខាន់មួយសម្រាប់ជំរុញការធ្វើពិពិធកម្ម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច។ គោលបំណងសំខាន់នៃអន្តរាគមន៍គោលនយោបាយនេះ គឺលើកកម្ពស់ការចុះបញ្ជីផ្លូវការរបស់សហគ្រាសធុនតូចនិងមធ្យម ដូចបានកំណត់ក្នុង IDP។

ការវាយតម្លៃបង្ហាញថា អត្រាចុះបញ្ជីសហគ្រាសធុនមធ្យម មាន ៨៧% នៅឆ្នាំ២០១៩ ដែលតួលេខនេះបានសម្រេចគោលដៅឆ្នាំ២០២០ (៨០%) រួចទៅហើយ ប៉ុន្តែអត្រាចុះបញ្ជីសហគ្រាសធុនតូចមានត្រឹម ៤៩,៧% នៅឆ្នាំ២០១៩ ដែលស្ថិតនៅឆ្ងាយពីគោលដៅឆ្នាំ២០២០ (៧០%)។ ដោយឡែក អត្រាសហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ នៅឆ្នាំ២០២០ មាន ៣៩% និងអត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យសាមញ្ញ នៅឆ្នាំ២០២០ មាន ១៩% ដែលអត្រាទាំង២នេះ មិនអាចសម្រេចតាមគោលដៅឆ្នាំ២០២០ (៥០% និង៣០% រៀងគ្នា) ឡើយ។ ផ្អែកលើទិន្នន័យនេះ យើងអាចសន្និដ្ឋានបានថា សហគ្រាសធុនតូចនៅតែមានការលំបាកក្នុងការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ បើទោះបីជារាជរដ្ឋាភិបាលបានខិតខំជំរុញនិងដាក់ចេញនូវបញ្ជីគណនេយ្យសាមញ្ញសម្រាប់អាជីវកម្មខ្នាតតូចនៅចុងឆ្នាំ២០១៥ ក៏ដោយ។ ស្ថានភាពនេះអាចកើតឡើង ដោយសារសហគ្រាសធុនតូចទាំងនោះនៅមិនទាន់ទទួលបានព័ត៌មានគ្រប់គ្រាន់អំពីអត្ថប្រយោជន៍នៃការចុះបញ្ជីផ្លូវការ សមត្ថភាពក្នុងការគ្រប់គ្រងអាជីវកម្មនៅមានកម្រិត ឬដោយសារមានការរារែកចិត្តចំពោះកាតព្វកិច្ចសារពើពន្ធដែលកើតចេញពីការចុះបញ្ជី។

ការវាយតម្លៃលើការរៀបចំគោលនយោបាយបង្ហាញថា វិធានការគោលនយោបាយទាំង៩ មានភាពប្រទាក់ក្រឡាគ្នា ដែលឆ្លើយតបនឹងគោលដៅនៃអន្តរាគមន៍គោលនយោបាយនេះ ប៉ុន្តែគ្មានវិធានការណាមួយបានរំលេចពីកញ្ចប់នៃការលើកទឹកចិត្តជាក់លាក់ ដើម្បីជំរុញការចុះបញ្ជីផ្លូវការរបស់សហគ្រាសធុនតូច និងមធ្យម ក៏ដូចជាការបង្កើតភ្នាក់ងារឯកទេស ដើម្បីផ្តល់ការគាំទ្របច្ចេកទេសជាក់លាក់សម្រាប់សហគ្រាសទាំងនោះឡើយ។ អត្រាចុះបញ្ជីរបស់សហគ្រាសធុនតូចនិងមធ្យម ដែលស្ថិតនៅក្នុងកម្រិតទាបបែបនេះ អាចជាលទ្ធផលនៃភាពយឺតយ៉ាវក្នុងការអនុវត្តវិធានការគោលនយោបាយមួយចំនួន។ ក្នុងចំណោមវិធានការគោលនយោបាយសរុបចំនួន ៩ មានតែវិធានការចំនួន ២ ប៉ុណ្ណោះត្រូវបានអនុវត្តសម្រេចពេញលេញ គឺវិធានការដែលទាក់ទងនឹងការធ្វើវិសោធនកម្មច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ នៅឆ្នាំ២០១៦ និងការដាក់ឱ្យប្រើប្រាស់បញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូចនិងមធ្យមនៅឆ្នាំ២០១៥ ដែលវឌ្ឍនភាពដ៏តិចតួចនេះបង្ហាញថា ការផ្តល់ការគាំទ្រដល់សហគ្រាស ជាពិសេសសហគ្រាសធុនតូច គួរត្រូវបានចាត់ទុកជាការងារអាទិភាព។ ទន្ទឹមនឹងនេះ ការអនុវត្តវិធានការគោលនយោបាយទាំងនោះ ក៏អាស្រ័យផងដែរទៅលើការអនុវត្តវិធានការក្រោមអន្តរាគមន៍គោលនយោបាយ "ការធ្វើឱ្យមានតុល្យភាព

ភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូច និងមធ្យម" ដែលការអនុវត្តនៅមានកម្រិតនៅឡើយ ដូចបានរៀបរាប់ខាងលើ។

### ៣.៨.៣.លទ្ធផលគន្លឹះ និងបច្ច័យសម្រាប់ការអនុវត្តបន្ត

សរុបសេចក្ដីមក លទ្ធផលនៃការពង្រឹងភាពធន់ និងធ្វើពិពិធកម្មសេដ្ឋកិច្ច ត្រូវបានវាយតម្លៃថា សម្រេចបានដោយផ្នែក។ ជាក់ស្ដែង ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង ធៀបនឹងការនាំចេញសរុប សម្រេចបានកំណើនគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងនេះ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់ ៥ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្ត-សាលសរុប បានបន្តធ្លាក់ចុះជារៀងរាល់ឆ្នាំ ដែលបង្ហាញពីវឌ្ឍនភាពនៃពិពិធកម្មក្នុងវិស័យនាំចេញ។ ទោះជាយ៉ាងនេះក្ដី ដំណើរការនៃការធ្វើពិពិធកម្មផលិតកម្ម ហាក់ដូចជាមានល្បឿនយឺត តួយ៉ាងមូលដ្ឋានផលិតកម្មនៅកម្ពុជានៅតែមានសភាពប្រមូលផ្ដុំជុំវិញអនុវិស័យកម្មន្តសាលមួយចំនួន ដូចជា តម្បាញ សម្លៀកបំពាក់និងស្បែកជើង, ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, និងឈើ ក្រដាស និងបោះពុម្ព។ លើសពីនេះ ការនាំចេញផលិតផលកម្មន្តសាល នៅតែពឹងផ្អែកលើទីផ្សារធំៗមួយចំនួនដដែល។

ការវាយតម្លៃលើការរៀបចំ និងការអនុវត្តវិធានការគោលនយោបាយ បានបង្ហាញពីភាពខ្វះចន្លោះនៃវិធានការគោលនយោបាយ ក៏ដូចជាភាពយឺតយ៉ាវក្នុងការអនុវត្ត ដោយវិធានការសម្រេចពេញលេញមានត្រឹមតែ ៣៨% ប៉ុណ្ណោះ។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ យើងសង្កេតឃើញថា ពិពិធកម្មសេដ្ឋកិច្ចកម្ពុជានៅមានកម្រិតនៅឡើយ ហើយវឌ្ឍនភាពនៃការធ្វើពិពិធកម្មនោះទៀតសោត នៅមានភាពយឺតយ៉ាវ។

ការជំរុញពិពិធកម្ម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពីគ្រប់តួអង្គពាក់ព័ន្ធ។ អាទិភាពមួយ ក្នុងចំណោមអាទិភាពជាច្រើននោះគឺ ការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ តាមរយៈការបង្កើតយុទ្ធសាស្ត្រជំរុញការទាក់ទាញវិនិយោគចំគោលដៅ, ការកំណត់ប្រភពនៃការវិនិយោគផ្ទាល់ពីបរទេសដែលមានសក្ដានុពល, ការផ្ដល់ការលើកទឹកចិត្តនិងការគាំទ្រជាក់លាក់ដល់ការវិនិយោគដែលមានសក្ដានុពល, ព្រមទាំងការដាក់ចេញនូវផែនការសកម្មភាពច្បាស់លាស់សម្រាប់អនុវត្តយុទ្ធសាស្ត្រអាទិភាពទាំងនេះ។ យុទ្ធសាស្ត្រផ្សេងៗទៀត ដែលអាចនឹងជំរុញវឌ្ឍនភាពនៃគោល-បំណងគោលនយោបាយនេះរួមមាន ការលើកកម្ពស់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការអភិវឌ្ឍជំនាញ ដើម្បីបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម ជាពិសេស ឧស្សាហកម្មធុនតូច និងមធ្យម រួមផ្សំនឹងការជំរុញការចរចាពាណិជ្ជកម្ម ដើម្បីបើកទីផ្សារបន្ថែមទៀតសម្រាប់ផលិតផលកម្ពុជា ខណៈពេលដែលកម្ពុជាកំពុងបាត់បង់បន្តិចម្ដងៗនូវភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម។ បន្ថែមលើនេះ គួរមានការពង្រឹងបន្ថែមទៀតផងដែរ នូវការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម ជាពិសេសចំពោះសហគ្រាស

ធុនតូច ដែលមិនបានចុះបញ្ជីផ្លូវការឱ្យធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងជំរុញការកសាងអភិបាលកិច្ចសាជីវកម្ម ក្នុងទិសដៅបង្កើនតួនាទីរបស់សហគ្រាសទាំងនោះ នៅក្នុងសេដ្ឋកិច្ចកម្ពុជា។

ការធ្វើពិពិធកម្ម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច ដើរតួយ៉ាងសំខាន់នៅក្នុងការសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្មទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ ដូចបានកំណត់ក្នុងគោលនយោបាយ IDP ហើយដើម្បីទទួលបានជោគជ័យក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយទី៣ ទាមទារឱ្យមានការគិតគូរឡើងវិញនូវការរៀបចំរិធានការគោលនយោបាយ ដែលគាំទ្រដល់អន្តរាគមន៍គោលនយោបាយក្រោមគោលបំណងនេះ។

# ៣.៨. សមិទ្ធកម្មគោលបំណងទី៨ “ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ”

# ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

## ៣.៩. សមិទ្ធកម្មគោលបំណងទី៩ “ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ”

### ៣.៩.១. ការវាយតម្លៃសមិទ្ធកម្មគោលបំណងទី៩

ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ តាមរយៈការលើកកម្ពស់លក្ខខណ្ឌការងារ ការពង្រឹងលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ និងការបង្កើនឱកាសការងារសមរម្យនិងផលិតភាពការងារខ្ពស់ ជាកត្តាមួយដ៏សំខាន់ចូលរួមចំណែកក្នុងការប្រែក្លាយវិស័យឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញ ស្របតាមចក្ខុវិស័យរបស់គោលនយោបាយ IDP។ បន្ថែមលើនេះ ការពង្រឹងគុណភាពការងារនឹងរួមចំណែកដល់ការកាត់បន្ថយវិសមភាព និងការបង្កើនសិនិទ្ធភាពសង្គម។ សូចនាករចំនួន២ត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃពីវឌ្ឍនភាពនៃអន្តរាគមន៍គោលនយោបាយនេះ ដោយវាស់វែងពីទិដ្ឋភាពផ្សេងគ្នានៃការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ។ សូចនាករទី១ “ចំនួនការងារនៅក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ” វាស់វែងពីវឌ្ឍនភាពនៃការបង្កើតការងារនៅក្នុងវិស័យកម្មន្តសាលក្រៅពីកាត់ដេរ ដែលត្រូវបានចាត់ទុកថាជាវិស័យដែលផ្តល់នូវលក្ខខណ្ឌការងារល្អប្រសើរជាងការងារក្នុងវិស័យកម្មន្តសាលកាត់ដេរ។ រីឯសូចនាករទី២ “ចំនួនការងារវិស័យឧស្សាហកម្ម និងចំណែកការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុប” វាស់វែងពីការរួមចំណែកនៃវិស័យឧស្សាហកម្មនៅក្នុងការបង្កើតការងារ ដោយផ្អែកតាមការសន្មតថា ការកើនឡើងនៃចំនួនការងារនៅក្នុងវិស័យឧស្សាហកម្ម នឹងធ្វើឱ្យគុណភាពការងារជាទូទៅមានភាពកាន់តែប្រសើរឡើង។

រូបភាពទី១០៖ ចំនួនការងារក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ (អាយុ១៥ឆ្នាំឡើង)




ប្រភពទិន្នន័យ៖ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើទិន្នន័យរបស់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១០ ដល់ ឆ្នាំ២០១៩/២០២០

**សម្គាល់៖** សម្រាប់ឆ្នាំ២០១៨ មិនមានការធ្វើអង្កេត និងសម្រាប់ឆ្នាំ២០២០ ការប្រមូលទិន្នន័យបានធ្វើឡើងក្នុងឆមាសទី២ឆ្នាំ២០១៩ និងឆមាសទី១ឆ្នាំ២០២០

រូបភាពទី១១៖ ចំណែកការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុប (អាយុ១៥ឆ្នាំឡើង)




ប្រភពទិន្នន័យ៖ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើទិន្នន័យរបស់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១០ ដល់ ឆ្នាំ២០១៩/២០២០

**សម្គាល់៖** សម្រាប់ឆ្នាំ២០១៨ មិនមានការធ្វើអង្កេត និងសម្រាប់ឆ្នាំ២០២០ ការប្រមូលទិន្នន័យបានធ្វើឡើងក្នុងឆមាសទី២ ឆ្នាំ២០១៩ និងឆមាសទី១ឆ្នាំ២០២០

ចំនួនការងារក្នុងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរបានកើនឡើងពីចំនួន ៣៤៧.០០០ នៅឆ្នាំ២០១០ ដល់ ៤៨៧.០០០ នៅឆ្នាំ២០២០ ខណៈចំនួនការងារនៅក្នុងវិស័យឧស្សាហកម្មបានកើនឡើងពីចំនួនប្រមាណ ១,៣លាននាក់ ទៅដល់ ២,៣លាននាក់ ដែលកើនឡើងប្រមាណជិត២ដងក្នុងរយៈពេលដូចគ្នា ដែលការណ៍នេះបង្ហាញពីការវិវឌ្ឍជាវិជ្ជមាន (រូបភាពទី១០ និង១១)។ ជាមួយគ្នានេះ ចំណែកការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុបក៏បានកើនឡើង បន្ទាប់ពីការដាក់ចេញគោលនយោបាយ IDP នៅឆ្នាំ២០១៥ ប៉ុន្តែការកើនឡើងនេះមានការធ្លាក់ចុះមកវិញនៅក្នុងឆ្នាំ២០២០ ដោយសារការកាត់ផ្តាច់ខ្សែប្រវាក់ផ្គត់ផ្គង់វត្ថុធាតុដើម និងការធ្លាក់ចុះនៃតម្រូវការខាងក្រៅ ជាពិសេសផលិតផលវាយនភណ្ឌកាត់ដេរ

ស្បែកជើង សម្ភារៈធ្វើដំណើរនិងកាបូប (រូបភាពទី១១) ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩។

### ៣.៥.២. ការវាយតម្លៃអន្តរាគមន៍គោលនយោបាយក្នុងគោលបំណងទី៥

ដើម្បីគាំទ្រការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ គោលនយោបាយ IDP ដាក់ចេញនូវវិធានការចំនួន ៣១ ក្រោមអន្តរាគមន៍គោលនយោបាយចម្បងចំនួន៥ រួមមាន៖ (១) ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស (២) បង្កើនតម្រូវការពលកម្មជំនាញ (៣) ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ (៤) លើកកម្ពស់ការផ្គូផ្គងការងារ និង (៥) ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ។ ខ្លឹមសារសង្ខេបពីការរួមចំណែករបស់អន្តរាគមន៍គោលនយោបាយចម្បងទាំងនេះ ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ មានរៀបរាប់នៅក្នុងតារាងទី៤ ខាងក្រោម។ បន្ថែមលើនេះ បច្ច័យនៃគោលបំណងទី៥នេះ ក៏ត្រូវបានបំពេញបន្ថែមដោយលទ្ធផលនៃការអនុវត្តវិធានការនានា នៅក្រោមអន្តរាគមន៍គោលនយោបាយចំនួន ២ ផ្សេងទៀត គឺ (១) បង្កើនផលិតភាពពលកម្មរបស់សហគ្រាស និង (២) បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស។

## តារាងទី៨៖ សង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គ.ប.ទី៨

| អន្តរាគមន៍គោលនយោបាយ | សមិទ្ធកម្ម | ការរៀបចំគោលនយោបាយ | ការអនុវត្ត |
|---|---|---|---|
| ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស | • ចំណែកនៃការចុះឈ្មោះចូលរៀនមធ្យមសិក្សា និងឧត្តមសិក្សាក្នុងចំនួនប្រជាជនសរុប ស្ថិតនៅទ្រឹងក្នុងរង្វង់ ២០% ចាប់តាំងពីឆ្នាំសិក្សា ២០០៧-២០០៨មក ប៉ុន្តែបានកើនឡើង ក្នុងរង្វង់ ០,៧% ក្នុងមួយឆ្នាំ ក្នុងអំឡុងពេលនៃការអនុវត្ត IDP (២០១៥-២០១៩)។<br>• អត្រាសិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់មធ្យមសិក្សាបានកើនឡើងបន្តិចពី ១៩,៤% នៅឆ្នាំ២០១៥ ទៅ ២៤,២៥% នៅឆ្នាំ២០១៩ ខណៈដែលអត្រាសិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) មាននិន្នាការប្រែប្រួលប្រហាក់ប្រហែលគ្នានឹងអត្រាសិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់មធ្យមសិក្សា គឺមានកំណើនពី១៧,៣% នៅឆ្នាំ២០១៥ ទៅដល់២៣,៥% នៅឆ្នាំ២០១៨។<br>• ចំនួនសិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បណ្ដុះបណ្ដាល បច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដោយមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១, ២ និង ៣ ( C1 C2 ឬ C3) បានកើនឡើងប្រមាណ១២%ក្នុងមួយឆ្នាំ ពី ១.១០០នាក់ | • វិធានការគោលនយោបាយភាគច្រើនផ្ដោតទៅលើការធ្វើឱ្យប្រសើរឡើងនូវជំនាញបច្ចេកទេស វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងជំនាញទន់ផ្សេងទៀត។<br>• ចំនួនវិធានការគោលនយោបាយនៅមិនទាន់គ្រប់គ្រាន់ ដែលតម្រូវឱ្យមានការដាក់ចេញនូវវិធានការបន្ថែមទៀត ដើម្បីបង្កើនលទ្ធភាពនៃការសម្រេចបាននូវលទ្ធផលរំពឹងទុក។<br>• ការរៀបចំគោលនយោបាយមានភាពច្បាស់លាស់ ដោយក្នុងនោះវិធានការគោលនយោបាយចំនួន ១៥ ជាវិធានការ | វិធានការគោលនយោបាយទាំង ១៦ និងអនុវិធានការចំនួន ១ បានសម្រេចពេញលេញ។ |

| | | | |
|---|---|---|---|
| | នៅឆ្នាំ២០០៨ ទៅដល់ចំនួន ២.៤០០នាក់ នៅឆ្នាំ២០១៥ និងដល់ចំនួន ៦.៣៩៨នាក់ នៅឆ្នាំ២០១៩។ | ច្បាស់លាស់ និងវិធានការចំនួន ១ ជាសកម្មភាពត្រៀម។ | |
| បង្កើនតម្រូវការពលកម្មជំនាញ | • ព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្ម ដែលបានប្រមូលនិងផ្សព្វផ្សាយបានកើនឡើងពី ១០.៣៣១ នៅឆ្នាំ ២០១០ ដល់ ៣៥.០៥៩ នៅឆ្នាំ២០១៥ និង១០១.៧០៩ នៅឆ្នាំ២០១៩។<br>• ចំនួនកម្មករជំនាញបានកើនឡើងពី ៣.៣៣០ នៅឆ្នាំ ២០០៨ ដល់ ៤.០៩៤ នៅឆ្នាំ២០១៥ និង ១០.១៧៩ នៅឆ្នាំ២០១៩។ | មិនមានវិធានការគោលនយោបាយជាក់លាក់ត្រូវបានដាក់ចេញដោយ IDP។ | មិនមានវិធានការ គោលនយោបាយជាក់លាក់ត្រូវបានដាក់ចេញដោយ IDP។ |
| ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ | • ប្រាក់ឈ្នួលអប្បបរមាសម្រាប់និយោជិត ក្នុងវិស័យកាត់ដេរ និងផលិតស្បែកជើង ត្រូវបានដំឡើងជាបន្តបន្ទាប់ពី ៤៥ ដុល្លារអាមេរិក នៅឆ្នាំ២០០៥ ទៅដល់ ១២៨ដុល្លារអាមេរិក នៅឆ្នាំ២០១៥ និងកើនដល់ ១៩០ដុល្លារអាមេរិក នៅឆ្នាំ២០២០។<br>• អត្រានៃភាពជោគជ័យក្នុងការដោះស្រាយវិវាទការងារធំៗ បានកើនឡើងពី ៧៤,៦% នៅឆ្នាំ២០១៤ ដល់ ៨១,៥% នៅឆ្នាំ២០១៩។ | • ផ្តោតសំខាន់ទៅលើសុខុដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈយន្តការត្រីភាគី (រាជរដ្ឋាភិបាល សហជីព និងនិយោជក)។<br>• វិធានការគោលនយោបាយ បាននាំមកនូវបច្ច័យវិជ្ជមានមួយចំនួនដល់ការសម្រេចបាននៃអន្តរាគមន៍គោលនយោបាយ ដោយសារការរៀបចំគោលនយោបាយភាគច្រើនមានភាពច្បាស់លាស់ ដោយ | ក្នុងចំណោមវិធានការគោលនយោបាយទាំង៦ មានវិធានការចំនួន ៣ ជាវិធានការសម្រេចពេញលេញ និងវិធានការចំនួន ១ ជាវិធានការយឺតយ៉ាវ។ |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| | | មានតែវិធានការចំនួន ១ ប៉ុណ្ណោះជាសកម្មភាពបម្រុង។ | |
| លើកកម្ពស់ការផ្គូផ្គងការងារ | • អត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះនឹងបញ្ហាគម្លាតជំនាញបានធ្លាក់ចុះពី ៥៤,៥%នៅឆ្នាំ២០១២ ទៅ ៣៩,៤% នៅឆ្នាំ២០១៥ និង ២៨,៩% នៅឆ្នាំ២០១៩។<br>• ចំណែកនៃសហគ្រាសរាយការណ៍ដែលមានស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ក្នុងចំនួនហគ្រាសសរុបដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្មយ៉ាងតិចមួយ បានធ្លាក់ចុះពី ៧៥% នៅឆ្នាំ ២០១២ មកត្រឹម៤៨,៤% នៅឆ្នាំ២០១៥ ប៉ុន្តែបានកើនឡើងដល់ ៥៨,៤% នៅឆ្នាំ២០១៩។ | • ផ្តោតលើការផ្គូផ្គងការងារឱ្យកាន់តែប្រសើរ និងការកាត់បន្ថយកម្រៃសេវាក្រៅផ្លូវការ ម្រាប់ការទទួលបានការងារ ការពង្រឹងយន្តការ គ្រប់គ្រងពលកម្មជំនាញក្នុងស្រុក និងការប្រមូលនិងផ្សព្វផ្សាយដំណឹងជ្រើសរើសកម្លាំងពលកម្ម។<br>• ចំនួនវិធានការគោលនយោបាយមានតិច ដែលប្រហែលជានឹងមិនអាចនាំមកនូវលទ្ធផលរំពឹងទុក ដោយវិធានការចំនួន២ មានភាពច្បាស់លាស់ និងវិធានការចំនួន១ មានភាពមិនច្បាស់លាស់។ | វិធានការ និងអនុវិធានការសរុបចំនួន ៤ បានសម្រេចពេញលេញរួចរាល់។ |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ | • អត្រាសហគ្រាស គ្រឹះស្ថានដែលមានសេវាសង្គ្រោះអប្បបរមាបានកើនឡើង ពី ៦៣,៨% នៅឆ្នាំ២០១២ ដល់ ៦៦,៤% នៅឆ្នាំ២០១៥ និង៨២,៦%នៅឆ្នាំ២០១៩។<br>• ចំនួនកម្មករដែលទទួលបានបណ្ណ សមាជិក ប.ស.ស. មានប្រមាណ ១,២លាននាក់ នៅឆ្នាំ២០១៧ និងបានកើនឡើងដល់ ១,៧លាននាក់ នៅឆ្នាំ២០១៩។ | • ការរៀបចំគោលនយោបាយផ្តោតលើការលើកកម្ពស់លក្ខខណ្ឌការងារ និងសុខុមាលភាពប ' កម្មករ។<br>• ការរៀបចំគោលនយោបាយមានភាពច្បាស់លាស់ ហើយចំនួនវិធានការគោលនយោបាយមានគ្រប់គ្រាន់ សម្រាប់ការសម្រេចបាននូវការផ្លាស់ប្តូរតាមការរំពឹងទុក។ | ក្នុងចំណោមវិធានការគោលនយោបាយ និងអនុវិធានការចំនួន ៦ មានវិធានការចំនួន ៣ សម្រេចបានពេញលេញ, វិធានការចំនួន ២ ជាវិធានការកំពុងអនុវត្ត និងវិធានការចំនួន ១ មិនមានទិន្នន័យ។ |

**កំណត់សម្គាល់៖** សម្រាប់ការវិភាគលម្អិតលើអន្តរាគមន៍គោលនយោបាយចម្បងទាំង៤ (ការវាយតម្លៃសមិទ្ធកម្មបែបបរិមាណវិស័យ ការរៀបចំគោលនយោបាយ និងការអនុវត្តគោលនយោបាយ) សូមមើលឧបសម្ព័ន្ធទី១។

### អន្តរាគមន៍គោលនយោបាយ “ធ្វើឱ្យប្រសើរឡើងនូវជំនាញ និងការអភិវឌ្ឍធនធានមនុស្ស”

សារៈសំខាន់នៃការធ្វើឱ្យប្រសើរឡើងនូវជំនាញ និងការអភិវឌ្ឍធនធានមនុស្ស នៅក្នុងគោលបំណងនេះ បានស្តែងចេញតាមរយៈចំនួនដ៏ច្រើននៃវិធានការ ដែលមានសរុបចំនួន១៦។ ទោះជាយ៉ាងណាក្តី លទ្ធផលនៃអន្តរាគមន៍គោលនយោបាយនេះ នឹងត្រូវបំពេញបន្ថែមដោយការអនុវត្តវិធានការគោលនយោបាយផ្សេងទៀតក្រោមអន្តរាគមន៍គោលនយោបាយដទៃ ដូចជាអន្តរាគមន៍គោលនយោបាយពាក់ព័ន្ធនឹងការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម និងកម្រិតបច្ចេកវិទ្យារបស់សហគ្រាស។ សូចនាករចំនួន៥ ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយនេះ ដែលសូចនាករទាំងនោះវាស់វែងផ្នែកផ្សេងៗនៃការអភិវឌ្ឍជំនាញ និងធនធានមនុស្ស ដែលរួមមានការអប់រំចំណេះទូទៅ ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ពាក់ព័ន្ធនឹងការជំរុញការអប់រំចំណេះទូទៅ គេសង្កេតឃើញមានវឌ្ឍនភាពគួរជាទីគាប់ប្រសើរក្នុងការបង្កើនចំនួនកម្លាំងពលកម្មវ័យក្មេងប្រកបដោយចំណេះដឹង និងជំនាញបច្ចេកវិទ្យាវិទ្យាសាស្ត្រ នៅក្នុងទីផ្សារការងារ។ ការវាយតម្លៃបែបបរិមាណវិស័យបង្ហាញថា ចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សា និងឧត្តមសិក្សាក្នុងចំនួនប្រជាជនគ្រប់អាយុចូលរៀន បានកើនឡើងបន្តិចក្នុងអត្រា ០,៧% ក្នុងមួយឆ្នាំ ក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP (២០១៥-២០១៩) ទោះបីជាតួលេខសូចនាករនេះហាក់នៅទ្រឹងក្នុងរង្វង់ ២០% ទៅ ២២% ចាប់តាំងពីឆ្នាំសិក្សា២០០៧-២០០៨មក។ ទន្ទឹមនឹងនេះ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិបានកើនឡើងពី ១៩,៤% ក្នុងឆ្នាំសិក្សា២០១៥-២០១៦ ដល់ ២៤,២៥% ក្នុងឆ្នាំសិក្សា២០១៩-២០២០ ខណៈអត្រានៃនិស្សិតបញ្ចប់ការសិក្សាផ្នែក STEM មានកំណើនវិជ្ជមានផងដែរ ដោយបានកើនឡើងពី ១៧,៣% ក្នុងឆ្នាំសិក្សា២០១៥-២០១៦ ដល់ ២៣,៥% ក្នុងឆ្នាំសិក្សា២០១៨-២០១៩។ ផ្អែកតាមទិន្នន័យ គេសង្កេតឃើញថាក្នុងអំឡុងពេលអនុវត្ត IDP សូចនាករទាំង៣នេះ មានសមិទ្ធកម្មល្អ ដែលឆ្លុះបញ្ចាំងតាមរយៈអត្រាកំណើនវិជ្ជមាន បើធៀបនឹងកំណើនអវិជ្ជមានមុនការដាក់ចេញគោលនយោបាយ IDP។ សមិទ្ធកម្មនេះអាចជាលទ្ធផលនៃការរៀបចំ និងការអនុវត្តគោលនយោបាយបានល្អប្រសើរ។ ចំពោះការរៀបចំគោលនយោបាយ យើងសង្កេតឃើញថា គោលនយោបាយ IDP បានដាក់ចេញនូវវិធានការប្រទាក់ក្រឡាគ្នា ក្នុងការជំរុញការអប់រំចំណេះទូទៅ ដែលក្នុងនោះរួមមាន ការលើកកម្ពស់លទ្ធភាពក្នុងការទទួលបានការអប់រំ គុណភាពនៃការអប់រំ ក៏ដូចជាការរៀបចំកម្មវិធីសិក្សា។ សម្រាប់ការអនុវត្តវិធានការទាំងអស់ដែលទាក់ទងនឹងការជំរុញការអប់រំចំណេះទូទៅ គឺសម្រេចបានពេញលេញ។ ជាក់ស្តែង គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនធំបានទទួលនូវការទទួលស្គាល់គុណភាព ខណៈពេលដែលវគ្គបណ្តុះបណ្តាល និងវគ្គសិក្សាបំពេញបន្ថែមមួយចំនួនត្រូវបានពិនិត្យឡើងវិញ និងរៀបចំកំណត់ជាអាទិភាព។ លើសពីនេះ ឯកសារគោលនយោបាយត្រូវបានរៀបចំឡើង ដើម្បី

តម្រង់ទិសការជំរុញការអប់រំចំណេះទូទៅ ខណៈពេលដែលប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃក៏ត្រូវបានរៀបចំឡើង ដើម្បីវាយតម្លៃស្តង់ដារនៃការអប់រំ។

វឌ្ឍនភាពល្អប្រសើរនេះ ក៏ត្រូវបានសង្កេតឃើញផងដែរនៅក្នុងការលើកកម្ពស់ការអប់រំបណ្តុះ-បណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ដែលមានការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនពលករជំនាញនៅក្នុងទីផ្សារការងារ។ ចំនួនសិស្ស និស្សិតបញ្ចប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP។ ជាក់ស្តែង ចំនួនសិស្សបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដោយមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១, ២ និង ៣ ( C1, C2 និង C3) បានកើនឡើងពីចំនួន ១.១០០នាក់ នៅឆ្នាំ២០០៨ ទៅដល់ចំនួន ២.៤០០នាក់ នៅឆ្នាំ២០១៥ និងដល់ចំនួន ៦.៣៩៨នាក់ នៅឆ្នាំ២០១៩ ខណៈចំនួនសិស្សនិស្សិតបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដោយមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស/បរិញ្ញាបត្ររង បានកើនឡើងក្នុងកម្រិតមួយខ្ពស់ពី ២.៥៦៥នាក់ នៅឆ្នាំ២០១៥ ទៅដល់ ៥.៨៨៤នាក់ នៅឆ្នាំ២០១៩។ ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនសិស្ស និស្សិតបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) អាចនឹងជួយសម្រួលដល់ក្រុមហ៊ុនក្នុងការស្វែងរកអ្នកបច្ចេកទេសដែលមានគុណវុឌ្ឍិ សម្រាប់រយៈពេលខ្លីខាងមុខ។ វឌ្ឍនភាពដ៏ល្អប្រសើរនេះ អាចជាលទ្ធផលនៃការដាក់ចេញនូវវិធានការគោលនយោបាយច្បាស់លាស់ជាច្រើន ដើម្បីជំរុញការអប់រំវិជ្ជាជីវៈ តាមរយៈការពង្រឹងលទ្ធភាពនៃការទទួលបានការបណ្តុះបណ្តាល ការពង្រឹងគុណភាពសិក្សា និងការរៀបចំកម្មវិធីសិក្សា។ នៅក្នុងការអនុវត្តគោលនយោបាយ វិធានការទាំងអស់ដែលពាក់ព័ន្ធនឹងការជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានសម្រេចពេញលេញ។

### អន្តរាគមន៍គោលនយោបាយ "បង្កើនតម្រូវការពលកម្មជំនាញ"

ដើម្បីរួមចំណែកក្នុងការបង្កើនគុណភាពការងារ គោលនយោបាយ IDP បានផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនតម្រូវការពលកម្មជំនាញ តាមរយៈការបង្កើនឱកាសការងារសម្រាប់កម្មករជំនាញក្នុងស្រុក នៅក្នុងវិស័យកម្មន្តសាលដែលប្រើប្រាស់បច្ចេកវិទ្យាខ្ពស់។ ដោយមិនមានទិន្នន័យចំនួនមុខតំណែង ដែលត្រូវការបុគ្គលិកជំនាញ ទិន្នន័យអំពីចំនួននៃការប្រកាសជ្រើសរើសកម្លាំងពលកម្មជំនាញ (មិនរាប់បញ្ចូលប្រកាសជ្រើសរើសកម្លាំងពលកម្មសម្រាប់ប្រភេទមុខរបរដែលមិនទាមទារឱ្យមានជំនាញ - elementary occupations) និងកំណើនចំនួនកម្មករជំនាញក្នុងឆ្នាំ ត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការពលកម្មជំនាញ។ ចំនួននៃការប្រកាសជ្រើសរើសបុគ្គលិកមានការឡើងចុះស្ទើរតែរៀងរាល់ឆ្នាំ ប៉ុន្តែគេសង្កេតឃើញចំនួននេះមានកំណើនប្រចាំឆ្នាំដ៏ខ្ពស់ទាំងមុន និងអំឡុងពេល ៥ឆ្នាំ នៃការអនុវត្ត

គោលនយោបាយ IDP ដោយបានកើនឡើងពី ១០.៣៣១ នៅឆ្នាំ២០១០ ទៅដល់ ៣៥.០៥៩ នៅឆ្នាំ ២០១៥ និង ១០១.៧០៩ នៅឆ្នាំ២០១៩។ កំណើននៃចំនួនកម្មករជំនាញក្នុងមួយឆ្នាំ បានកើនឡើងផងដែរ ពីចំនួន ៣.៣៣០ នៅឆ្នាំ២០០៨ ទៅ ៤.០៩៤ នៅឆ្នាំ២០១៥ និងទៅដល់ ១០.១៧៩ នៅឆ្នាំ២០១៩។ អត្រាកំណើនប្រចាំឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានការកើនឡើងខ្លាំងជាងមុនការដាក់ចេញគោលនយោបាយ IDP។ ទោះជាយ៉ាងនេះក្ដី គេមិនអាចផ្សារភ្ជាប់វឌ្ឍនភាពជាវិជ្ជមានទាំងនេះ ទៅនឹងលទ្ធផលនៃការអនុវត្តវិធានការដែលដាក់ចេញដោយគោលនយោបាយ IDP ដែលសុទ្ធសឹងជាវិធានការផ្នែកតម្រូវការបានឡើយ។ ការវាយតម្លៃការរៀបចំគោលនយោបាយបង្ហាញថា IDP មិនបានដាក់ចេញវិធានការណាមួយ ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យក្រុមហ៊ុន/សហគ្រាសបង្កើនឱកាសការងារបន្ថែមសម្រាប់អ្នកជំនាញក្នុងស្រុកនោះឡើយ ដែលអវត្តមាននៃវិធានការផ្នែកផ្គត់ផ្គង់នេះ នឹងជះឥទ្ធិពលអវិជ្ជមានដល់ការសម្រេចបាននៃអន្តរាគមន៍គោលនយោបាយនេះ។

**អន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ"**

គោលនយោបាយ IDP បានផ្ដោតសំខាន់ផងដែរទៅលើការលើកកម្ពស់សុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ ដោយធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជក ដើម្បីធានានូវសិទ្ធិ សេរីភាព និងការទទួលខុសត្រូវរបស់ភាគីទាំងពីរ និងជំរុញកិច្ចចរចាត្រីភាគីរវាងនិយោជក សហជីព និងរាជរដ្ឋាភិបាល។ ការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានចាត់ទុកថានឹងផ្ដល់នូវបច្ច័យវិជ្ជមានដល់ការបង្កើនផលិតភាព ភាពប្រកួតប្រជែង និងសុខុមាលភាពរបស់កម្មករនិយោជិត។ ដើម្បីវាយតម្លៃពីសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយនេះ សូចនាករចំនួន ២ ត្រូវបានយកមកប្រើប្រាស់ រួមមាន (១) ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង និង (២) ភាគរយនៃវិវាទការងារធំៗដែលត្រូវបានដោះស្រាយ។

ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ត្រូវបានដំឡើងជារៀងរាល់ឆ្នាំ ពី៤៥ដុល្លារអាមេរិក នៅឆ្នាំ២០០៥ ទៅដល់ ១២៨ដុល្លារអាមេរិក នៅឆ្នាំ ២០១៥ ហើយបានកើនឡើងដល់ ១៩០ដុល្លារអាមេរិក នៅឆ្នាំ២០២០ ដែលនេះបង្ហាញឱ្យឃើញពីភាពប្រសើរឡើងនៃលក្ខខណ្ឌការងារ និងការលើកកម្ពស់ជីវភាពសម្រាប់កម្មករនៅក្នុងវិស័យនេះ។ ជាមួយគ្នានេះ អត្រានៃភាពជោគជ័យក្នុងការដោះស្រាយវិវាទការងារធំៗ គឺស្ថិតនៅក្នុងកម្រិតមួយខ្ពស់ ៧២% ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ២០១៥ និងឆ្នាំ២០២០ រីឯចំនួនកូដកម្ម និងបាតុកម្មប្រចាំឆ្នាំក៏មានការធ្លាក់ចុះផងដែរនៅក្នុងរយៈពេលដូចគ្នា។ ករណីនេះបានឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃការអនុម័ត និងអនុវត្តច្បាប់ស្ដីពីសហជីព ច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា ព្រមទាំងការដាក់ចេញបទដ្ឋានគតិយុត្តនានា

ទាក់ទងនឹងវិស័យការងារ។ ជារួម ការរៀបចំគោលនយោបាយនៅក្នុងផ្នែកនេះ មានលក្ខណៈច្បាស់លាស់ ខណៈការអនុវត្តភាគច្រើនត្រូវបានបញ្ចប់។

**អន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងការផ្គូផ្គងការងារ"**

ដើម្បីធានាឱ្យបាននូវការបង្កើតការងារប្រកបដោយចីរភាព ការជំរុញការផ្គត់ផ្គង់ និងបង្កើនតម្រូវការការងារ មិនគ្រប់គ្រាន់នោះទេ។ ការផ្គូផ្គងការងារ ក៏ដើរតួយ៉ាងសំខាន់ផងដែរ ដើម្បីធានាថាជំនាញដែលកម្លាំងពលកម្ម/និយោជិតមាន គឺសមស្របទៅនឹងតម្រូវការរបស់និយោជក ហើយឱកាសការងារដែលកើតមានឡើងត្រូវបានចាប់យកយ៉ាងឆាប់រហ័ស។ សូចនាករចំនួន២ ត្រូវបានយកមកប្រើប្រាស់ដើម្បីកំណត់ពីបញ្ហាប្រឈមដែលក្រុមហ៊ុនកំពុងជួបប្រទះពាក់ព័ន្ធនឹងភាពមិនស៊ីចង្វាក់គ្នារវាងតម្រូវការ និងការផ្គត់ផ្គង់ជំនាញ។ ចំណែកនៃក្រុមហ៊ុន/សហគ្រាសដែលទទួលរងការប៉ះពាល់ដោយសារគម្លាតជំនាញបានថយចុះ។ ទោះជាយ៉ាងនេះក្តី ចំណែកនៃសហគ្រាសរាយការណ៍ដែលមានស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ក្នុងចំនួនសហគ្រាសសរុបដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្មយ៉ាងតិចមួយ បន្តស្ថិតនៅក្នុងរង្វង់៥០%។ ទោះបីវិធានការទាំងអស់បានសម្រេចពេញលេញក្តី ការវាយតម្លៃលើការរៀបចំគោលនយោបាយ បង្ហាញថាវិធានការទាំងនោះ នៅមិនទាន់មានចំនួនគ្រប់គ្រាន់ ដែលអាចនាំឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុក។

**អន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ"**

ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ គឺជាកត្តាសំខាន់មួយរបស់គោលនយោបាយ IDP នៅក្នុងការជំរុញគុណភាពការងារ តាមរយៈការផ្តល់ជូនកម្មករ និយោជិត នូវលក្ខខណ្ឌការងារកាន់តែល្អ មានសុវត្ថិភាពនិងសុខភាពការងារ ក៏ដូចជាប្រាក់ឈ្នួល ម៉ោងធ្វើការ និងអត្ថប្រយោជន៍ផ្សេងទៀតកាន់តែល្អប្រសើរ។ ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ រួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនផលិតភាពការងារ និងសុខុមាលភាពរបស់កម្មករនិយោជិត។ ដើម្បីវាយតម្លៃពីវឌ្ឍនភាពនៃការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ ការផ្តល់សេវាសង្គ្រោះអប្បរមាដោយសហគ្រាសនិងគ្រឹះស្ថាន និងការទទួលបានសេវាកម្មសុខភាពតម្លៃសមរម្យសម្រាប់កម្មករតាមរយៈបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ត្រូវបានយកមកប្រើប្រាស់ជាសូចនាកររង្វាស់វែង។ អត្រាសហគ្រាសគ្រឹះស្ថាន ដែលមានសេវាសង្គ្រោះអប្បបរមា មានការកើនឡើង ចំណែកចំនួនកម្មករនិយោជិតដែលទទួលបានបណ្ណសមាជិក ប.ស.ស បានកើនឡើងជិត ១,៧លាននាក់ នៅឆ្នាំ២០១៩។ ការណ៍នេះបានឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃការច្របាច់បញ្ចូលគ្នាក្រុមអធិការកិច្ចការងារច្រើនក្រុម ឱ្យទៅជាក្រុមអធិការកិច្ចការងារតែមួយ និងធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងចុះអធិការកិច្ចដោយផ្តោតចំណាត់ថ្នាក់នៃកម្រិតហានិភ័យរបស់

រោងចក្រសហគ្រាស គ្រឹះស្ថាននីមួយៗ ជាពិសេសផ្តោតលើកម្រិតហានិភ័យពាក់ព័ន្ធនឹងបទដ្ឋានស្នូលនៃលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ ដូចជាសេវាសង្គ្រោះអប្បបរមា បន្ទប់បំបៅកូន កន្លែងហូបបាយ នៅតាមតំបន់ឧស្សាហកម្ម។ វិធានការទាំង៥ ដែលគាំទ្រដល់អន្តរាគមន៍គោលនយោបាយនេះ អាចចាត់ទុកថាមានភាពគ្រប់គ្រាន់ ហើយការអនុវត្តវិធានការភាគច្រើនត្រូវបានបញ្ចប់ ដូចជាវិធានការដែលទាក់ទងនឹងការកំណត់ប្រាក់ឈ្នួលអប្បបរមា យន្តការនៃការពិនិត្យលក្ខខណ្ឌការងារ និងការទទួលបានលំនៅឋានដែលមានតម្លៃសមរម្យ។ ទោះជាយ៉ាងនេះក្តី ការអនុវត្តវិធានការដែលនៅសេសសល់ ហើយដែលកំពុងអនុវត្ត គួរត្រូវបានពន្លឿនបន្ថែម ដូចជា ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ដើម្បីជំរុញការទទួលបានលទ្ធផលល្អប្រសើរជាងនេះ។

### ៣.៤.៣. លទ្ធផលគន្លឹះ និងបច្ច័យសម្រាប់ការអនុវត្តបន្ត

សរុបមក ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ ត្រូវបានវាយតម្លៃថាសម្រេចបានភាគច្រើន។ ជាក់ស្តែង ចំនួនការងារនៅក្នុងវិស័យឧស្សាហកម្ម មានការកើនឡើងជាលំដាប់ ប៉ុន្តែជវភាពនៃកំណើននេះនៅមិនទាន់សមស្របទៅតាមការរំពឹងទុកដោយគោលនយោបាយ IDP នៅឡើយ។ ស្ថានភាពនេះអាចបណ្តាលមកពីការផ្គត់ផ្គង់កម្លាំងពលកម្មនៅមិនទាន់មានភាពសមស្របនឹងតម្រូវការរបស់សហគ្រាស គ្រឹះស្ថាន ទោះបីការអភិវឌ្ឍជំនាញ និងធនធានមនុស្សសម្រេចបាននូវវឌ្ឍនភាពជាបន្តបន្ទាប់ក្តី។

ទន្ទឹមនឹងនេះ គុណភាពការងារនៅកម្ពុជាមានលក្ខណៈល្អប្រសើរបន្តិចម្តងៗ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃអត្រាសហគ្រាស គ្រឹះស្ថានដែលមានសេវាសង្គ្រោះអប្បបរមា, ចំនួនកម្មករដែលទទួលបាន បណ្ណសមាជិក ប.ស.ស. មានការកើនឡើង, និងការពង្រឹងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដែលស្តែងចេញតាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទការងារ ការថយចុះនៃចំនួនកូដកម្ម និងបាតុកម្មប្រចាំឆ្នាំ និងយន្តការសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមាដែលមានដំណើរការល្អ។

ទោះជាយ៉ាងនេះក្តី ក៏នៅមានចំណុចមួយចំនួនដែលទាមទារឱ្យមានការកែលម្អ និងជំរុញការអនុវត្តបន្ថែម ដើម្បីលើកកម្ពស់គុណភាពការងារឱ្យកាន់តែប្រសើរឡើងថែមទៀត។ កិច្ចការដែលអាចធ្វើបានរួមមាន ការពន្លឿនការអភិវឌ្ឍជំនាញនិងធនធានមនុស្ស ជាពិសេសក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងកម្រិតបច្ចេកទេសនិងវិជ្ជាជីវៈ, ការដាក់ចេញនូវវិធានការដែលធានាឱ្យមានតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មជំនាញនៅក្នុងទីផ្សារ, និងការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ ជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដែលឆ្លើយតបនឹងតម្រូវការនៃគម្រោងវិនិយោគថ្មីសំដៅបង្កើតឱកាសការងារកាន់តែច្រើន បង្កើនផលិតភាពនិងជំនាញពលកម្ម និងការពង្រីកលទ្ធភាពនៃការទទួលបានសេវាថែទាំសុខភាពកាន់តែប្រសើរតាមរយៈ ប.ស.ស.។

# ៣.៦. សមិទ្ធកម្មគោលបំណងទី៨ “បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា”

## ៣.៦. សមិទ្ធកម្មគោលបំណងទី៨ “បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរិមា”

### ៣.៦.១. ការវាយតម្លៃសមិទ្ធកម្មនៃគោលបំណងទី៨

ការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងអាចចូលរួមចំណែកដល់ការបង្កើតប្រាក់ចំណូលសម្រាប់ប្រជាជន និងជួយកាត់បន្ថយភាពក្រីក្រ។ បច្ចុប្បន្នខ្សែច្រវាក់ផលិតកម្មក្នុងស្រុករបស់កម្ពុជា នៅមានភាពបែកខ្ញែក និងមានមូលដ្ឋានមិនសូវសម្បូរបែប ហើយភាគច្រើនគ្រប់ដណ្តប់ដោយសហគ្រាសបរទេស ដែលបណ្តាលឱ្យមានការហូរចេញនូវអត្ថប្រយោជន៍នានា។ ការបង្កើនផលប្រយោជន៍ក្នុងស្រុក គឺជាគោលបំណងដ៏សំខាន់នៃគោលនយោបាយ IDP ដែលអាចសម្រេចបានតាមរយៈការលើកកម្ពស់សមត្ថភាពផលិតរបស់សហគ្រាសក្នុងស្រុក ការបង្កើនតម្រូវការផលិតផលក្នុងស្រុក ព្រមទាំងការពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស។ សូចនាករ “ជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាល” ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងសមិទ្ធកម្មរបស់គោលនយោបាយ IDP ក្នុងការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា។




ប្រភពទិន្នន័យ៖ WITS

ឱនភាពជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាលកម្ពុជា បានបន្តរីកកាន់តែធំក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ (រូបភាពទី១២)។ ខណៈឱនភាពនេះមានទំហំប្រមាណ ១,២ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៥ ទំហំនេះបានកើនឡើងដល់ប្រមាណ ៤,៧ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ ដែលបង្ហាញឱ្យឃើញពីគម្លាតកាន់តែធំរវាងទំហំនាំចេញនិងនាំចូលនៃផលិតផលកម្មន្តសាលសរុប។ ឱនភាពជញ្ជីងពាណិជ្ជ-កម្មផលិតផលកម្មន្តសាលគឺជាបញ្ហាទូទៅដែលកើតមានក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍនានា ដូចជាប្រទេសកម្ពុជា ជាដើម ដោយសារសមត្ថភាពផលិតក្នុងស្រុកនៅមានកម្រិត ដែលមិនអាចឆ្លើយតបទៅនឹងកំណើននៃតម្រូវការប្រើប្រាស់ក្នុងស្រុក និងធាតុចូលផលិតកម្មសម្រាប់ផ្គត់ផ្គង់ក្នុងវិស័យកម្មន្តសាល។ ជាលទ្ធផល តម្លៃដែលសេដ្ឋកិច្ចកម្ពុជាអាចទាញយកបានពីសកម្មភាពផលិតកម្មនៅមានកម្រិតតិចតួចនៅឡើយ ដែលជាហេតុនាំឱ្យមានរំហូរចេញនូវប្រយោជន៍សេដ្ឋកិច្ចទៅខាងក្រៅ។ ការបន្តរីកកាន់តែធំនៃឱនភាពជញ្ជីងពាណិជ្ជកម្មបានសបញ្ជាក់ឱ្យឃើញថា បច្ច័យគោលនយោបាយទៅលើការកាត់បន្ថយរំហូរចេញនៃប្រយោជន៍សេដ្ឋកិច្ចទៅខាងក្រៅ នៅមិនទាន់លេចចេញជារូបរាងតាមការរំពឹងទុករបស់គោលនយោបាយ IDP នៅឡើយទេ។

## ៣.៦.២. ការវាយតម្លៃអន្តរាគមន៍គោលនយោបាយក្នុងគោលបំណងទី៥

គោលនយោបាយ IDP បានដាក់ចេញនូវវិធានការចំនួន៨ ដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយចម្បងចំនួន ៤ ដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលបំណងគោលនយោបាយនេះ។ អន្តរាគមន៍គោលនយោបាយទាំងនោះរួមមាន៖ (១) ពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា, (២) ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក, (៣) បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក និង (៤) បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ។ តារាងទី៥ បង្ហាញពីលទ្ធផលសង្ខេបស្តីពីការចូលរួមចំណែកនៃអន្តរាគមន៍គោលនយោបាយទាំងនេះ ក្នុងការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា។ គួរបញ្ជាក់ផងដែរថា បច្ច័យនៃគោលបំណងគោលនយោបាយទី៥ ត្រូវបានបំពេញបន្ថែមដោយអន្តរាគមន៍គោលនយោបាយបន្ទាប់បន្សំចំនួន ១ "បង្កើនតម្រូវការក្នុងស្រុក និងជំនួសការនាំចូល" ផងដែរ។

**តារាងទី៨៖ សង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គ.ប.ទី៥**

| អន្តរាគមន៍គោលនយោបាយ | សមិទ្ធកម្ម | ការរៀបចំគោលនយោបាយ | ការអនុវត្ត |
| --- | --- | --- | --- |
| ពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស (រួមទាំងការផ្ទេរបច្ចេកវិទ្យា) | សម្រាប់សូចនាករ "ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស" ពុំមានទិន្នន័យសម្រាប់ធ្វើការវិភាគឡើយ។ | • ផ្តោតលើការផ្តល់នូវការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម និងការកសាងសមត្ថភាពរបស់សហគ្រាសទាំងនោះ ដើម្បីតភ្ជាប់ជាមួយសហគ្រាសធុនធំ ប៉ុន្តែពុំមានវិធានការគោលនយោបាយដែលរំលេចអំពីតួនាទីរបស់សហគ្រាសធុនធំឬសហគ្រាសបរទេសក្នុងការផ្ទេរបច្ចេកវិទ្យាឡើយ។<br>• វិធានការគោលនយោបាយចំនួន ៣ ពុំ គ្រប់គ្រាន់ដើម្បីឈានទៅសម្រេចឱ្យបាននូវបច្ច័យរំពឹងទុកដោយផ្ទាល់នោះទេ ដោយសារតែវិធានការគោលនយោបាយចំនួន ២ គឺជាវិធានការត្រៀម និងវិធានការមួយទៀត ជាវិធានការមិនច្បាស់លាស់។ | ក្នុងចំណោមវិធានការគោលនយោបាយទាំង៣ មានវិធានការចំនួន ១ ប៉ុណ្ណោះត្រូវបានអនុវត្តពេញលេញ ចំណែកវិធានការចំនួន ២ ទៀត កំពុងអនុវត្តនៅឡើយ។ |

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក | ចំណែកនៃតម្លៃបន្ថែមក្នុងវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាល បានធ្លាក់ចុះជាបន្តបន្ទាប់ ពី ៤៥.៣% នៅឆ្នាំ២០០៥ មកត្រឹម ២៣.៧% នៅឆ្នាំ២០១៩។ | IDP ពុំបានដាក់ចេញនូវវិធានការគោលនយោបាយដាក់លាក់ណាមួយសម្រាប់គាំទ្រអន្តរាគមន៍គោលនយោបាយនេះ។ | IDP ពុំបានដាក់ចេញនូវវិធានការគោលនយោបាយដាក់លាក់ណាមួយសម្រាប់គាំទ្រអន្តរាគមន៍គោលនយោបាយនេះ។ |
| បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក | • ចំណែកនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលមានភាគហ៊ុនខ្មែរចាប់ពី៥១% ឡើងទៅ ធៀបនឹងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សរុបប្រែប្រួលឡើងចុះ ប៉ុន្តែស្ថិតនៅក្រោមអត្រា ៥០%។<br>• ចំណែកនៃចំនួនការងារដែលបង្កើតដោយសហគ្រាសបរទេសធៀបនឹងចំនួនការងារសរុប បានកើនឡើងពី ៣៦.៥% នៅឆ្នាំ២០០៨ ដល់ ៨២.៤% នៅឆ្នាំ២០១៥ ហើយបានធ្លាក់ចុះមកត្រឹម ៦៦.៧%នៅឆ្នាំ២០១៩។ | IDP ពុំបានដាក់ចេញនូវវិធានការដាក់លាក់ណាមួយ សម្រាប់គាំទ្រអន្តរាគមន៍គោលនយោបាយនេះ។ | IDP ពុំបានដាក់ចេញនូវវិធានការដាក់លាក់ណាមួយ សម្រាប់គាំទ្រអន្តរាគមន៍គោលនយោបាយនេះ ។ |
| បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ | ការនាំចេញកសិផលកែច្នៃ បានកើនឡើងពី ៥១៦,២ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៦ ដល់ ៨៤៥,៩លានដុល្លារអាមេរិក នៅឆ្នាំ ២០២០។ | • ផ្តោតលើការទាក់ទាញគម្រោងវិនិយោគឱ្យបោះទីតាំងក្នុងតំបន់កែច្នៃកសិផល និងការជំរុញការនាំចេញកសិផលកែច្នៃ។<br>• វិធានការគោលនយោបាយទាំង៤ក្រោមអន្តរាគមន៍គោលនយោបាយនេះ ពុំអាចធ្វើឱ្យសម្រេចបាននូវបច្ច័យរំពឹងទុកឡើយ ដោយសារក្នុងនោះ មានវិធានច្បាស់លាស់ចំនួន ២ | វិធានការមួយក្នុងចំណោមវិធានការចំនួន ៤ គឺជាវិធាន-ការពហុបំណង។ ដោយហេតុនេះ វិធានការមួយនេះត្រូវបានបែងចែកជាអនុវិធានការចំនួន ២។ ជាលទ្ធផល វិធានការគោលនយោបាយនិងអនុវិធានការ សរុបទាំងអស់មានចំនួន៥ ក្នុងនោះមានវិធានការ ចំនួន ៣ ត្រូវបានអនុវត្តពេញលេញ ខណៈវិធានការចំនួន ២ ទៀត មានការយឺតយ៉ាវក្នុងការអនុវត្ត។ |

៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

| | | | |
|---|---|---|---|
| | | ប៉ុណ្ណោះ ខណៈវិធានការចំនួន២ ទៀតជាវិធានការត្រៀម។ | |

**កំណត់សម្គាល់៖** សម្រាប់ការវិភាគលម្អិតលើអន្តរាគមន៍គោលនយោបាយចម្បងទាំង៤ (ការវាយតម្លៃសមិទ្ធកម្មបែបបរិមាណវិស័យ ការរៀបចំគោលនយោបាយ និងការអនុវត្តគោលនយោបាយ) សូមមើលឧបសម្ព័ន្ធទី១។

អន្តរាគមន៍គោលនយោបាយ “ពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា”

ក្នុងគោលបំណងពង្រឹងការតភ្ជាប់ឧស្សាហកម្មក្នុងស្រុក គោលនយោបាយ IDP បានកំណត់ការជំរុញឱ្យសហគ្រាសបរទេសក្នុងវិស័យកម្មន្តសាលប្រើប្រាស់ធាតុចូលផលិតកម្មពីសហគ្រាសក្នុងស្រុកកាន់តែច្រើនជាយុទ្ធសាស្ត្រមួយនៅក្នុងការជំរុញការបង្កើនផលប្រយោជន៍ក្នុងស្រុក។ វត្តមាននៃសហគ្រាសបរទេសនៅក្នុងសេដ្ឋកិច្ចជាតិ អាចជំរុញការផ្ទេរបច្ចេកវិទ្យា និងចំណេះធ្វើដល់កម្មករ-និយោជិត និងសហគ្រាសក្នុងស្រុក។ សូចនាករ “ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស” ត្រូវបានប្រើប្រាស់ដើម្បីវិភាគលទ្ធផលបែបបរិមាណវិស័យនៃអន្តរាគមន៍គោលនយោបាយនេះ ប៉ុន្តែសូចនាករនេះពុំមានទិន្នន័យសម្រាប់វាស់វែងឡើយ។ ដោយឡែក លទ្ធផលអង្កេតសហគ្រាសរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៅឆ្នាំ២០១៩ បានបង្ហាញថា ៩៦% នៃធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេសត្រូវបាននាំចូល។[២] សហគ្រាសបរទេសកាន់តែច្រើន ក៏បានងាកទៅរកប្រភពផ្គត់ផ្គង់ក្នុងស្រុកផងដែរ ប៉ុន្តែចំនួនសហគ្រាសក្នុងស្រុកដែលមានភាពប្រកួតប្រជែង នៅតែមានកម្រិតនៅឡើយ។ ករណីនេះអាចបណ្តាលមកពីសមត្ថភាពរបស់សហគ្រាសក្នុងស្រុកក្នុងការតភ្ជាប់ជាមួយសហគ្រាសបរទេស នៅមានភាពទន់ខ្សោយ។

វិធានការគោលនយោបាយទាំង ៣ ដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះ គឺសុទ្ធតែជាវិធានការត្រៀម ដែលពុំអាចនាំមកនូវលទ្ធផលវិជ្ជមានដល់ការសម្រេចបាននៃអន្តរាគមន៍គោលនយោបាយនេះបានឡើយ ហើយវិធានការគោលនយោបាយទាំងនេះទៀតសោត នៅខ្វះមធ្យោបាយជាក់លាក់ក្នុងការសម្រេចឱ្យបាននូវលទ្ធផលរំពឹងទុក។ ក្នុងកម្រិតប្រតិបត្តិ មានតែវិធានការគោលនយោបាយតែមួយគត់ ដែលត្រូវបានអនុវត្តពេញលេញ ពោលគឺវិធានការពាក់ព័ន្ធនឹងការសិក្សារៀបចំស្ទួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម។ វិធានការគោលនយោបាយចំនួន ២ ផ្សេងទៀតពាក់ព័ន្ធនឹងការផ្តល់ការគាំទ្រប្រកបដោយសក្តានុពលដល់សហគ្រាសធុនតូចនិងមធ្យម សម្រាប់ការបំពាក់គ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម និងការកសាងសមត្ថភាព សហគ្រិនភាព កំពុងស្ថិតនៅក្នុងដំណាក់កាលអនុវត្តនៅឡើយ។

[២] ប្រភពទិន្នន័យបានមកពីការអង្កេតសហគ្រាសរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)

### អន្តរាគមន៍គោលនយោបាយ “ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក”

ការពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក គឺជាអន្តរាគមន៍គោលនយោបាយមួយទៀតដែលគោលនយោបាយ IDP រំពឹងថានឹងរួមចំណែកដល់ការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា។ អន្តរាគមន៍គោលនយោបាយនេះ ផ្តោតសំខាន់លើការពង្រីកបណ្តាញផលិតកម្ម និងការបង្កើតតម្លៃក្នុងសេដ្ឋកិច្ចជាតិ ចាប់ពីសកម្មភាពកម្មន្តសាលដោនស្ទ្រីម ដូចជា សកម្មភាពផ្គុំដំឡើងនិងការកែច្នៃ រហូតដល់ការផលិតគ្រឿងបង្គុំឬធាតុចូលផលិតកម្មក្នុងសកម្មភាពកម្មន្តសាលអាប់ស្ទ្រីម។ ដើម្បីវិភាគលទ្ធផលរំពឹងទុកនៃអន្តរាគមន៍គោលនយោបាយនេះ សូចនាករ “ចំណែកនៃតម្លៃបន្ថែមក្នុងវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាល” ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងសមត្ថភាពផលិតកម្មក្នុងវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិផលកម្មន្តសាល។ ប្រសិនបើតម្លៃបន្ថែមក្នុងវិស័យកម្មន្តសាល មានចំនួនតូចជាងទំហំនៃការនាំចេញ នោះវិស័យកម្មន្តសាលរបស់ប្រទេស ពឹងផ្អែកខ្លាំងទៅលើការនាំចូលវត្ថុធាតុដើម ជាងការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក។ លទ្ធផលវិភាគបែបបរិមាណវិស័យបានបង្ហាញថា ចំណែកនៃតម្លៃបន្ថែមក្នុងវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាល បានថយចុះក្នុងរយៈកាលកន្លងមក ដែលនៅឆ្នាំ២០០៥ ចំណែកនេះស្ថិតនៅក្នុងអត្រាប្រមាណ ៤៥% ហើយបានធ្លាក់ចុះជាបន្តបន្ទាប់ មកត្រឹមប្រមាណ ៣១% នៅឆ្នាំ២០១៥ និង ២៤% នៅឆ្នាំ២០១៩។ និន្នាការនេះ បង្ហាញថា ឧស្សាហកម្មប្រតិគមន៍ និងខ្សែច្រវាក់តម្លៃក្នុងស្រុក ពុំទាន់ត្រូវបានពង្រឹងនៅឡើយ។ ការវាយតម្លៃទៅលើការរៀបចំគោលនយោបាយ បង្ហាញថាគោលនយោបាយ IDP ពុំបានដាក់ចេញនូវវិធានការគោលនយោបាយគ្រប់គ្រាន់ និងមានប្រសិទ្ធភាពក្នុងការជួយពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុកឡើយ។

### អន្តរាគមន៍គោលនយោបាយ “បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក”

អន្តរាគមន៍គោលនយោបាយនេះ ផ្តោតលើការបង្កើនភាពជាម្ចាស់លើមធ្យោបាយផលិតកម្មដោយផលិតករឬសហគ្រិនក្នុងស្រុក។ ការបង្កើនភាពជាម្ចាស់ ចូលរួមចំណែកបង្កើននូវផលប្រយោជន៍ក្នុងស្រុកក្រោមហេតុផលជាច្រើន។ ជាក់ស្តែង សហគ្រាសក្នុងស្រុក អាចប្រើប្រាស់ប្រាក់ចំណេញមួយភាគធំរបស់ខ្លួនទៅពង្រីកគម្រោងវិនិយោគក្នុងស្រុក ក៏ដូចជាប្រើប្រាស់ធាតុចូលផលិតកម្មក្នុងស្រុក និងផ្តល់ការងារជូនកម្មករនិយោជិតក្នុងស្រុក ដែលកត្តានេះអាចជួយបង្កើតតម្លៃបន្ថែមនៅក្នុងសេដ្ឋកិច្ចជាតិ។ ផលប្រយោជន៍សេដ្ឋកិច្ចដែលកើតចេញពីសកម្មភាពសេដ្ឋកិច្ចនេះ នឹងចូលរួមចំណែកជំរុញការប្រើប្រាស់ធនធានក្នុងស្រុក ព្រមទាំងបង្កើនមូលដ្ឋានពន្ធជាតិ បង្កើតប្រភពចំណូលពន្ធផ្សេងៗ និងទប់ស្កាត់រំហូរចេញនៃប្រយោជន៍សេដ្ឋកិច្ចទៅខាងក្រៅ។

## ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

ទោះបីអន្តរាគមន៍គោលនយោបាយនេះមានសារៈសំខាន់យ៉ាងណាក្តី គោលនយោបាយ IDP ពុំបានកំណត់វិធានការជាក់លាក់ណាមួយដើម្បីបង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុកឡើយ។ យ៉ាងណាមិញ អន្តរាគមន៍គោលនយោបាយនេះ អាចវាស់វែងបានតាមរយៈសូចនាករចំនួន ២ គឺចំនួនម្ចាស់ភាគហ៊ុនសញ្ជាតិខ្មែរ និងការចូលរួមចំណែករបស់ក្រុមហ៊ុនបរទេសក្នុងការបង្កើតការងារ។ ដោយសារសូចនាករចំនួនក្រុមហ៊ុនចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដែលមានភាគហ៊ុនខ្មែរចាប់ពី ៥១% ឡើងទៅ ពុំមានទិន្នន័យ ដូចនេះសូចនាករ ចំណែកនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលមានភាគហ៊ុនខ្មែរចាប់ពី៥១% ឡើងទៅ ធៀបនឹងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សរុប ត្រូវបានយកមកប្រើប្រាស់ជំនួសវិញ ដើម្បីវាស់វែងកម្រិតនៃភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុករបស់គម្រោងវិនិយោគ។ គួរកត់សម្គាល់ផងដែរថា សូចនាករជំនួសខាងលើនេះ ពុំអាចបង្ហាញនូវគ្រប់ទិដ្ឋភាពនៃភាពជាម្ចាស់របស់គម្រោងវិនិយោគក្នុងស្រុកនៅប្រទេសកម្ពុជាទាំងមូលបានទេ ព្រោះសូចនាករនេះរាប់បញ្ចូលតែគម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាប៉ុណ្ណោះ និងពុំបានរាប់បញ្ចូលគម្រោងវិនិយោគដែលពុំមានសិទ្ធិក្នុងការទទួលបាននូវការលើកទឹកចិត្តវិនិយោគ តួយ៉ាងគម្រោងវិនិយោគដែលស្ថិតនៅក្នុងវិស័យមួយចំនួន ដូចជាវិស័យ ធនាគារ ធានារ៉ាប់រង និងសំណង់។ ទិន្នន័យនៃសូចនាករជំនួសនេះ មានការប្រែប្រួលឡើងចុះ ទាំងមុនពេលការដាក់ចេញ និងក្នុងអំឡុងពេលនៃការអនុវត្ត IDP ហើយអត្រានេះស្ថិតនៅក្រោម ៥០% ជាប់ៗគ្នាក្នុងរយៈកាល ១០ឆ្នាំចុងក្រោយនេះ។ បើផ្អែកតាមនិន្នាការនៃសូចនាករជំនួសខាងលើនេះ វិនិយោគិនក្នុងស្រុកមិនទាន់មានភាពសកម្មក្នុងការបង្កើត ឬពង្រីកចំនួនគម្រោងវិនិយោគ (គ.ល.គ.) ឱ្យបានច្រើននៅឡើយទេ។ ប្រសិនបើពិនិត្យមើលចំណែកនៃចំនួនការងារដែលបង្កើតដោយសហគ្រាសបរទេស ធៀបនឹងចំនួនការងារសរុបវិញ គេសង្កេតឃើញថា ក្នុងរយៈកាល ៥ឆ្នាំចុងក្រោយ សហគ្រាសក្នុងស្រុកបាននិងកំពុងដើរតួនាទីកាន់តែសកម្មក្នុងការបង្កើតការងារ ប៉ុន្តែសហគ្រាសបរទេសនៅតែមានចំណែកធំលើសលុបក្នុងការបង្កើតការងារ ដែលស្ថានភាពនេះបង្ហាញថា រចនាសម្ព័ន្ធកម្មសិទ្ធិរបស់សហគ្រាសនៅកម្ពុជា ពុំទាន់មានការផ្លាស់ប្តូរជាដុំកំភួននៅឡើយ។

**អន្តរាគមន៍គោលនយោបាយ "បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ"**

ការបង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ ផ្តោតទៅលើការប្រែក្លាយកសិផលពុំទាន់កែច្នៃក្នុងស្រុកទៅជាកសិផលកែច្នៃដែលមានតម្លៃបន្ថែម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មទំនើប។ សូចនាករ "តម្លៃនាំចេញកសិផលកែច្នៃ" ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងសមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយនេះ។ លទ្ធផលនៃការវាយតម្លៃបែបបរិមាណវិស័យបានបង្ហាញថា ការនាំចេញកសិផលកែច្នៃបានកើនឡើងជាលំដាប់ ពី ៥១៦,២លានដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដល់ ៨៤៥,៩លានដុល្លារអាមេរិក នៅឆ្នាំ២០២០។

ចំពោះរៀបចំគោលនយោបាយ IDP បានដាក់ចេញវិធានការគោលនយោបាយច្បាស់លាស់ ចំនួន ៤ ដើម្បីបង្កើតតំបន់កែច្នៃកសិផល និងផ្តល់ការលើកទឹកចិត្តដល់បណ្តាសហគ្រាសដែលបោះទីតាំងនៅក្នុងតំបន់នោះ, កែលម្អកិច្ចសម្រួលពាណិជ្ជកម្ម និងធ្វើអត្តសញ្ញាណកម្មនៃមុខទំនិញកសិផលកែច្នៃដែលមានសក្តានុពលសម្រាប់ការនាំចេញ។ យ៉ាងណាមិញ វិធានការទាំងនេះប្រហែលជាពុំទាន់មានភាពគ្រប់គ្រាន់ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនៅឡើយ។ ការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) នៅក្នុងវិស័យកសិ-ឧស្សាហកម្ម ក្រោមអន្តរាគមន៍គោលនយោបាយនេះ អាចត្រូវបានបំពេញបន្ថែមដោយវិធានការផ្សេងទៀត ជាពិសេស វិធានការ "បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ" ក្នុងគោលបំណងទី២។ វិធានការចំនួន ៣ ត្រូវបានអនុវត្តពេញលេញ ដោយបានសម្រេចនូវសមិទ្ធផលមួយចំនួនរួចមកហើយ ដូចជា ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្មកម្ពុជា ការធ្វើអត្តសញ្ញាណកម្មនៃមុខទំនិញកសិផលកែច្នៃអាទិភាពសម្រាប់ការនាំចេញ និងការបង្កើនចំនួនសហគ្រាសកសិ-ឧស្សាហកម្ម (ពី ៣.៣៦៨ នៅឆ្នាំ២០១៨ ដល់ ៥.៧៥៤ នៅឆ្នាំ២០២០)។

### ៣.៦.៣. លទ្ធផលគន្លឹះ និងបច្ច័យសម្រាប់ការអនុវត្តបន្ត

លទ្ធផលនៃការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា ត្រូវបានវាយតម្លៃថានៅមានកម្រិតនៅឡើយ។ ទោះបីជាគោលបំណងនេះ មានសារៈសំខាន់ចំពោះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងរយៈពេលវែងក៏ដោយ គោលនយោបាយ IDP បានផ្ដោតការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះទៅលើគោលបំណងនេះ ដោយបានដាក់ចេញនូវវិធានការត្រឹមចំនួន ៨ ប៉ុណ្ណោះ ដែលក្នុងនោះវិធានការភាគច្រើនមានចរិតលក្ខណៈមិនច្បាស់លាស់ និងជាវិធានការត្រៀម។ ដើម្បីធ្វើឱ្យគោលបំណងនេះសម្រេចបានគោលនយោបាយ IDP គួរតែដាក់ចេញនូវឧបករណ៍គោលនយោបាយច្បាស់លាស់ ដែលជំរុញការតភ្ជាប់ចំគោលដៅរវាងសហគ្រាសក្នុងស្រុកដែលមានសក្ដានុពលជាមួយនឹងសហគ្រាសបរទេស ដើម្បីលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា ក៏ដូចជាការបង្កើនតម្រូវការសម្រាប់ផលិតផលក្នុងស្រុក តាមរយៈការជំរុញឱ្យមានការប្រើប្រាស់ផលិតផលក្នុងស្រុកកាន់តែច្រើន និងការកាត់បន្ថយការនាំចូលក្នុងវិស័យដែលកម្ពុជាមានសក្ដានុពលក្នុងការផលិត ព្រមទាំងបង្កើនភាពជាម្ចាស់នៃសហគ្រាសក្នុងស្រុក។

# ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

## ៣.៧. សមិទ្ធកម្មគោលនយោបាយ IDP ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ

បន្ថែមលើការវិភាគស៊ីជម្រៅនៃសមិទ្ធកម្មរបស់គោលនយោបាយ IDP ដើម្បីឈានឆ្ពោះទៅសម្រេចលទ្ធផលបន្ទាប់ ឬរយៈពេលមធ្យម ផ្នែកនេះពិនិត្យដោយសង្ខេបពីការចូលរួមរបស់គោលនយោបាយ IDP ក្នុងទិសដៅឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ដែលជាគោលដៅរយៈពេលវែងរបស់កម្ពុជា។

ឈរលើទស្សនវិស័យដែលមានចែងក្នុង "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**" ការរៀបចំ និងដាក់ចេញនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" គឺជាមគ្គុទ្ទេសក៍ដ៏សំខាន់ក្នុងការជំរុញឱ្យកម្ពុជាឆ្ពោះទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដើម្បីបូកសរុបសមិទ្ធផលដែលសម្រេចបានកន្លងមក និងធានាបាននូវស័ក្តិសិទ្ធភាពនៃការអនុវត្តគោលនយោបាយរាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា (២០១៨-២០២៣) នៅតែបន្តផ្តោតសារៈសំខាន់ និងភាពពាក់ព័ន្ធលើ **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** ជាគោលដៅអភិវឌ្ឍន៍ជាតិ។ ជាមួយគ្នានេះ "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**" ក៏ត្រូវបានដាក់ចេញក្រោមប្រធានបទដូចគ្នាគឺ **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** ដោយសម្រិតសម្រាំងបន្ថែមនិងធ្វើអាទិភាវូបនីយកម្មមុំនីមួយៗនៃចតុកោណយុទ្ធសាស្ត្រ។

ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ជាតិទាំង៤ គោលនយោបាយ IDP ត្រូវបានរំពឹងថានឹងចូលរួមចំណែកក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ជាតិចម្បងចំនួន ៣៖ (១) កំណើនសេដ្ឋកិច្ចដែលមានភាពធន់នឹងវិបត្តិ, (២) កំណើនបរិមាណការងារ, និង (៣) ការកាត់បន្ថយភាពក្រីក្រ។ ទីមួយ គោលនយោបាយ IDP មានគោលបំណងចូលរួមចំណែកក្នុងការពង្រឹងភាពធន់នៃសេដ្ឋកិច្ចកម្ពុជា តាមរយៈការបង្កើន និងការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម និងការនាំចេញ ព្រមទាំងការពង្រឹងសមត្ថភាពសេដ្ឋកិច្ចក្នុងស្រុក ដើម្បីពង្រីករចនាសម្ព័ន្ធសេដ្ឋកិច្ចដែលមានស្រាប់។ ការធ្វើពិពិធកម្ម និងការពង្រីកឧស្សាហកម្មនឹងចូលរួមចំណែកកាត់បន្ថយភាពងាយរងនឹងវិបត្តិ និងការប្រែប្រួលនានាដែលអាចកើតមានឡើងនៅក្នុងតំបន់ និងពិភពលោក។ ទីពីរ កំណើនសកម្មភាពឧស្សាហកម្ម នឹងជំរុញការបង្កើតការងារនៅក្នុងវិស័យផ្សេងៗទៀត តាមរយៈឧស្សាហកម្មប្រតិគមន៍ (backward linkages) និងឧស្សាហកម្មអនុគមន៍ (forward linkages)។ តាមរយៈការជំរុញការវិនិយោគនៅក្នុងវិស័យឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យា និងមានតម្លៃបន្ថែមខ្ពស់ គោលនយោបាយ IDP មិនត្រឹមតែរួមចំណែកក្នុងការបង្កើតឱកាសការងារបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកកម្ពស់គុណភាពការងារផងដែរ។ ទីបី ការកើនឡើងនៃឱកាសការងារនឹងជួយកាត់បន្ថយអត្រាគ្មានការងារធ្វើ និងជាពិសេសចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

សូចនាករចំនួន ៤ ត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃលើការរួមចំណែករបស់គោលនយោបាយ IDP ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិទាំង ៣ ដូចដែលបានរៀបរាប់ខាងលើ។ សូចនាករទី ១ គឺ "អត្រាកំណើន ផ.ស.ស. ពិត" ដែលវាស់ស្ទង់ពីនិន្នាការកំណើនសេដ្ឋកិច្ច និងភាពធន់នឹងវិបត្តិរបស់សេដ្ឋកិច្ចកម្ពុជា។ សូចនាករទី២ និងទី៣ គឺ "ចំនួនការងារផ្លូវការថ្មីដែលបានចុះបញ្ជី" និង "ចំនួនការងារក្នុងវិស័យកម្មន្តសាល" ដែលបង្ហាញពីនិន្នាការនៃការបង្កើតការងារ ពិសេសការរួមចំណែកនៃវិស័យកម្មន្តសាលក្នុងការបង្កើតការងារ។ សូចនាករចុងក្រោយគឺ "អត្រាភាពក្រីក្រ" ដែលបង្ហាញពីភាពប្រសើរឡើងនៃកម្រិតជីវភាពរបស់ប្រជាជន។




ប្រភពទិន្នន័យ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រូបភាពទី ១៣ បង្ហាញថា កម្ពុជារក្សាបាននូវកំណើន ផ.ស.ស. មួយខ្ពស់ ប្រមាណ ៧% ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ជាងនេះទៅទៀត ការចូលរួមចំណែករបស់វិស័យឧស្សាហកម្មក្នុងកំណើនសេដ្ឋកិច្ចមានការកើនឡើងជាលំដាប់ក្នុងរយៈពេល ២០១២-២០១៩។ កំណើននេះបង្ហាញឱ្យឃើញថា ឧស្សាហកម្ម គឺជាវិស័យចម្បងដែលបានរួមចំណែកយ៉ាងសំខាន់ដល់កំណើន ផ.ស.ស. របស់កម្ពុជា ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។



រូបភាពទី១៤៖ ចំនួនការងារផ្លូវការថ្មីដែលបានចុះបញ្ជី

ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



រូបភាពទី១៥៖ ចំនួនការងារក្នុងវិស័យកម្មន្តសាលនៅកម្ពុជា (អាយុ១៥ឆ្នាំឡើង)

ប្រភពទិន្នន័យ៖ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើទិន្នន័យរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០១០ ដល់ ឆ្នាំ២០១៩/២០២០

សម្គាល់៖ សម្រាប់ឆ្នាំ២០១៨ មិនមានការធ្វើអង្កេត និងសម្រាប់ឆ្នាំ២០២០ ការប្រមូលទិន្នន័យបានធ្វើឡើងក្នុងឆមាសទី២ ឆ្នាំ២០១៩ និងឆមាសទី១ ឆ្នាំ២០២០

ក្រៅពីកំណើនសេដ្ឋកិច្ច គោលនយោបាយ IDP ក៏ត្រូវបានរំពឹងថានឹងចូលរួមចំណែកក្នុងការបង្កើនចំនួនការងារផងដែរ។ ជាក់ស្តែង រូបភាពទី១៤ បង្ហាញថាចំណែកនៃចំនួនការងារក្នុងវិស័យកម្មន្តសាលបានបន្តកើនឡើងពី ១០,៧% នៅឆ្នាំ២០១០ ដល់ ១៦,៥%នៅឆ្នាំ២០១៥ និង ១៦,៧% នៅឆ្នាំ២០១៧ ប៉ុន្តែចំណែកនេះបានធ្លាក់ចុះបន្តិចមកត្រឹម១៥,៥% នៅឆ្នាំ២០២០ ដោយសារតែផលប៉ះពាល់អវិជ្ជមាននៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ប្រសិនបើពិនិត្យទៅលើចំនួនការងារ វិស័យកម្មន្តសាលបានចូលរួមបង្កើតការងារជាមធ្យមប្រមាណ ១២.២៥០នាក់ ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ២០១៥ និងឆ្នាំ២០២០។ ជាមួយគ្នានេះ ចំណែកនៃការងារក្នុងវិស័យកម្មន្តសាលក្រៅពីកាត់ដេរ ធៀបនឹងចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល បានកើនឡើងពី ២៨% នៅឆ្នាំ២០១៥ ដល់ ៣៣% នៅឆ្នាំ២០២០ ដែលនេះបង្ហាញពីតួនាទីកាន់តែសំខាន់នៃវិស័យកម្មន្តសាលក្រៅពីកាត់ដេរ ក្នុងការជំរុញកំណើនការងារ។

រូបភាពទី១៦៖ អត្រាភាពក្រីក្រ (%)




ប្រភពទិន្នន័យ៖ ក្រសួងផែនការ

បន្ថែមលើនេះ គោលនយោបាយ IDP ក៏ត្រូវបានរំពឹងថានឹងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ។ រូបភាពទី១៦ បង្ហាញថា ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាមានវឌ្ឍនភាពជាបន្តបន្ទាប់ ដោយបានបន្តធ្លាក់ចុះពី ១១,៩% នៅឆ្នាំ២០១៥ មកក្រោម ១០% នៅឆ្នាំ២០១៩។ យ៉ាងណាមិញ ការធ្វើពិពិធកម្មវិស័យឧស្សាហកម្មដើម្បីឆ្ពោះទៅរកសកម្មភាពបច្ចេកវិទ្យាទំនើប និងមានតម្លៃបន្ថែមខ្ពស់ ព្រមទាំងការពង្រឹងការទាញយកផលប្រយោជន៍ក្នុងស្រុក តាមរយៈការជំរុញការអនុវត្ត IDP នឹងជួយពន្លឿនល្បឿននៃការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យប្រសើរឡើងនូវជីវភាពប្រជាជន។

សរុបសេចក្តីមក ការអនុវត្តគោលនយោបាយ IDP បានចូលរួមចំណែកដោយផ្នែកក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ និងការអភិវឌ្ឍជារួមរបស់កម្ពុជា។ វឌ្ឍនភាពនេះអាចត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរក្សាបាននូវកំណើនសេដ្ឋកិច្ច ការបង្កើនឱកាសការងារ ក៏ដូចជាការចូលរួមកាត់បន្ថយភាពក្រីក្រ។

យើងអាចសម្គាល់ឃើញថា វិស័យកម្មន្តសាល នៅពុំទាន់ក្លាយជាវិស័យគន្លឹះក្នុងការជំរុញកំណើន ផ.ស.ស. នៅក្នុងប្រទេស តាមការរំពឹងទុករបស់គោលនយោបាយ IDP ហើយវិស័យនេះក៏ពុំទាន់ឈានដល់កម្រិតសក្តានុពលរបស់ខ្លួននៅឡើយ។ ក្នុងន័យនេះ ដើម្បីបន្តជំរុញការចូលរួមការអនុវត្តគោលនយោបាយ IDP ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ គួរបន្តជំរុញការធ្វើពិពិធកម្ម ជាពិសេសបង្កើនតួនាទីនៃសកម្មភាពកម្មន្តសាលទំនើបៗនៅក្នុងសេដ្ឋកិច្ចជាតិ ដែលនឹងរួមចំណែកបង្កើនការងារដែលមានគុណភាពខ្ពស់ប្រកបដោយចីរភាព។

# ៣.ការវាយតម្លៃលើបច្ច័យនៃការអនុវត្តគោលនយោបាយ IDP

## ៣.៨. ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងវិស័យធនាគារគាំទ្រការអនុវត្តគោលនយោបាយ IDP

ហិរញ្ញប្បទានសហប្រតិបត្តិការ បានដើរតួនាទីជាកាតាលីករក្នុងការកៀរគរប្រភពធនធានដទៃទៀត និងជាប្រភពធនធានគាំទ្រដោយផ្ទាល់ដល់ការអនុវត្តគោលនយោបាយ IDP លើការងារអាទិភាព រួមមាន ៖ ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធភស្តុភារកម្ម, កិច្ចសម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច, ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធាន មនុស្ស និងការអភិវឌ្ឍពលកម្មជំនាញ។ ក្នុងន័យនេះ ហិរញ្ញប្បទាននឹងជួយបង្កើតបរិស្ថានអំណោយផលសម្រាប់វិនិយោគឯកជន, ជំរុញការទាក់ទាញវិនិយោគ និងបង្កើនសកម្មភាពឧស្សាហកម្ម។

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) បានតាមដានលំហូរហិរញ្ញប្បទានសម្រាប់គាំទ្រគោលនយោបាយ IDP តាមរយៈទិន្នន័យដែលបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា។ ជាក់ស្តែង ហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានតម្រឹមជាមួយវិធានការគោលនយោបាយ, ផែនការសកម្មភាព និងវិធានការគន្លឹះបួនជាក់ស្តែងនៃគោលនយោបាយ IDP។

តារាងទី៦ : ធនធានរយៈពេលមធ្យមឆ្នាំ២០១៥-២០២០ គាំទ្រគោលនយោបាយ IDP (គិតជាលានដុល្លារអាមេរិក)

| វិធានការគោលនយោបាយ និង វិធានការគន្លឹះបួនជាក់ស្តែង | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ (ប៉ាន់ស្មាន) | សរុប |
|---|---|---|---|---|---|---|---|
| ការជំរុញការទាក់ទាញវិនិយោគ | ០,២ | ៣,៣ | ១,៨ | ២,៣ | ៤៧,៦ | ១៨,៥ | ៧៣,៧ |
| ការពង្រីក និងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម | ១,១ | ១,៧ | ៣,៦ | ៣,៩ | ៧,៣ | ៧,០ | ២៤,៦ |
| ការកែលម្អបរិស្ថាននិយ័តកម្ម | ៤,៣ | ៩,០ | ២៥,៩ | ៩,២ | ៨,៣ | ៥,២ | ៦១,៨ |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | ២៧,៤ | ២២,២ | ២៨,២ | ២៩,៣ | ៣១,៤ | ៥០,១ | ១៨៨,៦ |
| វិធានការគន្លឹះបួនជាក់ស្តែង | ៥៥,៩ | ១៤៨ | ១៦២ | ១០៤,៨ | ២០១,៩ | ២៦៦ | ៩៣៨,៥ |
| សរុប | ៨៨,៩ | ១៨៤,២ | ២២១,៤ | ១៤៩,៥ | ២៩៦,៤ | ៣៤៦,៧ | ១.២៨៧,២ |

ប្រភព៖ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា

តារាងទី៦ បង្ហាញថា ចាប់ពីឆ្នាំ២០១៥-២០២០ ហិរញ្ញប្បទានប្រមាណ ១.២៨៧,២ លានដុល្លារ ជាមធ្យម ២១៥ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ត្រូវបានផ្តល់ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ IDP។ ធនធានភាគច្រើនប្រមាណ ៩៣៨,៥ លានដុល្លារអាមេរិក បានគាំទ្រវិធានការគន្លឹះបួនជាក់ស្តែង។ ជាមួយគ្នានេះ ធនធានប្រមាណ ១៨៨,៦ លានដុល្លារអាមេរិក បានគាំទ្រការសម្របសម្រួលគោលនយោបាយគាំទ្រ ខណៈដែលធនធានត្រឹមតែ ២៤,៦ លានដុល្លារអាមេរិក បានគាំទ្រការពង្រីក និងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម។ ក្នុងចំណោមដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានផ្តល់ការគាំទ្រដល់ការអនុវត្តគោលនយោបាយ IDP, សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, បារាំង, ធនាគារអភិវឌ្ឍន៍អាស៊ី និងអូស្ត្រាលី គឺជាដៃគូអភិវឌ្ឍន៍សំខាន់ដែលបានបើកផ្តល់ហិរញ្ញប្បទានមួយភាគធំ ប្រមាណ ១.១៦១,៧ លានដុល្លារអាមេរិក ស្មើនឹង ៩០% នៃទំហំហិរញ្ញប្បទានសរុបគាំទ្រគោលនយោបាយ IDP។

ក្នុងឆ្នាំ២០២០ ហិរញ្ញប្បទានគាំទ្រការអនុវត្តគោលនយោបាយ IDP ត្រូវបានប៉ាន់ស្មានមានទំហំ ៣៤៦,៧ លានដុល្លារអាមេរិក ពោលគឺកើន ១៧% ធៀបនឹងឆ្នាំ២០១៩ ដោយសារកំណើនការបើកផ្តល់ហិរញ្ញប្បទានពីជប៉ុន និងបារាំង សម្រាប់គម្រោងអគ្គីសនី និងការអភិវឌ្ឍជំនាញ។ ដោយឡែកហិរញ្ញប្បទានប្រមាណ ៣/៤ បានគាំទ្រ ដល់វិធានការគន្លឹះបួនជាក់ស្តែង។ គោលនយោបាយ IDP បានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការអភិវឌ្ឍជំនាញ និងធនធានមនុស្ស តាមរយៈការលើកកម្ពស់ការអប់រំចំណេះទូទៅ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ក្នុងស្មារតីនេះ នាខែមិថុនា ឆ្នាំ២០១៧ រាជរដ្ឋាភិបាល បានអនុម័តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥។ ក្រោមការដឹកនាំរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ គោលនយោបាយនេះនឹងពង្រឹងមុខងារនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាតិ ក៏ដូចជាផ្តល់វេទិកាសម្រាប់ភាគីពាក់ព័ន្ធក្នុងការចូលរួម និងកៀរគរធនធាន។

ផ្អែកលើប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា ចាប់ពីឆ្នាំ ២០១៥-២០២០ ហិរញ្ញប្បទាន គាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា មានទំហំ ១៩៧,២លានដុល្លារអាមេរិក ជាមធ្យម ៣៣លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ដែលភាគច្រើនទទួលបានពីជប៉ុន អូស្ត្រាលី ធនាគារអភិវឌ្ឍន៍អាស៊ីបារាំង និងធនាគារពិភពលោក ក្នុងទំហំហិរញ្ញប្បទានប្រមាណ ៧៥% នៃហិរញ្ញប្បទានសរុបសម្រាប់វិស័យនេះ។

ជារួម ទន្ទឹមនឹងបញ្ហាប្រឈមពីវិបត្តិជំងឺកូវីដ-១៩ និងការសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដៃគូអភិវឌ្ឍន៍នៅតែបន្តបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដើម្បីគាំទ្រការអភិវឌ្ឍជាតិ រួមទាំងការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា។ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ, គ.ជ.នា/ក.អ.ក បន្តពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ដើម្បីកៀរគរ និងវិភាជធនធានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយ IDP។

ក្រៅពីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន ជាពិសេស វិស័យធនាគារក៏បានចូលរួមចំណែកអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា គួរឱ្យកត់សម្គាល់។ ចាប់ពីឆ្នាំ២០១៥-២០២០ ឥណទាននៃវិស័យធនាគារទៅកាន់វិស័យកម្មន្តសាលបានកើនឡើង ជាមធ្យម ៦,៦% ក្នុងមួយឆ្នាំ ជាមួយនឹងទំហំឥណទានសរុបប្រមាណ ៤១៧លានដុល្លារអាមេរិក ដែលបានជួយជំរុញកំណើនសកម្មភាពក្នុងវិស័យនេះ។

# ៨.ការវាយតម្លៃលើការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយ IDP

## ៨.១. របកគំហើញសំខាន់ៗពីការវិភាគលើការរៀបចំគោលនយោបាយ IDP

ការវិភាគបែបគុណវិស័យលើការរៀបចំគោលនយោបាយបានបង្ហាញឱ្យឃើញថា គោលនយោបាយ IDP ត្រូវបានតាក់តែងឡើងដោយមានទិសដៅ និងគោលបំណងច្បាស់លាស់ ក្នុងការឈានទៅសម្រេចបាននូវការផ្លាស់ប្តូរសំខាន់ៗដែលចាំបាច់ដើម្បីជំរុញកំណើនវិស័យឧស្សាហកម្មប្រកបដោយចីរភាព ប៉ុន្តែនៅតែចៀសមិនផុតពីកង្វះខាតមួយចំនួនតូច។ IDP បានដាក់ចេញនូវវិធានការគន្លឹះបួនដាក់ស្តែង ព្រមទាំងវិធានការគោលនយោបាយ និងផែនការសកម្មភាពចំនួន ១១៩ ផ្សេងទៀត សរុបទាំងអស់ចំនួន ១២៣ វិធានការ។ លទ្ធផលវិភាគលើខ្លឹមសារនៃវិធានការទាំងនេះ បានបង្ហាញឱ្យឃើញថា ក្នុងចំណោមវិធានការទាំង១២៣ មានវិធានការប្រមាណជាងពាក់កណ្តាល ផ្តោតសំខាន់លើអន្តរាគមន៍គោលនយោបាយចំនួន ៤ គឺ៖ (១) ការបង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម, (២) ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការភ្ជាប់, (៣) ការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម និង (៤) ការធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស។ អន្តរាគមន៍គោលនយោបាយទាំង ៤ នេះអាចចាត់ទុកជាបុរេលក្ខខណ្ឌចាំបាច់ មិនត្រឹមតែដើម្បីជំរុញការពង្រីកនិងការធ្វើពិពិធកម្មសកម្មភាពឧស្សាហកម្មនិងការនាំចេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស និងការបង្កើនការងារប្រកបដោយផលិតភាពនៅក្នុងសេដ្ឋកិច្ចផងដែរ។ យ៉ាងណាក្តី វិធានការមួយចំនួន នៅមិនទាន់គ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបនឹងបញ្ហាជាក់លាក់ក្នុងអន្តរាគមន៍គោលនយោបាយ នីមួយៗ។ ឧទាហរណ៍ វិធានការភាគច្រើនក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម" មានខ្លឹមសារផ្តោតសំខាន់តែទៅលើកិច្ចសម្រួលការវិនិយោគជាទូទៅ ខណៈដែលមានវិធានការតិចតួចប៉ុណ្ណោះផ្តោតការយកចិត្តទុកដាក់លើការទាក់ទាញការវិនិយោគចំគោលដៅ។

យោងតាមការវិភាគលើការរៀបចំវិធានការរបស់គោលនយោបាយ IDP, វិធានការភាគច្រើន (៨៥ ក្នុងចំណោម ១២៣) ត្រូវបានតាក់តែងឡើង ដោយមានមធ្យោបាយ ឬឧបករណ៍គោលនយោបាយជាក់លាក់សម្រាប់អនុវត្ត ដើម្បីជះឥទ្ធិពលលើឥរិយាបថរបស់តួអង្គសំខាន់ៗក្នុងសេដ្ឋកិច្ច និងអាចផ្តល់បច្ច័យបានភ្លាមៗ។ ឧទាហរណ៍ វិធានការមួយចំនួនដែលមានគោលបំណង "ផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិផល", "បញ្ចប់នូវគម្រោងកសាងស្ថានីយ៍ផលិតអគ្គិសនីតាមការគ្រោងទុក" និង "បង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេស" ជាដើម។ ដោយឡែក វិធានការមួយចំនួនទៀត (១៤) ហាក់ដូចជាមានខ្លឹមសារទូលាយ ដោយពុំបានចែងដាក់លាក់ពីមធ្យោបាយក្នុងការ

អនុវត្ត។ ករណីនេះមាននៅក្នុងវិធានការមួយចំនួនដូចជា "លើកទឹកចិត្តឱ្យសហគ្រាសធុនតូច និងមធ្យម ចុះបញ្ជី និងកាន់បញ្ជីគណនេយ្យ" និង "ជំរុញការផ្ទេរបច្ចេកវិទ្យាថ្មីៗក្នុងវិស័យកម្មន្តសាល" ជាដើម។ ប្រសិនបើមិនមានការសម្រេចវិធានការទាំងនេះដោយកំណត់ឱ្យបានច្បាស់លាស់នូវមធ្យោបាយ ឬឧបករណ៍ ជាក់លាក់នោះទេ, ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការទាំងនេះ នឹងជួបការលំបាកក្នុងការអនុវត្ត ហើយ ការវាស់វែងនូវបង្គោលចរសំខាន់ៗដែលត្រូវសម្រេចឱ្យបានក្នុងការអនុវត្តវិធានការក៏មានការលំបាក។ ក្រៅពី នោះ វិធានការមួយចំនួនទៀត (២៤) មានខ្លឹមសារត្រឹមតែជាសកម្មភាពត្រៀម ឬវិធានការត្រៀមតែ ប៉ុណ្ណោះ ដោយពុំមានជះឥទ្ធិពលភ្លាមៗដល់ការប្រែប្រួលណាមួយដែលគោលនយោបាយ IDP រំពឹងទុក នោះទេ។ ជាក់ស្តែងវិធានការគោលនយោបាយដូចជា "រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធ ឡូជីស្ទីក" និង "រៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម" គឺជា ឧទាហរណ៍នៃវិធានការដែលអាចចាត់ទុកថាត្រឹមតែជាវិធានការត្រៀម។ សម្រាប់បញ្ជីចំណាត់ថ្នាក់វិធានការ ដែលមានលក្ខណៈច្បាស់លាស់ មិនសូវច្បាស់លាស់ ឬត្រឹមជាវិធានការត្រៀម សូមមើលឧបសម្ព័ន្ធទី៣។

ខណៈដែលអន្តរាគមន៍គោលនយោបាយភាគច្រើនមានវិធានការគាំទ្រដែលមានលក្ខណៈច្បាស់លាស់ អន្តរាគមន៍គោលនយោបាយមួយចំនួនតូច មានវិធានការច្បាស់លាស់តិចតួច ឬមិនមានវិធានការច្បាស់លាស់ ទាល់តែសោះដែលអាចនាំឱ្យអន្តរាគមន៍គោលនយោបាយទាំងនោះ មិនអាចទទួលបានលទ្ធផលរំពឹងទុក នោះឡើយ។ ជាក់ស្តែង អន្តរាគមន៍គោលនយោបាយ "ពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុក និង សហគ្រាសបរទេស" មានវិធានការគោលនយោបាយចំនួន ៣ គឺៈ (១) សិក្សារៀបចំសួនឧស្សាហកម្ម សម្រាប់សហគ្រាសធុនតូច និងមធ្យម, (២) ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូច និង មធ្យម និង (៣) ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុកដើម្បីអាចផ្សារភ្ជាប់ និងទាញយក ផលប្រយោជន៍ពីសក្តានុពលសហគ្រាស និងវិនិយោគបរទេសធំៗ។ វិធានការទី១ និងទី២ ជាប្រភេទវិធានការ ត្រៀម ខណៈដែលវិធានការទី៣ ជាប្រភេទវិធានការមិនសូវច្បាស់លាស់ ព្រោះមិនបានបញ្ជាក់ពី មធ្យោបាយ ឬឧបករណ៍សម្រាប់ពង្រឹងសមត្ថភាពរបស់សហគ្រាសក្នុងស្រុក សម្រាប់ផ្សារភ្ជាប់ជាមួយ សហគ្រាសបរទេស។ វិធានការទាំង៣នេះ នឹងមិនអាចផ្តល់បច្ច័យភ្លាមៗ ឬដោយផ្ទាល់ដល់ការពង្រឹងការ តភ្ជាប់រវាងសហគ្រាសក្នុងស្រុក និងសហគ្រាសបរទេសបានឡើយ ។

របកគំហើញពីការវិភាគដ៏គួរឱ្យកត់សម្គាល់មួយទៀតគឺ គ្មានវិធានការគោលនយោបាយណាមួយ ដែលមានខ្លឹមសារជាក់លាក់ក្នុងការពង្រឹងភាពប្រកួតប្រជែងនៃឧស្សាហកម្មក្នុងស្រុក ដូចជាការបង្កើនការ ផលិតទំនិញជំនួសផលិតផលនាំចូល, ការពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក និងការបង្កើនភាពជាម្ចាស់របស់ សហគ្រាសក្នុងស្រុកក្នុងសកម្មភាពឧស្សាហកម្ម នោះឡើយ។ ចំពោះបញ្ហាកម្លាំងពលកម្មជំនាញ វិធានការ ភាគច្រើនយកចិត្តទុកដាក់ដោះស្រាយលើផ្នែកផ្គត់ផ្គង់ ដូចជាបញ្ហាកង្វះខាតអ្នកបច្ចេកទេស និងអ្នកជំនាញ

ប៉ុន្តែមិនមានអន្តរាគមន៍ទៅលើផ្នែកតម្រូវការ ដើម្បីលើកទឹកចិត្តឱ្យក្រុមហ៊ុនឧស្សាហកម្មជ្រើសរើសនិយោជិតកម្ពុជាបន្ថែមទៀតក្នុងដំណែងជាអ្នកគ្រប់គ្រង ឬអ្នកបច្ចេកទេស។

ជាចុងក្រោយ លទ្ធផលរំពឹងទុកនៃអន្តរាគមន៍គោលនយោបាយមួយចំនួន អាចនឹងមិនសម្រេចបានទាំងស្រុងដោយការអនុវត្តវិធានការមួយចំនួនដាច់តែឯងបាននោះទេ ប្រសិនបើគ្មានការរួមចំណែកពីការអនុវត្តវិធានការពាក់ព័ន្ធនឹងអន្តរាគមន៍គោលនយោបាយដទៃទៀត ដោយអន្តរាគមន៍គោលនយោបាយនីមួយៗ មានទំនាក់ទំនងបំពេញបន្ថែមឱ្យគ្នា ដើម្បីបង្កើនប្រសិទ្ធភាពជាអតិបរមា។ ឧទាហរណ៍សេណារីយ៉ូជោគជ័យនៃការបង្កើនសកម្មភាពវិនិយោគក្នុងវិស័យឧស្សាហកម្ម នឹងមិនអាចសម្រេចទៅបាន ដោយត្រឹមតែកិច្ចខិតខំប្រឹងប្រែងជំរុញការទាក់ទាញគម្រោងវិនិយោគជាទូទៅឡើយ ប៉ុន្តែតម្រូវឱ្យមានការលាយបញ្ចូលគ្នានៃអភិក្រមយុទ្ធសាស្ត្រ ដែលជំរុញគម្រោងវិនិយោគថ្មីៗនៅក្នុងឧស្សាហកម្មឈានមុខ ឬឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់, ជំរុញឱ្យសហគ្រាសប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មទំនើប និងបង្កើនការស្រាវជ្រាវឧស្សាហកម្ម និងនវានុវត្តន៍បន្ថែមទៀត។

## ៨.២. សង្ខេបវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ IDP

រូបភាពទី១៧៖ ការវាយតម្លៃជារួមលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ IDP




ការវាយតម្លៃជារួមលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ IDP អាចផ្តល់នូវព័ត៌មានសំខាន់ៗស្តីពីវឌ្ឍនភាព បង្ហាញអំពីបញ្ហាប្រឈម និងបច្ច័យដោយចេតនា និងអចេតនាដែលអាចកើតមានឡើងក្នុងពេលអនុវត្តគោលនយោបាយ ព្រមទាំងរំលេចនូវការប្រៀបធៀបរវាងផ្នែកផ្សេងៗ ឬកម្រិតនៃការចូលរួមអនុវត្តគោលនយោបាយ។ សូចនាករគោលចំនួន ៣ និងសូចនាករវឌ្ឍនភាពបន្ថែម ដែលបានកំណត់នៅក្នុងទម្រង់គំរូរបាយការណ៍ (RTF) ត្រូវបានយកមកប្រើប្រាស់ដើម្បីតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយនេះ។

ក្នុងចំណោមវិធានការទាំង ១២៣ មានវិធានការចំនួន ១១ ត្រូវបានកំណត់ជាសកម្មភាពពហុបំណង ដែលត្រូវបានចែកជា ២៦ អនុវិធានការ។ អនុវិធានការទាំងនេះ ត្រូវបានជ្រើសរើសយកមកប្រើប្រាស់ ដើម្បីធ្វើសាមញ្ញកម្មការវាយតម្លៃវិធានការដែលមានសកម្មភាពពហុបំណងទាំងនោះ។ សរុបជារួមវិធានការចម្បង និងអនុវិធានការចំនួន ១៣៨[៣] (វិធានការចំនួន ១ ពុំមានទិន្នន័យ)[៤] ត្រូវបានវិភាគ និងធ្វើ

[៣] វិធានការគោលនយោបាយចំនួន ៦ ពុំត្រូវបានចាត់ចូលក្នុងគោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយណាមួយឡើយ ដោយសារតែវិធានការទាំងនោះ ត្រូវបានកំណត់ជាវិធានការទូទៅ ដែលអាចជះឥទ្ធិពលដល់គោលបំណងទាំងអស់។ វិធានការទាំងនោះពាក់ព័ន្ធនឹងរដ្ឋបាលសារពើពន្ធទូទៅ, ការលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិនិយោគសាធារណៈសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម និងការពង្រឹងយន្តការត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងវិនិយោគ។

[៤] ក្រសួងផែនការដែលជាអ្នកទទួលខុសត្រូវអនុវត្តវិធានការចំនួន២ បានបញ្ជូនរបាយការណ៍ RTFមក ដែលមានព័ត៌មានអំពីវិធានការតែមួយប៉ុណ្ណោះ។ វិធានការដែលមានព័ត៌មានគឺ វិធានការ "ផ្តល់អាទិភាពខ្ពស់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ សម្រាប់សកម្មភាពគម្រោងនិងកម្មវិធីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម កន្សែង

ការវាយតម្លៃ។ ផ្អែកតាមការវាយតម្លៃ ក្នុងចំណោមវិធានការចម្បង និងអនុវិធានការចំនួន ១៣៨ មានវិធានការចំនួន ៧៧ (៥៦%) សម្រេចបានពេញលេញ, វិធានការចំនួន ២៨ (២០%) កំពុងអនុវត្ត, និងវិធានការចំនួន ៣២ (២៣%) យឺតយ៉ាវ។ វិធានការគោលនយោបាយដែលកំពុងអនុវត្ត និងយឺតយ៉ាវចាំបាច់ត្រូវជ្រើសរើស និងកំណត់អាទិភាពសម្រាប់ការអនុវត្តនៅដំណាក់កាលបន្ទាប់។

រូបភាពទី១៨៖ ការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ IDP ក្នុងគោលបំណងទាំង ៥




វឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ ពុំត្រូវបានអនុវត្តស្មើគ្នាឡើយ ដោយសារការដាក់ចេញវិធានការពុំស្មើគ្នាតាមគោលបំណងគោលនយោបាយនីមួយៗ។ គោលបំណងទី១ មានវិធានការសរុបចំនួន ២០ ក្នុងនោះមានវិធានការចំនួន ១០ សម្រេចបានពេញលេញ, វិធានការចំនួន ៣ កំពុងអនុវត្ត, និងវិធានការចំនួន ៧ យឺតយ៉ាវ។ គោលបំណងទី២ មានវិធានការសរុបចំនួន ២៨ ក្នុងនោះមានវិធានការចំនួន ១៤ សម្រេចបានពេញលេញ, វិធានការចំនួន ៩ កំពុងអនុវត្ត និងវិធានការចំនួន ៥ យឺតយ៉ាវ។ គោលបំណងទី៣ មានវិធានការសរុបចំនួន ៤២ ក្នុងនោះមានវិធានការចំនួន ១៦ សម្រេចបានពេញលេញ, វិធានការចំនួន ១២ កំពុងអនុវត្ត និងវិធានការចំនួន ១៤ យឺតយ៉ាវ។ គោលបំណងទី៤ មានវិធានការសរុបចំនួន ៣២ ក្នុងនោះមានវិធានការចំនួន ២៩ សម្រេចបានពេញលេញ, វិធានការចំនួន ២ កំពុងអនុវត្ត និងវិធានការចំនួន ១ យឺតយ៉ាវ។ គោលបំណងទី៥ មានវិធានការសរុបចំនួន ៨ ក្នុងនោះមានវិធានការចំនួន ៤ សម្រេចបានពេញលេញ, វិធានការចំនួន ២ កំពុងអនុវត្ត និងវិធានការចំនួន ២ យឺតយ៉ាវ។

ឧស្សាហកម្ម ឬរបៀងឧស្សាហកម្ម”។ ដោយឡែកវិធានការដែលពុំមានព័ត៌មានគឺ ជំរុញការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងយន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ការវាយតម្លៃនេះ បង្ហាញឱ្យឃើញថា គោលបំណងទី៤ គឺជាគោលបំណងដែលមានវិធានការសម្រេចពេញលេញច្រើនជាងគេ ខណៈដែលគោលបំណងទី៣ គឺជាគោលបំណងដែលមានវិធានការនៅមានភាពយឺតយ៉ាវច្រើនជាងគេ (១៤ វិធានការ)។ វិធានការយឺតយ៉ាវភាគច្រើន ក្នុងគោលបំណងទី៣ គឺជាវិធានការដែលស្ថិតក្នុងអន្តរាគមន៍គោលនយោបាយ ៣.៣ "ការធ្វើឱ្យមានតុល្យភាពឡើងវិញរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូចនិងមធ្យម", ៣.៤ "បង្កើននវានុវត្តន៍ឧស្សាហកម្ម", និង ៣.៥ "បង្កើនការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម"។ បញ្ហាប្រឈមចម្បងដែលរាំងស្ទះដល់វឌ្ឍនភាពនៃការអនុវត្តវិធានការក្នុងគោលបំណងទី៣នេះ គឺ កង្វះធនធានមនុស្សដែលមានសមត្ថភាព និងថវិកាសម្រាប់ការអនុវត្តនៅមានកម្រិតនៅឡើយ។ សម្រាប់ដំណាក់កាលបន្ទាប់នៃការអនុវត្តគោលនយោបាយ IDP ការពន្លឿនការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងនវានុវត្តន៍ឧស្សាហកម្ម គួរត្រូវបានយកចិត្តទុកដាក់ជាងមុន ដោយសារវិស័យទាំងនេះ អាចចូលរួមចំណែកយ៉ាងសម្បើមសម្រាប់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានភាពធន់នឹងវិបត្តិ។

លំអានទូទៅដែលបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការអនុវត្តវិធានការគោលនយោបាយរួមមាន៖ ១) វិធានការដែលត្រូវការការសម្របសម្រួលច្រើនរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន, ២) វិធានការដែលត្រូវការថវិកា និងធនធានមនុស្សដែលមានសមត្ថភាព និង ៣) វិធានការដែលត្រូវការពេលវេលាដើម្បីធ្វើការស្រាវជ្រាវបន្ថែម ដោយសារជាវិធានការថ្មីក្នុងបរិបទកម្ពុជា។

ជារួម វិធានការជាងពាក់កណ្តាល ត្រូវបានអនុវត្តបានពេញលេញទាន់ពេលវេលា ដែលតួលេខនេះបង្ហាញថា ការអនុវត្តគោលនយោបាយ IDP ក្នុងរយៈពេល ៥ឆ្នាំដំបូងកន្លងទៅនេះ មានវឌ្ឍនភាពល្អប្រសើរតាមកាលកំណត់។ ចំណែកឯវិធានការដែលនៅសល់ពាក់កណ្តាលទៀត នៅតែអាចត្រូវបានបន្តអនុវត្តឱ្យបានពេញលេញក្នុងរយៈពេល៥ឆ្នាំបន្ទាប់។ ការរៀបចំផែនការសកម្មភាពឱ្យបានច្បាស់លាស់ និងការកំណត់តួនាទីភារកិច្ចទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធដោយមានថវិកាអនុវត្តគ្រប់គ្រាន់ និងធនធានមនុស្សដែលមានសមត្ថភាព គឺជាកត្តាសំខាន់ដើម្បីពង្រឹងការអនុវត្តវិធានការគោលនយោបាយ។ ក្នុងនោះដែរ មានជម្រើស ២ ដែលអាចផ្តល់លទ្ធផលល្អប្រសើរដល់វឌ្ឍនភាព និងសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP រួមមាន៖ ១) ការធ្វើឱ្យប្រសើរឡើងនូវសូចនាករគោលដែលបង្ហាញពីដំណាក់កាលនីមួយៗនៃការអនុវត្ត និងសូចនាករវឌ្ឍនភាពបន្ថែមដែលអាចវាយតម្លៃពីកម្រិតនៃបច្ច័យ និងវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ ដែលបានកំណត់នៅក្នុងទម្រង់គំរូរបាយការណ៍ (RTF) និង ២) ការរៀបចំផែនការសកម្មភាពគ្រប់ជ្រុងជ្រោយមួយ ដែលតម្រូវឱ្យមានការអនុម័តពីរាជរដ្ឋាភិបាល។

# ៥.សមិទ្ធផលរំពឹងទុក និងអនុសាសន៍គោលនយោបាយ

ជំពូកមុននៃរបាយការណ៍នេះ បានវិភាគពីសមិទ្ធកម្មរបស់កម្ពុជា ក្នុងការអនុវត្តគោលនយោបាយ IDP នៅដំណាក់កាលដំបូង ដោយប្រើប្រាស់ឧបករណ៍ចម្បងនៃប្រព័ន្ធតាមដាន និងវាយតម្លៃ ដើម្បីកំណត់និងដោះស្រាយបញ្ហាប្រឈមនានា។ ជំពូកនេះនឹងពិនិត្យលើការពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត IDP តាមផ្នែកផ្សេងៗ ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់ IDP។

## ៥.១. សមិទ្ធផលរំពឹងទុករបស់គោលដៅ IDP

ដើម្បីសម្រេចចក្ខុវិស័យ រាជរដ្ឋាភិបាលកំណត់យកគោលដៅចម្បង៣ ដែលឆ្លុះបញ្ចាំងតាមរយៈការប្រែប្រួលរចនាសម្ព័ន្ធ និងសូចនាករគន្លឹះ ដូចខាងក្រោម៖

- **អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. (គោលដៅ ២៨% ឆ្នាំ២០២០ និង៣០% ឆ្នាំ២០២៥)**

អនុបាតបានកើនឡើងយ៉ាងឆាប់រហ័សពី ២៤,១%នៅឆ្នាំ២០១៣ ទៅ ២៧,៧% នៅឆ្នាំ២០១៥ រហូតដល់៣៤,២% នៅឆ្នាំ២០១៩ ជាមួយនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំប្រមាណ ១,៦% ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ដែលបានធ្វើឱ្យសូចនាករនេះសម្រេចគោលដៅមុនផែនការដែលបានគ្រោងទុក។ ជាក់ស្តែង គោលដៅអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. ចំនួន៣០% នៅឆ្នាំ២០២៥ សម្រេចបានតាំងពីឆ្នាំ២០១៩ មកម្ល៉េះ (៣៤,២%) ហើយប្រសិនបើអត្រាកំណើននេះនៅតែបន្តរហូតដល់ឆ្នាំ២០២៥ អនុបាតនឹងកើនដល់៤០%។

យ៉ាងណាមិញ បទពិសោធន៍អន្តរជាតិបង្ហាញថា អត្រាកំណើនខ្ពស់មិនអាចបន្តនិរន្តភាពក្នុងរយៈពេលវែងបានទេ ហើយនឹងថមថយទៅវិញ។ ក្នុងចំណោមបណ្តាប្រទេសប្រៀបធៀប ប្រទេសថៃជាប្រទេសដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកម្ពុជាជាងគេ ដែលនៅឆ្នាំមូលដ្ឋាន ផ.ស.ស. សម្រាប់មនុស្សម្នាក់ (ថៃ ៩២៩ដុល្លារអាមេរិក កម្ពុជា ៩២៣ដុល្លារអាមេរិក) និងអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. (ថៃ ២៥,៣% កម្ពុជា ២៤,១%) មានកម្រិតប្រហាក់ប្រហែលនឹងកម្ពុជា ប៉ុន្តែថៃអាចបង្កើនអនុបាតនេះត្រឹមកំណើន ៤,២%ប៉ុណ្ណោះ ក្នុងរយៈពេល១២ឆ្នាំ ពីឆ្នាំមូលដ្ឋាន (ឆ្នាំមូលដ្ឋាន ២៥,៣% ឆ្នាំគោលដៅ ២៩,៥%)។ សូម្បីតែប្រទេសកូរ៉េដែលបានចាប់ផ្តើមពីអនុបាតឧស្សាហកម្មក្នុង ផ.ស.ស. ទាបត្រឹម ១៧,៣% នៅឆ្នាំមូលដ្ឋានអាចធ្វើឱ្យអនុបាតនេះកើនឡើងត្រឹម ៧,៥% ប៉ុណ្ណោះក្នុងរយៈពេល១២ឆ្នាំ។ ដោយសារអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. របស់កម្ពុជាបានកើនឡើងប្រមាណ ១០% រួចទៅ

ហើយពី ២៤,១% នៅឆ្នាំ២០១៣ ដល់ ៣៤,២% នៅឆ្នាំ២០១៩ យើងពិតជាពិបាករំពឹងថាអត្រាកំណើននេះអាចរក្សាបានរហូតដល់ឆ្នាំ២០២៥។

មួយវិញទៀត ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ មកលើវិស័យសេវាកម្មក៏ជាកត្តាដែលបានធ្វើឱ្យអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. មានការកើនឡើងក្នុងរយៈពេលខ្លី ប៉ុន្តែនឹងថយចុះវិញនៅពេលដែលការរីករាលដាលនៃជំងឺឆ្លងនេះមានភាពស្រាកស្រាន្តដែលនឹងធ្វើឱ្យវិស័យសេវាកម្មងើបឡើងវិញ។

តារាងទី៧៖ បម្រែបម្រួលអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. នៃប្រទេសមួយចំនួន

| | ឆ្នាំមូលដ្ឋាន | ឆ្នាំគោលដៅ | ផ.ស.ស. សម្រាប់មនុស្សម្នាក់នៅឆ្នាំមូលដ្ឋាន គិតជាដុល្លារអាមេរិក | អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. គិតជាភាគរយ (%) | | |
|---|---|---|---|---|---|---|
| | | | | ឆ្នាំមូលដ្ឋាន | ឆ្នាំគោលដៅ | បម្រែបម្រួល |
| កម្ពុជា | ២០១៣ | ២០២៥ | ៩២៣ | ២៤,១ | | |
| ថៃ | ១៩៧០ | ១៩៨២ | ៩២៩ | ២៥,៣ | ២៩,៥ | ៤,២ |
| វៀតណាម | ២០០៣ | ២០១៥ | ៨៩៧ | ៣៩,៥ | ៣៣,៣ | -៦,២ |
| ឡាវ | ២០០៦ | ២០១៨ | ៩០១ | ២៦,២ | ៣១,៥ | ៥,៤ |
| កូរ៉េ | ១៩៦០ | ១៩៧២ | ៩៣២ | ១៧,៣ | ២៤,៩ | ៧,៥ |
| ចិន | ១៩៩២ | ២០០៤ | ៨៨៧ | ៤៣,១ | ៤៥,៩ | ២,៨ |

ប្រភពទិន្នន័យ៖ WDI

- អនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. (គោលដៅ ១៨% ឆ្នាំ២០២០ និង២០% ឆ្នាំ២០២៥)

អនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. បានកើនឡើងតិចតួចពី ១៥,៥% នៅឆ្នាំ២០១៣ ទៅ ១៦% នៅឆ្នាំ២០១៥ ដល់ ១៦,៣% នៅឆ្នាំ២០១៩ ជាមួយនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ប្រមាណ ០,២% ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩។ អត្រាកំណើននេះមានកម្រិតតិចតួចបើប្រៀបធៀបនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំរបស់អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. ដែលបង្ហាញថាការរីកដុះដាលនៃវិស័យឧស្សាហកម្មប៉ុន្មានឆ្នាំចុងក្រោយនេះ កើតចេញពីការចូលរួមរបស់វិស័យឧស្សាហកម្មមិនមែនកម្មន្តសាល ដូចជា វិស័យសំណង់ជាដើម។ ប្រសិនបើនិន្នាការនៃកំណើននេះនៅតែបន្ត វិស័យកម្មន្តសាលរបស់កម្ពុជានឹងរួមចំណែកត្រឹមប្រមាណ ១៦,៧% ក្នុងផ.ស.ស. នៅឆ្នាំ២០២៥ គឺស្ថិតក្នុងកម្រិតទាបជាងគោលដៅដែលមានអត្រា២០%។

ធៀបជាមួយប្រទេសដទៃទៀត នៅឆ្នាំ១៩៧០ប្រទេសថៃមានទាំង ផ.ស.ស. សម្រាប់មនុស្សម្នាក់ និងអនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. ប្រហាក់ប្រហែលនឹងកម្ពុជានៅឆ្នាំ២០១៣។ អនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. របស់ប្រទេសថៃមានកំណើន ៥,៤% ក្នុងរយៈពេល១២ឆ្នាំ ខណៈប្រទេសកូរ៉េដែលបានចាប់ផ្តើមនៅឆ្នាំ១៩៦០ ជាឆ្នាំមូលដ្ឋាន សម្រេចបានកំណើនខ្ពស់ជាងគេក្នុងចំណោមប្រទេសប្រៀបធៀបទាំងអស់គឺ ៧,៣% ក្នុងរយៈពេលដូចគ្នា។

ខណៈការរៀនសូត្រពីគោលនយោបាយឧស្សាហកម្មកូរ៉េនៅទសវត្សរ៍ទី៦០ និង៧០ ហាក់មិនសូវសមស្របទៅនឹងបរិការណ៍របស់កម្ពុជានាពេលបច្ចុប្បន្ន ការស្វែងយល់ឱ្យស៊ីជម្រៅពីប្រទេសថៃនៅក្នុងទសវត្សរ៍ទី៧០ និង៨០ នឹងផ្តល់អត្ថប្រយោជន៍ច្រើនដល់កម្ពុជា។ បើទោះជាអ្វីដែលថៃបានប្រឈមក្នុងទសវត្សរ៍ទី៧០ និង៨០ ក្នុងក្របខណ្ឌសេដ្ឋកិច្ចសកល និងភូមិសាស្ត្រនយោបាយ ខុសពីអ្វីដែលកម្ពុជាកំពុងជួបប្រទះនាពេលបច្ចុប្បន្នក៏ដោយ ជាពិសេសកត្តាដែលកម្ពុជាកំពុងមានកាតព្វកិច្ចអន្តរជាតិក្រោមកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី ការសិក្សាបន្ថែមពីអ្វីដែលប្រទេសថៃធ្វើបានត្រឹមត្រូវក្នុងទសវត្សរ៍នោះនឹងផ្តល់ប្រយោជន៍ដល់កម្ពុជាដើម្បីរៀនសូត្រពីភាពជោគជ័យទាំងនោះ។

តារាងទី៨៖ បម្រែបម្រួលអនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. នៃប្រទេសមួយចំនួន

| | ឆ្នាំមូលដ្ឋាន | ឆ្នាំគោលដៅ | ផ.ស.ស. សម្រាប់មនុស្សម្នាក់ក្នុងឆ្នាំមូលដ្ឋាន គិតជាដុល្លារអាមេរិក | អនុបាតវិស័យកម្មន្តសាលក្នុងផ.ស.ស. គិតជាភាគរយ (%) | | |
|---|---|---|---|---|---|---|
| | | | | ឆ្នាំមូលដ្ឋាន | ឆ្នាំ គោលដៅ | បម្រែ បម្រួល |
| កម្ពុជា | ២០១៣ | ២០២៥ | ៩២៣ | ១៥,៥ | | |
| ថៃ | ១៩៧០ | ១៩៨២ | ៩២៩ | ១៥,៩ | ២១,៣ | ៥,៤ |
| វៀតណាម | ២០០៣ | ២០១៥ | ៨៩៧ | ២០,៣ | ១៣,៧ | -៦,៦ |
| ឡាវ | ២០០៦ | ២០១៨ | ៩០១ | ៩,៥ | ៧,៥ | -២,០ |
| កូរ៉េ | ១៩៦០ | ១៩៧២ | ៩៣២ | ១១,៤ | ១៨,៧ | ៧,៣ |

ប្រភពទិន្នន័យ៖ WDI

- **ការនាំចេញកសិផលកែច្នៃ (គោលដៅ ១០% ឆ្នាំ២០២០ និង ១២% ឆ្នាំ២០២៥)**

ចំណែកនៃការនាំចេញកសិផលកែច្នៃ មិនត្រឹមតែគ្មានការកើនឡើងនោះទេ ប៉ុន្តែបានថមថយជាបន្តបន្ទាប់ពី ៥,៨% នៅឆ្នាំ២០១៥ ដល់ ៤,៩% នៅឆ្នាំ២០២០ ដែលធ្វើឱ្យការសម្រេចបានគោលដៅ ១២% នៅឆ្នាំ២០២៥ មានភាពមិនប្រាកដប្រជាយ៉ាងខ្លាំង។ ផ្ទុយពីអនុបាត តម្លៃដាច់ខាតនៃការនាំចេញកសិផលកែច្នៃបានកើនឡើងជាបន្តបន្ទាប់ពី ៥១៦លានដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដល់ ៨៤៦លានដុល្លារអាមេរិក នៅឆ្នាំ២០២០ ស្មើនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំចំនួន ១៣% ខ្ពស់ជាងបណ្តាប្រទេស

ជិតខាង ដែលថៃសម្រេចបានអត្រាកំណើនមធ្យមប្រចាំឆ្នាំត្រឹមតែ ៥% ហើយវៀតណាមសម្រេចបានត្រឹម ៩% ក្នុងអំឡុងពេលដូចគ្នា។

- **ការនាំចេញទំនិញកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង (គោលដៅ ១០% ឆ្នាំ២០២០ និង ១៥% ឆ្នាំ ២០២៥)**

ការនាំចេញទំនិញកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង បានកើនឡើងជាបន្តបន្ទាប់ពី ៥% នៅឆ្នាំ២០១៣ ទៅ៥,៦% នៅឆ្នាំ២០១៥ រហូតដល់ ១៥,៥% នៅឆ្នាំ២០២០ សម្រេចបានលើសគោលដៅដែលកំណត់ត្រឹម ១៥% នៅឆ្នាំ២០២៥។

ក្នុងការគណនាទំនិញកម្មន្តសាលសម្លៀកបំពាក់និងស្បែកជើងនៅក្នុងរបាយការណ៍នេះ ក៏បានរាប់បញ្ចូលទំនិញសម្រាប់ការធ្វើដំណើរផងដែរ ព្រោះទំនិញទាំងនេះប្រើប្រាស់បច្ចេកវិទ្យា ខ្សែច្រវាក់ផលិតកម្ម និងកម្រិតជំនាញប្រហាក់ប្រហែលគ្នានឹងទំនិញកម្មន្តសាលសម្លៀកបំពាក់និងស្បែកជើង។ ប្រសិនបើការនាំចេញទំនិញសម្រាប់ការធ្វើដំណើរត្រូវបានរាប់បញ្ចូលក្នុងកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើងដែរនោះ ការនាំចេញទំនិញកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើងនឹងត្រូវកើនឡើងដល់ ២១,១% នៃការនាំចេញសរុបនៅឆ្នាំ២០២០ ដែលបង្ហាញពីការធ្វើពិពិធកម្មមុខទំនិញនាំចេញបានយ៉ាងឆាប់រហ័ស។

- **អត្រាក្រុមហ៊ុនផ្លូវការបានចុះបញ្ជី (គោលដៅ៖សហគ្រាសធុនតូច ៧០% ឆ្នាំ២០២០ និង ៨០% ឆ្នាំ២០២៥, សហគ្រាសធុនមធ្យម ៨០% ឆ្នាំ២០២០ និង ៩៥% ឆ្នាំ២០២៥)**

តាមទិន្នន័យទទួលបានពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អត្រាចុះបញ្ជីផ្លូវការសហគ្រាសធុនតូចបានធ្លាក់ចុះពី៦៤,៤% នៅឆ្នាំ២០១៥ មកត្រឹម ៤៩,៧% នៅឆ្នាំ២០១៩ ដែលធ្វើឱ្យការសម្រេចបានអត្រា៨០% នៅឆ្នាំ២០២៥ ពិបាកនឹងសម្រេចបាន បើទោះបីរាជរដ្ឋាភិបាលបានដាក់ចេញវិធានការមួយចំនួនដូចជាអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព និងការដាក់ចេញនូវបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច ជាដើមក្តី។ ក្នុងបរិការណ៍នេះ ការបញ្ចប់ឱ្យបានឆាប់រហ័សនូវសេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមមានភាពចាំបាច់ណាស់។

ចំណែកអត្រាចុះបញ្ជីផ្លូវការសហគ្រាសធុនមធ្យមមានចំនួន ៨៣,១% នៅឆ្នាំ២០១៥ និងបានហក់ឡើងដល់៨៧% នៅឆ្នាំ២០១៩ ដែលតួលេខនេះលើសគោលដៅសម្រាប់ឆ្នាំ២០២០ ដែលកំណត់ត្រឹម ៨០% តាំងពីមុនការចាប់ផ្តើមអនុវត្តគោលនយោបាយ IDP ទៅទៀត។ ប្រសិនបើនិន្នាការបច្ចុប្បន្ននៅតែបន្ត អត្រានេះនឹងកើនដល់ប្រមាណ៩៣% នៅឆ្នាំ២០២៥ ទាបជាងគោលដៅសម្រាប់ឆ្នាំ២០២៥ បន្តិច

ដែលបង្ហាញពីតម្រូវការនៃការដាក់ចេញនូវវិធានការនិងគោលនយោបាយបន្ថែមទៀតដើម្បីសម្រេចឱ្យបានអត្រាដែលបានកំណត់សម្រាប់ឆ្នាំ២០២៥ ។

- អត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យសាមញ្ញ (គោលដៅ៖សហគ្រាសធុនតូច ៣០% ឆ្នាំ២០២០ និង ៥០% ឆ្នាំ២០២៥, សហគ្រាសធុនមធ្យម ៥០% ឆ្នាំ២០២០ និង ៧០% ឆ្នាំ២០២៥)

យោងតាមទិន្នន័យទទួលបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យសាមញ្ញ បានកើនឡើងពី១៣% នៅឆ្នាំ២០១៦ ដល់ ១៨,៥៣% នៅឆ្នាំ២០២០ ប៉ុន្តែទាបជាងអត្រាគោលដៅដែលកំណត់ត្រឹម ៣០% នៅឆ្នាំ២០២០ ហើយនៅឆ្ងាយពីគោលដៅ ៥០% នៅឆ្នាំ២០២៥ ។

អត្រាសហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ បានកើនពី ៣៤,៨៤% នៅឆ្នាំ២០១៦ ដល់ ៣៨,៦៩% នៅឆ្នាំ២០២០ ដែលអត្រានេះទាបជាងអត្រាគោលដៅដែលកំណត់ត្រឹម ៥០% នៅឆ្នាំ ២០២០ ហើយនៅឆ្ងាយពីគោលដៅ ៧០% នៅឆ្នាំ២០២៥។

ផ្អែកលើសមិទ្ធកម្មនៃសូចនាករគន្លឹះខាងលើ រាជរដ្ឋាភិបាលអាចពិចារណាកំណត់អត្រាគោលដៅថ្មីសម្រាប់សូចនាករទាំងឡាយណាដែលសម្រេចបានអត្រាគោលដៅឆ្នាំ២០២៥ មុនពេលកំណត់ និងសូចនាករទាំងឡាយណាដែលលទ្ធភាពក្នុងការសម្រេចបានហាក់នៅឆ្ងាយពីគោលដៅ។

## ៩.២. អនុសាសន៍សម្រាប់ពង្រឹងការអនុវត្តវិធានការគោលនយោបាយ

ការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព គឺជាកត្តាសំខាន់ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់គោលនយោបាយ IDP។ តាមរយៈមេរៀន បទពិសោធន៍ និងលទ្ធផលដែលទទួលបានពីការវាយតម្លៃពាក់កណ្តាលអាណត្តិនេះ យើងបានរកឃើញបញ្ហាប្រឈមរួមដែលបានធ្វើឱ្យរាំងស្ទះដល់ការអនុវត្តប្រកបដោយជោគជ័យនៃវិធានការគោលនយោបាយ IDP រួមមាន៖ (១) ការយល់ដឹងអំពីចក្ខុវិស័យ និងគោលបំណងរបស់គោលនយោបាយ IDP ពីសំណាក់ភាគីពាក់ព័ន្ធនៅមានកម្រិត (២) ការសម្របសម្រួលរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជននៅមានភាពខ្វះខាត (៣) កង្វះថវិកា និងធនធានមនុស្ស និង (៤) តម្រូវការនូវពេលវេលាបន្ថែមដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីវិធានការគោលនយោបាយដែលបានដាក់ចេញ ដោយសារវិធានការមួយចំនួននៅថ្មីនៅឡើយសម្រាប់បរិបទកម្ពុជា។ ជាមួយគ្នានេះ តាមរយៈការវាយតម្លៃពាក់កណ្តាលអាណត្តិ ចំណុចមួយចំនួនគួរមានការបញ្ជាក់ឱ្យបានច្បាស់លាស់ដើម្បីបង្កើនប្រសិទ្ធភាពសម្រាប់ការអនុវត្តនៅដំណាក់កាលបន្ទាប់។ ចំណុចទាំងនោះរួមមាន ការកំណត់ឧបករណ៍គោល

នយោបាយឱ្យបានជាក់លាក់ ការកម្រិតអំពីវិសាលភាពរបស់វិធានការដែលដាក់ចេញ និងការលុបចេញនូវវិធានការដែលស្ទួនគ្នា។

ដើម្បីធានាភាពជោគជ័យនៃការអនុវត្តវិធានការគោលនយោបាយ IDP ក្នុងដំណាក់កាលបន្ទាប់ ឆ្នាំ ២០២២-២០២៥ អនុសាសន៍មួយចំនួនដូចខាងក្រោមគួរត្រូវបានយកមកពិចារណា៖

### ៥.២.១. ការបញ្ជ្រាបអំពីចក្ខុវិស័យ និងគោលបំណងគោលនយោបាយជូនគ្រប់ភាគីពាក់ព័ន្ធ

ការយល់ដឹងឱ្យបានស៊ីជម្រៅអំពីចក្ខុវិស័យ និងគោលបំណងគោលនយោបាយ IDP មានសារៈសំខាន់ណាស់សម្រាប់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេសសម្រាប់ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវអនុវត្តគោលនយោបាយនេះ។ លើសពីនេះ វឌ្ឍនភាព បទពិសោធន៍ និងបញ្ហាប្រឈមនៃការសម្របសម្រួល និងការអនុវត្តគោលនយោបាយ ក៏គួរតែត្រូវបានចែករំលែកផងដែរ។ ដូចនេះ ការផ្សព្វផ្សាយអំពីចក្ខុវិស័យ និងគោលបំណងរបស់ IDP តាមរយៈការធ្វើសិក្ខាសាលានិងវគ្គបណ្តុះបណ្តាល គួរត្រូវបានរៀបចំឡើងជាប្រចាំ ដើម្បីឱ្យក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្តយល់ដឹងច្បាស់លាស់ពីគោលនយោបាយ។

### ៥.២.២. ការបង្កើតយន្តការដើម្បីធានាបាននូវការអនុវត្តប្រកបដោយចីរភាពនិងប្រសិទ្ធភាព

ដើម្បីធានាឱ្យការអនុវត្តគោលនយោបាយ IDP មានភាពរលូននិងប្រកបដោយប្រសិទ្ធភាព ក្រុមការងារទទួលបន្ទុកអនុវត្តគោលនយោបាយ IDP នៃក្រសួង ស្ថាប័នពាក់ព័ន្ធគួរមានមន្ត្រីបង្គោលច្បាស់លាស់ទទួលបន្ទុកកិច្ចការនេះ។ ក្នុងករណីមានការផ្លាស់ប្តូរមន្ត្រីបង្គោល គួរផ្តល់ព័ត៌មានមកលេខាធិការដ្ឋាន IDP នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយភ្ជាប់មកជាមួយនូវឈ្មោះ តួនាទី និងលេខទំនាក់ទំនងរបស់មន្ត្រីបង្គោលថ្មី។ មន្ត្រីបង្គោលថ្មីក៏ត្រូវទទួលបាននូវការចែករំលែកព័ត៌មាន វឌ្ឍនភាព និងកិច្ចការចាំបាច់ដទៃទៀតក្នុងការអនុវត្ត IDP នាពេលកន្លងមកក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នខ្លួនពីមន្ត្រីបង្គោលចាស់ដែលបានផ្លាស់ចេញផងដែរ។

### ៥.២.៣. ការកំណត់លទ្ធផលរំពឹងទុកនៅក្នុងផែនការសកម្មភាព

ការបង្កើតផែនការសកម្មភាពដែលមានលទ្ធផលរំពឹងទុកច្បាស់លាស់ មានសារៈសំខាន់ណាស់សម្រាប់ធ្វើឱ្យការអនុវត្តវិធានការគោលនយោបាយមានភាពរលូន និងប្រកបដោយប្រសិទ្ធភាព។ ក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ដំណាក់កាលទី២ នៃការអនុវត្តគោលនយោបាយ IDP មានជម្រើស២

ដែលគួរពិចារណា៖ (១) ការធ្វើឱ្យប្រសើរឡើងនូវសូចនាករគោល និងសូចនាករវឌ្ឍនភាពបន្ថែមដែលមានស្រាប់ក្នុងទម្រង់គំរូរបាយការណ៍ (RTF) ដើម្បីធានាឱ្យបាននូវភាពពាក់ព័ន្ធគ្នា និងភាពអាចសម្រេចបាន និង (២) ការរៀបចំផែនការសកម្មភាពពេញលេញ ដោយប្រើអភិក្រមរដ្ឋាភិបាលទាំងមូល (Whole-government approach) ដែលទាមទារនូវការសម្របសម្រួលកម្រិតនយោបាយខ្ពស់ ដែលជាទូទៅកិច្ចការសម្របសម្រួលអន្តរស្ថាប័នគឺជាបញ្ហាចម្បងក្នុងការអនុវត្តគោលនយោបាយក្រោមក្របខណ្ឌអន្តរស្ថាប័ន។ យ៉ាងណាមិញ ការកំណត់ស្ថាប័នទទួលបន្ទុកឱ្យច្បាស់លាស់ និងសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) គួរតែជាយុថ្កាសម្រាប់ការអនុវត្តផែនការសកម្មភាព។ សម្រាប់គំរូផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ សូមមើលឧបសម្ព័ន្ធទី២។

### ៥.២.៤. ការកំណត់ឧបករណ៍គោលនយោបាយជាក់លាក់ដែលមានវិសាលភាពសមស្រប

ការកំណត់ឧបករណ៍គោលនយោបាយច្បាស់លាស់ និងជាក់លាក់ អាចជួយពង្រឹងការអនុវត្តវិធានការគោលនយោបាយ។ ក្នុងចំណោមវិធានការទាំង ១២៣ ដែលបានដាក់ចេញដោយ IDP វិធានការចំនួន៨៥ (៦៩,១១%) មានភាពច្បាស់លាស់, ២៤ វិធានការ (១៩,៥១%) មានលក្ខណៈជាសកម្មភាពត្រៀម និង ១៤ វិធានការទៀត (១១,៣៨%) មានភាពមិនច្បាស់លាស់។ ឯកសារត្រួតពិនិត្យនិងវាយតម្លៃការពង្រឹងគុណភាពគោលនយោបាយឧស្សាហកម្ម (EQuIP) ដែលបង្កើតឡើងដោយអង្គការ UNIDO សហការជាមួយ អង្គការ GIZ នឹងជួយឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធយល់កាន់តែច្បាស់អំពីអត្ថន័យ និងភាពពាក់ព័ន្ធរបស់វិធានការ និងជំរុញការចូលរួមក្នុងការអនុវត្តគោលនយោបាយ (សូមមើលឧបសម្ព័ន្ធទី២)។

តាមរយៈការវាយតម្លៃ វិធានការគោលនយោបាយមួយចំនួនមានលក្ខណៈទូលំទូលាយ ដែលជាពហុបំណងនិងសកម្មភាព ហើយវិធានការមួយចំនួនស្ទួនគ្នានៅក្រោមយុទ្ធសាស្ត្រគន្លឹះតែមួយ។ វិធានការដែលមានវិសាលភាពធំទូលាយគួរត្រូវធ្វើការពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីញែកទៅជាអនុវិធានការ ឬបំបែកទៅជាវិធានការដាច់ដោយឡែកពីគ្នា ដែលដឹកនាំអនុវត្តដោយក្រសួងជាក់លាក់ណាមួយ។ វិធានការដែលស្ទួនគួរតែលុបចោល ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្ត។ បញ្ជីវិធានការដែលមានវិសាលភាពទូលំទូលាយ និងស្ទួនគ្នាមាននៅក្នុងឧបសម្ព័ន្ធទី២។

### ៥.២.៥.ទិសដៅបន្តសម្រាប់ពង្រឹងការអនុវត្តវិធានការគោលនយោបាយដែលមិនទាន់បានសម្រេចពេញលេញ

ការពង្រឹងការអនុវត្តវិធានការគោលនយោបាយដែលមិនទាន់បានសម្រេចពេញលេញ មានសារៈសំខាន់ណាស់។ វិធានការគោលនយោបាយដែលកំពុងអនុវត្ត និងមានភាពយឺតយ៉ាវ ចាំបាច់ត្រូវតែប្រមូល

ផ្តុំនិងកំណត់អាទិភាព សម្រាប់អនុវត្តនៅដំណាក់កាលបន្ទាប់។ វិធានការដែលកំពុងអនុវត្តដែលត្រូវប្រមូលផ្តុំ គឺជាវិធានការដែលនឹងផ្តល់បច្ច័យវិជ្ជមានក្នុងរយៈពេលខ្លីទៅមធ្យម រួមមានវិធានការដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយ ២.១ "**សមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក**", អន្តរាគមន៍គោលនយោបាយ ២.២ "**កែលម្អហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនិងការតភ្ជាប់**" និងអន្តរាគមន៍គោលនយោបាយ ៣.៣ "**ការធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូចនិងមធ្យម**"។ ជាមួយគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងនិងការផ្តល់នូវធនធានបន្ថែម គឺជាតម្រូវការជាចាំបាច់ដើម្បីពង្រឹងការអនុវត្តវិធានការដែលមានភាពយឺតយ៉ាវ។ វិធានការដែលមានភាពយឺតយ៉ាវដែលត្រូវផ្តល់អាទិភាព គឺជាវិធានការដែលពុំមានសូចនាករគោលណាមួយត្រូវបានសម្រេចពេញលេញ, ហួសពេលកំណត់, និងវិធានការទាំងឡាយដែលជះឥទ្ធិពលសំខាន់ទៅលើអន្តរាគមន៍គោលនយោបាយក្នុងរយៈពេលខ្លីទៅមធ្យម។ សម្រាប់បញ្ជីវិធានការគោលនយោបាយអាទិភាពដែលកំពុងអនុវត្ត និងមានភាពយឺតយ៉ាវ សូមមើលក្នុងឧបសម្ព័ន្ធទី២។

## ៥.៣.អនុសាសន៍សម្រាប់ការកែសម្រួលវិធានការគោលនយោបាយ និងអន្តរាគមន៍គោលនយោបាយ

តាមរយៈការវាយតម្លៃលើអន្តរាគមន៍គោលនយោបាយទាំង ២០ នៅក្នុងជំពូក៣ ទាមទារឱ្យមានការកែសម្រួលលើការរៀបចំគោលនយោបាយសម្រាប់អន្តរាគមន៍គោលនយោបាយមួយចំនួន ដើម្បីឱ្យការអនុវត្តគោលនយោបាយ IDP កាន់តែមានប្រសិទ្ធភាព។ ការកែសម្រួលលើការរៀបចំគោលនយោបាយចែកចេញជា ២ក្រុម រួមមាន៖ (១) ការកែសម្រួលលើអន្តរាគមន៍គោលនយោបាយដែលមិនមានវិធានការគោលនយោបាយឆ្លើយតប និង (២) ការកែសម្រួលលើអន្តរាគមន៍គោលនយោបាយដែលមានវិធានការគោលនយោបាយមិនគ្រប់គ្រាន់។

### ៥.៣.១.ការកែសម្រួលលើអន្តរាគមន៍គោលនយោបាយដែលមិនមានវិធានការគោលនយោបាយឆ្លើយតប

ក្នុងចំណោមវិធានការគោលនយោបាយទាំង ១២៣ ដែលមានចែងក្នុងគោលនយោបាយ IDP មិនមានវិធានការណាមួយឆ្លើយតបជាក់លាក់ទៅនឹងអន្តរាគមន៍គោលនយោបាយចំនួន ៤ ខាងក្រោមនោះទេ ដែលបណ្តាលឱ្យអន្តរាគមន៍គោលនយោបាយទាំងនេះមិនអាចរួមចំណែកក្នុងការសម្រេចបាននូវលទ្ធផលដែលរំពឹងទុក។ ជាក់ស្តែង វិធានការគោលនយោបាយមួយចំនួនអាចត្រូវបានរៀបចំឡើង

ដោយមានគោលបំណងមិនជាក់លាក់ហើយឆ្លើយតបដោយប្រយោលទៅនឹងអន្តរាគមន៍គោលនយោបាយទាំង ៤ នេះ។ ទោះជាយ៉ាងនេះក្តី ដើម្បីឱ្យការអនុវត្តគោលនយោបាយកាន់តែមានប្រសិទ្ធភាព វិធានការគោលនយោបាយគួរត្រូវបានរៀបចំឡើងដោយកំណត់ឱ្យបានច្បាស់លាស់នូវក្រុមគោលដៅ, មធ្យោបាយ ឬឧបករណ៍ និងលទ្ធផលដែលរំពឹងទុក។ ក្នុងន័យនេះ វិធានការគោលនយោបាយមួយចំនួនគួរតែត្រូវបានពិចារណាសម្រាប់អន្តរាគមន៍គោលនយោបាយទាំង ៤ នេះ ដើម្បីបង្កើនប្រសិទ្ធភាព។

១. ដើម្បី "**បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល**" នៃគោលបំណងគោលនយោបាយ "បង្កើនសកម្មភាពឧស្សាហកម្ម" គួរពិចារណាវិធានការគោលនយោបាយដូចខាងក្រោម ៖

- អនុវត្ត "យុទ្ធនាការទិញផលិតផលក្នុងស្រុក" ដើម្បីលើកទឹកចិត្តប្រជាជនឱ្យទិញទំនិញក្នុងស្រុក
- ផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនដែលទិញវត្ថុធាតុដើមក្នុងស្រុកសម្រាប់ប្រើប្រាស់ជាធាតុចូលផលិតកម្ម
- លើកទឹកចិត្តឱ្យផ្សារទំនើបក្នុងស្រុកទិញផលិតផលក្នុងស្រុក
- ពន្លឿនការអភិវឌ្ឍ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីការប្រើប្រាស់ប្រព័ន្ធទិន្នន័យអ្នកផ្គត់ផ្គង់ដើម្បីតភ្ជាប់ក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក ជាមួយនឹងក្រុមហ៊ុនបរទេស
- ផ្តល់ការអនុគ្រោះដល់ការទិញផលិតផលក្នុងស្រុកតាមរយៈលទ្ធកម្មសាធារណៈ
- រឹតត្បិតការនាំចូលផលិតផលដែលមិនអនុលោមតាមស្តង់ដារ ឬតម្រូវការបច្ចេកទេសក្នុងស្រុក
- គាំទ្រ និងផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនក្នុងស្រុកដើម្បីឱ្យក្រុមហ៊ុនផលិតនូវមុខទំនិញជំនួសទំនិញនាំចូល។

២. ដើម្បី "**បង្កើនតម្រូវការពលកម្មជំនាញ**" នៃគោលបំណងគោលនយោបាយ "ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ" វិធានការគោលនយោបាយ គួរត្រូវបានពិចារណា ដូចខាងក្រោម ៖

- ពង្រីកយន្តការថ្នាលសេវាការងារសាធារណៈរបស់ទីភ្នាក់ងារជាតិមុខរបរនិងការងារ ឱ្យទៅជាមធ្យោបាយសាធារណៈនាំមុខគេក្នុងការផ្គូផ្គងការងារគ្រប់ប្រភេទនិងគ្របដណ្តប់លើវិសាលភាពទូលំទូលាយទូទាំងប្រទេស ដើម្បីជួយឱ្យក្រុមហ៊ុនអាចស្វែងរកនិងជ្រើសរើសកម្លាំងពលកម្ម/បុគ្គលិកដែលមានសមត្ថភាព បានឆាប់រហ័សនិងដោយចំណាយតិច ឬមិនមានការចំណាយនិងប្រជាជនអាចស្វែងរកការងារធ្វើដោយងាយស្រួល
- ផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនឱ្យជ្រើសរើសកម្លាំងពលកម្មដែលមានគុណវុឌ្ឍិខ្ពស់ (ឧទាហរណ៍ តាមរយៈការឧបត្ថម្ភប្រាក់ឈ្នួលបណ្តោះអាសន្ន ឬការផ្តល់កម្ចី)
- ពិចារណាកំណត់លក្ខណវិនិច្ឆ័យ ឬការលើកទឹកចិត្តឱ្យក្រុមហ៊ុនបរទេសជ្រើសរើសកម្លាំងពលកម្មក្នុងស្រុកសម្រាប់មុខតំណែងខ្ពស់ៗ ជំនួសឱ្យការប្រើប្រាស់ពលករបរទេស។

៣. ដើម្បី "**ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក**" នៃគោលបំណងគោលនយោបាយ "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា" វិធានការគោលនយោបាយ គួរត្រូវបានពិចារណា ដូចខាងក្រោម៖

- គាំទ្រវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពអ្នកផ្គត់ផ្គង់ក្នុងស្រុកនៅក្នុងខ្សែច្រវាក់តម្លៃជាក់លាក់ណាមួយ ដោយកាត់ថ្លៃចំណាយលើការបណ្តុះបណ្តាលក្នុងចំនួនជាក់លាក់មួយពីការចំណាយជាប់ពន្ធ ឬតាមទម្រង់ជំនួយផ្សេងទៀតរបស់រាជរដ្ឋាភិបាល
- កំណត់ខ្សែច្រវាក់តម្លៃអាទិភាពដែលមានសក្តានុពលសម្រាប់ជំនួសការនាំចូល និងគាំទ្រក្រុមហ៊ុនក្នុងស្រុកឱ្យបង្កើនសមត្ថភាពផលិតកម្ម តាមរយៈការផ្តល់ការលើកទឹកចិត្ត
- បង្កើនការលើកទឹកចិត្តឱ្យមានការកែច្នៃ និងផលិតផលកែច្នៃពាក់កណ្តាលសម្រេច ក៏ដូចជាជំរុញតម្លៃបន្ថែមក្នុងស្រុកសម្រាប់ខ្សែច្រវាក់តម្លៃអាទិភាព
- បង្កើតគណៈកម្មាធិការ ឬ ក្រុមការងារកម្រិតបច្ចេកទេសជាន់ខ្ពស់ទទួលបន្ទុកការងារពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក។

៤. ដើម្បី "**បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក**" នៃគោលបំណងគោលនយោបាយ "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា" វិធានការគោលនយោបាយ គួរត្រូវបានពិចារណា ដូចខាងក្រោម៖

- ជំរុញឱ្យមានការបង្កើតសម្ព័ន្ធអាជីវកម្មរវាងក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុក ដែលចូលរួមក្នុងសកម្មភាពផលិត ដោយផ្តល់ការលើកទឹកចិត្តជាក់លាក់ពីរាជរដ្ឋាភិបាល
- ពង្រីកកម្មវិធីបណ្តុះពន្លកអាជីវកម្មសម្រាប់សហគ្រិនក្នុងស្រុក ដើម្បីផ្តល់ជូននូវសុខុបត្ថម្ភវត្ថុ និងសេវាកម្មចាំបាច់ដែលមានតម្លៃសមរម្យ សម្រាប់ដំណើរការផែនការអាជីវកម្ម ជាពិសេសនៅក្នុងឧស្សាហកម្មកែច្នៃកសិផល និងឧស្សាហកម្មកម្មន្តសាល។

## ៥.៣.២.ការកែសម្រួលលើអន្តរាគមន៍គោលនយោបាយដែលមានវិធានការគោលនយោបាយមិនគ្រប់គ្រាន់

ក្នុងចំណោមអន្តរាគមន៍គោលនយោបាយទាំង ២០ អន្តរាគមន៍គោលនយោបាយចំនួន ៧ ខាងក្រោម មានវិធានការគោលនយោបាយមិនគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវលទ្ធផលដែលរំពឹងទុក។

១. ដើម្បី "**បង្កើនផលិតភាពការងារ**" នៃគោលបំណងគោលនយោបាយ "បង្កើនសកម្មភាពឧស្សាហកម្ម"៖ អន្តរាគមន៍គោលនយោបាយនេះ មានវិធានការឆ្លើយតបតែ ១ ប៉ុណ្ណោះ ដែលមិនគ្រប់គ្រាន់ក្នុងការសម្រេចបាននូវលទ្ធផលដែលរំពឹងទុក ប្រសិនបើអនុវត្តដាច់ដោយឡែកពីអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស" និងអន្តរាគមន៍គោលនយោបាយ "បង្កើនកម្រិតបច្ចេកវិទ្យា

របស់សហគ្រាស"។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញវិធានការថ្មីបន្ថែមទៀត ឧទាហរណ៍ដូចជា ផ្តល់ការគាំទ្រតាមរយៈការបន្ថយពន្ធ ឬតាមទម្រង់ផ្សេងទៀតនៃជំនួយរបស់រាជរដ្ឋាភិបាល ដល់ក្រុមហ៊ុនកម្មន្តសាល ដែលត្រូវការកម្មវិធីពង្រឹងសមត្ថភាពសម្រាប់ប្រធានគ្រប់គ្រងខ្សែច្រវាក់ផលិតកម្ម និងនិយោជិត។

២. ដើម្បី **"បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស"** នៃគោលបំណងគោលនយោបាយ "បង្កើនសកម្មភាពឧស្សាហកម្ម"៖ អន្តរាគមន៍គោលនយោបាយនេះមានវិធានការឆ្លើយតបចំនួន ២ ប៉ុណ្ណោះ ដែលមិនគ្រប់គ្រាន់ក្នុងការសម្រេចបានលទ្ធផលដែលរំពឹងទុក។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញវិធានការថ្មីបន្ថែម ឧទាហរណ៍ដូចជា កាត់បន្ថយពន្ធលើការនាំចូលគ្រឿងម៉ាស៊ីន ឬសម្ភារៈបរិក្ខារផលិតកម្មថ្មី សម្រាប់ខ្សែច្រវាក់ផលិតកម្ម ដើម្បីជួយកាត់បន្ថយចំណាយលើការបំពាក់បច្ចេកវិទ្យាថ្មីសំដៅលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពធនធាននិងថាមពលក្នុងខ្សែច្រវាក់ផលិតកម្ម។

៣. ដើម្បី **"បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុនឬសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក"** នៃគោលបំណងគោលនយោបាយ "បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម"៖ អន្តរាគមន៍គោលនយោបាយនេះមានវិធានការឆ្លើយតបចំនួន ៣ ដែលអាចជួយឱ្យមានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះសម្រាប់អន្តរាគមន៍គោលនយោបាយនេះ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញវិធានការថ្មីបន្ថែម ឧទាហរណ៍ដូចជា៖

- ផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធដល់សហគ្រាសធុនតូចនិងមធ្យមគោលដៅដែលមានសក្តានុពលនាំចេញដូចជាសហគ្រាសក្នុងឧស្សាហកម្មកែច្នៃកសិផល ដើម្បីពង្រីកផលិតកម្មរបស់ខ្លួនសម្រាប់ការនាំចេញ
- រៀបចំវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាពសហគ្រាសធុនតូចនិងមធ្យមលើជំនាញអភិវឌ្ឍន៍ផលិតផល ការធានាគុណភាព និងការគ្រប់គ្រងភស្តុភារ ដែលអាចជួយបង្កើនសមត្ថភាពសហគ្រាសទាំងនោះ ក្នុងការបំពេញតម្រូវការបច្ចេកទេសសម្រាប់ការនាំចេញ
- រៀបចំឱ្យបានជាប្រចាំនូវពិព័រណ៍ពាណិជ្ជកម្ម និងព្រឹត្តិការណ៍ផ្គូផ្គងអាជីវកម្មនៅក្រៅប្រទេសដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុននិងសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកអាចពង្រីកភាពជាដៃគូអាជីវកម្ម និងបង្ហាញផលិតផលដែលមានសក្តានុពលទៅកាន់ទីផ្សារបរទេស ។

៤. ដើម្បី **"ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"** នៃគោលបំណងគោលនយោបាយ "បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម"៖ អន្តរាគមន៍គោលនយោបាយ

នេះមានវិធានការឆ្លើយតបរហូតដល់ ២១ ដែលភាគច្រើនផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ប៉ុន្តែមិនមានវិធានការណាមួយផ្តោតលើតម្រូវការជាក់ស្តែង ក្នុងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធឌីជីថលឡើយ។ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ទំនើប និងសុខុបត្ថម្ភវត្ថុ គឺជាផ្នែកមួយចាំបាច់ដើម្បីជួយកាច់ចង្កូតវិស័យផលិតកម្មរបស់កម្ពុជាឆ្ពោះទៅដំណាក់កាលថ្មីនៃការបង្កើតតម្លៃនៅក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្ម ៤.០។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញវិធានការថ្មីបន្ថែម ឧទាហរណ៍ដូចជា ពង្រីកការតភ្ជាប់អ៊ីនធឺណិតដើម្បីផ្តល់នូវការប្រើប្រាស់អ៊ីនធឺណិតដែលមានល្បឿនលឿន និងមានតម្លៃសមរម្យ ដើម្បីជួយសម្រួលដល់សកម្មភាពផលិតកម្មទំនើបដែលត្រូវការប្រព័ន្ធអ៊ីនធឺណិតល្បឿនលឿន និងអាចជឿទុកចិត្តបានក្នុងប្រតិបត្តិការអាជីវកម្ម ជាពិសេសសម្រាប់ប្រតិបត្តិការដែលប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃ និងដំណើរការស្វ័យប្រវត្តិកម្ម។

៥. ដើម្បី **"បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ"** នៃគោលបំណងគោលនយោបាយ "សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម"៖ អន្តរាគមន៍គោលនយោបាយនេះមានវិធានការឆ្លើយតបចំនួន ៤ ដែលមានគោលបំណងជាក់លាក់ ប៉ុន្តែវិធានការទាំងនេះមិនបានចែងច្បាស់ និងខ្វះការបញ្ជាក់ ក៏ដូចជាខ្វះកម្លាំងដើម្បីនាំមកនូវលទ្ធផលដែលរំពឹងទុកក្នុងការបង្កើតឧស្សាហកម្មថ្មីៗ។ ដូច្នេះ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញវិធានការថ្មីបន្ថែម ឧទាហរណ៍ដូចជា បង្កើត និងអនុវត្តយុទ្ធសាស្ត្រវិនិយោគឧស្សាហកម្មគោលដៅ ដោយកំណត់ឱ្យបានច្បាស់នូវសកម្មភាពឧស្សាហកម្មគោលដៅ, ប្រភពគោលដៅនៃការវិនិយោគផ្ទាល់ពីបរទេស (ជាពិសេសប្រទេសដែលមានយុទ្ធសាស្ត្រពាណិជ្ជកម្មចិន+១) និងការលើកទឹកចិត្តឆ្លាតវៃផ្សេងទៀត ។

៦. ដើម្បី **"បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ"** នៃគោលបំណងគោលនយោបាយ "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា"៖ អន្តរាគមន៍គោលនយោបាយនេះមានវិធានការគោលនយោបាយឆ្លើយតបចំនួន ៤ ដែលមិនគ្រប់គ្រាន់ក្នុងការសម្រេចបានលទ្ធផលដែលរំពឹងទុក។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញវិធានការថ្មីបន្ថែម ឧទាហរណ៍ដូចជា៖

- ធ្វើការសិក្សាស្រាវជ្រាវអំពីទីផ្សារដើម្បីទទួលបានព័ត៌មានថ្មីៗអំពីតម្រូវការទីផ្សារក្នុងស្រុកនិងអន្តរជាតិ, ការប្រកួតប្រជែង, និន្នាការនៃចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ និងកាលានុវត្តភាពសម្រាប់ផលិតផលកែច្នៃកម្ពុជាក្នុងការជ្រៀតចូលទីផ្សារ
- ផ្តល់ការគាំទ្រជាថវិកាដល់ស្ថាប័នស្រាវជ្រាវ ឬសាកលវិទ្យាល័យសម្រាប់ការអភិវឌ្ឍបច្ចេកទេស និងបច្ចេកវិទ្យាកែច្នៃដំណាំកសិ-ឧស្សាហកម្មដែលមានតម្លៃខ្ពស់ ហើយដែលសមស្របសម្រាប់ទីផ្សារ

- ផ្តល់ការគាំទ្រជាថវិកាដល់ស្ថាប័នស្រាវជ្រាវ ឬសាកលវិទ្យាល័យគោលដៅ ឬគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធ្វើសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ផលិតផលកែច្នៃកសិផលប្រកបដោយភាពច្នៃប្រឌិត ដោយមានចក្ខុវិស័យផ្លាស់ប្តូរស្ថាប័នទាំងនោះ ឬនាយកដ្ឋានឯកទេសរបស់ស្ថាប័នទាំងនោះ ឱ្យទៅជាមជ្ឈមណ្ឌលនវានុវត្តន៍អាហារ
- ផ្តល់ការផ្សព្វផ្សាយ ការបណ្តុះបណ្តាលបច្ចេកទេស និងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រុមហ៊ុនកែច្នៃកសិផលខ្នាតតូចដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពផលិតផលរបស់ក្រុមហ៊ុនទាំងនោះ ដោយបំពាក់នូវប្រព័ន្ធគ្រប់គ្រងត្រឹមត្រូវស្របតាមស្តង់ដារជាតិ និងអន្តរជាតិ (ឧទាហរណ៍ស្តង់ដារសុវត្ថិភាពម្ហូបអាហារអន្តរជាតិសម្រាប់ក្រុមហ៊ុនកែច្នៃម្ហូបអាហារ)។

៧. ដើម្បី "**បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម**" នៃគោលបំណងគោលនយោបាយ "សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម"៖ អន្តរាគមន៍គោលនយោបាយនេះមានវិធានការគោលនយោបាយឆ្លើយតបចំនួន ១៦ ដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់ការបង្កើននវានុវត្តន៍ ប៉ុន្តែវិធានការទាំងនេះហាក់មិនទាន់គ្រប់គ្រាន់ក្នុងការបង្កើនសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍នៅកម្ពុជានៅឡើយទេ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញវិធានការថ្មីបន្ថែម ឧទាហរណ៍ដូចជា៖

- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សាកលវិទ្យាល័យរដ្ឋ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានកន្លែងស្រាវជ្រាវប្រកបដោយស្តង់ដារខ្ពស់ ដើម្បីបង្កើនកិច្ចសហការជាមួយវិស័យឯកជនលើកិច្ចការស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផលក្នុងវិស័យអាទិភាព និង
- ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធនាំចូលនូវឧបករណ៍សិក្សាស្រាវជ្រាវដល់សាកលវិទ្យាល័យរដ្ឋ/ឯកជន, មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវប្រកបដោយស្តង់ដារខ្ពស់ ដើម្បីបង្កើនកិច្ចសហការជាមួយវិស័យឯកជនក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍផលិតផលថ្មីៗ។

សរុបមក ក្នុងចំណោមអន្តរាគមន៍គោលនយោបាយទាំង ២០ មានអន្តរាគមន៍គោលនយោបាយចំនួន ១១ ដែលតម្រូវឱ្យមានការកែសម្រួលការរៀបចំគោលនយោបាយ ដើម្បីពង្រឹងការអនុវត្ត IDP ទទួលបាននូវលទ្ធផលរំពឹងទុក។ ទោះបីជាអន្តរាគមន៍គោលនយោបាយផ្សេងទៀត (ការបង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម, ការធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស ។ល។) ត្រូវបានរៀបចំឡើងដោយមានចំនួនវិធានការគោលនយោបាយគ្រប់គ្រាន់ក៏ដោយ វិធានការគោលនយោបាយទាំងនោះក៏តម្រូវឱ្យមានការកែលម្អបន្ថែមដោយក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត ដើម្បីបត់បែនតាមការវិវត្តជាក់ស្តែងនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម។

## ៥.៨ អនុសាសន៍សម្រាប់ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាន និងវាយតម្លៃគោលនយោបាយ IDP

ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាន និងវាយតម្លៃគោលនយោបាយ IDP បញ្ហាមួយចំនួន ដែលបានលេចឡើងក្នុងដំណើរការនៃការរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្ដាលអាណត្តិនេះ តម្រូវឱ្យមានដំណោះស្រាយសមស្រប រួមមាន៖

### ១. ភាពខ្វះចន្លោះរបស់ទម្រង់គំរូរបាយការណ៍ (RTF)

ជាការកត់សម្គាល់ ការដាក់ឱ្យអនុវត្ត RTF នាពេលកន្លងមក សង្កេតឃើញមានលេចចេញនូវបញ្ហាចំនួន២។ បញ្ហាទីមួយ គឺឆ្នាំដាក់លាក់ ក្នុងការសម្រេចពេញលេញនូវការអនុវត្តវិធានការគោលនយោបាយមិនអាចកំណត់តាមដានបាន។ បញ្ហានេះកើតឡើងដោយសារតែចំណេះដឹងបច្ចេកទេសក្នុងការបំពេញ RTF នៅមានកម្រិត, មិនមានប្រព័ន្ធកត់ត្រាត្រឹមត្រូវ ហើយការណែនាំនិងដាក់ឱ្យប្រើប្រាស់ RTF ក៏មានលក្ខណៈឆាប់រហ័សពេក ដែលធ្វើឱ្យក្រសួង ស្ថាប័នមិនអាចសម្របខ្លួនក្នុងការប្រើប្រាស់ទម្រង់នេះបានភ្លាមៗ។ បញ្ហាទាំងនេះអាចដោះស្រាយបានតាមរយៈ (១) ការបង្កើត RTF ដែលមានលក្ខណៈងាយស្រួលជាងមុនតាមរយៈការបង្កើតឡើងនូវទម្រង់ឌីជីថល ឬអនឡាញ (២) ការផ្ដល់នូវគោលការណ៍ណែនាំច្បាស់លាស់អំពីសារៈសំខាន់ និងរបៀបបំពេញ RTF ឱ្យបានត្រឹមត្រូវតាមរយៈការបង្កើតវីដេអូ ឬការសរសេរពន្យល់ជាលាយលក្ខណ៍អក្សរ (៣) ការរៀបចំសិក្ខាសាលាតាមការស្នើសុំ និង (៤) ការប្រមូល RTF តាមកាលកំណត់ណាមួយជាប្រចាំ។

បញ្ហាទី២ គឺ ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនមិនបានបំពេញព័ត៌មានអំពីបញ្ហាប្រឈម និងដំណោះស្រាយនៅក្នុង RTF ទេ ដែលនេះអាចបណ្ដាលមកពីមន្ត្រីដែលទទួលបន្ទុកបំពេញ RTF មិនបានដឹង ឬមិនទទួលបានព័ត៌មានពេញលេញអំពីបញ្ហាប្រឈមនៅកម្រិតអនុវត្ត និង/ឬ មិនមានធនធាន និងពេលវេលាគ្រប់គ្រាន់ដើម្បីបំពេញព័ត៌មានលម្អិតនៅក្នុងប្រអប់ព័ណ៌នារបស់ RTF។ ដើម្បីដោះស្រាយបញ្ហានេះ លេខាធិការដ្ឋាន IDP នឹងសិក្សាបន្ថែមទៀតអំពីបញ្ហាប្រឈមជារួមពីឯកសារ RTF កន្លងមក ដើម្បីកំណត់និងរៀបចំព័ត៌មានទាំងនេះជាបញ្ជីពហុជម្រើសសម្រាប់ឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធជ្រើសរើសនៅក្នុងទម្រង់ឌីជីថល ឬអនឡាញរបស់ RTF ។

### ២. បញ្ហាក្នុងការប្រមូលទិន្នន័យ

លេខាធិការដ្ឋាន IDP បានជួបប្រទះការលំបាកក្នុងការប្រមូលទិន្នន័យរបស់សូចនាករគន្លឹះ។ បញ្ហាចម្បងនៅក្នុងដំណើរការនៃការប្រមូលទិន្នន័យនេះរួមមាន៖ ការកំណត់និយមន័យខុសគ្នា, ភាពខុសគ្នានៃវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ, ភាពខ្វះចន្លោះទិន្នន័យដែលបានស្នើសុំដោយទិន្នន័យខ្លះមានរយៈពេលតិចឆ្នាំ ឬសូចនាករខ្លះមិនមានទិន្នន័យតែម្តង។ ស្ថានភាពនេះនៅតែបន្តកើតមានឡើង បើទោះជាលេខាធិការដ្ឋាន IDP បានរៀបចំកិច្ចប្រជុំអន្តរក្រសួងពិនិត្យពិភាក្សាជាច្រើនលើកច្រើនសារក៏ដោយ។ ក្នុងករណីនេះ គួរតែមានការបង្កើតឡើងនូវម៉េតាទិន្នន័យ (metadata)[៥] ដែលនឹងគូសបញ្ជាក់យ៉ាងច្បាស់អំពីនិយមន័យ, ខ្នាត, ប្រភព និងវិធីសាស្ត្រគណនាទិន្នន័យ សម្រាប់ទុកប្រើប្រាស់នៅពេលខាងមុខ។

លើសពីនេះទៅទៀត ការអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃគោលនយោបាយ IDP អាចមានភាពកាន់តែប្រសើរ តាមរយៈការផ្តល់ការសហការយ៉ាងជិតស្និទ្ធដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសនោះគឺក្នុងការផ្តល់ទិន្នន័យដែលបានស្នើសុំឱ្យទាន់ពេលវេលា និងភ្ជាប់មកជាមួយនូវការពន្យល់ជាលាយលក្ខណ៍-អក្សរពីនិន្នាការលេចធ្លោ ឬមិនប្រក្រតីមួយចំនួន ឬចំណុចដែលងាយយល់ច្រឡំ។ ជាមួយគ្នានេះ ការរៀបចំនិងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃគោលនយោបាយ IDP ក្នុងដំណាក់កាលទី២ តម្រូវឱ្យមានការបន្តកែសម្រួលគោលបំណងគោលនយោបាយឱ្យកាន់តែមានភាពច្បាស់លាស់ដោយផ្តោតលើនិយមន័យ,ទិន្នន័យមូលដ្ឋាន និងតម្លៃគោលដៅ។

## ៥.៥. បច្ច័យវិជ្ជមាននៃការដាក់ចេញគោលនយោបាយថ្មីៗ

ស្របពេលដែលគោលនយោបាយ IDP ត្រូវបាននិងកំពុងអនុវត្ត រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនិងកំពុងរៀបចំនូវគោលនយោបាយ និងក្របខណ្ឌគោលនយោបាយមួយចំនួន ដែលនឹងមានបច្ច័យទៅលើការសម្រេចបាននូវគោលបំណងគោលនយោបាយ IDP។ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣** អាចនឹងផ្តល់ជាបច្ច័យវិជ្ជមានមកលើអន្តរាគមន៍គោលនយោបាយមួយចំនួន រួមមាន៖ ការជំរុញការកែច្នៃផលិតផលកសិកម្មសំខាន់ៗ, ការបង្កើតនិងដំណើរការតំបន់កសិឧស្សាហកម្ម, ការជំរុញការអនុវត្តបច្ចេកវិទ្យាសមស្រប, និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម។

ទន្ទឹមនឹងនេះ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥**វិញ នឹងចូលរួមចំណែកក្នុងការបង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម, ការបង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស, ការបង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក, ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនា-

---

[៥] របាយការណ៍ប្រចាំឆ្នាំ២០១១ ប្រព័ន្ធស្ថិតិជាតិកម្ពុជា រៀបចំដោយ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ក្នុងខែសីហា ឆ្នាំ២០១២, ទំព័រទី ១៣, https://www.nis.gov.kh/doc/Annual%20Report%202011_Kh_Aug_2012.pdf

សម្ព័ន្ធឧស្សាហកម្ម, ការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ, ការលើកកម្ពស់តួនាទីរបស់សហគ្រាសធុនតូច និងមធ្យម, ការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម, និងការពង្រឹងខ្សែច្រវាក់តម្លៃជាតិ។ **សេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាល ឌីជីថល ២០២១-២០៣០** អាចនឹងនាំមកនូវបច្ច័យវិជ្ជមានដល់កំណើនសេដ្ឋកិច្ចទាំងមូល រួមមានការធ្វើឱ្យប្រសើរឡើងនូវផលិតភាព, ការលើកកម្ពស់ផលិតកម្ម, ការចែកចាយផលិតផលកាន់តែឆាប់រហ័ស, ការប្រកួតប្រជែងផ្នែកធុរកិច្ច, ការលើកកម្ពស់នវានុវត្តន៍ក្នុងវិស័យឯកជន និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

ជាមួយគ្នានេះ ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍២០៣០ (STI Roadmap 2030) ក៏នឹងនាំមកនូវបច្ច័យវិជ្ជមានដល់ការលើកកម្ពស់ធនធានមនុស្ស ការផ្ទេរបច្ចេកវិទ្យា និងជំរុញនវានុវត្តន៍ក្នុងវិស័យឧស្សាហកម្មផងដែរ។ បន្ថែមលើនេះ **សេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ឆ្នាំ២០២១-២០២៦** នឹងចូលរួមចំណែកក្នុងការលើកកម្ពស់តួនាទីរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងសេដ្ឋកិច្ចកម្ពុជា។ ការដាក់ចេញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលនឹងជំរុញសហគ្រាសធុនតូចនិងមធ្យមក្រៅផ្លូវការដែលពុំទាន់បានចុះបញ្ជីឱ្យចុះបញ្ជី នឹងចូលរួមគាំទ្រសហគ្រាសធុនតូចនិងមធ្យមបន្ថែមទៀតក្នុងការពង្រឹងភាពប្រកួតប្រជែង, ភាពច្នៃប្រឌិត និងនវានុវត្តន៍, ការប្រើប្រាស់បច្ចេកវិទ្យា, ការអភិវឌ្ឍផលិតផល និងសមត្ថភាពក្នុងការនាំចេញ។

## ៥.៦. ផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើការអនុវត្ត IDP និងអនុសាសន៍គោលនយោបាយ

ជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គម-សេដ្ឋកិច្ច ស្ទើរតែគ្រប់ប្រទេសទាំងអស់ក្នុងសកលលោក ដែលបានធ្វើឱ្យមានផលរំខានដល់ការផលិត ការផ្គត់ផ្គង់វត្ថុធាតុដើម ការកើនឡើងនូវតម្លៃដឹកជញ្ជូន ដែលធ្វើឱ្យខ្សែច្រវាក់ផ្គត់ផ្គង់ត្រូវបានកាត់ផ្តាច់ ហើយដែលយើងមិនរំពឹងថាអ្វីៗនឹងវិលទៅរកសភាពដើមមុនពេលមានវិបត្តិកូវីដ-១៩ ឡើយ។ កម្ពុជាក៏ដូចជាបណ្តាប្រទេសផ្សេងៗដែរ ការរីករាលដាលនៃជំងឺកូវីដ-១៩ បាននាំមកនូវផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យមួយចំនួន រីឯវិស័យជាក់លាក់ខ្លះទៀតបែរជាទទួលអត្ថប្រយោជន៍ពីវិបត្តិនេះទៅវិញ។ ជាក់ស្តែង វិស័យដែលទទួលរងនូវផលប៉ះពាល់ខ្លាំងមានដូចជាសេវាកម្ម ការដឹកជញ្ជូននិងភស្តុភារកម្ម សំណង់និងអចលនទ្រព្យ និងកម្មន្តសាល ជាដើម។ វិស័យដែលរងផលប៉ះពាល់អវិជ្ជមានតិចជាងគេនោះគឺ វិស័យកសិកម្ម។

ចំពោះវិស័យកម្មន្តសាល ជាពិសេស អនុវិស័យកាត់ដេរ ជំងឺកូវីដ-១៩ បាននាំមកនូវការផ្លាស់ប្តូរយ៉ាងខ្លាំង និងបង្កឱ្យមានកង្វះខាត ឬការរាំងស្ទះដល់ការផ្គត់ផ្គង់នៃកត្តាផលិតកម្មមួយចំនួន ដូចជាកម្លាំងពលកម្ម វត្ថុធាតុដើម ជាដើម។ ម្ចាស់ក្រុមហ៊ុនជាច្រើនបានប្រឈមមុខនឹងការពន្យារពេល

ផលិតកម្ម ដោយសារតែការបង្អាក់នូវខ្សែច្រវាក់ផ្គត់ផ្គង់ និងការទទួលរងផលប៉ះពាល់អវិជ្ជមានដល់សុខភាពរបស់កម្មករនិយោជិតពីការឆ្លងរាតត្បាតជំងឺ។ ទោះជាយ៉ាងណា ជាមួយនឹងការពង្រឹងការអនុវត្តម៉ត់ចត់នូវវិធានការសុវត្ថិភាពនិងសុខភាពនៅកន្លែងធ្វើការ និងការផ្តល់អាទិភាពក្នុងការចាក់វ៉ាក់សាំងបង្ការការឆ្លងជំងឺកូវីដ-១៩ ដល់កម្មករនិយោជិត និងនិយោជក វិស័យនេះហាក់ដូចជាមានការឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងការផ្លាស់ប្តូរ ជាហេតុធ្វើឱ្យវិស័យនេះមានដំណើរការឡើងវិញជាបណ្តើរៗ។ ឧស្សាហកម្មកែច្នៃកសិផល និងវិស័យកម្មន្តសាលថ្មីៗដូចជាការផលិតនិងបង្គុំគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិក និងយានយន្ត រួមទាំងការផលិតនិងដំឡើងកង់ត្រូវបានពង្រីក។ យ៉ាងណាមិញ វិស័យកសិកម្មហាក់ដូចជាមិនសូវរងគ្រោះខ្លាំងពីវិបត្តិនេះទេ ដោយសារផលិតកម្មអង្ករមានការកើនឡើង ខណៈពេលដែលសមត្ថភាពផលិតដំណាំកសិផល និងអនុផលដទៃទៀតរបស់ប្រទេសត្រូវបានពង្រឹងនិងពង្រីកជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួនដូចជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជានិងចិន និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ ត្រូវបានរំពឹងទុកថានឹងជំរុញពន្លឿនកំណើននៃវិស័យនេះផងដែរ។ ទោះជាយ៉ាងណា ការកើនឡើងនៃថ្លៃដឹកជញ្ជូនបានធ្វើឱ្យប៉ះពាល់ទៅលើការនាំចេញអង្ករ ផលិតផលកសិកម្ម និងផលិតផលនាំចេញដទៃទៀតដែលកម្ពុជាផលិតបាន។

ជារួម ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កអោយមានផលប៉ះពាល់អវិជ្ជមាន។ យ៉ាងណាមិញ កម្ពុជាអាចសម្របខ្លួនទៅរកប្រក្រតីភាពថ្មីនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ តាមរយៈការដាក់ចេញវិធានការបុរេសកម្ម និងការឆ្លើយតបភ្លាមៗប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ កាត់ផ្តាច់ខ្សែចម្លង និងកាត់បន្ថយការឆ្លងបានទាន់ពេលវេលា ព្រមទាំងបានកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រគន្លឹះ កត្តាទាំងនេះ អាចក្លាយជាលក្ខខណ្ឌដ៏សំខាន់មួយសម្រាប់ផ្តល់នូវជំនឿចិត្ត និងសុវត្ថិភាពដល់ធុរជន ក៏ដូចជាវិនិយោគិនក្នុងការមកវិនិយោគ និងធ្វើធុរកិច្ចនៅកម្ពុជា។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងកំពុងអនុវត្តយ៉ាងសកម្មនូវគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ និងដូសជំរុញ ដើម្បីបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយសម្រាប់ទប់ទល់នឹងជំងឺកូវីដ-១៩ និងការវាយលុកនៃមេរោគប្រភេទថ្មី ដែលគិតត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ ប្រជាពលរដ្ឋអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ចំនួនប្រមាណ ៩៩,២០% ធៀបនឹងគោលដៅចំនួន ១០លាននាក់, កុមារ និងយុវជនចាប់ពី ១២ឆ្នាំដល់ក្រោម ១៨ឆ្នាំ ចំនួនប្រមាណ ៨៩,៨១% ធៀបនឹងគោលដៅចំនួនប្រមាណជិត ២លាននាក់, និងកុមារអាយុចាប់ពី ៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ ចំនួនប្រមាណ ៩៥,១៨% ធៀបនឹងគោលដៅចំនួនប្រមាណជិត ២លាននាក់ បានទទួលការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃ និងតាមគោលការណ៍ស្ម័គ្រចិត្ត។ ការសម្របខ្លួនបានទៅនឹងប្រក្រតីភាពថ្មី ព្រមទាំងភាពធូរស្រាលនៃការរីករាលដាលជំងឺកូវីដ១៩ បន្ទាប់ពីការចាក់វ៉ាក់សាំងត្រូវបានអនុវត្តយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស នឹងជួយជំរុញការងើបឡើងវិញជាសន្សឹមៗគ្រប់វិស័យក្នុងប្រទេស។

ទោះបីជាបច្ចុប្បន្ន រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ និងចំណាត់ការសំខាន់ៗដ៏មានប្រសិទ្ធ-ភាពក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩ ប៉ុន្តែសម្រាប់រយៈពេលមធ្យមទៅវែងខាងមុខ ការអភិវឌ្ឍវិស័យឧស្សាហកម្មរបស់កម្ពុជាអាចប្រឈមនឹងការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកល ដែលការណ៍នេះតម្រូវឱ្យមានការគិតគូរពីឥទ្ធិពលនៃកត្តាខាងក្រៅ និងខាងក្នុងមួយចំនួនដូចជា៖

១) បដិសកលភាវូបនីយកម្ម និងការរៀបចំឡើងវិញនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល

ការរីករាលដាលនៃជំងឺកូវីដ-១៩ បានពន្លឿនការផ្លាស់ប្តូរការរៀបចំគោលនយោបាយសេដ្ឋកិច្ចជាសកលពីសកលភាវូបនីយកម្មនិងពហុភាគីនិយម ទៅកាន់ជាតិនិយម ការគាំពារនិយម និងទ្វេភាគីនិយម។ អំឡុងពេលនៃការរីករាលដាលនេះ មានការកើនឡើងនូវចំនួនប្រទេសដែលបានដាក់ចេញនូវវិធានការគោល នយោបាយឧស្សាហកម្ម ដោយមានទំនោរប្រកាន់យកបដិសកលភាវូបនីយកម្ម។ លើសពីនេះ សាជីវ-កម្មពហុជាតិជាច្រើនក៏បានជួបផលប៉ះពាល់ដែលបណ្តាលមកពីការរាំងស្ទះនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ដែលជំរុញឱ្យមានការគិតគូរ និងរៀបចំឡើងវិញនូវយុទ្ធសាស្ត្រខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួន ដើម្បីពង្រឹងភាពធន់នឹងវិបត្តិ ក្នុងនោះរួមមាន ការផ្តោតលើតំបន់ភាវូបនីយកម្ម និងការបង្រួមនិងការធ្វើសាមញ្ញកម្មនៃខ្សែច្រវាក់តម្លៃសកល ឬតំបន់ មកកៀកនឹងទីផ្សារសំខាន់ៗ។

កម្ពុជាក៏អាចប្រឈមនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ចសកលនេះផងដែរ ដោយសារតែសេដ្ឋ-កិច្ចកម្ពុជាបានធ្វើសមាហរណកម្មទៅក្នុងខ្សែច្រវាក់ផលិតកម្មសកល ជាពិសេសវិស័យកាត់ដេរ និងសម្លៀក-បំពាក់។ បម្រែបម្រួល ឬការធ្លាក់ចុះការវិនិយោគប្រភេទស្វែងរកប្រសិទ្ធភាពផលិតកម្ម (efficiency-seeking FDI) ដែលកម្ពុជាទទួលបានកន្លងមក អាចនឹងមានផលប៉ះពាល់ខ្លាំងចំពោះការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ហើយកិច្ចការងារនេះតម្រូវឱ្យធ្វើការគិតគូរ និងតម្រង់ទិសឡើងវិញសម្រាប់ពេលខាងមុខ។

ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់គន្លងប្រក្រតីភាពថ្មី គោលនយោបាយ IDP គួរតែបន្តពង្រឹង (១) ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង (២) ការជំរុញធ្វើពិពិធកម្មទីផ្សារ ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមលើការនាំចេញទៅក្នុងទីផ្សារតំបន់ និងបង្កើនសកម្មភាពផលិតផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក តាមរយៈការបន្តអនុវត្តវិធានការគោលនយោបាយ IDP ដែលមានស្រាប់ និងពិចារណាដាក់ចេញនូវវិធានការថ្មីៗបន្ថែមទៀត ដើម្បីសម្របខ្លួនឱ្យបានឆាប់រហ័សទៅនឹងការផ្លាស់ប្តូរទាំងនេះ។

ក្នុងន័យនេះ អន្តរាគមន៍គោលនយោបាយនៅក្រោមគោលបំណងទី៣ "សេដ្ឋកិច្ចដែលមានភាពធន់នឹងវិបត្តិ និងការធ្វើពិពិធកម្ម" ពិតជាមានសារៈសំខាន់ណាស់ ព្រោះរចនាសម្ព័ន្ធផលិតកម្មដែលមិនសូវមានភាពប្រមូលផ្តុំ នឹងជួយពង្រឹងភាពធន់នឹងវិបត្តិ។ ជាមួយគ្នានេះ ការជំរុញការអនុវត្តអន្តរាគមន៍គោលនយោបាយនៅក្រោមគោលបំណងទី៥ "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា" ក៏មានសារៈសំខាន់ផងដែរក្នុងការចូលរួមតម្រង់ទិសវិស័យកម្មន្តសាលឡើងវិញ។

**២) ការបង្កើនការយកចិត្តទុកដាក់លើការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាព**

រដ្ឋាភិបាលប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន កំពុងដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលកាន់តែមានមហិច្ឆតាខ្ពស់ ដើម្បីធ្វើឱ្យឧស្សាហកម្មដែលមានស្រាប់ និងឧស្សាហកម្មបៃតងដែលទើបនឹងកើតឡើងថ្មីៗ កាន់តែមានចីរភាព ដែលការណ៍នេះបានកំណត់នូវលក្ខខណ្ឌតឹងរ៉ឹងជាងមុន សម្រាប់ការឈានចូលទៅក្នុងទីផ្សារនាពេលអនាគត ហើយការអនុវត្តវិធានបរិស្ថាននៃសកម្មភាពផលិតកម្មនឹងក្លាយជាកត្តាកំណត់ដ៏សំខាន់នៃការប្រកួតប្រជែងឧស្សាហកម្ម។ ជាមួយគ្នានេះ ដោយមានការកើនឡើងនូវការយល់ដឹងរបស់អតិថិជន និងវិនិយោគិន វិស័យឯកជនអន្តរជាតិបាននិងកំពុងអនុវត្តរបៀបវារៈចីរភាព លើវិស័យកម្មន្តសាលគន្លឹះមួយចំនួនរួចមកហើយ។ អាស្រ័យហេតុនេះ ការលក់ផលិតផលដែលមិនឆ្លើយតបនឹងលក្ខខណ្ឌចីរភាពអាចនឹងជួបប្រទះការលំបាកនាពេលអនាគត។

និន្នាការនៃការផ្លាស់ប្តូរទាំងនេះនឹងជះឥទ្ធិពលដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ដោយពឹងផ្អែកកាន់តែខ្លាំងទៅលើសមិទ្ធកម្មប្រកបដោយចីរភាព។ ក្នុងបរិការណ៍នេះ គំនិតផ្តួចផ្តើមថ្មីៗមួយចំនួនបាននិងកំពុងរៀបចំដើម្បីប្រែក្លាយឧស្សាហកម្មកម្ពុជាទៅជាឧស្សាហកម្មបៃតង។ ជាមួយគ្នានេះ ច្បាប់ស្តីពីវិនិយោគ ក៏នឹងផ្តល់ការលើកទឹកចិត្តជាអាទិភាពដល់វិស័យ និងសកម្មភាពវិនិយោគក្នុងការគ្រប់គ្រង និងការការពារបរិស្ថាន, សេដ្ឋកិច្ចចក្រា និងថាមពលបៃតង ។ល។

ដោយមើលឃើញពីសារៈសំខាន់ជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាពនាពេលអនាគត ដំណាក់កាលបន្ទាប់នៃការអនុវត្តគោលនយោបាយ IDP សម្រាប់ឆ្នាំ ២០២២-២០២៥ គួរពិចារណាទៅលើរបត់ថ្មីនេះផងដែរ។ ជម្រើសមួយ គឺបង្កើតជាគោលបំណងគោលនយោបាយថ្មីមួយបន្ថែមទៀត ដោយមានអន្តរាគមន៍គោលនយោបាយ និងវិធានការគោលនយោបាយគាំទ្រ ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាព។

**៣) ការថយចុះនៃតួនាទីរបស់សហគ្រាសធុនតូច និងមធ្យមក្នុងផលិតកម្មឧស្សាហកម្មទំនើប បន្ទាប់ពីជំងឺកូវីដ-១៩**

របត់នៃការផ្លាស់ប្តូរទី៣នេះ ពាក់ព័ន្ធទៅនឹងការធ្លាក់ចុះកាន់តែខ្លាំងនៃតួនាទីរបស់សហគ្រាសធុនមីក្រូ, តូច និងមធ្យម ក្នុងការអភិវឌ្ឍឧស្សាហកម្ម។ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ សហគ្រាសធំៗបានពន្លឿនការចាប់យកបច្ចេកវិទ្យាទំនើបក្នុងដំណើរការផលិតកម្ម ជាពិសេស រ៉ូបូតនីយកម្ម (Robotization), ស្វ័យប្រវត្តិកម្ម និងឌីជីថលូបនីយកម្ម។ ការប្រែប្រួលនេះបង្កជាបញ្ហាប្រឈមខ្លាំងដល់សហគ្រាសធុនតូច និងមធ្យម ក្នុងការដើរឱ្យទាន់ល្បឿននៃការវិវឌ្ឍនេះ ដែលតម្រូវឱ្យមានធនធាន និងសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់។ សហគ្រាសលក្ខណៈគ្រួសារខ្នាតតូចក៏មានការស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូរទៅប្រើប្រាស់បច្ចេកវិទ្យាឧស្សាហកម្ម ៤.០ ដោយសារតែការកាត់បន្ថយកម្លាំងពលកម្មដើម្បីជំរុញផលិតកម្មមិនមែនជាកម្មវត្ថុនៃអាជីវ-

កម្មរបស់សហគ្រាសប្រភេទនេះ។ ទោះជាយ៉ាងណា សហគ្រាសធុនតូច និងមធ្យម ដែលផ្គត់ផ្គង់ធាតុចូលផលិតកម្ម ដល់សាជីវកម្មពហុជាតិ នឹងរងសម្ពាធកាន់តែខ្លាំងក្នុងការចាប់យកបច្ចេកវិទ្យាឧស្សាហកម្ម ៤.០ ជាងសហគ្រាសធុនតូច និងមធ្យមដែល ផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ចុងក្រោយ។

នៅកម្ពុជា សហគ្រាសធុនមីក្រូ តូចនិងមធ្យម ក៏បានរងនូវផលប៉ះពាល់យ៉ាងខ្លាំងពីបច្ច័យអវិជ្ជមាន ដែលបណ្តាលមកពីជំងឺកូវីដ-១៩នេះដែរ។ អង្កេតសហគ្រាសដែលបានរៀបចំដោយអង្គការ UNIDO នៅកម្ពុជា បានបង្ហាញថាដោយសារតែកង្វះធនធានហិរញ្ញវត្ថុនិងសមត្ថភាព និងការទទួលបានការគាំទ្រនៅមានកម្រិត សហគ្រាសធុនតូចរងផលប៉ះពាល់ខ្លាំងជាងគេនៅក្នុងវិបត្តិនេះ។ ខណៈដែលគោលនយោបាយ IDP បានគូសបញ្ជាក់យ៉ាងច្បាស់ពីមហិច្ឆតាក្នុងការពង្រឹងសហគ្រាសធុនតូច និងមធ្យម ប៉ុន្តែលទ្ធផលនៃការអនុវត្តដែលទទួលបាននៅមានកម្រិតនៅឡើយ ដូច្នេះគួរមានការបង្កើនការយកចិត្តទុកដាក់ និងការជំរុញការអនុវត្តកិច្ចការនេះនៅក្នុងគោលនយោបាយ IDP សម្រាប់ដំណាក់កាលបន្ទាប់។

# ៦.សេចក្តីសន្និដ្ឋាន និងទិសដៅបន្ត

ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កម្ពុជា ឆ្នាំ២០១៥-២០២៥ តាមរយៈការរៀបចំ និងអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃដ៏ត្រឹមត្រូវ និងច្បាស់លាស់ ពិតជាមានសារៈសំខាន់និងចាំបាច់បំផុតក្នុងការធានាឱ្យបាននូវប្រសិទ្ធភាពនៃការត្រួតពិនិត្យលើវឌ្ឍនភាពដែលសម្រេចបាន និងបញ្ហាប្រឈមនៃការអនុវត្តនាពេលកន្លងមក ដើម្បីលើកសំណើដំណោះស្រាយនិងធ្វើជាមូលដ្ឋានកែតម្រូវនិងតម្រង់ទិសដល់ការអនុវត្តបន្តសម្រាប់ដំណាក់កាលបន្ទាប់។ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយដោយគ្របដណ្តប់ទាំងការវាយតម្លៃលើសមិទ្ធកម្ម, ការរៀបចំនិងការអនុវត្តវិធានការគោលនយោបាយ ដែលក្នុងនោះមានចក្ខុវិស័យចំនួន១, គោលបំណងគោលនយោបាយចំនួន៥, អន្តរាគមន៍គោលនយោបាយចំនួន២០ និងវិធានការគោលនយោបាយចំនួន១២៣។ អភិក្រមចម្រុះនៃវិធីសាស្ត្របែបគុណវិស័យ និងបែបបរិមាណវិស័យ ត្រូវបានប្រើប្រាស់រួមគ្នាដើម្បីធ្វើការវាយតម្លៃនិងទទួលបានលទ្ធផលមួយដែលមានលក្ខណៈវិទ្យាសាស្ត្រ និងផ្អែកលើមូលដ្ឋានភស្តុតាងច្បាស់លាស់ ដោយប្រើទាំងទិន្នន័យពីប្រភពស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិ សម្រាប់វិភាគសូចនាករសមិទ្ធកម្មគន្លឹះទាំងក្នុងកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យ។

ផ្អែកលើការវាយតម្លៃពាក់កណ្តាលអាណត្តិនេះ លទ្ធផលគន្លឹះកម្រិតម៉ាក្រូឬយុទ្ធសាស្ត្រ ដែលបង្ហាញនូវសមិទ្ធកម្មនៃការសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងគោលនយោបាយ ត្រូវបានរំលេចដោយសង្ខេបដូចខាងក្រោម៖

(១) **សមិទ្ធកម្មចក្ខុវិស័យគោលនយោបាយ៖** សមិទ្ធកម្មនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជាបានបង្ហាញថា កម្ពុជាកំពុងធ្វើដំណើរតាមគន្លងដ៏សមស្របមួយ និងសម្រេចបាននូវលទ្ធផលលើសការរំពឹងទុក ប្រសិនបើពិនិត្យទៅលើអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. ដែលបានកើនឡើងពី ២៧,៧% នៅឆ្នាំ២០១៥ រហូតដល់ ៣៤,២% នៅឆ្នាំ២០១៩ លើសគោលដៅដែលបានកំណត់ ៣០% សម្រាប់ឆ្នាំ២០២៥។ ផ្ទុយទៅវិញ បើពិនិត្យទៅលើការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជាដែលប្រើប្រាស់បច្ចេកវិទ្យាកម្រិតមធ្យម និងខ្ពស់ (កំណើនត្រឹម ០,១% ប៉ុណ្ណោះតាំងពីឆ្នាំ២០១៥) បានបង្ហាញឱ្យឃើញថា លទ្ធភាពដែលកម្ពុជាអាចឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យនៃគោលនយោបាយ IDP ក្នុងការជំរុញកែប្រែនិងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ គឺពិតជាមានភាពយឺតយ៉ាវនៅឡើយ ទាំងល្បឿន និងទាំងបរិមាណនៅមានកម្រិត ដែលជាដំណើរវែងឆ្ងាយទៅមុខទៀតរបស់កម្ពុជា និងដែលតម្រូវឱ្យមានការគិតគូរបន្ថែមទៀតពីអង្គពាក់ព័ន្ធទាំងអស់។

(២) សមិទ្ធកម្មគោលបំណងគោលនយោបាយ៖ ការវាយតម្លៃជារួមទៅលើគោលបំណងគោលនយោបាយទាំង៥ បានបង្ហាញឱ្យឃើញថា គោលបំណងចំនួន២ រួមមាន **"គ.ប.ទី២-បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម"** និង **"គ.ប.ទី៤-ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ" សម្រេចបានភាគច្រើន** ដែលបានឆ្លុះបញ្ចាំងរៀងគ្នាតាមរយៈសូចនាករសមិទ្ធកម្មគន្លឹះមួយចំនួន ដូចជា ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ បានកើនឡើងពីចំនួន ៥៣៤ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ដល់ ៨៥៥ដុល្លារអាមេរិក នៅឆ្នាំ២០១៩ និងចំណែកនៃការងារក្នុងវិស័យឧស្សាហកម្ម មានកំណើនរឹងមាំពី១៣,៤% នៅឆ្នាំ២០១៥ ដល់២៨,១% នៅឆ្នាំ២០១៩។ ជាមួយគ្នានេះ គោលបំណងគោលនយោបាយចំនួន២ទៀត គឺ **"គ.ប.ទី១-បង្កើនសកម្មភាពឧស្សាហកម្មៗ"** និង **"គ.ប.ទី៣-សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម" សម្រេចបានដោយផ្នែក** ដែលចង្អុលបង្ហាញដោយសូចនាករសមិទ្ធកម្មគន្លឹះមួយចំនួន។ សមិទ្ធកម្មនៃ គ.ប.ទី១ ត្រូវបានបញ្ជាក់តាមរយៈកំណើនជាប់ជានិច្ចនៃតម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់ ដែលបានកើនឡើងពី ២២៨,៣ ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ដល់ ៣២០,៧ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ប៉ុន្តែតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់បែរជាមានកំណើនយឺតជាងមុនទៅវិញ។ ចំពោះសមិទ្ធកម្មនៃគ.ប.ទី៣ ត្រូវបានបង្ហាញតាមរយៈចំណែកនៃការនាំចេញនៃផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើងធៀបនឹងការនាំចេញសរុបដែលមានការកើនឡើងពី ៥,៦% នៅឆ្នាំ២០១៥ ដល់ ១៥,៥% នៅឆ្នាំ២០២០ ដែលតួលេខនេះបានបង្ហាញថាការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជាមិនមែនពឹងផ្អែក ឬប្រមូលផ្តុំតែលើផលិតផលនាំមុខមួយចំនួននោះទេ មានន័យថាកម្ពុជាបាននិងកំពុងចាប់ផ្តើមពង្រីកការនាំចេញផលិតផលកម្មន្តសាលដទៃផ្សេងទៀតក្រៅពីផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង។ ទោះជាយ៉ាងនេះក្តី ដំណើរការភាពនៃការធ្វើពិពិធកម្មផលិតកម្មហាក់មានវឌ្ឍនភាពយឺត ព្រមទាំងមានលក្ខណៈប្រមូលផ្តុំតែនៅក្នុងអនុវិស័យកម្មន្តសាលមួយចំនួនតូចនៅឡើយ ដូចជា តម្បាញ សម្លៀកបំពាក់និងស្បែកជើង, ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, និងឈើ ក្រដាស និងបោះពុម្ព។

ដោយឡែក វឌ្ឍនភាពនៃគោលបំណងគោលនយោបាយមួយទៀត គឺ **"គ.ប.ទី៥-បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា"** នៅមានកម្រិតនៅឡើយ។ ជញ្ជីងពាណិជ្ជកម្មនៃផលិតផលកម្មន្តសាលមានឱនភាពកាន់តែខ្លាំងឡើងពីត្រឹម ១,២ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០១៥ ឡើងដល់ ៤,៧ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩។ ទន្ទឹមនឹងនេះ ចំណែកនៃតម្លៃបន្ថែមក្នុង វិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាល បានថយចុះជាបន្តបន្ទាប់ពីប្រមាណ ៣០,៧% នៅឆ្នាំ២០១៥ មកត្រឹម ២៣,៧% នៅឆ្នាំ២០១៩ ហើយការប្រើប្រាស់វត្ថុធាតុដើមពីក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក ដើម្បីជំរុញការបង្កើនការតភ្ជាប់ឧស្សាហកម្មនៅមានបញ្ហាប្រឈមជាច្រើន ទាំងការប្រកួតប្រជែង គុណភាព និងតម្លៃ។

និន្នាការទាំងនេះ បង្ហាញថាឧស្សាហកម្មប្រតិគមន៍ និងខ្សែច្រវាក់តម្លៃក្នុងស្រុក ពុំទាន់ត្រូវបានពង្រឹងឱ្យមានប្រសិទ្ធភាពនៅឡើយ។

ចំពោះការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ ក្នុងចំណោមវិធានការគោលនយោបាយទាំង១២៣ មានវិធានការចំនួន១១ ត្រូវបានពិនិត្យឃើញថា មានលក្ខណៈពហុបំណងហើយដែលត្រូវបានបំបែកជាអនុវិធានការចំនួន២៦ ដោយក្រសួង ស្ថាប័នទទួលខុសត្រូវនាំមុខលើការអនុវត្តវិធានការទាំងនោះ។ ដូច្នេះ សរុបទាំងវិធានការនិងអនុវិធានការ មានចំនួន១៣៨។ ជាលទ្ធផល **វិធានការចំនួន៧៧ ស្មើនឹង ៥៦% សម្រេចបានពេញលេញ, វិធានការចំនួន ២៨ ស្មើនឹង២០% កំពុងបន្តអនុវត្តក្នុងកាលបរិច្ឆេទគោលដៅ និងវិធានការចំនួន ៣២ ទៀត ស្មើនឹង២៣% មានភាពយឺតយ៉ាវ** ក្នុងការអនុវត្តដោយផុតកាលបរិច្ឆេទគោលដៅទៅហើយ។

យ៉ាងណាមិញ ការរីករាលដាលនៃជំងឺកូវីដ-១៩ ចាប់តាំងពីចុងឆ្នាំ២០១៩មក គឺជាបញ្ហាប្រឈម និងការរំខានធំបំផុតនៃសកលភាវូបនីយកម្មក្នុងប្រវត្តិសាស្ត្រទំនើប ដែលបានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ច និងសង្គម។ កម្ពុជាក៏ដូចជាបណ្តាប្រទេសផ្សេងៗដែរ ការរីករាលដាលនៃជំងឺកូវីដ-១៩ បាននាំមកនូវផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យមួយចំនួន ដូចជា វិស័យសេវាកម្មដែលរួមមានសកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ ការលក់ដុំ-លក់រាយ, ការដឹកជញ្ជូននិងភស្តុភារកម្ម, វិស័យសំណង់និងអចលនទ្រព្យ និងវិស័យកម្មន្តសាល ជាដើម។ វិស័យដែលរងផលប៉ះពាល់តិចជាងគេនោះគឺ វិស័យកសិកម្ម។ ក្នុងបរិការណ៍នេះ ការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា អាចប្រឈមនឹងការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកលដែលមាននិន្នាការធំៗចំនួន ៣ បានលេចឡើងគឺ ១) បដិសកលភាវូបនីយកម្ម និងការរៀបចំឡើងវិញនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល, ២) ការបង្កើនការយកចិត្តទុកដាក់លើការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាព, និង ៣) ការថយចុះនៃតួនាទីរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងផលិតកម្មឧស្សាហកម្មទំនើបបន្ទាប់ពីជំងឺកូវីដ-១៩។ និន្នាការទាំងនេះទាមទារឱ្យមានការគិតគូរ និងរៀបចំឡើងវិញនូវយុទ្ធសាស្ត្រមួយចំនួនដើម្បីឆ្លើយតបទៅនឹងរបត់ថ្មីៗនេះ។

ជារួម ការដាក់ចេញនិងការអនុវត្តគោលនយោបាយ IDP រយៈពេល៥ឆ្នាំកន្លងមកនេះ ថ្វីត្បិតតែយើងទទួលបានលទ្ធផលល្អមួយចំនួន និងលទ្ធផលមួយចំនួនទៀតនៅមានភាពយឺតយ៉ាវ ឬមិនទាន់ស្របនឹងការរំពឹងទុកក៏ដោយ។ បើពិនិត្យទៅលើទិដ្ឋភាពមួយទៀត ក្នុងរយៈពេល៥ឆ្នាំកន្លងមកបន្ទាប់ពី IDP ត្រូវបានដាក់ឱ្យអនុវត្ត គឺជាដំណាក់កាលដែលកម្ពុជាបាននិងកំពុងអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករូបវន្ត (ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូននិងភស្តុភារកម្ម ការកសាងផ្លូវល្បឿនលឿន ការពង្រីកវិសាលភាពនិងពង្រឹងគុណភាពនៃការផ្គត់ផ្គង់អគ្គិសនី ។ល។) និងទាំងផ្នែកទន់ (ច្បាប់និងបទដ្ឋានគតិយុត្តិ ប្រព័ន្ធឌីជីថល ថ្នាលបច្ចេកវិទ្យា ជាដើម) ហើយដែលហេដ្ឋារចនាសម្ព័ន្ធទាំងនោះអាចនឹងមិនទាន់មានបច្ច័យភ្លាមៗដល់គោលបំណងគោលនយោបាយដែលជាលទ្ធផលរំពឹងទុកសម្រាប់រយៈពេល

៥ឆ្នាំកន្លងមកនេះ ប៉ុន្តែសម្រាប់ រយៈពេល៥ឆ្នាំខាងមុខ និងឆ្នាំបន្តបន្ទាប់។ ជាមួយគ្នានេះ ការដាក់ចេញ និងការរៀបចំនូវច្បាប់ បទដ្ឋានគតិយុត្តគោលនយោបាយ និងក្របខណ្ឌគោលនយោបាយមួយចំនួនទៀត ដូចជា ច្បាប់ស្តីពីវិនិយោគ, ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥, សេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣០, ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍២០៣០ (STI Roadmap 2030) និងសេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ឆ្នាំ២០២១-២០២៦ ក៏នឹងមានបច្ច័យទៅលើការសម្រេចបាននូវគោលបំណងរបស់គោលនយោបាយ IDP ផងដែរ។

ឈរលើលទ្ធផលនៃការវាយតម្លៃខាងលើនេះ និងផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ-១៩ ការកំណត់ទស្សនវិស័យ ឬការប្រមើលមើលទៅថ្ងៃខាងមុខ ព្រមទាំងសំណើអនុសាសន៍គោលនយោបាយជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់បញ្ចូលនៅក្នុងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនេះ។ ក្នុងន័យនេះ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ គឺជាឯកសារឆ្លុះបញ្ចាំងដែលមានមូលដ្ឋានរឹងមាំនិងច្បាស់លាស់សម្រាប់ជូនរាជរដ្ឋាភិបាល និងអង្គពាក់ព័ន្ធ ពិនិត្យពិចារណាក្នុងការកំណត់គោលដៅថ្មី, ការតម្រង់ទិសសម្រាប់ការអនុវត្តបន្ត, និងការដាក់ចេញនូវវិធានការជាកញ្ចប់ដែលនឹងដើរតួនាទីជាកូនសោគន្លឹះដ៏ស័ក្តិសិទ្ធិក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានរកឃើញខាងលើ ហើយទន្ទឹមគ្នានេះដែរ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិការណ៍ថ្មីៗ ដូចជា បដិវត្តន៍ឧស្សាហកម្ម៤.០ បរិវត្តកម្មឌីជីថល និងការរីករាលដាលនៃជំងឺកូវីដ-១៩ សំដៅជំរុញសម្រេចឱ្យបានពេញលេញនូវគោលបំណង និងចក្ខុវិស័យនៃគោលនយោបាយនេះ ព្រមទាំងអាចចូលរួមស្តារនិងពន្លឿនកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យល្អប្រសើរឡើងវិញតាមប្រក្រតីភាពនៃគន្លងថ្មី។

ការដាក់ចេញគោលនយោបាយ IDP នៅឆ្នាំ២០១៥ បានគូសបញ្ជាក់ពីភាពចាំបាច់និងភាពបន្ទាន់ក្នុងការបង្កើតនូវ "យុទ្ធសាស្ត្រកំណើនថ្មី" ដើម្បីឆ្លើយតបនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក ព្រមទាំងដើម្បីជាមូលដ្ឋានក្នុងការសម្រេចបាននូវចក្ខុវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ២០៣០។ តាមរយៈចក្ខុវិស័យ "**ជំរុញកែប្រែ និងធ្វើទំនើបកម្មឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥**" កម្ពុជាមានគោលដៅជំរុញការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃសកល និងសមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡាទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពផលិតកម្មក្នុងស្រុក ក៏ដូចជាបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើបដែលផ្អែកលើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។

## ៦.សេចក្តីសន្និដ្ឋាន និងទិសដៅបន្ត

ចាប់តាំងពីការដាក់ឱ្យអនុវត្តគោលនយោបាយ IDP ស្ថានការណ៍ភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចបានវិវត្តជាបន្តបន្ទាប់ ក្នុងនោះរួមមាន ការប្រេយមរវាងប្រទេសមហាអំណាច សង្គ្រាមបច្ចេកវិទ្យា និងពាណិជ្ជកម្ម ក៏ដូចជាចរន្តថ្មីនៃសេដ្ឋកិច្ចសកល ដែលឆ្លុះបញ្ចាំងតាមរយៈការមកដល់យ៉ាងឆាប់រហ័សនៃឧស្សាហកម្មទី៤ បរិវត្តកម្មឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាបៃតង។ កត្តាទាំងនេះ បាននិងកំពុងជំរុញឱ្យនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងសកលមានការប្រែប្រួលខុសពីការរំពឹងទុក។ ជាមួយគ្នានេះ ពិភពលោកក៏បាននិងកំពុងជួបប្រទះបញ្ហាប្រឈមផ្នែកសង្គម និងសេដ្ឋកិច្ចបង្កឡើងដោយការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានពន្លឿនការប្រែប្រួលផ្នែកសេដ្ឋកិច្ច ក៏ដូចជាជំរុញបន្ថែមទៀតនូវនិន្នាការបដិសកលភាវូបនីយកម្ម និងការរៀបចំឡើងវិញនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល។ ស្ថានការណ៍ទាំងអស់នេះ សុទ្ធសឹងជាកត្តាសត្យានុម័តសំខាន់ៗដែលបាននិងកំពុងជះឥទ្ធិពលដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម។

ផ្អែកតាមបេកគំហើញនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ និងដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលបរិការណ៍ខាងលើ ការពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវនិងភាពពាក់ព័ន្ធនៃចក្ខុវិស័យ IDP គឺជាកិច្ចការចាំបាច់សម្រាប់តម្រង់ទិសការអនុវត្តក្នុងដំណាក់កាលបន្ទាប់។ ក្នុងន័យនេះ ដើម្បីពន្លឿន និងធានាប្រសិទ្ធភាពនៃការកំណត់ទិសដៅបន្ទាប់នៃគោលនយោបាយ IDP រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូន **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ដឹកនាំការសិក្សាវាយតម្លៃលម្អិតទៅលើនិន្នាការ និងការផ្លាស់ប្តូរនៃនិម្មាបនកម្មតំបន់ និងសកល ទាំងផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយ ដើម្បីកែសម្រួលចក្ខុវិស័យ គោលដៅ និងគោលបំណងនៃគោលនយោបាយ IDP សម្រាប់រយៈពេលបន្តខាងមុខ ដោយមានការចូលរួមសហការពីលេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្តគោលនយោបាយ IDP នៃ ក.អ.ក។ ទន្ទឹមនឹងនេះ ការងារតាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ប្រចាំឆ្នាំសម្រាប់ឆ្នាំបន្តបន្ទាប់ និងចុងអាណត្តិ ត្រូវបន្តសម្របសម្រួលដោយ ក.អ.ក។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ត្រូវបន្តពង្រឹងការអនុវត្តឱ្យកាន់តែសកម្មចំពោះវិធានការគោលនយោបាយដែលខ្លួនទទួលខុសត្រូវដូចបានកំណត់ក្នុងឯកសារគោលនយោបាយ IDP បច្ចុប្បន្ន និងក្រោយឯកសារនេះត្រូវបានធ្វើបច្ចុប្បន្នកម្មនាពេលខាងមុខ៕

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១៖ ការរួមចំណែករបស់អន្តរាគមន៍គោលនយោបាយចម្បងក្នុងគោលបំណង IDP

## ១. ការរួមចំណែករបស់អន្តរាគមន៍គោលនយោបាយចម្បងក្នុងគោលបំណងទី១ “បង្កើនសកម្មភាពឧស្សាហកម្ម”

### ១.១. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល”

#### ១.១.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.១៖ ផលធៀបរវាងការនាំចូលផលិតផលកម្មន្តសាលធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល គិតជាភាគរយ (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ WITS និង ក្រសួងផែនការ

រូបភាពទី១.១ បង្ហាញពីផលធៀបរវាងការនាំចូលផលិតផលកម្មន្តសាល ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៩។ ផលធៀបនេះតាងឱ្យកម្រិតនៃការពឹងផ្អែកទៅលើការនាំចូលផលិតផលកម្មន្តសាលដើម្បីផ្គត់ផ្គង់ជាធាតុចូលផលិតកម្មនិងការប្រើប្រាស់ក្នុងស្រុក។ នៅឆ្នាំ២០០៥ ផលធៀបនេះមានទំហំប្រមាណ២២៦% ដែលបង្ហាញឱ្យឃើញថា ការនាំចូលផលិតផលកម្មន្តសាលមានទំហំធំជាងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលទ្វេដង។ ផលធៀបនេះកើនឡើងជាលំដាប់ក្នុងអំឡុងពេលនៃការអនុវត្ត គោលនយោបាយ IDP ដោយនៅចន្លោះឆ្នាំ២០១៨ និងឆ្នាំ២០១៩ ការនាំចូលផលិតផលកម្មន្តសាល មានទំហំកាន់តែធំរហូតស្មើនឹង ៥ដង នៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល។ តួលេខផលធៀបកាន់តែធំ សបញ្ជាក់ថា ទំហំនៃការនាំចូលផលិតផលកម្មន្តសាលកើនឡើងលឿនជាងទំហំនៃផលិតផលកម្មន្តសាលដែលកម្ពុជាបានផលិត ប្រការនេះឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាមិនទាន់បានជំរុញផលិតកម្មក្នុងស្រុកឱ្យអស់សក្តានុពលនៅឡើយ។

#### ១.១.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

លទ្ធផលនៃការវាយតម្លៃបែបគុណវិស័យ បានបង្ហាញថា ពុំមានវិធានការណាមួយក្នុងគោលនយោបាយ IDP ដែលបានចែងជាក់លាក់អំពីការបង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូលនោះឡើយ។

សម្រាប់ជំហានបន្ទាប់នៃការអនុវត្តគោលនយោបាយ IDP រាជរដ្ឋាភិបាល គួរដាក់ចេញនូវវិធានការថ្មីៗដែលរួមចំណែកសម្រេចនូវលទ្ធផលរំពឹងទុកក្នុងអន្តរាគមន៍គោលនយោបាយមួយនេះ។

### ១.២. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម"

#### ១.២.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.២៖ ការវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រូបភាពទី១.២ បង្ហាញពីទំហំទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៩។ ក្នុងអំឡុងពេលមុនការដាក់ចេញគោលនយោបាយ IDP ទំហំទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្មបានកើនឡើងជាបន្តបន្ទាប់ពី ២១៧លានដុល្លារអាមេរិក នៅឆ្នាំ២០០៥ ដល់ ១.៦៥៣លានដុល្លារអាមេរិក នៅឆ្នាំ២០១៥ តាមអត្រាកំណើនប្រមាណ២២,៥% ក្នុងមួយឆ្នាំ។ ក្រោយការដាក់ចេញ គោលនយោបាយ IDP ទុនវិនិយោគនេះនៅតែបន្តកើនឡើង រហូតដល់ ៣,២ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ ប៉ុន្តែស្ថិតក្នុងអត្រាកំណើនយឺតជាងមុន ពោលគឺប្រមាណ ១៨% ក្នុងមួយឆ្នាំ។ ជារួម ការវិនិយោគដោយវិនិយោគិនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម នៅតែមានភាពប្រសើរឡើងជាលំដាប់ ដែលបានជួយជំរុញកំណើនចំនួនការងារក្នុងស្រុកឱ្យមានស្ថិរភាព។

រូបភាពទី១.៣៖ វិហរូទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល (២០០៨-២០១៩)




ប្រភពទិន្នន័យ៖ ធនាគារជាតិនៃកម្ពុជា

រូបភាពទី១.៣ បង្ហាញពីវិហរូទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩។ ទុនវិនិយោគនេះបានកើនឡើងពី ១៦៣លានដុល្លារអាមេរិក នៅឆ្នាំ២០០៨ ដល់ ៤៩៧លានដុល្លារអាមេរិក នៅឆ្នាំ២០១៥ តាមអត្រាកំណើនប្រមាណ ១៧% ក្នុងមួយឆ្នាំ។ ក្រោយការដាក់ចេញគោលនយោបាយ IDP វិហរូទុនវិនិយោគនេះមានការថយចុះបន្តិចនៅចន្លោះឆ្នាំ២០១៥ និងឆ្នាំ២០១៧ ដែលអាចបណ្តាលមកពីការថយចុះនៃវិហរូទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងឧស្សាហកម្មកែច្នៃផលិតផលឈើ។ យ៉ាងណាក្តី ទុនវិនិយោគនេះបានកើនឡើងវិញនៅឆ្នាំបន្តបន្ទាប់ រហូតដល់ ៦៣១លានដុល្លារអាមេរិក នៅឆ្នាំ២០១៩។ បើពិនិត្យលើសន្ទុះកំណើន ទោះបីជាកំណើនទុនវិនិយោគក្នុងដំណាក់កាលដំបូងនៃការអនុវត្តគោលនយោបាយ IDP (៦%/ឆ្នាំ) ស្ថិតក្នុងអត្រាមួយដែលវិជ្ជមាន ប៉ុន្តែកំណើននេះហាក់ដូចជាយឺតជាងកំណើនទុនវិនិយោគមុនពេលដាក់ចេញគោលនយោបាយ IDP (១៧%/ឆ្នាំ)។

ជារួម ទំហំទុនវិនិយោគក្នុងស្រុក និងទុនវិនិយោគផ្ទាល់ពីបរទេស នៅតែរក្សាកំណើនវិជ្ជមាន ទាំងមុន និងក្រោយការដាក់ចេញគោលនយោបាយ IDP។ យ៉ាងណាក្តី វិហរូទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល ហាក់ដូចជាមានសន្ទុះកំណើនក្នុងល្បឿនមួយយឺតនៅឡើយក្នុងប៉ុន្មានឆ្នាំចុងក្រោយ។ និន្នាការនេះ បង្ហាញថា ការអភិវឌ្ឍខ្លួនរបស់កម្ពុជាឱ្យកាន់តែមានភាពទាក់ទាញសម្រាប់វិនិយោគិនបរទេសមកវិនិយោគក្នុងវិស័យឧស្សាហកម្ម នៅមានកម្រិតនៅឡើយ។

រូបភាពទី១.៤៖ ចំណែកនៃការវិនិយោគលើសម្ភារៈបរិក្ខារជាប់បានយូរ (Durable equipment) ធៀបនឹងការកកើតទុនអចល័តសរុប (Gross Fixed Capital Formation) (២០០៥-២០១៨)




ប្រភពទិន្នន័យ៖ ក្រសួងផែនការ

រូបភាពទី១.៤ បង្ហាញពីចំណែកនៃការវិនិយោគលើសម្ភារៈបរិក្ខារជាប់បានយូរ (Durable equipment) ធៀបនឹងការកកើតទុនអចល័តសរុប (Gross Fixed Capital Formation) ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៨។ សូចនាករនេះត្រូវបានប្រើសម្រាប់វាស់វែងស្ថានភាពវិនិយោគលើទំនិញមូលធន ដូចជាគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខារដែលត្រូវបានសហគ្រាសប្រើប្រាស់ជាបន្តបន្ទាប់នៅក្នុងដំណើរការផលិតកម្ម។ ចំណែកនៃការវិនិយោគលើសម្ភារៈបរិក្ខារជាប់បានយូរ ធៀបនឹងការកកើតទុនអចល័តសរុប បានកើនឡើងតិចតួច ពី ៣៥.៩% នៅឆ្នាំ២០០៥ ដល់៣៧% នៅឆ្នាំ២០១៥។ ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP (២០១៥-២០១៨) ចំណែកនេះបានធ្លាក់ចុះបន្តិចមកវិញប្រមាណ ០,៣% ក្នុងមួយឆ្នាំ ដែលជាសញ្ញាបង្ហាញពីការថមថយនៃការបណ្តាក់ទុនវិនិយោគក្នុងសកម្មភាពផលិតកម្ម។

### ១.២.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

គោលនយោបាយ IDP បានផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការទាក់ទាញវិនិយោគឯកជនក្នុងវិស័យឧស្សាហកម្ម ដោយបានដាក់ចេញនូវវិធានការគោលនយោបាយជាច្រើន (សរុប ១៥ វិធានការ) ទាក់ទងនឹងការលើកកម្ពស់ការវិនិយោគ ដែលត្រូវបានកំណត់ជាយុទ្ធសាស្ត្រចម្បងទី១ ក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗទាំង ៤ ដែលមានចែងក្នុងគោលនយោបាយ IDP។ វិធានការភាគច្រើនដែលទាក់ទងនឹងការវិនិយោគ ត្រូវបានអនុវត្តរួមគ្នាដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាដើម។ វិធានការទាំង១៥នេះ អាចបែងចែកជា៣ចង្កោមវិធានការគោលនយោបាយ គឺ៖ (១) ការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌបទប្បញ្ញត្តិ និងនីតិវិធីរដ្ឋបាល សម្រាប់វិនិយោគិន (មាន ១១វិធានការ), (២) ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់និងការទទួលបាននូវព័ត៌មានវិនិយោគសម្រាប់វិនិយោគិន (មាន ២វិធានការ) និង (៣) ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាស (មាន ៣វិធានការ)។

រូបភាពទី១.៥៖ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម"




ចង្កោមវិធានការចំនួន២ ពាក់ព័ន្ធនឹងក្របខណ្ឌគតិយុត្ត និងការផ្តល់ព័ត៌មានសម្រាប់វិនិយោគិន គឺជាចង្កោមវិធានការសំខាន់ដែលគោលនយោបាយ IDP យកចិត្តទុកដាក់បំផុត។ ចង្កោមវិធានការទី១ មាន ១១ វិធានការ ដោយក្នុងនោះ ៤ វិធានការ ត្រូវបានចាត់ទុកជាវិធានការច្បាស់លាស់ សំដៅលើកកម្ពស់បរិយាកាសធុរកិច្ច និងវិនិយោគទាំងមុនពេលចុះបញ្ជី (តាមរយៈសេវាច្រកចេញ-ចូលតែមួយ) និងក្រោយពេលចុះបញ្ជីស្ថាពរនៃគម្រោងវិនិយោគ (តាមរយៈសេវាថែទាំវិនិយោគ)។ វិធានការផ្សេងទៀតដែលនៅសល់ មានលក្ខណៈបំពេញបន្ថែម ដោយមានគោលបំណងបង្កើតនូវក្របខណ្ឌលើកទឹកចិត្តវិនិយោគឆ្លាតវៃជាងមុន (ឧទាហរណ៍៖ តាមរយៈការរៀបចំច្បាប់ថ្មីស្តីពីវិនិយោគ ជាដើម) ដើម្បីទាក់ទាញគម្រោងវិនិយោគគោលដៅ និងពង្រឹងសមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការផ្តល់សេវាទាក់ទងនឹងការវិនិយោគប្រកបដោយគុណភាពខ្ពស់។ ចង្កោមវិធានការទី២ មាន ២វិធានការ សុទ្ធសឹងជាវិធានការច្បាស់លាស់ សំដៅរួមចំណែកលើកកម្ពស់អភិវឌ្ឍប្រទេសកម្ពុជាឱ្យក្លាយជាគោលដៅវិនិយោគដ៏ទាក់ទាញលើឆាកអន្តរជាតិ និងជួយសម្រួលការផ្លាស់ប្តូរព័ត៌មានវិនិយោគរវាងរដ្ឋនិងវិស័យឯកជន (ដូចជា តាមរយៈវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន)។

ដោយឡែក ចង្កោមវិធានការទី៣ បង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការសម្រួលឱ្យវិនិយោគិន ទទួលបានហិរញ្ញវត្ថុ តាមរយៈការពង្រឹងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ចង្កោមវិធានការនេះមានវិធានការចំនួន២។ វិធានការទី១ ទាក់ទងនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ត្រូវបានចាត់ទុកជាវិធានការច្បាស់លាស់ ដែលមានគោលបំណងជំរុញវិស័យហិរញ្ញវត្ថុឱ្យមានភាពរស់រវើក និងផ្តល់មធ្យោបាយកាន់តែប្រសើរដល់វិនិយោគិនក្នុងការទទួលបាននូវហិរញ្ញប្បទានសម្រាប់ពង្រីកសកម្មភាពវិនិយោគរបស់ខ្លួន។ វិធានការទី២ សំដៅបង្កើតមូលបត្រតនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម។ ការបង្កើតមូលបត្រតនាគារ មិនត្រឹមតែជួយកាត់បន្ថយហានិភ័យ និងបង្កើនទំនុកចិត្តលើការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍគម្រោងវិនិយោគយុទ្ធសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការផ្តល់នូវការលើកទឹកចិត្ត

ដល់គម្រោងវិនិយោគឯកជនធំៗផងដែរ។ យ៉ាងណាក្តី វិធានការទី២នេះមិនបានចែងលម្អិតអំពីមធ្យោបាយជាក់លាក់ក្នុងការអនុវត្តឡើយ។

### ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ គាំទ្រដោយវិធានការគោលនយោបាយដែលមានភាពបំពេញបន្ថែមគ្នា ពិសេសទាក់ទងនឹងការជំរុញវិនិយោគទូទៅ។ ការរួមបញ្ចូលគ្នានៃចង្កោមវិធានការទី១ និងទី២ បង្កើតបានជាកញ្ចប់វិធានការបំពេញបន្ថែមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ជាក់ស្តែង ការពង្រឹងសេវាថៃទាំវិនិយោគ និងសេវាច្រកចេញចូលតែមួយ ព្រមទាំងការសម្រួលនីតិវិធីនិងបទប្បញ្ញត្តិផ្សេងទៀត សុទ្ធសឹងជាវិធានការដែលមានលក្ខណៈបំពេញឱ្យគ្នាទៅវិញទៅមក ក្នុងការទាក់ទាញគម្រោងវិនិយោគថ្មីៗនិងថែទាំគម្រោងវិនិយោគដែលមានស្រាប់។ ការបណ្តុះបណ្តាលមន្ត្រីផ្តល់សេវា ក៏រួមចំណែកដល់ការបង្កើនគុណភាពនៃការផ្តល់សេវាពាក់ព័ន្ធជូនវិនិយោគិន។ រីឯការពង្រឹងប្រសិទ្ធភាពនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដែលជាយន្តការកម្រិតខ្ពស់នៃការផ្លាស់ប្តូរព័ត៌មានវិនិយោគរវាងរដ្ឋនិងឯកជន ក៏ជាវិធានការសំខាន់ដែលជួយអន្តរាគមន៍ក្នុងការកែសម្រួលនីតិវិធី និងគោលនយោបាយនានាឱ្យមានភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់វិស័យឯកជន ទន្ទឹមគ្នានឹងការបន្តបង្កើនការផ្សព្វផ្សាយគ្រប់រូបភាពអំពីសក្តានុពលវិនិយោគនៅកម្ពុជា។ សរុបមក ផ្អែកលើការវិភាគតាមបែបគុណវិស័យ បង្ហាញឱ្យឃើញថា គ្មានវិធានការណាមួយដែលមានខ្លឹមសារប្រឆាំងគ្នាក្នុងចំណោមវិធានការទាំង១៥ទេ។

### ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃវិធានការគោលនយោបាយ

លទ្ធផលវិភាគបែបគុណវិស័យ បង្ហាញថា ការរៀបចំអន្តរាគមន៍គោលនយោបាយនេះពុំមានភាពខ្វះចន្លោះគួរឱ្យកត់សម្គាល់ ដែលអាចរារាំងដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការដែលគាំទ្រដល់ការជំរុញការវិនិយោគក្នុងវិស័យឧស្សាហកម្មឡើយ។ បើពិនិត្យលើស័ក្តិសិទ្ធភាពនៃការរៀបចំគោលនយោបាយ យើងសង្កេតឃើញថា ខ្លឹមសារវិធានការមួយចំនួនមានលក្ខណៈស្ទួនគ្នា ដែលទាមទារឱ្យមានការសម្របសម្រួលនិងការពិគ្រោះយោបល់បន្ថែមទៀតក្នុងចំណោមបណ្តាក្រសួង ស្ថាប័នដែលទទួលបន្ទុកអនុវត្ត។ ជាក់ស្តែង វិធានការចំនួន៣ រួមមាន៖ "ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានការច្បាប់ពាក់ព័ន្ធដទៃទៀត...", "ពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ..." និង "ពិនិត្យឡើងវិញនូវក្របខណ្ឌលើកទឹកចិត្តសម្រាប់...ក្រុមហ៊ុននិងសហគ្រាសធុនតូច និងមធ្យមដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស" ត្រូវបានអនុវត្តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នដឹកនាំការអនុវត្តរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ វិធានការទាំងនេះសុទ្ធសឹងតែពាក់ព័ន្ធនឹងការកែសម្រួលច្បាប់និងបទប្បញ្ញត្តិស្តីពីវិនិយោគដូចគ្នា ដូច្នេះគួរច្របាច់បញ្ចូលវិធានការទាំងនេះជាវិធានការគោលនយោបាយតែមួយ។

សរុបមក ការវាយតម្លៃតាមបែបគុណវិស័យបានបង្ហាញឱ្យឃើញថា ការលើកកម្ពស់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម ត្រូវបានចាត់ទុកជាអន្តរាគមន៍គោលនយោបាយគន្លឹះនៃគោលនយោបាយ IDP ដែលគាំទ្រដោយវិធានការយ៉ាងច្រើន។ អន្តរាគមន៍គោលនយោបាយនេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់

ជាពិសេសចំពោះអតិក្រមនៃការទាក់ទាញវិនិយោគទូទៅ ដោយផ្តោតសំខាន់លើការសម្រួលនីតិវិធីរដ្ឋបាល និងបង្កើនការផ្លាស់ប្តូរព័ត៌មានវិនិយោគរវាងស្ថាប័នរដ្ឋនិងវិស័យឯកជន។ យ៉ាងណាក្តី ការរៀបចំវិធានការមួយចំនួនក្នុងចំណោម ១៥ វិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះ នៅមិនទាន់មានភាពច្បាស់លាស់ដែលទាមទារនូវការបកស្រាយលម្អិតបន្ថែមទៀត។ ការវាយតម្លៃនេះក៏បានបង្ហាញឱ្យឃើញផងដែរថា កង្វះការសម្របសម្រួលគោលនយោបាយក្នុងការលើកកម្ពស់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម អាចជាមូលហេតុបណ្តាលឱ្យវិធានការមួយចំនួនតូចមានលក្ខណៈស្ទួនគ្នា។ ដូច្នេះ ការពិនិត្យ និងច្របាច់បញ្ចូលគ្នានូវវិធានការមួយចំនួន ជាមួយនឹងវិធានការលើកកម្ពស់ការវិនិយោគចំគោលដៅ គឺជាកិច្ចការដ៏មានសារៈសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការទាក់ទាញការវិនិយោគក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា។

### ១.២.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

គោលនយោបាយ IDP កំណត់វិធានការគោលនយោបាយចំនួន ១៥ ដើម្បីគាំទ្រដល់អន្តរាគមន៍គោលនយោបាយនេះ។ វិធានការគោលនយោបាយចំនួន ២ ត្រូវបានចាត់ទុកជាវិធានការពហុសហកម្មភាព ដូចនេះវិធានការទាំងនេះ ត្រូវបានបែងចែកជាអនុវិធានការចំនួន៤។ ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តវិធានការដែលជាវិធានការពហុសកម្មភាពទាំងនេះ មានតែអនុវិធានការគោលនយោបាយប៉ុណ្ណោះ ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃ។ ក្នុងចំណោមវិធានការគោលនយោបាយចម្បង ឬអនុវិធានការគោលនយោបាយសរុបចំនួន ១៧, វិធានការគោលនយោបាយចំនួន ១០ សម្រេចបានពេញលេញ, វិធានការគោលនយោបាយចំនួន ១ កំពុងអនុវត្ត និងវិធានការគោលនយោបាយចំនួន ៦ ផ្សេងទៀត មានការយឺតយ៉ាវ។

រូបភាពទី១.៦៖ ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម"






ចំពោះចង្កោមវិធានការគោលនយោបាយទី ១ ដែលផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគតិយុត្តិ ក៏ដូចជានីតិវិធីនិងសេវារដ្ឋបាលនានាសម្រាប់វិនិយោគិន មានវិធានការគោលនយោបាយចំនួន៥ សម្រេចបានពេញលេញ និងវិធានការគោលនយោបាយចំនួន៦ មានការយឺតយ៉ាវ។ វិធានការគោលនយោបាយទាំង៥ ដែលបានសម្រេចពេញលេញ បានបង្ហាញពីបច្ច័យវិជ្ជមាន ដែលក្នុងនោះសេវារដ្ឋបាលសំខាន់ៗចំនួន២ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការគឺ សេវាច្រកចេញចូលតែមួយ និងសេវាថែទាំវិនិយោគ។ ជាលទ្ធផល ក្នុងរយៈកាល ៥ឆ្នាំ (២០១៥-២០២០) កន្លងមក គម្រោងវិនិយោគថ្មី ចំនួន ៧០៩ ត្រូវបានទទួលស្គាល់ជាគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទំហំទុនវិនិយោគសរុបប្រមាណ ៣៥,៨ប៊ីលានដុល្លារអាមេរិក និងគម្រោងពង្រីកចំនួន ១៥២ ដែលមានទំហំទុនវិនិយោគសរុបប្រមាណ ២,៣ប៊ីលានដុល្លារអាមេរិក ត្រូវបានអនុម័ត។ ដោយ

ឡែក វិធានការគោលនយោបាយចំនួន ៦ ដែលគាំទ្រចង្កោមវិធានការគោលនយោបាយនេះ មានការយឺតយ៉ាវ។ បញ្ហាប្រឈមចម្បងដែលក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្តបានជួបប្រទះគឺ កង្វះពេលវេលា និងធនធាន (ធនធានមនុស្ស និងហិរញ្ញវត្ថុ) និងការផ្លាស់ប្តូរស្ថាប័នទទួលបន្ទុកអនុវត្តនិងសម្របសម្រួល។ ក្រសួង ស្ថាប័នដែលទទួលបន្ទុកអនុវត្តបានស្នើនូវដំណោះស្រាយមួយចំនួនចំពោះបញ្ហាខាងលើ ដូចជា៖ ១) ការកៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍និង/ឬប្រភពផ្សេងទៀត, និង ២) ការពន្លឿនដំណើរនៃការរៀបចំកិច្ចចរចានិងការចុះហត្ថលេខាលើអនុស្សារណៈយោគយល់ជាមួយភាគីពាក់ព័ន្ធ (ជាពិសេស ចំពោះការអនុវត្តវិធានការគោលនយោបាយ "ការអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង..." )។

ចំពោះចង្កោមវិធានការគោលនយោបាយទី២ ដែលត្រូវបានកំណត់ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពងាយស្រួលក្នុងការទទួលបានព័ត៌មានស្តីពីវិនិយោគ មានវិធានការគោលនយោបាយចំនួន២ ដែលសម្រេចពេញលេញ។ ការរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (GPSF) បានក្លាយជាករណីជោគជ័យនៃការបង្កើតឱ្យមានកិច្ចសន្ទនារវាងរដ្ឋនិងវិស័យឯកជននៅកម្ពុជា។ ក្រុមការងារដែលបានបង្កើតឡើងក្រោមយន្តការនៃវេទិកានេះ បានបំពេញការងារយ៉ាងមានប្រសិទ្ធភាព ដោយបានរៀបចំកិច្ចប្រជុំពិភាក្សាដើម្បីដោះស្រាយបញ្ហាបានយ៉ាងទៀងទាត់ ដូច្នេះហើយទើបវេទិកានេះមិនត្រូវបានរៀបចំក្នុងអំឡុងពេលពីឆ្នាំ២០១៤ ដល់ ២០១៨។ នៅឆ្នាំ២០១៩ វេទិកានេះត្រូវបានរៀបចំម្តងទៀត និងទទួលបានការវាយតម្លៃខ្ពស់ពីសំណាក់វិស័យឯកជននិងតួអង្គពាក់ព័ន្ធផ្សេងទៀត។ បញ្ហាប្រមាណ ៩០% ដែលបានលើកឡើង ត្រូវបានដោះស្រាយក្នុងកម្រិត ក្រុមការងារ និងក្នុងវេទិកាផ្ទាល់តែម្តង។ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ វេទិកានេះ ពុំត្រូវបានរៀបចំឡើយនៅឆ្នាំ២០២០។

ចង្កោមវិធានការគោលនយោបាយទី៣ ដែលសំដៅធ្វើឱ្យប្រសើរឡើងនូវការទទួលបានហិរញ្ញវត្ថុ មានវិធានការចម្បង ឬអនុវិធានការចំនួន ៣ ក្នុងនោះមានវិធានការគោលនយោបាយចំនួន ២ បានសម្រេចពេញលេញ និងវិធានការគោលនយោបាយចំនួន ១ កំពុងត្រូវបានអនុវត្តនៅឡើយ។ ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១១-២០២០ សម្រេចបាននូវលទ្ធផលជាផ្លែផ្កា ហេតុនេះទើបយុទ្ធសាស្ត្រនេះត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់ការអនុវត្តបន្ត ឆ្នាំ២០១៦-២០២៥។ លទ្ធផលគួរឱ្យកត់សម្គាល់មួយទៀតនៃការអនុវត្តចង្កោមវិធានការគោលនយោបាយនេះ គឺការអនុម័តច្បាប់ស្តីពីមូលបត្រ។ ទោះយ៉ាងនេះក្តី ទីផ្សារភាគហ៊ុន និងមូលបត្រនៅកម្ពុជា ទាមទារឱ្យមានការពង្រឹងបន្ថែម។

ផ្អែកលើការវាយតម្លៃខាងលើ វិធានការគោលនយោបាយសរុប ៥៩% ត្រូវបានសម្រេចពេញលេញ។ វឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នេះ បានជះផលវិជ្ជមានក្នុងការលើកកម្ពស់មុខមាត់កម្ពុជាឱ្យក្លាយជាគោលដៅវិនិយោគ។ អាស្រ័យហេតុនេះ ធនធាននិងការដាក់ចេញទិសដៅយុទ្ធសាស្ត្រដែលមានភាពមុតស្រួចសម្រាប់ជំរុញការវិនិយោគ គួរតែត្រូវបានគិតគូរ និងអនុម័តជាបន្តបន្ទាប់ ដើម្បីបង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា។

## ១.៣. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនផលិតភាពការងាររបស់សហគ្រាស”

### ១.៣.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៧៖ ផលិតភាពការងារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា (២០១០-២០១៩)




ប្រភពទិន្នន័យ៖ WDI និង ILO

រូបភាពទី១.៧ បង្ហាញពីទំហំផលិតភាពការងាររបស់សហគ្រាសក្នុងវិស័យឧស្សាហកម្ម គិតជាដុល្លារអាមេរិកក្នុងកម្មករម្នាក់ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩។ ទំហំផលិតភាពការងារ ត្រូវបានគណនាដោយយកតម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម ធៀបនឹងចំនួនអ្នកចូលរួមការងារសរុបនៅក្នុងវិស័យឧស្សាហកម្ម។ ទំហំនេះមានការកើនឡើងបន្តិចពី ១.៨៩៩ដុល្លារអាមេរិកក្នុងកម្មករម្នាក់ នៅឆ្នាំ២០១០ ដល់ ១.៩៨០ដុល្លារអាមេរិកក្នុងកម្មករម្នាក់ នៅឆ្នាំ២០១៥។ ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP ទំហំផលិតភាពការងាររបស់សហគ្រាសកើនឡើងជាបន្តបន្ទាប់ រហូតដល់ ២.៤២៦ដុល្លារអាមេរិកក្នុងកម្មករម្នាក់ នៅឆ្នាំ២០១៩ តាមអត្រាកំណើនជាមធ្យម ៥,២%ក្នុងមួយឆ្នាំ ដែលអត្រាកំណើននេះ គឺកើនលឿនជាងអំឡុងពេលមុនការដាក់ចេញគោលនយោបាយ IDP រហូតដល់៥ដង។

រូបភាពទី១.៨ បង្ហាញពីថាមវន្តនៃកំណើនផលិតភាពការងារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ធៀបនឹងប្រទេសមួយចំនួនដូចជា បង់ក្លាដែស អេត្យូពី និងវៀតណាម នៅចន្លោះឆ្នាំ២០១០-២០១៩។ ខណៈដែលផលិតភាពការងារនៅក្នុងប្រទេសទាំងនេះមានកំណើនវិជ្ជមានជាមធ្យមដូចគ្នាក្នុងរយៈកាល១០ឆ្នាំនេះ ប្រទេសកម្ពុជាមានទំហំផលិតភាពទាបជាងគេក្នុងអំឡុងពេល ២-៣ឆ្នាំចុងក្រោយ។ នៅឆ្នាំ២០១៩ ផលិតភាពការងារនៅបង់ក្លាដែស និងវៀតណាម ធំជាងផលិតភាពការងារនៅកម្ពុជាប្រមាណ២ដង។ ប្រសិនបើគេឡេតមើលសន្ទុះកំណើនផលិតភាពការងារនៅកម្ពុជា ក្រោយពេលដាក់ចេញគោលនយោបាយ IDP (ជាមធ្យម

៥,២%ក្នុងមួយឆ្នាំ) គឺកើនលឿនជាងវៀតណាម (ជាមធ្យម ២,៦%ក្នុងមួយឆ្នាំ) ប៉ុន្តែនៅតែយឺតជាងបង់ក្លាដេស។

រូបភាពទី១.៨៖ ផលិតភាពការងារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ប្រៀបធៀបនឹងប្រទេសមួយចំនួន




| | CAGR 2010-2015 | CAGR 2015-2019 |
|---|---|---|
| បង់ក្លាដេស | 4.8% | 6.6% |
| កម្ពុជា | 0.8% | 5.2% |
| អេត្យូពី | 12.7% | 11.9% |
| វៀតណាម | 4.6% | 2.6% |

បង់ក្លាដេស   កម្ពុជា   អេត្យូពី   វៀតណាម

ប្រភពទិន្នន័យ÷ WDI និង ILO

*កំណត់សម្គាល់៖ ប្រទេសឡាវមិនត្រូវបានយកមកប្រៀបធៀបទេ ដោយសាររចនាសម្ព័ន្ធឧស្សាហកម្មរបស់ប្រទេសនេះមានភាពខុសប្លែកខ្លាំងបើធៀបនឹងប្រទេសដទៃទៀតខាងលើ ដែលធ្វើឱ្យមានការលំបាកក្នុងការប្រៀបធៀបលទ្ធផលបានពេញលេញ។ ជាក់ស្តែង វិស័យឧស្សាហកម្មនៅប្រទេសឡាវ មានការរួមចំណែកខ្លាំងពីអនុវិស័យរ៉ែនិងថាមពល ជាជាងអនុវិស័យកម្មន្តសាលដែលប្រើប្រាស់កម្លាំងពលកម្មច្រើន។*

ជារួម ផ្អែកតាមតួលេខទាំងនេះ យើងអាចពិបាកក្នុងការសន្និដ្ឋានថាតើកំណើនផលិតភាពការងារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ អាចជាបច្ច័យពីការអនុវត្តគោលនយោបាយ IDP ដែរឬទេ ដោយហេតុថានិន្នាការកំណើនផលិតភាពរបស់កម្ពុជា ហាក់ដូចជាកើតឡើងស្របគ្នានឹងប្រទេសមួយចំនួនទៀតដែរ។

### ១.៣.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការគាំទ្រដោយផ្ទាល់ចំនួន ១ ប៉ុណ្ណោះនៅក្នុង IDP គឺ *"ជួយគាំទ្រលើកកម្ពស់សមត្ថភាព និង សមត្ថកិច្ចរបស់មជ្ឈមណ្ឌលផលិតភាពកម្ពុជា សំដៅលើកកម្ពស់ផលិតភាព*

*និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម។"* យ៉ាងណាមិញ វិធានការមួយចំនួនដែលគាំទ្រផ្ទាល់ដល់អន្តរាគមន៍គោលនយោបាយដទៃ ដូចជា (១) ការធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស និង (២) ការបង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស ក៏អាចផ្តល់នូវបច្ច័យវិជ្ជមានបន្ថែមដល់ការបង្កើនផលិតភាពការងាររបស់សហគ្រាស ផងដែរ។ វិធានការខាងលើនេះ ត្រូវបានចាត់ទុកជាវិធានការច្បាស់លាស់សម្រាប់គាំទ្រដល់ការលើកកម្ពស់ផលិតភាពរបស់សហគ្រាស តាមរយៈការពង្រឹងសមត្ថភាពរបស់មជ្ឈមណ្ឌលផលិតភាពកម្ពុជាដែលជាស្ថាប័នទទួលបន្ទុកការលើកកម្ពស់ផលិតភាព។ កាលណាសមត្ថភាពរបស់មជ្ឈមណ្ឌលត្រូវបានពង្រឹង មជ្ឈមណ្ឌលនេះនឹងដើរតួនាទីកាន់តែសំខាន់ ក្នុងការពង្រីកការយល់ដឹងអំពីសារៈសំខាន់នៃការបង្កើន ផលិតភាពនៅកម្ពុជា និងមានលទ្ធភាពក្នុងការវាស់វែង និងលើកកម្ពស់ផលិតភាព ក៏ដូចជាលើកទឹកចិត្តដល់ការធ្វើនវានុវត្តន៍ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូចនិងមធ្យម។

ជារួម បើពិនិត្យលើវិសាលភាព និងស័ក្តិសិទ្ធិភាព, វិធានការតែមួយដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយនេះ ហាក់ដូចជាមិនអាចធ្វើឱ្យសម្រេចបាននូវលទ្ធផលតាមការរំពឹងទុក។ ដើម្បីបន្តរួមចំណែកបង្កើនផលិតភាពការងាររបស់សហគ្រាស រាជរដ្ឋាភិបាលអាចពិចារណាដាក់ចេញវិធានការថ្មីបន្ថែម ដូចជាផ្តល់ការលើកទឹកចិត្តដល់កម្មករនិយោជិតឆ្នើម ឬផ្តល់វគ្គបណ្តុះបណ្តាលដល់កម្មករនិយោជិត និងអ្នកគ្រប់គ្រងក្នុងសហគ្រាស សំដៅបង្កើនសមត្ថភាពបច្ចេកទេសរបស់ពួកគេ និងលើកកម្ពស់ផលិតភាពការងារជារួម។

### ១.៣.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៩៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនផលិតភាពការងាររបស់សហគ្រាស"




គោលនយោបាយ IDP បានដាក់ចេញវិធានការគោលនយោបាយតែមួយប៉ុណ្ណោះ ក្រោមអន្តរាគមន៍គោលនយោបាយនេះ ដែលបច្ចុប្បន្នកំពុងអនុវត្តនៅឡើយ។ វិធានការគោលនយោបាយដែលបានដាក់ចេញមានគោលបំណងដើម្បីបំប៉នសមត្ថភាពមជ្ឈមណ្ឌលផលិតភាពកម្ពុជាក្នុងការពង្រឹងគុណភាព និងលើកកម្ពស់ផលិតភាពរបស់សហគ្រាសធុនតូច និងមធ្យម។ ទោះបីការអនុវត្តវិធានការនេះនៅមិនទាន់បានសម្រេចពេញលេញនៅឡើយក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ វិធានការនេះក៏មានវឌ្ឍនភាពមួយចំនួនផងដែរ ដែលបង្ហាញថា មជ្ឈមណ្ឌលផលិតភាពកម្ពុជា បានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក/មន្ត្រីបម្រើការងារ

នៅក្នុងមជ្ឈមណ្ឌល និងសហគ្រាសធុនតូច និងមធ្យម លើប្រធានបទស្តីពីវិធីសាស្ត្រផលិតភាពកម្រិតមូលដ្ឋានគ្រឹះ និងកម្រិតខ្ពស់ និងវិធីសាស្ត្រអភិវឌ្ឍន៍ផលិតភាព ។ល។ បន្ថែមពីនេះ មជ្ឈមណ្ឌលផលិតភាពកម្ពុជាក៏បានផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមហ៊ុនគំរូតាមរយៈគម្រោងក្រុមហ៊ុនគំរូលើវិធីសាស្ត្រផលិតភាព ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០២៥។ ក្នុងចន្លោះឆ្នាំ ២០១៥-២០២០ (ពុំមានទិន្នន័យនៅឆ្នាំ២០១៩) ជាមធ្យមក្រុមហ៊ុនចំនួន ៩ ក្នុងមួយឆ្នាំ បានចូលរួមវគ្គបណ្តុះបណ្តាលតាមរយៈគម្រោងក្រុមហ៊ុនគំរូនេះ។

សរុបមក វិធានការនេះបង្ហាញពីវឌ្ឍនភាពនៃការផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក/មន្ត្រី និងសិក្ខាសាលាដល់វិស័យឯកជន ដែលកំពុងបន្តអនុវត្ត ទោះបីកាលបរិច្ឆេទកំណត់នៃវិធានការនេះ ស្ថិតនៅឆ្នាំ២០២៥ ក៏ដោយ។

## ១.៨. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស"

### ១.៨.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.១០៖ ផលធៀបរវាងការនាំចូលផលិតផលមូលធនធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ WITS

រូបភាពទី១.១០ បង្ហាញពីផលធៀបរវាងការនាំចូលផលិតផលមូលធនធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៩។ សូចនាករនេះត្រូវបានប្រើប្រាស់សម្រាប់វាស់វែងកម្រិតនៃការប្រើប្រាស់សម្ភារៈបរិក្ខារ និងគ្រឿងម៉ាស៊ីនទំនើបសម្រាប់បម្រើផលិតកម្មក្នុងស្រុក។ តួលេខផលធៀបនេះបានកើនឡើងពី៤៤,៤% នៅឆ្នាំ២០០៥ ដល់៦៧,៨% នៅឆ្នាំ២០១៥ តាមអត្រាកំណើន២,៣% ក្នុងមួយឆ្នាំ។ ក្រោយពេលដាក់ចេញ IDP ផលធៀបនេះបានបន្តកើនឡើងជារៀងរាល់ឆ្នាំរហូតដល់ ១០២,៣% ក្នុងឆ្នាំ២០១៩ ដោយមានសន្ទុះកំណើន ៨,៦%/ឆ្នាំ លឿនជាងមុនការដាក់ចេញគោលនយោបាយ IDP ។ អត្រាកំណើននេះ ឆ្លុះបញ្ចាំងឱ្យឃើញថា មានក្រុមហ៊ុនកាន់តែច្រើនបាននិងកំពុងទទួលយកបច្ចេកវិទ្យាថ្មីៗបន្ថែម

សម្រាប់អនុវត្តក្នុងខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន។ យ៉ាងនេះក្តី ផលធៀបនៅឆ្នាំ២០១៩ សម្រេចលើសពី ១០០%ទៅទៀត ឬអាចនិយាយម្យ៉ាងទៀតបានថា ការនាំចូលផលិតផលមូលធន មានទំហំច្រើនជាងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល។ កំណើនលើស១០០%ដូច្នេះ អាចមកពីសហគ្រាសជាច្រើននៅមិនទាន់ប្រើប្រាស់គ្រឿងម៉ាស៊ីនដែលបាននាំចូលទាំងនោះ ដើម្បីផលិតទំនិញដែលមានតម្លៃបន្ថែមខ្ពស់ឱ្យបានកាន់តែច្រើននៅក្នុងប្រទេសកម្ពុជានៅឡើយ។

### ១.៨.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការចំនួន២គាំទ្រ គឺ *(១) ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ទាំងនៅក្នុងវិស័យកម្មន្តសាល និងផ្នែកសិប្បកម្ម* និង *(២) ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យាតាមរយៈទស្សនកិច្ចសិក្សា និងទទួលបាននូវការបណ្តុះបណ្តាលពីបណ្តាប្រទេសនានាជុំវិញពិភពលោក*។ វិធានការទាំង២នេះ ត្រូវបានអនុវត្តដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ វិធានការទី១ ត្រូវបានចាត់ទុកជាវិធានការមិនច្បាស់លាស់ ព្រោះមិនបានបញ្ជាក់ច្បាស់អំពីមធ្យោបាយឬឧបករណ៍គោលនយោបាយ សម្រាប់ជំរុញការផ្ទេរបច្ចេកវិទ្យាថ្មីៗក្នុងវិស័យកម្មន្តសាល និងផ្នែកសិប្បកម្ម។ ដោយឡែកវិធានការទី២ គឺជាវិធានការច្បាស់លាស់ដើម្បីលើកកម្ពស់កម្រិតបច្ចេកវិទ្យារបស់សហគ្រាស ពីព្រោះតាមរយៈការធ្វើទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាលពីប្រទេសនានាជុំវិញពិភពលោក សហគ្រាសអាចនឹងទទួលបាននូវចំណេះដឹង និងការយល់ដឹងអំពីបច្ចេកវិទ្យាថ្មីៗ ពីបណ្តាសហគ្រាសបរទេសសម្រាប់ប្រើប្រាស់ក្នុងដំណើរការផលិតកម្មរបស់ខ្លួន។ បើពិនិត្យលើវិសាលភាព វិធានការទាំងពីរនេះប្រហែលជាមិនអាចជះឥទ្ធិពលដោយផ្ទាល់ដល់ការបង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស ដើម្បីសម្រេចលទ្ធផលរំពឹងទុកបានគ្រប់គ្រាន់នៅឡើយទេ។

#### ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

វិធានការទាំងពីរដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយនេះ មានលក្ខណៈបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ ជាក់ស្តែង ការជំរុញការផ្ទេរបច្ចេកវិទ្យាថ្មីៗ អាចធ្វើឡើងតាមរយៈការផ្តល់ការលើកទឹកចិត្តដល់សហគ្រាសដែលមានបំណងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុងសកម្មភាពឧស្សាហកម្មរបស់ខ្លួន ឬអាចតាមរយៈការបញ្ជូនម្ចាស់សហគ្រាសក្នុងស្រុកឱ្យចូលរួមទស្សនកិច្ចសិក្សានៅបណ្តាប្រទេសមួយចំនួន ដើម្បីរៀនសូត្រពីបច្ចេកវិទ្យាថ្មីៗ និងទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសក្នុងការប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ ហើយយកមកអនុវត្តក្នុងដំណើរការផលិតកម្មនៅកម្ពុជា។ ដូច្នេះ ការអនុវត្តវិធានការទាំងពីរទន្ទឹមគ្នាដោយមានមធ្យោបាយច្បាស់លាស់ នឹងអាចរួមចំណែកសម្រួលដល់ការផ្ទេរបច្ចេកវិទ្យារបស់សហគ្រាសបានមួយកម្រិត។

#### ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

ការវិភាគលើប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ បានបង្ហាញថា វិធានការទាំងពីរនេះពុំមានខ្លឹមសារស្ទួនគ្នាក្នុងការអនុវត្តនោះទេ។ យ៉ាងណាក្តី ការរៀបចំអន្តរាគមន៍គោលនយោបាយនេះនៅមានចន្លោះប្រហោងមួយចំនួនតូច ដែលនឹងអាចបំពេញបន្ថែមដោយការដាក់ចេញនូវវិធានការថ្មី ដើម្បីបង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស។ វិធានការថ្មីបន្ថែមដែលរាជរដ្ឋាភិបាលអាចពិចារណាគឺ កាត់បន្ថយ

អត្រាពន្ធនាំចូលលើការនាំចូលគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្មថ្មីសម្រាប់ផលិតកម្មកម្មន្តសាល ដើម្បីជួយសម្រាលដល់សហគ្រាសកាត់បន្ថយចំណាយមូលធនសម្រាប់ការបង្កើនកម្រិតបច្ចេកវិទ្យាបន្ថែមទៀត។

### ១.៨.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.១១៖ ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ "ការធ្វើឱ្យប្រសើរឡើងកម្រិតបច្ចេកវិទ្យារបស់សហគ្រាស







គោលនយោបាយ IDP បានកំណត់វិធានការគោលនយោបាយចំនួន ២ ក្រោមអន្តរាគមន៍គោលនយោបាយនេះ ក្នុងនោះមានវិធានការចំនួន ១ កំពុងអនុវត្ត និងវិធានការចំនួន ១ ទៀត នៅមានភាពយឺតយ៉ាវ។

វិធានការគោលនយោបាយ "ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាល..." កំពុងត្រូវបានអនុវត្តនៅឡើយ។ ទោះបីជាវិធានការនេះពុំទាន់បានសម្រេចពេញលេញ ប៉ុន្តែមានវឌ្ឍនភាពគួរកត់សម្គាល់មួយចំនួន ដូចជា ដំណើរទស្សនកិច្ចសិក្សា និងវគ្គបណ្តុះបណ្តាលមួយចំនួន ត្រូវបានរៀបចំជូនដល់មន្ត្រីក្រសួង ស្ថាប័ន និងក្រុមហ៊ុនឯកជន ចាប់ពីឆ្នាំ ២០១៥-២០២០។

ចំពោះវិធានការមួយទៀត ដែលមានភាពយឺតយ៉ាវ គឺដោយសារការផ្លាស់ប្តូរការរៀបចំស្ថាប័ន ដែលជាបញ្ហាប្រឈមមួយដែលរារាំងដល់ការសម្រេចបានពេញលេញនូវការអនុវត្តវិធានការនេះ។ កម្មវិធី/សេចក្តីព្រាងច្បាប់ស្តីពីការផ្ទេរបច្ចេកវិទ្យាដើម្បីជំរុញការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល និងផ្នែកសិប្បកម្ម កំពុងត្រូវបានរៀបចំនៅឡើយ ប៉ុន្តែដំណើរការរៀបចំសេចក្តីព្រាងច្បាប់នេះ ត្រូវបានផ្ទេរទៅឱ្យអង្គភាពមួយទៀតក្រោមឱវាទក្រសួងតែមួយ ដែលត្រូវបានបង្កើតថ្មី ដើម្បីបញ្ចប់ការរៀបចំ។

ផ្អែកលើការវាយតម្លៃខាងលើ, ពុំមានវិធានការគោលនយោបាយណាមួយត្រូវបានអនុវត្តពេញលេញឡើយ ដោយក្នុងនោះមានវិធានការគោលនយោបាយតែមួយប៉ុណ្ណោះដែលកំពុងអនុវត្ត ប៉ុន្តែវិធានការនេះហាក់ដូចជាមានការរួមចំណែកតិចតួចក្នុងការបង្កើនកម្រិតបច្ចេកវិទ្យា។

## ២. ការរួមចំណែករបស់អន្តរាគមន៍គោលនយោបាយចម្បងក្នុងគោលបំណងទី២ “បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម”

### ២.១. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក”

#### ២.១.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះមានសូចនាករចំនួន ២ គឺ៖

- ចំណែកនៃចំនួនសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាលដែលធ្វើការនាំចេញធៀបនឹងចំនួនសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាលសរុប
- ចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាល ធៀបនឹងការនាំចេញសរុប

សូចនាករទាំងពីរនេះមានទិន្នន័យត្រឹមតែមួយឆ្នាំប៉ុណ្ណោះ (ឆ្នាំ២០១៩) ដែលត្រូវបានផ្តល់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ក្នុងឆ្នាំ ២០១៩ ចំណែកនៃចំនួនសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាលបានធ្វើការនាំចេញធៀបនឹងចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលសរុប មានត្រឹមប្រមាណ ០,០២% ប៉ុណ្ណោះ ខណៈដែលចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាល ធៀបនឹងការនាំចេញសរុបមានចំនួនត្រឹមតែ ០,០១%។ ជារួម សកម្មភាពនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុកនៅកម្ពុជា នៅមានកម្រិតតិចតួចនៅឡើយ។

#### ២.១.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

មានវិធានការចំនួន៣នៅក្នុងគោលនយោបាយ IDP ដែលផ្សារភ្ជាប់នឹងការបង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន ឬសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក។ វិធានការទាំងនេះរួមមាន៖

- *ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមដោយកំណត់យកមុខសញ្ញាដែលមានសក្តានុពលក្នុងការនាំចេញ ...*
- *ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល*
- *បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ។*

ការវាយតម្លៃបែបគុណវិស័យទៅលើអន្តរាគមន៍គោលនយោបាយនេះ បង្ហាញថា គោលនយោបាយ IDP ផ្តោតលើការជួយជ្រោមជ្រែងសហគ្រាសធុនតូចនិងមធ្យមថ្មីៗក្នុងនាំចេញ ជាជាងការកសាងសមត្ថភាពសហគ្រាសធុនតូចនិងមធ្យមដែលមានសកម្មភាពនាំចេញរួចមកហើយ។ ការវិភាគ ក៏បង្ហាញថា គោលនយោបាយ

IDP បានដាក់ចេញនូវវិធានការដែលគាំទ្រដល់ការកសាងសមត្ថភាពនាំចេញរបស់សហគ្រាសធុនតូច និងមធ្យម ច្រើនជាងវិធានការដែលគាំទ្រដល់ការកសាងសមត្ថភាពក្រុមហ៊ុនធំៗក្នុងស្រុកឱ្យនាំចេញ។

ដោយសង្កេតឃើញថាសហគ្រាសធុនតូចនិងមធ្យមភាគច្រើនមានលក្ខណៈគ្រួសារ ហើយខ្វះសមត្ថភាពក្នុងការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ គោលនយោបាយ IDP បានដាក់ចេញនូវវិធានការត្រៀមមួយគឺ *"ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមដោយកំណត់យកមុខសញ្ញាដែលមានសក្តានុពលក្នុងការនាំចេញ..."* សំដៅផ្តល់ការគាំទ្រចំគោលដៅដល់សហគ្រាសធុនតូច និងមធ្យមដែលមានសក្តានុពលក្នុងការនាំចេញ តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលជួយឱ្យសហគ្រាសទាំងនោះអាចធ្វើការនាំចេញបាន។ វិធានការនេះក៏ផ្តោតសំខាន់ទៅលើការតភ្ជាប់សហគ្រាសធុនតូច និងមធ្យម ជាមួយនឹងសាជីវកម្មពហុជាតិ សំដៅធ្វើសមាហរណកម្មសហគ្រាសធុនតូច និងមធ្យមទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល។

ក្នុងដំណើរការនៃការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ការទទួលបានព័ត៌មានគ្រប់គ្រាន់គឺជាកត្តាសំខាន់។ ការទទួលបានព័ត៌មានមិនគ្រប់គ្រាន់អំពីសក្តានុពលនាំចេញ និងការដែលមិនមានឱកាសក្នុងការចងក្រងបណ្តាញធុរកិច្ច អាចរារាំងការបង្កើនសមត្ថភាពរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងការនាំចេញ។ ហេតុនេះហើយ គោលនយោបាយ IDP បានដាក់ចេញនូវវិធានការច្បាស់លាស់មួយគឺ *"ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល"* ផ្តោតទៅលើការពង្រឹងទំនាក់ទំនងក្នុងចំណោមសហគ្រាសធុនតូចនិងមធ្យម, រវាងសហគ្រាសធុនតូចនិងមធ្យម និងសហគ្រានធុនធំក្នុងស្រុក, និងទំនាក់ទំនងរបស់ពួកគេជាមួយរាជរដ្ឋាភិបាល។ សកម្មភាពទាំងអស់នេះអាចជួយសហគ្រាសធុនតូចនិងមធ្យមដោះស្រាយបញ្ហា ដែលបណ្តាលមកពីភាពមិនស្មើគ្នានៃការទទួលបានព័ត៌មាន តាមរយៈការបង្កើនលទ្ធភាពរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការទទួលបានព័ត៌មាន និងការចែករំលែកចំណេះដឹង។

ទន្ទឹមនឹងនេះ ដោយមើលឃើញពីសារៈសំខាន់នៃការលើកកម្ពស់ផលិតកម្ម និងការនាំចេញទំនិញកសិ-ឧស្សាហកម្មជាពិសេសការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យនេះឱ្យមានសមត្ថភាពនាំចេញកាន់តែច្រើន, គោលនយោបាយ IDP បានដាក់ចេញនូវវិធានការច្បាស់លាស់មួយគឺ *"បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ"* សំដៅផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសកែច្នៃកសិផលដល់សហគ្រាសធុនតូច និងមធ្យម និងសហគ្រាសក្នុងស្រុកផ្សេងទៀត។ ការអនុវត្តនូវវិធានការនេះអាចជួយឱ្យពួកគេទទួលបានទុន និងបច្ចេកទេសក្នុងការចាប់ផ្តើម ឬបន្តបង្កើនសកម្មភាពផលិតដើម្បីនាំចេញទំនិញកសិ-ឧស្សាហកម្ម។

បើក្រឡេកមើលពីវិសាលភាពវិញ វិធានការទាំង៣ខាងលើនេះអាចនឹងឱ្យអន្តរាគមន៍គោលនយោបាយនេះសម្រេចបានលទ្ធផលរំពឹងទុកក្នុងកម្រិតតិចតួច។

**ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ**

នៅក្នុងអន្តរាគមន៍គោលនយោបាយនេះ មានវិធានការចំនួន២ដែលត្រូវបានរកឃើញថាមានខ្លឹមសារបំពេញឱ្យគ្នាទៅវិញទៅមក ទី១គឺវិធាន*ការ "ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមដោយកំណត់យកមុខសញ្ញាដែលមានសក្តានុពលក្នុងការនាំចេញ..."* និងទី២ គឺ *"ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល"*។ ដើម្បីសម្របសម្រួលការកំណត់អត្តសញ្ញាណសហគ្រាសធុនតូចនិងមធ្យមដែលមានសក្តានុពលក្នុងការនាំចេញ រាជរដ្ឋាភិបាលត្រូវការព័ត៌មានឧស្សាហកម្មជាក់លាក់ ដោយក្នុងនោះការបង្កើតសមាគមតាមអនុវិស័យនីមួយៗ គឺជាមធ្យោបាយល្អមួយដែលអាចជួយរាជរដ្ឋាភិបាលក្នុងការទទួលបានព័ត៌មានគ្រប់គ្រាន់សម្រាប់ការកំណត់អត្តសញ្ញាណនេះ។ ជាមួយគ្នានេះ សមាគមតាមអនុវិស័យនីមួយៗអាចជាថ្នាលមួយដែលភ្ជាប់សហគ្រាសធុនតូចនិងមធ្យមទៅនឹងសាជីវកម្មពហុជាតិឬសហគ្រាសធុនធំក្នុងស្រុកដែលប្រតិបត្តិការក្នុងអនុវិស័យដូចគ្នា។ ក្រៅពីខ្លឹមសារដែលមានលក្ខណៈបំពេញគ្នានេះ គ្មានវិធានការណាមួយដែលមានលក្ខណៈប្រឆាំង ឬផ្ទុយគ្នានោះទេ។

## ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

នៅក្នុងអន្តរាគមន៍គោលនយោបាយនេះ មិនមានវិធានការណាដែលមានលក្ខណៈស្ទួនគ្នានោះទេ ប៉ុន្តែនៅមានភាពខ្វះចន្លោះមួយចំនួន។ វិធានការទាំង៣ដែលបានរៀបរាប់ខាងលើ គ្រាន់តែអាចរួមចំណែកដោះស្រាយបញ្ហាប្រឈមខ្លះដែលរារាំងសហគ្រាសកម្ពុជាឈានចូលទៅទីផ្សារអន្តរជាតិ ដូចជាបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាបញ្ហាពាក់ព័ន្ធនឹងការដែលទទួលបានព័ត៌មានមិនគ្រប់គ្រាន់ជាដើម។ យ៉ាងណាមិញ របាំងដែលរារាំងការនាំចេញផ្សេងទៀតមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ។ សហគ្រាសធុនធំក្នុងស្រុកមួយចំនួនប្រហែលជាមានលទ្ធភាពក្នុងការទទួលបាននូវឥណទាន និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានមួយចំនួន ព្រមទាំងមានចំណេះដឹងផ្នែកបច្ចេកទេសផងដែរ ប៉ុន្តែឧបសគ្គដែលបង្អាក់ពួកគេមិនឱ្យនាំចេញ ឬបង្កើនការនាំចេញ អាចបណ្តាលមកពីកង្វះសមត្ថភាពក្នុងការដោះស្រាយឧបសគ្គការិយាធិបតេយ្យដែលពាក់ព័ន្ធនឹងការនាំចេញ ហើយនេះក៏ជាបញ្ហាប្រឈមដែលសហគ្រាសធុនតូច និងមធ្យមបាន និងកំពុងជួបប្រទះផងដែរ។ ក្រៅពីនេះ នៅមានបញ្ហាប្រឈមជាច្រើនទៀតដូចជា ការលំបាកក្នុងការបំពេញតាមគ្រប់ស្តង់ដារ និងគុណភាពផលិតផលនាំចេញ, កង្វះបុគ្គលិកដែលមានជំនាញ, កង្វះសមត្ថភាពក្នុងការបង្កើតផលិតផលឬសេវាកម្មថ្មីជាច្រើនមុខ, កង្វះព័ត៌មាន និងលទ្ធភាពក្នុងការចងក្រងបណ្តាញធុរកិច្ច និងទាក់ទងអតិថិជនក្រៅប្រទេសដែលមានសក្តានុពលដោយខ្លួនឯង ជាដើម។

ដើម្បីទទួលបានលទ្ធផលកាន់តែប្រសើរជាងនេះ រាជរដ្ឋាភិបាលអាចពិចារណាដាក់ចេញនូវវិធានការមួយចំនួនបន្ថែមទៀតដូចជា ផ្តល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យមគោលដៅដើម្បីពង្រីកការផលិតបម្រើការនាំចេញ, រៀបចំវគ្គបណ្តុះបណ្តាលនានាពាក់ព័ន្ធនឹងតម្រូវការបច្ចេកទេសនាំចេញដល់សហគ្រាស, និងរៀបចំព្រឹត្តិការណ៍ផ្គូផ្គងធុរកិច្ច ជាដើម។

### ២.១.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

នៅក្នុងអន្តរាគមន៍គោលនយោបាយ ២.១នេះ មានវិធានការគោលនយោបាយចំនួន ៣ ដែលក្នុងនោះមានវិធានការគោលនយោបាយតែមួយប៉ុណ្ណោះ ដែលត្រូវបានសម្រេចបានពេញលេញ។ រីឯវិធានការគោលនយោបាយចំនួន ២ ទៀត កំពុងត្រូវបានអនុវត្ត និងយឺតយ៉ាវ។

វិធានការគោលនយោបាយដែលត្រូវបានសម្រេចបានពេញលេញគឺ "ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ"។ ក្នុងរយៈពេលបួនឆ្នាំ (២០១៥-២០១៨) មានសមាគមតាមអនុវិស័យ ចំនួន៤៨ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ ការបង្កើតមូលនិធិដើម្បីជំរុញការអភិវឌ្ឍផលិតផលសម្រាប់ការនាំចេញកំពុងត្រូវបានអនុវត្តនៅឡើយ ដោយការរៀបចំមូលនិធិនេះ គ្រោងនឹងចាប់ផ្តើមនៅឆ្នាំ២០២៣។ យ៉ាងណាមិញ វិធានការគោលនយោបាយចំនួន ១ មានការយឺតយ៉ាវ។ បទដ្ឋានគតិយុត្តចាំបាច់សម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម រួមមាន គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម, អនុក្រឹត្យស្តីពីការបង្កើត និងគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម និងច្បាប់ស្តីពីសហគ្រាសធុនតូច និងមធ្យម ត្រូវបានព្រាង និងបញ្ជូនទៅគណៈកម្មាធិការគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ប៉ុន្តែមានការយឺតយ៉ាវក្នុងដំណើរការកិច្ចប្រជុំនៅកម្រិតគណៈកម្មាធិការ។ ក្រសួងដែលទទួលបន្ទុកលើកិច្ចការនេះ នឹងបន្តធ្វើការជាមួយគណៈកម្មាធិការគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងពន្លឿនដំណើរការនៃកិច្ចប្រជុំ។

រូបភាពទី១.១២៖ ការវាយតម្លៃទៅលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក/សហគ្រាសធុនតូចនិងមធ្យម"






យោងតាមការវិភាគ សមាគមតាមអនុវិស័យមួយចំនួនត្រូវបានបង្កើតឡើង, មូលនិធិដើម្បីជំរុញការអភិវឌ្ឍផលិតផលសម្រាប់នាំចេញ និងបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ក៏ត្រូវបានព្រាងរៀបចំរួចរាល់។ ដើម្បីអាចជំរុញសមត្ថភាពរបស់សហគ្រាសក្នុងស្រុក និងសហគ្រាសធុនតូច និងមធ្យមឱ្យធ្វើការនាំចេញបាន ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពីគ្រប់ភាគីពាក់ព័ន្ធ។

## ២.២. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់”

### ២.២.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.១៣៖ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក (២០១៦-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

រូបភាពទី១.១៣ បង្ហាញពីបរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក ចាប់ពីឆ្នាំ ២០១៦-២០២០។ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក កើនឡើងពី ១,៧ លានតោន នៅឆ្នាំ២០១៦ ដល់ ២,២ លានតោន នៅឆ្នាំ២០២០ ក្នុងអត្រាកំណើនប្រចាំឆ្នាំប្រមាណ ៦,៣%។

រូបភាពទី១.១៤៖ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវដែក (២០០៥-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

រូបភាពទី ១.១៤ បង្ហាញពីបរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវដែក ចាប់ពីឆ្នាំ២០០៥-២០២០។ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវដែកបានធ្លាក់ចុះជាគំហុកពីប្រមាណ ៣១៧ពាន់តោន នៅឆ្នាំ២០០៦ មកត្រឹមប្រមាណ ៤ពាន់តោន នៅឆ្នាំ២០១០។ ការប្រើប្រាស់ផ្លូវដែកសម្រាប់ដឹកជញ្ជូនទំនិញបានថយចុះ គឺដោយសារតែផ្លូវដែកមានសភាពទ្រុឌទ្រោមខ្លាំង ហើយរាជរដ្ឋាភិបាលបានសម្រេចឱ្យមានការស្តារឡើងវិញនូវផ្លូវដែកទាំងពីរទិស ចាប់ពីឆ្នាំ២០០៩-២០១៣ និងប្រគល់ការធ្វើអាជីវកម្មផ្លូវដែកទៅឱ្យក្រុមហ៊ុនឯកជន (Toll Holding Group and Royal Group) ជាអ្នកគ្រប់គ្រង។ បន្ទាប់ពីការស្តារឡើងវិញនូវផ្លូវដែកទ្រុឌទ្រោម និងការធ្វើឯកជនភាវូនីយកម្មទំនិញដឹកជញ្ជូនតាមផ្លូវដែកត្រូវបានសង្កេតឃើញថា មានសន្ទុះងើបឡើងវិញគួរឱ្យកត់សម្គាល់ គឺប្រមាណ ៨៣ពាន់តោន នៅឆ្នាំ២០១៣ និងកើនឡើងយ៉ាងខ្លាំងដល់ប្រមាណ ៤១៩ពាន់តោន នៅឆ្នាំបន្ទាប់។ នៅឆ្នាំ២០១៧ ការប្រើប្រាស់ផ្លូវដែកកាន់តែសកម្មជាងមុន ដោយសារបណ្តាញផ្លូវដែកនៅភាគខាងជើងនៃប្រទេសកម្ពុជា ត្រូវបានជួសជុល និងស្តារឡើងវិញជាដំណាក់កាល និងរួចរាល់ទាំងស្រុងនៅឆ្នាំ ២០១៩ ដោយភ្ជាប់ផ្លូវដែកកម្ពុជាជាមួយផ្លូវដែកថៃ ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP ទំនិញដែលដឹកជញ្ជូនតាមផ្លូវដែកបានកើនឡើងជាបន្តបន្ទាប់ពីប្រមាណ ៥៣៨ពាន់តោន នៅឆ្នាំ២០១៥ ដល់ប្រមាណ ១,១លានតោន នៅឆ្នាំ២០២០ តាមអត្រាកំណើនប្រមាណ ១៥,៦% ក្នុងមួយឆ្នាំ។

រូបភាពទី១.១៥៖ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់កំពង់ផែ (២០០៥-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

រូបភាពទី១.១៥ បង្ហាញពីបរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់កំពង់ផែ ចាប់ពីឆ្នាំ២០០៥-២០២០។ នៅអំឡុងពេលមុនការដាក់ចេញគោលនយោបាយ IDP ការដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែបានកើនឡើងក្នុងអត្រា ២៣,២%ក្នុងមួយឆ្នាំ ពីប្រមាណ ៧៣៧ពាន់តោននៅឆ្នាំ២០០៥ ដល់ប្រមាណជិត ៦លានតោន នៅឆ្នាំ២០១៥។ ក្រោយការដាក់ចេញគោលនយោបាយ IDP ការដឹកជញ្ជូនតាមកំពង់ផែនៅតែមាននិន្នាការវិជ្ជមាន ដោយបានកើនឡើងទ្វេដងរហូតដល់ប្រមាណ ១០,២លានតោន ក្នុងឆ្នាំ២០២០ ប៉ុន្តែស្ថិតក្នុងអត្រាកំណើនមួយយឺត (១១,៤%ក្នុងមួយឆ្នាំ) ជាងអំឡុងពេលមុនដាក់ចេញគោលនយោបាយ IDP។

រូបភាពទី១.១៦៖ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាស (២០០៥-២០២០)




ប្រភពទិន្នន័យ៖ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

រូបភាពទី១.១៦ បង្ហាញពីបរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាសចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០២០។ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាសបានកើនឡើងពីប្រមាណ ១៧ពាន់តោន នៅឆ្នាំ២០០៥ ដល់ប្រមាណ ៣៧ពាន់តោន នៅឆ្នាំ២០១៥ តាមអត្រាកំណើន ៨,១%ក្នុងមួយឆ្នាំ។ ក្រោយពេលដាក់ចេញគោលនយោបាយ IDP បរិមាណនេះ បានកើនឡើងខ្លាំងជាបន្តបន្ទាប់ទៅដល់ប្រមាណ ១១១ពាន់តោន នៅឆ្នាំ២០២០ ស្ថិតក្នុងអត្រាកំណើនប្រចាំឆ្នាំ ២៤,៥% ដែលលឿនជាងកំណើនមុនការដាក់ចេញគោលនយោបាយ IDP ជាងបីដង។

រូបភាពទី១.១៧៖ ការប្រៀបធៀបបរិមាណទំនិញដឹកជញ្ជូនតាមគ្រប់បណ្តាញគមនាគមន៍




ប្រភពទិន្នន័យ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

រូបភាព១.១៧ បង្ហាញពីបរិមាណទំនិញដែលដឹកជញ្ជូនតាមគ្រប់បណ្តាញគមនាគមន៍ (ផ្លូវគោក ផ្លូវដែក កំពង់ផែ និងផ្លូវអាកាស)។ សូចនាករទាំងនេះត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅកម្ពុជា។ ផ្អែកតាមទិន្នន័យខាងលើ កំពង់ផែគឺជាបណ្តាញដឹកជញ្ជូនដ៏ពេញនិយមបំផុត បន្ទាប់មកគឺផ្លូវថ្នល់ ដោយសារតែថ្លៃទាបនៃការដឹកជញ្ជូនតាមបណ្តាញទាំងពីរនេះ ខណៈដែលមធ្យោបាយតាមផ្លូវអាកាសមិនសូវពេញនិយមក្នុងការដឹកជញ្ជូន។ ផ្លូវដែកឈរនៅលំដាប់លេខរៀងទីពពីព្រោះបណ្តាញដឹកជញ្ជូននេះ ទើបត្រូវបានអភិវឌ្ឍក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ។ គួរកត់សម្គាល់ដែរថា បរិមាណទំនិញដែលដឹកជញ្ជូនគ្រប់បណ្តាញគមនាគមន៍ បានកើនឡើងជាលំដាប់ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ជាពិសេសក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP យើងសង្កេតឃើញថាការដឹកជញ្ជូនតាមផ្លូវដែក និងផ្លូវអាកាស មានកំណើនលឿនជាងគេ។ ទិន្នន័យទាំងនេះ បានបង្ហាញថា កិច្ចខិតខំប្រឹងប្រែងដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន បានធ្វើឱ្យការដឹកជញ្ជូនតាមបណ្តាញគមនាគមន៍ទាំងអស់បន្តរីកលូតលាស់យ៉ាងឆាប់រហ័ស ជាពិសេសការដឹកជញ្ជូនតាមផ្លូវអាកាស និងផ្លូវដែកកាន់តែដើរតួនាទីសំខាន់ជាងមុនក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP។ ជារួមគោលនយោបាយ IDP បានផ្តល់បច្ច័យវិជ្ជមានក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើង និងបង្កើនការប្រើប្រាស់គ្រប់បណ្តាញគមនាគមន៍នៅកម្ពុជា សម្រាប់បម្រើសកម្មភាពដឹកជញ្ជូនទំនិញ។

រូបភាពទី១.១៨៖ ស្ថានភាពនៃការអភិវឌ្ឍច្រកទ្វារព្រំដែន (២០១៥-២០២០)







ប្រភពទិន្នន័យ៖ ក្រសួងមហាផ្ទៃ

រូបភាពទី១.១៨ បង្ហាញពីស្ថានភាពនៃការអភិវឌ្ឍច្រកទ្វារព្រំដែន ដោយអង្កេតលើចំនួនច្រកទ្វារព្រំដែនដែលបានបង្កើតនិងដាក់ឱ្យដំណើរការជាផ្លូវការនិងចំនួនច្រកទ្វារព្រំដែនដែលបានដំឡើងកម្រិតសមត្ថភាពឱ្យមានភាពស្មើគ្នាជាមួយប្រទេសជិតខាងចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០។ ជារួមច្រកទ្វារព្រំដែនចំនួន ៥ ត្រូវបានបង្កើតជាផ្លូវការនៅឆ្នាំ២០១៦ និងឆ្នាំ២០១៧ ហើយច្រកទ្វារព្រំដែនសរុបចំនួន ៧ ត្រូវបានដំឡើងកម្រិតសមត្ថភាពឱ្យស្មើគ្នាជាមួយប្រទេសជិតខាងចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។

រូបភាពទី១.១៩៖ ស្ថានភាពនៃការប្រើប្រាស់ និងវិសាលភាពគ្របដណ្តប់នៃសេវាអ៊ីនធឺណិត (២០១៥-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

រូបភាពទី១.១៩ បង្ហាញពីស្ថានភាពនៃការប្រើប្រាស់ និងវិសាលភាពគ្របដណ្តប់នៃសេវាអ៊ីនធឺណិត ដោយអង្កេតមើលលើអត្រាអ្នកប្រើប្រាស់អ៊ីនធឺណិតល្បឿនលឿន និងវិសាលភាពគ្របដណ្តប់នៃសេវាអ៊ីនធឺណិតល្បឿនលឿននៅក្នុងតំបន់ដែលមានប្រជាជនរស់នៅ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០។ អត្រាអ្នកប្រើប្រាស់អ៊ីនធឺណិតល្បឿនលឿនបានកើនឡើងយ៉ាងខ្លាំងពីប្រមាណ ០,៩% នៅឆ្នាំ២០១៥ ដល់ ៨៧,៨% នៅឆ្នាំ ២០២០ ដោយសារការរីកលូតលាស់នៃសេវាអ៊ីនធឺណិតចល័ត ពោលគឺការប្រើប្រាស់អ៊ីនធឺណិតតាមរយៈឧបករណ៍ទូរស័ព្ទឆ្លាតវៃ និងការវិនិយោគលើបច្ចេកវិទ្យាថ្មី (4G)។ ម្យ៉ាងវិញទៀត គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏បានរួមចំណែកជំរុញកំណើននេះផងដែរ។ ទន្ទឹមនឹងនេះ សេវាអ៊ីនធឺណិតល្បឿនលឿនក៏បានពង្រីកវិសាលកាន់តែទូលំទូលាយទៅដល់តំបន់ដែលមានប្រជាជនរស់នៅច្រើន ដោយវិសាលគ្របដណ្តប់បានកើនពីប្រមាណ១៣,៨២% នៅឆ្នាំ២០១៥ ដល់ ៨៤,៦% នៅឆ្នាំ២០២០។

រូបភាពទី១.២០៖ វិសាលភាពគ្របដណ្តប់នៃអគ្គិសនី (២០០៥-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា

រូបភាពទី១.២០ បង្ហាញពីវិសាលភាពគ្របដណ្តប់អគ្គិសនី វាស់វែងដោយសន្ទស្សន៍ភូមិដែលទទួលបានការផ្គត់ផ្គង់អគ្គិសនីពីឆ្នាំ២០០៥ ដល់២០២០។ សន្ទស្សន៍ភូមិដែលទទួលបានការផ្គត់ផ្គង់អគ្គិសនីបានកើនឡើង

គួរឱ្យកត់សម្គាល់ពី ៧,៨% នៅឆ្នាំ២០០៥ ដល់ ៦៦,៦% នៅឆ្នាំ២០១៥ តាមអត្រាកំណើន ៥,៩%ក្នុងមួយឆ្នាំ។ ក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP សន្ទស្សន៍នេះ បានបន្តកើនក្នុងអត្រាកំណើនលឿនជាងមុនបន្តិច (៦,២%ក្នុងមួយឆ្នាំ) រហូតដល់ ៩៧,៤% នៅឆ្នាំ២០២០។ ភូមិដែលនៅសល់ប្រមាណ ២,៦% គឺជាភូមិដែលពិបាកពង្រីកការផ្គត់ផ្គង់ ដូចជាភូមិនៅតំបន់ដាច់ស្រយាល និងគ្មានផ្លូវចូលកោះ តំបន់អណ្ដែតទឹក និងជំនន់ទឹកភ្លៀងនៅរដូវវស្សាជាដើម។ ជារួម លទ្ធភាពប្រើប្រាស់អគ្គិសនីមានភាពប្រសើរជាងមុនច្រើនគួរឱ្យកត់សម្គាល់។

រូបភាពទី១.២១៖ ស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី (២០១៧-២០២០)







ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា

រូបភាពទី១.២១ បង្ហាញអំពីស្ថិរភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនី ដែលវាស់ដោយរយៈពេល និងចំនួនដង នៃការដាច់ចរន្តអគ្គិសនីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០។ ដើម្បីធានាបាននូវស្ថិរភាព និងភាពជឿជាក់នៃការផ្គត់ផ្គង់ថាមពលដោយកាត់បន្ថយអត្រានៃការដាច់ចរន្តអគ្គិសនី, អគ្គិសនីកម្ពុជា បានសាងសង់បណ្តាញចែកចាយថ្មីរបស់ខ្លួនពីស្ថានីយរង និងខ្សែបណ្តាញចែកចាយទៅកាន់តំបន់សំខាន់ៗជាពិសេសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ យ៉ាងណាក្តី ការដាច់ចរន្តអគ្គិសនីនៅតែកើនឡើងពី ៨ដង នៅឆ្នាំ២០១៧ ដល់ ២៣ដង នៅឆ្នាំ២០២០ ដោយសារតែការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីបានធ្វើឱ្យប៉ះពាល់ដល់បណ្តាញចែកចាយអគ្គិសនី។ ទោះបីជាចំនួននៃការដាច់ចរន្តអគ្គិសនីកើនឡើងយ៉ាងនេះក្តី ក៏រយៈពេលនៃការដាច់ចរន្តអគ្គិសនីស្ថិតនៅក្នុងសូចនាករដែលបានបញ្ជាក់ (មិនឱ្យលើសពី ២៤ ម៉ោងក្នុងមួយឆ្នាំ)។ ក្នុងន័យនេះ អគ្គិសនីកម្ពុជានឹងបន្តត្រួតពិនិត្យ និងកាត់បន្ថយចំនួននៃការដាច់ចរន្តអគ្គិសនីក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ សរុបមក លទ្ធភាពទទួលបានអគ្គិសនីមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែភាពជឿជាក់នៃការប្រើប្រាស់អគ្គិសនីដោយរលូននៅតែជាបញ្ហានៅឡើយ សូម្បីតែនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបញ្ហាស្ថិរភាពនេះ គួរតែត្រូវដោះស្រាយឱ្យបានឆាប់រហ័សនាពេលអនាគត។

រូបភាពទី១.២២៖ ថ្លៃលក់អគ្គិសនីតាមប្រភពនៃការទិញសម្រាប់ការប្រើប្រាស់ក្នុងឧស្សាហកម្ម




ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា

*កំណត់សម្គាល់៖ នៅឆ្នាំ២០១៩ និងឆ្នាំ២០២០ ថ្លៃទិញពីអនុស្ថានីយមានភាពប្រែប្រួលរវាងរាជធានីភ្នំពេញ និងខេត្ត។ តម្លៃនៅឆ្នាំ២០១៩ និងឆ្នាំ២០២០ ដែលបង្ហាញក្នុងរូបភាពខាងលើ គឺសម្រាប់ខេត្ត។ តម្លៃនៅភ្នំពេញគឺ ១៣,៥សេន/១គីឡូវ៉ាត់ម៉ោង និង ១៣,២សេន/១គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០១៩ និងឆ្នាំ២០២០ រៀងគ្នា ដែលមានតម្លៃថ្លៃជាងនៅតាមបណ្ដាខេត្ត ដោយសារការបន្ថែមថ្លៃពីអ្នកផលិតអគ្គិសនីឯករាជ្យ ដើម្បីរក្សាការផ្គត់ផ្គង់អគ្គិសនីឱ្យមានស្ថិរភាពនៅក្នុងទីក្រុងភ្នំពេញ។ នៅពេលដែលមិនមានថាមពលគ្រប់គ្រាន់ពីបណ្ដាញអគ្គិសនីជាតិ, អ្នកផ្គត់ផ្គង់ផ្សេងទៀតនឹងបំពេញបន្ថែមនូវកង្វះថាមពលដើម្បីផ្គត់ផ្គង់ដល់រាជធានីភ្នំពេញ។*

រូបភាពទី១.២២ បង្ហាញពីតម្លៃអគ្គិសនីក្នុងមួយគីឡូវ៉ាត់ម៉ោងដែលមានភាពខុសគ្នាក្នុងចំណោមប្រភពទាំង៣នៃការទិញសម្រាប់ការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម។ ក្នុងអំឡុងពេលមុនការដាក់ចេញគោលនយោបាយ IDP (២០១០-២០១៥) ថ្លៃទិញពីទ្វារចរន្តអនុស្ថានីយបានកើនឡើងក្នុងអត្រាកំណើន ១% ក្នុងមួយឆ្នាំ ប៉ុន្តែ ថយចុះមកវិញបន្ទាប់ពីការដាក់ចេញ IDP។ ក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP តម្លៃអគ្គិសនីដែលបានទិញពីអនុស្ថានីយបានធ្លាក់ចុះពី ១២,៩សេន/គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០១៥ មក

១២,១សេន/គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០២០ ដែលជាតម្លៃថោកជាងតម្លៃគោលដៅឆ្នាំ២០២០ទៅទៀត (១២,៦សេន/គីឡូវ៉ាត់ម៉ោង)។ ស្របគ្នានេះ ថ្លៃអគ្គិសនីទិញពីខ្សែមេភ្នំពេញ និងកណ្តាល បានថយចុះក្នុងអត្រា ៥% ក្នុងមួយឆ្នាំ ក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP ពោលគឺថយចុះពី ១៧,៧សេន/គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០១៥ មកនៅត្រឹម ១៣,៧សេន/គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០២០ ទាបជាងតម្លៃគោលដៅឆ្នាំ២០២០ទៅទៀត (១៦,២សេន/គីឡូវ៉ាត់ម៉ោង)។ ដូចគ្នាដែរចំពោះថ្លៃអគ្គិសនីទិញពីខ្សែមេនៅខេត្តផ្សេងទៀត ក៏ត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP ក្នុងអត្រា ៤,៥%ក្នុងមួយឆ្នាំ ពោលគឺធ្លាក់ចុះពី ១៧,៣សេន/គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០១៥ មកនៅត្រឹម ១៣,៧សេន/គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០២០ ទាបជាងផែនការឆ្នាំ២០២០ដែលបានកំណត់ឱ្យបញ្ចុះមកនៅត្រឹម ១៦,២សេន/គីឡូវ៉ាត់ម៉ោង។ សរុបមក គោលនយោបាយ IDP ពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយថ្លៃអគ្គិសនីស្របតាមផែនការកំណត់។

### ២.២.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការគាំទ្រចំនួន២១ ក្នុងនោះភាគច្រើនផ្តោតលើការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម (វិធានការចំនួន៩) និងវិស័យថាមពល (វិធានការចំនួន៤)។ មានវិធានការតែមួយគត់ ដែលផ្តោតលើការពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ឧស្សាហកម្មគោលដៅ ក្រៅពីនេះវិធានការដែលនៅសេសសល់ ផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាទូទៅ។ របកគំហើញទាំងនេះសបញ្ជាក់ថា គោលនយោបាយ IDP ផ្តល់អាទិភាពខ្ពស់ដល់ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្មរួមជាមួយការធានានិរន្តរភាពនៃការផ្គត់ផ្គង់អគ្គិសនី ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់វិស័យឯកជនពាក់ព័ន្ធទៅនឹងការចំណាយខ្ពស់ក្នុងការធ្វើអាជីវកម្មនៅកម្ពុជា។

បើពិនិត្យលើទិដ្ឋភាពនៃការរៀបចំគោលនយោបាយ និងវិសាលភាព, យើងសង្កេតឃើញថាក្នុងចំណោមវិធានការទាំង ២១ នៃអន្តរាគមន៍គោលនយោបាយនេះ, មានវិធានការចំនួន ៧ ដែលមានភាពលេចធ្លោ អាចរួមចំណែកសំខាន់ក្នុងការកែលម្អស្ថានភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់។ ក្នុងនោះ វិធានការបីរួមមាន៖ "រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី...", "អនុវត្តគម្រោងកសាងស្ថានីយ៍ផលិតអគ្គិសនីដែលបានគ្រោងទុក..." និង "ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត..." គឺជាវិធានការដ៏សំខាន់ដែលអាចផ្តល់បច្ច័យវិជ្ជមានដល់ការផ្គត់ផ្គង់ថាមពល និងទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម។ វិធានការចំនួន ៤ ផ្សេងទៀតដែលមានគោលបំណង "រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម..." និងបន្តការពង្រីក និងថែទាំ "បណ្តាញផ្លូវសំខាន់ៗ" "ប្រព័ន្ធផ្លូវដែក" និង "បណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ" អាចរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយថ្លៃដឹកជញ្ជូន ក៏ដូចជាថ្លៃស្តុក និងលើកដាក់ទំនិញ។ ទោះបីជាយ៉ាងនេះក្តី លទ្ធផលនៃការវិភាគនេះមិនទាន់អាចសន្និដ្ឋានបានថា សេណារីយ៉ូជោគជ័យនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់ អាចសម្រេចបានទាំងស្រុង ដោយការអនុវត្តប្រកបដោយប្រសិទ្ធភាពតែវិធានការចំនួន ៧ នេះទេ។ ការរួមចំណែកនៃវិធានការដទៃទៀតក៏នៅតែសំខាន់ សម្រាប់អន្តរាគមន៍គោលនយោបាយនេះ ដរាបណាវិធានការទាំងនោះមិនមានលក្ខណៈស្មុគស្មាញ។

រូបភាពទី១.២៣៖ ចង្កោមទាំងបួននៃវិធានការដែលគាំទ្រដល់អន្តរាគមន៍គោលនយោបាយ "ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"




*សម្គាល់÷ (ច) វិធានការគោលនយោបាយច្បាស់លាស់, (ម) វិធានការគោលនយោបាយមិនច្បាស់លាស់, (ត) វិធានការត្រៀម*

## ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

ក្នុងចំណោមវិធានការទាំង២១ មានវិធានការមួយចំនួនដែលមានខ្លឹមសារបំពេញបន្ថែមឱ្យគ្នា។ ជាក់ស្តែងករណីបែបនេះ គឺមាននៅក្នុងចំណោមវិធានការចំនួន៤ ដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី។ វិធានការទី១ *"អនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី ពង្រឹងភាពទុកចិត្ត និងពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី"* នឹងមិនអាចសម្រេចបានទេ ប្រសិនបើស្ថានីយផលិតថាមពលអគ្គិសនីមានចំនួនតិចតួច។ អាស្រ័យហេតុនេះ វិធានការទី២ ដែលមានគោលបំណង *"បញ្ចប់នូវគម្រោងកសាងស្ថានីយផលិតអគ្គិសនីតាមការគ្រោងទុក"* នឹងបំពេញបន្ថែមលើប្រភពផលិតថាមពលអគ្គិសនីដែលមានស្រាប់។ នៅពេលដែលផលិតថាមពលអគ្គិសនីបានច្រើន កិច្ចការសំខាន់បន្ទាប់គឺ *"ពិនិត្យ និងតម្រង់ការផ្គត់ផ្គង់ថាមពលទៅកាន់តំបន់ផលិតកម្មសំខាន់ៗ"* ដែលនេះជាគោលបំណងនៃវិធានការទី៣ ដែលអនុញ្ញាតឱ្យរោងចក្រនានាអាចរៀបចំផែនការផលិតកម្មប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ដើម្បីធានាបាននូវការផ្គត់ផ្គង់ថាមពលប្រកបដោយចីរភាព វិធានការទី៤ មានបំណង *"ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងផែនការអភិវឌ្ឍវិស័យថាមពល"* សំដៅឆ្លើយតបទៅនឹងការប្រែប្រួលនៃតម្រូវការថាមពលដែលបណ្តាលមកពីការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃវិស័យឧស្សាហកម្មនាពេលអនាគត។

ករណីមួយទៀតនៃភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ ត្រូវបានសង្កេតឃើញក្នុងចំណោមវិធានការចំនួន២ ផ្សេងទៀត។ វិធានការទី១ ផ្តោតលើ *"ការពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ"* នៅតាមច្រករបៀងសេដ្ឋកិច្ចសំខាន់ៗ ដែលតភ្ជាប់ប្រទេសកម្ពុជា ទៅប្រទេសថៃ និងវៀតណាម និងវិធានការទី២ ផ្តោតលើ *"ការសាងសង់ផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង ដើម្បីដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ"*។ តាមរយៈវិធានការទី១ កំណាត់ផ្លូវជាតិសំខាន់ៗនឹងត្រូវបានពង្រីកដើម្បីឱ្យការដឹកជញ្ជូន

ទំនិញនៅតាមតំបន់ឧស្សាហកម្មសំខាន់ៗ ដូចជា រាជធានីភ្នំពេញ និងខេត្តព្រះសីហនុកាន់តែរលូន និងមានស័ក្តិសិទ្ធិភាពជាងមុន និងតភ្ជាប់តំបន់ទាំងនោះជាមួយមាត់ច្រកនាំចេញ នៅតាមព្រំដែនថៃ និងវៀតណាម។ ខណៈលទ្ធផលនៃការអនុវត្តវិធានការនេះ នឹងធ្វើឱ្យបរិមាណដឹកជញ្ជូនពីខេត្តមួយទៅខេត្តមួយមានការកើនឡើង វាក៏នឹងអាចបន្ថែមបន្ទុកចរាចរណ៍នៅរាជធានីភ្នំពេញដែលជាតំបន់ឆ្លងកាត់ផងដែរ។ បញ្ហានេះអាចដោះស្រាយបាន តាមរយៈការអនុវត្តវិធានការទី២ខាងលើ ដែលសំដៅកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង ដើម្បីពង្វាងរថយន្តកុងតឺន័រដឹកទំនិញកុំឱ្យឆ្លងកាត់ទីប្រជុំជននៃក្រុងភ្នំពេញ។ ដូច្នេះ វិធានការទាំងពីរនេះមានភាពស៊ីចង្វាក់គ្នាយ៉ាងខ្លាំង ដើម្បីបង្កើនស័ក្តិសិទ្ធិភាពក្នុងការដឹកជញ្ជូន និងកាត់បន្ថយថ្លៃភស្តុភារកម្មនៅកម្ពុជា។

ក្រៅពីករណីនៃភាពបំពេញបន្ថែមគ្នាទាំងនេះ គ្មានវិធានការណាមួយដែលមានខ្លឹមសារផ្ទុយគ្នានោះទេសម្រាប់អន្តរាគមន៍គោលនយោបាយនេះ។

## ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

ចំពោះស័ក្តិសិទ្ធិភាពនៃការអនុវត្តគោលនយោបាយ វិធានការមួយចំនួនក្នុងអន្តរាគមន៍គោលនយោបាយនេះមានភាពស្ទួនគ្នា។ ឧទាហរណ៍ជាក់ស្តែងគឺការស្ទួនគ្នារវាងវិធានការចំនួន២៖ (១) *"រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម [...]"* និង (២) *"រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម [...]"*។ វិធានការទាំងពីរនេះ មានឧបករណ៍គោលនយោបាយដូចគ្នាដែលជា "ផែនការមេ" ហើយមានគោលបំណងដូចគ្នាក្នុងការកាត់បន្ថយថ្លៃភស្តុភារកម្ម។ ទោះជាយ៉ាងនេះក្តី តាមការពិតការស្ទួនគ្នារវាងវិធានការទាំងពីរនេះ គឺមានហេតុផលសមស្រប។ វិធានការទី១ ត្រូវបានតាក់តែងជាវិធានការគន្លឹះមួយ ក្នុងចំណោមវិធានការជាក់ស្តែងគន្លឹះ៤ ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ "គ" នៃ IDP, ដោយឡែក វិធានការទី២វិញ គឺជាវិធានការមួយក្នុងចំណោមវិធានការគោលនយោបាយ និងផែនការសកម្មភាពចំនួន ១១៩ ផ្សេងទៀត ដែលត្រូវបានចែងនៅក្នុងឧបសម្ព័ន្ធ "ឃ" នៃ IDP ហើយវិធានការទាំងពីរនេះ មានរយៈពេលសម្រាប់ការបញ្ចប់ការអនុវត្តខុសគ្នា។ វិធានការទី២នេះ ត្រូវបានរំពឹងថានឹងសម្រេចការអនុវត្តក្នុងរយៈពេលមធ្យម ត្រឹមឆ្នាំ២០២០។ វិធានការនេះ *(ការរៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម)* ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាអាទិភាពចម្បង ដូច្នេះហើយទើបស្រង់យកវិធានការនេះទៅដាក់ក្នុងចំណោមវិធានការអាទិភាពទាំង៤ (ឬហៅថា *វិធានការគន្លឹះបួនជាក់ស្តែង*) ដែលត្រូវសម្រេចការអនុវត្តក្នុងរយៈពេលខ្លីជាងមុន ត្រឹមឆ្នាំ២០១៨ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ក្នុងការកាត់បន្ថយថ្លៃភស្តុភារកម្មសម្រាប់សហគ្រាសឧស្សាហកម្ម។

ក្រៅពីនេះ ក៏មានករណីស្ទួនគ្នានៃវិធានការផ្សេងទៀត ដូចជា វិធានការ *"បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានទឹកស្អាត អគ្គិសនី គមនាគមន៍..."* ដែលវិធានការនេះ គឺគ្រាន់តែជាការរួមបញ្ចូលគ្នានៃវិធានការជាច្រើន ដូចជា *ការពង្រីកបណ្តាញផ្លូវ*, *ការកសាងស្ថានីយ៍ផលិតអគ្គិសនី* និង *ការពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត* ដែលវិធានការទាំងអស់នេះត្រូវបានរៀបចំឡើងជាវិធានការដាច់ដោយឡែកផ្សេងគ្នានៅក្នុង IDP។ ដូច្នេះ ការអនុវត្តវិធានការ *"បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានទឹកស្អាត អគ្គិសនី គមនាគមន៍..."* អាច

នឹងមិនរួមចំណែកខ្លាំងក្នុងការសម្រេចបាននូវលទ្ធផលរំពឹងទុកនោះទេ បើធៀបទៅនឹងការអនុវត្តវិធានការផ្សេងទៀតដែលមានសកម្មភាពជាក់លាក់ជាងនេះ។

ខណៈវិធានការភាគច្រើននៅក្នុងអន្តរាគមន៍គោលនយោបាយនេះ ផ្តោតជាចម្បងលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាការពង្រីកបណ្តាញផ្លូវ និងការកសាងស្ថានីយផលិតអគ្គិសនី, លទ្ធផលនៃការវិភាគរកឃើញថា ពុំមានវិធានការណាមួយសោះ ផ្តោតលើតម្រូវការក្នុង*ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល*ឡើយ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលទំនើប គឺជាបុរេលក្ខខណ្ឌមួយចាំបាច់ដើម្បីជួយកាច់ចង្កូតឱ្យវិស័យផលិតកម្មរបស់កម្ពុជា ឈានឆ្ពោះទៅដំណាក់កាលថ្មីនៃការបង្កើតតម្លៃបន្ថែមនៅក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤។ ឧទាហរណ៍ ការពង្រីកការតភ្ជាប់អ៊ីនធឺណិតដើម្បីផ្តល់នូវការប្រើប្រាស់អ៊ីនធឺណិតដែលមានល្បឿនលឿន និងមានតម្លៃសមរម្យ អាចជាវិធានការមួយសមស្រប ដើម្បីជួយសម្រួលដល់សកម្មភាពផលិតកម្មទំនើបដែលត្រូវការប្រព័ន្ធអ៊ីនធឺណិតល្បឿនលឿន និងអាចទុកចិត្តបានក្នុងប្រតិបត្តិការអាជីវកម្មជាពិសេសសម្រាប់ប្រតិបត្តិការដែលប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃ និងដំណើរការស្វ័យប្រវត្តិកម្ម។

### ២.២.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការគោលនយោបាយសរុបចំនួន ២១។ វិធានការចំនួន ២ ក្នុងចំណោមវិធានការទាំងនេះ ត្រូវបានចាត់ទុកជាវិធានការគោលនយោបាយពហុសកម្មភាព ដូច្នេះវិធានការទាំង២នេះ ត្រូវបានបំបែកទៅជាអនុវិធានការគោលនយោបាយចំនួន ៦។ ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តវិធានការពហុសកម្មភាពនេះ មានតែអនុវិធានការគោលនយោបាយប៉ុណ្ណោះ ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃ។ ជាលទ្ធផលវិធានការគោលនយោបាយ និងអនុវិធានការគោលនយោបាយសរុបចំនួន ២៥ ត្រូវបានវាយតម្លៃ។

រូបភាពទី១.២៤៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"






យោងតាមការវាយតម្លៃ មានវិធានការចំនួន ១៣ ត្រូវបានសម្រេចពេញលេញ ដែលស្មើនឹង ៥០% នៃវិធានការសរុបក្រោមអនុភាគមន៍គោលនយោបាយនេះ។ ក្នុងនោះ មានវឌ្ឍនភាពល្អគួរឱ្យកត់សម្គាល់ក្នុងការផ្គត់ផ្គង់ថាមពល និងការអនុម័តផែនការប្រើប្រាស់ដីនៅទីតាំងយុទ្ធសាស្ត្រចំនួន ៥ រួមមានរាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, ខេត្តកោះកុង, ក្រុងបាវិត និងក្រុងប៉ោយប៉ែត។ ទន្ទឹមនឹងនេះ វិធានការប្រមាណតែ ១០% ប៉ុណ្ណោះ មានការយឺតយ៉ាវ ដោយសារកត្តាពេលវេលា, ធនធានមានកំណត់, កង្វះព័ត៌មាន, កង្វះយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តផែនការសកម្មភាព និងដោយសារការរីកចម្រើនយ៉ាងឆាប់រហ័សនៃតំបន់ទីប្រជុំជន។

ទោះជាយ៉ាងណាក៏ដោយ ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់ គឺជាការងារដែលត្រូវធ្វើជាបន្តបន្ទាប់ ហើយត្រូវការធនធានបន្ថែមទៀត ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ, យន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងក្រសួង ស្ថាប័ននានា, និងផែនការ/គម្រោងនគរូបនីយកម្មដែលមានចក្ខុវិស័យវែងឆ្ងាយ ដើម្បីបង្ការការអភិវឌ្ឍដែលមិនបានគ្រោងទុកជាមុន។

## ៣. ការរួមចំណែករបស់អន្តរាគមន៍គោលនយោបាយចម្បងក្នុងគោលបំណងទី៣ “សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម”

### ៣.១. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ”

#### ៣.១.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.២៥៖ ចំនួនក្រុមហ៊ុននិងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជី (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងពាណិជ្ជកម្ម

រូបភាពទី១.២៥ បង្ហាញពីចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជី ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៩។ ក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជី បានកើនឡើងប្រមាណបីដងពី ១.៩៤២ក្រុមហ៊ុន នៅឆ្នាំ២០០៥ ដល់៥.៩២១ក្រុមហ៊ុន នៅឆ្នាំ២០១៥ តាមអត្រាកំណើនប្រមាណ ១១,៨% ក្នុងមួយឆ្នាំ។ នៅឆ្នាំ២០១៦ តួលេខក្រុមហ៊ុនចុះបញ្ជីថ្មីមានការថយចុះខ្លាំង ដោយសារក្រសួងពាណិជ្ជកម្មទើបតែបានដាក់ឱ្យប្រើប្រាស់ថ្នាលចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធអនឡាញ នៅចុងឆ្នាំ២០១៥ ហើយវិនិយោគិន និងធុរជនមួយចំនួននៅពុំទាន់បានជ្រាបច្បាស់អំពីដំណើរការនៃថ្នាលនោះនៅឡើយ។ ក្រោយពីក្រសួងពាណិជ្ជកម្ម បានខិតខំផ្សព្វផ្សាយ និងសម្រួលឱ្យធុរជនបានយល់ច្បាស់ពីនីតិវិធីនៃថ្នាលចុះបញ្ជីតាមប្រព័ន្ធអនឡាញរួចមកតួលេខចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជីបានកើនដល់ប្រមាណ ១៣.៥០០ក្រុមហ៊ុន នៅឆ្នាំ២០១៩ ។ ជាមួយគ្នានេះ យើងក៏សង្កេតឃើញថា តួលេខក្រុមហ៊ុនថ្មីដែលបានចុះបញ្ជីក្នុងអំឡុងពេល អនុវត្តគោលនយោបាយ IDP មានអត្រាកំណើនប្រមាណ ២៣%ក្នុងមួយឆ្នាំ លឿនជាងអត្រាកំណើនមុនពេលការដាក់ចេញគោលនយោបាយ IDP ទៅទៀត (១១,៨%)។ ជារួម ក្រុមហ៊ុន និងសហគ្រាសថ្មីកាន់តែច្រើនបានចូលរួមក្នុងវិស័យកម្មន្តសាល ប៉ុន្តែមិនប្រាកដថាក្រុមហ៊ុននិងសហគ្រាសទាំងនោះ មានមុខសញ្ញាផលិតកម្ម “ថ្មី” ដែលកម្ពុជាមិនធ្លាប់មានពីមុនមកទេ។

រូបភាពទី១.២៦៖ ចំនួនមុខទំនិញនាំចេញ (ឆ្នាំ២០០៥-២០១៩)




ប្រភពទិន្នន័យ៖ WITS/UNCOMTRADE

រូបភាពទី១.២៦ បង្ហាញអំពីចំនួនមុខទំនិញនាំចេញរបស់កម្ពុជាពីឆ្នាំ២០០៥ ដល់ឆ្នាំ ២០១៩។ នៅឆ្នាំ ២០០៥ កម្ពុជា បាននាំចេញផលិតផលចំនួន ៥៨២មុខ ទៅកាន់ទីផ្សារពិភពលោក ហើយតួលេខនេះបាន កើនឡើងដល់ ១.០៣៥មុខ នៅឆ្នាំ២០១៥។ ក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP កម្ពុជាបាននាំចេញ ផលិតផលថ្មីប្រមាណ ១០០មុខបន្ថែមទៀត ធ្វើឱ្យចំនួនផលិតផលនាំចេញពីកម្ពុជាកើនដល់ ១.១៦៣មុខ នៅឆ្នាំ ២០១៩ ប៉ុន្តែស្ថិតក្នុងអត្រាកំណើនមួយ ដែលយឺតជាងអត្រាកំណើននៅអំឡុងពេលមុនការដាក់ចេញគោល នយោបាយ IDP។ យ៉ាងណាក្តី កម្ពុជាសម្រេចបានវឌ្ឍនភាពប្រសើរក្នុងការពង្រីកបន្ថែមនូវមុខទំនិញនាំចេញ ដែលអាច រាប់បញ្ចូលនូវផលិតផលប្រភេទថ្មីមួយចំនួន ប៉ុន្តែស្ថិតក្នុងល្បឿនយឺតនៅឡើយ។

រូបភាពទី១.២៧៖ ចំនួនមុខទំនិញកម្មន្តសាលនាំចេញពីកម្ពុជា ឆ្នាំ២០១៧-២០២០




សម្គាល់៖ ចំនួនមុខទំនិញត្រូវបានរាប់ដោយផ្អែកលើ ASEAN Harmonized Tariff Nomenclature (AHTN)
ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រូបភាពទី១.២៧ បង្ហាញអំពីចំនួនមុខទំនិញកម្មន្តសាលដែលបាននាំចេញពីកម្ពុជា ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០។ ទំនិញកម្មន្តសាលដែលបាននាំចេញ មានការកើនឡើងពី ៥៦៨មុខ នៅឆ្នាំ២០១៧ ដល់ ៧៨៣មុខ នៅឆ្នាំ២០១៩ ប៉ុន្តែបែរជាថមថយបន្តិចមកនៅត្រឹម ៦៨៤មុខ នៅឆ្នាំ២០២០។ ជាការកត់សម្គាល់ ទំនិញកម្មន្តសាលថ្មី មិនតិចជាង១០០មុខទំនិញ ត្រូវបានបន្ថែមក្នុងកន្ត្រកទំនិញកម្មន្តសាលសរុបដែលកម្ពុជាបាននាំចេញក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ ជាក់ស្តែង នៅឆ្នាំ២០២០ ទំនិញកម្មន្តសាលថ្មីកើនទៅដល់ ២៩២មុខ។

ជារួម ក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP, មានវត្តមានសហគ្រាសកម្មន្តសាលថ្មីៗកាន់តែច្រើននៅកម្ពុជា ដោយបានចូលរួមបង្កើនមុខសញ្ញាផលិតកម្ម និងមុខទំនិញនាំចេញថ្មីៗទៅកាន់ប្រទេសដៃគូពាណិជ្ជកម្មនានា។ ដូចនេះ គោលនយោបាយ IDP ពិតជាបានរួមចំណែកវិជ្ជមានដល់ការបង្កើនសកម្មភាពឧស្សាហកម្មថ្មីរបស់កម្ពុជា។ ប៉ុន្តែការរួមចំណែករបស់គោលនយោបាយ IDP គួរសម្រេចបាននូវបច្ច័យវិជ្ជមានច្រើនជាងនេះ ដោយបង្កើនចំនួនមុខទំនិញថ្មីៗដែលកម្ពុជាមិនធ្លាប់បានផលិតនិងនាំចេញពីមុនមក។

### ៣.១.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការគាំទ្រចំនួន៤ រួមមាន៖

- *រៀបចំនិងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រនិងវិធានការជាក់ស្តែង ដើម្បីជំរុញការផ្សព្វផ្សាយនិងទាក់ទាញការវិនិយោគ ដោយផ្ទាល់លើប្រទេសគោលដៅមួយចំនួន និងកំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់*
- *ពិនិត្យឡើងវិញនិងកែសម្រួលលក្ខខណ្ឌនិទ្ទិដ្ឋយពិសេស សម្រាប់ទាក់ទាញ "គម្រោងវិនិយោគដែលមានសក្តានុពលនិងគុណភាព" ដែលផ្តល់ផលវិជ្ជមាននិងតម្លៃបន្ថែម សម្រាប់ការបើកផ្លូវដល់ការអភិវឌ្ឍ និងទាក់ទាញឧស្សាហកម្មថ្មីៗមកកម្ពុជា*
- *បន្តពង្រឹងនិងលើកកម្ពស់នូវសមត្ថភាពរដ្ឋបាលនិងក្របខណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស...។*
- *ពិនិត្យឡើងវិញនិងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់។*

ការវិភាគលើវិធានការទាំង៤ បានបង្ហាញថា គោលនយោបាយ IDP ផ្តោតជាចម្បងលើការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ ជាជាងការបង្កើនសកម្មភាពផលិតកម្មដែលមានស្រាប់។ ភាពចាំបាច់នៃការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ អាចសម្គាល់បាន តាមរយៈការកំណត់ប្រភេទឧស្សាហកម្មអាទិភាពចំនួន ៥ ដែលមានចែងក្នុងគោលនយោបាយ IDP។ វិស័យអាទិភាពទាំង៥ នេះរួមមាន៖ ឧស្សាហកម្មឬកម្មន្តសាលចម្រុះថ្មីៗ មានចរិតជាការបើកច្រកចូលទីផ្សារ, សហគ្រាសធុនតូច និងមធ្យមលើគ្រប់វិស័យ, ផលិតកម្មកសិ-ឧស្សាហកម្ម, ប្រភេទឧស្សាហកម្មគាំទ្រផ្សេងៗ, និងប្រភេទឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់ និងមានចរិតយុទ្ធសាស្ត្រសម្រាប់អនាគត។

យ៉ាងណាក្តី គោលនយោបាយ IDP ហាក់ពុំសូវបានកំណត់ច្បាស់លាស់ថាតើការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ គួរទទួលបានការគាំទ្រអ្វីខ្លះនៅឡើយ ដែលកិច្ចការនេះគួរតែត្រូវបានគិតគូរក្នុងអំឡុងពេលអនុវត្តគោលនយោបាយ។ វិធានការស្តីពី *"ការរៀបចំនិងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រនិងវិធានការជាក់ស្តែងដើម្បីជំរុញការផ្សព្វផ្សាយនិងទាក់ទាញវិនិយោគក្នុងវិស័យឧស្សាហកម្មអាទិភាព"* ជាវិធានការដ៏សំខាន់មួយដែលមានបំណងរៀបចំយុទ្ធសាស្ត្រទាក់ទាញវិនិយោគចំគោលដៅ ដើម្បីបង្កើនសកម្មភាពឧស្សាហកម្មអាទិភាពនៅកម្ពុជា។ វិធានការពាក់ព័ន្ធមួយទៀតស្តីពី *"ការពិនិត្យ និងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ទាក់ទាញគម្រោងវិនិយោគដែលមានសក្តានុពល និងគុណភាព"* ត្រូវបានចាត់ទុកជាវិធានការច្បាស់លាស់មួយ សំដៅកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យដែលនឹងត្រូវចែងក្នុងសេចក្តីព្រាងច្បាប់ថ្មីស្តីពីវិនិយោគ សម្រាប់ទាក់ទាញគម្រោងវិនិយោគដែលមានសក្តានុពលនិងគុណភាព ជាពិសេសសកម្មភាពថ្មីៗដែលអាចទទួលបាននូវការលើកទឹកចិត្តពិសេស។

ក្រៅពីនេះ គោលនយោបាយ IDP ក៏ដាក់ចេញនូវវិធានការជាក់លាក់មួយទៀត គឺ*ជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស* ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទាក់ទាញការវិនិយោគនៅក្នុងវិស័យអាទិភាពមួយចំនួនដូចជា ការកែច្នៃកសិផលសម្រាប់នាំចេញ ឬសកម្មភាពផ្គុំដំឡើងគ្រឿងបង្គុំអេឡិចត្រូនិកនិងមេកានិចជាដើម។ តាមរយៈការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេសស្ថាប័នរដ្ឋមានភារកិច្ចបង្កើនប្រសិទ្ធភាពនៃយន្តការសេវាច្រកចេញចូលតែមួយ សម្រាប់សម្រួលដល់នីតិវិធីរដ្ឋបាល និងផ្តល់នូវការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគដែលបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ។

លើសពីនេះ គោលនយោបាយ IDP ក៏បានដាក់ចេញនូវវិធានការជាក់លាក់១បន្ថែម ដើម្បីលើកកម្ពស់ឧស្សាហកម្មធុនធ្ងន់ដែលបច្ចុប្បន្នបានរួមចំណែកបន្តិចបន្តួចនៅឡើយក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា។ វិធានការនេះគឺ *"ការពិនិត្យឡើងវិញនិងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់"*។ វិធានការនេះគឺជាវិធានការច្បាស់លាស់ និងមានសារៈសំខាន់ក្នុងការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ។ ការសិក្សាពិនិត្យឡើងវិញនេះ រំពឹងថានឹងរកឃើញនូវប្រភេទធនធានធម្មជាតិដែលជាវត្ថុធាតុដើមមានសក្តានុពល សម្រាប់កែច្នៃឱ្យទៅជាទំនិញពាក់កណ្តាលសម្រេច ដើម្បីផ្គត់ផ្គង់ឧស្សាហកម្មធុនធ្ងន់។ សកម្មភាពកម្មន្តសាលភាគច្រើននៅកម្ពុជា ប្រើប្រាស់វត្ថុធាតុដើមនាំចូលពីបរទេស ដោយសារបញ្ហាកង្វះខាតវត្ថុធាតុដើមក្នុងស្រុក។ ដូច្នេះ លទ្ធផលនៃការសិក្សាពិនិត្យឡើងវិញនេះ នឹងផ្តល់ជាព័ត៌មានដល់វិនិយោគិនដែលមានបំណងវិនិយោគក្នុងសកម្មភាពឧស្សាហកម្មកែច្នៃធនធានធម្មជាតិ។ ទោះជាយ៉ាងនេះក្តី វិធានការនេះមិនបានចែងជាក់លាក់ថាតើលទ្ធផលនៃការសិក្សាពិនិត្យឡើងវិញនេះ នឹងត្រូវផ្សព្វផ្សាយក្នុងកម្រិតណាមួយនោះទេ។

## ភាពស៊ីចង្វាក់គ្នារវាងវិធានការគោលនយោបាយ

វិធានការទាំង៤ ដែលគាំទ្រការអនុវត្តអន្តរាគមន៍គោលនយោបាយនេះ មានលក្ខណៈបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដើម្បីជំរុញការទាក់ទាញសកម្មភាពឧស្សាហកម្មថ្មីៗ។ ជាក់ស្តែង វិធានការដែលពាក់ព័ន្ធនឹង

*"ការវាយតម្លៃពីសក្តានុពលធនធានធម្មជាតិ"* មានភាពស៊ីចង្វាក់គ្នាខ្លាំងជាមួយវិធានការស្តីពី *"ការពិនិត្យនិងកែសម្រួលលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគម្រោងវិនិយោគប្រកបដោយគុណភាព"*។ លទ្ធផលបានបង្ហាញថាប្រភេទធនធានធម្មជាតិដែលមានសក្តានុពល អាចជំរុញឱ្យវិនិយោគិនកាន់តែច្រើនចាប់អារម្មណ៍មកកម្ពុជា ហើយរាជរដ្ឋាភិបាលអាចមានលទ្ធភាពយ៉ាងទូលំទូលាយ ក្នុងការជ្រើសរើសគម្រោងវិនិយោគប្រកបដោយគុណភាពតាមរយៈការរៀបចំកញ្ចប់លើកទឹកចិត្តសម្រាប់ទាក់ទាញសកម្មភាពឧស្សាហកម្មថ្មីៗ។ ក្រៅពីភាពស៊ីចង្វាក់គ្នារវាងវិធានការទាំងនេះ គ្មានវិធានការណាមួយដែលមានខ្លឹមសារផ្ទុយគ្នានោះទេ។

## ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

ផ្អែកលើប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការរៀបចំគោលនយោបាយ គ្មានករណីស្មួនគ្នាក្នុងចំណោមវិធានការទាំង៤នេះឡើយ។ ទោះយ៉ាងណាក៏ដោយ វិធានការទាំងនេះ ហាក់មិនទាន់មានភាពពេញលេញដោយសារតែហេតុផលមួយចំនួនដូចខាងក្រោម៖

- អន្តរាគមន៍គោលនយោបាយនេះ មានសារៈសំខាន់ខ្លាំងដល់ការសម្រេចបាននូវចក្ខុវិស័យនៃការកែប្រែរចនាសម្ព័ន្ធឧស្សាហកម្ម ប៉ុន្តែមានវិធានការគាំទ្រមិនទាន់គ្រប់គ្រាន់ ហើយខ្លឹមសារមិនទាន់មុតស្រួចនៅឡើយ
- កង្វះការកំណត់វិស័យជាក់លាក់ដើម្បីជំរុញ (ក្រៅពីសកម្មភាពកែច្នៃកសិផល)
- អវត្តមាននៃយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់ក្នុងការអភិវឌ្ឍឧស្សាហកម្មអាទិភាព
- ការផ្តោតត្រឹមតែទៅលើការលើកទឹកចិត្តផ្នែកសារពើពន្ធក្នុងការទាក់ទាញវិនិយោគិនមួយបែប គឺពុំទាន់គ្រប់គ្រាន់ទេ ហេតុនេះទាមទារឱ្យមានការផ្សារភ្ជាប់ជាមួយអន្តរាគមន៍គោលនយោបាយផ្សេងទៀតដូចជាការបង្កើនការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញ ជាដើម។

ជារួម គោលនយោបាយ IDP បានកំណត់ទិសដៅសមស្របក្នុងការបង្កើនសកម្មភាពឧស្សាហកម្មថ្មីៗនៅកម្ពុជា។ វិធានការទាំង៤ខាងលើ ពិតជាអាចរួមចំណែកជំរុញកំណើនសកម្មភាពឧស្សាហកម្មថ្មីៗបានមែន ប៉ុន្តែពុំសូវមានភាពច្បាស់លាស់និងឥទ្ធិពលគ្រប់គ្រាន់នៅឡើយ។ លទ្ធផលរំពឹងទុកនៃអន្តរាគមន៍គោល-នយោបាយនេះ ចាំបាច់ត្រូវមានការចូលរួមពីការអនុវត្តវិធានការមួយចំនួន ដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយផ្សេងទៀត ដូចជាការអភិវឌ្ឍជំនាញដើម្បីបង្កើនការផ្គត់ផ្គង់ និងត្រៀមរៀបចំកម្លាំងពលកម្មវ័យក្មេងសម្រាប់តម្រូវការការងារនាពេលអនាគតសម្រាប់សកម្មភាពផលិតកម្មកម្មន្តសាលកម្រិតខ្ពស់ ជាដើម។

### ៣.១.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.២៨៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ"







គោលនយោបាយ IDP កំណត់វិធានការគោលនយោបាយច្បាស់លាស់ចំនួន ៤ ដើម្បីគាំទ្រដល់ការអនុវត្តអន្តរាគមន៍គោលនយោបាយនេះ។ វិធានការចំនួន២ ត្រូវបានសម្រេចពេញលេញ, វិធានការចំនួន ១ កំពុងអនុវត្ត និងវិធានការចំនួន ១ ទៀត មានការយឺតយ៉ាវ។

វិធានការដែលបានសម្រេចពេញលេញចំនួន២ បានបង្ហាញនូវលទ្ធផលវិជ្ជមានគួរឱ្យកត់សម្គាល់ដោយសារការដាក់ចេញនូវវិធានការជាក់ស្ដែងមួយចំនួន ដើម្បីទាក់ទាញវិនិយោគចំគោលដៅ ដូចជា៖ ១) ការរៀបចំ "តុចិន" "តុជប៉ុន" និង "តុកូរ៉េ", ២) ការរៀបចំនិងការចូលរួមក្នុងសិក្ខាសាលា/ការតាំងពិព័រណ៍ផ្សព្វផ្សាយ និងជំរុញវិនិយោគនៅតាមបណ្ដាប្រទេសនានា ជាពិសេស ចិន ជប៉ុន និងកូរ៉េ, ៣) ការរៀបចំកិច្ចប្រជុំទ្វេភាគីជាទៀងរាល់ឆ្នាំជាមួយវិនិយោគិនជប៉ុន ចិន និងកូរ៉េ ដើម្បីដោះស្រាយនូវបញ្ហាប្រឈម និងកង្វល់ផ្សេងៗ, ៤) ជំរុញការអនុវត្តយុទ្ធសាស្ត្រជាក់ស្ដែង ថៃ+១ និងវៀតណាម+១ សម្រាប់វិនិយោគជប៉ុន និង/ឬ

វិនិយោគចិន ដែលមានបំណងផ្លាស់ប្តូរទីតាំងផលិតកម្មមកកម្ពុជា។ យុទ្ធសាស្ត្រទាក់ទាញវិនិយោគចិន ហាក់ទទួលបានជោគជ័យជាងយុទ្ធសាស្ត្រទាក់ទាញវិនិយោគពីប្រទេសដែលជាគោលដៅផ្សេងទៀត។ និន្នាការវិនិយោគ បង្ហាញពីកំណើនរំហូរទុនវិនិយោគចិនចូលមកកម្ពុជា ប្រមាណ ៩០០% ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។ យ៉ាងនេះក្តី ក្នុងរយៈកាល ៣ឆ្នាំចុងក្រោយនេះ (២០១៨-២០២០) រំហូរទុនវិនិយោគចិនមានការថយចុះប្រមាណ ៥៨%។

ចំពោះនិយមន័យនៃឧស្សាហកម្មថ្មីៗ និងឧស្សាហកម្មគោលដៅ ត្រូវបានកំណត់យ៉ាងទូលំទូលាយដោយគោលនយោបាយ IDP ដែលបណ្តាលឱ្យមានការលំបាកក្នុងការទាក់ទាញវិនិយោគក្នុងឧស្សាហកម្មទាំង២នេះ។ ដូចនេះ រាជរដ្ឋាភិបាល គួរតែដាក់ចេញនូវយុទ្ធសាស្ត្រជាក់លាក់បន្ថែមទៀតក្នុងការទាក់ទាញសកម្មភាពឧស្សាហកម្មថ្មីៗ និងប្រភេទឧស្សាហកម្មគោលដៅ។

ដោយឡែក មានវិធានការចំនួន ១ កំពុងអនុវត្ត និងវិធានការ ចំនួន ១ ទៀត មានភាពយឺតយ៉ាវ។ បញ្ហាប្រឈមដែលបណ្តាលឱ្យមានភាពយឺតយ៉ាវនៃការអនុវត្តវិធានការគោលនយោបាយ ដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះគឺៈ ១) ភាពស្មុគស្មាញនៃការរៀបចំបញ្ជីសកម្មភាពវិនិយោគដែលទាមទារឱ្យមានការស្រាវជ្រាវលម្អិត និងការពិភាក្សាផ្ទៃក្នុងជាច្រើនលើកច្រើនសារ, ២) កង្វះនូវមូលដ្ឋាននិងលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ក្នុងការរៀបចំបញ្ជី និងសកម្មភាពវិនិយោគក្នុងការទាក់ទាញវិនិយោគដែលមានសក្តានុពលនិងប្រកបដោយគុណភាព។ ក្រសួង ស្ថាប័នដែលទទួលបន្ទុកក្នុងការអនុវត្តវិធានការទាំងនេះ បានស្នើនូវដំណោះស្រាយចំនួន ២ រួមមានៈ ១) ការទាមទារឱ្យមានការសិក្សាស៊ីជម្រៅនិង/ឬដាក់ចេញនូវគោលនយោបាយដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីសកម្មភាពវិនិយោគ ឱ្យមានលក្ខណៈសមស្របទៅនឹងតម្រូវការជាក់ស្តែងនៃបរិការណ៍របស់កម្ពុជា និងតំបន់, និង ២)ការទាមទារឱ្យមានការគាំទ្រនិងការប្តេជ្ញាចិត្តពីថ្នាក់ដឹកនាំគោលនយោបាយ។

ផ្អែកតាមការវាយតម្លៃខាងលើ បានបង្ហាញថា រាជរដ្ឋាភិបាលបាននិងកំពុងខិតខំប្រឹងប្រែងក្នុងការទាក់ទាញវិនិយោគក្នុងសកម្មភាពឧស្សាហកម្មថ្មីៗ និងឧស្សាហកម្មគោលដៅមកកម្ពុជា។ យ៉ាងណាក៏ដោយប្រសិនបើយើងក្រឡេកមើលនិន្នាការវិនិយោគវិញ បង្ហាញថា កំណើនទុនវិនិយោគជាក់ស្តែងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ មានភាពខុសគ្នាពីការរំពឹងទុករបស់គោលនយោបាយ IDP ដែលចង់បង្កើនការវិនិយោគក្នុងប្រភេទឧស្សាហកម្មទាំង ២។ ការដាក់ចេញនូវគោលនយោបាយជាក់លាក់ ឬវិធានការជាក់ស្តែង សម្រាប់ទាក់ទាញប្រភេទឧស្សាហកម្មថ្មីៗ និងឧស្សាហកម្មគោលដៅ ជាកត្តាចាំបាច់។ ទន្ទឹមនឹងនេះ ការបន្តអនុវត្តវិធានការគោលនយោបាយដែលនៅសេសសល់ និងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗ ក៏ជាកិច្ចការចាំបាច់ក្នុងការទាក់ទាញ ជំរុញវិនិយោគលើសកម្មភាពឧស្សាហកម្មថ្មីៗបន្ថែមទៀត ដើម្បីធានាបាននូវភាពជោគជ័យក្នុងការអនុវត្តអន្តរាគមន៍គោលនយោបាយនេះ។

## ៣.២. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ "ពង្រីក និងធ្វើពិពិធកម្មទីផ្សារនិងផលិតផលនាំចេញ"

### ៣.២.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.២៩៖ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់៥នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ WITS/UNCOMTRADE

រូបភាពទី១.២៩ បង្ហាញពីចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់ ៥ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៩ សម្រាប់វាយតម្លៃពីការធ្វើពិពិធកម្មផលិតផលនាំចេញ។ តួលេខចំណែកនេះ បានថយចុះពី ៩៤,៦%នៅឆ្នាំ២០០៥ មកត្រឹម ៨៣,៥%នៅឆ្នាំ២០១៥ ហើយ នៅតែបន្តថយចុះក្នុងអំឡុងពេលអនុវត្តគោលនយោបាយ IDP រហូតដល់ ៦៣,៣%នៅឆ្នាំ២០១៩។ មុនពេលដាក់ចេញ IDP តួលេខចំណែកនេះ ថយចុះតិចប៉ុណ្ណោះក្នុងអត្រាប្រមាណ -១,១%ក្នុងមួយឆ្នាំ ខណៈអំឡុងពេលអនុវត្តគោលនយោបាយ IDP អត្រានៃការថយចុះ (៥,១% ក្នុងមួយឆ្នាំ) ស្មើប្រមាណ ៥ដងអត្រានៃការថយចុះ មុនការដាក់ចេញគោលនយោបាយ IDP ដែលនេះជាសញ្ញាណវិជ្ជមាននៃការកាត់បន្ថយការពឹងផ្អែកខ្លាំងលើមុខសញ្ញាផលិតផលនាំចេញមួយចំនួនតូចជាបណ្តើរៗ។

រូបភាពទី១.៣០៖ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់៣នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ WITS/UNCOMTRADE

រូបភាពទី១.៣០ បង្ហាញអំពីចំណែកនៃការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់ ៣ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៩។ មុនពេលការដាក់ចេញគោលនយោបាយ IDP តួលេខចំណែកនេះ បានថយចុះជាបន្តបន្ទាប់ពីប្រមាណ ៨៣,៣% នៅឆ្នាំ២០០៥ មកនៅត្រឹមប្រមាណ ៤៦,១% នៅឆ្នាំ២០១៥។ អំឡុងពេលអនុវត្តគោលនយោបាយ IDP តួលេខចំណែកនេះ បែរជាកើនឡើងវិញទៅដល់ ៤៨,៣% នៅឆ្នាំ២០១៩ ដែលបង្ហាញថាការនាំចេញផលិតផលកម្មន្តសាលនៅតែពឹងផ្អែកលើទីផ្សារធំៗមួយចំនួនដដែល។ និន្នាការនៃការកើនឡើងវិញនូវចំណែកនៃការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់ ៣នាំមុខគេ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហាក់បង្ហាញថាការរំពឹងទុករបស់គោលនយោបាយ IDP ចំពោះការធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជាស្ថិតនៅកម្រិតមួយពិបាកសម្រេចបាន។

រូបភាពទី១.៣១៖ ចំនួនទីផ្សារនាំចេញដែលមានទំហំលើសពី ១០លានដុល្លារអាមេរិក (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ WITS/UNCOMTRADE

រូបភាពទី១.៣១ បង្ហាញអំពីចំនួនទីផ្សារនាំចេញដែលមានទំហំលើសពី ១០លានដុល្លារអាមេរិក ពីឆ្នាំ ២០០៥ ដល់ឆ្នាំ២០១៩។ កាលពីឆ្នាំ២០០៥ ទីផ្សារដែលបាននាំចូលទំនិញពីកម្ពុជា លើសពី១០លានដុល្លារ

អាមេរិកឡើងទៅ មានចំនួនត្រឹមតែ ១១ប្រទេសប៉ុណ្ណោះ ប៉ុន្តែមកដល់ឆ្នាំ២០១៥ តួលេខចំនួនទីផ្សារក៏បាន កើនឡើងប្រមាណ ៤ដង ដល់ទៅ ៤០ប្រទេស នៅឆ្នាំ២០១៥។ បន្ទាប់ពីការដាក់ចេញគោលនយោបាយ IDP ចំនួនទីផ្សារនាំចេញនៅតែបន្តកើនឡើងប្រមាណ ៥ ទៅ ៧ប្រទេសបន្ថែមទៀត ដែលអត្រាកំណើន (៣% ក្នុងមួយឆ្នាំ) ស្ថិតក្នុងកម្រិតយឺត បើធៀបនឹងរយៈពេលមុនការដាក់ចេញគោលនយោបាយ IDP (ដែលមាន អត្រាកំណើន ១៣,៨%ក្នុងមួយឆ្នាំ)។

ជារួម គោលនយោបាយ IDP បានរួមចំណែកជាវិជ្ជមានដល់ការពង្រីកនិងធ្វើពិពិធកម្មផលិតផលនាំចេញ ប៉ុន្តែនៅពុំទាន់មានវឌ្ឍនភាពប្រសើរនៅឡើយ ក្នុងការកាត់បន្ថយការពឹងផ្អែកលើទីផ្សារធំមួយចំនួនសម្រាប់ការ នាំចេញទំនិញ។

### ៣.២.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការគោលនយោបាយចំនួន ៨ ដែលអាចបែងចែកជា ៤ ចង្កោមវិធានការ គឺ៖ (១) ការផ្តល់សេវាសាធារណៈដើម្បីសម្របសម្រួលដល់ការនាំចេញ (២ វិធានការ), (២) ការពង្រឹងវិធានការគតិយុត្តស្តីពីការនាំចេញ (៤ វិធានការ), (៣) ធ្វើឱ្យប្រសើរការទទួលបានហិរញ្ញវត្ថុសម្រាប់ អ្នកវិនិយោគក្នុងវិស័យឧស្សាហកម្មជាអាទិភាព (១ វិធានការ) និង (៤) ការបង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់ អ្នកនាំចេញខ្ពស់ (១ វិធានការ)។

រូបភាពទី១.៣២ ៖ ចង្កោមទាំងបួននៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ពង្រីក និងពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ"




ការវាយតម្លៃលើវិធានការគោលនយោបាយទាំង ៨ នៃអន្តរាគមន៍គោលនយោបាយនេះបង្ហាញថា គោលនយោបាយ IDP ផ្តោតចម្បងទៅលើការលើកកម្ពស់ និងការសម្រួលការនាំចេញ ដែលមានគោលបំណងពង្រីក និងធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារក្នុងតំបន់ និងពិភពលោក។ ចង្កោមវិធានការទី ១ ផ្តោតចម្បងលើការផ្តល់នូវបរិយាកាសអំណោយផល និងលើកទឹកចិត្តឱ្យក្រុមហ៊ុនបង្កើនការនាំចេញតាមរយៈ ការបង្កើតមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មដែលអាចប្រើប្រាស់តាមប្រព័ន្ធអនឡាញ និងការបង្កើតទីភ្នាក់ងារជំរុញការនាំចេញ។ វិធានការគោលនយោបាយ ៣ ផ្សេងទៀតនៅក្នុងចង្កោមវិធានការទី ២ ផ្តោតលើការធ្វើឱ្យប្រសើរឡើង និងពង្រឹងវិធានការគតិយុត្តស្តីពីការនាំចេញនៅទូទាំងតំបន់អាស៊ាន និងទីផ្សារអន្តរជាតិ។ ខណៈវិធានការគោលនយោបាយ ២ ទៀតនៃចង្កោមវិធានការទី ៣ និងទី ៤ មានគោលបំណងចម្បងដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ្នកនាំចេញនៅក្នុងវិស័យឧស្សាហកម្មអាទិភាព និងផ្តល់ការលើកទឹកចិត្ត ផ្តល់រង្វាន់ដល់ក្រុមហ៊ុននាំចេញច្រើន ដើម្បីរួមចំណែកដល់ការពង្រីក និងធ្វើពិពិធកម្មទីផ្សារនាំចេញ និងផលិតផល។ តាមរយៈការវាយតម្លៃនេះបានបង្ហាញថា ការធ្វើឱ្យប្រសើរឡើងនូវការសម្រួលពាណិជ្ជកម្ម និងនីតិវិធី គឺជាវិធានការសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចាត់វិធានការសកម្មភាពបន្ថែម ដើម្បីលើកទឹកចិត្ត និងអនុញ្ញាតឱ្យក្រុមហ៊ុនបង្កើនការនាំចេញ ដែលនឹងរួមចំណែកដល់ការពង្រីក និងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ។ វិធានការគោលនយោបាយទាំងនេះ ភាគច្រើនដឹកនាំដោយក្រសួងពាណិជ្ជកម្ម ដោយមានការសហការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍។

ចំពោះវិសាលភាព និងការរៀបចំគោលនយោបាយបង្ហាញថា វិធានការគោលនយោបាយទាំង ៨ នេះគឺគ្រប់គ្រាន់ដើម្បីរួមចំណែកសម្រេចបាននូវការជំរុញ និងបង្កើនការពង្រីក និងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ ដោយហេតុវិធានការទាំងនេះមិនត្រឹមតែជួយសម្រួលដល់វិធានការគតិយុត្ត និងនីតិវិធីនាំចេញ ប៉ុន្តែក៏ជាការផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនដែលសម្រេចបានការនាំចេញក្នុងវិស័យឧស្សាហកម្មជាអាទិភាព។

## ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

វិធានការគោលនយោបាយទាំងអស់នៃអន្តរាគមន៍គោលនយោបាយទី ៣.២ នេះ បានបំពេញបន្ថែមឱ្យគ្នាទាក់ទងនឹងការលើកកម្ពស់ការពង្រីក និងការធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ។ ឧទាហរណ៍ វិធានការគោលនយោបាយ ២ នៃចង្កោមវិធានការទី១ គឺពិតជាបានបំពេញបន្ថែមឱ្យគ្នាក្នុងការជំរុញការសម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់ការនាំចេញ។ វិធានការទី ១ មានគោលបំណងបង្កើតមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មតែមួយ និងទូលំទូលាយ ដែលងាយស្រួលសម្រាប់ក្រុមហ៊ុនក្នុងការទទួលបានព័ត៌មានទាំងអស់អំពីវិធានការពាណិជ្ជកម្ម ពន្ធគយ និងថ្លៃសេវាផ្លូវការនៅកន្លែងតែមួយ ហើយវិធានការនេះត្រូវបានបំពេញបន្ថែមដោយវិធានការមួយទៀតស្តីពីការបង្កើតទីភ្នាក់ងារជំរុញការនាំចេញដែលមានជំនាញខ្ពស់ក្នុងការស្រាវជ្រាវទីផ្សារ ការកំណត់អត្តសញ្ញាណផលិតផលនាំចេញ និងបណ្តាញអាជីវកម្ម។ វិធានការគោលនយោបាយទាំង ២ នេះ អាចធ្វើឱ្យនីតិវិធីធ្វើអាជីវកម្មនៅកម្ពុជាមានភាពទាក់ទាញ និងផ្តល់ភាពងាយស្រួលដល់ក្រុមហ៊ុនទាំងអស់ ដើម្បីជំរុញទីផ្សារ និងផលិតផលនាំចេញរបស់ខ្លួន។ វិធានការគោលនយោបាយទាំង ៨ នេះ មិនមានភាពផ្ទុយគ្នាឡើយ ។

## ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

ចំពោះប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការរៀបចំ និងការអនុវត្តវិធានការគោលនយោបាយ បានបង្ហាញថា មិនមានករណីស្ទួនគ្នាក្នុងចំណោមវិធានការគោលនយោបាយទាំង ៨ ឡើយ ព្រោះវិធានការទាំងនេះបានបែងចែកជា ៤ ចង្កោមវិធានការដែលមានគោលបំណងផ្សេងៗគ្នាដូចរៀបរាប់ខាងលើ ដើម្បីលើកកម្ពស់ការពង្រីក និងការធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញរបស់កម្ពុជា។ ទោះយ៉ាងនេះក្តី វិធានការគោលនយោបាយទាំងនេះ នៅមានចន្លោះប្រហោងមួយចំនួនក្នុងការរៀបចំអន្តរាគមន៍គោលនយោបាយនេះ ដោយវិធានការគោលនយោបាយទាំង ៥ ក្នុងចង្កោមវិធានការទី ១ និងទី ២ គឺផ្តោតសំខាន់លើការលើកកម្ពស់ការពង្រីកទីផ្សារនាំចេញ និងការធ្វើពិពិធកម្ម ហើយមានវិធានការគោលនយោបាយតែ ២ ប៉ុណ្ណោះ ជាវិធានការត្រៀមដែលរួមចំណែកដល់ការពង្រីក និងការធ្វើពិពិធកម្មផលិតផលនាំចេញ។ ក្នុងន័យនេះ គោលនយោបាយ IDP គួរពិចារណាដាក់ចេញវិធានការគោលនយោបាយបន្ថែម ដើម្បីលើកកម្ពស់ និងលើកទឹកចិត្តដល់ក្រុមហ៊ុនក្នុងការផលិតទំនិញមានតម្លៃបន្ថែមខ្ពស់ដែលអាចនាំចេញទៅកាន់ទីផ្សារផ្សេងទៀត។

### ៣.២.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៣៣៖ ការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ពង្រីក និងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ"






វិធានការគោលនយោបាយចំនួន ៨ ត្រូវបានកំណត់ក្នុងគោលនយោបាយ IDP សម្រាប់គាំទ្រអន្តរាគមន៍គោលនយោបាយនេះ។ វិធានការចំនួន១ ក្នុងចំណោមវិធានការទាំងនោះ ត្រូវបានចាត់ទុកថាជាវិធានការពហុបំណង ហើយត្រូវបានបែងចែកជាអនុវិធានការចំនួន២។ ដើម្បីឆ្លុះបញ្ចាំងឱ្យបានលម្អិតពីវឌ្ឍនភាពនៃ ការអនុវត្តវិធានការពហុបំណងនេះមានតែអនុវិធានការប៉ុណ្ណោះដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃ។ ជាលទ្ធផល មានវិធានការចម្បង/អនុវិធានការ សរុបចំនួន ៩ ក្នុងនោះវិធានការចំនួន៦ ត្រូវបានសម្រេចពេញលេញ, វិធានការ ចំនួន១ កំពុងអនុវត្ត និងវិធានការចំនួន២ មានភាពយឺតយ៉ាវ។

វិធានការ "ពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងការដាក់ឱ្យប្រើប្រាស់សេវាបញ្ជរតែមួយជាតិ ដោយមានការសម្របសម្រួលគ្នាក្នុងចំណោមអាជ្ញាធរតាមមាត់ច្រកអន្តរជាតិទាំងអស់ ហើយធានាឱ្យមានសមាហរណកម្មជាមួយនឹងសេវាបញ្ជរតែមួយអាស៊ាន ដើម្បីគាំទ្រដល់បណ្តាញដឹកជញ្ជូនអន្តរជាតិ" ត្រូវបានអនុវត្តពេញលេញ ដោយសេវាបញ្ជរតែមួយជាតិ ត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់ការចេញអាជ្ញាប័ណ្ណនាំចេញ-នាំចូល។ វិធានការសំខាន់ចំនួន១ ទៀត ស្តីពី "ការលុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការក្នុងការធ្វើបែបបទបញ្ចេញទំនិញ" ត្រូវបានអនុវត្តតាមរយៈប្រកាសលេខ ១១៥១ សហវ ប្រក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ និងប្រកាសលេខ ១៦០៨ សហវ ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ឯកសារស្តីពីយន្តការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នពាក់ព័ន្ធ, ការសម្រួលឯកសារ និងនីតិវិធី សម្រាប់ការលើកលែងកាតព្វកិច្ចពន្ធ ត្រូវបានអនុម័ត និងអនុវត្តផងដែរ។ បន្ថែមលើនេះ ប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនក្នុងស្រុក និងសហគ្រាសធុនតូច និងមធ្យមឱ្យចូលរួមក្នុងការតាំងពិព័រណ៍ និងព្រឹត្តិការណ៍ពាណិជ្ជកម្មក៏ត្រូវបានបង្កើតផងដែរ ដែលជាលទ្ធផល មានកំណើននៃការចូលរួមរបស់ក្រុមហ៊ុន និងសហគ្រាសធុនតូច និងមធ្យមក្នុងកម្មវិធី ពាណិជ្ជកម្មនានាទាំងក្នុង និងក្រៅប្រទេសជាប្រចាំ។

បញ្ហាប្រឈមមួយចំនួនចំពោះវិធានការដែលកំពុងអនុវត្ត និងយឺតយ៉ាវ រួមមាន៖ បញ្ហាបច្ចេកទេស និងហិរញ្ញវត្ថុ និងការធ្វើប្រតិភូកម្មអំណាចដែលមិនពេញលេញ។

រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការអនុវត្តវិធានការក្រោមអន្តរាគមន៍គោលនយោបាយនេះដូចបានរៀបរាប់ខាងលើ។ វិធានការភាគច្រើនត្រូវបានអនុវត្តពេញលេញ។ យោងតាមរបាយការណ៍ពីក្រសួងស្ថាប័នពាក់ព័ន្ធ បានបង្ហាញថា ការអនុវត្តវិធានការគោលនយោបាយទាំងនេះបានរួមចំណែក ដល់អន្តរាគមន៍គោលនយោបាយនេះ ដោយទីផ្សារនាំចេញ និងផលិតផលមានការកើនឡើងក្នុងរយៈពេលនៃការអនុវត្តគោលនយោបាយ IDP។ ប៉ុន្តែផលិតផលនាំចេញ និងទីផ្សារនាំចេញ ពុំទាន់ត្រូវបានធ្វើពិពិធកម្មតាមការរំពឹងរបស់គោលនយោបាយ IDP នៅឡើយ។

### ៣.៣. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “ធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូចនិងមធ្យម”

#### ៣.៣.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៣៤៖ ចំណែកនៃចំនួនការងារដែលផ្តល់ដោយសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម (២០១៨-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រូបភាពទី១.៣៤ បង្ហាញអំពីចំណែកនៃចំនួនការងារដែលផ្តល់ដោយសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម ដើម្បីវាយតម្លៃតួនាទីរបស់សហគ្រាសធុនតូចនិងមធ្យម ក្នុងការបង្កើតការងារនៅក្នុងវិស័យឧស្សាហកម្ម។ តួលេខចំណែកនេះ បានកើនឡើងគួរឱ្យកត់សម្គាល់ពីប្រមាណ ២១,៨% នៅឆ្នាំ២០១៨ ដល់៣៣,៥% នៅឆ្នាំ២០១៩។ កង្វះទិន្នន័យរយៈពេលវែងសម្រាប់ធ្វើការវិភាគ នាំឱ្យមានការពិបាកសន្និដ្ឋានអំពីបច្ច័យរបស់គោលនយោបាយ IDP ក្នុងការជំរុញតួនាទីរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងការបង្កើតការងារក្នុងវិស័យឧស្សាហកម្ម។ ប៉ុន្តែយ៉ាងណាក្តី តួលេខឆ្នាំ២០១៩ ដែលជាអត្រាមួយទាបនៅឡើយ អាចបង្ហាញបានថា សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា នៅតែមិនទាន់អាចពង្រីកតួនាទីរបស់ខ្លួនក្នុងការបង្កើតឱកាសការងារបានច្រើនក្នុងវិស័យឧស្សាហកម្មដូចសហគ្រាសធំៗនៅឡើយ។

#### ៣.៣.២.ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះមានវិធានការច្បាស់លាស់ចំនួន ៣ ដែលមានមធ្យោបាយអនុវត្ត, ក្រុមគោលដៅ និងលទ្ធផលរំពឹងទុកច្បាស់លាស់ រួមមាន៖

- *បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ...*
- *ពង្រឹងអភិបាលកិច្ចសាជីវកម្ម សម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម...*

- *សិក្សានិងរៀបចំឱ្យមានយន្តការហិរញ្ញវត្ថុសមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព។*

ការវិភាគទៅលើវិធានការទាំង៣ បង្ហាញថា គោលនយោបាយ IDP ផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយផ្នែកផ្គត់ផ្គង់ជាងគោលនយោបាយផ្នែកតម្រូវការ ក្នុងគោលដៅធ្វើឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម។

ជំហានដំបូងក្នុងការធ្វើឱ្យមានតុល្យភាពគឺការជួយសហគ្រាសធុនតូច និងមធ្យមឱ្យមានវត្តមានកាន់តែច្រើនក្នុងវិស័យកម្មន្តសាល។ ជាមួយនឹងការកើនឡើងនៃចំនួនសហគ្រាសធុនតូច និងមធ្យម លទ្ធផលសរុបនិងចំនួនបុគ្គលិកសរុបរបស់សហគ្រាសធុនតូច និងមធ្យម អាចនឹងត្រូវបានបង្កើនឱ្យស្មើនឹងសហគ្រាសធុនធំដែរ។ ហេតុនេះហើយ វិធានការគោលនយោបាយ ចំនួន ១ "បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ..." ផ្តោតលើការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដល់សហគ្រាសធុនតូច និងមធ្យម ព្រោះបើគ្មានលក្ខខណ្ឌមូលដ្ឋានសមស្របទេ សហគ្រាសធុនតូច និងមធ្យមនឹងមិនអាចមានវត្តមានឡើយ។ វិធានការគោលនយោបាយនេះមិនត្រឹមតែរួមចំណែកក្នុងការបង្កើនចំនួននៃសហគ្រាសធុនតូច និងមធ្យមថ្មីប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមដែលមានវត្តមានស្រាប់ដែរ។

ទោះជាយ៉ាងណា ការកើនឡើងតែចំនួនសហគ្រាសធុនតូច និងមធ្យម នឹងមិនមាននិរន្តរភាពទេ ព្រោះសហគ្រាសធុនតូច និងមធ្យមទាំងនោះអាចដួលរលំបានយ៉ាងងាយស្រួលប្រសិនបើសមត្ថភាពគ្រប់គ្រងអាជីវកម្មរបស់ពួកគេនៅមានកម្រិត ហេតុនេះហើយការជំរុញឱ្យសហគ្រាសធុនតូចនិងមធ្យមកាន់តែមានភាពរឹងមាំពិតជាមានសារៈសំខាន់ណាស់។ ដើម្បីធានាបាននូវភាពរស់រាន ព្រមទាំងពង្រឹងភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូចនិងមធ្យម វិធានការគោលនយោបាយមួយទៀតគឺ "ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និង..." ផ្តោតធនធានទៅលើការពង្រឹងសមត្ថភាពសហគ្រាសធុនតូចនិងមធ្យម ដែលអាចឱ្យពួកគេអាចជៀសផុតពីការប្រកួតប្រជែងដ៏លំបាកជាមួយសហគ្រាសធុនធំ។

ក្រៅពីបញ្ហាប្រឈមផ្នែកប្រតិបត្តិការ លទ្ធភាពរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងការទទួលបានឥណទាន និងសេវាហិរញ្ញវត្ថុក៏នៅមានកម្រិត។ ហេតុនេះហើយ វិធានការគោលនយោបាយ "សិក្សានិងរៀបចំឱ្យមានយន្តការហិរញ្ញវត្ថុសមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព" សំដៅដោះស្រាយបញ្ហាខ្វះចន្លោះផ្នែកហិរញ្ញវត្ថុរបស់សហគ្រាសធុនតូច និងមធ្យមដើម្បីជួយគាំទ្រការរីកចម្រើន និងការពង្រីកអាជីវកម្មរបស់ពួកគេ។ នៅពេលដែលអាជីវកម្មរីកចម្រើនសហគ្រាសធុនតូចនិងមធ្យមអាចនឹងផលិត ផលិតផល ក៏ដូចជាជួលបុគ្គលិកបានច្រើនជាងមុនហើយនៅទីបំផុតតួនាទីរបស់ពួកគេនៅក្នុងវិស័យកម្មន្តសាលក៏នឹងកើនឡើងដែរ។

បើក្រឡេកមើលពីវិសាលភាពវិញ វិធានការគោលនយោបាយទាំង៣នេះប្រហែលជាអាចនឹងនាំមកនូវការផ្លាស់ប្តូរមួយចំនួនក្នុងអន្តរាគមន៍គោលនយោបាយនេះ។ ទោះជាយ៉ាងណា ដើម្បីបង្កើតការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ គួរតែបន្ថែមវិធានការជាពិសេសផ្អែកតម្រូវការទៅក្នុងអន្តរាគមន៍គោលនយោបាយនេះ។

### ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

នៅក្នុងអន្តរាគមន៍គោលនយោបាយនេះ វិធានការគោលនយោបាយចំនួន៣ ត្រូវបានរកឃើញថាមានភាពស៊ីចង្វាក់គ្នា និងបំពេញឱ្យគ្នាទៅវិញទៅមកក្នុងគោលដៅ ធ្វើឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម។ ប្រសិនបើមិនមានការទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានទេសហគ្រាសធុនតូច និងមធ្យមនឹងមិនអាចមានវត្តមានឡើយ។ ម្យ៉ាងទៀតការដែលមានសហគ្រាសធុនតូច និងមធ្យមច្រើនមិនមែនមានន័យថាមានសហគ្រាសធុនតូច និងមធ្យមដែលរឹងមាំ និងមានភាពធន់នោះទេ។ ការរស់រានរបស់ពួកគេមិនត្រូវបានធានាដោយការដែលគ្រាន់តែទទួលបាននូវតម្រូវការមូលដ្ឋានប៉ុណ្ណោះទេ។ ហេតុនេះហើយ ការពង្រឹងភាពប្រកួតប្រជែងតាមរយៈការកសាងសមត្ថភាពពិតជាមានសារៈសំខាន់ណាស់។ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម ការគាំទ្រភាពរីកចម្រើនរបស់សហគ្រាសធុនតូច និងមធ្យម តាមរយៈការផ្តល់ហិរញ្ញប្បទាន គឺមានសារៈសំខាន់ក្នុងការជួយពង្រីកអាជីវកម្មរបស់ពួកគេ។

ក្រៅពីខ្លឹមសារដែលមានលក្ខណៈបំពេញគ្នានេះ គ្មានវិធានការគោលនយោបាយណាមួយដែលមានខ្លឹមសារផ្ទុយគ្នានោះទេ។

### ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

បើក្រឡេកមើលពីប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយវិញ ឃើញថាមិនមានវិធានការណាដែលមានខ្លឹមសារដូចគ្នាទាំងស្រុងក្នុងចំណោមវិធានការគោលនយោបាយទាំង៣ នេះទេ ប៉ុន្តែនៅមានភាពខ្វះចន្លោះមួយចំនួន។ ក្រៅពីការផ្តល់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន គួរមានការលើកទឹកចិត្ត និងលើកកម្ពស់ការវិនិយោគក្នុងស្រុកបន្ថែម តាមរយៈយន្តការលើកទឹកចិត្តមួយចំនួនដែលផ្តោតលើសហគ្រិនក្នុងស្រុកក្នុងវិស័យកម្មន្តសាល។ ការធ្វើបែបនេះអាចបង្កើនចំនួននៃសហគ្រាសធុនតូច និងមធ្យមហើយចុងក្រោយអាចបង្កើនលទ្ធផល ក៏ដូចជាចំនួនបុគ្គលិកដែលពួកគេជួលផងដែរ។ ទន្ទឹមនឹងនេះ វិធានការគោលនយោបាយផ្អែកតម្រូវការរួមមានលទ្ធកម្មសាធារណៈ ដែលផ្តល់អាទិភាពដល់ផលិតផល និងសេវាកម្មរបស់សហគ្រាសធុនតូច និងមធ្យមគួរតែត្រូវបានរៀបចំឡើងដើម្បីជានាទីផ្សារសម្រាប់ផលិតផលនិងសេវាកម្មរបស់សហគ្រាសធុនតូច និងមធ្យម។

### ៣.៣.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៣៥៖ ការវាយតម្លៃទៅលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនតុល្យភាពឡើងវិញរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម"







វិធានការគោលនយោបាយច្បាស់លាស់ចំនួន ៣ ត្រូវបានដាក់ចេញក្នុងគោលនយោបាយ IDP ដើម្បីគាំទ្រអន្តរាគមន៍គោលនយោបាយនេះ។ វិធានការចំនួន ១ ត្រូវបានបំបែកចេញជាអនុវិធានការចំនួន ២ ដោយសារវិធានការនេះ ជាវិធានការពហុសកម្មភាព។ ដើម្បីឆ្លុះបញ្ចាំងឱ្យបានលម្អិតពីវឌ្ឍនភាពនៃការ

អនុវត្តវិធានការពហុបំណងនេះ មានតែអនុវិធានការប៉ុណ្ណោះដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃ។ ជាលទ្ធផល មានវិធានការ និងអនុវិធានការចំនួន ៤ ដែលត្រូវបានវាយតម្លៃ ដែលក្នុងនោះមានវិធានការនិង អនុវិធានការចំនួន ២ ត្រូវបានសម្រេចពេញលេញ, វិធានការចំនួន ១ កំពុងអនុវត្ត និងវិធានការចំនួន ១ មានភាពយឺតយ៉ាវ។

វិធានការដែលត្រូវបានសម្រេចបានពេញលេញគឺ "សិក្សានិងរៀបចំឱ្យមានយន្តការហិរញ្ញវត្ថុសមស្រប សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងជំរុញ ការផ្តល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព" មានយន្តការហិរញ្ញវត្ថុចំនួន ២ ត្រូវបានឱ្យដំណើរការគឺ ធនាគារសហគ្រាសធុនតូច និងមធ្យម និងសាជីវកម្មធានាឥណទានកម្ពុជា។ ធនាគារសហគ្រាសធុនតូច និង មធ្យម ត្រូវបានបង្កើតឡើងក្នុងត្រីមាសទី២ ឆ្នាំ២០២០ ដែលមានដើមទុនដំបូងចំនួន ១០០លានដុល្លារអាមេរិក ហើយរហូតមកដល់ពេលនេះបានផ្តល់ប្រាក់កម្ចីចំនួន ៤៨,៣លានដុល្លារអាមេរិក ដល់សហគ្រាសធុនតូចនិង មធ្យម ចំនួន ៧៥៣ រួចមកហើយ។ រីឯសាជីវកម្មធានាឥណទានកម្ពុជាវិញ ត្រូវបានបង្កើតឡើង នៅចុងឆ្នាំ ២០២០ ជាមួយនឹងដើមទុនដំបូងចំនួន ២០០លានដុល្លារអាមេរិក។

បញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះ ក្នុងពេលអនុវត្តវិធានការកំពុងអនុវត្ត និងយឺតយ៉ាវ រួមមាន៖ (១) កង្វះខាតធនធាន និងពេលវេលា, (២) ការផ្តល់ការគាំទ្រផ្អែកតាមករណីនីមួយៗសម្រាប់ការអភិវឌ្ឍ មូលដ្ឋានប្រមូលផ្តុំរបស់សហគ្រាសធុនតូច និងមធ្យម, និង (៣) ស្ថាប័នសម្របសម្រួលមិនមានសមត្ថកិច្ច គ្រប់គ្រាន់ក្នុងការបំពេញភារកិច្ច។ ដំណោះស្រាយមួយចំនួនដែលបានស្នើឡើងដោយស្ថាប័នទទួលបន្ទុក អនុវត្ត ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើមានដូចជា៖ (១) ការបែងចែកថវិកា និងពេលវេលាឱ្យបាន ប្រសើរជាងមុនដើម្បីជួយគាំទ្រដល់ការអនុវត្តវិធានការគោលនយោបាយ, (២) ការរៀបចំកិច្ចពិភាក្សា អន្តរក្រសួងដើម្បីកំណត់គោលការណ៍រួមសម្រាប់គាំទ្រការអភិវឌ្ឍមូលដ្ឋានប្រមូលផ្តុំរបស់សហគ្រាសធុនតូច និង មធ្យមឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងការផ្តល់ការគាំទ្រផ្អែកតាមករណីនីមួយៗ, និង (៣) ការផ្តល់ ប្រតិភូកម្មអំណាចសម្របសម្រួលពេញលេញដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីរៀបចំនិងសម្របសម្រួល លើការងារនេះ។

យោងតាមរបាយការណ៍ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ការអនុវត្តវិធានការដែលស្ថិតនៅក្នុងអន្តរាគមន៍ គោលនយោបាយនេះត្រូវបានអនុវត្តតាមជំហានត្រឹមត្រូវចាប់តាំងពីការដាក់ឱ្យដំណើរការធនាគារសហគ្រាស ធុនតូច និងមធ្យម និងសាជីវកម្មធានាឥណទានកម្ពុជា ដើម្បីជួយគាំទ្រសហគ្រាសធុនតូច និងមធ្យមក្នុងការ ទទួលបានហិរញ្ញវត្ថុ ឬឥណទានកាន់តែងាយស្រួលជាងមុន។ ការបណ្តុះបណ្តាលបន្ថែមដល់សហគ្រាសធុន តូច និងមធ្យម គួរត្រូវបានរៀបចំសម្រាប់ពង្រឹងសមត្ថភាពសហគ្រាសទាំងនោះក្នុងការគ្រប់គ្រងទូទៅ, ការ គ្រប់គ្រងប្រព័ន្ធផលិតកម្ម និងបច្ចេកវិទ្យា។ បន្ថែមលើនេះ ការផ្តល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម និងមូលដ្ឋានប្រមូលផ្តុំរបស់សហគ្រាសធុនតូច និងមធ្យមគួរតែអនុលោមតាមក្របខណ្ឌលើក ទឹកចិត្តរួមតែមួយ ដើម្បីជៀសវាងការផ្តល់ការលើកទឹកចិត្តផ្អែកតាមករណីនីមួយៗ។

## ៣.៨. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម”

### ៣.៨.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៣៦៖ ចំនួនប្រកាសនីយបត្រតក្កកម្មជាធរមាន (ឆ្នាំ២០០៧-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រូបភាពទី១.៣៦ បង្ហាញអំពីចំនួនសំណើនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០២០។ ចំនួនសំណើនៃការដាក់ពាក្យសុំសរុប បានកើនឡើងទាំងមុនពេលដាក់ចេញគោលនយោបាយ IDP និងក្រោយពេលដាក់ចេញគោលនយោបាយ IDP ដោយក្នុងនោះ នៅឆ្នាំ២០០៧ មានសំណើចំនួន ១៣ ហើយបានកើនដល់ ៦៥នៅឆ្នាំ២០១៥។ ជាការកត់សម្គាល់ ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP ចំនួនសំណើបានកើនឡើងខ្លាំងរហូតដល់ ១.១៩០ នៅឆ្នាំ ២០២០។ យ៉ាងណាក្តី ក្នុងចំណោមសំណើទាំងនេះ សំណុំដែលដាក់ពាក្យដោយនិវាសនជនកម្ពុជានៅមានចំនួនតិចតួចបំផុត ដោយឆ្នាំខ្លះពុំមានការស្នើសុំពីនិវាសនជនកម្ពុជាម្នាក់សោះឡើយ។ ភាគច្រើន អនិវាសនជនដែលបានដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម គឺមានគោលបំណងគ្រាន់តែយកបច្ចេកវិទ្យានវានុវត្តន៍ ដែលត្រូវបានបង្កើតនៅក្នុងប្រទេសរបស់ពួកគេរួចហើយ មកសុំការការពារបន្ថែមទៀតនៅកម្ពុជាប៉ុណ្ណោះ ដើម្បីប្រកបអាជីវកម្មជាមួយនឹងបច្ចេកវិទ្យានវានុវត្តន៍នោះនៅកម្ពុជា។

រូបភាពទី១.៣៧៖ ចំនួនប្រកាសនីយបត្រតក្កកម្មដែលផ្ដល់ជូន (២០០៧-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រូបភាពទី១.៣៧ បង្ហាញពីចំនួនប្រកាសនីយបត្រតក្កកម្មដែលផ្ដល់ជូន ចាប់ពីឆ្នាំ២០០៧ដល់ឆ្នាំ២០២០។ ក្នុងអំឡុងពេលចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ មានសំណើដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មជាច្រើនរៀងរាល់ឆ្នាំ ប៉ុន្តែគ្មានសំណើណាមួយបានទទួលការអនុម័តឡើយ ដោយសារមូលហេតុចម្បងពីររួមមាន (១) អ្នកដាក់ពាក្យសុំមិនបានផ្ដល់ឯកសារគ្រប់គ្រាន់សម្រាប់នីតិវិធីត្រួតពិនិត្យក្នុងការផ្ដល់ការការពារប្រកាសនីយបត្រតក្កកម្ម និង (២) កង្វះមន្ត្រីជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យលើប្រកាសនីយបត្រតក្កកម្មដែលមានបច្ចេកវិទ្យាខ្ពស់។ លុះមកដល់ឆ្នាំ២០១៥ ទើបមានសំណើដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មចំនួន ១ ទទួលបានជោគជ័យ។ ចាប់តាំងពីឆ្នាំនោះមក ចំនួនប្រកាសនីយបត្រតក្កកម្មសរុបដែលបានផ្ដល់ជូន បានកើនឡើងជាបន្តបន្ទាប់រហូតដល់ចំនួន ១៨៣ នៅឆ្នាំ២០១៩ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គភាពកម្មសិទ្ធិឧស្សាហកម្មរបស់សិង្ហបុរី និងដៃគូកម្មសិទ្ធិឧស្សាហកម្មផ្សេងទៀតដូចជា ជប៉ុន កូរ៉េ ចិន អឺរ៉ុប អាមេរិក ជាដើម ដើម្បីពន្លឿនការពិនិត្យសំណើសុំប្រកាសនីយបត្រតក្កកម្ម។ គួរកត់សម្គាល់ផងដែរថា សំណើសុំខ្លះអាចត្រូវការពេលច្រើនជាងមួយឆ្នាំ ដើម្បីពិនិត្យ និងសម្រេច ហើយសំណើខ្លះត្រូវបានស្នើសុំដកវិញដោយអ្នកស្នើសុំ មុនពេលចេញលទ្ធផលក៏មាន។

គិតចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ សំណើដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មដោយនិវាសនជនមានសរុបត្រឹមតែ ១១ សំណើប៉ុណ្ណោះ ប៉ុន្តែមានតែ ១ សំណើប៉ុណ្ណោះដែលជោគជ័យក្នុងការទទួលបានប្រកាសនីយបត្រតក្កកម្មនៅឆ្នាំ២០១៥។

### ៣.៨.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

ការវាយតម្លៃទៅលើវិធានការគោលនយោបាយចំនួន ១៦ ដែលត្រូវបានផ្សារភ្ជាប់ជាមួយអន្តរាគមន៍គោលនយោបាយនេះបង្ហាញយ៉ាងច្បាស់ថា គោលនយោបាយ IDP ដាក់ការផ្តោតទៅលើ "នវានុវត្តន៍ផ្នែកបច្ចេកវិទ្យា" ជាង "នវានុវត្តន៍ទៅលើការគ្រប់គ្រងក្រុមហ៊ុន ឬស្ថាប័ន"។ ការណ៍ដែលគោលនយោបាយ IDP ផ្តោតខ្លាំងទៅលើនវានុវត្តន៍ផ្នែកបច្ចេកវិទ្យា អាចត្រូវបានមើលឃើញក្នុងលទ្ធផលរំពឹងទុករបស់វិធានការនីមួយៗ។ ចំនួនវិធានការជាច្រើនក្រោមអន្តរាគមន៍គោលនយោបាយនេះ បង្ហាញពីសារៈសំខាន់នៃនវានុវត្តន៍ផ្នែកឧស្សាហកម្មក្នុងគោលនយោបាយ IDP។ វិធានការភាគច្រើនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ វិធានការគោលនយោបាយទាំង១៦ ត្រូវបានបែងចែកជាពីរចង្កោមវិធានការគោលនយោបាយ រួមមាន (១) ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់គាំទ្រនវានុវត្តន៍ (៩ វិធានការ) និង (២) ការស្រាវជ្រាវ និងការអភិវឌ្ឍ (៧ វិធានការ)។

រូបភាពទី១.៣៨៖ ចង្កោមទាំងពីរនៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម"




ដូចដែលសេដ្ឋកិច្ចត្រូវការហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីលូតលាស់ នវានុវត្តន៍ក៏ត្រូវការហេដ្ឋារចនាសម្ព័ន្ធមួយបែបដែរ ហេតុនេះហើយ ចង្កោមវិធានការគោលនយោបាយទី១ "ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់គាំទ្រនវានុវត្តន៍" សំដៅជួយឱ្យនវានុវត្តន៍កើតមានឡើង តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍ រួមមានប្រព័ន្ធសិក្សារបស់ជាតិ, ការវិនិយោគទៅលើវិទ្យាសាស្ត្រមូលដ្ឋាន, ការបណ្តុះបណ្តាលនិងការរក្សាបុគ្គលិក និងហេដ្ឋារចនាសម្ព័ន្ធទន់ដទៃទៀត។ ចង្កោមវិធានការគោលនយោបាយនេះមានវិធានការគោលនយោបាយចំនួន៩ ក្នុងនោះវិធានការគោលនយោបាយចំនួន៤ "ការកែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ...", "ចាត់វិធានការជាក់ស្តែងក្នុងការពង្រឹងការអនុវត្តស្តង់ដារ...", "បង្កើនការយល់ដឹង និងការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ, មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម..." និង "ពន្លឿនការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ និងវិធានការ..." សំដៅបង្កើតលក្ខខណ្ឌមូលដ្ឋានសម្រាប់ជួយឱ្យនវានុវត្តន៍កើតមានឡើង

និងរីកចម្រើនតាមរយៈការដាក់ចេញនិងបន្តធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌបទប្បញ្ញត្តិនិងដំណើរការនៃហេដ្ឋា-រចនាសម្ព័ន្ធនវានុវត្តន៍រួមមានមាត្រាសាស្ត្រ, កម្មសិទ្ធិបញ្ញាឧស្សាហកម្ម, ស្តង់ដារ។ល។ ការដាក់ឱ្យប្រតិបត្តិនូវកម្មសិទ្ធិបញ្ញាឧស្សាហកម្ម អាចលើកទឹកចិត្តក្រុមហ៊ុនឱ្យច្នៃប្រឌិតប្រកបដោយទំនុកចិត្ត ព្រោះការធ្វើបែបនេះអាចទប់ស្កាត់ការចម្លងដោយគ្មានការអនុញ្ញាតនូវគំនិតច្នៃប្រឌិត និងនវានុវត្តន៍។ ហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍ផ្សេងទៀត ក៏មានសារៈសំខាន់ក្នុងការលើកកម្ពស់នវានុវត្តន៍ដែរ ដោយពួកគេអាចធានាបាននូវសុវត្ថិភាព, ភាពជឿជាក់ និង ភាពរឹងមាំនៃបច្ចេកវិទ្យាថ្មី ឬបច្ចេកវិទ្យាដែលត្រូវបានយកមកប្រើប្រាស់។

ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធរបស់នវានុវត្តន៍បានជោគជ័យ វិធានការគោលនយោបាយចំនួន ៣ "បន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាព...", "ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចមាត្រាសាស្ត្រ...", និង "លើកស្ទួយសមត្ថភាពវិទ្យាស្ថានឧត្តមសិក្សាដើម្បីក្រេបជញ្ជក់..." ផ្តោតទៅលើការកសាងសមត្ថភាពនៃស្ថាប័នសាធារណៈក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធនេះឱ្យបានប្រសើរជាងមុន ក៏ដូចជាជួយឱ្យគ្រឹះស្ថានអប់រំអាចក្រេបជញ្ជក់យកចំណេះដឹងវិទ្យាសាស្ត្រផងដែរ។ ដោយធនធានមនុស្សជាធាតុផ្សំដ៏សំខាន់មួយទៀតរបស់ហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍ វិធានការគោលនយោបាយពីរផ្សេងទៀត "បង្កើតពានរង្វាន់សម្រាប់ការប្រកួត-ប្រជែងបច្ចេកទេស នៅលើគ្រប់មុខសញ្ញាអាទិភាព" និង "បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករដែលមានទេពកោសល្យ ..." សំដៅកសាងធនធានមនុស្សនិងគណិតវិទ្យា (STEM)។ ហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍ ដែលត្រូវបានធ្វើឱ្យប្រសើរឡើង និងមានលក្ខណៈគ្រប់គ្រាន់អាចធ្វើឱ្យមានការកើនឡើងនូវសកម្មភាពសហគ្រិនភាព ប្រកបដោយនវានុវត្តន៍ក្នុងប្រទេសកម្ពុជា ដែលអាចបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្មទាំងមូលក្នុងប្រទេស។ យ៉ាងណាមិញ វិធីសាស្ត្រក្នុងការអនុវត្តវិធានការគោលនយោបាយមួយក្នុងចំណោមវិធានការគោលនយោបាយទាំង ៩ មិនត្រូវបានចែងច្បាស់លាស់ទេ ហើយវិធានការគោលនយោបាយមួយទៀតមានលក្ខណៈជាវិធានការត្រៀម។ "ចាត់វិធានការដាក់ស្តែងក្នុងការពង្រឹងការអនុវត្តស្តង់ដារ..."ជាវិធានការគោលនយោបាយមិនច្បាស់លាស់ដោយមធ្យោបាយក្នុងការអនុវត្តវិធានការនេះមិនត្រូវបានចែង រីឯ "ពន្លឿនការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិនិង វិធានការ..." ជាវិធានការត្រៀមព្រោះការអនុវត្តវិធានការនេះនឹងមិនផ្តល់ផលភ្លាមៗនោះទេ។

ចង្កោមវិធានការគោលនយោបាយទី២ "ការស្រាវជ្រាវ និងការអភិវឌ្ឍ" ផ្តោតទៅលើការពង្រឹងសមត្ថភាព, ការបង្កើនសកម្មភាពពាក់ព័ន្ធ និងការបង្កើនចំណាយទៅលើការស្រាវជ្រាវ និងការអភិវឌ្ឍ។ ចង្កោមវិធានការគោលនយោបាយនេះមានវិធានការគោលនយោបាយត្រៀមចំនួន ៤, វិធានការគោលនយោបាយមិនច្បាស់លាស់ចំនួន ២ និងវិធានការគោលនយោបាយច្បាស់លាស់ចំនួន ១។ វិធានការគោលនយោបាយចំនួន ២ តម្រូវឱ្យមានការសិក្សាសមិទ្ធិលទ្ធភាពចំនួន ២ ដែលជាមគ្គុទ្ទេសក៍បង្ហាញផ្លូវដល់ការវិនិយោគ ក្នុងវិទ្យាស្ថានស្រាវជ្រាវរបស់រាជរដ្ឋាភិបាល និងវិធីសាស្ត្រក្នុងការបង្កើតសួនវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ឱ្យមានដំណើរការល្អបំផុតក្នុងការផ្តល់នូវការពិសោធន៍និងការស្រាវជ្រាវផ្នែកឧស្សាហកម្ម។ ក្រៅពីបរិក្ខារគាំទ្រការស្រាវជ្រាវ និងថវិកាដើម្បីចាប់ផ្តើមសកម្មភាពពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការអភិវឌ្ឍ ការកសាងសមត្ថភាពក្នុងការធ្វើការស្រាវជ្រាវនិងការអភិវឌ្ឍក៏មានសារៈសំខាន់ដែរ។ ហេតុនេះហើយ វិធានការគោលនយោបាយចំនួន៥គឺ "ពង្រឹងសមត្ថភាព "វិទ្យាស្ថានស្តង់ដារកម្ពុជា" ក្នុងការសិក្សាស្រាវជ្រាវ...", "ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រក្នុងការ

សិក្សាស្រាវជ្រាវ...", "សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា បច្ចេកវិទ្យា និង នវានុវត្តន៍ ...", និង "ពង្រឹងការគ្រប់គ្រងមណ្ឌលច្នៃប្រឌិត និងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតតក្កកម្ម..." ផ្តោតលើការកសាងសមត្ថភាពរបស់វិទ្យាស្ថានជាតិក្នុងការធ្វើការស្រាវជ្រាវ និងការអភិវឌ្ឍ។ ការផ្តោតទៅលើការស្រាវជ្រាវ និងការអភិវឌ្ឍ គឺជាការវិនិយោគលើបច្ចេកវិទ្យានិងសមត្ថភាពសម្រាប់ពេលអនាគត ដែលអាចនាំមកនូវលទ្ធភាពគ្មានទីបញ្ចប់ ហេតុនេះហើយ ការស្រាវជ្រាវ និងការអភិវឌ្ឍ គឺជាធាតុផ្សំដ៏សំខាន់មួយក្នុងការធ្វើឱ្យកើតមានឡើងនូវនវានុវត្តន៍។

បើក្រឡេកមើលពីវិសាលភាពវិញ វិធានការទាំង១៦ មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្មបានឆាប់រហ័សនោះទេ។ វិធានការចំនួន៩ នៅក្នុងចង្កោមវិធានការទី១ មានលក្ខណៈគ្រប់គ្រាន់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់គាំទ្រនវានុវត្តន៍នៅក្នុងប្រទេសកម្ពុជា។ យ៉ាងណាមិញ វិធានការចំនួន ៧ នៅក្នុងចង្កោមវិធានការគោលនយោបាយទី២ មិនអាចបង្កើនការស្រាវជ្រាវ និងការអភិវឌ្ឍបានភ្លាមៗនោះទេ ហេតុនេះហើយគួរតែមានវិធានការគោលនយោបាយច្បាស់លាស់បន្ថែមទៀតសម្រាប់លើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ ព្រោះជាចំណុចសំខាន់នៃនវានុវត្តន៍ផ្នែកបច្ចេកវិទ្យា។

### ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

នៅក្នុងអន្តរាគមន៍គោលនយោបាយនេះ វិធានការគោលនយោបាយភាគច្រើនត្រូវបានរកឃើញថាមានខ្លឹមសារចុះសម្រុងគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក ដែលមានវិធានការគោលនយោបាយចំនួនបីពាក់ព័ន្ធនឹងហេដ្ឋរចនាសម្ព័ន្ធនវានុវត្តន៍ជាឧទាហរណ៍។ វិធានការគោលនយោបាយ "បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម..." បំពេញខ្លឹមសារឱ្យវិធានការគោលនយោបាយពីរផ្សេងទៀតគឺ "បន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម..." និង "កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធីធ្វើកិច្ចសហការប្រតិបត្តិការផ្តល់សិទ្ធិចុះបញ្ជី..."។ ដើម្បីបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម ការដែលមានហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍ពិតជាមានសារៈសំខាន់ណាស់ ព្រោះអាចជួយឱ្យនវានុវត្តន៍កើតមានឡើង និងលូតលាស់។ ដូចគ្នាដែរ ការធានាបានថាស្ថាប័នសាធារណៈអាចដាក់ឱ្យប្រើប្រាស់ ក៏ដូចជាគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធទាំងនោះ នឹងជួយឱ្យហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍កាន់តែមានលក្ខណៈល្អប្រសើរឡើង។ ការដែលគ្រាន់តែកសាង និងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ មិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ តម្រូវឱ្យមានការធានាធ្វើឱ្យប្រាកដថាសហគ្រាស ឬក្រុមហ៊ុននឹងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ ហេតុនេះហើយសារៈសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍គួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

ក្រៅពីខ្លឹមសារដែលមានលក្ខណៈបំពេញគ្នានេះ គ្មានវិធានការគោលនយោបាយណាមួយដែលមានខ្លឹមសារ ប្រទាំងគ្នា ឬផ្ទុយគ្នានោះទេ។ ជាក់ស្តែង វិធានការគោលនយោបាយទាំងនេះបំពេញឱ្យគ្នាទៅវិញទៅមកក្នុងគោលដៅបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម។

## ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

បើក្រលេកមើលពីប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយនេះវិញ ឃើញថាមានវិធានការមួយចំនួនដែលដូចគ្នាទាំងស្រុងក្នុងចំណោមវិធានការគោលនយោបាយទាំង១៦នេះ។ វិធានការគោលនយោបាយ "ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដារក្នុងការធានា..." គឺដូចគ្នានឹងវិធានការគោលនយោបាយ "បន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម..." ព្រោះវិធានការគោលនយោបាយទាំងពីរនេះមានគោលបំណងដូចគ្នា គឺដាក់ឱ្យប្រើប្រាស់ និងធ្វើឱ្យមានការអនុលោមខ្ពស់តាមស្តង់ដានិងមាត្រាសាស្ត្រ និងមានមធ្យោបាយក្នុងការអនុវត្តដូចគ្នាគឺ តាមរយៈការពង្រឹងសមត្ថភាពរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជាក្នុងការគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដា។

ជាមួយគ្នានេះ អន្តរាគមន៍គោលនយោបាយនេះនៅមានភាពខ្វះចន្លោះមួយចំនួន។ ភាពខ្វះចន្លោះទី១ គឺ គ្មានវិធានការគោលនយោបាយនៅក្នុងអន្តរាគមន៍គោលនយោបាយនេះ ដែលផ្តោតលើការកសាងប្រព័ន្ធនវានុវត្តន៍មួយដែលរឹងមាំ ដោយធ្វើឱ្យមានការសហការរវាងសកលវិទ្យាល័យ និងវិស័យឯកជនក្នុងការធ្វើការស្រាវជ្រាវ និងការអភិវឌ្ឍនោះទេ។ អត្ថប្រយោជន៍នៃការសហការបែបនេះគឺអាចអនុញ្ញាតឱ្យពួកគេប្រើប្រាស់កន្លែង និងឧបករណ៍ស្រាវជ្រាវរួមគ្នា ដែលធ្វើឱ្យនិស្សិតអាចប្រើប្រាស់កន្លែង និងឧបករណ៍ស្រាវជ្រាវបានងាយស្រួលជាងមុន។ លើសពីនេះទៀត ការលំបាកក្នុងការជ្រើសរើសបុគ្គលដែលមានសមត្ថភាពមកធ្វើការក្នុងវិស័យ STEM ក៏អាចដោះស្រាយបាន ព្រោះតាមរយៈកិច្ចសហការបែបនេះ ក្រុមហ៊ុនអាចមានភាពងាយស្រួលជាងមុនក្នុងការសំអិតសំអាង និងជ្រើសរើសនិស្សិតមកធ្វើការក្នុងវិស័យនវានុវត្តន៍។ ភាពខ្វះចន្លោះទី២គឺ គ្មានវិធានការគោលនយោបាយណាសំដៅបង្កើតទិសដៅយុទ្ធសាស្ត្រឬឯកសារគោលនយោបាយច្បាស់លាស់ក្នុងការលើកកម្ពស់នវានុវត្តន៍នោះទេ។ ការមានទិសដៅយុទ្ធសាស្ត្រច្បាស់លាស់អាចតម្រង់ទីភ្នាក់ងាររដ្ឋាភិបាលទាំងអស់ក្នុងទិសដៅតែមួយ ដើម្បីធានាបានថានឹងមិនមានវិធានការគោលនយោបាយណាមិនមានសង្គតិ-ភាព ឬប្រឆាំងគ្នា ដែលនាំឱ្យរាំងស្ទះដល់វឌ្ឍនភាពនៃនវានុវត្តន៍ឡើយ។ ភាពខ្វះចន្លោះទី៣គឺ វិធានការគោលនយោបាយភាគច្រើនដែលពាក់ព័ន្ធនឹងនវានុវត្តន៍ផ្នែកឧស្សាហកម្មនៅក្នុង IDP ផ្តោតតែលើផ្នែកផ្គត់ផ្គង់ (supply side) តែប៉ុណ្ណោះ រីឯផ្នែកតម្រូវការវិញ (demand side) គឺមិនសូវមានវិធានការគោលនយោបាយទេ។ វិធានការគោលនយោបាយផ្នែកតម្រូវការគឺមានសារៈសំខាន់ក្នុងការជំរុញតម្រូវការសម្រាប់នវានុវត្តន៍ដែលអាចធ្វើឱ្យនវានុវត្តន៍ផ្នែកឧស្សាហកម្មកាន់តែមាននិរន្តរភាព។ ភាពខ្វះចន្លោះទី៤គឺ គ្មានវិធានការគោលនយោបាយណាដែលបានលើកឡើងពីនវានុវត្តន៍ទៅលើការគ្រប់គ្រងក្រុមហ៊ុន ឬស្ថាប័នទេ។ នវានុវត្តន៍ប្រភេទនេះគឺមានសារៈសំខាន់ដូចនវានុវត្តន៍ផ្នែកបច្ចេកវិទ្យាដែរ ព្រោះអាចធ្វើឱ្យប្រសើរឡើងនូវសមិទ្ធកម្មរបស់ក្រុមហ៊ុន តាមរយៈការកាត់បន្ថយថ្លៃរដ្ឋបាល និងប្រតិបត្តិការ និងការបង្កើនផលិតភាព ។ល។ គំរូអាជីវកម្មប្រកបដោយនវានុវត្តន៍ ឬរបៀបរបបធ្វើការងារថ្មីអាចចូលរួមចំណែកក្នុងការបង្កើនភាពប្រកួតប្រជែង និងការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាពរបស់សហគ្រាសនីមួយៗ និងវិស័យឧស្សាហកម្មទាំងមូលផងដែរ។

ជារួម IDPបានកំណត់ចំណុចចាប់ផ្តើមដ៏ត្រឹមត្រូវក្នុងការលើកកម្ពស់នវានុវត្តន៍ផ្នែកឧស្សាហកម្មក្នុងប្រទេសកម្ពុជា។ វិធានការគោលនយោបាយទាំង១៦ មានចំណុចល្អមួយចំនួន ហើយប្រហែលជាមានសក្តានុពល

ក្នុងការបង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្មក្នុងប្រទេសកម្ពុជា។ យ៉ាងណាមិញ ដើម្បីធ្វើឱ្យនវានុវត្តន៍ផ្នែកឧស្សាហកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់ តម្រូវឱ្យមានវិធានការគោលនយោបាយដែលមានលក្ខណៈច្បាស់លាស់បន្ថែមទៀត។

### ៣.៨.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

វិធានការចំនួន ១៦ ត្រូវបានកំណត់ដើម្បីគាំទ្រដល់អន្តរាគមន៍គោលនយោបាយនេះ។ វិធានការចំនួន ១ ត្រូវបានបំបែកចេញជាអនុវិធានការចំនួន ២ ដោយសារវិធានការនេះ ជាវិធានការពហុសកម្មភាព។ ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តវិធានការពហុបំណងនេះ មានតែអនុវិធានការគោលនយោបាយប៉ុណ្ណោះ ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃ។ ជាលទ្ធផល មានវិធានការនិងអនុវិធានការចំនួន ១៦ ត្រូវបានវាយតម្លៃ ដែលក្នុងនោះវិធានការចំនួន ៤ ត្រូវបានសម្រេចបានពេញលេញ, វិធានការចំនួន ៨ កំពុងអនុវត្ត និងវិធានការចំនួន ៤ មានភាពយឺតយ៉ាវ។

រូបភាពទី១.៣៩៖ ការវាយតម្លៃទៅលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម"






ចង្កោមវិធានការគោលនយោបាយទី១ ផ្តោតលើ "ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់គាំទ្រនវានុវត្តន៍" មានវិធានការ ចំនួន២ ដែលត្រូវបានសម្រេចពេញលេញ ។ ក្របខណ្ឌគោលនយោបាយត្រូវបានបង្កើតឡើងជាមូលដ្ឋាន ដើម្បីកសាងសមត្ថភាពស្ថាប័នឧត្តមសិក្សា ក្នុងការស្រូបយកចំណេះដឹងវិទ្យាសាស្ត្រ និងលើកកម្ពស់នវានុវត្តន៍ផ្នែកបច្ចេកវិទ្យាដែលជំរុញដោយទីផ្សារ ក្នុងនោះមានដូចជា គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា ២០៣០ (អនុម័តនៅខែមេសាឆ្នាំ ២០១៤) (ឆ្នាំគោលដៅ ២០៣០) និងគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (អនុម័តនៅខែមីនា ២០១៦) (គ្មានឆ្នាំគោលដៅ)។ ដោយសារការដាក់ចេញនូវគោលនយោបាយទាំងនេះ និងតម្រូវក្នុងទីផ្សារការងារផងនោះ មានសិស្ស និស្សិតចំនួន ៤.០០០នាក់ បានសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៩។ ផ្ទុយទៅវិញ ចំពោះចង្កោមវិធានការនេះ មានវិធានការចំនួន ៣ ដែលកំពុងត្រូវបានអនុវត្ត ហើយវិធានការចំនួន ៣ ទៀត មានភាពយឺតយ៉ាវ។ បញ្ហាដែលរារាំងដល់វឌ្ឍនភាពនៃការអនុវត្តចង្កោមវិធានការទី១ រួមមាន (១) កង្វះធនធានមនុស្ស និងថវិកាសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍ និងការរៀបចំការប្រកួតប្រជែងផ្នែកបច្ចេកវិទ្យា, (២) សមត្ថភាពរបស់ស្ថាប័ននៅមានកម្រិត (ទាំងធនធានមនុស្ស និងការបង្កើតកម្មវិធីសម្រាប់ការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម), និង (៣) កង្វះការចូលរួមពីវិស័យឯកជន និងតួអង្គពាក់ព័ន្ធផ្សេងទៀត។ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងពាក់ព័ន្ធទទួលបន្ទុកលើការងារនេះបានសំណូមពរនូវចំណុចមួយចំនួនដូចជា៖ (១) ស្នើឱ្យមានធនធានមនុស្សបន្ថែមដើម្បីពង្រឹងការស្រាវជ្រាវនិងការអភិវឌ្ឍ, មូលនិធិផ្ទាល់សម្រាប់អង្គភាពដែលអនុវត្តការងារនេះ និងថវិកាបន្ថែមសម្រាប់រៀបចំការប្រកួតប្រជែងផ្នែកបច្ចេកវិទ្យា, (២) ត្រូវការជំនួយពីភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ក្នុងការកសាងសមត្ថភាពពាក់ព័ន្ធនឹងកម្មវិធីចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម, និង (៣) ព្យាយាមភ្ជាប់ទំនាក់ទំនងជាមួយវិស័យឯកជន និងតួអង្គពាក់ព័ន្ធឱ្យបានញឹកញាប់។

ចង្កោមវិធានការគោលនយោបាយទី២ "ការស្រាវជ្រាវនិងការអភិវឌ្ឍ" ក៏មានវិធានការចំនួន ២ ត្រូវបានសម្រេចពេញលេញផងដែរ ក្នុងនោះមានវិធានការមិនច្បាស់លាស់មួយ និងវិធានការត្រៀមមួយ។ ក្របខណ្ឌគោលនយោបាយ ដែលត្រូវបានបង្កើតឡើងជាមូលដ្ឋានសម្រាប់កសាងសមត្ថភាពស្រាវជ្រាវ និងការអភិវឌ្ឍក្នុងផ្នែកបច្ចេកវិទ្យាឧស្សាហកម្ម គឺគោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ (អនុម័តនៅឆ្នាំ២០១០)។ គោលនយោបាយនេះត្រូវបានរៀបចំឡើងសម្រាប់កសាងវប្បធម៌ស្រាវជ្រាវក្នុងគ្រឹះស្ថានឧត្តមសិក្សា និងដើម្បីធានាបាននូវការតភ្ជាប់រវាងស្ថាប័នបណ្តុះបណ្តាល និងស្ថាប័នស្រាវជ្រាវ។ ទន្ទឹមនឹងនេះ ក្នុងកម្រិតគោលនយោបាយ ក៏មានការស្រាវជ្រាវគោលនយោបាយផ្អែកលើសក្ខីកម្មស្តីពីសេដ្ឋកិច្ចការងារ, ផលិតភាពនិងភាពប្រកួតប្រជែងផងដែរ។ ចាប់ពីឆ្នាំ២០១៥ ដល់២០១៩ ឯកសារគោលនយោបាយជាមធ្យម ចំនួន ៣ ត្រូវបានរៀបចំជាប្រចាំសម្រាប់ថ្នាក់ដឹកនាំ និងអ្នករៀបចំគោលនយោបាយ ដើម្បីពង្រឹងការរៀបចំគោលនយោបាយជាតិដោយផ្អែកលើភស្តុតាងជាក់លាក់។ យ៉ាងណាមិញ មានវិធានការចំនួន៥ ដែលកំពុងអនុវត្ត និងវិធានការយឺតយ៉ាវចំនួន ១។ បញ្ហាប្រឈមមួយចំនួនដែលរារាំងវឌ្ឍនភាពនៃការអនុវត្តចង្កោមវិធានការនេះ រួមមាន (១) កង្វះពេលវេលា, ធនធានមនុស្ស និងថវិកា និង (២) កង្វះការធ្វើបច្ចុប្បន្នភាពព័ត៌មាន និងឯកសារមួយចំនួន។ ក្រសួងពាក់ព័ន្ធបានលើកឡើងពីតម្រូវការក្នុងការបែងចែកពេលវេលា ធនធានមនុស្ស និងថវិកាឱ្យបានល្អជាងមុន, និងការពន្លឿនដំណើរការស្រាវជ្រាវ និងការពិភាក្សាជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត។

ជារួម វិធានការក្នុងអន្តរាគមន៍គោលនយោបាយនេះប្រមាណ ២៥% ត្រូវបានសម្រេចពេញលេញ, ៥០% កំពុងត្រូវបានអនុវត្ត និង ២៥% មានភាពយឺតយ៉ាវ ដែលនេះទាមទារឱ្យមានការខិតខំបន្ថែមទៀតដើម្បីសម្រេចបាននូវអន្តរាគមន៍គោលនយោបាយនេះ។

## ៣.៩. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម"

### ៣.៩.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៤០៖ អត្រាចុះបញ្ជីសហគ្រាសធុនតូច ធុនមធ្យម និងធុនធំ




ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រូបភាពទី១.៤០ បង្ហាញអំពីអត្រាចុះបញ្ជីរបស់សហគ្រាសធុនតូចនិងមធ្យម ពីឆ្នាំ២០១៥ ដល់ឆ្នាំ ២០១៩ និងអត្រាចុះបញ្ជីរបស់សហគ្រាសធុនធំ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩។ អត្រាចុះបញ្ជីរបស់សហគ្រាសធុនតូចបានកើនឡើងជាលំដាប់ពីប្រមាណ ៦៤,៤% នៅឆ្នាំ២០១៥ ដល់ ៦៥,៥% នៅឆ្នាំ ២០១៧ ប៉ុន្តែមានការធ្លាក់ចុះមកត្រឹម ៤៩,៧% នៅឆ្នាំ២០១៨ និង២០១៩ ដែលទាបជាងអត្រាគោលដៅ (៧០%) នៅឆ្នាំ២០២០។ ដោយឡែក អត្រាចុះបញ្ជីរបស់សហគ្រាសធុនមធ្យម បានកើនឡើងជាលំដាប់ពី ៨៣,១%នៅឆ្នាំ២០១៥ ដល់ ៨៧% ឆ្នាំ២០១៩ ដែលសម្រេចបានអត្រាគោលដៅ (៨០%) នៅឆ្នាំ២០២០ ប៉ុន្តែពុំទាន់សម្រេចបានអត្រាគោលដៅ (៩៥%) នៅឆ្នាំ២០២៥នៅឡើយ។ ចំពោះអត្រាចុះបញ្ជីរបស់សហគ្រាសធុនធំវិញ តួលេខបានកើនឡើងបន្តិចពី ៩៦% នៅឆ្នាំ២០១៦ ដល់ ៩៨% នៅឆ្នាំ២០១៧ ហើយ

នៅរក្សាលំនឹងដដែល នៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលទាបជាងអត្រាគោលដៅបន្តិច (១០០%) នៅឆ្នាំ ២០២០ និងនៅឆ្នាំ២០២៥។

រូបភាពទី១.៤១៖ អត្រាសហគ្រាសធុនតូច ធុនមធ្យម និងធុនធំដែលមានតារាងតុល្យការ ឬកាន់បញ្ជីគណនេយ្យសាមញ្ញ










ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រូបភាពទី១.៤១ បង្ហាញអំពីអត្រាសហគ្រាសធុនតូច ធុនមធ្យម និងធុនធំ ដែលមានតារាងតុល្យការ ឬកាន់បញ្ជីគណនេយ្យសាមញ្ញ។ អត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យសាមញ្ញ បានកើនពី ១៣% ក្នុងឆ្នាំ២០១៦ ដល់ត្រឹម ១៨,៥៣% ក្នុងឆ្នាំ២០២០ ដែលទាបជាងអត្រាគោលដៅឆ្នាំ២០២០

(៣០%)។ គួររំឭកផងដែរថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ឱ្យអនុវត្តនូវបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូចចាប់តាំងពីឆ្នាំ២០១៦មក ដោយពុំតម្រូវឱ្យអ្នកជាប់ពន្ធតូចមានតារាងតុល្យការនោះទេ។ ដោយឡែក អត្រាសហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ បានកើនពី ៣៤,៨៤% ក្នុងឆ្នាំ២០១៦ ដល់ត្រឹម ៣៨,៦៩% ក្នុងឆ្នាំ២០២០ ដែលទាបជាងអត្រាគោលដៅឆ្នាំ២០២០ (៥០%)។ ចំណែកឯអត្រាសហគ្រាសធុនធំដែលមានតារាងតុល្យការវិញ បានកើនពី ៧៨% ក្នុងឆ្នាំ២០១៦ ដល់ត្រឹម ៨០% ក្នុងឆ្នាំ២០២០ ដែលទាបជាងអត្រាគោលដៅឆ្នាំ២០២០ (១០០%)។

ជារួម ផ្អែកតាមទិន្នន័យទាំងអស់ខាងលើ បង្ហាញថាសហគ្រាសធុនតូចជាច្រើននៅតែមានការស្ទាក់ស្ទើរក្នុងការអភិវឌ្ឍអាជីវកម្មរបស់ខ្លួនទៅក្នុងសេដ្ឋកិច្ចផ្លូវការ បើទោះបីជារាជរដ្ឋាភិបាលបានខិតខំកែទម្រង់ប្រព័ន្ធបញ្ជីគណនេយ្យឱ្យកាន់តែសាមញ្ញសម្រាប់អាជីវកម្មខ្នាតតូចកាលពីចុងឆ្នាំ២០១៥ហើយក៏ដោយ។ យ៉ាងណាក្ដី យើងក៏សង្កេតឃើញថាគោលនយោបាយ IDP សម្រេចបានវឌ្ឍនភាពជាវិជ្ជមានក្នុងការជំរុញការចុះបញ្ជីផ្លូវការនៃសហគ្រាសធុនមធ្យម ប៉ុន្តែពុំទាន់ទទួលបានលទ្ធផលល្អក្នុងការជំរុញសហគ្រាសធុនតូចឱ្យចុះបញ្ជីជាផ្លូវការនៅឡើយ។

### ៣.៩.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

ការវាយតម្លៃលើវិធានការទាំង៩ ដែលគាំទ្រដល់ការអនុវត្តអន្តរាគមន៍គោលនយោបាយនេះ បង្ហាញថាគោលនយោបាយ IDP ផ្ដោតសំខាន់លើការពង្រឹងសមត្ថភាពរបស់សហគ្រាសធុនតូច និងមធ្យម ដែលជាការងារចម្បងមួយក្នុងការធ្វើទំនើបកម្មសហគ្រាស។ វិធានការទាំង៩ ត្រូវបានបែងចែកជា ៣ចង្កោមវិធានការគោលនយោបាយរួមមាន (១) ការពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យម (មាន ៦វិធានការ), (២) ការធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមមានលក្ខណៈផ្លូវការនៅទូទាំងប្រទេស (មាន ២វិធានការ), និង (៣) ការធ្វើឱ្យសេវាសាធារណៈពាក់ព័ន្ធនានាប្រសើរឡើង (មាន ១វិធានការ)។

រូបភាពទី១.៤២៖ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម"



ចង្កោមវិធានការគោលនយោបាយទី១ ផ្តោតលើការពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យម លើការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តសវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យប្រកបដោយស្តង់ដារ តាមរយៈការបណ្តុះបណ្តាលសហគ្រាសធុនតូច និងមធ្យម ការបោះពុម្ពផ្សាយឱ្យបានទូលំទូលាយ ការធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ រួមទាំងការបង្កើតមូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍និងការជំរុញការបង្កើតសមាគមន៍តាមអនុវិស័យនីមួយៗ។

ចង្កោមវិធានការគោលនយោបាយទី២ ផ្តោតសំខាន់លើការធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមមានលក្ខណៈផ្លូវការនៅទូទាំងប្រទេសតាមរយៈការពង្រឹងក្របខណ្ឌ និងយន្តការនៃការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដោយការលើកទឹកចិត្តសហគ្រាសទាំងនោះឱ្យកាន់បញ្ជីការគណនេយ្យបានត្រឹមត្រូវ និងចុះបញ្ជីជាអ្នកបង់ពន្ធតាមរបបពិត ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដូចជាការលើកទឹកចិត្តនិងការគាំទ្រនានាពីរដ្ឋាភិបាល។ ចង្កោមវិធានការគោលនយោបាយទី៣ ផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈពាក់ព័ន្ធនានាដូចជាការពង្រឹងយន្តការសេវាក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម។ លទ្ធផលនៃការវិភាគបង្ហាញថា ការបង្កើនសមត្ថភាពរបស់សហគ្រាសធុនតូចនិងមធ្យម គឺជាការងារអាទិភាពដែលគោលនយោបាយ IDP រំពឹងថានឹងសម្រេចបាននូវការធ្វើទំនើបកម្ម។

ផ្អែកលើវិសាលភាពនិងការរៀបចំវិធានការគោលនយោបាយ បង្ហាញថា វិធានការគោលនយោបាយចំនួន ៤ ក្នុងចំណោមវិធានការគោលនយោបាយទាំង៩ គឺមានលក្ខណៈគ្រប់គ្រាន់ និងលេចធ្លោដើម្បីរួមចំណែកក្នុងការសម្រេចបាននូវបច្ច័យរំពឹងទុកនៃការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។ វិធានការគោលនយោបាយទាំង៤ នេះ រួមមាន៖ "ការធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ..." "ការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃប្រព័ន្ធកាន់បញ្ជីការគណនេយ្យថ្មីដែលបានធ្វើសាមញ្ញកម្ម...","ការផ្តល់ការបណ្តុះបណ្តាលផ្នែកគណនេយ្យដល់សហគ្រាសធុនតូច និងមធ្យម..." "ការជំរុញការបង្កើតសមាគមន៍តាមអនុវិស័យ..."។ តាមរយៈលទ្ធផលនៃការវិភាគនេះ ពុំអាចធ្វើការសន្និដ្ឋានបានទេថា នៅពេលវិធានការគោលនយោបាយទាំង៤ ត្រូវបានអនុវត្ត នោះនឹងនាំឱ្យកើតរចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យមឡើយ។ ការរួមចំណែកនៃបច្ច័យរបស់វិធានការគោលនយោបាយផ្សេងទៀត មានភាពចាំបាច់ចំពោះការអនុវត្តអន្តរាគមន៍គោលនយោបាយនេះ ល្គឹកណាវិធានការគោនយោបាយបន្ទាប់បន្សំទាំងនោះពុំមានភាពស្ទួនគ្នានឹងវិធានការគោលនយោបាយនេះ។

### ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

ក្នុងចំណោមវិធានការគោលនយោបាយទាំងអស់ដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះ វិធានការគោលនយោបាយមួយចំនួនមានលក្ខណៈបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ តួយ៉ាង ក្នុងចំណោមវិធានការគោលនយោបាយចំនួន ៤ មានវិធានការគោលនយោបាយចំនួន ៣ ដែលផ្តោតលើការពង្រឹងសមត្ថភាពនៃចង្កោមសហគ្រាសធុនតូច និងមធ្យម និងវិធានការមួយទៀតផ្តោតលើការធ្វើឱ្យចង្កោមសហគ្រាសធុនតូច និងមធ្យមមានលក្ខណៈផ្លូវការនៅទូទាំងប្រទេស។ វិធានការគោលនយោបាយទី ១ ទាក់ទងទៅនឹង "ការលើកទឹកចិត្ត

ដល់សហគ្រាសធុនតូច និងមធ្យមឱ្យកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ និងធ្វើការបង់ពន្ធតាមរបបពិត" មិនអាចសម្រេចបានតាមការរំពឹងទុកឡើយ ប្រសិនណាបើ សហគ្រាសធុនតូច និងមធ្យមមិនមានចំណេះដឹងគ្រប់គ្រាន់ពាក់ព័ន្ធនឹងការបង្កើតបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវដើម្បីរក្សាកំណត់ត្រាគណនេយ្យ និងអនុលោមភាពលើនីតិវិធីនៃការចុះបញ្ជីដើម្បីធ្វើការបង់ពន្ធតាមរបបពិត។ អាស្រ័យហេតុនេះ វិធានការគោលនយោបាយទី២ ទាក់ទងនឹង "ការផ្ដល់ការបណ្ដុះបណ្ដាលលើការកាន់បញ្ជិកាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម" ដើរតួនាទីក្នុងការបំពេញបន្ថែមដើម្បីជួយដល់សហគ្រាសធុនតូច និងមធ្យមតាមរយៈការបណ្ដុះបណ្ដាលដើម្បីឱ្យសហគ្រាសប្រើប្រាស់ប្រព័ន្ធបញ្ជិកាគណនេយ្យ ព្រមទាំងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការកាន់កាប់បញ្ជិកាគណនេយ្យ និងតារាងតុល្យការឱ្យបានត្រឹមត្រូវ។

ដើម្បីធានាបានថាសហគ្រាសធុនតូច និងមធ្យមនឹងមានឆន្ទៈក្នុងការរៀនសូត្រនិងប្រើប្រាស់នូវប្រព័ន្ធបញ្ជិកាគណនេយ្យផ្លូវការនិងត្រឹមត្រូវ ទាមទារឱ្យមានវិធានការគោលនយោបាយទី៣ និងទី៤ បន្ថែមទៀតទាក់ទងនឹង "ការធ្វើវិសោធនកម្មកែលម្អច្បាប់ស្ដីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដោយរៀបចំស្ដង់ដារគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម" និង "ការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃប្រព័ន្ធបញ្ជិកាគណនេយ្យសាមញ្ញថ្មីសម្រាប់សហគ្រាសធុនតូច និងមធ្យម"។ វិធានការគោលនយោបាយទាំង២ នេះនឹងជួយលើកកម្ពស់ការយល់ដឹងរបស់សហគ្រាសធុនតូច និងមធ្យមពីអត្ថប្រយោជន៍ក្នុងរយៈពេលវែង នៃការបញ្ឈប់ការប្រើប្រាស់ប្រព័ន្ធបញ្ជិកាគណនេយ្យតាមបែបប្រពៃណី ហើយងាកមកប្រើប្រាស់ប្រព័ន្ធបញ្ជីការគណនេយ្យថ្មីដែលសហគ្រាសនឹងទទួលបានពីរាជរដ្ឋាភិបាល ជាហេតុដែលអាចនាំឱ្យសហគ្រាសធុនតូចនិងមធ្យមអាចអភិវឌ្ឍនិងធ្វើទំនើបកម្មបាន។

ក្រៅពីបច្ច័យបំពេញគ្នាទាំងនេះ គ្មានវិធានការគោលនយោបាយណាដែលប្រទាំងគ្នាត្រូវបានកត់សម្គាល់ក្នុងអន្តរាគមន៍គោលនយោបាយនេះទេ។

### ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពភាពនៃវិធានការគោលនយោបាយ

ចំពោះប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការរៀបចំគោលនយោបាយ ពុំមានករណីស្មុគស្មាញក្នុងចំណោមវិធានការគោលនយោបាយទាំងនេះឡើយ។ ទោះយ៉ាងណាក៏ដោយ ខណៈវិធានការគោលនយោបាយភាគច្រើនដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះ បានគិតគូរជាពិសេសលើការដោះស្រាយបញ្ហាជាច្រើនដែលរាំងខ្ទប់ដល់ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យមតាមរយៈការពង្រឹងសមត្ថភាព និងធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមមានលក្ខណៈផ្លូវការ, គោលនយោបាយ IDP អាចពិចារណាផងដែរលើការផ្ដល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមដើម្បីជំរុញការចុះបញ្ជីផ្លូវការ។ លើសពីនេះ ការបង្កើតទីភ្នាក់ងារឯកទេសសម្រាប់គាំទ្រសហគ្រាសធុនតូច និងមធ្យមក៏នឹងនាំមកនូវអត្ថប្រយោជន៍យ៉ាងធំធេងក្នុងការធ្វើទំនើបកម្មផងដែរ។ ក្រៅពីទទួលបានការលើកទឹកចិត្ត សហគ្រាសធុនតូច និងមធ្យមក៏អាចនឹងទទួលបានជំនួយផ្សេងទៀតដូចជាការគាំទ្រនិងជំនួយបច្ចេកទេសសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវកម្រិតបច្ចេកវិទ្យាឬការទទួលយកបច្ចេកវិទ្យា

ក៏ដូចជាស្តង់ដារនៃយកម្មសហគ្រាសដូចករណី Spring Singapore ដែលដើរតួនាទីជាភ្នាក់ងារសម្រាប់អភិវឌ្ឍសហគ្រាស និងជួយសហគ្រាសបង្កើនភាពប្រកួតប្រជែងក្នុងទីផ្សារ។

### ៣.៩.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះមានវិធានការគោលនយោបាយចំនួន៩ ដែលក្នុងនោះមានវិធានការចំនួន ២ ត្រូវបានសម្រេចពេញលេញ, វិធានការ ចំនួន១ កំពុងអនុវត្ត និងវិធានការ ចំនួន៦ មានភាពយឺតយ៉ាវ។

វិធានការគោលនយោបាយដែលសម្រេចបានពេញលេញទាំង ២ ពាក់ព័ន្ធនឹងការជំរុញការប្រើប្រាស់បញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ព្រមទាំងការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីអត្ថប្រយោជន៍នៃការកាន់បញ្ជីគណនេយ្យសាមញ្ញ។ ដើម្បីធ្វើឱ្យស្តង់ដារថ្មីនៃបញ្ជីគណនេយ្យកាន់តែមានភាពងាយស្រួលនិងទាក់ទាញសម្រាប់សហគ្រាសធុនតូច និងមធ្យម ក្រុមប្រឹក្សាជាតិគណនេយ្យ បានបង្កើតនូវបទដ្ឋានគតិយុត្តិ និងសេចក្តីជូនដំណឹងជាបន្តបន្ទាប់។ ក្នុងរយៈកាល ៥ឆ្នាំ (២០១៦-២០២០) កន្លងមកនេះ មានអនុក្រឹត្យចំនួន៣ សេចក្តីជូនដំណឹងចំនួន៩ និងសារាចរណែនាំចំនួន៣ ត្រូវបានដាក់ចេញ និងប្រកាសផ្សព្វផ្សាយ។ ប្រព័ន្ធគណនេយ្យសាមញ្ញត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយចំនួន ៤លើក ជូនដល់ ២០០សហគ្រាស ក្នុងមួយឆ្នាំ។ ប៉ុន្តែ ពុំមានទិន្នន័យលើអត្រាកំណើននៃសហគ្រាសធុនតូច និងមធ្យមចុះបញ្ជី ដែលប្រើប្រាស់ប្រព័ន្ធគណនេយ្យសាមញ្ញឡើយ។

រូបភាពទី១.៤៣៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម"






វិធានការកំពុងអនុវត្ត ចំនួន ១ បាននិងកំពុងប្រឈមនឹងកង្វះកិច្ចសហប្រតិបត្តិការពីក្រសួងពាក់ព័ន្ធក្នុងការធ្វើសមាហរណកម្មប្រព័ន្ធចុះបញ្ជីសហគ្រាសធុនតូច និងមធ្យមក្រោមយន្តការច្រកចេញចូលតែមួយ។ យ៉ាងណាមិញ ជាដំណោះស្រាយ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតថ្នាលចុះបញ្ជីតាមប្រព័ន្ធអនឡាញមួយ ឈ្មោះថា CamDx ដែលអនុញ្ញាតឱ្យសហគ្រាសនានាអាចធ្វើការចុះបញ្ជី ឬទទួលបានសេវារដ្ឋបាលផ្សេងៗពីក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈប្រព័ន្ធអនឡាញ។

បញ្ហាប្រឈមចំនួន ៣ ដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្តវិធានការ ចំនួន ៤ រួមមាន៖ ១) កង្វះធនធានមនុស្សនិងហិរញ្ញវត្ថុ, ២) តម្រូវការពេលវេលាបន្ថែមដើម្បីសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅនិងបង្កើនការយល់ដឹងរបស់វិស័យឯកជន, និង ៣) ការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត ក៏បានផ្តល់ជាធាតុចូលសម្រាប់ដោះស្រាយនូវបញ្ហាប្រឈមខាងលើផងដែរ រួមមាន៖ ១) កែសម្រួលផែនការសកម្មភាពដើម្បីសម្របខ្លួនទៅនឹងបរិបទថ្មី និងជ្រើសរើសមន្ត្រីបន្ថែម រួមទាំងពង្រឹងសមត្ថភាពមន្ត្រីដែលមានស្រាប់, ២) ពន្លឿនការបិទបញ្ចប់ការស្រាវជ្រាវ និង ៣) ពន្លឿនការពិនិត្យនិងរៀបចំកិច្ចប្រជុំអន្តរក្រសួង។

ការអនុវត្តវិធានការដែលគាំទ្រដល់អន្តរាគមន៍គោលនយោបាយនេះ មានភាពយឺតយ៉ាវភាគច្រើន។ ម្យ៉ាងវិញទៀត បើទោះបីជាវិធានការទាំងអស់ក្នុងអន្តរាគមន៍គោលនយោបាយនេះត្រូវបានសម្រេចពេញលេញ ក៏ដោយ នឹងពុំមានបច្ច័យជាដុំកំភួនដល់ការបង្កើនការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យមឡើយដោយសារវិធានការគោលដែលបានដាក់ចេញ គឺពុំគ្រប់គ្រាន់ ដើម្បីលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមឱ្យចុះបញ្ជីជាផ្លូវការនោះទេ។ ដូច្នេះ នៅមានការងារជាច្រើនទៀតដែលត្រូវបំពេញដើម្បីដោះស្រាយបញ្ហាប្រឈម

នានាដែលលេចឡើង ដោយហេតុថា ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម គឺជាកត្តាស្នូលសម្រាប់ការបង្កើនភាពធន់នៃសេដ្ឋកិច្ចជាតិ។

គួរកត់សម្គាល់ផងដែរថា ការអនុវត្តវិធានការទាំងនេះ បានបំពេញបន្ថែមទៅនឹងការអនុវត្តវិធានការគាំទ្រអន្តរាគមន៍គោលនយោបាយ៣.៣ ស្តីពី "ការធ្វើឱ្យមានតុល្យភាពឡើងវិញរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម"។

# ៨. ការរួមចំណែករបស់អន្តរាគមន៍គោលនយោបាយចម្បងក្នុងគោលបំណងទី៨ "ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ"

## ៨.១. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញនិងធនធានមនុស្ស"

### ៨.១.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៤៤៖ ចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សានិងឧត្តមសិក្សា ក្នុងចំនួនប្រជាជនគ្រប់អាយុចូលរៀន




ប្រភពទិន្នន័យ៖ ក្រសួងអប់រំ យុវជន និងកីឡា

រូបភាពទី១.៤៤ បង្ហាញពីចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សានិងឧត្តមសិក្សាក្នុងចំនួនប្រជាជនគ្រប់អាយុចូលរៀន ចាប់ពីឆ្នាំសិក្សា២០០៧-២០០៨ ដល់ឆ្នាំសិក្សា២០១៨-២០១៩។ ប្រជាជនគ្រប់អាយុចូលរៀននៅទីនេះ សំដៅដល់ប្រជាជនដែលមានអាយុពី១២ឆ្នាំ ដល់ ២៦ឆ្នាំ ខណៈដែលការចុះឈ្មោះចូលរៀននៅមធ្យមសិក្សានិងឧត្តមសិក្សា រាប់បញ្ចូលតែប្រជាជនដែលបានចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សា និងសាកលវិទ្យាល័យ ដែលជាទូទៅមានអាយុចន្លោះពី១២ឆ្នាំដល់២៦ឆ្នាំ។ សូចនាករនេះ ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងកម្រិតជំនាញ និងការអប់រំរបស់កម្លាំងពលកម្ម ដែលនឹងឈានចូលក្នុងទីផ្សារការងារ នាពេលអនាគត។ តួលេខសូចនាករនេះហាក់នៅនឹងថ្កល់ក្នុងរង្វង់ ២០% ទៅ ២២% ចាប់តាំងពីឆ្នាំសិក្សា២០០៧-២០០៨ ទោះបីជាបានកើនឡើងបន្តិចប្រមាណ ០,៧% ក្នុងមួយឆ្នាំក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP (២០១៥-២០១៩)។ ទន្ទឹមនឹងនេះ បើពិនិត្យលើទិន្នន័យលម្អិត យើងសង្កេតឃើញថា អត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សា (៤១,៩% នៅឆ្នាំសិក្សា២០១៨-២០១៩) មានវឌ្ឍនភាពប្រសើរជាងអត្រាចុះឈ្មោះចូលរៀននៅឧត្តមសិក្សា (៧,៦% នៅឆ្នាំសិក្សា២០១៨-២០១៩) ទាំងបរិមាណនិងអត្រាកំណើន។

រូបភាពទី១.៤៥៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និងអត្រានិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)



ប្រភពទិន្នន័យ៖ ក្រសួងអប់រំ យុវជន និងកីឡា

រូបភាពទី១.៤៥ បង្ហាញពីអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ចាប់ពីឆ្នាំសិក្សា ២០១១-២០១២ ដល់ឆ្នាំសិក្សា ២០១៩-២០២០ និងអត្រានិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា (STEM) ចាប់ពីឆ្នាំសិក្សា២០១២-២០១៣ ដល់ឆ្នាំសិក្សា២០១៨-២០១៩។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ គឺជាផលធៀបរវាងចំនួនសិស្សថ្មី (មិនរាប់សិស្សរៀនត្រួតថ្នាក់) រៀនថ្នាក់ទី១២ នៅឆ្នាំសិក្សា (T) និងចំនួនប្រជាជនសរុបដែលមានអាយុ ១៧ឆ្នាំនៅឆ្នាំសិក្សា (T)។ អត្រានិស្សិតបញ្ចប់ការសិក្សាផ្នែក STEM គឺជាផលធៀបរវាងចំនួននិស្សិតបញ្ចប់ការសិក្សាផ្នែក STEM និងចំនួននិស្សិតសរុបបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា។

អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិបានកើនឡើងពី ១៩,៤% នៅឆ្នាំសិក្សា២០១៥-២០១៦ ទៅ ២៤,២៥% នៅឆ្នាំសិក្សា២០១៩-២០២០ តាមអត្រាកំណើន ១,២% ក្នុងមួយឆ្នាំ ដែលជាអត្រាកំណើនវិជ្ជមាន បើធៀបនឹងរយៈពេលមុនការដាក់ចេញគោលនយោបាយ IDP (-២,១% ក្នុងមួយឆ្នាំ)។ ជាមួយគ្នានេះដែរ អត្រានិស្សិតបញ្ចប់ការសិក្សាផ្នែក STEM បានកើនឡើងពី ១៧,៣%នៅឆ្នាំសិក្សា២០១៥-២០១៦ ទៅ ២៣,៥% នៅឆ្នាំសិក្សា២០១៨-២០១៩ តាមអត្រាកំណើន ២%ក្នុងមួយឆ្នាំ ដែលជាអត្រាកំណើនវិជ្ជមាន បើធៀបនឹងរយៈពេលមុនការដាក់ចេញ IDP (-0,៤%ក្នុងមួយឆ្នាំ)។

សរុបមក សូចនាករពាក់ព័ន្ធនឹងការអប់រំចំណេះទូទៅ ហាក់ដូចជាមិនសូវមានវឌ្ឍនភាពលេចធ្លោគួរឱ្យកត់សម្គាល់នោះទេ ដែលអាចបង្ហាញពីឧបសគ្គក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារក្នុងរយៈពេលវែង។ សិស្ស និស្សិតដែលកំពុងទទួលការអប់រំនាពេលបច្ចុប្បន្ននឹងចូលបម្រើទីផ្សារការងារក្នុងរយៈពេល៥ឆ្នាំខាងមុខ។ ដូច្នេះ ដោយសារការចុះឈ្មោះចូលរៀនស្ថិតក្នុងអត្រាមួយទាបនៅឡើយនាពេលបច្ចុប្បន្ន កម្រិតអប់រំអាចនឹងនៅទ្រឹងរហូតដល់ចប់អាណត្តិនៃការអនុវត្ត IDP នៅឆ្នាំ២០២៥។ ជាការសន្និដ្ឋានរួម គោលនយោបាយ IDP បានរួមចំណែកតិចតួចប៉ុណ្ណោះក្នុងការបង្កើនការផ្គត់ផ្គង់កម្លាំងពលកម្មដែលទទួលបានការអប់រំ ជាពិសេសកម្លាំងពលកម្មវ័យក្មេងដែលមានជំនាញទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

រូបភាពទី១.៤៦៖ ស្ថានភាពនៃកម្លាំងពលកម្មវ័យក្មេងដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

រូបភាពទី១.៤៦ បង្ហាញពីចំនួនកម្លាំងពលកម្មវ័យក្មេងដែលទទួលបានការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជំនាញបច្ចេកទេស ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ សម្រាប់វាស់វែងចំនួនអ្នកបច្ចេកទេសចូលបម្រើដល់ទីផ្សារការងារ។ ចំនួនសិស្សបញ្ចប់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ ឬ ៣ (C1, C2 ឬ C3) នៅឆ្នាំ២០១៥ មានចំនួន ២.៣៩៦នាក់ កើនឡើងជិតទ្វេដងបើធៀបនឹងតួលេខដូចគ្នានៅឆ្នាំ២០០៨ ហើយបានបន្តកើនឡើងខ្លាំងទៅដល់ ចំនួន ៦.៣៩៨នាក់ នៅឆ្នាំ២០១៩។ កំណើនប្រចាំឆ្នាំនៃតួលេខនេះក្នុងរយៈពេលនៃការអនុវត្តគោលនយោបាយ IDP (២៧,៨%) កើនលឿនជាងមុនពេលដាក់ចេញគោលនយោបាយ IDP (១២%) ទៅទៀត។ ជាមួយគ្នានេះ ចំនួននិស្សិតបញ្ចប់ការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស/បរិញ្ញាបត្ររងបានកើនឡើងខ្លាំងពីប្រមាណ ២.៦០០នាក់ នៅឆ្នាំ២០១៥ ដល់ប្រមាណជិត ៥.៩០០នាក់ នៅឆ្នាំ២០១៩ តាមអត្រាកំណើនប្រចាំឆ្នាំ ២៣,១% ដែលជាកំណើនលឿនខ្លាំងបើធៀបនឹងអត្រាកំណើនមុនការដាក់ចេញគោលនយោបាយ IDP (១,៩%)។

ក្នុងរយៈពេលខ្លី កំណើនយ៉ាងឆាប់រហ័សនៃចំនួននិស្សិតបញ្ចប់ការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ នឹងបង្កភាពងាយស្រួលដល់សហគ្រាសឧស្សាហកម្ម ក្នុងការជ្រើសរើសអ្នកបច្ចេកទេសដែលមានសមត្ថភាព

ដើម្បីគាំទ្រដល់ការពង្រីកប្រតិបត្តិការរបស់សហគ្រាស។ ជារួម គោលនយោបាយ IDP ពិតជាបានរួមចំណែកជាវិជ្ជមានក្នុងការបង្កើនការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញ និងអ្នកបច្ចេកទេស ទៅក្នុងទីផ្សារការងារ។

### ៨.១.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការសរុបចំនួន ១៦ ដែលអាចចែកចេញជា ២ ចង្កោមៈ (១) វិធានការដែលសំដៅពង្រឹងជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) (វិធានការចំនួន ១១) និង (២) វិធានការដែលសំដៅពង្រឹងគុណភាព និងលទ្ធភាពទទួលបានការអប់រំ (វិធានការចំនួន ៥)។

រូបភាពទី១.៤៧៖ ចង្កោមទាំងពីរនៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស"




ការវាយតម្លៃបែបគុណវិស័យលើវិធានការទាំង១៦ ដែលនៅក្រោមអន្តរាគមន៍គោលនយោបាយនេះ បង្ហាញថាការពង្រឹងជំនាញបច្ចេកទេស និង STEM ក៏ដូចជាការពង្រឹងគុណភាព និងលទ្ធភាពទទួលបានការអប់រំ គឺជាការងារអាទិភាពសម្រាប់ការអនុវត្តគោលនយោបាយ IDP ដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះជំនាញ។

ចំពោះវិសាលភាព និងការរៀបចំគោលនយោបាយ យើងសង្កេតឃើញថាវិធានការគោលនយោបាយចំនួន ៧ ក្នុងចំណោមវិធានការគោលនយោបាយទាំង១៦ មានភាពលេចធ្លោដែលអាចនាំឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុកក្នុងការអភិវឌ្ឍជំនាញ និងធនធានមនុស្ស។ ក្នុងនោះ វិធានការចំនួន ៤ ដែលមានគោលបំណង "កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់...", "បង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេសឱ្យបានច្រើនជងជាងមុន...", "ពង្រឹងការអប់រំនៅសាកលវិទ្យាល័យលើកម្មវិធីសិក្សាទាក់ទងទៅនឹងវិទ្យាសាស្ត្រកសិកម្ម និងវិទ្យាសាស្ត្រមូលដ្ឋានសំខាន់ផ្សេងទៀត ..." និង "ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)..." នឹងផ្តល់បច្ច័យវិជ្ជមានចំពោះការពង្រឹងជំនាញ

បច្ចេកទេស និងចំណេះដឹងសម្រាប់កម្លាំងពលកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការពលកម្មជំនាញក្នុងវិស័យឧស្សាហកម្ម។ ទន្ទឹមនឹងនេះ វិធានការចំនួន៣ ផ្សេងទៀតរួមមាន "...បង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន...", "ពង្រីកការបណ្តុះបណ្តាលជំនាញនៅនឹងកន្លែង ដោយផ្តោតការយកចិត្តទុកដាក់លើកម្មកររោងចក្រ..." និង "ជំរុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់ ៩ ឆ្នាំ..." គឺជាវិធានការសំខាន់ ដែលគាំទ្រដល់ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ ដែលជាផ្នែកសំខាន់មួយសម្រាប់ការអភិវឌ្ឍជំនាញ និងធនធានមនុស្ស។ ទោះយ៉ាងនេះក្តី របកគំហើញនៃការវិភាគនេះមិនសន្និដ្ឋានថា សេណារីយ៉ូជោគជ័យនៃការអភិវឌ្ឍជំនាញ និងធនធានមនុស្ស អាចសម្រេចបាន ដោយការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការចំនួន៧តែប៉ុណ្ណោះទេ។ ការរួមចំណែកនៃវិធានការដទៃទៀតនៅតែសំខាន់សម្រាប់អន្តរាគមន៍គោលនយោបាយនេះ ដរាបណាវិធានការទាំងនោះមិនស្ទួនគ្នា។

## ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

វិធានការគោលនយោបាយមួយចំនួនមានភាពបំពេញបន្ថែមឱ្យគ្នា។ ជាក់ស្តែង ភាពស៊ីចង្វាក់គ្នានៃវិធានការត្រូវបានរកឃើញក្នុងវិធានការ ចំនួន ២ ដែលមានគោលបំណងបង្កើនកម្លាំងពលកម្មមានជំនាញទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ វិធានការទី ១ ផ្តោតលើការ "ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ពីកម្រិតបឋមសិក្សារហូតដល់ក្រោយមធ្យមសិក្សា ពិសេសផ្តោតលើសិស្សក្មេងៗ ជាមួយនឹងការកែទម្រង់កម្មវិធីសិក្សា ដោយការធ្វើស្តង់ដារនីយកម្មនៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ"។ វិធានការនេះតែមួយ មិនអាចធានាបាននូវការបង្កើតកម្លាំងពលកម្មដែលមានសមត្ថភាពខ្ពស់ ជាមួយនឹងជំនាញទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានោះទេ។ ក្នុងន័យនេះ វិធានការទី២ ដែលផ្តោតលើ "ការពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា ដោយផ្តោតលើការពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជនលើផ្នែកគណិតវិទ្យា, វិទ្យាសាស្ត្រ, អក្សរសាស្ត្រ និងបច្ចេកវិទ្យា" ហាក់បំពេញបន្ថែមឱ្យវិធានការទី១ ដើម្បីបង្កើតកម្លាំងពលកម្មដែលមានសមត្ថភាពខ្ពស់ ជាមួយនឹងជំនាញទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ វិធានការទាំងពីរនេះមានភាពបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ព្រោះបើគុណភាពអប់រំមិនល្អនោះ សិស្សានុសិស្សនឹងមិនអាចទទួលបានយ៉ាងពេញលេញនូវចំណេះដឹង និងជំនាញដែលពួកគេបានសិក្សានោះឡើយ។

ករណីមួយទៀតនៃភាពស៊ីចង្វាក់គ្នារវាងវិធានការគោលនយោបាយ ត្រូវបានគេសង្កេតឃើញរវាងវិធានការចំនួន ៣ ផ្សេងទៀតដែលមានគោលបំណងបង្កើនជំនាញបច្ចេកទេសដែលចាំបាច់ ដើម្បីបង្កើតមូលដ្ឋាននៃការអភិវឌ្ឍឧស្សាហកម្ម។ វិធានការទី១ ផ្តោតលើ "បង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេសឱ្យបានច្រើនជាងមុន តាមលទ្ធភាពលើជំនាញបច្ចេកទេស ជាពិសេសនៅក្នុងផ្នែកអគ្គិសនី, អេឡិចត្រូនិក, មេកានិច, ស្តង់ដារ, មាត្រាសាស្ត្រ..."។ វិធានការទី២ ផ្តោតលើ "កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ (soft skills) រួមមានជំនាញទំនាក់ទំនងសង្គមក្នុងការដោះស្រាយបញ្ហា, ការគោរពវិន័យនៅកន្លែងធ្វើការ និងជំនាញចាំបាច់ផ្សេងទៀត..."។ វិធានការទី៣ ផ្តោតលើ "...បង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន..."។ ដើម្បីបង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេស គឺមានភាពចាំបាច់ក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សាដែលផ្តោតលើការពង្រឹងជំនាញសំខាន់ៗ។ ទោះយ៉ាងណាក៏ដោយ គោលដៅក្នុងការបង្កើនការ

បណ្តុះបណ្តាល ជំនាញបច្ចេកទេសនឹងមិនអាចសម្រេចបានទេ ប្រសិនបើគ្មានការបង្កើតសាលាបច្ចេកទេស។ ក្នុងន័យនេះ វិធានការទាំង៣នេះ មានភាពបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកក្នុងគោលបំណងបង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដែលចាំបាច់ដើម្បីបង្កើតមូលដ្ឋាននៃការអភិវឌ្ឍឧស្សាហកម្ម។

ក្រៅពីបច្ច័យបំពេញបន្ថែមទាំងនេះ គ្មានវិធានការណាមួយដែលមានខ្លឹមសារផ្ទុយគ្នានោះទេ សម្រាប់អន្តរាគមន៍គោលនយោបាយនេះ។

**ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ**

ចំពោះប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការរៀបចំគោលនយោបាយ ពុំមានករណីស្ទួនគ្នានៃវិធានការទាំង ១៦ ក្រោមអន្តរាគមន៍គោលនយោបាយនេះទេ។ ប៉ុន្តែ ការរៀបចំវិធានការសម្រាប់អន្តរាគមន៍គោលនយោបាយនេះ ហាក់នៅមានភាពខ្វះចន្លោះ។ យោងតាមទិន្នន័យការស្ទង់មតិនិយោជកឆ្នាំ ២០១៨ នៃទីភ្នាក់ងារជាតិមុខរបរនិងការងារ, និយោជក ៤៧.៩% បានបញ្ជាក់ពីការលំបាកក្នុងការជ្រើសរើសបុគ្គលិក ដែលក្នុងនោះប្រមាណ ៥៣.១% បណ្តាលមកពីកង្វះបេក្ខជនមានជំនាញដែលត្រូវការ និងកង្វះបទពិសោធន៍ការងារ ឬគុណវុឌ្ឍិ។ ទន្ទឹមនឹងនេះ បើនិយាយអំពីជំនាញដែលនិយោជកស្វែងរក, ភាសាបរទេសគឺស្ថិតក្នុងចំណោមជំនាញផ្សេងទៀតដែលមានតម្រូវការខ្ពស់។ នេះបញ្ជាក់ថា បេក្ខជនគ្មានជំនាញដែលត្រូវការ រួមទាំងភាសាបរទេស នឹងពិបាកស្វែងរកការងារធ្វើ។ ខណៈវិធានការភាគច្រើនផ្តោតលើការពង្រឹងជំនាញបច្ចេកទេស, ស្រាវជ្រាវ និងអភិវឌ្ឍន៍, នវានុវត្តន៍, STEM និងជំនាញទន់ដទៃទៀត, គោលនយោបាយ IDP មិនបានដាក់ចេញនូវវិធានការសម្រាប់លើកកម្ពស់ការសិក្សាភាសាបរទេសនោះទេ។ ជំនាញភាសាបរទេសមានសារៈសំខាន់ណាស់សម្រាប់និយោជិត ជាពិសេសក្នុងបរិបទនៃសកលភាវូបនីយកម្ម ដែលសាជីវកម្មពហុជាតិកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការងារ។

**៨.១.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ**

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការសរុបចំនួន ១៥។ ទន្ទឹមនឹងនេះ ដោយសាភាពពាក់ព័ន្ធនៃវិធានការគោលនយោបាយ អនុវិធានការចំនួន១ ត្រូវបានបំបែកចេញពីវិធានការមួយ ក្នុងចំណោមវិធានការជាក់ស្តែងគន្លឹះ៤ ដែលផ្តោតលើការគ្រប់គ្រងទីផ្សារការងារ ហើយត្រូវបានបន្ថែមទៅក្នុងអន្តរាគមន៍គោលនយោបាយនេះ។ ដូច្នេះ ជាលទ្ធផល អន្តរាគមន៍គោលនយោបាយនេះមានវិធានការ និងអនុវិធានការសរុបចំនួន ១៦។ វិធានការទាំង១៦នេះ ត្រូវបានសម្រេចពេញលេញ។

រូបភាពទី១.៤៨៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស"






វិធានការទាំងអស់ដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយនេះ ត្រូវបានសម្រេចពេញលេញដែលបង្ហាញពីសន្ទុះនៃការអភិវឌ្ឍជំនាញ និងធនធានមនុស្ស។ ជាក់ស្តែង គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានបង្កើតកាន់តែច្រើន ហើយជំនាញជាច្រើនទៀតកំពុងត្រូវបានរៀបចំសម្រាប់ប្រជាជនកម្ពុជាដើម្បីឈានឆ្ពោះទៅមូលដ្ឋានការងារដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម។ រីឯចំនួនសិស្ស និស្សិតបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ ឬ ៣ (C1, C2 ឬ C3) និងសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស/បរិញ្ញាបត្ររង ក៏មានការកើនឡើង។ ដូចគ្នានេះដែរ អត្រានិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ក៏មានការកើនឡើងផងដែរ។ ចំណុចទាំងនេះបង្ហាញថាសិស្ស និស្សិតកម្ពុជាកាន់តែច្រើនចាប់អារម្មណ៍លើការបង្កើនជំនាញបច្ចេកទេស និងមុខវិជ្ជាផ្នែក STEM។ លើសពីនេះ ការបញ្ចូលកម្មវិធីប្រព័ន្ធកម្មសិក្សា (apprenticeship scheme) ទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងរោងចក្រ គឺជាវិធីសាស្ត្រដ៏សមស្របមួយសម្រាប់សិស្ស និស្សិត និងកម្មករនិយោជិត ដើម្បីទទួលបាននូវបទពិសោធន៍ជាក់ស្តែង។ ហើយកម្មវិធីប្រព័ន្ធកម្មសិក្សានេះ ក៏គួរតែត្រូវបានពង្រីកដល់សិស្សនៅសាលាអប់រំចំណេះទូទៅក៏ដូចជានិស្សិតនៅកម្រិតសាកលវិទ្យាល័យផងដែរ។

ទោះបីជាវិធានការទាំងអស់ដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយនេះ ត្រូវបានសម្រេចពេញលេញក៏ដោយ ក៏នៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ ដើម្បីពន្លឿនការពង្រឹងជំនាញ និងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

## ៨.២. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនតម្រូវការកម្លាំងពលកម្មជំនាញ”

### ៨.២.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៤៩៖ ចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញ (ឆ្នាំ២០១០-២០២០)




ប្រភពទិន្នន័យ៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សំគាល់៖ ចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញ គឺមិនរាប់បញ្ចូលដំណឹងជ្រើសរើសកម្លាំងពលកម្មសម្រាប់ប្រភេទមុខរបរដែលមិនទាមទារឱ្យមានជំនាញ-elementary occupations ដោយផ្អែកលើចំណាត់ថ្នាក់ ISCO របស់ ILO

រូបភាពទី១.៤៩ បង្ហាញពីចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញ ចាប់ពីឆ្នាំ២០១០ ដល់២០២០។ ព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញ មានចំនួនជាង ៣៥.០០០នាក់ នៅឆ្នាំ ២០១៥ ខ្ពស់ជាងតួលេខឆ្នាំ២០១០ ដល់ទៅ៣ដង។ ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP តួលេខនេះបានបន្តកើនឡើងដល់ជាង ១៦ម៉ឺននាក់ នៅឆ្នាំ២០២០ តាមអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ប្រមាណ ៣៥,៨% ដែលជាអត្រាកំណើនមួយលឿនជាងមុនពេលការដាក់ចេញ IDP (២២,៦%) ដែលការកើនឡើងនេះបណ្តាលមកពីការពង្រឹងនិងពង្រីកយន្តការប្រមូលនិងផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិក តាមរយៈ ការបង្កើតបន្ថែមមជ្ឈមណ្ឌលការងារនៅតាមបណ្តារាជធានីខេត្តនិងមជ្ឈមណ្ឌលការងារចល័ត ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងការរៀបចំវេទិកាការងារនានា។

រូបភាពទី១.៥០៖ ចំនួនកម្លាំងពលកម្មជំនាញ (២០០៨-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រូបភាពទី១.៥០ បង្ហាញពីចំនួនកម្លាំងពលកម្មជំនាញ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩។ ចំនួនកម្លាំងពលកម្មជំនាញបានកើនឡើងតិចតួចពី ៣.៣៣០នាក់ នៅឆ្នាំ២០០៨ ទៅ ៤.០៩៤នាក់ នៅឆ្នាំ២០១៥ តាមអត្រាកំណើន ជាមធ្យម ៣%ក្នុងមួយឆ្នាំ។ បន្ទាប់ពីការដាក់ចេញគោលនយោបាយ IDP តួលេខនេះបានកើនឡើងយ៉ាងឆាប់រហ័ស រហូតដល់ ១០.១៧៩នាក់ នៅឆ្នាំ២០១៩ តាមអត្រាកំណើនជាមធ្យម ២៥,៦% ក្នុងមួយឆ្នាំ លឿនជាងមុនពេលការដាក់ចេញគោលនយោបាយ IDP ដល់ទៅ ៨ដង។

សរុបមក តួលេខកម្លាំងពលកម្មទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ ហាក់ដូចជាមានវឌ្ឍនភាពល្អប្រសើរ ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP។

### ៤.២.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

លទ្ធផលនៃការវាយតម្លៃបែបគុណវិស័យ បានបង្ហាញថា ពុំមានវិធានការណាមួយក្នុងគោលនយោបាយ IDP ដែលបានចែងជាក់លាក់អំពីការបង្កើនតម្រូវការកម្លាំងពលកម្មជំនាញនោះទេ។ សម្រាប់ជំហានបន្ទាប់នៃការអនុវត្តគោលនយោបាយ IDP រាជរដ្ឋាភិបាលគួរតែដាក់ចេញនូវវិធានការថ្មីៗ ដើម្បីរួមចំណែកសម្រេចបាននូវលទ្ធផលរំពឹងទុកក្នុងអន្តរាគមន៍គោលនយោបាយមួយនេះ។

## ៨.៣. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ"

### ៨.៣.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៥១៖ ប្រាក់ឈ្នួលអប្បបរមា (ឆ្នាំ២០០៥-២០២០)




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

រូបភាពទី១.៥១ បង្ហាញពីប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងពីឆ្នាំ២០០៥ ដល់ឆ្នាំ២០២០។ មុនការដាក់ចេញគោលនយោបាយ IDP ប្រាក់ឈ្នួលអប្បបរមាក្នុងមួយខែ បានកើនឡើងពី ៤៥ដុល្លារអាមេរិក នៅឆ្នាំ២០០៥ ដល់ ១២៨ដុល្លារអាមេរិក នៅឆ្នាំ២០១៥ តាមអត្រាកំណើនជាមធ្យម ១១%ក្នុងមួយឆ្នាំ។ ក្រោយការដាក់ចេញគោលនយោបាយ IDP ប្រាក់ឈ្នួលអប្បបរមាបានបន្តដំឡើងជារៀងរាល់ឆ្នាំ ជាបន្តបន្ទាប់រហូតដល់ចំនួន ១៩០ដុល្លារអាមេរិក នៅឆ្នាំ២០២០ ដោយមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ៨,២% ដោយផ្អែកលើបម្រែបម្រួលលក្ខណៈវិនិច្ឆ័យផ្នែកសង្គម និងសេដ្ឋកិច្ច និងយន្តការត្រីភាគី។

រូបភាពទី១.៥២ បង្ហាញពីភាគរយនៃវិវាទការងារ (ធំៗ) ដែលបានដោះស្រាយពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩។ សូចនាករនេះត្រូវបានប្រើប្រាស់ដើម្បីវាស់វែងប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទការងារ។ ភាគរយនៃវិវាទការងារដែលបានដោះស្រាយ បានថយចុះជាបន្តបន្ទាប់ពី ៧៤,៦% នៅឆ្នាំ២០១៤ ដល់ ៥៦,៧%នៅឆ្នាំ២០១៧ ប៉ុន្តែបានកើនឡើងខ្ពស់វិញ នៅឆ្នាំ២០១៨ (៧៣,៧%) និងឆ្នាំ២០១៩ (៨១,៥%)។

រូបភាពទី១.៥២៖ ភាគរយនៃវិវាទការងារ (ធំៗ) ដែលបានដោះស្រាយ (ឆ្នាំ២០១៤-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លទ្ធផលតួលេខសូចនាករទាំងពីរនេះ អាចបញ្ជាក់បានថា រាជរដ្ឋាភិបាលបានបន្តរក្សាទំនាក់ទំនងវិជ្ជាជីវៈល្អ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយ IDP។ យន្តការត្រីភាគីក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗត្រូវបានពង្រឹង ដោយមុនឆ្នាំ២០១៩ តាមរយៈគណៈកម្មការប្រឹក្សាការងារ និងចាប់ពីឆ្នាំ២០១៩ តាមរយៈក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលទទួលបានលទ្ធផលនៃការដំឡើងប្រាក់ឈ្នួលអប្បបរមាប្រកបដោយសុខដុម ស្របតាមកាលវិភាគ ទទួលបានការគាំទ្រពីគ្រប់ភាគី និងជៀសបាននូវការតវ៉ាតាមផ្លូវសាធារណៈ។ យន្តការនេះ បាននិងកំពុងដំណើរការយ៉ាងរលូន ដោយប្រាក់ឈ្នួលអប្បបរមា បានកើនឡើងជាលំដាប់បន្តបន្ទាប់។ ចំពោះការដោះស្រាយវិវាទការងារ គោលនយោបាយ IDP ហាក់ដូចជាមិនសូវមានបច្ច័យលើបញ្ហានេះឡើយ។

### ៨.៣.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការចំនួន ៦ ដូចមានបង្ហាញក្នុងរូបភាពខាងក្រោម។ វិធានការទាំងនេះ អាចត្រូវបានបែងចែកជា ៣ ចង្កោម រួមមាន ៖ ១) ការពង្រឹងទីផ្សារពលកម្ម, ការបណ្តុះបណ្តាលជំនាញ និងយន្តការត្រីភាគី (២ វិធានការ), ២) ការត្រួតពិនិត្យ និងបង្កើតក្របខណ្ឌគតិយុត្តស្តីពីការងារ និងមុខរបរ (៣ វិធានការ) និងដំណោះស្រាយបញ្ហាវិវាទការងារក្នុងវិស័យឧស្សាហកម្ម (១ វិធានការ)។

ចង្កោមវិធានការទី ១ ផ្តោតចម្បងលើការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងការយោគយល់គ្នារវាងនិយោជក និងនិយោជិតតាមរយៈយន្តការត្រីភាគី (រដ្ឋាភិបាល, និយោជក និងនិយោជិត) និងការពង្រឹងយន្តការទីផ្សារការងារ និងកម្មវិធីបណ្តុះបណ្តាលជំនាញ។ វិធានការទាំងនេះ អាចធានាបាននូវការឯកភាពលើប្រាក់ឈ្នួលអប្បបរមា និងតម្រូវការជំនាញ។ ទន្ទឹមនឹងនេះ ភាគីនិយោជក និងនិយោជិតក៏នឹងបំពេញនូវការពេញចិត្ត និងការយោគយល់គ្នា ដោយសារភាគីនិយោជកអាចពង្រឹង និងបង្កើនផលិតភាពឧស្សាហកម្មរបស់ខ្លួន ខណៈភាគីនិយោជិតក៏អាចលើកកម្ពស់ជីវភាពរស់នៅកាន់តែប្រសើរផងដែរ។

រូបភាពទី១.៥៣៖ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ"




ចង្កោមវិធានការទី ២ មានការពាក់ព័ន្ធទៅនឹងក្របខណ្ឌគតិយុត្តស្តីពីការងារ និងមុខរបរ ដោយពង្រឹង និងពិនិត្យឡើងវិញនូវច្បាប់ស្តីពីការងារ និងសន្តិសុខសង្គម ក៏ដូចជាការបង្កើតច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីតុលាការការងារ និងគោលនយោបាយការងារ និងមុខរបរជាតិ។ លទ្ធផលនៃការវាយតម្លៃវិធានការទាំងនេះមានលក្ខណៈគ្រប់គ្រាន់ក្នុងការផ្តល់នូវសិទ្ធិត្រឹមត្រូវ និងស្មើភាព ព្រមទាំងយន្តការសម្រាប់ចរចាមួយប្រកបដោយប្រសិទ្ធភាពរវាងនិយោជក និងនិយោជិត។ បន្ថែមលើនេះ ចង្កោមវិធានការនេះក៏នឹងផ្តល់នូវទិសដៅច្បាស់លាស់ និងតម្រូវការនៃការវាយតម្លៃលើការងារ ដែលសម្រួលឱ្យភាគីពាក់ព័ន្ធ ពិសេសរាជរដ្ឋាភិបាលរៀបចំ និងដាក់ចេញនូវគោលនយោបាយ/យុទ្ធសាស្ត្រជាតិស្តីពីការងារ ប្រកបដោយប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម។ វិធានការចំនួន១ ទៀត (វិធានការត្រៀម) ផ្តោតសំខាន់លើការកំណត់បទពិសោធន៍ល្អៗក្នុងការស្វែងរកដំណោះស្រាយជាប្រព័ន្ធមួយនៃវិវាទការងារក្នុងវិស័យឧស្សាហកម្ម។ ទោះយ៉ាងនេះក្តី លទ្ធផលរំពឹងទុកនៃវិធានការហាក់ដូចជាមិនច្បាស់លាស់នៅឡើយ។

ការវាយតម្លៃលើវិធានការទាំង ៦ នៃអន្តរាគមន៍គោលនយោបាយនេះ បានបង្ហាញថាវិធានការទាំង ៦ នេះ នឹងអាចសម្រេចបាននូវលទ្ធផលរំពឹងទុក ក្នុងការបង្កើន និងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ ដោយហេតុថាវិធានការគោលនយោបាយ ៥ ក្នុងចំណោម ៦ គឺជាវិធានការច្បាស់លាស់ដែលមានក្រុមគោលដៅ, មធ្យោបាយ និងលទ្ធផលរំពឹងទុកជាក់លាក់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងប្រកបដោយផលិតភាពរវាងនិយោជក និងនិយោជិត ខណៈវិធានការតែមួយប៉ុណ្ណោះជាវិធានការត្រៀម។ លើសពីនេះ វិធានការទាំងអស់ ស្ថិតនៅក្រោមអាណត្តិការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន ពាក់ព័ន្ធមួយចំនួន ដែលកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការសម្របសម្រួល និងអនុវត្តវិធានការគោលនយោបាយទាំងនេះ ដើម្បីឆ្ពោះទៅសម្រេចបាននូវគោលដៅរបស់អន្តរាគមន៍គោលនយោបាយនេះ។



## ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

វិធានការគោលនយោបាយទាំងអស់ដែលពាក់ព័ន្ធនឹងអន្តរាគមន៍គោលនយោបាយនេះមានភាពបំពេញបន្ថែមឱ្យគ្នា ដោយមានគោលដៅរួមក្នុងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ។ ឧទាហរណ៍ ក្នុងចំណោមវិធានការទាំង២ នៃចង្កោមវិធានការទី ១ គឺមានភាពស៊ីចង្វាក់គ្នាក្នុងការធ្វើឱ្យទំនាក់ទំនង និងការយោគយល់គ្នាកាន់តែល្អប្រសើររវាងនិយោជក និងនិយោជកដើម្បីផលប្រយោជន៍រួម។ វិធានការទី ១ ផ្តោតលើការពង្រឹងយន្តការទីផ្សារការងារ, ការបណ្តុះបណ្តាលជំនាញ និងការធ្វើសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដោយផ្អែកលើឥរិយាបថវិជ្ជមានរបស់សហជីព និងសីលធម៌របស់និយោជកចំពោះនិយោជិត។ វិធានការនេះតែមួយ ពុំទាន់អាចធ្វើឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុកក្នុងការធ្វើឱ្យប្រសើរឡើងនៃទំនាក់ទំនងវិជ្ជាជីវៈ ដែល ភាគីនិយោជក និងនិយោជិតពេញចិត្ត និងមានការយោគយល់គ្នាទៅវិញទៅមក។ ដើម្បីបំពេញបន្ថែមវិធានការមួយផ្សេងទៀតទាក់ទងនឹងការពង្រឹងយន្តការទំនាក់ទំនងត្រីភាគី (រាជរដ្ឋាភិបាល, និយោជក និងនិយោជិត) អាចបំពេញបន្ថែមលើលទ្ធផលនៃវិធានការទី១ ព្រោះវិធានការនេះមានសារៈសំខាន់ណាស់ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា។ ទន្ទឹមនឹងនេះ ចង្កោមវិធានការទី២ នៃវិធានការចំនួន ៣ ក៏បំពេញបន្ថែមគ្នា នឹងចង្កោមវិធានការទី១ ផងដែរ ព្រោះវិធានការទាំងនេះមានគោលបំណងដើម្បីធានាថាក្របខណ្ឌគតិយុត្តស្តីពីការងារ ដែលជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងវិជ្ជាជីវៈ។ ក្រៅពីនេះ ការស្រាវជ្រាវបែបវិទ្យាសាស្ត្រស្តីពីទំនាក់ទំនងវិជ្ជាជីវៈ ក៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍទីផ្សារការងារប្រកបដោយថាមវន្តភាព និងគោលនយោបាយស្តីពីការងារ។ វិធានការទាំង ៦ នៃអន្តរាគមន៍គោលនយោបាយនេះ គឺពុំមានខ្លឹមសារផ្ទុយគ្នាឡើយ។

## ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការរៀបចំ និងអនុវត្តវិធានការគោលនយោបាយ បង្ហាញថាពុំមានករណីស្ទួនគ្នាក្នុងចំណោមវិធានការគោលនយោបាយទាំង ៦ នោះទេ ពីព្រោះវិធានការទាំងនេះមានគោលបំណងដូចគ្នាក្នុងការរួមចំណែកដល់ការពេញចិត្តរបស់និយោជក និងនិយោជិតក្នុងឧស្សាហកម្មរបស់ខ្លួន ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ។ ទោះយ៉ាងនេះក្តី ការរៀបចំវិធានការទាំងនេះ គឺនៅមានចន្លោះប្រហោង ដោយហេតុថាវិធានការទាំងនេះផ្តោតសំខាន់តែលើការបង្កើនផលិតភាព និងការប្រកួតប្រជែងនៃឧស្សាហកម្ម និងការលើកកម្ពស់ជីវភាពរបស់និយោជិតជាមួយនឹងប្រាក់ឈ្នួលសមរម្យ ប៉ុន្តែនៅមានការខ្វះចន្លោះលើការគាំទ្រផ្នែកសុខភាព និងសុវត្ថិភាពរបស់និយោជិតក្នុងឧស្សាហកម្មដែលជាកត្តាចម្បងនៃទំនាក់ទំនងវិជ្ជាជីវៈមួយប្រកបដោយស្ថិរភាព។ ដូចនេះ គោលនយោបាយ IDP គួរដាក់បញ្ចូលនូវវិធានការគោលនយោបាយដែលខ្វះចន្លោះដូចរៀបរាប់ខាងលើបន្ថែម និងកែសម្រួលអតុល្យភាពអំណាចរវាងអាជីវកម្ម និងកម្លាំងពលកម្ម ដើម្បីធានាថានិយោជិតទទួលបានសិទ្ធិនៅកន្លែងបំពេញការងារហើយសុខភាព និងសុវត្ថិភាពរបស់កម្មករត្រូវបានលើកកម្ពស់ឱ្យប្រសើរឡើងផងដែរ។ ទាំងនិយោជក និងនិយោជិត គឺជាអ្នកឈ្នះទាំងអស់គ្នាក្នុងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ ព្រោះនិយោជកអាចលើកកម្ពស់ និងបង្កើន

ផលិតភាព ក៏ដូចជាភាពប្រកួតប្រជែងរបស់ខ្លួន ហើយនិយោជិតវិញក៏ទទួលបាននូវតម្រូវការមូលដ្ឋានរបស់ខ្លួនផងដែរ។

### ៤.៣.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៥៤៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ"







វិធានការគោលនយោបាយ ចំនួន ៥ ត្រូវបានដាក់ចេញសម្រាប់គាំទ្រអន្តរាគមន៍គោលនយោបាយនេះ។ ទន្ទឹមនឹងនេះ ដោយសារភាពពាក់ព័ន្ធនៃវិធានការគោលនយោបាយ អនុវិធានការ ចំនួន ១ ត្រូវបាន

បំបែកចេញពីវិធានការមួយ ក្នុងចំណោមវិធានការដាក់ស្ដែងគន្លឹះ៤ ដែលផ្ដោតលើការគ្រប់គ្រងទីផ្សារការងារ ត្រូវបានបន្ថែម។ ដូចនេះ ទាំងវិធានការនិងអនុវិធាន សរុបមានចំនួន ៦ ដោយវិធានការ ចំនួន ៥ ត្រូវបាន សម្រេចពេញលេញ រីឯវិធានការមួយទៀត មានភាពយឺតយ៉ាវ។

វឌ្ឍនភាពនៃការពង្រឹងទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងគួរឱ្យកត់សម្គាល់ នូវភាគរយនៃវិវាទការងារដែលត្រូវបានដោះស្រាយប្រមាណ ៧២% ជាមធ្យមក្នុងរយៈពេល ៦ឆ្នាំ (២០១៥-២០២០)។ ចំនួនកូដកម្ម និងបាតុកម្មប្រចាំឆ្នាំ ក៏មានការថយចុះគួរឱ្យកត់សម្គាល់ ក្នុងអំឡុងពេលដូចគ្នា ដោយចំនួននៃការធ្វើកូដកម្ម និងបាតុកម្មមានប្រមាណ ២០០ ដងនៅឆ្នាំ២០១៥ មកត្រឹម ៩០ ដង នៅឆ្នាំ ២០២០ ហើយការធ្វើបាតុកម្មមានត្រឹមតែ ៩ ប៉ុណ្ណោះ នៅឆ្នាំ២០២០។ លទ្ធផលវិជ្ជមាននៃការងារនេះ ក៏អាច ត្រូវបានមើលឃើញ តាមរយៈការពង្រឹងយន្តការត្រីភាគី រវាងរាជរដ្ឋាភិបាល, និយោជក និងសហជីព។ យន្តការនេះបានបង្ហាញអំពីប្រសិទ្ធភាពក្នុងការចរចាកំណត់ប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំ និងជាយន្តការ ស្នូលមួយ ដើម្បីរក្សាសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ។ កិច្ចប្រជុំត្រីភាគីដើម្បីកំណត់ប្រាក់ឈ្នួល អប្បបរមាប្រចាំឆ្នាំ ត្រូវបានរៀបចំយ៉ាងទៀងទាត់ ជាមួយនឹងលទ្ធផលនៃការដំឡើងប្រាក់ឈ្នួលអប្បបរមាជា រៀងរាល់ឆ្នាំ និងមានការកើនឡើងប្រមាណ ៣៧% នៅចន្លោះ ឆ្នាំ២០១៥-២០២០។

បន្ថែមលើយន្តការខាងលើ ឯកសារក្របខណ្ឌគតិយុត្តក៏ត្រូវបានអនុម័ត និងពិនិត្យឡើងវិញដើម្បី គាំទ្រដល់ទំនាក់ទំនងវិជ្ជាជីវៈ ក្នុងនោះរួមមាន៖ ច្បាប់ស្ដីពីសហជីព ច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា គោលនយោបាយជាតិស្ដីពីមុខរបរនិងការងារ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីការងារ។ ចាប់តាំងពីការ ប្រកាសឱ្យប្រើច្បាប់ស្ដីពីសហជីពនៅឆ្នាំ២០១៦ កន្លងមក សហជីពចំនួនប្រមាណ ២.០០០ បានចុះបញ្ជីជា ផ្លូវការ។

យ៉ាងណាមិញ មានវិធានការយឺតយ៉ាវ ចំនួន ១ ពាក់ព័ន្ធនឹងការផ្ដួចផ្ដើមឱ្យមានការសិក្សាស្រាវជ្រាវទៅ លើទំនាក់ទំនងរវាង និយោជិត និងនិយោជក ដើម្បីជួយដោះស្រាយបញ្ហាជាប្រព័ន្ធនៃវិវាទវិជ្ជា ដែលពុំមានការ បញ្ជាក់ច្បាស់លាស់អំពីមូលហេតុនៃភាពយឺតយ៉ាវឡើយ។

យោងតាមការវាយតម្លៃនៃការអនុវត្តវិធានការគោលនយោបាយនេះ បានបង្ហាញថា សុខដុមនីយកម្មនៃ ទំនាក់ទំនងវិជ្ជាជីវៈត្រូវបានបន្តរក្សាបាន តាមរយៈយន្តការត្រីភាគី (រាជរដ្ឋាភិបាល, និយោជក និងសហជីព) និងការអនុម័តលើឯកសារគតិយុត្តពាក់ព័ន្ធថ្មីៗ។ ទោះយ៉ាងណាក៏ដោយ ដើម្បីបន្តនិរន្តរភាពទំនាក់ទំនងវិជ្ជាជីវៈ ល្អរវាងនិយោជក និងនិយោជិត គឺទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្តទៀត។

## ៨.៨. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “ធ្វើឱ្យប្រសើរឡើងនូវការផ្គូផ្គងការងារ”

### ៨.៨.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៥៥៖ អត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះបញ្ហាគម្លាតជំនាញ (ឆ្នាំ២០១២-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រូបភាពទី១.៥៥ បង្ហាញពីអត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះបញ្ហាគម្លាតជំនាញ ដើម្បីវាយតម្លៃពីបញ្ហាផ្គូផ្គងការងារ និងកង្វះជំនាញដែលក្រុមហ៊ុន/សហគ្រាសត្រូវការពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៩។ អត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះបញ្ហាគម្លាតជំនាញបានថយចុះពី ៥៤,៥% នៅឆ្នាំ២០១២ មកត្រឹម ៣៩,៤% នៅ ឆ្នាំ ២០១៥ (ថយជាមធ្យម -៥ពិន្ទុភាគរយក្នុងមួយឆ្នាំ)។ ក្នុងអំឡុងពេលនៃការអនុវត្ត IDP តួលេខអត្រានេះបានបន្តថយចុះមកនៅត្រឹម ២៨,៩%នៅឆ្នាំ២០១៩ ដែលការថយចុះនេះមានល្បឿនយឺត (ជាមធ្យម -២,៦ពិន្ទុភាគរយក្នុងមួយឆ្នាំ) ជាងរយៈពេលមុនមាន IDP។

រូបភាពទី១.៥៦៖ ចំណែកនៃសហគ្រាសរាយការណ៍ដែលមានស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្មក្នុងចំនួនសហគ្រាសសរុបដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្មយ៉ាងតិចមួយ (ឆ្នាំ២០១២-២០១៩)




ប្រភពទិន្នន័យ៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រូបភាពទី១.៥៦ បង្ហាញពីចំណែកនៃសហគ្រាសរាយការណ៍ដែលមានស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ក្នុងចំនួនសហគ្រាសសរុបដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្មយ៉ាងតិចមួយ ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៩។ តួលេខចំណែកនេះបានថយចុះពី ៧៥% នៅឆ្នាំ២០១២ មកត្រឹម ៤៨,៥% នៅឆ្នាំ២០១៥ (ថយជាមធ្យម -៨,៨ពិន្ទុភាគរយក្នុងមួយឆ្នាំ)។ ប៉ុន្តែក្រោយការដាក់ចេញ IDP តួលេខចំណែកនេះបែរជាកើនឡើងបន្តិចវិញដល់ ៥៨,៤% នៅឆ្នាំ២០១៩ (កើនជាមធ្យម ២,៤ពិន្ទុភាគរយក្នុងមួយឆ្នាំ)។

នៅឆ្នាំ២០១២ ទីភ្នាក់ងារជាតិមុខរបរ និងការងារ បានធ្វើការស្ទង់មតិលើវិស័យមួយប៉ុណ្ណោះ ដើម្បីវាយតម្លៃសូចនាករទាំងពីរខាងលើ ខណៈដែលវិស័យចំនួន ១០ ត្រូវបានគិតគូរសម្រាប់ឆ្នាំបន្តបន្ទាប់។ ដូច្នេះនេះអាចជាមូលហេតុដែលតួលេខសូចនាករទាំងពីរនេះនៅឆ្នាំ២០១២ គឺខ្ពស់ជាងឆ្នាំបន្តបន្ទាប់។ ការស្ទង់មតិនេះផ្អែកលើការយល់ឃើញពីផ្នែកតម្រូវការ (ឧទាហរណ៍៖ អ្នកគ្រប់គ្រងធនធានមនុស្ស និងនិយោជក) ដូច្នេះពួកគេតែងតែនិយាយថាកម្ពុជានៅមានបញ្ហាកង្វះកម្លាំងពលកម្មជំនាញ។ សរុបមក ខណៈពេលដែលបញ្ហាគម្លាតជំនាញ ត្រូវបានកាត់បន្ថយ សហគ្រាសភាគច្រើននៅតែជួបការលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្មជំនាញ។

### ៨.៨.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

មានវិធានការគោលនយោបាយចំនួន ៣ ដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះ រួមមាន៖

- *ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាព និងសិទ្ធិស្របច្បាប់របស់ខ្លួន ពិសេសកាត់បន្ថយការចំណាយហួសហេតុក្នុងការទទួលបានការងារ*
- *ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន*

- *ពង្រឹងការយល់ដឹងអំពីការចាប់អាជីព និងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្ត ដើម្បីអភិវឌ្ឍជំនាញដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់។*

វិធានការគោលនយោបាយ ២ ក្នុងចំណោម ៣ ត្រូវបានដឹកនាំ និងអនុវត្តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខណៈវិធានការគោលនយោបាយមួយទៀត ត្រូវបានសហការអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ វិធានការគោលនយោបាយទី ១ គឺជាវិធានការគោលនយោបាយច្បាស់លាស់ដែលផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការផ្គូផ្គងការងារ និងកាត់បន្ថយចំណាយ និងពេលវេលាសម្រាប់កម្មករនិយោជិត និងកម្លាំងពលកម្មដែលឈានចូលទីផ្សារការងារក្នុងការទទួលបានការងារដែលរំពឹងទុក។ វិធានការគោលនយោបាយនេះអាចធានាបានទាំងការផ្គូផ្គងការងារ និងដំណើរការឧស្សាហកម្មបានល្អប្រសើរ។ វិធានការ ២ ផ្សេងទៀតនៃអន្តរាគមន៍គោលនយោបាយនេះ ត្រូវបានកំណត់ថាជាវិធានការគោលនយោបាយមិនច្បាស់លាស់ ព្រោះពុំមានវិធានការច្បាស់លាស់ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកឡើយ។ ក្នុងនោះ វិធានការគោលនយោបាយមួយមានគោលបំណងពង្រឹងយន្តការសម្រាប់ការគ្រប់គ្រងកម្លាំងពលកម្មជំនាញក្នុងស្រុក ដើម្បីត្រៀមខ្លួនសម្រាប់ការធ្វើសមាហរណកម្មក្នុងតំបន់ រីឯវិធានការគោលនយោបាយមួយទៀត គឺមាននិន្នាការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការផ្គូផ្គងការងារ សម្រាប់បំពេញទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។

ការវាយតម្លៃលើវិធានការទាំង ៣ នៃអន្តរាគមន៍គោលនយោបាយនេះ បានបង្ហាញថាគោលនយោបាយ IDP បានផ្តោតសំខាន់លើការពង្រឹងយន្តការគ្រប់គ្រងការងារសម្រាប់ការជ្រើសរើសកម្លាំងពលកម្ម និងការផ្តល់ព័ត៌មានទីផ្សារការងារ និងការបណ្តុះបណ្តាលកម្មករនិយោជិតអំពីការទទួលខុសត្រូវការងារ សិទ្ធិនិងសេរីភាពស្របច្បាប់របស់ខ្លួន ដែលនឹងរួមចំណែកដល់ការផ្គូផ្គងការងារឱ្យបានល្អប្រសើរ និងកាត់បន្ថយចំណាយនិងពេលវេលា ដើម្បីទទួលបានការងារធ្វើ។ ចំពោះវិសាលភាពវិញ វិធានការទាំង៣នេះ គឺពុំទាន់អាចសម្រេចបាននូវលទ្ធផលរំពឹងទុកស្តីពីការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការផ្គូផ្គងការងារបាននៅឡើយ ដោយសារវិធានការគោលនយោបាយចំនួន២ គឺជាវិធានការគោលនយោបាយមិនច្បាស់លាស់ ដោយគ្មានមធ្យោបាយ និងលទ្ធផលរំពឹងទុកជាក់លាក់។

***ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ***

វិធានការគោលនយោបាយទាំង ៣ នៃអន្តរាគមន៍គោលនយោបាយនេះ មានភាពបំពេញបន្ថែមគ្នាទៅវិញទៅមក ទោះបីជាលទ្ធផលរំពឹងទុកពុំទាន់ត្រូវបានសម្រេចពេញលេញក៏ដោយ។ ជាក់ស្តែង ក្នុងចំណោមវិធានការគោលនយោបាយ ២ ទាក់ទងនឹងព័ត៌មានដែលមានសារៈសំខាន់ក្នុងការផ្គូផ្គងការងារ គឺមានភាពស៊ីចង្វាក់ និងបំពេញបន្ថែមគ្នា។ ឧទាហរណ៍ វិធានការគោលនយោបាយច្បាស់លាស់មួយដែលមានគោលបំណងផ្គូផ្គងការងារឱ្យកាន់តែប្រសើរ និងកាត់បន្ថយចំណាយនិងពេលវេលា ក្នុងការទទួលបានការងារ និងវិធានការគោលនយោបាយមិនច្បាស់លាស់មួយផ្តោតលើការពង្រឹងការយល់ដឹងលើការជ្រើសរើសអាជីពមុខរបរ និងការអភិវឌ្ឍជំនាញបច្ចេកទេសសម្រាប់បុគ្គលិកដោយផ្តល់កម្មវិធីអប់រំ ក៏ដូចជាការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ វិធានការគោលនយោបាយទាំងពីរនេះរួមគ្នានឹងបំពេញបន្ថែមគ្នា ដើម្បី

ឱ្យប្រសើរឡើងនូវការផ្គូផ្គងការងារព្រោះភាគីនិយោជកអាចចែករំលែកព័ត៌មានទាក់ទងនឹងអ្វីដែលខ្លួនត្រូវការ តាមរយៈការពង្រឹងយន្តការជ្រើសរើសកម្លាំងពលកម្ម ហើយភាគីកម្មករនិយោជិត និងកម្លាំងពលកម្មដែលឈានចូលទីផ្សារការងារ ដែលយល់ច្បាស់ពីអាជីពមុខរបរ និងជំនាញ គឺអាចទទួលបានការងារត្រូវនឹងជំនាញរបស់ខ្លួនផងដែរ។

## ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

ចំពោះប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការរៀបចំវិធានការគោលនយោបាយ បង្ហាញថាពុំមានករណីស្ទួនគ្នាក្នុងចំណោមវិធានការគោលនយោបាយទាំង ៣ នេះទេ ព្រោះវិធានការគោលនយោបាយទាំងអស់សុទ្ធសឹងបានរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្គូផ្គងការងារ។ ទោះយ៉ាងណានេះក្តី ការរៀបចំវិធានការគោលនយោបាយទាំងនេះ គឺនៅមានចន្លោះប្រហោង ដោយហេតុថាមានវិធានការគោលនយោបាយមិនច្បាស់លាស់ចំនួន ២ ដែលគ្មានវិធានការជាក់លាក់ និងមិនអាចសម្រេចបានពេញលេញនូវលទ្ធផលរំពឹងទុកក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្គូផ្គងការងារ។ ដូចនេះ គោលនយោបាយ IDP គួរបន្តពង្រឹងបន្ថែមទៀតនូវប្រសិទ្ធភាពនៃយន្តការគ្រប់គ្រងការងារ និងការជ្រើសរើសកម្លាំងពលកម្ម ដើម្បីធានាបាននូវការងារដែលស្របទៅនឹងតម្រូវការឧស្សាហកម្ម។ ឧទាហរណ៍ តាមរយៈការបើកយុទ្ធនាការជាសាធារណៈទូលំទូលាយស្តីពីអាជីពមុខរបរ ជំនាញនិងផលិតភាពការងារព្រមទាំង ការលើកកម្ពស់ការអភិវឌ្ឍជំនាញបន្ថែមទៀត ដើម្បីធានាបាននូវគុណវុឌ្ឍិនៅកម្រិតមួយដែលឆ្លើយតបទៅនឹងតម្រូវការការងាររបស់ឧស្សាហកម្ម។ ប្រសិនបើវិធានការទាំងនេះត្រូវបានអនុវត្តពេញលេញ កម្ពុជានឹងអាចឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម ព្រមទាំងអាចទាក់ទាញការវិនិយោគដែលមានបន្ថែមតម្លៃខ្ពស់កាន់តែច្រើន។

### ៨.៨.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៥៧៖ ការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការផ្គូផ្គងការងារ"







វិធានការចំនួន ៣ ត្រូវបានដាក់ចេញសម្រាប់គាំទ្រអន្តរាគមន៍គោលនយោបាយនេះ ហើយវិធានការទាំងអស់ ត្រូវបានសម្រេចពេញលេញតាមកាលបរិច្ឆេទកំណត់។ វិធានការទាំងនេះ មានគោលបំណងពង្រឹងយន្តការស្ទួលក្នុងការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ទីផ្សារការងារ និងការអភិវឌ្ឍធនធានមនុស្សដែលមានជំនាញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម។

គុណភាពការងារ និងភាពមានការងារធ្វើ គឺជាបញ្ហាសំខាន់សម្រាប់ប្រទេសដែលមានអត្រាប្រជាជនវ័យក្មេងច្រើន ដូចជាប្រទេសកម្ពុជា។ ការកែប្រែឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើជំនាញ នឹងបង្កើនចំនួនការងារប្រកបដោយគុណភាពកាន់តែច្រើន ដែលនឹងរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ និងចក្ខុវិស័យ IDP។ កម្មវិធីអប់រំស្ដីពីការរៀបចំផែនការ និងចាប់យកអាជីព មុខរបរ និងជំនាញបច្ចេកទេស ជំរុញ

ជាកម្មវិធីសិក្សាបន្ត បានផ្តល់អត្ថប្រយោជន៍ដល់សិស្សមធ្យមសិក្សា និស្សិតវិទ្យាស្ថានបច្ចេកទេស និងសាកលវិទ្យាល័យ ប្រមាណចំនួន ៨៨ពាន់នាក់ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០។ ការផ្តល់លទ្ធភាពចូលទីផ្សារការងារសម្រាប់អ្នកស្វែងរកការងារធ្វើ ការបង្កើតមជ្ឈមណ្ឌលការងារ និងថ្នាលសេវាការងារសាធារណៈឌីជីថល សម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការបង្កើនអត្រាការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្មដែលមានសក្តានុពលទៅនឹងការងារដែលពាក់ព័ន្ធ។ ចំពោះការអភិវឌ្ឍធនធានមនុស្ស និងការធ្វើឱ្យប្រសើរឡើងនូវអាជីពការងារ គឺអាចសម្រេចបានតាមរយៈការកើនឡើងនៃចំណាប់អារម្មណ៍ក្នុងកម្មវិធី ជ្រើសរើសជំនាញ ដែលត្រូវបានបង្កើតឡើងក្រោមវិធានការគោលនយោបាយនេះ។ ការអនុវត្តវិធានការទាំងនេះ ត្រូវបានវាយតម្លៃខ្ពស់ និងរួមចំណែកប្រកបដោយប្រសិទ្ធភាពដល់អន្តរាគមន៍គោលនយោបាយ។ បន្ថែមលើនេះ ដើម្បីរៀបចំធនធានមនុស្ស និងកម្មករជំនាញសម្រាប់សមាហរណកម្មអាស៊ាន ការសិក្សា និងក្របខណ្ឌស្តីពីការផ្គូផ្គងគុណវុឌ្ឍិថ្នាក់ជាតិរបស់កម្ពុជាជាមួយក្របខណ្ឌយោងអាស៊ាន ក៏ត្រូវបានរៀបចំ និងអនុម័តដោយគណៈកម្មាធិការក្របខណ្ឌយោងអាស៊ាន (AQRFC) នៅឆ្នាំ២០២០ ផងដែរ។

ទោះយ៉ាងណាក៏ដោយ ជាមួយនឹងការអភិវឌ្ឍ និងនវានុវត្តន៍យ៉ាងឆាប់រហ័សនៅក្នុងទីផ្សារ និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចឌីជីថល, បច្ចេកវិទ្យាថ្មីៗនឹងដំណើរការដោយស្វ័យប្រវត្តិ ហើយនឹងជំនួសឱ្យជំនាញដែលមានស្រាប់នៅគ្រប់វិស័យ។ ករណីនេះ គឺទាមទារឱ្យមានមូលដ្ឋានគ្រឹះដ៏រឹងមាំនៅក្នុងជំនាញបច្ចេកទេស និងការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវជំនាញពាក់ព័ន្ធ ដើម្បីអាចរកការងារធ្វើ និងរក្សាបាននូវកម្លាំងពលកម្មដែលមានភាពប្រកួតប្រជែង។ ការបណ្តុះបណ្តាលជំនាញថ្មីៗដល់កម្លាំងពលកម្ម គឺជាបេសកកម្មរយៈពេលវែងមួយដែលទាមទារឱ្យរាជរដ្ឋាភិបាលមិនត្រឹមតែបញ្ជ្រាបកម្មវិធីបណ្តុះបណ្តាលជំនាញដល់ស្រទាប់ប្រជាជននានា និងកម្មវិធីសិក្សាជាតិនោះទេ ប៉ុន្តែថែមទាំងលើកទឹកចិត្តក្រុមហ៊ុនឱ្យបន្តបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនដើម្បីរក្សាជំនាញពាក់ព័ន្ធ និងស្របតាមការវិវត្តនៃបច្ចេកវិទ្យានិងសម័យកាល។

## ៨.៥. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ”

### ៨.៥.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៥៨៖ អត្រាសហគ្រាស គ្រឹះស្ថាន ដែលមានសេវាសង្គ្រោះអប្បបរមា (ឆ្នាំ២០១២-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រូបភាពទី១.៥៨ បង្ហាញពីអត្រាសហគ្រាសគ្រឹះស្ថាន ដែលមានសេវាកម្មសង្គ្រោះអប្បបរមា ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៩។ តួលេខអត្រានេះបានកើនឡើងបន្តិចពី ៦៣,៨% នៅឆ្នាំ២០១២ ដល់ ៦៦,៤% នៅឆ្នាំ២០១៥ (កើនជាមធ្យម ០,៩ពិន្ទុភាគរយ ក្នុងមួយឆ្នាំ)។ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP អត្រានេះបន្តកើនរហូតដល់ ៨២,៦% នៅឆ្នាំ២០១៩ ហើយមានអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ៤,១ពិន្ទុភាគរយ លឿនជាងអត្រាកំណើនមុនពេលការដាក់ចេញគោលនយោបាយ IDP ដល់ទៅ៤ ដង។

រូបភាពទី១.៥៩៖ ចំនួន (តួលេខស្តុក) កម្មករនិយោជិតដែលទទួលបានបណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) (២០១៧-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រូបភាពទី១.៥៩ បង្ហាញពីចំនួន (តួលេខស្តុក) កម្មករនិយោជិតដែលទទួលបានបណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩។ នៅឆ្នាំ២០១៧ មានកម្មករនិយោជិតសរុបប្រមាណ ១,២លាននាក់ បានទទួលប័ណ្ណសមាជិក ប.ស.ស. លុះមកដល់ឆ្នាំ២០១៩ តួលេខនេះក៏បានកើនដល់សរុបប្រមាណ ១,៧លាននាក់។

សរុបមក ទោះបីសូចនាករទាំងពីរខាងលើ ពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីវាយតម្លៃអំពីលក្ខខណ្ឌការងារក៏ដោយ ក៏យើងអាចសន្និដ្ឋានបានថា លក្ខខណ្ឌការងារទូទៅមានភាពប្រសើរឡើង។

### ៨.៥.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការសរុបចំនួន៥ ដូចមានបង្ហាញជូនក្នុងរូបភាព ១.៦០ ខាងក្រោម។ វិធានការទាំងនេះ ចែកចេញជា ៣ ចង្កោមរួមមាន៖ (១) ការពង្រឹងបទបញ្ញត្តិ /វិធាន ដើម្បីលើកកម្ពស់ស្តង់ដារសុខាភិបាល និងស្តង់ដារការងារនៅកន្លែងបំពេញការងារ (៣ វិធានការ), (២) ការផ្តល់លទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋាន ដើម្បីលើកកម្ពស់សុខុមាលភាពរបស់កម្មករ (១វិធានការ) និង (៣) ការធានា
ស្ថិរភាពហិរញ្ញវត្ថុ/ប្រាក់ចំណូល សម្រាប់កម្មករនិយោជិត (១វិធានការ)។

រូបភាពទី១.៦០ ៖ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ"




ចង្កោមទី១ មានវិធានការចំនួន ៣ ដូចជា៖ "កំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម...", "ការពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ..." និង "កែលម្អកម្រិតជីវភាពរបស់ពលករតាមរយៈ... ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បរមា..."។ ចង្កោមទី១ នេះផ្តោតលើការពង្រឹងបទប្បញ្ញត្តិ/វិធាន ដែលទាក់ទងនឹងការពង្រឹងការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម, ពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ និងលើកកម្ពស់កម្រិតជីវភាពរបស់ពលករ (ប្រាក់ឈ្នួល) ដែលកត្តាទាំងនេះនឹងនាំឱ្យមានការធានាបាននូវស្តង់ដារការងារល្អ និងលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករ។ ទន្ទឹមនឹងនេះ ចង្កោមទី២ មានវិធានការមួយផ្តោតលើ "ការជំរុញឱ្យមានគោលនយោបាយលំនៅដ្ឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋាន..." ដែលអាចលើកកម្ពស់សុខុមាលភាពរបស់កម្មករ។ វិធានការចុងក្រោយផ្តោតលើការធានាស្ថិរភាពហិរញ្ញវត្ថុ/ប្រាក់ចំណូល សម្រាប់កម្មករនិយោជិត តាមរយៈ "ការពង្រឹងយន្តការសន្សំក្នុងស្រុករួមមានការអភិវឌ្ឍ និងការកែទម្រង់មូលនិធិសោធន និងវិស័យធានារ៉ាប់រង..."។

ការវាយតម្លៃលើវិធានការទាំង ៥ នៃអន្តរាគមន៍គោលនយោបាយនេះបង្ហាញថា គោលនយោបាយ IDP យកចិត្តទុកដាក់ក្នុងការធ្វើឱ្យប្រសើរឡើងនូវស្តង់ដារសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ ដែលជាកត្តាចម្បងមួយសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារសម្រាប់កម្មករ។ ចំពោះវិសាលភាព និងការរៀបចំគោលនយោបាយ, វិធានការទាំង៣ ក្រោមចង្កោមទី១ ដែលផ្តោតលើការលើកកម្ពស់ការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម, ការពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ និងការលើកកម្ពស់កម្រិតជីវភាពរបស់កម្មករ (ប្រាក់ឈ្នួល) គឺមានភាពគ្រប់គ្រាន់ដើម្បីនាំមកនូវលទ្ធផលរំពឹងទុកក្នុងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ។ ទន្ទឹមនឹងនេះ វិធានការចំនួន២ ផ្សេងទៀតដែលស្ថិតនៅក្រោមចង្កោមទី២ និងទី៣ ផ្តោតលើការជំរុញឱ្យមានគោលនយោបាយលំនៅដ្ឋានសម្រាប់កម្មករ និងការពង្រឹងយន្តការសន្សំក្នុងស្រុក មានសារៈសំខាន់ដើម្បីធានាបាននូវស្ថានភាពរស់នៅល្អ និងស្ថិរភាពហិរញ្ញវត្ថុ/ប្រាក់ចំណូលសម្រាប់កម្មករ។

ទោះយ៉ាងនេះក្តី វិធានការទាំង២នេះ ហាក់ផ្តល់បច្ច័យដោយប្រយោលតែប៉ុណ្ណោះទៅលើអន្តរាគមន៍គោលនយោបាយ។

## ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

នៅក្នុងអន្តរាគមន៍គោលនយោបាយនេះ វិធានការចំនួន២ ដែលនៅក្រោមចង្កោមទី១ មានខ្លឹមសារបំពេញបន្ថែមគ្នា ដើម្បីលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារ នៅកន្លែងធ្វើការ។ វិធានការទី១ ផ្តោតលើ "ការកំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម..."។ វិធានការនេះតែមួយមិនអាចធានាបានថា រោងចក្រ/សហគ្រាសនឹងអនុវត្តតាមបទដ្ឋាន និងគោលការណ៍ណែនាំដែលបានចែង ដើម្បីផ្តល់នូវសុវត្ថិភាពនិងសុខភាពការងារល្អឱ្យកម្មករនិយោជិតនោះទេ។ ដូច្នេះហើយ វិធានការមួយទៀតដែលផ្តោតលើ "ការពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ..." បំពេញបន្ថែមលើវិធានការមុន ពីព្រោះដើម្បីធានាថាស្តង់ដារដែលបានកំណត់ត្រូវបានអនុវត្តដោយរោងចក្រ/សហគ្រាស, រាជរដ្ឋាភិបាល ឬភាគីពាក់ព័ន្ធត្រូវចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ នៅតាមរោងចក្រ/សហគ្រាសទាំងនោះ។

ក្រៅពីផលបច្ច័យបំពេញបន្ថែមទាំងនេះ គ្មានវិធានការគោលនយោបាយណាមួយ ដែលមានខ្លឹមសារផ្ទុយគ្នានោះទេ សម្រាប់អន្តរាគមន៍គោលនយោបាយនេះ។

## ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

ចំពោះប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការរៀបចំគោលនយោបាយ, យើងសង្កេតឃើញថាមិនមានភាពស្ទួនគ្នានៃវិធានការគោលនយោបាយទាំង៥នេះទេ ដោយសារវិធានការនីមួយៗផ្តោតលើសកម្មភាពផ្សេងៗគ្នា។ ប៉ុន្តែ ការរៀបចំវិធានការសម្រាប់អន្តរាគមន៍គោលនយោបាយនេះទេ ហាក់ដូចជានៅមានខ្វះចន្លោះខ្លះ។ ជាក់ស្តែង កម្រិតវប្បធម៌របស់ពលករកម្ពុជាភាគច្រើននៅមានកម្រិតនៅឡើយ ដូចនេះពួកគេពុំទាន់យល់ដឹងច្រើនអំពីលក្ខណវិនិច្ឆ័យនៃលក្ខខណ្ឌការងារសមរម្យ ដូចជាអត្រាប្រាក់ខែ, អត្ថប្រយោជន៍សង្គមផ្សេងៗ និងសុវត្ថិភាពនិងសុខភាពការងារនៅកន្លែងធ្វើការជាដើម។ ក្នុងន័យនេះ រដ្ឋាភិបាលអាចរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនដែលស្ថិតក្នុងវ័យធ្វើការ តាមរយៈការផ្តល់ព័ត៌មានតាមទូរទស្សន៍ ឬបណ្តាញសង្គម ឬតាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់អ្នកដែលឈានដល់វ័យធ្វើការ លើប្រធានបទមួយចំនួនដែលទាក់ទងនឹងលក្ខខណ្ឌការងាររួមមាន ស្តង់ដារការងារ, ច្បាប់ការងារ, សិទ្ធិ និងសុវត្ថិភាពកម្មករជាដើម។ នៅពេលដែលកម្មករនិយោជិតមានចំណេះដឹងអំពីប្រធានបទពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ ដូចបានរៀបរាប់ខាងលើ, ពួកគេនឹងមានអំណាចចរចា ដើម្បីចរចាជាមួយនិយោជក នៅពេលដែលពួកគេទទួលបានលក្ខខណ្ឌការងារមិនសមរម្យ ឬយ៉ាងហោចណាស់ពួកគេនឹងដឹងពីទីតាំងដែលពួកគេអាចសុំជំនួយ។ បន្ថែមលើការផ្តល់ព័ត៌មានទាក់ទងនឹងលក្ខខណ្ឌការងារដល់ប្រជាជនក្នុងវ័យធ្វើការ,រាជរដ្ឋាភិបាលក៏អាចពិចារណាផ្តល់ការលើកទឹកចិត្តដល់រោងចក្រ/សហគ្រាស ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ។ ឧទាហរណ៍ រាជរដ្ឋាភិបាលអាចផ្តល់នូវការកាត់បន្ថយពន្ធសម្រាប់រោងចក្រ/សហគ្រាស ដែលអនុវត្តល្អប្រសើរនូវលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ ជាដើម។

### ៩.៥.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

គោលនយោបាយ IDP បានដាក់ចេញនូវវិធានការចំនួន៤ ដើម្បីគាំទ្រអន្តរាគមន៍គោលនយោបាយនេះ។ ក្នុងនោះ វិធានការ ចំនួន ១ ត្រូវបានចាត់ទុកជាវិធានការពហុសកម្មភាព ដូច្នេះវិធានការនេះត្រូវបានបំបែកទៅជាអនុវិធានការចំនួន ២។ ដើម្បីឆ្លុះបញ្ចាំងឱ្យបានលម្អិតនូវវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយដែលជាពហុសកម្មភាព មានតែអនុវិធានការគោលនយោបាយប៉ុណ្ណោះ ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃ។ ទន្ទឹមនឹងនេះ ដោយសារភាពពាក់ព័ន្ធនៃវិធានការគោលនយោបាយ អនុវិធានការចំនួន ១ ត្រូវបានបំបែកចេញពីវិធានការមួយ ក្នុងចំណោមវិធានការគន្លឹះ៤ជាក់ស្តែង ដែលផ្តោតលើការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បរមា ត្រូវបានបន្ថែមក្នុងអន្តរាគមន៍គោលនយោបាយនេះ។ ជាលទ្ធផល វិធានការនិងអនុវិធានការសរុបចំនួន ៦ ត្រូវបានវាយតម្លៃ ដែលក្នុងនោះវិធានការ ចំនួន ៤ ត្រូវបានសម្រេចពេញលេញ និងវិធានការ ចំនួន ២ទៀត កំពុងអនុវត្ត។

ចង្កោមវិធានការទី១ ដែលផ្តោតលើការពង្រឹងបទប្បញ្ញត្តិ ដើម្បីលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារនៅកន្លែងធ្វើការ មានវិធានការ/អនុវិធានការចំនួន ៣ ដែលត្រូវបានអនុវត្តសម្រេចពេញលេញ។ ជាក់ស្តែង ឯកសារបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានដាក់ឱ្យអនុវត្ត និងសម្រេចពេញលេញនៅឆ្នាំ ២០១៩។ ទន្ទឹមនឹងនេះ ក្រុមការងារចម្រុះចុះអធិការកិច្ចលក្ខខណ្ឌការងារត្រូវបានបង្កើត ហើយចាប់តាំងពីការបង្កើតក្រុមការងារនេះមក ចំនួននៃការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ បានធ្លាក់ចុះយ៉ាងគំហុក ពីប្រមាណ ៩.០០០ ដងនៅឆ្នាំ ២០១៥ មកត្រឹមប្រមាណ ២.០០០ ដងនៅឆ្នាំ ២០២០ ដែលបង្ហាញពីប្រសិទ្ធភាពរបស់ ក្រុមការងារចម្រុះអន្តរក្រសួងនេះ។ វិធានការមួយទៀត មានគោលបំណងពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បរមា។ យន្តការត្រីភាគីត្រូវបានបង្កើត និងដំណើរការជាប្រចាំ។ យោងតាមតួលេខប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ជារៀងរាល់ឆ្នាំ តាមរយៈប្រកាសដែលធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្ហាញថាប្រាក់ឈ្នួលអប្បបរមាមានការកើនឡើងជាលំដាប់ពី ១២៨ ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ដល់ ១៨២ដុល្លារអាមេរិក នៅឆ្នាំ២០១៩ និង ១៩០ដុល្លារអាមេរិក នៅឆ្នាំ២០២០។

រូបភាពទី១.៦១៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ"







ចង្កោមវិធានការទី២ ដែលផ្តោតលើការផ្តល់លទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋានដល់កម្មករ មានវិធានការមួយដែលបានអនុវត្តសម្រេចពេញលេញ។ ជាក់ស្តែង គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍលំនៅដ្ឋានដែលមានតម្លៃសមរម្យត្រូវបានអនុម័ត។ គោលនយោបាយនេះអនុញ្ញាតឱ្យមានការអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យដែលផ្តល់ផលប្រយោជន៍ផ្ទាល់ដល់កម្មករ។ ការផ្តល់លំនៅដ្ឋានតម្លៃសមរម្យ ដែលកម្មករអាចមានលទ្ធភាពបង់រំលស់ដោយមិនដាក់បន្ទុកលើប្រាក់ចំណូល នឹងជួយដល់កម្មករមិនឱ្យធ្វើចំណាកស្រុក។ ទន្ទឹមនឹងនេះ ឯកសារបច្ចេកទេសនានាត្រូវបានរៀបចំ និងចែកចាយ

ដើម្បីគាំទ្រដល់ការអនុវត្តគម្រោងលំនៅដ្ឋានតម្លៃសមរម្យ ដែលឯកសារទាំងនោះរួមមាន៖ ១) ឯកសារទស្សនាទានតម្រូវការបច្ចេកទេស (តំបន់ឯកជន និងទីសាធារណៈ) នៃលំនៅដ្ឋានតម្លៃសមរម្យសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម និងទាប, ២) សៀវភៅណែនាំស្តីពីការសម្របសម្រួលបច្ចេកទេសសាងសង់លំនៅដ្ឋានទៅនឹងការប្រែប្រួលអាកាសធាតុ និង ៣) សៀវភៅណែនាំបច្ចេកទេសសាងសង់លំនៅដ្ឋានសម្រាប់គ្រួសារដែលមានចំណូលទាប និងមធ្យម។ រហូតមកដល់ពេលនេះ មានការអនុញ្ញាតលើគម្រោងលំនៅដ្ឋានតម្លៃសមរម្យចំនួន ៤ ដែលមានសក្តានុពលអាចផ្តល់ជម្រើសលំនៅដ្ឋានសម្រាប់កម្មករនិយោជិត ជាពិសេសគ្រួសារដែលមានចំណូលមធ្យមកម្រិតទាប។ គម្រោងលំនៅដ្ឋានតម្លៃសមរម្យទាំង៤ នោះមានដូចជា៖ ១) លំនៅដ្ឋានសិរីមង្គល (Worldbridge Home), ២) B&BM Development, ៣) បូរីហ្រ្គែនផាក (BRGP Development), និង ៤) លំនៅដ្ឋានខុនដូអារ៉ាកាវ៉ា (ARAKAWA Residence)។ បច្ចុប្បន្នគម្រោងទាំងនេះកំពុងស្ថិតក្នុងការអភិវឌ្ឍយ៉ាងរលូន។

ចង្កោមវិធានការទី៣ "ការធានាស្ថិរភាពហិរញ្ញវត្ថុ/ប្រាក់ចំណូលសម្រាប់កម្មករ" មានអនុវិធានការចំនួន ២ ដែលកំពុងអនុវត្ត។ តាមការរាយការណ៍របស់ក្រសួងដែលទទួលបន្ទុកអនុវត្ត, មូលហេតុដែលអនុវិធានការទាំង២នេះ មិនទាន់សម្រេចបាន គឺដោយសារភាពស្មុគស្មាញនៃកំណែទម្រង់ប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីរាជការស៊ីវិល និងភាពស្មុគស្មាញផ្នែកបច្ចេកទេសក្នុងការរៀបចំអនុក្រឹត្យស្តីពីធានារ៉ាប់រង។

សរុបមក លក្ខខណ្ឌការងារនៅកម្ពុជាកាន់តែមានភាពប្រសើរគួរឱ្យកត់សម្គាល់ ដែលផ្តល់បច្ច័យវិជ្ជមានដល់សុខុមាលភាពរបស់កម្មករក្នុងរយៈពេលវែង។

## ៩. ការរួមចំណែករបស់អន្តរាគមន៍គោលនយោបាយចម្បងក្នុងគោលបំណងទី៩ “បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា”

### ៩.១. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនការតភ្ជាប់រវាងសហគ្រាសក្នុងស្រុក ជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា”

#### ៩.១.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានសូចនាករមួយប៉ុណ្ណោះសម្រាប់វាស់វែងលទ្ធផលគឺ ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស។ យ៉ាងណាក្តី យោងតាមលទ្ធផលអង្កេតមួយរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ កាលពីឆ្នាំ២០១៩ បានបង្ហាញថា ជាមធ្យមប្រមាណ ៩៦% នៃធាតុចូលផលិតកម្មរបស់សហគ្រាសបរទេសនៅកម្ពុជា គឺត្រូវបាននាំចូល។ សហគ្រាសបរទេសជាច្រើនមានបំណងចង់ទិញធាតុចូលផលិតកម្មក្នុងស្រុក ប៉ុន្តែសហគ្រាសដែលអាចផ្គត់ផ្គង់ធាតុចូលទាំងនោះបាន មានចំនួនតិចតួចមែនទែននៅកម្ពុជា។

#### ៩.១.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

គោលនយោបាយ IDP បានដាក់ចេញនូវវិធានការចំនួន៣ ដើម្បីគាំទ្រអន្តរាគមន៍គោលនយោបាយនេះ ដូចជា៖

- *សិក្សារៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេសនិងសហគ្រាសក្នុងស្រុក [...]*
- *ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមសម្រាប់ការវិនិយោគលើគ្រឿងម៉ាស៊ីនឬបរិក្ខារផលិតកម្ម [...]*
- *ពង្រឹងសមត្ថភាពនិងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាសនិងវិនិយោគបរទេសធំៗ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស។*

វិធានការទី១ គឺជាវិធានត្រៀម សំដៅលើកកម្ពស់ការតភ្ជាប់រវាងសហគ្រាសធុនតូច និងមធ្យមជាមួយសហគ្រាសធំបរទេស។ សួនឧស្សាហកម្មនឹងដើរតួនាទីក្នុងការបម្រើដល់ការគាំទ្រការផ្គូផ្គងរវាងសហគ្រាសក្នុងស្រុក និងសហគ្រាសបរទេសលើការតភ្ជាប់ច្រវាក់ផលិតកម្ម។ តួយ៉ាង សួនឧស្សាហកម្ម ផ្តល់នូវការគាំទ្រយ៉ាងទូលំទូលាយសម្រាប់វិនិយោគិន ដូចជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ អត្ថប្រយោជន៍នៃទីតាំង ការផ្តល់នូវយន្តការលើកទឹកចិត្ត និងការជួយសម្រួលអាជីវកម្ម រួមទាំងឯកសិទ្ធផ្សេងៗទៀត ដែលនឹងអនុញ្ញាតឱ្យសហគ្រាសក្នុងស្រុកអាចសល់នូវប្រាក់ចំណេញមួយចំណែកសម្រាប់ពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការតភ្ជាប់ជាមួយបណ្តាសហគ្រាសធំបរទេស។ ក្នុងន័យនេះ ភាពល្អប្រសើរនៃការផ្គូផ្គងអាជីវកម្មនឹងឆ្លុះបញ្ចាំងពីការចូលរួមរបស់សហគ្រាសក្នុងស្រុកកាន់តែច្រើនទៅក្នុងខ្សែច្រវាក់តម្លៃតំបន់និងសកល ដែលជាលទ្ធផលរំពឹងទុកនៃការអនុវត្តគោលនយោបាយ IDP។

វិធានការទី២ គឺជាវិធានការត្រៀមដែលអនុវត្តដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួងទាំង២ នេះនឹងត្រូវធ្វើការរួមគ្នាដើម្បីចងក្រងនូវឧបករណ៍គោលនយោបាយដែលមានភាពល្អមសមស្របនឹងស្រេចបាន តាមរយៈការដាក់បញ្ចូលនូវក្រុបខណ្ឌលើកទឹកចិត្តផ្នែកពន្ធដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម។ ការគាំទ្រប្រភេទនេះ អាចផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូច និងមធ្យមក្នុងការជួល ឬទិញគ្រឿងម៉ាស៊ីន និងសម្ភារៈបរិក្ខារផលិតកម្មទំនើបៗដើម្បីកែច្នៃវត្ថុធាតុដើមក្នុងស្រុក និងកែលម្អនូវគុណភាពផលិតផលរបស់ខ្លួន។ ក្នុងន័យនេះ សហគ្រាសធុនតូច និងមធ្យមនឹងមានសិទ្ធិទទួលបាននូវការគាំទ្រពីរដ្ឋាភិបាល និងអាចប្រើប្រាស់ធនធានគាំទ្រទាំងនោះដើម្បីធ្វើទំនើបកម្មផលិតកម្មរបស់ខ្លួន ហើយជាលទ្ធផល នឹងរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រាសក្នុងស្រុក ដើម្បីការតភ្ជាប់ជាមួយក្រុមហ៊ុនសាជីវកម្មពហុជាតិនានា។

វិធានការទី៣ មានគោលបំណងច្បាស់លាស់ ប៉ុន្តែខ្វះខាតនូវឧបករណ៍ជាក់លាក់ក្នុងការកំណត់នូវមធ្យោបាយដើម្បីកសាងសមត្ថភាពសហគ្រាសក្នុងស្រុក។ ការរៀបចំបែបនេះ គឺមានចេតនាទុកជូនក្រសួងស្ថាប័នសាមី ដូចជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវលំហគោលនយោបាយក្នុងការសហការរួមគ្នាដើម្បីបង្កើតកម្មវិធីកសាងសមត្ថភាពដើម្បីឱ្យសហគ្រាសក្នុងស្រុកមានសមត្ថភាពក្នុងការតភ្ជាប់ខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន ជាមួយសហគ្រាសធំបរទេសក្នុងតំបន់សេដ្ឋកិច្ចពិសេស។

ការវាយតម្លៃតាមបែបគុណវិស័យនៃវិធានការទាំង៣ ដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះបង្ហាញថា វិធានការទាំងនេះត្រូវបានរៀបចំដើម្បីពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយបរទេសតាមរយៈមធ្យោបាយផ្សេងៗគ្នា។ ផ្អែកទៅលើវិសាលភាពនិងការរៀបចំគោលនយោបាយ វិធានការទាំង៣ស្ថិតក្នុងដំណាក់កាលត្រៀមនៅឡើយ ដូច្នេះពុំអាចជះឥទ្ធិពលបានភ្លាមៗលើការតភ្ជាប់សហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេសឡើយ។ លើសពីនេះ ខណៈវិធានការទាំងនេះ ផ្តោតសំខាន់លើការជ្រោមជ្រែងសហគ្រាសធុនតូច និងមធ្យមឱ្យលូតលាស់ ប៉ុន្តែពុំមានវិធានការណាមួយផ្តោតលើការផ្ទេរបច្ចេកវិទ្យាពីសហគ្រាសធំបរទេសទៅសហគ្រាសធុនតូច និងមធ្យមនោះទេ។

## ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

វិធានការស្តីពី "ការពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម" មានលក្ខណៈបំពេញបន្ថែមគ្នាបានយ៉ាងល្អទៅវិញទៅមកជាមួយនឹងវិធានការស្តីពី "ការពង្រឹងសមត្ថភាពនិងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក"។ ការផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមក្នុងការធ្វើទំនើបកម្មខ្សែច្រវាក់ផលិតកម្ម អាចធ្វើទៅបាន តាមរយៈការដាក់ចេញនូវយន្តការនៃការលើកលែងពន្ធ ឬការផ្តល់នូវឧបត្ថម្ភធនដើម្បីផ្តល់លទ្ធភាពដល់សហគ្រាសធុនតូច និងមធ្យមក្នុងការប្រើប្រាស់នូវគ្រឿងម៉ាស៊ីន ឬសម្ភារៈបរិក្ខារទំនើបៗសំដៅពង្រឹងគុណភាពនិងពង្រីកទំហំផលិតកម្មសហគ្រាស។ ថ្វីបើមានការដាក់ចេញនូវយន្តការលើកទឹកចិត្តក៏ដោយ សហគ្រាសធុនតូច និងមធ្យមភាគច្រើននៅតែពុំទាន់មានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយសារមូលហេតុមួយចំនួនផ្សេងទៀត។ ដូច្នេះហើយ ទើបវិធានការគោលនយោបាយមួយទៀតដែលពាក់ព័ន្ធនឹងការបង្កើន

សមត្ថភាពសហគ្រិនក្នុងស្រុកនឹងជួយលើកស្ទួយសហគ្រាសធុនតូច និងមធ្យមក្នុងការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម និងយុទ្ធសាស្ត្រអាជីវកម្មរយៈពេលវែង ដើម្បីពង្រីកអាជីវកម្ម និងទាញយកប្រយោជន៍ពីសក្តានុពលទីផ្សារថ្មីៗ។ កាលណាវិធានការទាំង២ ត្រូវបានដាក់ឱ្យអនុវត្ត សហគ្រាសក្នុងស្រុកត្រូវបានរំពឹងថានឹងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្សារភ្ជាប់បណ្តាញទំនាក់ទំនងជាមួយនឹងសហគ្រាសបរទេស។ ក្រៅពីនេះ គ្មានវិធានការដែលផ្ទុយគ្នាឡើយនៅក្នុងអន្តរាគមន៍គោលនយោបាយនេះ។

### ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពភាពនៃវិធានការគោលនយោបាយ

ដោយផ្អែកទៅលើប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពភាពនៃការចងក្រងគោលនយោបាយ ពុំមានករណីស្ទួនក្នុងចំណោមវិធានការ ដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះឡើយ ប៉ុន្តែភាពខ្វះចន្លោះមួយចំនួនត្រូវបានកត់សម្គាល់។ ដូចដែលបានរៀបរាប់ខាងលើ វិធានការទាំង៣ ក្នុងអន្តរាគមន៍គោលនយោបាយនេះសុទ្ធតែជាវិធានការត្រៀម។ ដូច្នេះ ការផ្លាស់ប្តូរវិធានការទាំងនេះឱ្យក្លាយជាវិធានការច្បាស់លាស់ដែលមានឧបករណ៍គោលនយោបាយគាំទ្រដ៏មុតស្រួច គឺជាកិច្ចការចាំបាច់ដើម្បីពង្រឹងការតភ្ជាប់សកម្មភាពឧស្សាហកម្មក្នុងស្រុក។ លើសពីនេះ វិធានការទាំង៣ ផ្តោតត្រឹមតែចំពោះសហគ្រាសធុនតូច និងមធ្យម ហើយហាក់ដូចជាខកខានក្នុងការជំរុញនិងលើកទឹកចិត្តសហគ្រាសធំបរទេសក្នុងការផ្ទេរបច្ចេកវិទ្យាដល់សហគ្រាសក្នុងស្រុក។

#### ៥.១.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះគាំទ្រដោយវិធានការចំនួន ៣ ក្នុងនោះ វិធានការចំនួន ១ បានសម្រេចពេញលេញ, វិធានការចំនួន ២ កំពុងអនុវត្ត។ វិធានការដែលសម្រេចបានពេញលេញ គឺជាវិធានការត្រៀម ចំណែកក្នុងចំណោមវិធានការចំនួន ២ ផ្សេងទៀត មាន ១វិធានការជាវិធានការមិនច្បាស់លាស់ និង ១វិធានការទៀតជាវិធានការត្រៀម។ នេះបង្ហាញឱ្យឃើញថា វិធានការ ដែលគាំទ្រអន្តរាគមន៍គោលនយោបាយនេះហាក់ដូចជាមិនទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេសនៅឡើយ។

វិធានការ ដែលបានសម្រេចពេញលេញពាក់ព័ន្ធទៅនឹងការសិក្សារៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម ដើម្បីពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេសតាមរយៈការជំរុញការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យមទៅក្នុងខ្សែច្រវាក់ផលិតកម្មនិងខ្សែច្រវាក់តម្លៃតំបន់និងសកលក្នុងបរិការណ៍នៃសមាហរណកម្មតំបន់។ ចំណែក វិធានការចំនួន ២ ផ្សេងទៀត កំពុងអនុវត្ត ដោយសារកាលបរិច្ឆេទគោលដៅ ត្រូវបានកំណត់រហូតដល់ឆ្នាំ២០២៥។

រូបភាពទី១.៦២៖ លទ្ធផលវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា"




**បង្កើនការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា**

(ត) ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូចនិងមធ្យម សម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគ...

(ម) ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញយកផលប្រយោជន៍...

(ត) សិក្សារៀបចំស្ទួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុកពិសេស ការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និងខ្សែចង្វាក់ផលិតកម្មតំបន់ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់

*សម្គាល់÷ (ម) វិធានការគោលនយោបាយមិនច្បាស់លាស់, (ត) វិធានការត្រៀម*

*វិធានការគោលនយោបាយ*

*កំពុងអនុវត្ត (ក្នុងកាលបរិច្ឆេទគោលដៅ) (សូចនាករគោលទី២ បានសម្រេច)*

*សម្រេចពេញលេញ (សូចនាករគោលទាំង៣បានសម្រេច)*

## ៥.២. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក”

### ៥.២.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៦៣៖ ចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប (២០០៥-២០១៩)




ប្រភពទិន្នន័យ៖ ក្រសួងផែនការ និង WITS

រូបភាពទី១.៦៣ បង្ហាញពីចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប ចាប់ពីឆ្នាំ២០០៥ ដល់២០១៩។ ប្រសិនបើតួលេខចំណែកនេះកើនឡើង មានន័យថា ការផលិតទំនិញក្នុងស្រុកសម្រាប់គោលដៅបម្រើទីផ្សារក្នុងស្រុក កាន់តែមានការកើនឡើង ឬអាចនិយាយម្យ៉ាងទៀតបានថា ការពឹងផ្អែកលើការនាំចេញក្នុងវិស័យឧស្សាហកម្មកម្ពុជា ត្រូវបានកាត់បន្ថយជាបណ្តើរៗ។ ចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប បានថមថយពី ៤៥,៣% នៅឆ្នាំ២០០៥ ដល់ ៣០,៧% នៅឆ្នាំ២០១៥ (ថយជាមធ្យម -១,៥%ក្នុងមួយឆ្នាំ) ហើយកាន់តែបន្តធ្លាក់ចុះដល់ ២៣,៧% នៅឆ្នាំ២០១៩ (ថយជាមធ្យម -១,៧%ក្នុងមួយឆ្នាំ)។ ដូច្នេះ គោលនយោបាយ IDP ហាក់ដូចជាមិនបានចូលរួមចំណែកពង្រឹងខ្សែច្រវាក់តម្លៃជាតិ និងបង្កើតឧស្សាហកម្មប្រតិគមន៍ (Backward Linkages)។

### ៥.២.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

លទ្ធផលនៃការវាយតម្លៃបែបគុណវិស័យ បានបង្ហាញថា ពុំមានវិធានការណាមួយក្នុង IDP ដែលបានចែងជាក់លាក់អំពីការពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុកនោះឡើយ។ សម្រាប់ជំហានបន្ទាប់នៃការអនុវត្តគោលនយោបាយ IDP រាជរដ្ឋាភិបាលគួរតែដាក់ចេញនូវវិធានការថ្មីៗ ដែលរួមចំណែកសម្រេចនូវលទ្ធផលរំពឹងទុកក្នុងអន្តរាគមន៍គោលនយោបាយមួយនេះ។

## ៥.៣. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “ បង្កើនភាពជាម្ចាស់របស់ក្រុមហ៊ុននិងសហគ្រាសក្នុងស្រុក”

### ៥.៣.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៦៤៖ ចំណែកនៃចំនួនគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី៥១% ឡើងទៅ ធៀបនឹងចំនួនគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សរុប




ប្រភពទិន្នន័យ៖ គណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

រូបភាពទី១.៦៤ បង្ហាញពីចំណែកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី៥១% ធៀបនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សរុប ដើម្បីវាយតម្លៃទំហំនៃគម្រោងវិនិយោគដែលប្រតិបត្តិការដោយវិនិយោគិនកម្ពុជា ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០២០។ ចំណែកនេះ បានកើនឡើងជាលំដាប់ពី២៩,៨% នៅឆ្នាំ២០០៥ ដល់៣៨% នៅឆ្នាំ២០០៨ ប៉ុន្តែបែរជាថយចុះយ៉ាងគំហុកនៅឆ្នាំ២០០៩ និងបន្តថយចុះរហូតដល់ ១៣,២% នៅឆ្នាំ២០១៣។ នៅឆ្នាំ២០១៤ និង ២០១៥ ចំណែកនេះបានងើបឡើងវិញក្នុងរង្វង់ ២០% ប៉ុន្តែក្រោយមកទៀត ក៏មានការឡើងចុះក្នុងរង្វង់ចន្លោះពី ១៦% ដល់ទាបជាង ៣០% ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។ ជារួម តួលេខសូចនាករនេះ គ្របដណ្តប់បានតែមួយផ្នែកនៃប្រតិបត្តិការអាជីវកម្មរបស់សហគ្រាសក្នុងប្រទេសកម្ពុជា ព្រោះសូចនាករនេះរាប់បញ្ចូលតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាប៉ុណ្ណោះ។ យ៉ាងណាក្តី តួលេខខាងលើអាចបង្ហាញបានថា កម្ពុជានៅមិនទាន់ពង្រឹងភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុកក្នុងវិស័យឧស្សាហកម្មបាននៅឡើយទេ។

រូបភាពទី១.៦៥៖ ចំណែកនៃចំនួនការងារសរុបដែលបានបង្កើតដោយសហគ្រាសបរទេសធៀបនឹងចំនួនការងារសរុប




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រូបភាពទី១.៦៥ បង្ហាញពីចំណែកនៃចំនួនការងារសរុបដែលបានបង្កើតដោយសហគ្រាសបរទេសធៀបនឹងចំនួនការងារសរុប ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩។ ចំណែកនេះបានកើនឡើងពី ៣៦,៥% នៅឆ្នាំ២០០៨ ដល់៨២,៤% នៅឆ្នាំ២០១៥ តាមអត្រាកំណើនជាមធ្យម ៦,៦ពិន្ទុភាគរយក្នុងមួយឆ្នាំ។ ក្រោយការដាក់ចេញគោលនយោបាយ IDP ចំណែកនេះបានថយចុះមកនៅត្រឹម ៦៦,៧% នៅឆ្នាំ២០១៩ (ថយជាមធ្យមប្រមាណ ៣,៩ពិន្ទុភាគរយក្នុងមួយឆ្នាំ) ដែលតួលេខនេះនៅតែស្ថិតនៅក្នុងកម្រិតមួយខ្ពស់នៅឡើយ។ យ៉ាងណាក្តី ការថមថយនៃ ចំណែកនៃការងារដែលបង្កើតដោយសហគ្រាសបរទេសនេះ ក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ IDP ឆ្លុះបញ្ចាំងឱ្យឃើញថា សហគ្រាសក្នុងស្រុកចាប់ផ្តើមចូលរួមចំណែកកាន់តែសកម្មក្នុងការបង្កើតការងារនៅកម្ពុជា។

### ៥.៣.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

លទ្ធផលនៃការវាយតម្លៃបែបគុណវិស័យ បានបង្ហាញថា ពុំមានវិធានការណាមួយក្នុងគោលនយោបាយ IDP ដែលបានចែងជាក់លាក់អំពីការបង្កើនភាពជាម្ចាស់របស់ក្រុមហ៊ុន និងសហគ្រាសក្នុងស្រុកនោះឡើយ។ សម្រាប់ជំហានបន្ទាប់នៃការអនុវត្តគោលនយោបាយ IDP រាជរដ្ឋាភិបាលគួរតែដាក់ចេញនូវវិធានការថ្មីៗ ដែលរួមចំណែកសម្រេចនូវលទ្ធផលរំពឹងទុកក្នុងអន្តរាគមន៍គោលនយោបាយមួយនេះ។

## ៥.៨. ការពិនិត្យលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកនិងនាំចេញ”

### ៥.៨.១. ការវិភាគបែបបរិមាណវិស័យលើលទ្ធផលក្នុងអន្តរាគមន៍គោលនយោបាយ

រូបភាពទី១.៦៦៖ ការនាំចេញកសិផលកែច្នៃ (ឆ្នាំ២០១៦-២០២០)




ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រូបភាពទី១.៦៦ បង្ហាញពីការនាំចេញកសិផលកែច្នៃ ដើម្បីវាយតម្លៃសមត្ថភាពរបស់កម្ពុជាក្នុងការនាំចេញផលិតផលកែច្នៃចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០។ ទំហំនាំចេញនៃកសិផលកែច្នៃបានកើនឡើងគួរឱ្យកត់សម្គាល់ពី ៥១៦,២លានដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដល់ ៨៤៥,៩លានដុល្លារអាមេរិក នៅឆ្នាំ២០២០ តាមអត្រាកំណើនជាមធ្យម ១៣,១%ក្នុងមួយឆ្នាំ។ ដូច្នេះ គោលនយោបាយ IDP បានចូលរួមចំណែកជាវិជ្ជមានដល់ការបង្កើនការនាំចេញកសិផលកែច្នៃរបស់កម្ពុជា។

### ៥.៨.២. ការវាយតម្លៃលើការរៀបចំអន្តរាគមន៍គោលនយោបាយ

គោលនយោបាយ IDP បានកំណត់វិធានការចំនួន៤ ក្នុងអន្តរាគមន៍គោលនយោបាយនេះ រួមមាន (១) *ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិកម្ម [..] ដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន*, (២) *ផ្ដល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណា ដែលបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិកម្ម*, (៣) *ដោះស្រាយបញ្ហាកស្តុភារកម្ម លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម* និង (៤) *សិក្សាកំណត់នូវមុខទំនិញអាទិភាព ដែលមានសក្ដានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើខ្សែច្រវាក់តម្លៃ*។ វិធានការទាំងនេះត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នមួយចំនួនដូចជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា។

វិធានការទី១ គឺជាវិធានការត្រៀមដែលមានគោលបំណងបង្កើតតំបន់កែច្នៃកសិឧស្សាហកម្ម ប៉ុន្តែមិនបានបញ្ជាក់ច្បាស់អំពីឧបករណ៍គោលនយោបាយ ដើម្បីបង្កើតតំបន់កែច្នៃកសិផលឡើយ។ ការបង្កើតតំបន់កសិ-ឧស្សាហកម្មកែច្នៃ នឹងផ្តល់នូវមូលដ្ឋានឧស្សាហកម្មឯកទេសដែលអាចទាក់ទាញគម្រោងវិនិយោគ ក្នុង

ការផលិតគ្រឿងសង្ហារឹម, និងកែច្នៃម្ហូបអាហារ។ ជាមួយគ្នានេះដែរ ការបង្កើនវិនិយោគបន្ថែមនៅក្នុងឧស្សាហកម្ម អាចបង្កើនតម្រូវការវត្ថុធាតុដើមដែលអាចមានប្រភពពីអ្នកផលិតក្នុងស្រុក ទាំងកសិករខ្នាតតូច និងខ្នាតពាណិជ្ជកម្ម។ ដូចនេះ វត្ថុធាតុដើមជាច្រើនអាចត្រូវបានផលិតនៅក្នុងស្រុកសម្រាប់ក្រុមហ៊ុនកែច្នៃកសិកម្ម ដើម្បីទិញយកមកប្រើប្រាស់បាន ហើយអាចផ្តល់តម្លៃបន្ថែមបម្រើដល់សេដ្ឋកិច្ចក្នុងស្រុក។

វិធានការទី២ គឺជាវិធានការច្បាស់លាស់ដោយកំណត់ពីឧបករណ៍គោលនយោបាយអំពីវិធីទាក់ទាញវិនិយោគបន្ថែមទៀតនៅក្នុងតំបន់កែច្នៃកសិកម្ម ដើម្បីបង្កើនខ្សែច្រវាក់តម្លៃជាតិ។ វិធានការគោលនយោបាយនេះមានសារៈសំខាន់សម្រាប់ការជំរុញការបង្កើតក្រុមហ៊ុនថ្មីៗឬដើម្បីលើកទឹកចិត្តឱ្យក្រុមហ៊ុនដែលមានស្រាប់ពង្រីក និងកំណត់ទីតាំងនៅក្នុងតំបន់កែច្នៃកសិកម្មក្នុងគោលបំណងធ្វើឱ្យវិនិយោគិនមកដាក់ទីតាំង ហើយទទួលបានផលវិជ្ជមានពីការវិនិយោគផ្ទាល់ក្នុងស្រុក និងបរទេសនៅក្នុងតំបន់កែច្នៃកសិកម្មនោះ។

វិធានការទី៣ ក៏ជាវិធានការដែលបានកំណត់យ៉ាងច្បាស់លាស់ផងដែរ ព្រោះបង្ហាញពីឧបករណ៍គោលនយោបាយដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុក តាមរយៈការបង្កើតយន្តការសម្របសម្រួល សម្រាប់ការនាំចេញផលិតផលកសិកម្មកែច្នៃដែលនាំឱ្យមានកំណើនសកម្មភាពច្រើនពាក់ព័ន្ធនឹងការកែច្នៃកសិកម្ម។

វិធានការទី៤ គឺជាវិធានការត្រៀម។ វិធានការនេះមានគោលបំណងជំរុញរាជរដ្ឋាភិបាលផ្តល់ការគាំទ្រជាក់ស្តែងដល់ការនាំចេញផលិតផលកែច្នៃអាទិភាព។

ការពិនិត្យលើទិដ្ឋភាពនៃការរៀបចំគោលនយោបាយ បានបង្ហាញថា វិធានការចំនួន២ រួមមាន (១) *ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិកម្ម* និង (២) *សិក្សាកំណត់នូវមុខទំនិញអាទិភាព* នៅមិនទាន់អាចផ្តល់បច្ច័យភ្លាមៗដល់ការបង្កើនការកែច្នៃកសិផលនៅឡើយទេ ព្រោះវិធានការទាំងនេះស្ថិតក្នុងដំណាក់កាលត្រៀមប៉ុណ្ណោះ។ ចំណែកឯវិធានការចំនួន២ផ្សេងទៀត ដូចជា (១) *ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិកម្ម* និង (២) *ដោះស្រាយបញ្ហាភស្តុភារកម្ម លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម ដែលផ្តោតលើការពង្រីកខ្សែច្រវាក់តម្លៃជាតិ និងការនាំចេញផលិតផលកសិកម្មកែច្នៃ* អាចរួមចំណែកបានភ្លាមៗដល់ការបង្កើនការកែច្នៃកសិផលក្នុងកម្រិតមួយតិចតួច។ ជារួម វិធានការទាំងនេះនៅមិនទាន់គ្រប់គ្រាន់ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនៅឡើយទេ។

## ភាពស៊ីចង្វាក់គ្នានៃវិធានការគោលនយោបាយ

ការវាយតម្លៃលើវិធានការទាំង៤ ដែលស្ថិតនៅក្រោមអន្តរាគមន៍គោលនយោបាយនេះ បង្ហាញឱ្យឃើញថា មានភាពស៊ីចង្វាក់គ្នារវាងវិធានការចំនួន២៖ វិធានការ *ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិកម្ម* និងវិធានការ *ដោះស្រាយបញ្ហាភស្តុភារកម្ម លុបបំបាត់ថ្លៃសេវាក្រៅផ្លូវការ និងការកែលម្អការសម្រួលពាណិជ្ជកម្ម*។ ចំពោះវិធានការទី១ គោលបំណងសំខាន់គឺទាក់ទាញក្រុមហ៊ុនបន្ថែមទៀតឱ្យវិនិយោគនៅក្នុងតំបន់កែច្នៃកសិផល តាមរយៈការផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុន ដែលអាចជាការផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដូចជាផ្តល់ហិរញ្ញប្បទាន និងកម្ចីផ្សេងៗ រួមទាំងការលើកលែងពន្ធលើប្រាក់ចំណូល ឬការបញ្ចុះអត្រាពន្ធ ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ប៉ុន្តែការលើក

ទឹកចិត្តទាំងនេះនៅមិនទាន់គ្រប់គ្រាន់ដើម្បីទាក់ទាញវិនិយោគិននោះទេ។ ការដោះស្រាយបញ្ហាកស្តុភារកម្ម ការលុបបំបាត់ថ្លៃសេវាក្រៅផ្លូវការ និងការសម្រួលពាណិជ្ជកម្ម គឺកត្តាជំរុញដ៏សំខាន់មួយទៀត តាមរយៈការផ្តល់ភាពងាយស្រួលដល់ក្រុមហ៊ុន ដូចជាធ្វើឱ្យប្រសើរឡើងនូវសេវាដឹកជញ្ជូន និងកស្តុភារកម្មប្រកបដោយស័ក្តិសិទ្ធិភាព ដើម្បីសម្រួលលំហូរផ្គត់ផ្គង់ទំនិញឱ្យបានទាន់ពេលវេលា, ហើយការលុបចោលថ្លៃសេវាក្រៅផ្លូវការ និងការសម្រួលពាណិជ្ជកម្ម នឹងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផល សម្រាប់សម្រួលដល់ប្រតិបត្តិការសកម្មភាពឧស្សាហកម្មនានា។ ដូចនេះ ការអនុវត្តវិធានការទាំងពីរ នឹងរួមចំណែកដល់ការបង្កើនការកែច្នៃកសិផលក្នុងស្រុកប្រកបដោយប្រសិទ្ធភាព។

ក្រៅពីការផ្តល់បច្ច័យបំពេញបន្ថែមឱ្យគ្នាទាំងនេះ មិនមានវិធានការណាមួយដែលមានខ្លឹមសារផ្ទុយគ្នាក្នុងអន្តរាគមន៍គោលនយោបាយនេះឡើយ។

### ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃវិធានការគោលនយោបាយ

បើពិនិត្យលើប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការរៀបចំគោលនយោបាយ យើងសង្កេតឃើញថា មិនមានករណីស្ទួនគ្នាក្នុងចំណោមវិធានការទាំង៤ នោះទេ។ ទោះយ៉ាងណានេះក្តី ការរៀបចំអន្តរាគមន៍គោលនយោបាយនេះហាក់បីដូចជានៅមានចន្លោះប្រហោងមួយចំនួន។ ដូចបានថែងខាងលើ វិធានការទាំង ២ រួមមាន (១) ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិកម្ម និង (២) សិក្សាកំណត់នូវមុខទំនិញអាទិភាព ត្រូវបានចាត់ទុកជាវិធានការត្រៀម។ ដូចនេះ ការកែសម្រួលវិធានការនេះឱ្យទៅជាវិធានការគោលនយោបាយច្បាស់លាស់ជាមួយនឹងឧបករណ៍គោលនយោបាយ គឺជាការសមស្របបំផុត ដើម្បីគាំទ្រការកែច្នៃកសិផលក្នុងស្រុកសម្រាប់បម្រើទីផ្សារក្នុងស្រុក និងការនាំចេញ។ ក្នុងន័យនេះ ដើម្បីសម្រេចលទ្ធផលរំពឹងទុកនៃអន្តរាគមន៍គោលនយោបាយនេះឱ្យកាន់តែប្រសើរ រាជរដ្ឋាភិបាលគួរពិចារណាដាក់ចេញនូវឧបករណ៍គោលនយោបាយបន្ថែម ដូចជាការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ (R&D) ជាមួយសហគ្រាស/ក្រុមហ៊ុន ដើម្បីបង្កើតផលិតផលថ្មីដែលមាននវានុវត្តន៍បច្ចេកវិទ្យា ក្នុងឧស្សាហកម្មកែច្នៃកសិផលនៅកម្ពុជា។

### ៥.៨.៣. ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ

អន្តរាគមន៍គោលនយោបាយនេះ មានវិធានការចំនួន ៤ ក្នុងនោះវិធានការចំនួន ២ ត្រូវបានចាត់ទុកជាវិធានការច្បាស់លាស់ និងវិធានការចំនួន២ទៀត គឺជាវិធានការត្រៀម។ វិធានការមួយក្នុងចំណោមវិធានការទាំងនោះ ត្រូវបានបែងចែកជាពីរអនុវិធានការគោលនយោបាយ ដើម្បីបង្កភាពងាយស្រួលដល់ការតាមដានវឌ្ឍនភាពនៃការអនុវត្ត។ ជារួម អន្តរាគមន៍គោលនយោបាយនេះ មានវិធានការចំនួន ៥ ក្នុងនោះវិធានការចំនួន៣ ត្រូវបានសម្រេចពេញលេញ និងវិធានការចំនួន២ មានភាពយឺតយ៉ាវ។

វិធានការដែលបានសម្រេចពេញលេញទាំង៣ បានរួមចំណែកដល់ការបង្កើនចំនួនសហគ្រាសកសិ-ឧស្សាហកម្មពី ៣.៣៦៨ ដល់ ៥.៧៥៤ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។ ទោះជាយ៉ាងនេះក្តី ទំហំនៃការនាំចេញផលិតផល/ទំនិញកសិ-ឧស្សាហកម្មកែច្នៃ បានថយចុះពី ២.៧២៥.២៤៤ តោន មក ២.១៤៦.៤២៤ តោន ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។

រូបភាពទី១.៦៧៖ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ “បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកនិងនាំចេញ”







យ៉ាងណាមិញ វិធានការដែលកំពុងអនុវត្ត ក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជាថវិកាគាំទ្រពីដៃគូអភិវឌ្ឍន៍នៅមានកម្រិត, ច្បាប់ស្តីពីវិនិយោគ និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសមិនទាន់ត្រូវបានអនុម័តនៅឡើយ។

ការដាក់ចេញ និងការដាក់ឱ្យអនុវត្តវិធានការក្រោមអន្តរាគមន៍គោលនយោបាយនេះ មិនទាន់អាចសម្រេចបាននូវការផ្លាស់ប្តូរដែលបានរំពឹងទុកដោយ IDP ឡើយ ទោះបីជាមានការខិតខំប្រឹងប្រែងមួយចំនួនហើយក៏ដោយ។ ប្រសិនបើកម្ពុជាចង់កាត់បន្ថយការនាំចូល និងប្រកួតប្រជែងជាមួយប្រទេសជិតខាង គួរតែមានការយកចិត្តទុកដាក់បន្ថែម និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់ភាគីពាក់ព័ន្ធក្នុងការកែប្រែវិស័យនេះ ឱ្យក្លាយជាវិស័យសក្តានុពលសម្រាប់កម្ពុជា។

# ឧបសម្ព័ន្ធទី២៖ អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងការអនុវត្តវិធានការគោលនយោបាយ IDP

## តារាងទី២.១៖ ទម្រង់គំរូនៃផែនការសកម្មភាពដែលមានលក្ខណៈពេញលេញ

| វិធានការគោលនយោបាយ | ស្ថាប័ននាំមុខអនុវត្ត | គោលបំណង និងអន្តរាគមន៍គោលនយោបាយ | ប្រភេទនៃវិធានការគោលនយោបាយ | សេចក្ដីពន្យល់វិធានការគោលនយោបាយ | លទ្ធផលរំពឹងទុកនៃវិធានការគោលនយោបាយ |
|---|---|---|---|---|---|
| ផ្ដល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិផល។ *(ឧបសម្ព័ន្ធ ឃ នៃ IDP ទំព័រទី៩)* | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា និងការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ | ការផ្ដល់ការលើកទឹកចិត្ត | កម្មវិធីលើកទឹកចិត្តនឹងផ្ដល់ជូនទាំងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស ដែលបង្កើតផលិតកម្មកែច្នៃនៅក្នុងតំបន់កែច្នៃកសិផល។ រាជរដ្ឋាភិបាល នឹងលើកលែងពន្ធប្រាក់ចំណូល ១០% សម្រាប់រយៈពេល ៥ឆ្នាំ ហើយអាចលើកលែងពន្ធដល់ ៧-៩ឆ្នាំ សម្រាប់ក្រុមហ៊ុនដែលប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក។ ព្រមទាំងលើកលែងពន្ធនាំចូលសម្រាប់គ្រឿងម៉ាស៊ីន, គ្រឿងចក្រយានយន្តដើម្បីអនុវត្តគម្រោង។ | ការផ្ដល់ជូនការលើកទឹកចិត្តនេះរំពឹងថានឹងទាក់ទាញក្រុមហ៊ុនផ្សេងៗបន្ថែមទៀតដើម្បីមកវិនិយោគក្នុងវិស័យកែច្នៃកសិផលដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក។ ការលើកទឹកចិត្តនេះរំពឹងថានឹងបង្កើនចំនួនក្រុមហ៊ុនក្នុងតំបន់កែច្នៃកសិផល និងបង្កើតប្រព័ន្ធអេកូឡូស៊ីក្នុងប្រទេសមួយសម្រាប់កសិកម្មកែច្នៃក្នុងស្រុក។ ជាមួយគ្នានេះក៏រំពឹងថានឹងរួមចំណែកដល់ការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមាផងដែរ។ |
| **សូចនាករមូលដ្ឋាន សម្រាប់វិធានការគោលនយោបាយ** | **គោលដៅសម្រាប់វិធានការគោលនយោបាយ** | **បន្ទាត់ពេលវេលានៃការអនុវត្ត** | **ថវិកា** | **ប្រភពថវិកា** | **ស្ថាប័នសហការអនុវត្ត** |
| - ១ បង្កើតតំបន់កែច្នៃកសិផល<br>- ២ មានក្រុមហ៊ុនស្ថិតនៅក្នុងតំបន់<br>- ២ភាគរយ នៃការនាំចេញផលិតផលកសិកម្មក្នុងការនាំចេញសរុប<br>- ១ ភាគរយនៃកសិផលកែច្នៃសម្រាប់ប្រើប្រាស់ក្នុងស្រុក | - ៥ បង្កើតតំបន់កែច្នៃ<br>- ២៥ ក្រុមហ៊ុនស្ថិតនៅក្នុងតំបន់<br>- ៥% នៃការនាំចេញនៃផលិតផលសិកម្មក្នុងការនាំចេញសរុប<br>- ៥% នៃផលិតផលកសិកម្មកែច្នៃសម្រាប់ប្រើប្រាស់ក្នុងស្រុក | គម្រោងនឹងចាប់ផ្ដើមក្នុងខែកក្កដា ឆ្នាំ ២០២៥<br>ចាប់ផ្ដើមការអនុវត្តក្នុងខែមករា ឆ្នាំ ២០២៦<br>ការវាយតម្លៃពាក់កណ្ដាលអាណត្តិ: ២០៣០<br>កាលបរិច្ឆេទបិទគម្រោងបញ្ចប់: ខែធ្នូ ឆ្នាំ២០៣៥ | ១០ លានដុល្លារ-អាមេរិក<br>៥០,០០០លានដុល្លារអាមេរិកបន្ថែមសម្រាប់ការងាររដ្ឋបាល, ការអនុវត្ត, ការតាមដាន និងវាយតម្លៃគម្រោង | ចំណូលពន្ធ<br><br>ថវិការជាតិ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ)<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងឧស្សាហកម្ម, វិទ្យាសាស្ត្រ,បច្ចេកវិទ្យា, និងនវានុវត្តន៍ |

តារាងទី២.២ បង្ហាញពីឧទាហរណ៍នៃប្រភេទវិធានការគោលនយោបាយចំនួន ៨ ដែលត្រូវបានរៀបចំឡើង សម្រាប់គាំទ្រដល់គោលបំណងគោលនយោបាយ, អន្តរាគមន៍គោលនយោបាយ និងក្រុមគោលដៅ។

- គោលបំណងគោលនយោបាយ៖ បង្កើនសកម្មភាពឧស្សាហកម្ម
- អន្តរាគមន៍គោលនយោបាយ៖ បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល
- ក្រុមគោលដៅ៖ ១) វិស័យម្ហូបអាហារ និង ២) សហគ្រាសធុនតូច និងមធ្យមផលិត ផលិតផលកសិកម្មដើម្បីធ្វើជាធាតុចូលទៅក្នុងវិស័យកសិផលកែច្នៃ

**តារាងទី២.២៖ ឧទាហរណ៍នៃប្រភេទវិធានការគោលនយោបាយទាំង៨**

| បទប្បញ្ញត្តិ | ការលើកទឹកចិត្ត | ព័ត៌មាន | ការគាំទ្ររបស់រដ្ឋាភិបាលជាលក្ខណៈសេវាសាធារណៈ |
|---|---|---|---|
| • ជំរុញផ្សារទំនើបឱ្យធ្វើលទ្ធកម្មក្នុងស្រុក<br>• តម្រូវការឱ្យប្រើប្រាស់ផលិតផលក្នុងស្រុក/ ជំរុញឱ្យការវិនិយោគផ្ទាល់ពីបរទេស | • កាត់បន្ថយពន្ធលក់ដូរសម្រាប់ម្ហូបអាហារផលិតក្នុងស្រុក | • បង្កើតយុទ្ធនាការទិញដូរផលិតផលក្នុងស្រុក<br>• ប្រព័ន្ធទិន្នន័យ/កម្មវិធីជួញដូរសម្រាប់ផ្គូផ្គងអ្នកផ្គត់ផ្គង់ជាមួយអ្នកផលិត<br>• សិក្ខាសាលាផ្នែកវេចខ្ចប់ និងផ្សព្វផ្សាយទីផ្សារ | • លទ្ធកម្មសាធារណៈនៃម្ហូបអាហារក្នុងស្រុក<br>• រោងចក្រកែច្នៃកសិផលគ្រប់គ្រងដោយរាជរដ្ឋាភិបាលសម្រាប់សហគ្រាសធុនតូច និងមធ្យម<br>• អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើតទំនាក់ទំនងទៅតំបន់កសិកម្មតាមខេត្ត |

តារាងទី២.៣ បង្ហាញពីធាតុសំខាន់ៗទាំង៣ មានដូចជា ក្រុមគោលដៅ, លទ្ធផលរំពឹងទុក និងមធ្យោបាយដាក់លាក់ ដែលគួរតែរំលេចក្នុងវិធានការច្បាស់លាស់នីមួយៗដូចខាងក្រោម៖

តារាងទី២.៣៖ ឧទាហរណ៍នៃវិធានការច្បាស់លាស់ និងវិធានការមិនច្បាស់លាស់

ឧទាហរណ៍នៃវិធានការច្បាស់លាស់៖

| វិធានការ | ការវាយតម្លៃ |
|---|---|
| ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមានការទាក់ទាញការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ និងបណ្តុះបណ្តាលជំនាញ និងការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម (ឧបសម្ព័ន្ធ ឃ,ទំព័រទី១) | ក្រុមគោលដៅ៖ វិស័យឯកជន<br>លទ្ធផលរំពឹងទុក៖ ធ្វើឱ្យប្រសើរឡើងនៃបរិយាកាសធុរកិច្ច, សម្រួលនីតិវិធីក្នុងការវិនិយោគ, ទាក់ទាញគម្រោងវិនិយោគដែលមានតម្លៃបន្ថែម, បង្កើតការងារ...<br>មធ្យោបាយ៖ ពិនិត្យឡើងវិញទៅលើច្បាប់ស្តីពីការវិនិយោគចាស់ និងរៀបចំច្បាប់ថ្មីស្តីពីការវិនិយោគ និងវិធានច្បាប់គាំទ្រដទៃទៀត |

ឧទាហរណ៍នៃវិធានការមិនច្បាស់លាស់ ត្រូវបានប្រែក្លាយជាវិធានការច្បាស់លាស់៖

| វិធានការ | ការវាយតម្លៃ |
| --- | --- |
| ចាត់វិធានការ និងជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្ដាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក សំដៅធានាឱ្យមានភាពទាក់ទាញ និងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិន ដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ<br>(ឧបសម្ព័ន្ធ ឃ,ទំព័រទី៣) | ក្រុមគោលដៅ៖ អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស<br>លទ្ធផលរំពឹង៖ ធានាការទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេសសម្រាប់វិនិយោគិនដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្ម,<br>មធ្យោបាយ៖ វិធានការនេះ មិនមានមធ្យាបាយច្បាស់លាស់ដើម្បីជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្ដាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាល |
| ផ្ដល់ការលើកទឹកចិត្ត/ ការលើកលែងពន្ធលើគ្រឿងសំណង់/ ការលើកលែងពន្ធរយៈពេលមួយឆ្នាំជាអប្បបរមាសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីធានាភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេសសម្រាប់វិនិយោគិនដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្ម | ក្រុមគោលដៅ៖ អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស<br>លទ្ធផលរំពឹង៖ ធានាភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេសសម្រាប់វិនិយោគិនដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្ម,<br>មធ្យោបាយ៖ ផ្ដល់ការលើកទឹកចិត្ត/ ការលើកលែងពន្ធលើគ្រឿងសំណង់/ ការលើកលែងពន្ធរយៈពេលមួយឆ្នាំជាអប្បបរមា |

## តារាងទី២.៨៖ បញ្ជីវិធានការដែលមានវិសាលភាពទូលំទូលាយ និងស្មុនគ្នា

| ល.រ | មូលបទ | វិធានការគោលនយោបាយ | លេខទំព័រក្នុង IDP |
|---|---|---|---|
| | **១. វិធានការដែលមានវិសាលភាពទូលំទូលាយ** | | |
| ១ | | រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍច្រកសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះសីហនុ ភ្នំពេញ-បាវិត និង ភ្នំពេញ-ប៉ោយប៉ែត ឱ្យក្លាយទៅជាច្រករបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវ ហាយវេស្តង់ដារអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុភារកម្ម ប្រកបដោយប្រសិទ្ធភាព | ឧបសម្ព័ន្ធ គ, ទំព័រទី១ |
| ២ | | ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្មនិងការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ឥរិយាបថវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ ជាអាទិ៍យន្តការ "គណៈកម្មការប្រឹក្សាការងារ" និង "គណៈកម្មាធិការផលិតភាពកម្ពុជា" | ឧបសម្ព័ន្ធ គ, ទំព័រទី២ |
| ៣ | | ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងស្មុនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត "ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស" សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស | ឧបសម្ព័ន្ធ ឃ, ទំព័រទី៣ |
| ៤ | | បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេសតាមរយៈការផ្តល់អាទិភាពលើការតភ្ជាប់បណ្តាញអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងភស្តុភារកម្ម ព្រមទាំងការសម្រួល និងការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៣ |

| | | | |
|---|---|---|---|
| ៥ | | រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្តោតលើខេត្ត ព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និងក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្តការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួមមាន ការកំណត់តំបន់ដីធ្លីផ្អែកលើផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ការគ្រប់គ្រងបរិស្ថានដែលជានាទីភាពនៃប្រព័ន្ធអេកូឡូស៊ី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរួមមាន អគ្គិសនី ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និងទឹកសម្អុយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេលវែង | ឧបសម្ព័ន្ធ ឃ, ទំព័រទី៤ |
| ៦ | | បន្តពង្រឹង និងលើកកម្ពស់សមត្ថភាពរដ្ឋបាល និងក្របខ័ណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស ដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជា ការកែច្នៃកសិផលសម្រាប់នាំចេញ (ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចឯកទេស ត្រូវចំណុះលើកត្តាសំខាន់ៗ ដូចជា ទីតាំងភូមិសាស្ត្រ ប្រភេទប្រតិបត្តិការអាជីវកម្ម មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ រួមទាំង អគ្គិសនី និងទឹកស្អាត និងប្រព័ន្ធភស្តុភារកម្ម ព្រមទាំងការលើកទឹកចិត្តផងដែរ) | ឧបសម្ព័ន្ធ ឃ, ទំព័រទី៦ |
| ៧ | | ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង "យន្តការបញ្ជរតែមួយ" ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខ័ណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធភស្តុភារកម្ម កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយ អាជ្ញាធរដៃគូពាក់ព័ន្ធ ដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស និងទំនិញ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១១ |
| ៨ | | បន្តពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេស ផ្លូវជាតិឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់ប្រទេសថៃ និងវៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ-សៀមរាប និងភ្នំពេញ-ក្រុងព្រះសីហនុ ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវលទ្ធភាពកសាងផ្លូវហាយវេចំពោះ ផ្លូវជាតិសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធភស្តុភារកម្មរវាងកម្ពុជា និងប្រទេសជិតខាងទៀត ជាអាទិ៍ ប្រទេសថៃ និងវៀតណាម | ឧបសម្ព័ន្ធ ឃ, ទំព័រទី២១ |
| ៩ | | កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជ និង ការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម | ឧបសម្ព័ន្ធ ឃ, ទំព័រទី២២ |

| | | | |
|---|---|---|---|
| ១០ | | ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភពហិរញ្ញវត្ថុ និងប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ជាពិសេស ពិចារណាលើលទ្ធភាពបង្កើតមូលបត្រតនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម | ឧបសម្ព័ន្ធ ឃ, ទំព័រទី២៣ |
| | **២. វិធានការដែលស្នូនគ្នា** | | |
| ១ | ផែនការមេសម្រាប់ប្រព័ន្ធភស្តុភារកម្ម | រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅ បង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះសីហនុ ភ្នំពេញ-បាវិត និង ភ្នំពេញ-ប៉ោយប៉ែត ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវហាយវេស្តង់ដារអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុ-ភារកម្ម ប្រកបដោយប្រសិទ្ធភាព | ឧបសម្ព័ន្ធ គ, ទំព័រទី១ |
| | | រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ដែលជាមូលដ្ឋានក្នុងការជួយ សម្រួលពាណិជ្ជកម្ម និងជាប្រព័ន្ធដែលមានប្រសិទ្ធភាពអាចទុកចិត្តបាន និងមានភាពប្រកួតប្រជែងខ្ពស់ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១១ |
| ២ | ការសម្រួលពាណិជ្ជកម្ម | ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង "យន្តការបញ្ជរតែមួយ" ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខ័ណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធភស្តុភារកម្ម កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយ អាជ្ញាធរដៃគូពាក់ព័ន្ធ ដែលមានភាគពួកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស និងទំនិញ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១១ |
| | | ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកែលម្អនីតិវិធី ការពង្រឹងយន្តការដឹកជញ្ជូនឆ្លងដែន ការកាត់បន្ថយថ្លៃចម្លងការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន | ឧបសម្ព័ន្ធ ឃ, ទំព័រទី១២ |
| ៣ | មាត្រាសាស្ត្រ និងស្តង់ដារ | បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារដែលជាគ្រឹះ សម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី១២ |
| | | ពង្រឹងសមត្ថភាព "**វិទ្យាស្ថានស្តង់ដារកម្ពុជា**" ក្នុងការសិក្សាស្រាវជ្រាវរៀបចំស្តង់ដារជាតិ សម្រាប់ផលិតផល សេវាកម្ម ផលិតកម្ម និងបច្ចេកទេស អនុលោមតាមស្តង់ដារតំបន់ និង អន្តរជាតិ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣ |

| | | | |
|---|---|---|---|
| | | ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ក្នុងការសិក្សាស្រាវជ្រាវរៀបចំ នីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្មតេស្តវិភាគ និងការអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ដែលបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤ |
| ៤ | ការបង្កើតសមាគមតាមអនុវិស័យ | ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង តស៊ូមតិ និងការពារសិទ្ធិប្រយោជន៍ ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៨ |
| | | ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល | ឧបសម្ព័ន្ធ ឃ, ទំព័រទី១២ |

# រូបភាពទី២.១៖ វិធានការកំពុងអនុវត្ត និងវិធានការយឺតយ៉ាវដែលតម្រូវឱ្យពន្លឿនការអនុវត្តក្នុងដំណាក់កាលទី២

## វិធានការគោលនយោបាយកំពុងអនុវត្តឱ្យពន្លឿន

បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ
*អ.គ ២.១ "សមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក និងសហគ្រាសធុនតូច និងមធ្យម"*

បន្តពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេស ផ្លូវជាតិឱ្យក្លាយជា...
*អ.គ ២.២ "ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"*

បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ-ខេត្តព្រះសីហនុ បានដាក់ឱ្យដំណើរការ....
*អ.គ ២.២ "ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"*

អភិវឌ្ឍបណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្តានុពលក្នុងការកាត់បន្ថយចំណាយឡូជីស្ទីក...
*អ.គ ២.២ "ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"*

ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយឡូជិស្ទីកកើនឡើងជាប្រចាំ...
*អ.គ ២.២ "ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនា-សម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"*

បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ...
*អ.គ ៣.៣ "ការធ្វើឱ្យមានតុល្យភាពឡើងវិញរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម"*

## វិធានការគោលនយោបាយយឺតយ៉ាវដែលតម្រូវឱ្យពន្លឿន

បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច...
*មិនមានសូចនាករគោលបានសម្រេចបានពេញលេញ និងផុតពេលវេលាកំណត់ (២០១៥)*

ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ពិសេសសំដៅរៀបចំការចុះបញ្ជី ការគ្រប់គ្រង...
*មិនមានសូចនាករគោលបានសម្រេចបានពេញលេញ និងផុតពេលវេលាកំណត់ (២០១៨)*

កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការផ្តល់សិទ្ធិចុះ...
*មិនមានសូចនាករគោលបានសម្រេចបានពេញលេញ ផុតកំណត់ (ឆ្នាំ២០២០)*

អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពហុបំណង ដែលគ្រោងអនុ...
*សូចនាករគោល ចំនួន ១សម្រេចបានពេញលេញ, និងផុតពេលវេលាកំណត់ (២០១៨)*

រៀបចំនិងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូននិងឡូជីស្ទីក ក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូន
*សូចនាករគោល ចំនួន ១ សម្រេចបានពេញលេញ, និងផុតពេលវេលាកំណត់ (២០១៨)*

ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអយមាម៉ែត "ច្បាប់សីៗ ធំបយម៉ាដេស្និចិសេស" សំដៅអភិឌ្ឍ...
*បានបញ្ចប់សូចនាករគោល ចំនួន២ និងផុតពេលវេលាកំ ត់ (២០១៥)*

កាត់បន្ថយនូវនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និងគ្មានតម្លាភាព
*បានបញ្ចប់សូចនាករគោល ចំនួន ២ និងផុតពេលវេលាកំណត់ (២០១៥)*

ពង្រឹងការប្រើប្រាស់ស្តង់ដារនីយកម្ម និងការវាយតម្លៃការទទួលស្គាល់អនុលោមភាព...
*សូចនាករគោល ចំនួន ១សម្រេចបានពេញលេញ, និងផុតពេលវេលាកំណត់ (២០២០) បច្ច័យអាចចូលរួមទៅ អ.គ ៣.៥ "ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម"*

ជំរុញនិងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម...
*បានបញ្ចប់សូចនាករគោល ចំនួន ១, ផុតកំណត់ (ឆ្នាំ២០២០), បច្ច័យអាចចូលរួមទៅ អ.គ ១.៤ " បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស"*

បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ...
*បានបញ្ចប់សូចនាករគោល ចំនួន ១, ផុតកំណត់ (ឆ្នាំ២០២០), បច្ច័យអាចចូលរួមទៅ អ.គ ៣.៥ " ការធ្វើទំនើបកម្មសហគ្រាសធុនទូច និងមធ្យម"*

លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូចនិងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត...
*សូចនាករគោល ចំនួន ១សម្រេចបានពេញលេញ, ផុតកំណត់ (ឆ្នាំ២០២០), បច្ច័យអាចចូលរួមទៅ អ.គ ៣.៥ " ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម"*

ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម
*បានបញ្ចប់សូចនាករគោល ចំនួន ១, ផុតកំណត់ (ឆ្នាំ២០២០), បច្ច័យអាចចូលរួមទៅ អ.គ ៣.៥ " ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម"*

កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជ និង ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ពិសេស ការវិភាជ...
*បានបញ្ចប់សូចនាករគោល ចំនួន ១, ផុតកំណត់ (ឆ្នាំ២០២០), បច្ច័យអាចចូលរួមទៅដល់ការអនុវត្តទាំងស្រុងនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា*

រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធឡូជីស្ទីក ដែលជាមូលដ្ឋានក្នុងការ...
*សូចនាករគោល ចំនួន ២សម្រេចបានពេញលេញ, ផុតកំណត់ (ឆ្នាំ២០២០); បច្ច័យសំខាន់ចូលរួមទៅ អ.គ ២.២ " ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់"*

ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ដោយកំណត់...
*សូចនាករគោល ចំនួន២ សម្រេចបានពេញលេញ*
*អ.គ ២.១ "សមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក និងសហគ្រាសធុនតូច និងមធ្យម"*

ពង្រឹងអភិបាលកិច្ចសាជីវកម្ម សម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌...
*សូចនាករគោល ចំនួន ២សម្រេចបានពេញលេញ, ផុតកំណត់ (ឆ្នាំ ២០២០); បច្ច័យចូលរួមទៅ អ.គ ៣.៣ " ការធ្វើឱ្យមានតុល្យភាពឡើងវិញរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូចនិងមធ្យម"*

ពិនិត្យឡើងវិញអំពីក្របខ័ណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំង...
*សូចនាករគោល ចំនួន ២សម្រេចបានពេញលេញ ផុតកំណត់ (ឆ្នាំ២០២០) បច្ច័យចូលរួមទៅ អ.គ ១.២ " បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម"*

ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ (តំបន់កែច្នៃកសិផល)
*សូចនាករគោល ចំនួន២សម្រេចបានពេញលេញ ផុតកំណត់ (ឆ្នាំ ២០២០), បច្ច័យសំខាន់ចូលរួមទៅ អ.គ ៥.៤ " បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកនិងនាំចេញ"*

# តារាងទី២.៥៖ បញ្ជីលម្អិតនៃវិធានការកំពុងអនុវត្ត និងវិធានការឃើតយ៉ាវដែលតម្រូវឱ្យពន្លឿនការអនុវត្តក្នុងដំណាក់កាលទី២

| ល.រ | វិធានការគោលនយោបាយ | សូចនាករគោលសម្រេចបាន | កាលបរិច្ឆេទគោលដៅ | ក្រសួងទទួលខុសត្រូវ | លេខទំព័រក្នុង IDP |
|---|---|---|---|---|---|
| **១. វិធានការគោលនយោបាយដែលកំពុងអនុវត្ត** | | | | | |
| ១ | បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ | គ្មាន | ២០២៥ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១០ |
| ២ | សិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម | គ្មាន | ២០២៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩ |
| ៣ | ពិនិត្យលទ្ធភាពវិនិយោគលើវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្តោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពិសេស ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិស័យអាទិភាពនីមួយៗ ដោយជ្រើសរើសអ្នកវិទ្យាសាស្ត្រ និងវិស្វករមានសមត្ថភាពជាមួយនឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប | គ្មាន | ២០២៥ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩ |
| ៤ | បង្កើតនូវមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម ដែលប្រមូលផ្តុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្លូវការដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្តាញអ៊ីនធឺណិត | ១ | ២០២៥ | ក្រសួងពាណិជ្ជកម្ម | ឧបសម្ព័ន្ធ ឃ, ទំព័រទី១០ |
| ៥ | ពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់ | ១ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី២០ |
| ៦ | បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន សម្រាប់សម្រួល និងជួយគាំទ្រប្រតិបត្តិការអាជីវកម្ម | ១ | ២០២៥ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ ឃ, ទំព័រទី២០ |
| ៧ | បន្តពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេស ផ្លូវជាតិឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់ប្រទេសថៃ និងវៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ-សៀមរាប និងភ្នំពេញ-ក្រុងព្រះសីហនុ ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវលទ្ធភាពកសាង | ១ | ២០២៥ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ ឃ, ទំព័រទី២១ |

| | | | | | |
|---|---|---|---|---|---|
| | ផ្លូវហាយវេចំពោះ ផ្លូវជាតិសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធភស្តុ-ភារកម្មរវាងកម្ពុជា និងប្រទេសជទៃទៀត ជាអាទិ៍ ប្រទេសថៃ និងវៀតណាម | | | | |
| ៨ | បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ-ខេត្តព្រះសីហនុ បានដាក់ឱ្យដំណើរការ ដើម្បីប្រែក្លាយផ្លូវដែកជាជម្រើសដឹកជញ្ជូនមួយសំខាន់ ដែលចូលរួមចំណែកធ្វើឱ្យថ្លៃដឹកជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន | ១ | ២០២៥ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ ឃ, ទំព័រទី២១ |
| ៩ | អភិវឌ្ឍបណ្ដាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្ដានុពលក្នុងការកាត់បន្ថយចំណាយភស្តុភារកម្ម ជាពិសេស សម្រាប់ការដឹកជញ្ជូនកសិផល ដោយកសាងកំពង់ផែតូចៗ ដែលអាចឱ្យនាវាដឹកជញ្ជូនចូលផ្ទុក និងផ្ទេរទំនិញនៅតាមដងទន្លេ មេគង្គស្របគ្នានឹងការសាងសង់កំពង់ផែថ្មីនៅភ្នំពេញ និងខេត្តព្រះសីហនុ ដែលនឹងសម្រួលដល់ការដឹកជញ្ជូនតាមនាវាក្នុងបរិមាណកាន់តែច្រើន | ១ | ២០២៥ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ ឃ, ទំព័រទី២១ |
| ១០ | ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយភស្តុភារកម្មកើនឡើងជាប្រចាំ ពិសេស ការកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង ដើម្បីធានាឱ្យចរាចរណ៍ប្រព្រឹត្តទៅដោយរលូន | ១ | ២០២៥ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ ឃ, ទំព័រទី២២ |
| ១១ | ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភពហិរញ្ញវត្ថុ និងប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ជាពិសេស ពិចារណាលើលទ្ធភាពបង្កើតមូលបត្រតេនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម<br>- រៀបចំឯកសារជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍទីផ្សារភាគហ៊ុននៅកម្ពុជា *(អនុវិធានការទី២)* | ១ | ២០២៥ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី២៣ |
| ១២ | ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និងការកែទម្រង់មូលនិធិ-សោធន និងវិស័យធានារ៉ាប់រង ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ<br>- ពង្រឹងយន្តការសន្សំក្នុងស្រុក តាមរយៈការអភិវឌ្ឍ និងការកែទម្រង់របបសោធន *(អនុវិធានការទី១)*<br>- ការរៀបចំអនុក្រឹត្យ ស្ដីពីការការធានារ៉ាប់រងថ្មីឡើងវិញ *(អនុវិធានការទី២)* | ១ | ២០២៥ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី២៣ |
| ១៣ | បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្ដាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្ដុំនៃសហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេសតាមរយៈការផ្ដល់អាទិភាពលើការតភ្ជាប់បណ្ដាញអគ្គិ | ២ | ២០២៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី៣ |

| | | | | | |
|---|---|---|---|---|---|
| | សនី និងការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងភស្តុភារកម្ម ព្រមទាំងការសម្រួល និងការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ | | | | |
| ១៤ | ជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង (Southern Coastal Economic Corridor) រួមមាន ខេត្តព្រះសីហនុ និងខេត្តកោះកុង ព្រមទាំងរបៀងតាមបណ្តោយផ្លូវជាតិសំខាន់ៗ ដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជា តភ្ជាប់របៀងសេដ្ឋកិច្ចកម្ពុជាទៅនឹងប្រទេសជិតខាង នៅក្នុងក្របខ័ណ្ឌនៃរបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ និងអាស៊ាន | ២ | ២០២៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី៤ |
| ១៥ | រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្តោតលើខេត្ត ព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និងក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្តការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួមមាន ការកំណត់តំបន់ដីធ្លីផ្អែកលើផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ការគ្រប់គ្រងបរិស្ថានដែលជានាទីភាពនៃប្រព័ន្ធអេកូ-ឡូស៊ី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរួមមាន អគ្គិសនី ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និងទឹកសម្អុយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេលវែង<br>- រៀបចំផែនការអភិវឌ្ឍទីប្រជុំជនខេត្តកោះកុង *(អនុវិធានការទី២)* | ២ | ២០២៥ | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៤ |
| ១៦ | ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាលពីបណ្តាប្រទេសនានាជុំវិញពិភពលោក | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៧ |
| ១៧ | ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមសម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និងទំនើបកម្មនៃខ្សែច្រវាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៧ |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញ យកផលប្រយោជន៍ពីសក្តានុពលសហគ្រាសនិងវិនិយោគបរទេសធំៗ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៨ |
| ១៩ | ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ដោយប្រើប្រាស់ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យសម្រាប់ជាមូល-ដ្ឋានវាយតម្លៃ និងជាលក្ខខណ្ឌសម្រាប់ការផ្តល់ការលើកទឹកចិត្ត និងការគាំទ្រពីរាជរដ្ឋាភិបាល | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៨ |
| ២០ | បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារដែលជាគ្រឹះ សម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១២ |
| ២១ | ជួយគាំទ្រលើកកម្ពស់សមត្ថភាពនិងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដារ ក្នុងការធានានូវ បរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងគ្រប់គ្រង | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣ |
| ២២ | ចាត់វិធានការជាក់ស្តែងក្នុងការពង្រឹងការអនុវត្តស្តង់ដារ មាត្រាសាស្ត្រ និងកម្ម-សិទ្ធិឧស្សាហកម្ម ដើម្បីប្រែក្លាយក្របខ័ណ្ឌទាំងនេះឱ្យក្លាយជាឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣ |
| ២៣ | ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់ "**មជ្ឈមណ្ឌលផលិតភាពកម្ពុជា**" សំដៅលើកកម្ពស់ផលិតភាព និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១២ |
| ២៤ | ពង្រឹងសមត្ថភាព "**វិទ្យាស្ថានស្តង់ដារកម្ពុជា**" ក្នុងការសិក្សាស្រាវជ្រាវរៀបចំស្តង់ដារជាតិ សម្រាប់ផលិតផល សេវាកម្ម ផលិតកម្ម និងបច្ចេកទេស អនុលោមតាមស្តង់ដារតំបន់ និងអន្តរជាតិ | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣ |
| ២៥ | ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិក្នុងការសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម តេស្តវិភាគ និងការអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤ |
| ២៦ | ពង្រឹងការគ្រប់គ្រងមណ្ឌលថ្មៃប្រឌិត និងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតតក្កកម្ម និងការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម | ២ | ២០២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩ |

| | | | | | |
|---|---|---|---|---|---|
| ២៧ | ធ្វើឱ្យប្រសើរឡើង និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃតំបន់សេដ្ឋកិច្ចពិសេស រួមមាន ប្រព័ន្ធផ្លូវថ្នល់ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហ-កម្ម ជាពិសេស នៅខេត្តស្វាយរៀង និងកោះកុង ដែលមានច្រកព្រំដែនអន្តរជាតិ និងខេត្តព្រះសីហនុ ដែលមានកំពង់ផែសមុទ្រអន្តរជាតិ | ២ | ២០២៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី២១ |
| **២. វិធានការគោលនយោបាយដែលមានភាពយឺតយ៉ាវ** | | | | | |
| ១ | លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករស្តង់ដារ សម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យ ក្នុងការផ្តល់ការលើកទឹកចិត្តនិងជំរុញឧត្តមានុវត្តន៍ | គ្មាន | ២០២០ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី៤ |
| ២ | ពង្រឹងនូវក្របខ័ណ្ឌ និងយន្តការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ពិសេសសំដៅរៀបចំការចុះបញ្ជី ការគ្រប់គ្រង និងការតាមដានវឌ្ឍនភាពនៃវិស័យនេះ ដែលទាក់ទាញសហគ្រាស កម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធផ្លូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់លាស់សម្រាប់រៀបចំគោលនយោបាយ គាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះមានលទ្ធភាពទទួលបានព័ត៌មានពីឥណទាន និងការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាព និងការវិនិយោគ | គ្មាន | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៧ |
| ៣ | កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធី ធ្វើកិច្ចសហប្រតិបត្តិការ ផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម | គ្មាន | ២០១៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣ |
| ៤ | បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករដែលមាន ទេពកោសល្យ ដើម្បីចម្រាញ់ឧស្សាហករ ដែលមានទេពកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករ និងសហគ្រិនវ័យក្មេង | គ្មាន | ២០១៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩ |
| ៥ | រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារ-កម្ម ក្នុងគោលដៅ បង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធ | ១ | ២០១៨ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ គ, ទំព័រទី១ |

| | | | | | |
|---|---|---|---|---|---|
| | ភស្តុភារកម្មដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះ-សីហនុ ភ្នំពេញ-បាវិត និង ភ្នំពេញ-ប៉ោយប៉ែត ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវ ហាយវេស្តង់ដារអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុភារកម្មប្រកបដោយប្រសិទ្ធភាព | | | | |
| ៦ | អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍ ក្របខណ្ឌច្បាប់ និងនិយ័តកម្ម ព្រមទាំងយន្តការគ្រប់គ្រងចាំបាច់នានា ដែលនឹងផ្តល់សិទ្ធិអំណាចនិងយុត្តាធិការពេញលេញសម្រាប់ការកៀគរទាក់ទាញ និងប្រមូលផ្តុំនូវប្រភពធនធាន បញ្ញាញាណ សកម្មភាពធុរកិច្ចនិងវិនិយោគ ដើម្បីអភិវឌ្ឍខេត្តនេះឱ្យទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយនិងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ស្របតាមទស្សនាទាននៃការអភិវឌ្ឍ ប្រកបដោយចីរភាព និងមានតុល្យភាពបរិស្ថាន ព្រមទាំងឱ្យប្រែក្លាយជាទីក្រុងឧស្សាហកម្មបៃតងអាស៊ាន នាពេលអនាគត | ១ | ២០១៨ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ គ, ទំព័រទី៣ |
| ៧ | ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូររវាងរដ្ឋ និងវិស័យឯកជន | ១ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៦ |
| ៨ | បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដោយ រដ្ឋាភិបាលផ្តល់នូវការវិភាជថវិកាសមស្រប យោងតាមតម្រូវការ និងលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ | ១ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៧ |
| ៩ | ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង តស៊ូមតិ និងការពារសិទ្ធិប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ | ១ | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៨ |
| ១០ | លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូចនិងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត | ១ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៨ |
| ១១ | ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម | ១ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៨ |

| | | | | | |
|---|---|---|---|---|---|
| ១២ | ពិចារណាបង្កើតស្ថាប័នហិរញ្ញប្បទានតាមគោលនយោបាយដែលមានកាតព្វកិច្ចផ្តល់កម្ចី ទៅឱ្យអ្នកនាំចេញដែលផលិតទំនិញនាំចេញ ក្នុងឧស្សាហកម្មអាទិភាព និងផ្តល់នូវ សេវាធានារ៉ាប់រងការនាំចេញ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាទាក់ទងនឹងការនាំចេញ | ១ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១២ |
| ១៣ | ពង្រឹងការប្រើប្រាស់ស្តង់ដារនីយកម្ម និងការវាយតម្លៃការទទួលស្គាល់អនុលោមភាព ដោយ ផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ | ១ | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣ |
| ១៤ | ជំរុញនិងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម | ១ | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩ |
| ១៥ | សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>- សហការ និងជំរុញការស្រាវជ្រាវ និងផ្តល់ការលើកទឹកចិត្តលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ *(អនុវិធានការទី២)* | ១ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩ |
| ១៦ | កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជ និង ការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម<br>- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ *(អនុវិធានការទី១)*<br>- កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេសការវិភាជ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម *(អនុវិធានការទី២)* | ១ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី២២ |
| ១៧ | ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមានការទាក់ទាញការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ និងបណ្តុះបណ្តាលជំនាញ និងការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម | ២ | ២០២០ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី១ |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ពិនិត្យឡើងវិញនិងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញ "គម្រោងវិនិយោគសក្តានុពលនិងមានគុណភាព" ដែលផ្តល់ផលវិជ្ជមាននិងតម្លៃបន្ថែមសម្រាប់ការបើកផ្លូវដល់ការអភិវឌ្ឍ និងការទាក់ទាញឧស្សាហកម្មថ្មីៗមកកម្ពុជា | ២ | ២០១៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី១ |
| ១៩ | ពិនិត្យឡើងវិញអំពីក្របខ័ណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ទាំងក្រុមហ៊ុនក្នុងស្រុក និងទាំងសហគ្រាសធុនតូច និងមធ្យម | ២ | ២០២០ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី៣ |
| ២០ | ជំរុញការបង្កើតតម្រង់ឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត "ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស" សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដាអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស | ២ | ២០១៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី៣ |
| ២១ | ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខ័ណ្ឌសកម្មភាពចាំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍសហគ្រាសទាំងនោះ | ២ | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៣ |
| ២២ | ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និងលទ្ធភាពទទួលបានហិរញ្ញប្ប-ទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យម | ២ | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៣ |
| ២៣ | ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជាតំបន់កែច្នៃ និងផលិតសង្ខារឹម តំបន់កែច្នៃផលិតសម្ភារៈពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេសដោយប្រើប្រាស់យន្តការភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជន | ២ | ២០២០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ឧបសម្ព័ន្ធ ឃ, ទំព័រទី៦ |

| | | | | | |
|---|---|---|---|---|---|
| | - រៀបចំច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា *(អនុវិធានការទី២)* | | | | |
| ២៤ | ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ (តំបន់កែច្នៃកសិផល) | ២ | ២០២០ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី៩ |
| ២៥ | កាត់បន្ថយនូវនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និងគ្មានតម្លាភាព | ២ | ២០១៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ឧបសម្ព័ន្ធ ឃ, ទំព័រទី៩ |
| ២៦ | រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ដែលជាមូលដ្ឋានក្នុងការជួយ សម្រួលពាណិជ្ជកម្ម និងជាប្រព័ន្ធដែលមានប្រសិទ្ធភាពអាចទុកចិត្តបាន និងមានភាពប្រកួតប្រជែងខ្ពស់<br>- រៀបចំផែនការអភិវឌ្ឍន៍ដឹកជញ្ជូន និងភស្តុភារកម្ម ២០២០-២០៣០ *(អនុវិធានការទី២)* | ២ | ២០២០ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ ឃ, ទំព័រទី៩ |
| ២៧ | ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង **"យន្តការបញ្ជរតែមួយ"** ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខ័ណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធភស្តុភារកម្ម កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយ អាជ្ញាធរដៃគូពាក់ព័ន្ធ ដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស និងទំនិញ | ២ | ២០២០ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ឧបសម្ព័ន្ធ ឃ, ទំព័រទី១១ |
| ២៨ | បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ មាត្រា-សាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទូលំទូលាយពីសំណាក់សហគ្រិន | ២ | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១១ |
| ២៩ | ផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវទៅលើទំនាក់ទំនងរវាងបុគ្គលិកនិយោជិត និងនិយោជក ដើម្បីកំណត់ពីបទពិសោធន៍ល្អៗក្នុងការស្វែងរកដំណោះស្រាយជាប្រព័ន្ធមួយដែលអាចបង្កើនផលិតផលសរុប ជាពិសេសការបណ្តុះបណ្តាលអាជីពក្នុងការដោះស្រាយបញ្ហារបស់កម្មករ ស្របទៅតាមច្បាប់ការងារ និងបទប្បញ្ញត្តិជាធរមាន | ២ | ២០២០ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១១ |

| | | | | | |
|---|---|---|---|---|---|
| ៣០ | ពិនិត្យ និងសម្រួលឡើងវិញនូវក្របខ័ណ្ឌនៃការអនុវត្ត ដោយសម្រួល ឬដកចេញនូវយន្តការ ទាំងឡាយណាដែលបណ្តាលឱ្យខ្វាស់គ្នារវាង នីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ | ២ | ២០២០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣ |
| ៣១ | ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាព អង្គភាព រដ្ឋាករទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និងអនុលោមតាមស្តង់ដារទឹកបរិភោគជាតិ | ២ | ២០២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ឧបសម្ព័ន្ធ ឃ, ទំព័រទី១៥ |

# ឧបសម្ព័ន្ធទី៣៖ ការវាយតម្លៃលើចរិតលក្ខណៈនៃគោលលនយោបាយ IDP

| ពណ៌កូដ | |
|---|---|
| | វិធានការច្បាស់លាស់ (៨៥) |
| | វិធានការត្រៀម (២៤) |
| | វិធានការមិនច្បាស់លាស់ (១៤) |

| គោលលបំណងគោលនយោបាយ/ ផ្នែក អន្តរាគមន៍គោលនយោបាយ | វិធានការគោលនយោបាយ | ការវាយតម្លៃ | ក្រសួងស្ថាប័ន ទទួលបន្ទុកខុសត្រូវ | ចង្អោម |
|---|---|---|---|---|
| **១. បង្កើនសកម្មភាពឧស្សាហកម្ម** | | | | |
| **១.១ បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល** | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | | |
| **១.២. បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម (១៥)**<br>**វិធានការច្បាស់លាស់ = ១០**<br>**វិធានការមិនច្បាស់លាស់ = ១**<br>**វិធានការត្រៀម = ៤** | ១.២.១. អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់ សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍ ក្របខណ្ឌ ច្បាប់ និងនិយតកម្ម ព្រមទាំងយន្តការគ្រប់គ្រង ចាំបាច់នានា ដែលនឹងផ្តល់សិទ្ធិអំណាចនិងយុត្តាធិការពេញលេញសម្រាប់ការកៀរគរ ទាក់ទាញ និងប្រមូលផ្តុំនូវប្រភពធនធាន បញ្ញាញាណ សកម្មភាពធុរកិច្ច និងវិនិយោគ ដើម្បីអភិវឌ្ឍខេត្តនេះឱ្យទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយនិងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ស្របតាមទស្សនាទាននៃការអភិវឌ្ឍ ប្រកបដោយចីរភាព និងមានតុល្យភាពបរិស្ថាន ព្រមទាំងឱ្យប្រែក្លាយជា ទីក្រុងឧស្សាហកម្មបៃតងអាស៊ាន នាពេលអនាគត | វិធានការត្រៀម<br>- ក្រុមគោលដៅ៖ វិនិយោគិន។<br>- លទ្ធផលរំពឹងទុក៖ អភិវឌ្ឍខេត្តព្រះសីហនុ ឱ្យទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ និងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍។<br>- មធ្យោបាយ៖ រៀបចំគម្រោង និងផែនការមេ ក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការរៀបចំបែបបទរដ្ឋបាលផ្សេងៗទៀត។<br>មិនមានផលជះភ្លាមៗទេ | សម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ទីស្តីការគណៈរដ្ឋមន្ត្រី<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត | |

| | | | |
|---|---|---|---|
| ១.២.២. ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមានការទាក់ទាញការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ និងបណ្តុះបណ្តាលជំនាញ និងការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិនឯកជន (ទាំងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស)។<br>- លទ្ធផលរំពឹងទុក÷ កែលម្អបរិយាកាសធុរកិច្ច, ធ្វើសាមញ្ញកម្មនីតិវិធីចុះបញ្ជីវិនិយោគ, ទាក់ទាញវិនិយោគដែលមានតម្លៃបន្ថែម, បង្កើតការងារបន្ថែម ជាដើម ដោយរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីវិនិយោគ និងក្របខណ្ឌគតិយុត្តិគាំទ្រផ្សេងៗទៀត បច្ច័យនៃវិធានការនេះគឺដើម្បីកែលម្អបរិយាកាសវិនិយោគជាទូទៅ ដើម្បីទាក់ទាញវិនិយោគដែលមានតម្លៃបន្ថែម និងបង្កើតការងារបន្ថែមទៀតសម្រាប់ប្រជាជនកម្ពុជា។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 1 |
| ១.២.៣. បន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខ័ណ្ឌគតិយុត្ត ក្របខ័ណ្ឌអភិបាលកិច្ច និងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ ពិសេស ការពង្រឹងយន្តការ “ច្រកចេញចូលតែមួយ” នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យក្លាយជាយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទាក់ទាញវិនិយោគ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក÷ បង្កើនការវិនិយោគដោយផ្តល់នូវនីតិវិធីវិនិយោគសាមញ្ញ តាមរយៈសេវាកម្មច្រកចេញចូលតែមួយនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (កអក)<br>- មធ្យោបាយ÷ វិនិយោគិនមិនចាំបាច់ទៅក្រសួងពាក់ព័ន្ធផ្សេងៗ ដើម្បីទទួលបានអាជ្ញាប័ណ្ណទេ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ | 1 |
| ១.២.៤. ពង្រឹងសមត្ថភាពស្ថាប័ន និងសមាហរណកម្មមុខងារគ្រប់គ្រង និងទាក់ទាញវិនិយោគ ជាមួយមុខងារជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចរួមនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈការរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យម ការកែទម្រង់ និងទំនើបកម្មស្ថាប័ន និងការលើកកម្ពស់សមត្ថភាពមន្រ្តី ដើម្បីប្រកប ដោយប្រសិទ្ធភាពទៅនឹងចក្ខុវិស័យនិងគោលដៅនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ភ្នាក់ងារជំរុញការវិនិយោគ។<br>- លទ្ធផលរំពឹងទុក÷ ពង្រឹងសមត្ថភាពស្ថាប័ន<br>- មធ្យោបាយ÷ តាមរយៈការជំរុញការវិនិយោគ<br>វាជាវិធានការទូទៅសម្រាប់ភ្នាក់ងារជំរុញការវិនិយោគ សម្រាប់ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីសម្រេចគួនាទីចម្បងក្នុងការជំរុញការវិនិយោគ។ ទោះជាយ៉ាងក៏ដោយ វាមានតំណភ្ជាប់ខ្សោយទៅនឹងអន្តរាគមន៍គោលនយោបាយនេះ។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 1 |

| | | | |
|---|---|---|---|
| ១.២.៥. ពង្រឹងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការ វិនិយោគ និងដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិនក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ៖ រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក៖ វិនិយោគិននឹងពេញចិត្តជាមួយនឹងសេវាកម្មដែលផ្តល់ឱ្យ ហើយមានទំនុកចិត្តកាន់តែខ្លាំងក្នុងការពង្រីកគម្រោងវិនិយោគនៅកម្ពុជា<br>- មធ្យោបាយ៖ វិនិយោគិននឹងចែករំលែកបទពិសោធន៍ល្អៗជាមួយវិនិយោគិនផ្សេងទៀតនៅពេលខាងមុខ ដើម្បីមកវិនិយោគនៅកម្ពុជា។ ការបង្កើតការិយាល័យទទួលពាក្យបណ្តឹងនានាពីវិនិយោគិន និងការប្រជុំទ្វេភាគីជាមួយវិនិយោគិននៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាប្រចាំក្នុងចំណោមយន្តការដែលមានប្រសិទ្ធិភាពក្នុងការផ្តល់សេវាថែទាំវិនិយោគ ដើម្បីដោះស្រាយកង្វល់/បញ្ហាប្រឈមរបស់វិនិយោគិន។ ដូច្នេះតាមរយៈការកែលម្អយន្តការទាំងនេះ វាវិនិយោគិននឹងពេញចិត្តជាមួយសេវាកម្មដែលបានផ្តល់ជូន ហើយនឹងមានទំនុកចិត្តកាន់តែខ្លាំងក្នុងការពង្រីកគម្រោងវិនិយោគនៅកម្ពុជា។ ការកែលម្អនេះ ក៏ផ្តល់លទ្ធភាពដល់វិនិយោគិនដែលកំពុងវិនិយោគនៅកម្ពុជា ឱ្យចែករំលែកបទពិសោធន៍ល្អៗជាមួយវិនិយោគិនផ្សេងទៀតនៅពេលខាងមុខ ដើម្បីមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 1 |
| ១.២.៦. បន្តពង្រឹងប្រសិទ្ធភាពនៃ “វេទិការាជរដ្ឋាភិបាល ជាមួយនឹងវិស័យឯកជន” ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ៖ រដ្ឋាភិបាល និងវិនិយោគិនឯកជន<br>- លទ្ធផលរំពឹងទុក៖ កសាងទំនុកចិត្ត និងដោះស្រាយបញ្ហាផ្សេងៗ<br>- មធ្យោបាយ៖ កាន់តែពេញចិត្ត និងមានទំនុកចិត្តក្នុងការពង្រីកគម្រោងវិនិយោគ។ វេទិការរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន គឺជាយន្តការមួយដែលត្រូវបានលើកកម្ពស់ដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ និងដោះស្រាយរាល់កង្វល់នានា ដែលលើកឡើងដោយវិស័យឯកជន ដើម្បីដាក់ចេញនូវវិធានការឱ្យបានទាន់ពេលវេលា ក្នុងគោលបំណងធានានូវអត្ថប្រយោជន៍សម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ការប្រកួតប្រជែងដោយយុត្តិធម៌ និងបរិយាកាសវិនិយោគប្រកបដោយភាពអំណោយផល។ នៅក្នុងបរិបទនេះ វិស័យសាធារណៈ និងវិស័យឯកជន លើកឡើងពីបញ្ហារបស់ពួកគេ និងផ្លាស់ប្តូរយោបល់ជាមួយរាជរដ្ឋាភិបាល ដើម្បីស្វែងរកដំណោះស្រាយសមស្របសម្រាប់ភាគីពាក់ព័ន្ធទាំងអស់។ ដូច្នេះតាមរយៈការកែលម្អយន្តការនេះ វិនិយោគិននឹងពេញចិត្ត និងមានទំនុកចិត្តកាន់តែខ្លាំងក្នុងការពង្រីកគម្រោងវិនិយោគរបស់ខ្លួន។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 2 |

| | | | |
|---|---|---|---|
| ១.២.៧. ពិនិត្យឡើងវិញនូវយន្តការផ្តល់ព័ត៌មានវិនិយោគ ដោយយកចិត្តដាក់លើភាពងាយស្រួលក្នុងការទទួលព័ត៌មាន ពិសេស ការកែលម្អមាតិកាព័ត៌មាន ដែលផ្អែកលើប្រតិកម្មតបនៃអ្នកប្រើប្រាស់ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក÷ ដើម្បីជួយសម្រួលដល់វិនិយោគិនឱ្យមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ ផ្តល់ការពិគ្រោះយោបល់ និងផ្តល់ជាជំនួយលើបញ្ហាដែលទាក់ទងនឹងការផ្តល់សេវាដែលបានដាក់ចេញ<br>- មធ្យោបាយ÷ រូបភាពវិជ្ជមានសម្រាប់កម្ពុជា បង្កើនការចាប់អារម្មណ៍របស់វិនិយោគិនអនាគតឱ្យមកបណ្តាក់ទុននៅកម្ពុជា។ តុទទួលភ្ញៀវនៅច្រកចេញចូលតែមួយ និងតុទទួលពាក្យបណ្តឹង ជួយសម្រួលដល់វិនិយោគិនឱ្យមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ ផ្តល់ការពិគ្រោះយោបល់ និងផ្តល់ជាជំនួយលើបញ្ហាដែលទាក់ទងនឹងការផ្តល់សេវាដែលបានដាក់ចេញ។ ការពិនិត្យឡើងវិញនូវយន្តការទាំងនេះ តាមរយៈការយកមតិយោបល់របស់វិនិយោគិន មកពិចារណា នឹងបង្ហាញថាកម្ពុជាមានបរិយាកាសវិនិយោគល្អប្រសើរ និងទាក់ទាញដែលសមស្របសម្រាប់ប្រត្តិបត្តិការធុរកិច្ច។ ការអនុវត្តដោយជោគជ័យនៃយន្តការទាំងនេះនឹងបង្កើតបានជារូបភាពវិជ្ជមានសម្រាប់កម្ពុជា ដោយបង្កើនការចាប់អារម្មណ៍វិនិយោគិនអនាគតឱ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 2 |
| ១.២.៨. ពិនិត្យឡើងវិញអំពីក្របខ័ណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ទាំងក្រុមហ៊ុនក្នុងស្រុក និងទាំងសហគ្រាសធុនតូច និងមធ្យម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក÷ ការកែសម្រួលការផ្តល់ការលើកទឹកចិត្តលើការវិនិយោគដែលមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីការវិនិយោគ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស នឹងក្លាយជាចំណុចទាក់ទាញ/ការលើកទឹកចិត្តសម្រាប់វិនិយោគិន ដើម្បីពង្រីកគម្រោងវិនិយោគរបស់ខ្លួន ឬសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីផ្លាស់ប្តូរទីតាំង/បង្កើតអាជីវកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស/ជាពិសេសតំបន់សេដ្ឋកិច្ចពិសេសសម្រាប់សហគ្រាសធុនតូចនិងមធ្យម<br>- មធ្យោបាយ÷ បង្កើនការវិនិយោគរបស់ក្រុមហ៊ុនក្នុងស្រុកនិង ក្រុមហ៊ុនបរទេស/ សហគ្រាសធុនតូចនិងមធ្យម។ ការកែសម្រួលការផ្តល់ការលើកទឹកចិត្តលើការវិនិយោគដែលមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីការវិនិយោគ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស នឹងក្លាយជាចំណុចទាក់ទាញ/ការលើកទឹកចិត្តសម្រាប់វិនិយោគិន ដើម្បីពង្រីកគម្រោងវិនិយោគរបស់ខ្លួន ឬសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីផ្លាស់ប្តូរទីតាំង/បង្កើតអាជីវកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស/ជាពិសេសតំបន់សេដ្ឋកិច្ចពិសេសសម្រាប់សហគ្រាសធុនតូចនិងមធ្យម។ នេះពិតជានឹងបង្កើនការវិនិយោគរបស់ក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស/សហគ្រាសធុនតូច និងមធ្យម។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 3 |

| | | | |
|---|---|---|---|
| ១.២.៩. ជំរុញការបង្កើតគម្រោងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត "ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស" សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ អ្នកអភិវឌ្ឍន៍តំបន់ និងវិនិយោគិនក្នុងតំបន់<br>- លទ្ធផលរំពឹងទុក÷ ការបង្កើតសួនឧស្សាហកម្មធំៗ និងចង្កោម នឹងជំរុញការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស<br>- មធ្យោបាយ÷ ផ្តល់នីតិវិធីសាមញ្ញក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ការបង្កើតសួនឧស្សាហកម្មធំៗ និងចង្កោមដែលមានការគាំទ្រយ៉ាងច្រើនពីរដ្ឋាភិបាលគឺជាលក្ខណៈសំខាន់ក្នុងការទាក់ទាញការវិនិយោគកាន់តែច្រើននៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| ១.២.១០. លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករសួល សម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យក្នុងការផ្តល់ការលើកទឹកចិត្ត និងជំរុញឧត្តមានុវត្តន៍ | វិធានការត្រៀម<br>ក្រុមគោលដៅ÷<br>លទ្ធផលរំពឹងទុក÷<br>មធ្យោបាយ÷<br>វិធានការនេះគ្រាន់តែជាវិធានការត្រៀមមួយ ខណៈដែល ក.អ.ក កំពុងតែរៀនសូត្រពីបទពិសោធន៍របស់បណ្តាប្រទេសនានាក្នុងតំបន់ អំពីរបៀបវាយតម្លៃប្រសិទ្ធភាពនៃតំបន់សេដ្ឋកិច្ចពិសេស។ សកម្មភាពនេះ គឺគ្រាន់តែជាសកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេង ដែលពុំមានបច្ច័យភ្លាមៗទៅលើតួអង្គពាក់ព័ន្ធក្នុងសេដ្ឋកិច្ចនោះទេ។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| ១.២.១១. ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ អ្នកអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស<br>- លទ្ធផលរំពឹងទុក÷ អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗដែលមានស្តង់ដារខ្ពស់<br>- មធ្យោបាយ÷ វាយតម្លៃអំពីសមិទ្ធិលទ្ធភាពក្នុងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសទាំងនោះ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន<br>ពុំមានបច្ច័យភ្លាមៗនោះទេ។ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |

| | | | | |
|---|---|---|---|---|
| | ១.២.១២. សិក្សាឡើងវិញពីប្រព័ន្ធពន្ធដារ និងពន្ធគយ ដោយប្រែក្លាយឱ្យទៅជាឧបករណ៍ប្រមូលចំណូលផង និងជាឧបករណ៍ជំរុញការអភិវឌ្ឍឧស្សាហកម្មផង | វិធានការត្រៀម<br>- ក្រុមគោលដៅ÷<br>- លទ្ធផលរំពឹងទុក÷<br>- មធ្យោបាយ÷<br>ពុំមានបច្ច័យភ្លាមៗនោះទេ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | ១.២.១៣. ជំរុញការបង្វិលសងឱ្យបានឆាប់ ឬប្រើប្រាស់ជាឥណទានយោង (Tax Credit) ស្របតាមបទប្បញ្ញត្តិពន្ធដារជាធរមាន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ អ្នកបង់ពន្ធ/ក្រុមហ៊ុន។<br>- លទ្ធផលរំពឹងទុក÷ ដើម្បីកសាងទំនុកចិត្តរបស់អ្នកជាប់ពន្ធមកលើប្រព័ន្ធពន្ធដារ ជាពិសេសពាក់ព័ន្ធនឹងការបង្វិលសងប្រាក់ពន្ធ។<br>- មធ្យោបាយ÷ តាមរយៈការប្រើបទប្បញ្ញត្តិពន្ធដែលមានស្រាប់ដើម្បីគាំទ្រយន្តការនេះ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | ១.២.១៤. បន្តអនុវត្ត “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០” ដែលជាក្របខ័ណ្ឌរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក÷ ដើម្បីកៀរគរ និងបែងចែកធនធានមកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព<br>មធ្យោបាយ÷ ជំរុញការប្រើប្រាស់ប្រាក់រៀល និងកាត់បន្ថយដុល្លាររូបនីយកម្មដើម្បីធានានូវទំនុកចិត្តរបស់វិនិយោគិនក្នុងការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។<br>យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០ គឺជាឯកសារមួយក្នុងចំណោមឯកសារសំខាន់ៗនិងទូលំទូលាយបំផុតដែលត្រូវបានអនុម័ត ដើម្បីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដែលផ្តោតទៅលើទីផ្សារ ដែលនឹងត្រូវកៀរគរ និងបែងចែកធនធានមកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ជាពិសេសដើម្បីផ្តល់ហិរញ្ញប្បទានក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ជំរុញការប្រើប្រាស់ប្រាក់រៀល និងងកាត់បន្ថយដុល្លាររូបនីយកម្ម ដើម្បីធានានូវទំនុកចិត្តរបស់វិនិយោគិនក្នុងការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ធនាគារជាតិនៃកម្ពុជា | 4 |
| | ១.២.១៥. ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភព ហិរញ្ញវត្ថុ និងប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ជាពិសេស ពិចារណាលើលទ្ធភាពបង្កើតមូលបត្ររតនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម | វិធានការមិនច្បាសលាស់<br>- ក្រុមគោលដៅ÷ រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក្ខ÷ សំខាន់សម្រាប់កម្ពុជាក្នុងការបង្កើតហិរញ្ញវត្ថុពីវិនិយោគិនទាំងក្នុងស្រុក និងបរទេស<br>- មធ្យោបាយ÷ មិនមានមធ្យោបាយជាក់លាក់ដែលបញ្ជាក់ពីមធ្យោបាយក្នុងការអនុវត្ត។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 4 |

| | | | | |
|---|---|---|---|---|
| **១.៣. បង្កើនផលិតភាពរបស់សហគ្រាស (១)**<br><br>**វិធានការច្បាស់លាស់ = ១**<br>**វិធានការមិនច្បាស់លាស់ = 0**<br>**វិធានការត្រៀម = 0** | ១.៣.១. ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់ "មជ្ឈមណ្ឌលផលិតភាពកម្ពុជា" សំដៅលើកកម្ពស់ផលិតភាព និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ៖ សហគ្រាសធុនតូច និងមធ្យម។<br>- លទ្ធផលរំពឹងទុក៖ ដើម្បីបង្កើនផលិតភាព និងលើកកម្ពស់គុណភាពសហគ្រាសធុនតូចនិងមធ្យម។<br>- មធ្យោបាយ៖ គាំទ្រ និងលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់មជ្ឈមណ្ឌលផលិតភាពជាតិកម្ពុជា តាមរយៈការពង្រឹងសមត្ថភាព និងសមត្ថកិច្ចរបស់មជ្ឈមណ្ឌលផលិតភាពជាតិកម្ពុជា គឺកាន់តែមានសមត្ថភាពក្នុងការផ្តល់ការគាំទ្រដល់សគ្រាសធុនតូចនិងមធ្យមក្នុងការបង្កើនផលិតភាពរបស់សហគ្រាស។<br>វិធានការនេះមានទំនាក់ទំនងប្រយោល/ខ្សោយទៅនឹងអន្តរាគមន៍គោលនយោបាយ។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| **១.៤. បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស (២)**<br><br>**វិធានការច្បាស់លាស់ = ១**<br>**វិធានការមិនច្បាស់លាស់ = ១**<br>**វិធានការត្រៀម = 0** | ១.៤.១. ជំរុញនិងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ៖ សហគ្រាសវិស័យកម្មន្តសាល និងផ្នែកសិប្បកម្ម<br>- លទ្ធផលរំពឹងទុក៖ ជំរុញនិងលើកទឹកចិត្តដល់ការផ្ទេរបច្ចេកវិទ្យាថ្មីៗ<br>- មធ្យោបាយ៖ មិនបានចង្អុលបង្ហាញឱ្យច្បាស់លាស់ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ១.៤.២. ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាលពីបណ្តាប្រទេសនានាជុំវិញពិភពលោក | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍និង សហគ្រាសធុនតូចនិងមធ្យមនៅក្នុងស្រុក។<br>- លទ្ធផលរំពឹងទុក៖ បង្កើនសមត្ថភាពក្នុងការផ្ទេរបច្ចេកវិទ្យា<br>- មធ្យោបាយ៖ ដំណើរទស្សនកិច្ចសិក្សា និងបង្កើនសមត្ថភាពបច្ចេកវិទ្យាពីបណ្តាប្រទេសនានាដែលមានការអនុវត្តល្អៗរួចមកហើយ<br>ក្រុមគោលដៅនឹងអាចចាប់យកបច្ចេកវិទ្យា និងដឹងពីវិធីសាស្ត្រក្នុងការផ្ទេរចំណេះដឹងទៅអ្នកដទៃទៀតនិងអាចយកមកប្រើប្រាស់នៅក្នុងការអនុវត្តរបស់ពួកគេ។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| **២. បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម** | | | | |

| | | | | |
|---|---|---|---|---|
| **២.១. បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក (៣)**<br><br>**វិធានការច្បាស់លាស់ = ២**<br>**វិធានការមិនច្បាស់លាស់ = 0**<br>**វិធានការត្រៀម = ១** | ២.២.១. ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខ័ណ្ឌសកម្មភាពចាំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍន៍ សហគ្រាសទាំងនោះ | វិធានការត្រៀម<br>- ក្រុមគោលដៅ: ÷ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ ផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម<br>- មធ្យោបាយ÷ កំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខ័ណ្ឌសកម្មភាពចាំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍន៍ សហគ្រាសទាំងនោះ។<br>មិនមានផលជះភ្លាមៗទេ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងពាណិជ្ជកម្ម | |
| | ២.១.២. បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិនក្នុងវិស័យកែច្នៃកសិផល<br>- លទ្ធផលរំពឹងទុក÷ បង្កើនការអភិវឌ្ឍកសិផលសម្រាប់នាំចេញ ដោយប្រើប្រាស់បច្ចេកវិទ្យាកសិកម្មកែច្នៃ<br>- មធ្យោបាយ÷ ផ្តល់មូលនិធិដល់ក្រុមហ៊ុននៅក្នុងវិស័យកែច្នៃកសិផល (មិនមានព័ត៌មានលម្អិត)។<br>ជាមួយនឹងកញ្ចប់មូលនិធិនេះ វិនិយោគិននឹងអាចពង្រីក និងធ្វើពិពិធកម្មកសិផលកែច្នៃសម្រាប់នាំចេញ និងអភិវឌ្ឍបច្ចេកទេស ដោយប្រើប្រាស់បច្ចេកវិទ្យាកសិកម្មកែច្នៃ។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | |
| | ២.១.៣. ជំរុញការបង្កើតសមាគមតាមអនុវិស័យ នីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ ចែករំលែកចំណេះដឹងក្នុងចំណោមសហគ្រាសធុនតូចនិងមធ្យម និងទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល<br>- មធ្យោបាយ÷ បង្កើតសមាគមតាមអនុវិស័យ<br>នៅពេលសហគ្រាសធុនតូចនិងមធ្យមទទួលបានការចែករំលែកចំណេះដឹងនិងមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល សហគ្រាសអាចពង្រឹងសមត្ថភាពរបស់ខ្លួន ដូច្នេះសហគ្រាសអាចបង្កើនការនាំចេញផលិតផលរបស់ខ្លួន។ | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | | |
|---|---|---|---|---|
| **២.២. ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់ (២១)**<br><br>**វិធានការច្បាស់លាស់ = ១២**<br>**វិធានការមិនច្បាស់លាស់= ៣**<br>**វិធានការត្រៀម = ៦** | ២.២.១. រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់ វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្តនិងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ អ្នកប្រើប្រាស់សម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម<br>- លទ្ធផលរំពឹងទុក÷ តម្លៃអគ្គិសនីទាបជាមួយនឹងការផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព<br>- មធ្យោបាយ÷ រៀបចំ និងអនុវត្តផែនការដោយធានាពីនិរន្តរភាពនៃប្រភពថាមពល តាមរយៈការសាងសង់រោងចក្រអគ្គិសនី និងទិញអគ្គិសនីពីប្រទេសជិតខាង<br>តម្លៃអគ្គិសនីទាបនាំឱ្យតម្លៃផលិតកម្មទាប។ | - ក្រសួងរ៉ែនិងថាមពល<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- ក្រុមហ៊ុនអគ្គិសនីកម្ពុជា | |
| | ២.២.២. រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅ បង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធភស្តុភារកម្ម ដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ច សំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះសីហនុ ភ្នំពេញ-បាវិត និង ភ្នំពេញ-ប៉ោយប៉ែត ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវ ហាយវេស្តង់ដារអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុភារកម្ម ប្រកបដោយប្រសិទ្ធភាព | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ តម្លៃដឹកជញ្ជូន និងភស្តុភារកម្មទាប<br>- មធ្យោបាយ÷ រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម (ផ្លូវថ្នល់, មណ្ឌល/មជ្ឈមណ្ឌលភស្តុភាកម្ម ។ល។ អាចរកមើលផែនការមេ)<br>តម្លៃដឹកជញ្ជូន និងភស្តុភារកម្មទាប នាំឱ្យតម្លៃលើប្រតិបត្តិការអាជីវកម្មចុះទាប | សម្របសម្រួលដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងស្ថាប័នចូលរួម<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| | ២.២.៣. ចាត់វិធានការ និងជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេសដែលបានទទួល គោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក សំដៅ ធានាឱ្យមានភាពទាក់ទាញ និងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិន ដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ អ្នកអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស<br>- លទ្ធផលរំពឹងទុក÷ ធានាឱ្យមានភាពទាក់ទាញតំបន់សេដ្ឋកិច្ចពិសេស និងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិន ដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ<br>- មធ្យោបាយ÷ មិនមានមធ្យោបាយច្បាស់លាស់ដើម្បីជំរុញឱ្យមានការចូលរួមកាន់តែសកម្មពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបរវត្តនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |

| | | | |
|---|---|---|---|
| ២.២.៤. ជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង (Southern Coastal Economic Corridor) រួមមាន ខេត្តព្រះសីហនុ និងខេត្តកោះកុង ព្រមទាំងរបៀងតាមបណ្តោយផ្លូវជាតិសំខាន់ៗដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជា តភ្ជាប់របៀងសេដ្ឋកិច្ចកម្ពុជាទៅនឹងប្រទេសជិតខាង នៅក្នុងក្របខ័ណ្ឌនៃរបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ និងអាស៊ាន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ / អ្នកទទួលផល÷ ក្រុមហ៊ុននានា<br>- លទ្ធផលរំពឹងទុក÷ សម្រួលដល់ការដឹកជញ្ជូនក្នុងប្រទេស និងនាំចេញទំនិញទៅកាន់ប្រទេសជិតខាង។<br>- មធ្យោបាយ÷ កសាងផ្លូវនៅតាមច្រករបៀងឧស្សាហកម្ម (មិនទាន់មានព័ត៌មានអំពីផែនការសកម្មភាពច្បាស់លាស់នៅឡើយទេ)។<br>ការតភ្ជាប់កាន់តែងាយស្រួលដល់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក និងក្នុងតំបន់ នឹងធ្វើឱ្យបរិយាកាសអំណោយផលសម្រាប់វិនិយោគិន ដើម្បីពង្រីកនិងធ្វើពិពិធកម្មទីផ្សារនិងនាំចេញផលិតផល។ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ | |
| ២.២.៥. រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្តោតលើខេត្ត ព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និងក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្តការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួមមាន ការកំណត់តំបន់ដីធ្លីផ្អែកលើផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ការគ្រប់គ្រងបរិស្ថានដែលធានាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរួមមាន អគ្គិសនី ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និងទឹកសម្អុយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍរយៈពេលវែង | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ ការបន្សាំទីប្រជុំជន / ទីក្រុងទៅនឹងការអភិវឌ្ឍឧស្សាហកម្មក្នុងតំបន់<br>- មធ្យោបាយ÷ រៀបចំផែនការអភិវឌ្ឍទីប្រជុំជន / ទីក្រុងដោយផ្តោតលើខេត្តព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និងក្រុងប៉ោយប៉ែត។<br>មិនមានបច្ច័យភ្លាមៗទេ។ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសាធារណការនិងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងពាក់ព័ន្ធផ្សេងទៀត | |
| ២.២.៦. អភិវឌ្ឍតំបន់ជុំវិញទីក្រុងភ្នំពេញឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ដោយបែងចែកដាច់រវាងតំបន់ឧស្សាហកម្ម និងតំបន់និវេសនដ្ឋាន ឬទីប្រជុំជន រួមទាំងផែនការរយៈពេលវែងសម្រាប់ប្រែក្លាយទីក្រុងភ្នំពេញទៅជាមជ្ឈមណ្ឌលរដ្ឋបាល ឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ វិស័យឯកជន។<br>- លទ្ធផលរំពឹងទុក÷ ការបន្សាំទីក្រុងភ្នំពេញទៅនឹងការផ្លាស់ប្តូរសេដ្ឋកិច្ច/ឧស្សាហកម្ម។<br>- មធ្យោបាយ÷ អភិវឌ្ឍទីប្រជុំជន/ ផែនការប្រើប្រាស់ដីធ្លី ដោយបែងចែកតំបន់ឧស្សាហកម្ម។<br>មិនមានបច្ច័យភ្លាមៗទេ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់<br>-ក្រសួងមហាផ្ទៃ/ សាលារាជធានីភ្នំពេញ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសាធារណការនិងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត | |

| | | | |
|---|---|---|---|
| ២.២.៧. បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបរិវត្ត រួមមាន ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍ជាដើម សំដៅបម្រើឱ្យគោលដៅឧស្សាហកម្ម ពិសេសការបោះទីតាំងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍប៉ូលឧស្សាហកម្ម និងការប្រែក្លាយតំបន់ទីប្រជុំជន/ទីក្រុងជាមជ្ឈមណ្ឌលឧស្សាហកម្មជាតិ ស្របតាម ផែនការរៀបចំដែនដី នគរូបនីយកម្ម និងផែនការប្រើប្រាស់ដី | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិនតំបន់<br>- លទ្ធផលរំពឹងទុក÷ បង្កើតចង្កោមឧស្សាហកម្ម និងប្រែក្លាយតំបន់ទីប្រជុំជនឱ្យទៅជាមជ្ឈមណ្ឌលឧស្សាហកម្មជាតិ<br>- មធ្យោបាយ÷ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបរិវត្ត រួមមាន ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស<br>បទប្បញ្ញត្តិបន្ថែមនៃទំនិញសាធារណៈដូចជា ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស នឹងកាត់បន្ថយថ្លៃដើមផលិតកម្ម និងថ្លៃដឹកជញ្ជូន សម្រាប់វិនិយោគិនតំបន់ និងអាចធ្វើឱ្យមានឥទ្ធិពលជាចង្កោមនៅក្នុងតំបន់។ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងរ៉ែនិងថាមពល<br>-ក្រសួងសាធារណៈការនិងដឹកជញ្ជូន<br>-ក្រសួង/ស្ថាប័នពាក់ព័ន្ធផ្សេងទៀត | |
| ២.២.៨. រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ដែលជាមូលដ្ឋានក្នុងការជួយ សម្រួលពាណិជ្ជកម្ម និងជាប្រព័ន្ធដែលមានប្រសិទ្ធភាពអាចទុកចិត្តបាន និងមានភាពប្រកួតប្រជែងខ្ពស់ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ បង្កើតឱ្យថ្នាលដែលមានប្រសិទ្ធភាព អាចទុកចិត្តបាន និងមានភាពប្រកួតប្រជែងខ្ពស់ ដែលជាមូលដ្ឋានក្នុងការជួយសម្រួលពាណិជ្ជកម្ម ។<br>- មធ្យោបាយ÷ រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម។<br>មិនមានបច្ច័យភ្លាមៗទេ។ | ក្រសួងសាធារណៈការនិងដឹងជញ្ជូន<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| ២.២.៩. ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង "យន្តការបញ្ចតែមួយ" ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខ័ណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធភស្តុភារកម្ម កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយ អាជ្ញាធរដៃគូពាក់ព័ន្ធ ដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស និងទំនិញ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ វិស័យសាធារណៈ<br>- លទ្ធផលរំពឹងទុក÷ កែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ<br>- មធ្យោបាយ÷ ផ្តោតជាពិសេសលើការអភិវឌ្ឍក្របខណ្ឌស្ថាប័នទាក់ទងនឹងការសម្រួលការដឹកជញ្ជូន<br>មិនមានបច្ច័យភ្លាមៗទេ។ | -ក្រសួងសាធារណៈការនិងដឹងជញ្ជូន<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| ២.២.១០. បង្កើតយន្តការសម្របសម្រួលការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវអាកាស និងកំពង់ផែ) ដោយផ្សារភ្ជាប់ទៅនឹងតំបន់គោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យសាធារណៈ<br>- លទ្ធផលរំពឹងទុក÷ កែលម្អនូវការតភ្ជាប់សម្រាប់តំបន់ឧស្សាហកម្មគោលដៅ។<br>- មធ្យោបាយ÷ បង្កើតយន្តការសម្របសម្រួល? (កង្វះព័ត៌មានដែលអាចរកបាន មន្ត្រីនៃក្រសួងសាធារណៈការ និងដឹកជញ្ជូន ក៏មិនបានដឹងព័ត៌មានច្បាស់លាស់)<br>មិនមានបច្ច័យភ្លាមៗទេ។ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | |

| | | | |
|---|---|---|---|
| ២.២.១១. ពិនិត្យតម្រង់ការផ្គត់ផ្គង់ថាមពលទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់ផ្គង់ចរន្តអគ្គិសនីស្របតាមតម្រូវការ និងមានស្ថិរភាពបំផុត ដែលអនុញ្ញាតឱ្យរោងចក្រ អាចគ្រោងផលិតកម្មខ្លួនប្រកបដោយប្រសិទ្ធភាព | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុននៅក្នុងតំបន់ផលិតកម្មសំខាន់ៗ (តំបន់ប៉ូលសេដ្ឋកិច្ច រួមមាន តំបន់រោងចក្រ តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស)<br>- លទ្ធផលរំពឹងទុក÷ ផ្តល់នូវការផ្គត់ផ្គង់ថាមពលស្របតាមតម្រូវការ និងមានស្ថិរភាពបំផុត នៅក្នុងតំបន់ផលិតកម្មសំខាន់ៗ។<br>- មធ្យោបាយ: ការត្រួតពិនិត្យតាមដាន និងដោះស្រាយបញ្ហាដាច់ចរន្ត និងផ្គត់ផ្គង់យ៉ាងទៀងទាត់ ពីក្រុមការងារបច្ចេកទេស កែលម្អនូវគុណភាពបណ្តាញអគ្គិសនី និងសាងសង់ខ្សែបណ្តាញមេទៅបណ្តាទីតាំងសំខាន់ៗទាំងនោះ។<br>ជាមួយនឹងការផ្គត់ផ្គង់ថាមពលប្រកបដោយប្រសិទ្ធភាពនិងស្ថិរភាព ក្រុមហ៊ុនឧស្សាហកម្ម អាចដំណើរការគ្រឿងម៉ាស៊ីន ឬឧបករណ៍ដោយប្រើប្រាស់អគ្គិសនីកាន់តែមានប្រសិទ្ធភាពក្នុងផលិតកម្មរបស់ក្រុមហ៊ុន។ | -ក្រសួងរ៉ែនិងថាមពល<br>-អាជ្ញាធរអគ្គិសនីកម្ពុជា<br>-ក្រុមហ៊ុនអគ្គិសនីកម្ពុជា | |
| ២.២.១២. អនុវត្តគម្រោងកសាងស្ថានីយផលិតអគ្គិសនីដែលបានគ្រោង និងកំពុងបន្តអនុវត្តឱ្យទាន់ពេលវេលា ដើម្បីបំពេញកង្វះខាតថាមពលអគ្គិសនីនៅឆ្នាំ២០២០ រួមទាំងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងគុណភាពនៃការបញ្ជូនថាមពល | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ សម្រេចបាននូវស្ថិរភាពនៃការផ្គត់ផ្គង់ថាមពល និងតម្លៃអគ្គិសនីទាប និងការបញ្ចុះតម្លៃអគ្គិសនីតាមផែនការ<br>- មធ្យោបាយ÷ គម្រោងកសាងស្ថានីយផលិតអគ្គិសនី<br>ស្ថានីយអគ្គិសនីដែលបានសាងសង់ និងដាក់ឱ្យដំណើរការស្ថានីយផលិតអគ្គិសនីទាន់ពេលវេលាដោយផ្គត់ផ្គង់តាមតម្រូវការប្រើប្រាស់ និងសាងសង់ខ្សែបណ្តាញបញ្ជូន អនុស្ថានីយអគ្គិសនី និងខ្សែបណ្តាញចែកចាយដែលបង្កើនប្រសិទ្ធភាព និងស្ថិរភាពផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់។ | -ក្រសួងរ៉ែនិងថាមពល<br>-អាជ្ញាធរអគ្គិសនីកម្ពុជា<br>-ក្រុមហ៊ុនអគ្គិសនីកម្ពុជា | |
| ២.២.១៣. ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងផែនការអភិវឌ្ឍវិស័យ ថាមពល ធៀបនឹងចក្ខុវិស័យថ្មីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្ម រួមទាំងពិនិត្យឡើងវិញនូវជម្រើសក្នុងការផ្គត់ផ្គង់ថាមពល ដែលមានសមត្ថភាពគ្រប់គ្រាន់ ជាពិសេស សម្រាប់ផ្គត់ផ្គង់តំបន់ឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុននៅក្នុងតំបន់ឧស្សាហកម្មសំខាន់ៗ<br>- លទ្ធផលរំពឹងទុក÷ ធានានូវសមត្ថភាពគ្រប់គ្រាន់នៃការផ្គត់ផ្គង់ថាមពលដល់តំបន់ឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ<br>- មធ្យោបាយ÷ ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងជម្រើសក្នុងការផ្គត់ផ្គង់ថាមពលមិនមានបច្ច័យភ្លាមៗទេ។ | -ក្រសួងរ៉ែនិងថាមពល<br>-អាជ្ញាធរអគ្គិសនីកម្ពុជា<br>-ក្រុមហ៊ុនអគ្គិសនីកម្ពុជា | |

| | | | |
|---|---|---|---|
| ២.២.១៤. បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបវន្ត និងកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន សម្រាប់សម្រួល និងជួយគាំទ្រប្រតិបត្តិការអាជីវកម្ម | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបវន្ត<br>- មធ្យោបាយ÷ មិនមានវិធីសាស្ត្រជាក់លាក់ បង្ហាញពីរបៀបបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបវន្ត តាមរយៈការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធរបវន្ត ដូចជាទំនិញសាធារណៈ សហគ្រាសអាជីវកម្មអាចទទួលបានអត្ថប្រយោជន៍ពីការកាត់បន្ថយថ្លៃដឹកជញ្ជូនទំនិញ ជាពិសេសជាមួយនឹងការកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូនផងដែរ។ | -ក្រសួងសាធារណៈការនិងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| ២.២.១៥. ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាព អង្គភាព រដ្ឋាករទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និងអនុលោមតាមស្តង់ដារបរិភោគទឹកជាតិ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស<br>- មធ្យោបាយ÷ បង្កើនសមត្ថភាពរបស់អង្គភាពផ្គត់ផ្គង់ទឹក (កង្វះព័ត៌មានដែលអាចរកបាន) (សមត្ថភាពរបស់ក្រុមហ៊ុនរដ្ឋ និងឯកជន?)<br>ជាមួយនឹងការបង្កើនសមត្ថភាពរបស់អង្គភាពផ្គត់ផ្គង់ទឹករដ្ឋ និងឯកជន ទឹកដែលមានគុណភាពស្តង់ដារក្នុងបរិមាណកាន់តែច្រើន អាចត្រូវបានចែកចាយតាមផ្ទះ និងឧស្សាហកម្មនៅក្នុងតំបន់ទីប្រជុំជន និងតំបន់ឧស្សាហកម្មគោលដៅ។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ២.២.១៦. បន្តពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេស ផ្លូវជាតិឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់ប្រទេសថៃ និងវៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ-សៀមរាប និងភ្នំពេញ-ក្រុងព្រះសីហនុ ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវលទ្ធភាពកសាងផ្លូវហាយវ៉េចំពោះ ផ្លូវជាតិសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធភស្តុភារកម្មរវាងកម្ពុជា និងប្រទេសដទៃទៀត ជាអាទិ៍ ប្រទេសថៃ និងវៀតណាម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ ពង្រឹងសមត្ថភាពប្រព័ន្ធភស្តុភារកម្មរវាងកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាម<br>- មធ្យោបាយ÷ បន្តពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ជាពិសេសពង្រីកផ្លូវជាតិនៅតាមប៉ូលសេដ្ឋកិច្ចសំខាន់ៗ ដែលតភ្ជាប់កម្ពុជាទៅប្រទេសជិតខាង ប្រទេសថៃ និងវៀតណាម<br>ប្រព័ន្ធផ្លូវថ្នល់ដែលបានកែលម្អគឺអាចធ្វើឱ្យការដឹកជញ្ជូនទំនិញកាន់តែរលូន និងមានប្រសិទ្ធិភាពពីកន្លែងផលិតកម្មឧស្សាហកម្មមួយទៅកន្លែងមួយផ្សេងទៀតនៅក្នុងប្រទេស និងជាពិសេសជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនរវាងកម្ពុជា និងប្រទេសជិតខាង ប្រទេសថៃនិងវៀតណាម។ | -ក្រសួងសាធារណៈការនិងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |

| | | | |
|---|---|---|---|
| ២.២.១៧. ធ្វើឱ្យប្រសើរឡើង និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃតំបន់សេដ្ឋកិច្ចពិសេស រួមមាន ប្រព័ន្ធផ្លូវថ្នល់ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មជាពិសេស នៅខេត្តស្វាយរៀង និងកោះកុង ដែលមានច្រកព្រំដែនអន្តរជាតិ និងខេត្តព្រះសីហនុ ដែលមានកំពង់ផែ សមុទ្រអន្តរជាតិ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិននៅតំបន់សេដ្ឋកិច្ចពិសេសដែលស្ថិតនៅក្នុងខេត្តស្វាយរៀង ខេត្តកោះកុង និងខេត្តព្រះសីហនុ<br>- លទ្ធផលរំពឹងទុក÷ ជំរុញកំណើនសកម្មភាពឧស្សាហកម្មនៅក្នុងខេត្តគោលដៅដូចជាខេត្តស្វាយរៀង ខេត្តកោះកុង និងខេត្តព្រះសីហនុ<br>- មធ្យោបាយ÷ ធ្វើឱ្យប្រសើរឡើង និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រដល់តំបន់សេដ្ឋកិច្ចពិសេស រួមទាំងប្រព័ន្ធផ្លូវថ្នល់ ហេដ្ឋារចនាសម្ព័ន្ធដែលបានធ្វើឱ្យប្រសើរឡើងដែលរួមបញ្ចូលប្រព័ន្ធផ្លូវថ្នល់ដែលល្អសមរម្យជាងមុន នឹងធ្វើឱ្យការដឹកជញ្ជូនទំនិញមានប្រសិទ្ធភាពនៅតំបន់សេដ្ឋកិច្ចពិសេស ក្នុងខេត្តទាំងបីនេះ ឈានដល់ទីផ្សារគោលដៅ ក៏ដូចជាការដឹកជញ្ជូនវត្ថុធាតុដើមទាន់ពេលវេលាសម្រាប់ផលិតកម្មឧស្សាហកម្មទៅតំបន់សេដ្ឋកិច្ចពិសេស។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងសាធារណការនិងដឹកជញ្ជូន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | |
| ២.២.១៨. បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ-ខេត្តព្រះសីហនុបានដាក់ឱ្យដំណើរការ ដើម្បីប្រែក្លាយផ្លូវដែកជាជម្រើសដឹកជញ្ជូនមួយសំខាន់ ដែលចូលរួមចំណែកធ្វើឱ្យថ្លៃដឹកជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ ប្រែក្លាយប្រព័ន្ធផ្លូវដែកដែលជាមធ្យោបាយដឹកជញ្ជូនមួយសំខាន់ ដែលនឹងចូលរួមចំណែកថ្លៃដឹកជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន<br>- មធ្យោបាយ÷ បន្តអភិវឌ្ឍប្រព័ន្ធផ្លូវដែកនៅកម្ពុជា<br>ប្រព័ន្ធផ្លូវដែកដែលមានភាពប្រសើរឡើងនឹងផ្តល់នូវមធ្យោបាយនៃការដឹកជញ្ជូនជំនួសប្រព័ន្ធផ្លូវថ្នល់ សម្រាប់ការដឹកជញ្ជូនទំនិញប្រកបដោយប្រសិទ្ធភាពដោយមិនចាំបាច់ប្រឈមនឹងការកកស្ទះចរាចរណ៍ញឹកញាប់។ | ក្រសួងសាធារណការនិងដឹកជញ្ជូន | |

| | | | | |
|---|---|---|---|---|
| | ២.២.១៩. អភិវឌ្ឍបណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្តានុពលក្នុងការកាត់បន្ថយចំណាយភស្តុភារកម្ម ជាពិសេស សម្រាប់ការដឹកជញ្ជូនកសិផល ដោយកសាងកំពង់ផែតូចៗ ដែលអាចឱ្យនាវាដឹកជញ្ជូនចូលផ្ទុក និងផ្ទេរទំនិញនៅតាមដងទន្លេ មេគង្គ ស្របគ្នានឹងការសាងសង់កំពង់ផែថ្មីនៅភ្នំពេញ និងខេត្តព្រះសីហនុ ដែលនឹងសម្រួលដល់ការដឹកជញ្ជូនតាមនាវាក្នុងបរិមាណកាន់តែច្រើន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ កាត់បន្ថយចំណាយភស្តុភារកម្ម ងាយស្រួលក្នុងការចូលផ្ទុកនិងផ្ទេរទំនិញ និងសម្រួលដល់ការដឹកជញ្ជូនតាមនាវាក្នុងបរិមាណកាន់តែច្រើន<br>- មធ្យោបាយ÷ អភិវឌ្ឍបណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ ជាពិសេសកំពង់ផែតូចៗ នៅតាមដងទន្លេមេគង្គ និងសាងសង់កំពង់ផែថ្មីនៅភ្នំពេញនិងខេត្តព្រះសីហនុ<br>ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទន្លេដែលមានភាពល្អប្រសើរ រួមទាំងកំពង់ផែ ដែលត្រូវបានសាងសង់ អាចកែប្រែការដឹកជញ្ជូនតាមផ្លូវទឹក មកជាការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពជាងមុន ដែលមានសមត្ថភាពដោះស្រាយការដឹកជញ្ជូនទំនិញ ក្នុងបរិមាណច្រើនដោយចំណាយតិចជាងមុន។ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | |
| | ២.២.២០. ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយភស្តុភារកម្មកើនឡើងជាប្រចាំ ពិសេស ការកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង ដើម្បីធានា<br>ឱ្យចរាចរប្រព្រឹត្តទៅដោយរលូន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ ដើម្បីបន្ថយការចំណាយភស្តុភាកម្ម<br>- មធ្យោបាយ÷ ការកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង<br>ផ្លូវក្រវាត់ក្រុងនឹងផ្តល់ជម្រើសផ្លូវច្រើន សម្រាប់រថយន្តដឹកទំនិញធុនធំទៅមករោងចក្រ ដែលមានទីតាំងនៅជាយក្រុងភ្នំពេញ អនុញ្ញាតឱ្យរថយន្តដឹកទំនិញធុនធំ ដឹកជញ្ជូនទំនិញប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា និងជៀសវាងបង្កការកកស្ទះចរាចរណ៍នៅលើផ្លូវជាតិ។ | -ក្រសួងសាធារណៈការនិងដឹកជញ្ជូន<br>-សាលាក្រុងភ្នំពេញ | |
| | ២.២.២១. ពិនិត្យលទ្ធភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធដែលអាចបន្ធូរបន្ទុកវិនិយោគសាធារណជន | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ បន្ធូរបន្ទុកវិនិយោគសាធារណជនសម្រាប់ការអភិវឌ្ឍ<br>ហេដ្ឋារចនាសម្ព័ន្ធ<br>- មធ្យោបាយ÷ ពិនិត្យលទ្ធភាពនៃការអនុវត្តយន្តការភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍ<br>ហេដ្ឋារចនាសម្ព័ន្ធ។<br>មិនមានបច្ច័យភ្លាមៗទេ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| ៣. សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម | | | | |

| | | | | |
|---|---|---|---|---|
| **៣.១. បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ (៤)**<br><br>**វិធានការច្បាស់លាស់ = ៤**<br>**វិធានការមិនច្បាស់លាស់ = 0**<br>**វិធានការត្រៀម = 0** | ៣.១.១. ពិនិត្យឡើងវិញនិងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញ "គម្រោងវិនិយោគសក្តានុពលនិងមានគុណភាព" ដែលផ្តល់ផលវិជ្ជមាននិងតម្លៃបន្ថែម សម្រាប់ការបើកផ្លូវដល់ការអភិវឌ្ឍ និងការទាក់ទាញឧស្សាហកម្មថ្មីៗមកកម្ពុជា | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិន<br>- លទ្ធផលរំពឹងទុក÷ ទាក់ទាញឧស្សាហកម្មកម្ពុជាថ្មីៗ ឬឧស្សាហកម្មគាំទ្រនានាឱ្យមកបណ្តាក់ទុននៅកម្ពុជា<br>- មធ្យោបាយ÷ ពិនិត្យឡើងវិញនិងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញ "គម្រោងវិនិយោគសក្តានុពលនិងមានគុណភាព"។<br>ការពិនិត្យឡើងវិញពីលក្ខខណ្ឌវិនិច្ឆ័យត្រូវមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការវិនិយោគ។ លក្ខខណ្ឌវិនិច្ឆ័យអាចត្រូវបានប្រើសម្រាប់កំណត់គម្រោងវិនិយោគសក្តានុពលនិងមានគុណភាព ដើម្បីមានសិទ្ធិទទួលបានការលើកទឹកចិត្តពិសេស។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងស្ថាប័នពាក់ព័ន្ធ | |
| | ៣.១.២. រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និងវិធានការជាក់ស្តែង ដើម្បីជំរុញការផ្សព្វផ្សាយនិងទាក់ទាញការវិនិយោគ ដោយផ្តោតលើប្រទេសគោលដៅមួយចំនួន និងកំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិន<br>- លទ្ធផលរំពឹងទុក÷ ជំរុញការផ្សព្វផ្សាយ និងទាក់ទាញវិនិយោគិនពីប្រទេសគោលដៅក្នុងវិស័យអាទិភាព<br>- មធ្យោបាយ÷ រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និងវិធានការជាក់ស្តែង<br>តាមរយៈការអនុវត្តនូវយុទ្ធសាស្ត្រវិនិយោគដែលបានកំណត់ ភ្នាក់ងារជំរុញការវិនិយោគរបស់កម្ពុជា នឹងកាន់តែសកម្មនិងទាក់ទាញការវិនិយោគកាន់តែប្រសើរ ដែលសមស្របសម្រាប់គោលបំណងអភិវឌ្ឍន៍រយៈពេលវែងរបស់កម្ពុជា | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |

| | | | | |
|---|---|---|---|---|
| | ៣.១.៣. បន្តពង្រឹង និងលើកកម្ពស់សមត្ថភាពរដ្ឋបាលនិងក្របខ័ណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស ដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជា ការកែច្នៃកសិផល សម្រាប់នាំចេញ (ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចឯកទេស ត្រូវចំណុះលើកត្តាសំខាន់ៗ ដូចជា ទីតាំងភូមិសាស្ត្រ ប្រភេទប្រតិបត្តិការអាជីវកម្ម មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ រួមទាំង អគ្គិសនី និងទឹកស្អាត និងប្រព័ន្ធភស្តុភារកម្ម ព្រមទាំងការលើកទឹកចិត្តផងដែរ) | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិន<br>- លទ្ធផលរំពឹងទុក÷ ជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនិងការវិនិយោគក្នុងវិស័យអាទិភាព<br>- មធ្យោបាយ÷ ពង្រឹង និងលើកកម្ពស់សមត្ថភាពរដ្ឋបាលនិងក្របខណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស<br>ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស វានឹងក្លាយជាកត្តាមួយក្នុងការជំរុញកំណើននៃវិស័យជាក់លាក់ដែលរាជរដ្ឋាភិបាលបានកំណត់/ដាក់គោលដៅនៅក្នុងបញ្ជីអាទិភាព។ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស វិនិយោគិនអាចស្វែងរកយន្តការសេវាច្រកចេញចូលតែមួយនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅតំបន់សេដ្ឋកិច្ចពិសេសណាមួយដែលមានភាពងាយស្រួលដល់វិនិយោគិន។<br>យន្តការនេះនឹងជួយសម្រួលរៀបចំចាត់ចែងអាជ្ញាប័ណ្ណនិងឯកសារផ្សេងទៀត សម្រាប់វិនិយោគិនដោយមិនចាំបាច់ឱ្យវិនិយោគិនចេញពីក្រសួងមួយទៅក្រសួងមួយទៀត។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| | ៣.១.៤. ពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិនក្នុងវិស័យឧស្សាហកម្មធុនធ្ងន់<br>- លទ្ធផលរំពឹងទុក÷ ពង្រីកវិស័យឧស្សាហកម្មនៅកម្ពុជាទៅវិស័យថ្មីៗផ្សេងទៀត ដូចជាវិស័យឧស្សាហកម្មធុនធ្ងន់<br>- មធ្យោបាយ÷ សិក្សាពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិរបស់ប្រទេស<br>ការពិនិត្យឡើងវិញពីសក្តានុពលធនធានធម្មជាតិនេះ ជាការសិក្សាអំពីលទ្ធភាព ឬយុទ្ធសាស្ត្រ/របាយការណ៍របស់រដ្ឋាភិបាលដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ នៅពេលវិនិយោគិនទទួលបានការសិក្សាដែលបង្ហាញពីសក្តានុពលរបស់កម្ពុជា ការវិនិយោគផ្ទាល់ពីបរទេសដែលកំពុងស្វែងរកធនធានអាចចាប់អារម្មណ៍ក្នុងការប្រើប្រាស់ធនធានធម្មជាតិនៅកម្ពុជា។ វិធានការនេះបំពេញបន្ថែមចំពោះអន្តរាគមន៍គោលនយោបាយ។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | | |
|---|---|---|---|---|
| **៣.២. ពង្រីក និងពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ (៨)**<br><br>**វិធានការច្បាស់លាស់ = ៥**<br>**វិធានការមិនច្បាស់លាស់ = ១**<br>**វិធានការត្រៀម = ២** | ៣.២.១. ពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងការដាក់ឱ្យប្រើប្រាស់សេវា "បញ្ជរតែមួយជាតិ" ដោយមានការសម្របសម្រួលគ្នាក្នុងចំណោមអាជ្ញាធរតាមមាត់ច្រកអន្តរជាតិទាំងអស់ ហើយធានាឱ្យមានសមាហរណកម្មជាមួយនឹងសេវា "បញ្ជរតែមួយអាស៊ាន" និងការតភ្ជាប់ទៅនឹង បណ្តាញភស្តុភារកម្មអន្តរជាតិ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ សម្រួលនីតិវិធីនៃការនាំចេញសម្រាប់ក្រុមហ៊ុនក្នុងអាស៊ាន<br>- មធ្យោបាយ÷ ដំណើរការស្តង់ដារ/ ធ្វើឱ្យមានភាពសុខដុមរមនានៃ"បញ្ជរតែមួយជាតិ" ជាមួយសេវា "បញ្ជរតែមួយអាស៊ាន" តាមរយៈការធ្វើដូច្នេះ វិនិយោគិននឹងទទួលបានអត្ថប្រយោជន៍ច្រើនក្នុងការធ្វើអាជីវកម្មនៅកម្ពុជា ព្រោះវិនិយោគិនអាចនាំចេញផលិតផលទៅកាន់ទីផ្សារទាំងនៅក្នុងតំបន់ និងអន្តរជាតិបានយ៉ាងងាយស្រួល។ | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងសាធារណៈការនិងដឹកជញ្ជូន | |
| | ៣.២.២. បង្កើតនូវមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម ដែលប្រមូលផ្តុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្សេងៗដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្តាញអ៊ីនធើណែត | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ កាត់បន្ថយការចំណាយលើថ្លៃប្រតិបត្តិការ ព័ត៌មានពាក់ព័ន្ធទាំងអស់គឺអាចរកបានសម្រាប់ក្រុមហ៊ុន<br>- មធ្យោបាយ÷ ផ្តល់នូវព័ត៌មានពាណិជ្ជកម្មទាំងអស់ដែលអាចចូលមើលបានយ៉ាងងាយស្រួល និងបើកដំណើរការមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មរួមជាមួយប្រព័ន្ធទិន្នន័យលើអ៊ីនធើណែត<br>វិនិយោគិននឹងទទួលបានចំណេះដឹងច្បាស់លាស់អំពីរាល់បទប្បញ្ញត្តិ និងព័ត៌មាននៃការធ្វើធុរកិច្ចនៅកម្ពុជា ដែលងាយស្រួលក្នុងការដាក់ទុនវិនិយោគ និងពង្រីកការវិនិយោគ។ | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | ៣.២.៣. កែលម្អការធ្វើបែបបទបញ្ចេញទំនិញ (Custom Clearance) សម្រាប់ទំនិញដែលលើកលែងពន្ធ ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ កាត់បន្ថយនូវតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស និងលុបបំបាត់ចំណាយក្រៅផ្លូវការ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ រាល់នីតិវិធីទាំងអស់គឺនៅកន្លែងតែមួយ ដែលវិនិយោគិនងាយស្រួលបញ្ចេញទំនិញ សម្រាប់ទំនិញដែលលើកលែងពន្ធ កាត់បន្ថយនូវនីតិវិធីរដ្ឋបាលដែលមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស<br>- មធ្យោបាយ÷ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ ការរៀបចំឯកសារ ការសម្របសម្រួលនីតិវិធី និងលុបបំបាត់ការចំណាយក្រៅផ្លូវការ។<br>វិនិយោគិនកាន់តែមានទំនុកចិត្ត និងភាពងាយស្រួលក្នុងការធ្វើសកម្មភាពពាណិជ្ជកម្ម ដែលបានផ្តល់ឱ្យនូវនីតិវិធីដែលបានកែលម្អ។ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |

| | | | |
|---|---|---|---|
| ៣.២.៤. កាត់បន្ថយនូវនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និងគ្មានតម្លាភាព | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ សម្រួលដល់ការវិនិយោគ / ការចុះបញ្ជីអាជីវកម្ម / នីតិវិធីសម្រួលពាណិជ្ជកម្ម (មិនទាន់ច្បាស់ថាតើបែបបទបែបណា)<br>- មធ្យោបាយ÷ មធ្យោបាយក្នុងការអនុវត្តវិធានការនេះមិនច្បាស់លាស់ទេ។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួង/ស្ថាប័នពាក់ព័ន្ធ | |
| ៣.២.៥. ពង្រឹងសមត្ថភាពអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ឱ្យក្លាយជាភ្នាក់ងារ ជំរុញការនាំចេញ ដែលមានជំនាញខ្ពស់ក្នុងការវិភាគទីផ្សារនាំចេញ កំណត់មុខសញ្ញានាំចេញ និងរៀបចំបណ្ណាញធុរកិច្ចដែលជាមូលដ្ឋានក្នុងការផ្ដល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម ផ្ដល់ព័ត៌មានអំពីទីផ្សារក្រៅប្រទេស និងជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំង ការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬការតាំងពិព័រណ៍ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ លើកទឹកចិត្ត ផ្ដល់ព័ត៌មាន និងបង្កើនការនាំចេញ<br>- មធ្យោបាយ÷ កសាងសមត្ថភាព សម្រាប់អនុវត្តឱ្យជាក្លាយជាភ្នាក់ងារជំរុញការនាំចេញ។<br>អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម នឹងអាចបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ជាទីភ្នាក់ងារជំរុញការនាំចេញ ក្នុងការផ្ដល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម ផ្ដល់ព័ត៌មានអំពីទីផ្សារក្រៅប្រទេស និងជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំង ការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬការតាំងពិព័រណ៍។ ដូច្នេះវិនិយោគិនក៏នឹងទទួលបានអត្ថប្រយោជន៍ពីមូលដ្ឋាននេះ ដែលអាចផ្ដល់លទ្ធភាពឱ្យពួកគេឈានទៅដល់ទីផ្សារ និងពង្រីកផលិតផលបន្ថែមផងដែរ។ | ក្រសួងពាណិជ្ជកម្ម | |
| ៣.២.៦. ពិចារណាបង្កើតស្ថាប័នហិរញ្ញប្បទានតាមគោលនយោបាយដែលមានកាតព្វកិច្ចផ្ដល់កម្ចីទៅឱ្យអ្នកនាំចេញ ដែលផលិតទំនិញនាំចេញក្នុងឧស្សាហកម្មអាទិភាព និងផ្ដល់នូវ សេវាធានារ៉ាប់រងការនាំចេញ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាទាក់ទងនឹងការនាំចេញ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ ក្រុមហ៊ុននឹងទទួលបានអត្ថប្រយោជន៍កាន់តែច្រើន តាមរយៈការផ្ដល់កម្ចី និងអាចបង្កើនផលិតផលនាំចេញ<br>- មធ្យោបាយ÷ ស្វែងរក និងពិចារណាសម្រាប់ការបង្កើតស្ថាប័នពិសេសហិរញ្ញ-ប្បទាន<br>មិនមានបច្ច័យភ្លាមៗទេ។ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងពាណិជ្ជកម្ម | |
| ៣.២.៧. ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកែលម្អនីតិវិធី ការពង្រឹងយន្តការដឹកជញ្ជូនឆ្លងដែន ការកាត់បន្ថយថ្លៃចំណាយការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ កាន់តែមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម<br>- មធ្យោបាយ÷ កែលម្អនីតិវិធី និងវិធានការសម្របសម្រួលពាណិជ្ជកម្ម<br>វិនិយោគិននឹងមានទំនុកចិត្ត និងមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មនៅកម្ពុជា។ | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងសាធារណៈការនិងដឹកជញ្ជូន | |

| | | | | |
|---|---|---|---|---|
| | ៣.២.៨. ពិចារណាបង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនក្នុងស្រុកដែលនាំចេញទំនិញថ្មីៗ និងនាំចេញបានចំនួនច្រើនជាងគេ ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តពិសេស និងរង្វាន់នានា សម្រាប់ក្រុមហ៊ុនដែលបាននាំទំនិញដល់ចំនួនដែលបានកំណត់ តាមរយៈការវាយតម្លៃប្រកបដោយតម្លាភាព ដោយផ្សារភ្ជាប់នឹងគោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុនក្នុងស្រុក<br>- លទ្ធផលរំពឹងទុក÷ លើកទឹកចិត្តខ្ពស់ដល់ក្រុមហ៊ុនក្នុងស្រុកដែលនាំចេញទំនិញថ្មីៗ និងនាំចេញបានចំនួនច្រើនជាងគេ ដើម្បីពង្រឹងការនាំចេញរបស់ក្រុមហ៊ុន<br>- មធ្យោបាយ÷ ពិចារណាអភិវឌ្ឍ និងបង្កើតប្រព័ន្ធផ្តល់រង្វាន់លើកទឹកចិត្តដល់ក្រុមហ៊ុន មិនមានបច្ច័យភ្លាមៗទេ | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៣. ធ្វើឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម (៣)<br><br>**វិធានការច្បាស់លាស់ = ៣**<br>**វិធានការមិនច្បាស់លាស់ = 0**<br>**វិធានការត្រៀម = 0** | ៣.៣.១. បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេសតាមរយៈការផ្តល់អាទិភាពលើការតភ្ជាប់បណ្តាញអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងភស្តុភារកម្ម ព្រមទាំងការសម្រួល និងការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន/ សហគ្រាសធុនតូច និងមធ្យម<br>- លទ្ធផលរំពឹងទុក÷ ផ្តល់នូវប្រព័ន្ធអេកូឡូសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីរីកចម្រើន និងអភិវឌ្ឍខ្លួនសម្រាប់ប្រកួតប្រជែងជាមួយសហគ្រាសធំៗ។<br>- មធ្យោបាយ÷ រដ្ឋាភិបាលផ្តល់ការគាំទ្រផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធដល់វិស័យឯកជន / សហគ្រាសធុនតូចនិងមធ្យមដូចជាការលើកទឹកចិត្ត និងការសម្របសម្រួល ផ្គត់ផ្គង់ការតភ្ជាប់បណ្តាញអគ្គិសនី ការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងភស្តុភារកម្ម។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-រដ្ឋបាលថ្នាក់ក្រោមជាតិ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ៣.៣.២. ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និងលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន/ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន<br>- មធ្យោបាយ÷ ផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យម<br>ការពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន នាំឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំៗ និងសហគ្រាសធុនតូចនិងមធ្យម។ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម | |

| | | | | |
|---|---|---|---|---|
| | ៣.៣.៣. សិក្សា និងរៀបចំឱ្យមានយន្តការហិរញ្ញវត្ថុ សមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូច និងមធ្យម<br>- លទ្ធផលរំពឹងទុក÷ រៀបចំឱ្យមានយន្តការហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម<br>- មធ្យោបាយ÷ ផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យឧស្សាហកម្មអាទិភាព តាមរយៈធនាគារសហគ្រាសធុនតូចនិងមធ្យម និងសាជីវកម្មធានាឥណទានកម្ពុជា។ល។<br>យន្តការហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដើម្បីផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម នាំឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំៗ និងសហគ្រាសធុនតូចនិងមធ្យម។ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| **៣.៤ បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម (១៦)**<br><br>**វិធានការច្បាស់លាស់ = ៨**<br>**វិធានការមិនច្បាស់លាស់ = ៣**<br>**វិធានការត្រៀម = ៥** | ៣.៤.១. លើកស្ទួយសមត្ថភាពវិទ្យាស្ថានឧត្តមសិក្សាដើម្បីជាមូលដ្ឋានរឹងមាំមួយសម្រាប់ក្រេបជញ្ជក់យកវិទ្យាសាស្ត្រ បង្កើនការហ្វឹកហ្វឺន និងនវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ សម្រាប់តម្រូវការទីផ្សារ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ គ្រឹះស្ថានឧត្តមសិក្សា។<br>- លទ្ធផលរំពឹងទុក÷ ពង្រឹងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>- មធ្យោបាយ÷ តាមរយៈការដាក់ចេញនូវគោលនយោបាយអប់រំនានា។ | ក្រសួងអប់រំ យុវជន និងកីឡា | |
| | ៣.៤.២. បង្កើតពានរង្វាន់សម្រាប់ការប្រកួតប្រជែងបច្ចេកទេសនៅលើគ្រប់មុខសញ្ញាអាទិភាព | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យសាធារណៈ និងវិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ បង្កើននវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ<br>- មធ្យោបាយ÷ បង្កើតពានរង្វាន់សម្រាប់ នវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ<br>ការផ្តល់រង្វាន់សម្រាប់នវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ ជំរុញឱ្យវិស័យសាធារណៈនិងឯកជនបង្កើននវានុវត្តន៍ឧស្សាហកម្ម។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ៣.៤.៣. បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារដែលជាគ្រឹះ សម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា<br>- លទ្ធផលរំពឹងទុក÷ ណែនាំផលិតផលស្តង់ដារ និងមានគុណភាព និងបង្កើនឱកាសនាំចេញផលិតផល<br>- មធ្យោបាយ÷ រៀបចំក្របខណ្ឌគតិយុត្ត ការពង្រឹងមាត្រាសាស្ត្រគ្រប់គ្រង និងស្តង់ដារ បន្ថែមតម្លៃយ៉ាងសម្បើម ក្នុងការបង្កើននវានុវត្តន៍ឧស្សាហកម្ម។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | |
|---|---|---|---|
| ៣.៤.៤. កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការ ផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ភ្នាក់ងារនៃប្រទេសជាដៃគូ<br>- លទ្ធផលរំពឹងទុក÷ កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារ តាមរយៈស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម។<br>- មធ្យោបាយ÷ អនុវត្តនីតិវិធីកិច្ចសហប្រតិបត្តិការ ដើម្បីទទួលស្គាល់ការចុះឈ្មោះភ្នាក់ងារ តាមរយៈស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម។<br>ការកែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម នាំឱ្យបង្កើននវានុវត្តន៍ឧស្សាហកម្ម។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៤.៥. បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទូលំទូលាយពីសំណាក់សហគ្រិន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រិន<br>- លទ្ធផលរំពឹងទុក÷ ណែនាំផលិតផលស្តង់ដារ និងមានគុណភាព និងបង្កើនឱកាសនាំចេញផលិតផល និងលើកទឹកចិត្តក្រុមហ៊ុននានា ឱ្យចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម<br>- មធ្យោបាយ÷ បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៤.៦. ជួយគាំទ្រលើកកម្ពស់សមត្ថភាពនិងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដារក្នុងការធានានូវ បរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងគ្រប់គ្រង | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា<br>- លទ្ធផលរំពឹងទុក÷ មានការអនុលោមភាពខ្ពស់ជាងសម្រាប់ស្តង់ដារ និងមាត្រាសាស្ត្រ<br>- មធ្យោបាយ÷ លើកកម្ពស់សមត្ថភាពនិងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដារ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៤.៧. ចាត់វិធានការជាក់ស្តែងក្នុងការពង្រឹងការអនុវត្តស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីប្រែក្លាយក្របខណ្ឌទាំងនេះឱ្យក្លាយជាឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន<br>- លទ្ធផលរំពឹងទុក÷ លើកកម្ពស់ការប្រកួតប្រជែងដែលនាំឱ្យមាននវានុវត្តន៍កាន់តែច្រើន<br>- មធ្យោបាយ÷ មិនមានមធ្យោបាយអនុវត្តវិធានការច្បាស់លាស់ទេ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | |
|---|---|---|---|
| ៣.៤.៨. ពង្រឹងសមត្ថភាព "វិទ្យាស្ថានស្តង់ដារកម្ពុជា" ក្នុងការសិក្សាស្រាវជ្រាវ រៀបចំស្តង់ដារជាតិ សម្រាប់ផលិតផល សេវាកម្ម ផលិតកម្ម និងបច្ចេកទេស អនុលោមតាមស្តង់ដារតំបន់ និង អន្តរជាតិ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ វិទ្យាស្ថានស្តង់ដារកម្ពុជា<br>- លទ្ធផលរំពឹងទុក÷ រៀបចំស្តង់ដារជាតិ សម្រាប់ផលិតផល សេវាកម្ម ផលិតកម្ម និងបច្ចេកទេស<br>- មធ្យោបាយ÷ ពង្រឹងសមត្ថភាពនៃវិទ្យាស្ថានស្តង់ដារកម្ពុជា | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៤.៩. ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិក្នុងការសិក្សាស្រាវជ្រាវ រៀបចំនីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម តេស្តវិភាគ និងការអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ<br>- លទ្ធផលរំពឹងទុក÷ រៀបចំនីតិវិធីសម្រាប់ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម និងតេស្តវិភាគ<br>- មធ្យោបាយ÷ ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៤.១០. ជំរុញការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងយន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ មិនបានបញ្ជាក់ច្បាស់<br>- លទ្ធផលរំពឹងទុក÷ ការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- មធ្យោបាយ÷ ក្របខ័ណ្ឌឯកសារបទដ្ឋានគតិយុត្ត<br>មិនមានបច្ច័យភ្លាមៗទេ | ក្រសួងផែនការ | |
| ៣.៤.១១. ពង្រឹងការគ្រប់គ្រងមណ្ឌលច្នៃប្រឌិត និងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតតក្កកម្ម និងការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ មជ្ឈមណ្ឌលច្នៃប្រឌិត និងបង្កើតថ្មីកម្ពុជា។<br>- លទ្ធផលរំពឹងទុក÷ លើកកម្ពស់ការបង្កើតថ្មី និងការបណ្តុះបណ្តាលលើកម្មសិទ្ធិឧស្សាហកម្ម<br>- មធ្យោបាយ÷ ពង្រឹងការគ្រប់គ្រងមជ្ឈមណ្ឌល<br>ការលើកកម្ពស់ការបង្កើតថ្មី និងការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម នឹងនាំឱ្យមានការច្នៃប្រឌិតបន្ថែមទៀត។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៤.១២. ពង្រឹង និងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ មិនបានបង្ហាញច្បាស់<br>- លទ្ធផលរំពឹងទុក÷ ពង្រឹង និងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម<br>- មធ្យោបាយ÷ មិនមានមធ្យោបាយអនុវត្តវិធានការច្បាស់លាស់ទេ | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |

| | | | | |
|---|---|---|---|---|
| | ៣.៤.១៣. សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ មិនបានបង្ហាញច្បាស់<br>- លទ្ធផលរំពឹងទុក÷ សិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ មានកាន់តែច្រើន<br>- មធ្យោបាយ÷ មិនមានមធ្យោបាយអនុវត្តវិធានការច្បាស់លាស់ទេ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ៣.៤.១៤. សិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និង បច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ មិនបានបង្ហាញច្បាស់។<br>- លទ្ធផលរំពឹងទុក÷ ពិសោធន៍ និងសិក្សាស្រាវជ្រាវលើវិស័យឧស្សាហកម្ម។<br>- មធ្យោបាយ÷ សួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។<br>មិនមានបច្ច័យភ្ជាមៗទេ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ៣.៤.១៥. បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករដែលមាន ទេពកោសល្យ ដើម្បីចម្រាញ់ឧស្សាហករ ដែលមានទេពកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករ និងសហគ្រិនវ័យក្មេង | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ អ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករដែលមានទេពកោសល្យ<br>- លទ្ធផលរំពឹងទុក÷ បង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករ និងសហគ្រិនវ័យក្មេង<br>- មធ្យោបាយ÷ ការប្រឡងប្រណាំង<br>វិស្វករ និងសហគ្រិនប្រកបដោយគំនិតនវានុវត្តន៍ នឹងបង្កើននវានុវត្តន៍ឧស្សាហកម្ម។ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| | ៣.៤.១៦. ពិនិត្យលទ្ធភាពវិនិយោគលើវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្តោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពិសេស ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិស័យអាទិភាពនីមួយៗ ដោយជ្រើសរើសអ្នកវិទ្យាសាស្ត្រ និងវិស្វករមានសមត្ថភាពជាមួយនឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ អ្នកវិទ្យាសាស្ត្រ និងវិស្វករ<br>- លទ្ធផលរំពឹងទុក÷ វិទ្យាស្ថានស្រាវជ្រាវរដ្ឋ<br>- មធ្យោបាយ÷ អ្នកវិទ្យាសាស្ត្រ និងវិស្វករដែលមានសមត្ថភាព និងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប។<br>មិនមានបច្ច័យភ្ជាមៗទេ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | | |
|---|---|---|---|---|
| **៣.៩. ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម (៩)**<br><br>**វិធានការច្បាស់លាស់ = ៧**<br>**វិធានការមិនច្បាស់លាស់ = ២**<br>**វិធានការត្រៀម = 0** | ៣.៩.១. ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ពិសេសសំដៅរៀបចំការចុះបញ្ជី ការគ្រប់គ្រង និងការតាមដានវឌ្ឍនភាពនៃវិស័យនេះ ដែលទាក់ទាញសហគ្រាស កម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធផ្លូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់លាស់សម្រាប់រៀបចំគោលនយោបាយ គាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះមានលទ្ធភាពទទួលបានព័ត៌មានពីឥណទាន និងការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាព និងការវិនិយោគ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ លើកទឹកចិត្តសហគ្រាសនៅកម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធផ្លូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់លាស់សម្រាប់រៀបចំគោលនយោបាយគាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះមានទទួលបានព័ត៌មានពីឥណទាន និងការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាព និងការវិនិយោគ<br>- មធ្យោបាយ÷ ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម<br>-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត | |
| | ៣.៩.២. បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដោយ រដ្ឋាភិបាលផ្តល់នូវការវិភាជថវិកាសមស្រប យោងតាមតម្រូវការ និងលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន (សហគ្រាសធុនតូចនិងមធ្យម) វិទ្យាស្ថានសិក្សាស្រាវជ្រាវ សាកលវិទ្យាល័យ<br>- លទ្ធផលរំពឹងទុក÷ បង្កើនសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ដើម្បីបង្កើតផលិតផលថ្មីៗ<br>- មធ្យោបាយ÷ បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដោយរដ្ឋាភិបាលផ្តល់នូវការវិភាជថវិកាសមស្រប យោងតាមតម្រូវការ និងលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | ៣.៩.៣. ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង តស៊ូមតិ និងការពារសិទ្ធិប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម។<br>- លទ្ធផលរំពឹងទុក÷ ចែករំលែកចំណេះដឹង និងព័ត៌មាន និងគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូចនិងមធ្យម។<br>- មធ្យោបាយ÷ ការបង្កើតសមាគមតាមអនុវិស័យនីមួយៗ។<br>នៅពេលសហគ្រាសធុនតូចនិងមធ្យម អាចទទួលបានព័ត៌មាន និងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សហគ្រាសទាំងនោះអាចពង្រឹងសមត្ថភាព និងបង្កើនការនាំចេញ។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | |
|---|---|---|---|
| ៣.៥.៤. ធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដោយរៀបចំស្តង់ដារគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ បង្កើនអត្រាចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម និងអាចផ្តល់ព័ត៌មានអំពីសហគ្រាសធុនតូចនិងមធ្យមដែលមានជូនដល់រដ្ឋាភិបាល<br>- មធ្យោបាយ÷ រៀបចំស្តង់ដារគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម ដោយធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម និងវិជ្ជាជីវៈគណនេយ្យ។<br>ធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដោយរៀបចំស្តង់ដារគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម នាំឱ្យមានការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម។ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាជាតិគណនេយ្យ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៥.៥. ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ដោយប្រើប្រាស់ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យសម្រាប់ជាមូលដ្ឋានវាយតម្លៃ និងជាលក្ខខណ្ឌសម្រាប់ការផ្តល់ការលើកទឹកចិត្តនិងការគាំទ្រពីរាជរដ្ឋាភិបាល | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ បង្កើនអត្រាចុះបញ្ជី និងប្រើប្រាស់ព័ត៌មានរបស់សហគ្រាសធុនតូចនិងមធ្យម ដែលបានចុះបញ្ជីជាមូលដ្ឋានដើម្បីផ្តល់ការលើកទឹកចិត្ត / ការគាំទ្រ<br>- មធ្យោបាយ÷ ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម<br>ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម នាំឱ្យមានការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៣.៥.៦. លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូចនិងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម និងសហគ្រាសធុនធំ<br>- លទ្ធផលរំពឹងទុក÷ បង្កើនចំនួនសហគ្រាសធុនធំ សហគ្រាសធុនតូចនិងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត<br>- មធ្យោបាយ÷ មិនមានមធ្យោបាយអនុវត្តច្បាស់លាស់ទេ។ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាជាតិគណនេយ្យ | |

| | | | | |
|---|---|---|---|---|
| | ៣.៥.៧. ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃការចុះបញ្ជី | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ សហគ្រាសធុនតូចនិងមធ្យមកាន់តែច្រើនដឹងអំពីអត្ថប្រយោជន៍នៃប្រព័ន្ធបញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូចនិង<br>មធ្យម<br>- មធ្យោបាយ÷ ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃប្រព័ន្ធចុះបញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូចនិង<br>មធ្យម | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ៣.៥.៨. ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូច និងមធ្យម<br>- លទ្ធផលរំពឹងទុក÷ សហគ្រាសធុនតូច និងមធ្យមមានសមត្ថភាពអាចកាន់បញ្ជីគណនេយ្យ និងតារាងតុល្យការបាន<br>- មធ្យោបាយ÷ ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម<br>ការផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម នាំឱ្យមានការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ៣.៥.៩. ពង្រឹងការប្រើប្រាស់ស្តង់ដារនីយកម្ម និងការវាយតម្លៃការទទួលស្គាល់អនុលោមភាពដោយ ផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុនឯកជន<br>- លទ្ធផលរំពឹងទុក÷ ធ្វើឱ្យផលិតកម្ម/ សេវាកម្មឧស្សាហកម្មមានលក្ខណៈស្តង់ដារ ដើម្បីបំពេញតាមស្តង់ដារជាក់លាក់<br>- មធ្យោបាយ÷ នមានឧបករណ៍ច្បាស់លាស់ទេ (ការផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៤. ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ | | | | |

| | | | | |
|---|---|---|---|---|
| **៤.១. ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស (១៦)**<br><br>**វិធានការច្បាស់លាស់ = ១៥**<br>**វិធានការមិនច្បាស់លាស់ = ០**<br>**វិធានការត្រៀម = ១** | ៤.១.១. ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្មនិងការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ឥរិយាបថវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ជាអាទិ៍យន្តការ "គណៈកម្មការប្រឹក្សាការងារ" និង "គណៈកម្មាធិការផលិតភាពកម្ពុជា" | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ ទំនាក់ទំនងប្រកបដោយផលិតភាពរវាងនិយោជិក និងនិយោជិត<br>- មធ្យោបាយ÷ ពង្រឹងយន្តការនៃការធ្វើសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ (មិនប្រាកដថាយន្តការសុខដុមនីយកម្មដំណើរការយ៉ាងដូចម្តេច)<br>តាមរយៈការធ្វើដូច្នេះ វាមិនត្រឹមតែជួយបង្កើនភាពប្រកួតប្រជែង និងផលិតភាពរបស់ឧស្សាហកម្មប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងជួយលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករ ដែលរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងឧស្សាហកម្ម។ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-គណៈកម្មាការប្រឹក្សាការងារ<br>-គណៈកម្មាការផលិតភាពកម្ពុជា | |
| | ៤.១.១.១. បន្តអភិវឌ្ឍយន្តការបណ្តុះបណ្តាល ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ជំនាញ<br>*អនុវិធានការដែលបំបែកចេញពីវិធានការក្នុងអន្តរាគមន៍គោលនយោបាយ ៤.៣* | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ បំពេញការផ្គត់ផ្គង់កម្លាំងជំនាញ ដល់ក្រុមហ៊ុន និងអាចជួយលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករ<br>- មធ្យោបាយ÷ បន្តអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ | | |
| | ៤.១.២. ធ្វើវិចារណកម្មលើការលើកទឹកចិត្តបន្ថែម ចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុង ការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ បង្កើនការបណ្តុះបណ្តាលជំនាញ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍<br>- មធ្យោបាយ÷ ផ្តល់ការលើកទឹកចិត្តបន្ថែមសម្រាប់គម្រោងវិនិយោគ ដែលផ្តោតលើការបណ្តុះបណ្តាលជំនាញស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍ ដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការវិនិយោគ។ (ការរំលស់ ១៥០% -២០០% លើការចំណាយនៃការបណ្តុះបណ្តាលជំនាញ និងលើសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ )។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងស្ថាប័នពាក់ព័ន្ធ | |
| | ៤.១.៣. កសាងធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំ និងជវភាព ដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេស សម្រាប់ដោះស្រាយកង្វះខាតជំនាញក្នុងវិស័យ អាទិភាព ដោយបង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលវិស្វករ និងអ្នកបច្ចេកទេស | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស្វករ និងអ្នកបច្ចេកទេស<br>- លទ្ធផលរំពឹងទុក÷ បង្កើនចំណេះដឹងបច្ចេកទេស<br>- មធ្យោបាយ÷ បង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាល<br>ការផ្តល់ការបណ្តុះបណ្តាលជំនាញឯកទេស នាំឱ្យមានការអភិវឌ្ឍជំនាញ។ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |

| | | | |
|---|---|---|---|
| ៤.១.៤. បង្កើតនិកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្តដែលអនុញ្ញាតឱ្យទទួលបានវិញ្ញាបនបត្រចំណេះដឹងទូទៅគ្រប់កម្រិត ទោះនៅក្រៅប្រព័ន្ធអប់រំផ្លូវការក៏ដោយ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្ស<br>- លទ្ធផលរំពឹងទុក÷ ផ្តល់និកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា<br>- មធ្យោបាយ÷ ការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្តដែលអនុញ្ញាតឱ្យទទួលបានវិញ្ញាបនបត្រចំណេះដឹងទូទៅគ្រប់កម្រិត ទោះនៅក្រៅប្រព័ន្ធអប់រំផ្លូវការក៏ដោយ<br>ការផ្តល់និកាសទីពីរដល់សិស្សសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា នាំឱ្យមានការអភិវឌ្ឍធនធានមនុស្ស។ | ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.៥. ពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដោយផ្តោតលើការពង្រឹង មូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជន លើផ្នែក គណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្សនៅបឋមសិក្សា និងមធ្យមសិក្សា<br>- លទ្ធផលរំពឹងទុក÷ បង្កើនគុណភាពអប់រំ<br>- មធ្យោបាយ÷ ពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជន លើផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា<br>ការបង្កើនគុណភាពអប់រំ នាំឱ្យមានការអភិវឌ្ឍធនធានមនុស្ស។ | ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.៦. ជំរុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់ប្រាំបួនឆ្នាំ ដោយកាត់បន្ថយឱ្យបានជា អតិបរមានូវអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងលើកកម្ពស់ការចូលរៀននៅថ្នាក់មធ្យមសិក្សា | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្សនៅកម្រិតអប់រំចំណេះទូទៅ<br>- លទ្ធផលរំពឹងទុក÷ កាត់បន្ថយអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងបង្កើនអត្រាចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សា<br>- មធ្យោបាយ÷ មធ្យោបាយដើម្បីសម្រេចបាននូវវិធានការនេះគឺត្រូវអនុវត្តផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ និង ២០១៩-២០២៣ | ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.៧. កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ (Soft Skills) រួមមានជំនាញទំនាក់ទំនង សង្គមក្នុងការដោះស្រាយបញ្ហា ការគោរពវិន័យនៅកន្លែងធ្វើការ និងជំនាញជាច្រើនទៀតដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្ស<br>- លទ្ធផលរំពឹងទុក÷ ដាក់បញ្ចូលជំនាញទន់ដែលមានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍ កែលម្អកម្មវិធីសិក្សា ដែលជាមូលដ្ឋានគ្រឹះឧស្សាហកម្ម<br>- មធ្យោបាយ÷ កែលម្អកម្មវិធីសិក្សា<br>ការកែលម្អកម្មវិធីសិក្សាអាចជួយសិស្សឱ្យទទួលបាននូវជំនាញជាក់លាក់។ | ក្រសួងអប់រំ យុវជន និងកីឡា | |

| | | | |
|---|---|---|---|
| ៤.១.៨. បង្កើនការបណ្តុះបណ្តាលបច្ចេកទេសឱ្យបានច្រើនជាងមុន តាមលទ្ធភាពលើជំនាញ បច្ចេកទេស ជាពិសេស នៅក្នុងផ្នែកអគ្គិសនី មេកានិក ស្តង់ដារមាត្រាសាស្ត្រ (ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាករម្ម តេស្ត និងជំនាញប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ) និងគីមីសាស្ត្រ ទាំងក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស ទាំងក្នុងកម្រិតឧត្តមសិក្សា | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្សនៅកម្រិតមធ្យមសិក្សាបច្ចេកទេសនិងឧត្តមសិក្សា<br>- លទ្ធផលរំពឹងទុក÷ បង្កើនការផ្គត់ផ្គង់អ្នកបច្ចេកទេសជំនាញ<br>- មធ្យោបាយ÷ បង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេស ផ្នែកអគ្គិសនី អេឡិចត្រូនិច មេកានិច គីមីវិទ្យា ស្តង់ដារនិងមាត្រាសាស្ត្រ | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| ៤.១.៩. ផ្តល់អាទិភាពដល់ការបង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន (ទាំងក្នុងប្រព័ន្ធអប់រំទូទៅ ទាំងក្រៅប្រព័ន្ធ) ដោយផ្តោតលើផ្នែក សំខាន់ៗ ដូចជា អគ្គិសនី ព័ត៌មានវិទ្យា កុំព្យូទ័រ ម៉ាស៊ីន ការជួសជុល និងការដំឡើងរថយន្តនិង ម៉ូតូ ការកែច្នៃកសិផល និងសិប្បកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្សបច្ចេកទេសនៅសាលាមធ្យមសិក្សា<br>- លទ្ធផលរំពឹងទុក÷ ផ្គត់ផ្គង់អ្នកបច្ចេកទេសជំនាញកាន់តែច្រើន ផ្នែកអគ្គិសនី អេឡិចត្រូនិច ព័ត៌មានវិទ្យា កុំព្យូទ័រ ម៉ាស៊ីន ការជួសជុល និងការដំឡើងរថយន្តនិង ម៉ូតូ ការកែច្នៃកសិផល និងសិប្បកម្ម<br>- មធ្យោបាយ÷ បង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.១០. រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម ដោយរួមមានផែនការវិនិយោគច្បាស់លាស់ និងក្នុងទស្សនវិស័យរយៈពេលវែង | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ មិនបានបង្ហាញច្បាស់<br>- លទ្ធផលរំពឹងទុក÷ រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ<br>- មធ្យោបាយ÷ មិនមានមធ្យោបាយសម្រាប់ការអនុវត្តច្បាស់លាស់ទេ មិនមានបច្ច័យភ្លាមៗទេ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.១១. ជំរុញស្ថាប័ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes) ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់ក្រុមហ៊ុន និងសហគ្រាសដែលទទួលអនុវត្តតាមប្រព័ន្ធកម្មសិក្សាបែបនេះ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ និយោជិតវ័យក្មេងដែលមានការងារធ្វើលើកដំបូងមានជំនាញគ្រប់គ្រាន់សម្រាប់បំពេញការងារដែលចាំបាច់<br>- មធ្យោបាយ÷ ផ្តល់នូវការលើកទឹកចិត្តដល់ក្រុមហ៊ុន ដោយផ្តល់នូវកម្មវិធីប្រព័ន្ធកម្មសិក្សា នៅពេលដែលក្រុមហ៊ុនចូលរួមក្នុងកម្មវិធីប្រព័ន្ធកម្មសិក្សា កម្មករវ័យក្មេងក្នុងក្រុមហ៊ុនទាំងនោះ អាចពង្រឹងជំនាញរបស់ខ្លួន។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |

| | | | |
|---|---|---|---|
| ៤.១.១២. ពង្រឹងការបណ្ដុះបណ្ដាលជំនាញឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជនទាំងវិន័យ កម្រិត ជំនាញ និងសមត្ថភាពតាមរយៈការធ្វើសហប្រតិបត្តិការជាមួយនឹងវិនិយោគិនបរទេសគោលដៅ មានដូចជាការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញជប៉ុន កូរ៉េ សិង្ហបុរី | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន វិទ្យាស្ថានបណ្ដុះបណ្ដាល និងសិស្ស<br>- លទ្ធផលរំពឹងទុក÷ ពង្រឹងការបណ្ដុះបណ្ដាលជំនាញឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជន<br>- មធ្យោបាយ÷ បង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញជាមួយជប៉ុន កូរ៉េ សិង្ហបុរី។ល។<br>ពង្រឹងការបណ្ដុះបណ្ដាលជំនាញ នាំឱ្យមានការអភិវឌ្ឍជំនាញ។ | -ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.១៣. ជំរុញការបណ្ដុះបណ្ដាលត្រីភាគី "រដ្ឋ-ស្ថាប័នបណ្ដុះបណ្ដាលក្រុមហ៊ុន/រោងចក្រ" ដើម្បីបំពាក់ជំនាញ និងបង្កើនផលិតភាព ជាពិសេស ការដាក់បញ្ចូលក្នុងកម្មវិធីអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងសមាគមមនុស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រសួងមានសមត្ថកិច្ច វិទ្យាស្ថានបណ្ដុះបណ្ដាល ក្រុមហ៊ុននិងកម្មករ / និយោជិត / សិស្ស<br>- លទ្ធផលរំពឹងទុក÷ បង្កើនជំនាញនិងផលិតភាពក្នុងចំណោមសិស្សនិងកម្មករ<br>- មធ្យោបាយ÷ អនុវត្តកម្មវិធីអប់រំត្រីភាគី និងកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងសមាគមមនុស្សាហកម្មសាធារណៈ<br>ជំរុញការបណ្ដុះបណ្ដាលលើជំនាញនិងផលិតភាព នាំឱ្យមានការអភិវឌ្ឍជំនាញ។ | -ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.១៤. ពង្រីកការបណ្ដុះបណ្ដាលជំនាញនៅនឹងកន្លែង ដោយផ្ដោតការយកចិត្តទុកដាក់លើពលករតាមរោងចក្រ ដើម្បីឱ្យពលករទាំងនោះទទួលបានការអប់រំបណ្ដុះបណ្ដាល និង<br>ផ្ដល់ក្ដីសង្ឃឹម ក្នុងការអភិវឌ្ឍជំនាញ និងបច្ចេកទេសក្នុងពេលអនាគត | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ កម្មកររោងចក្រ<br>- លទ្ធផលរំពឹងទុក÷ បង្កើនទាំងជំនាញ និងចំណេះធ្វើ<br>- មធ្យោបាយ÷ ពង្រីកការបណ្ដុះបណ្ដាលជំនាញ និងវិជ្ជាជីវៈ<br>កម្មកររោងចក្រនឹងទទួលបានការបណ្ដុះបណ្ដាលជំនាញ ដូច្នេះរួមចំណែកដល់ការអភិវឌ្ឍជំនាញ។ | -ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.១.១៥. ពង្រឹងការអប់រំនៅសាកលវិទ្យាល័យដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រមូលដ្ឋានសំខាន់ៗផ្សេងទៀត និងវិស្វកម្ម ដោយពង្រឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍ ដើម្បីឈានទៅកសាងគុណភាពអប់រំសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សាកលវិទ្យាល័យ<br>- លទ្ធផលរំពឹងទុក÷ លើកកម្ពស់គុណភាពសំរាប់ការស្រាវជ្រាវជាមួយកម្មវិធីសិក្សាទាក់ទងនឹងវិទ្យាសាស្ត្រកសិកម្ម និងវិទ្យាសាស្ត្រ និងវិស្វកម្មសំខាន់ៗផ្សេងទៀត<br>- មធ្យោបាយ÷ ពង្រឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍<br>ការលើកកម្ពស់គុណភាពសម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ នាំឱ្យមានការអភិវឌ្ឍធនធានមនុស្ស។ | ក្រសួងអប់រំ យុវជន និងកីឡា | |

| | | | | |
|---|---|---|---|---|
| | ៤.១.១៦. ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM) ពីកម្រិតបឋមសិក្សា រហូតដល់ក្រោយមធ្យមសិក្សា ពិសេសផ្តោតលើសិស្សក្មេងៗ ជាមួយ នឹងការកែទម្រង់កម្មវិធីសិក្សា ដោយការធ្វើស្តង់ដារនីយកម្មនៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្សនៅកម្រិតបឋមសិក្សា រហូតដល់ក្រោយមធ្យមសិក្សា<br>- លទ្ធផលរំពឹងទុក÷ បង្កើនការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM)<br>- មធ្យោបាយ÷ កែទម្រង់កម្មវិធីសិក្សា ដោយការធ្វើស្តង់ដារនីយកម្មនៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM) នាំឱ្យមានការអភិវឌ្ឍធនធានមនុស្ស។ | ក្រសួងអប់រំ យុវជន និងកីឡា | |
| ៤.២. បង្កើនតម្រូវការពលកម្មជំនាញ | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | | |
| **៤.៣. ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ (៦)**<br><br>**វិធានការច្បាស់លាស់ = ៥**<br>**វិធានការមិនច្បាស់លាស់ = 0**<br>**វិធានការត្រៀម = ១** | ៤.៣.១. ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្មនិងការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ឥរិយាបថវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ជាអាទិ៍យន្តការ "គណៈកម្មការប្រឹក្សាការងារ" និង "គណៈកម្មាធិការផលិតភាពកម្ពុជា" | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ ទំនាក់ទំនងប្រកបដោយផលិតភាពរវាងនិយោជិក និងនិយោជិត<br>- មធ្យោបាយ÷ ពង្រឹងយន្តការនៃការធ្វើសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ (មិនប្រាកដថាយន្តការសុខដុមនីយកម្មដំណើរការយ៉ាងដូចម្តេច)<br>តាមរយៈការធ្វើដូច្នេះ វាមិនត្រឹមតែជួយបង្កើនភាពប្រកួតប្រជែង និងផលិតភាពរបស់ឧស្សាហកម្មប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងជួយលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករ ដែលរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងឧស្សាហកម្ម។ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-គណៈកម្មាការប្រឹក្សាការងារ<br>-គណៈកម្មាការផលិតភាពកម្ពុជា | |
| | ៤.៣.១.១. ពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ឥរិយាបថវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត<br>*អនុវិធានការ នៃវិធានការនេះ* | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ ទំនាក់ទំនងប្រកបដោយផលិតភាពរវាងនិយោជក និងនិយោជិត<br>- មធ្យោបាយ÷ ពង្រឹងយន្តការនៃការធ្វើសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ (មិនប្រាកដថាយន្តការសុខដុមនីយកម្មដំណើរការយ៉ាងដូចម្តេច) | | |
| | ៤.៣.២. បន្តពង្រឹងយន្តការទំនាក់ទំនងត្រីភាគី រួមមាន រដ្ឋាភិបាល និយោជក និងនិយោជិត តាមរយៈ "គណៈកម្មការប្រឹក្សាការងារ" ដើម្បីបង្កើនការយោគយល់គ្នាទន្ទឹមនឹងការខិតខំរៀបចំប្រព័ន្ធយន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ដែលស៊ីចង្វាក់ទៅនឹងផលិតភាពការងារ សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ចសង្គម និងធានាបាននូវការអភិវឌ្ឍឧស្សាហកម្មជារួម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ រដ្ឋាភិបាល និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ បង្កើនការយោគយល់គ្នា និងសម្រេចបានលើការកំណត់ប្រាក់ឈ្នួលអប្បបរមា ក្នុងចំណោមរដ្ឋាភិបាល និយោជក និងនិយោជិត<br>- មធ្យោបាយ÷ ពង្រឹងយន្តការទំនាក់ទំនងត្រីភាគីបន្ថែមទៀត<br>ទាំងនិយោជក និងនិយោជិតនឹងមានទំនាក់ទំនង និងការយោគយល់គ្នាខ្លាំងឡើង ក្នុងសកម្មភាពការងារប្រចាំថ្ងៃ។ យន្តការនេះនឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនៃគុណភាពការងារ។ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួង/ស្ថាប័នពាក់ព័ន្ធ | |

| | | | | |
|---|---|---|---|---|
| | ៤.៣.៣. ផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវទៅលើទំនាក់ទំនងរវាងបុគ្គលិក និយោជិត និងនិយោជក ដើម្បីកំណត់ពីបទពិសោធល្អៗក្នុងការស្វែងរកដំណោះស្រាយជាប្រព័ន្ធមួយដែលអាចបង្កើនផលិតផលសរុប ជាពិសេសការបណ្តុះបណ្តាលអាជីពក្នុងការដោះស្រាយបញ្ហារបស់កម្មករ ស្របទៅតាមច្បាប់ការងារ និងបទប្បញ្ញត្តិជាធរមាន | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ ដំណោះស្រាយជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាពនៃជម្លោះឧស្សាហកម្ម<br>- មធ្យោបាយ÷ ធ្វើការស្រាវជ្រាវលើទំនាក់ទំនងរវាងនិយោជិក និងនិយោជក។<br>មិនមានបច្ច័យភ្លាមៗទេ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| | ៤.៣.៤. រៀបចំច្បាប់ស្តីពីសហជីពនិងច្បាប់ស្តីពីតុលាការការងារ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ រដ្ឋាភិបាល និយោជក និយោជិត និងសហជីព<br>- លទ្ធផលរំពឹងទុក÷ ពង្រឹងការការពារសិទ្ធិរបស់កម្មករ<br>- មធ្យោបាយ÷ រៀបចំ និងអនុវត្តច្បាប់ស្តីពីសហជីព (និងច្បាប់ស្តីពីតុលាការការងារ)<br>នឹងមានច្បាប់ច្បាស់លាស់ និងជាក់លាក់ដើម្បីគ្របដណ្តប់លើទិដ្ឋភាពការងារ ដែលក្រុមគោលដៅពាក់ព័ន្ធទាំងអស់ត្រូវរៀបចំឡើងស្របតាមបទបញ្ញត្តិច្បាស់លាស់ និងស្មើភាពគ្នា។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| | ៤.៣.៥. ពិនិត្យឡើងវិញពីច្បាប់ការងារ និងការអនុវត្តកន្លងមក ដើម្បីស្វែងរកចំណុចវិជ្ជមាន និង ចំណុចអវិជ្ជមាន ហើយធ្វើការគូសបញ្ជាក់ឡើងវិញពីតួនាទីរបស់និយោជក និងសហជីពក្នុងដំណើរការអភិវឌ្ឍទីផ្សារការងារ ដែលថ្លឹងបាននូវតុល្យភាពនៃការអភិវឌ្ឍ និងសុខុមាលភាព កម្មករ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក សហជីព និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ យន្តការចរចាដែលមានប្រសិទ្ធិភាពរវាងនិយោជក និងនិយោជិត<br>- មធ្យោបាយ÷ ពិនិត្យឡើងវិញពីច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសន្តិសុខសង្គម<br>និយោជក និងសហជីពនឹងអាចអនុវត្តតួនាទីកាន់តែមានប្រសិទ្ធភាព ក្នុងដំណើរការអភិវឌ្ឍទីផ្សារការងារ ដែលថ្លឹងបាននូវតុល្យភាពនៃការអភិវឌ្ឍ និងសុខុមាលភាព កម្មករ។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| | ៤.៣.៦. រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ គោលនយោបាយការងារជាតិប្រកបដោយប្រសិទ្ធភាព<br>- មធ្យោបាយ÷ រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ<br>នឹងមានគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ដែលអាចផ្តល់នូវទិសដៅច្បាស់លាស់ និងតម្រូវការនៃការវាយតម្លៃលើការងារ។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |

| | | | | |
|---|---|---|---|---|
| **៤.៤. ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ការងារ (៣)**<br><br>**វិធានការច្បាស់លាស់ = ១**<br>**វិធានការមិនច្បាស់លាស់ = ២**<br>**វិធានការត្រៀម = 0** | ៤.៤.១. ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាពនិងសិទ្ធិស្របច្បាប់របស់ខ្លួន ពិសេស កាត់បន្ថយការចំណាយហួសហេតុក្នុងការទទួលបានការងារ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ ការផ្គូផ្គងការងារបានល្អប្រសើរ និងកាត់បន្ថយការចំណាយក្រៅផ្លូវការ ក្នុងការទទួលបានការងារ<br>- មធ្យោបាយ÷ ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាពនិងសិទ្ធិស្របច្បាប់របស់ខ្លួន<br>នៅពេលដែលយន្តការ និងការផ្តល់ឱ្យទាំងនេះត្រូវបានពង្រឹងទាំងស្រុង និយោជកនឹងមានភាពងាយស្រួលក្នុងការជ្រើសរើសនិយោជិតតាមចំណង់ចំណូលចិត្តរបស់ពួកគេ។ និយោជិតក៏ទទួលបានការងារត្រឹមត្រូវផងដែរ។ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ទីភ្នាក់ងារជាតិមុខរបរ | |
| | ៤.៤.២. ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជិត<br>- លទ្ធផលរំពឹងទុក÷ យន្តការដ៏មានប្រសិទ្ធភាពមួយ ក្នុងការគ្រប់គ្រងកម្មករជំនាញ<br>- មធ្យោបាយ÷ មិនបានបង្ហាញច្បាស់។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| | ៤.៤.៣. ពង្រឹងការយល់ដឹងអប់រំអំពីការចាប់អាជីពនិងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្ត ដើម្បីអភិវឌ្ឍជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ សិស្ស<br>- លទ្ធផលរំពឹងទុក÷ ការផ្គូផ្គងការងារ<br>- មធ្យោបាយ÷ មិនមានមធ្យោបាយសម្រាប់ការអនុវត្តច្បាស់លាស់ទេ។ | ក្រសួងអប់រំ យុវជន និងកីឡា | |
| **៤.៥. ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ (៥)**<br><br>**វិធានការច្បាស់លាស់ = ៥**<br>**វិធានការមិនច្បាស់លាស់ = 0**<br>**វិធានការត្រៀម = 0** | ៤.៥.១. ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្មនិងការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ត្រីភាគីវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ជាអាទិ៍យន្តការ "គណៈកម្មការប្រឹក្សាការងារ" និង "គណៈកម្មាធិការផលិតភាពកម្ពុជា" | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជក និងនិយោជិត<br>- លទ្ធផលរំពឹងទុក÷ ទំនាក់ទំនងប្រកបដោយផលិតភាពរវាងនិយោជិក និងនិយោជិត<br>- មធ្យោបាយ÷ ពង្រឹងយន្តការនៃការធ្វើសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ (មិនប្រាកដថាយន្តការសុខដុមនីយកម្មដំណើរការយ៉ាងដូចម្តេច)<br>តាមរយៈការធ្វើដូច្នេះ វាមិនត្រឹមតែជួយបង្កើនភាពប្រកួតប្រជែង និងផលិតភាពរបស់ឧស្សាហកម្មប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងជួយលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករ ដែលរួមចំណែកការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ។ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-គណៈកម្មាការប្រឹក្សាការងារ<br>-គណៈកម្មាការផលិតភាពកម្ពុជា | |

| | | | |
|---|---|---|---|
| ៤.៥.១.១. ពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមាដោយប្រើប្រាស់យន្តការមានស្រាប់ " គណៈកម្មាធិការប្រឹក្សាការងារ" /" ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា"<br>*អនុវិធានការដែលត្រូវបានបំបែកចេញពីវិធានការក្នុងអន្តរាគមន៍គោលនយោបាយ ៤.៣* | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ និយោជិត<br>- លទ្ធផលរំពឹងទុក÷ ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់កម្មករ<br>- មធ្យោបាយ÷ ការបង្កើតក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា និងការអនុម័តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា | | |
| ៤.៥.២. កំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មផ្សេងទៀត | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិនិយោគិន និងកម្មករ។<br>- លទ្ធផលរំពឹងទុក÷ មានឯកសារបទដ្ឋាន និងគោលការណ៍ច្បាស់លាស់ស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម។<br>- មធ្យោបាយ÷ ចេញបទប្បញ្ញត្តិពាក់ព័ន្ធលើបទដ្ឋាន និងគោលការណ៍ណែនាំនៃការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម។ រាល់គម្រោងវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មផ្សេងទៀតនឹងអនុវត្តតាមបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្មដែលនឹងរួមចំណែកដល់ទាំងការងារ និងជីវភាពរស់នៅរបស់កម្មករ។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងបរិស្ថាន | |
| ៤.៥.៣. ពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ តាមរយៈការពង្រីកកម្មវិធីរោងចក្រល្អប្រសើរ ឬពិនិត្យលទ្ធភាពក្នុងការបង្កើតក្រុមការងារចម្រុះធ្វើអធិការកិច្ចជាប្រចាំ និងមានកម្មវិធីច្បាស់លាស់ ដើម្បីកាត់បន្ថយចំនួនត្រួតពិនិត្យផង និងធានាបានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យផង។ ក្រុមការងារចម្រុះនេះត្រូវរាយការណ៍ជាទៀងទាត់ជូនរាជរដ្ឋាភិបាល | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុន និងរោងចក្រ<br>- លទ្ធផលរំពឹងទុក÷ យន្តការអធិការកិច្ចដែលមានប្រសិទ្ធភាពសម្រាប់លក្ខខណ្ឌការងារល្អប្រសើរ<br>- មធ្យោបាយ÷ ពង្រីកកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងបង្កើតជាក្រុមការងារ សម្រាប់ការចុះធ្វើអធិការកិច្ចឱ្យបានទៀងទាត់ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| ៤.៥.៤. លើកកម្ពស់សុខុមាលភាពរបស់កម្មករ តាមរយៈការជំរុញអនុវត្តគោលនយោបាយលំនៅឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេ អាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ កម្មករ។<br>- លទ្ធផលរំពឹងទុក÷ សុខុមាលភាពរបស់កម្មករគឺត្រូវបានលើកកម្ពស់ និងកែលម្អ។<br>- មធ្យោបាយ÷ បង្កើតគោលនយោបាយលំនៅដ្ឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេ អាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋាន។<br><br>កម្មករនឹងអាចមានសុខុមាលភាពសង្គមល្អប្រសើរ នៅពេលពួកគេកំពុងធ្វើការ។ នេះក៏អាចរួមចំណែកក្នុងការកាត់បន្ថយបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី។ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | |

| | | | | |
|---|---|---|---|---|
| | ៤.៥.៥. ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និងការកែទម្រង់មូលនិធិសោធន និងវិស័យធានារ៉ាប់រង ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ កម្មករ/និយោជិត<br>- លទ្ធផលរំពឹងទុក÷ ធ្វើឱ្យប្រសើរឡើងនូវមូលប័ត្រហិរញ្ញវត្ថុរបស់កម្មករ / និយោជិត<br>- មធ្យោបាយ÷ ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និងការកែទម្រង់មូលនិធិសោធន និងវិស័យធានារ៉ាប់រង ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងសង្គមកិច្ច យុវនីតិសម្បទា និងអតីតយុទ្ធជន<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| ៥. បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា | | | | |
| ៥.១. ការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស (ព្រមទាំងការផ្ទេរបច្ចេកវិទ្យា)<br>(៣)<br><br>វិធានការច្បាស់លាស់ = 0<br>វិធានការមិនច្បាស់លាស់ = ១<br>វិធានការត្រៀម = ២ | ៥.១.១. សិក្ខាសាលាស្តីពីបច្ចេកវិទ្យាឧស្សាហកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែច្រវាក់តម្លៃ និងខ្សែច្រវាក់ផលិតកម្មតំបន់ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ សហគ្រាស/ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ ជំរុញការតភ្ជាប់រវាងសហគ្រាសក្នុងស្រុក និងធំបរទេស<br>- មធ្យោបាយ÷ អភិវឌ្ឍឧស្សាហកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក និងលើកកម្ពស់ការតភ្ជាប់ជាមួយសហគ្រាសធុនតូចនិងមធ្យមបរទេស<br>មិនមានបច្ច័យភ្លាមៗទេ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ | |
| | ៥.១.២. ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមសម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និងទំនើបកម្មនៃខ្សែច្រវាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ សហគ្រាសធុនតូចនិងមធ្យម<br>- លទ្ធផលរំពឹងទុក÷ សហគ្រាសធុនតូចនិងមធ្យមកាន់តែច្រើនវិនិយោគលើផ្នែកគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម<br>- មធ្យោបាយ÷ ពិនិត្យ និងពិចារណា ផ្តល់ការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យមទាំងនោះ<br>មិនមានបច្ច័យភ្លាមៗទេ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | ៥.១.៣. ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញ យកផលប្រយោជន៍ពីសក្តានុពលសហគ្រាសនិងវិនិយោគបរទេសធំៗ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស | វិធានការមិនច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាសក្នុងស្រុក<br>- លទ្ធផលរំពឹងទុក÷ ការផ្សារភ្ជាប់មានភាពស្មើគ្នាកាន់តែច្រើនក្នុងការធ្វើពាណិជ្ជកម្មរវាងសហគ្រាសក្នុងស្រុក និងសហគ្រាសបរទេសធំៗ<br>- មធ្យោបាយ÷ មធ្យោបាយដើម្បីសម្រេចបាននូវវិធានការនេះគឺមិនច្បាស់លាស់ទេ។ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| ៥.២. ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | | |

| | | | | |
|---|---|---|---|---|
| ៥.៣ បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | | |
| ៥.៤. បង្កើនការកែច្នៃកសិកម្មក្នុងស្រុក (៤)<br><br>វិធានការច្បាស់លាស់ = ២<br>វិធានការមិនច្បាស់លាស់ = 0<br>វិធានការត្រៀម = ២ | ៥.៤.១. ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជាតំបន់កែច្នៃ និងផលិតសង្ហារិម តំបន់កែច្នៃផលិតសម្ភារៈពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេសដោយប្រើប្រាស់យន្តការភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជន | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ តំបន់កែច្នៃកសិផលត្រូវបានបង្កើតឡើង<br>- មធ្យោបាយ÷ មិនមានឧបករណ៍ច្បាស់លាស់ទេ<br>មិនមានបច្ច័យភ្លាមៗទេ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| | ៥.៤.២. ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ គម្រោងវិនិយោគកាន់តែច្រើននៅក្នុងតំបន់កែច្នៃកសិផល<br>- មធ្យោបាយ÷ ផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនទាំងឡាយណាដែលបានទីតាំងនៅក្នុងតំបន់កែច្នៃកសិផល<br>ការវិនិយោគកាន់តែច្រើនលើការកែច្នៃកសិផលអាចជួយបង្កើនខ្សែច្រវាក់តម្លៃជាតិ។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | ៥.៤.៣. រៀបចំនូវយន្តការសម្រួលដល់ការនាំចេញ កសិផលកែច្នៃ ដោយដោះស្រាយបញ្ហាភស្តុភារកម្ម លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ វិស័យឯកជន<br>- លទ្ធផលរំពឹងទុក÷ ដោះស្រាយបញ្ហាភស្តុភារកម្ម ការលុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម<br>- មធ្យោបាយ÷ រៀបចំនូវយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ<br>ដោយមានយន្តការសម្របសម្រួលច្បាស់លាស់សម្រាប់ការនាំចេញកសិផលកែច្នៃ សកម្មភាពដែលទាក់ទងនឹងការកែច្នៃកសិផលនឹងកើនឡើង។ | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | ៥.៤.៤. សិក្សាកំណត់នូវមុខទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយផ្អែកលើខ្សែច្រវាក់តម្លៃ ដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ។ | វិធានការត្រៀម<br>- ក្រុមគោលដៅ÷ ក្រុមហ៊ុនកែច្នៃកសិផល<br>- លទ្ធផលរំពឹងទុក÷ តំហើញពីការសិក្សា អាចជួយឱ្យរដ្ឋាភិបាលផ្តល់ការគាំទ្រយ៉ាងជាក់លាក់ដល់ការនាំចេញផលិតផលអាទិភាពដែលបានកែច្នៃ<br>- មធ្យោបាយ÷ សិក្សាកំណត់នូវមុខទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយផ្អែកលើខ្សែច្រវាក់តម្លៃ<br>មិនមានបច្ច័យភ្លាមៗទេ | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | | |
|---|---|---|---|---|
| **វិធានការទូទៅដែលមិនត្រូវនឹងអន្តរាគមន៍គោលនយោបាយ (៦)**<br><br>**វិធានការច្បាស់លាស់ = ៦**<br>**វិធានការមិនច្បាស់លាស់ = 0**<br>**វិធានការត្រៀម = 0** | ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោង វិនិយោគ ដើម្បីធានាការគោរពគោលការណ៍និងលក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគ ព្រមទាំងអនុលោមភាពនៃច្បាប់កម្ពុជាជាធរមាន | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់<br>- លទ្ធផលរំពឹងទុក÷ ធានាបាននូវគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងគោរពតាមអនុលោមភាពនៃច្បាប់<br>- មធ្យោបាយ÷ តាមរយៈក្រុមត្រួតពិនិត្យ និងវាយតម្លៃនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| | ធ្វើចារណកម្មយន្តការប្រមូលចំណូល និងកែលម្អសេវាអ្នកជាប់ពន្ធ សំដៅលើកកម្ពស់វប្បធម៌បង់ពន្ធ ក្នុងចំណោមសហគ្រាស និងអ្នកជាប់ពន្ធគ្រប់ប្រភេទ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ សហគ្រាស និងអ្នកជាប់ពន្ធ<br>- លទ្ធផលរំពឹងទុក÷ លើកកម្ពស់វប្បធម៌បង់ពន្ធ ក្នុងចំណោមសហគ្រាស និងអ្នកជាប់ពន្ធគ្រប់ប្រភេទ<br>- មធ្យោបាយ÷ មិនមានមធ្យោបាយច្បាស់លាស់សម្រាប់ការអនុវត្តទេ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | បង្កើនការផ្តល់សេវាដើម្បីឱ្យអ្នកជាប់ពន្ធងាយស្រួលទទួលព័ត៌មានពីការបង់ពន្ធ និងការលើកលែងពន្ធ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ អ្នកជាប់ពន្ធ<br>- លទ្ធផលរំពឹងទុក÷ ផ្តល់ព័ត៌មានពីការបង់ពន្ធ និងការលើកលែងពន្ធ ដល់អ្នកជាប់ពន្ធ<br>- មធ្យោបាយ÷ តាមរយៈការបង្កើតមជ្ឈមណ្ឌលហៅទូរស័ព្ទ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | ពិនិត្យ និងសម្រួលឡើងវិញនូវក្របខ័ណ្ឌនៃការអនុវត្ត ដោយសម្រួល ឬដកចេញនូវយន្តការ ទាំងឡាយណាដែលបណ្តាលឱ្យខ្វាស់គ្នារវាង នីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ អ្នកជាប់ពន្ធ<br>- លទ្ធផលរំពឹងទុក÷ ជៀសវៀងភាពខ្វាស់គ្នារវាង នីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ<br>- មធ្យោបាយ÷ ពិនិត្យ និងកែលម្អនីតិវិធីនៃការយកពន្ធ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជ និង ការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រសួងពាក់ព័ន្ធ/រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក÷ ដឹកនាំ / តំរង់ទិសការបែងចែកថវិកាសាធារណៈសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម<br>- មធ្យោបាយ÷ តាមរយៈការអភិវឌ្ឍន៍កម្មវិធីវិនិយោគសាធារណៈ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រសួងផែនការ | |
| | ផ្តល់អាទិភាពខ្ពស់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ សម្រាប់សកម្មភាពគម្រោងនិងកម្មវិធីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម កន្សោមឧស្សាហកម្ម ឬច្រៀងឧស្សាហកម្ម | វិធានការច្បាស់លាស់<br>- ក្រុមគោលដៅ÷ ក្រសួងពាក់ព័ន្ធ/រដ្ឋាភិបាល<br>- លទ្ធផលរំពឹងទុក÷ កំណត់អាទិភាពក្នុងកម្មវិធីវិនិយោគសាធារណៈសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម<br>- មធ្យោបាយ÷ តាមរយៈការអភិវឌ្ឍសកម្មភាពគម្រោង និងកម្មវិធីវិនិយោគសាធារណៈ | -ក្រសួងផែនការ<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |

# បញ្ជីពាក្យកាត់

## បញ្ជីពាក្យកាត់ជាភាសាខ្មែរ

| | |
|---|---|
| ក.ស.ហ.វ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ក.អ.ក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| គ.ជ.នា | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| គ.ប | គោលបំណង |
| គ.ល.គ | គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប |
| ប.ស.ស | បេឡាជាតិរបបសន្តិសុខសង្គម |
| អ.គ | អន្តរាគមន៍គោលនយោបាយ |

## បញ្ជីពាក្យកាត់សំខាន់ៗជាភាសាបរទេស

| | | |
|---|---|---|
| AAGR | Annual Average Growth Rate | អត្រាកំណើនមធ្យមប្រចាំឆ្នាំ (ប្រើចំពោះតួលេខទិន្នន័យដែលមានតម្លៃផលធៀប) |
| AQRFC | ASEAN Qualifications Reference Framework Committee | គណៈកម្មាធិការក្របខណ្ឌយោងអាស៊ាន |
| API | Additional Progress Indicator | សូចនាករវឌ្ឍនភាពបន្ថែម |
| CAGR | Compound Annual Growth Rate | អត្រាកំណើនមធ្យមប្រចាំឆ្នាំ (ប្រើចំពោះតួលេខទិន្នន័យដែលមានតម្លៃដាច់ខាត) |
| CBTA | Cross-Border Transport Facilitation Agreement | កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន |
| EQuIP | Enhancing the Quality of Industrial Policies | ឯកសារស្តីពីការធ្វើឱ្យប្រសើរឡើងនូវគុណភាពគោលនយោបាយវិស័យឧស្សាហកម្ម |

| | | |
|---|---|---|
| FDI | Foreign Direct Investment | ការវិនិយោគផ្ទាល់ពីបរទេស |
| GIZ | Deutsche Gesellschaft f¬r Internationale Zusammenarbeit | ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| GPSF | Government-Private Sector Forum | វេទិការាជរដ្ឋាភិបាលផ្នែកឯកជន |
| IDP | Cambodia Industrial Development Policy | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា |
| IFC | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| ILO | International Labor Organization | អង្គការអន្តរជាតិខាងការងារ |
| KPIs | Key Performance Indicators | សូចនាករគន្លឹះ |
| MNCs | Multinational Corporations | សាជីវកម្មពហុជាតិ |
| MHT | Medium and High Technology | បច្ចេកវិទ្យាមធ្យម និងខ្ពស់ |
| MTR | Mid-Term Review | ការវាយតម្លៃពាក់កណ្ដាលអាណត្តិ |
| MVA | Manufacturing Value Added | តម្លៃបន្ថែមកម្មន្តសាល |
| M&E | Monitoring and Evaluation | ការតាមដាន និងវាយតម្លៃ |
| P.A | Per Annum | ក្នុងមួយឆ្នាំ |
| PCP | Programme for Country Partnership | កម្មវិធីសម្រាប់ភាពជាដៃគូប្រចាំប្រទេស |
| RTF | Report Template Format | ទម្រង់គំរូរបាយការណ៍ |
| R&D | Research and Development | ការស្រាវជ្រាវ និងការអភិវឌ្ឍ |
| SMEs | Small and Medium Enterprises | សហគ្រាសធុនតូច និងមធ្យម |
| STEM | Science, Technology, Engineering and Math | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| STI Roadmap | Science, Technology, Innovation Roadmap | ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| TVET | Technical and Vocational Education and Training | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |

| | | |
|---|---|---|
| UNIDO | United Nations Industrial Development Organization | អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម |
| UN-COMTRADE | United Nations International Trade Statistics Database | ប្រព័ន្ធទិន្នន័យស្ថិតិពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ |
| WDI | World Development Indicators | ប្រព័ន្ធទិន្នន័យសូចនាករអភិវឌ្ឍន៍ពិភពលោករបស់ធនាគារពិភពលោក |
| WITS | World Integrated Trade Solution | ប្រព័ន្ធទិន្នន័យពាណិជ្ជកម្មពិភពលោករបស់ធនាគារពិភពលោក |
| N/A | Not Applicable | មិនមានព័ត៌មាន |
| CamDX | Cambodia Data eXchange | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |

# បញ្ជី រូបភាព និងតារាង

ក. រូបភាព និងតារាងនៅក្នុងខ្លឹមសាររបាយការណ៍

## រូបភាព


រូបភាពទី១ តក្កកម្មអន្តរាគមន៍គោលនយោបាយ IDP........................................................................ ៥

រូបភាពទី២ ចំណែកនៃវិស័យឧស្សាហកម្ម និងកម្មន្តសាលក្នុង ផ.ស.ស ................................................ ៦

រូបភាពទី៣ ចំណែកនៃការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យម និងខ្ពស់ (MHT) ក្នុងការនាំចេញទំនិញកម្មន្តសាលសរុប ............................................................................................................. ៧

រូបភាពទី៤ តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់............................................. ១០

រូបភាពទី៥ តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់.............................................. ១០

រូបភាពទី៦ ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ ................................................... ១៩

រូបភាពទី៧ ចំណែកនៃការនាំចេញកសិផលកែច្នៃក្នុងការនាំចេញសរុប ............................................. ២០

រូបភាពទី៨ ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្ត-សាល.......................................................................................................................... ២៩

រូបភាពទី៩ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងផលិតស្បែកជើង ធៀបនឹងការនាំចេញសរុប................................................................................................................. ៣០

រូបភាពទី១០ ចំនួនការងារនៅក្នុងវិស័យកម្មន្តសាលដែលមិនមែនកាត់ដេរ.......................................... ៤៣

រូបភាពទី១១ ចំណែកនៃការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុប ............................... ៤៤

រូបភាពទី១២ ជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាល...................................................................... ៥៥

រូបភាពទី១៣ កំណើន ផ.ស.ស និងការចូលរួមចំណែកតាមវិស័យ ........................................................ ៦៦

រូបភាពទី១៤ ចំនួនការងារផ្លូវការថ្មីដែលបានចុះបញ្ជី ............................................................................ ៦៧

រូបភាពទី១៥ ចំនួនការងារក្នុងវិស័យកម្មន្តសាលនៅកម្ពុជា..................................................................... ៦៧

រូបភាពទី១៦ អត្រាភាពក្រីក្រ .............................................................................................................. ៦៨

រូបភាពទី១៧ ការវាយតម្លៃជារួមលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ IDP............................ ៧៦

រូបភាពទី១៨ ការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ IDP ក្នុងគោលបំណងទាំង ៥ ...................... ៧៧


## តារាង


តារាងទី១ តារាងសង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់ គ.ប ទី១ .................................................................................................................. ១៣

តារាងទី២ តារាងសង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់ គ.បទី២ .................................................................................................................. ២២

តារាងទី៣ តារាងសង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់ គ.ប ទី៣ .................................................................................................................. ៣២

តារាងទី៤ តារាងសង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់ គ.ប ទី៤ .................................................................................................................. ៤៦

តារាងទី៥ តារាងសង្ខេបអំពីសមិទ្ធកម្ម ការរៀបចំគោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយ របស់ គ.ប ទី៥ ....៤៦
តារាងទី៦ ធនធានរយៈពេលមធ្យមឆ្នាំ២០១៥-២០២០ គាំទ្រគោលនយោបាយ IDP ....៧០
តារាងទី៧ បម្រែបម្រួលអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស នៃប្រទេសមួយចំនួន ....៨០
តារាងទី៨ បម្រែបម្រួលអនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស នៃប្រទេសមួយចំនួន ....៨២

ខ. រូបភាព និងតារាងនៅក្នុងឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១**

**រូបភាព**

រូបភាពទី១.១ ផលធៀបរវាងការនាំចូលផលិតផលកម្មន្តសាលធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល....១
រូបភាពទី១.២ ការវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម ....២
រូបភាពទី១.៣ លំហូរទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល....៣
រូបភាពទី១.៤ ចំណែកនៃការវិនិយោគលើសម្ភារៈបរិក្ខារជាប់បានយូរ (Durable equipment) ធៀបនឹងការកកើតទុនអចល័តសរុប (Gross Fixed Capital Formation) ....៤
រូបភាពទី១.៥ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម" ....៥
រូបភាពទី១.៦ ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម" ....៨
រូបភាពទី១.៧ ផលិតភាពការងារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ....១១
រូបភាពទី១.៨ ផលិតភាពការងារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ប្រៀបធៀបនឹងប្រទេសមួយចំនួន....១២
រូបភាពទី១.៩ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនផលិតភាពការងាររបស់សហគ្រាស" .... ១៣
រូបភាពទី១.១០ ផលធៀបរវាងការនាំចូលផលិតផលមូលធនធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ....១៤
រូបភាពទី១.១១ ការវាយតម្លៃលើការអនុវត្តវិធានការក្នុងអន្តរាគមន៍គោលនយោបាយ "ការធ្វើឱ្យប្រសើរឡើងកម្រិតបច្ចេកវិទ្យារបស់សហគ្រាស ....១៦
រូបភាពទី១.១២ ការវាយតម្លៃទៅលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក/សហគ្រាសធុនតូចនិងមធ្យម" .... ២១
រូបភាពទី១.១៣ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក ....២២
រូបភាពទី១.១៤ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវដែក ....២៣
រូបភាពទី១.១៥ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់កំពង់ផែ ....២៤
រូបភាពទី១.១៦ បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាស ....២៤
រូបភាពទី១.១៧ ការប្រៀបធៀបបរិមាណទំនិញដឹកជញ្ជូនតាមគ្រប់បណ្តាញគមនាគមន៍ ....២៥
រូបភាពទី១.១៨ ស្ថានភាពនៃការអភិវឌ្ឍច្រកទ្វារព្រំដែន ....២៦
រូបភាពទី១.១៩ ស្ថានភាពនៃការប្រើប្រាស់ និងវិសាលភាពគ្របដណ្តប់នៃសេវាអ៊ីនធឺណិត ....២៦
រូបភាពទី១.២០ វិសាលភាពគ្របដណ្តប់នៃអគ្គិសនី ....២៧
រូបភាពទី១.២១ ស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី ....២៨

រូបភាពទី១.២២ ថ្លៃលក់អគ្គិសនីតាមប្រភពនៃការទិញសម្រាប់ការប្រើប្រាស់ក្នុងឧស្សាហកម្ម ........................២៩
រូបភាពទី១.២៣ ចង្កោមទាំងបួននៃវិធានការដែលគាំទ្រដល់អន្តរាគមន៍គោលនយោបាយ "ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់" ........................................................ ៣១
រូបភាពទី១.២៤ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់" ....................................... ៣៤
រូបភាពទី១.២៥ ចំនួនក្រុមហ៊ុននិងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជី .........................................៣៦
រូបភាពទី១.២៦ ចំនួនមុខទំនិញនាំចេញ .......................................................................................៣៧
រូបភាពទី១.២៧ ចំនួនមុខទំនិញកម្មន្តសាលនាំចេញពីកម្ពុជា ...........................................................៣៧
រូបភាពទី១.២៨ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ" .......................................................................................... ៤១
រូបភាពទី១.២៩ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់៥នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប .............................................................................................................៤៣
រូបភាពទី១.៣០ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់៣នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប ...................................................................................................៤៤
រូបភាពទី១.៣១ ចំនួនទីផ្សារនាំចេញដែលមានទំហំលើសពី ១០លានដុល្លារអាមេរិក .................................៤៤
រូបភាពទី១.៣២ ចង្កោមទាំងបួននៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ពង្រីក និងពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ" ........................................................................................... ៤៦
រូបភាពទី១.៣៣ ការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ការពង្រីក និងការធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ" .............................................................. ៤៨
រូបភាពទី១.៣៤ ចំណែកនៃចំនួនការងារដែលផ្តល់ដោយសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម ...........................................................................................៥០
រូបភាពទី១.៣៥ ការវាយតម្លៃទៅលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនតុល្យភាពឡើងវិញរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម" ............................... ៥៣
រូបភាពទី១.៣៦ ចំនួនប្រកាសនីយបត្រតក្កកម្មជាធរមាន ................................................................៥៥
រូបភាពទី១.៣៧ ចំនួនប្រកាសនីយបត្រតក្កកម្មដែលផ្តល់ជូន ...........................................................៥៦
រូបភាពទី១.៣៨ ចង្កោមទាំងពីរនៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "បង្កើននវានុវត្តន៍ផ្នែកឧស្សាហ-កម្ម" ........................................................................................................................៥៧
រូបភាពទី១.៣៩ ការវាយតម្លៃទៅលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើននវា-នុវត្តន៍ផ្នែកឧស្សាហកម្ម" ............................................................................................ ៦១
រូបភាពទី១.៤០ អត្រាចុះបញ្ជីសហគ្រាសធុនតូច ធុនមធ្យម និងធុនធំ ...................................................៦៤
រូបភាពទី១.៤១ អត្រាសហគ្រាសធុនតូច ធុនមធ្យម និងធុនធំដែលមានតារាងតុល្យការ ឬកាន់បញ្ជីគណនេយ្យសាមញ្ញ ....................................................................................................................៦៥
រូបភាពទី១.៤២ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម" ....................................................................................................៦៦

រូបភាពទី១.៤៣ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម" ...................................................... ៦៩
រូបភាពទី១.៤៤ ចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សានិងឧត្តមសិក្សាក្នុងចំនួនប្រជាជនគ្រប់អាយុចូលរៀន ...................................................... ៧២
រូបភាពទី១.៤៥ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និងអត្រានិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ...................................................... ៧៣
រូបភាពទី១.៤៦ ស្ថានភាពនៃកម្លាំងពលកម្មយុវវ័យក្មេងដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ ...................................................... ៧៤
រូបភាពទី១.៤៧ ចង្កោមទាំងពីរនៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស" ...................................................... ៧៥
រូបភាពទី១.៤៨ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស" ...................................................... ៧៨
រូបភាពទី១.៤៩ ចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្ម ...................................................... ៧៩
រូបភាពទី១.៥០ ចំនួនកម្លាំងពលកម្មជំនាញ ...................................................... ៨០
រូបភាពទី១.៥១ ប្រាក់ឈ្នួលអប្បបរមា ...................................................... ៨១
រូបភាពទី១.៥២ ភាគរយនៃវិវាទការងារ (ធំៗ) ដែលបានដោះស្រាយ ...................................................... ៨២
រូបភាពទី១.៥៣ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ" ...................................................... ៨៣
រូបភាពទី១.៥៤ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ពង្រឹងទំនាក់ទំនងវិជ្ជាជីវៈ" ...................................................... ៨៥
រូបភាពទី១.៥៥ អត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះបញ្ហាគម្លាតជំនាញ ...................................................... ៨៧
រូបភាពទី១.៥៦ ចំណែកនៃសហគ្រាសរាយការណ៍ដែលមានស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ក្នុងចំនួនសហគ្រាសសរុបដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្មយ៉ាងតិចមួយ ...................................................... ៨៨
រូបភាពទី១.៥៧ ការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវការផ្គូផ្គងការងារ" ...................................................... ៩១
រូបភាពទី១.៥៨ អត្រាសហគ្រាស គ្រឹះស្ថាន ដែលមានសេវាសង្គ្រោះអប្បបរមា ...................................................... ៩២
រូបភាពទី១.៥៩ ចំនួន (តួលេខស្តុក) កម្មករនិយោជិតដែលទទួលបានបណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ...................................................... ៩៣
រូបភាពទី១.៦០ ចង្កោមទាំង៣នៃវិធានការដែលគាំទ្រអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ" ...................................................... ៩៤
រូបភាពទី១.៦១ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ" ...................................................... ៩៧
រូបភាពទី១.៦២ លទ្ធផលវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "ការពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា" ......១០២
រូបភាពទី១.៦៣ ចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប...១០៣

រូបភាពទី១.៦៤ ចំណែកនៃចំនួនគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី៥១% ឡើងទៅ ធៀបនឹងចំនួនគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សរុប ........................................................................................................................១០៤
រូបភាពទី១.៦៥ ចំណែកនៃចំនួនការងារសរុបដែលបានបង្កើតដោយសហគ្រាសបរទេសធៀបនឹងចំនួនការងារសរុប.........................................................................................................................១០៥
រូបភាពទី១.៦៦ ការនាំចេញកសិផលកែច្នៃ .........................................................................................១០៦
រូបភាពទី១.៦៧ ការវាយតម្លៃលើការអនុវត្តវិធានការគោលនយោបាយក្នុងអន្តរាគមន៍គោលនយោបាយ "បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកនិងនាំចេញ" ...........................១០៩

**ឧបសម្ព័ន្ធទី២**

**តារាង**

តារាងទី២.១ ទម្រង់គំរូនៃផែនការសកម្មភាពដែលមានលក្ខណៈពេញលេញ ..........................................១១១
តារាងទី២.២ ឧទាហរណ៍នៃប្រភេទវិធានការគោលនយោបាយទាំង៤ ..................................................១១២
តារាងទី២.៣ ឧទាហរណ៍នៃវិធានការច្បាស់លាស់ និងវិធានការមិនច្បាស់លាស់ .....................................១១២
តារាងទី២.៤ បញ្ជីវិធានការដែលមានវិសាលភាពទូលំទូលាយ និងស្មុគស្មាញ..................................,........១១៤
តារាងទី២.៥ បញ្ជីលម្អិតនៃវិធានការកំពុងអនុវត្ត និងវិធានការយឺតយ៉ាវដែលតម្រូវឱ្យពន្លឿនការអនុវត្តក្នុងដំណាក់-កាលទី២ ........................................................................................................................១១៩

**រូបភាព**

រូបភាពទី២.១ វិធានការកំពុងអនុវត្ត និងវិធានការយឺតយ៉ាវដែលតម្រូវឱ្យពន្លឿនការអនុវត្តក្នុងដំណាក់កាលទី២..១១៨

## គណៈគ្រប់គ្រង៖ គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- ឯកឧត្តម ជិន ប៊ុនស៊ាន — ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធាន ក.អ.ក.
- ឯកឧត្តម សុខ ចិន្តាសោភា — រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការ ក.អ.ក.
- ឯកឧត្តម ឈៀង យ៉ាណារ៉ា — រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការ គ.ជ.នា.
- ឯកឧត្តម ជា វុទ្ធី — អគ្គលេខាធិការរង គ.វ.ក.
- ឯកឧត្តម ហេង សុខណាង — អគ្គលេខាធិការរង គ.វ.ក.
- ឯកឧត្តម នុត អ៊ុនវ័ណារ៉ា — អគ្គលេខាធិការរង គ.វ.ក.
- ឯកឧត្តម រ៉ិត វុទ្ធី — អគ្គលេខាធិការរង គ.ជ.នា.
- ឯកឧត្តម អ៊ឹម សួរ — អគ្គលេខាធិការរង គ.ជ.នា.

## ក្រុមការងារប្រតិបត្តិ៖ លេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការអនុវត្ត IDP

- ឯកឧត្តម នុត អ៊ុនវ័ណារ៉ា
- ឯកឧត្តម អ៊ឹម សួរ
- ឯកឧត្តម លឹម វិសាល
- ឯកឧត្តម កែន ដាវីត
- លោក ហ៊ុល បុណ្ណារិទ្ធ
- លោក គឹម លំអងបុព្វតា
- លោក លុច្ស រចនា
- លោក គ្រី សិរីរិទ្ធ
- លោក ជួប បិតបេរឫទ្ធិ
- លោកស្រី វណ្ណ សេរីរ័ត្ន
- លោក សេង ស៊ុនលី
- លោក សៀម ពេជ្រណូរៈ
- លោកស្រី ជា កេសរភារម្យ
- កញ្ញា សុង រ៉ានី
- លោក តែ គីមហុក
- លោកស្រី គង់ យ៉ាដា
- លោកស្រី អ៊ូ ចិន្តា
- លោក ជ័យ ឫទ្ធីរ៉ា
- កញ្ញា រ៉ិត បូណ៌មី
- លោកស្រី ស៊ូន ហ៊ាង
- លោក ប៊ី វណ្ណារិទ្ធ
- កញ្ញា បូរ៉ា ស៊ុនហ្សូលីណែត
- លោក ហុក លាងហាក់
- លោក ឆាយ ម៉េងឡេង

អតីតមន្ត្រីបម្រើការនៅលេខាធិការដ្ឋាន IDP ៖ ឯកឧត្តម ឡេង សុខឡុង, លោក កាង ស៊ីងឈាង, លោក ប៊ុត ដាឌីយ៉ា, កញ្ញា អ៊ឹង សុជាតិ, លោកស្រី ភោគ មុន្នីអមរា និងកញ្ញា ពៅ លីនដា។

ដឹកនាំរៀបចំដោយ៖

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ចូលរួមសហការដោយ៖

គាំទ្រដោយ៖

UNIDO UNITED NATIONS INDUSTRIAL DEVELOPMENT ORGANIZATION

IN PARTNERSHIP WITH THE REPUBLIC OF KOREA

https://bit.ly/3pif0vZ

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### លេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួល
### ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា


| | |
|---|---|
| អាសយដ្ឋាន | ៖ វិមានរដ្ឋាភិបាល (វត្តភ្នំ) វិថីព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ទូរស័ព្ទ | ៖ (+៨៥៥) ២៣ ៩៩២ ៤៥៥ |
| សារអេឡិចត្រូនិក | ៖ idpsecretariat.cdc@gmail.com |
| គេហទំព័រ | ៖ www.cambodiainvestment.gov.kh |